រាជរដ្ឋាភិបាលកម្ពុជា

# វិវាទដីធ្លីនៅកម្ពុជា ២០០១-២០០៩

# Land Conflict in Cambodia 2001-2009

[illegible] ទី១

[illegible]

[illegible]

២០១២

រាជបណ្ឌិត្យសភាកម្ពុជា

# វិវាទដីធ្លីនៅកម្ពុជា

## ២០០១-២០០៩

Land Conflict in Cambodia

2001-2009

ទ្រី ហ៊ាង

និក្ខេបបទបណ្ឌិតនីតិសាស្ត្រ

ឯកទេស៖ នីតិឯកជន

២០១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

លេខ ៥៥៧/១១ របសក

# សេចក្ដីសម្រេច
## ស្ដីពី
## ការអនុញ្ញាតឱ្យបេក្ខជនបណ្ឌិតការពារបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិត

## ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣/០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួល បទបញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩។
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ/បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃរាជបណ្ឌិត្យសភាកម្ពុជា។
- បានឃើញសេចក្ដីសម្រេចលេខ ៩០ សសរ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៧ ស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិតបង់វិភាគទានស្រាវជ្រាវ នៅរាជបណ្ឌិត្យសភាកម្ពុជា របស់ទីស្ដីការគណៈរដ្ឋមន្ត្រី។
- បានឃើញសេចក្ដីសម្រេចលេខ ១០២ សសរ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការកែសម្រួលសមាសភាពគណៈកម្មការគ្រប់គ្រងថ្នាក់បណ្ឌិតបង់វិភាគទានស្រាវជ្រាវ នៅរាជបណ្ឌិត្យសភាកម្ពុជា របស់ទីស្ដីការគណៈរដ្ឋមន្ត្រី។
- យោងគោលការណ៍ស្ដីពីលក្ខខណ្ឌជ្រើសរើស និងបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត នៅរាជបណ្ឌិត្យសភាកម្ពុជា ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨។

## សម្រេច

**ប្រការ ១៖** អនុញ្ញាតឱ្យបេក្ខជន **ទ្រី ហ៊ាង** បេក្ខជនបណ្ឌិត ជំនាន់ទី១ វគ្គទី១ ឯកទេស នីតិសាស្ត្រ នៃរាជបណ្ឌិត្យសភាកម្ពុជា ការពារបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិត នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០១១។

**ប្រការ ២៖** គណៈកម្មការវាយតម្លៃនិក្ខេបបទថ្នាក់បណ្ឌិត គណៈកម្មការប្រតិបត្តិ ប.វ.ស. និងសាមីខ្លួន ត្រូវអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ[illegible] ឆ្នាំ២០១១*

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

**បណ្ឌិតសភាចារ្យ ខ្លូត ធីតា**

*កន្លែងទទួល ៖*
- *អគ្គលេខាធិការដ្ឋាន របសក*
- *ខុទ្ទកាល័យ របសក*
- *ដូចប្រការ ២ "ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*

*អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា*
Tel/Fax: (855) 23 890 180 Website: www.rac-academy.edu.kh, E-mail: arc_racademy@yahoo.com P.O Box 531 Phnom Penh, Cambodia

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia

Académie Royale du Cambodge

លេខ ៥៥៣/១១ របសក-ឧទន

# លិខិតឧទ្ទេសនាម

## គណៈកម្មការវាយតម្លៃការការពារបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិត

| ល.រ. | គោត្តនាម និង នាម | កម្រិតសញ្ញាបត្រ | តួនាទី | ជំនាញឯកទេស | ភារកិច្ចក្នុងគណៈកម្មការ | ហត្ថលេខា |
|---|---|---|---|---|---|---|
| ១ | បណ្ឌិតសភាចារ្យ ខ្លួត ធីតា | បណ្ឌិត | ប្រធាន រ.ប.ស.ក | ទស្សនវិជ្ជា និងនីតិសាស្ត្រ | ប្រធានគណៈកម្មការ | |
| ២ | បណ្ឌិត លឹម ស៊ុយហុង | បណ្ឌិត | សាស្ត្រាចារ្យ | នីតិអន្តរជាតិ | សាស្ត្រាចារ្យណែនាំ | |
| ៣ | បណ្ឌិត ឃឹម ឈុនអ៊ី | បណ្ឌិត | សាស្ត្រាចារ្យ | នីតិសាធារណៈ | សាស្ត្រាចារ្យវាយតម្លៃទី១ | |
| ៤ | បណ្ឌិត ផុន ប៊ុនថាល់ | បណ្ឌិត | សាស្ត្រាចារ្យ | នីតិសាធារណៈ | សាស្ត្រាចារ្យវាយតម្លៃទី២ | |
| ៥ | បណ្ឌិត អិម វិបុល | បណ្ឌិត | សាស្ត្រាចារ្យ | នីតិសាធារណៈ | សាស្ត្រាចារ្យវាយតម្លៃទី៣ | |
| ៦ | បណ្ឌិត សុខ ទូច | បណ្ឌិត | អនុប្រធាន វ.ទ.អ.ក. | វិ. នយោបាយ | សមាជិក | |
| ៧ | បណ្ឌិត សំ នារី | បណ្ឌិត | សាស្ត្រាចារ្យ | នីតិសាស្ត្រ | លេខាធិការ | |

## វាយតម្លៃនិក្ខេបបទបណ្ឌិត

- និក្ខេបបទរបស់បេក្ខជនបណ្ឌិត ៖ **ឡី ហៀង** ភេទ ៖ ប្រុស
- មុខជំនាញ ៖ នីតិសាស្ត្រ
- ប្រធានបទ ៖ *វិវាទដីធ្លីនៅកម្ពុជា ២០០១-២០០៩*
- កាលបរិច្ឆេទ ៖ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ វេលាម៉ោង ៖ ៩:៣០ នាទី ព្រឹក
- សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត **លឹម ស៊ុយហុង**

*<u>កំណត់សម្គាល់ ៖</u> សម្លៀកបំពាក់ អាវធំ។*

*រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០១១*

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

**បណ្ឌិតសភាចារ្យ ខ្លួត ធីតា**

*<u>កន្លែងទទួល ៖</u>*

- *អគ្គលេខាធិការដ្ឋាន របសក*
- *ខុទ្ទកាល័យ របសក*
- *សាមីខ្លួន "ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*

*អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា*

Tel/Fax: (855) 23 890 180 Website: www.rac-academy.edu.kh, E-mail: arc_racademy@yahoo.com P.O Box 531 Phnom Penh, Cambodia

# រាជបណ្ឌិត្យសភាកម្ពុជា

***

## ប្រធានបទ: វិវាទដីធ្លីនៅកម្ពុជា ២០០១-២០០៩

គណៈកម្មការវាយតម្លៃនិក្ខេបបទ បញ្ចប់ថ្នាក់បណ្ឌិតជំនាញនីតិសាស្ត្រ បញ្ជាក់ថា
បេក្ខជនបណ្ឌិត **ទ្រី ហ៊ាង**
ពិតជាបានការពារបញ្ចប់ដោយជោគជ័យពិតប្រាកដមែន។

| | |
|---|---|
| សាស្ត្រាចារ្យ បណ្ឌិតសភាចារ្យ **ខ្លូត ធីតា** | ប្រធាន |
| សាស្ត្រាចារ្យ បណ្ឌិត **លឹម ស៊ីយហុង** | សាស្ត្រាចារ្យណែនាំ |
| សាស្ត្រាចារ្យ បណ្ឌិត **ឃឹម ឈុនអ៊ី** | វាយតម្លៃទី១ |
| សាស្ត្រាចារ្យ បណ្ឌិត **ផុន ម៉ិនថាល់** | វាយតម្លៃទី២ |
| សាស្ត្រាចារ្យ បណ្ឌិត **អិម ចិន្តុល** | វាយតម្លៃទី៣ |
| សាស្ត្រាចារ្យ បណ្ឌិត **សុខ ទូច** | សមាជិក |
| សាស្ត្រាចារ្យ បណ្ឌិត **សំ នារី** | សមាជិក |

ផ្នែកបណ្តុះបណ្តាល និងស្រាវជ្រាវ
**អគ្គលេខាធិការរង**

**បណ្ឌិត សាបូ អូហ្សាណូ**

ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

បណ្ឌិតសភាចារ្យ **ខ្លូត ធីតា**

# ការឧទ្ទិសស្នាដៃ

ខ្ញុំបាទសូមឧទ្ទិសស្នាដៃនៃនិក្ខេបបទនេះ

ជូនចំពោះ

ជីដូនបង្កើត ឧបាសិកា ស៊ុម សាម

ដោយក្តីគោរព និង ស្រឡាញ់។

# សេចក្តីថ្លែងអំណរគុណ

ស្នាដៃនៃនិក្ខេបបទនេះ គឺអាចមានរូបរាងឡើងដោយសារមានការចូលរួមជ្រោមជ្រែងពីលោកសាស្ត្រាចារ្យបណ្ឌិត ឥស្សរជននយោបាយ និង មិត្តភក្តិ ដែលបានជួយណែនាំតម្រង់ទិស និង ផ្តល់ឯកសារសម្រាប់កិច្ចសិក្សាស្រាវជ្រាវនេះ។ ការរួមចំណែកទាំងផ្នែកគំនិត ស្មារតី ថវិកា និង បច្ចេកទេសពីអស់លោក លោកស្រី ទាំងនេះពិតជាវិភាគទានដ៏ថ្លៃថ្លាសម្រាប់ជួយឱ្យការស្រាវជ្រាវ និង ការរៀបចំស្នាដៃប្រព្រឹត្តទៅទទួលបានលទ្ធផលល្អ។

ខ្ញុំបាទសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ ៖

ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដែលបានអនុញ្ញាតឱ្យធ្វើកម្មសិក្សាស្រាវជ្រាវនៅអាជ្ញាធរនេះក្នុងរយៈពេល១២ខែ ចាប់ពី ខែឧសភា ឆ្នាំ២០០៩ ដល់ ខែមេសា ឆ្នាំ២០១០។

ឯកឧត្តម **អ៊ឹម ឈុនលឹម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដែលបានផ្តល់ភាពងាយស្រួលឱ្យខ្ញុំបាទបានសិក្សាស្រាវជ្រាវនៅគណៈកម្មការនេះ ចាប់ពីខែឧសភា ឆ្នាំ២០០៩ ដល់ខែមេសា ឆ្នាំ២០១០។

បណ្ឌិតសភាចារ្យ **ខ្លូត ធីតា** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និង ថ្នាក់ដឹកនាំព្រមទាំងមន្ត្រីរាជបណ្ឌិត្យសភាទាំងអស់ ដែលបានបំពេញការងារដើម្បីសម្រួលដល់ដំណើរការនៃការសិក្សា។

គណៈកម្មការវាយតម្លៃរួមមាន៖ បណ្ឌិតសភាចារ្យ **ខ្លូត ធីតា** បណ្ឌិត **យឹម ឈុនអ៊ី** បណ្ឌិត **ផុន ប៊ុនថាល់** បណ្ឌិត **អិម វិបុល** បណ្ឌិត **សុខ ទូច** បណ្ឌិត **សំ នារី** ដែលបានផ្តល់យោបល់ណែនាំដ៏ល្អទាក់ទងនឹងនិក្ខេបបទនេះ។

សាស្ត្រាចារ្យបណ្ឌិត **លឹម ស៊ុយហុង** ដែលជាសាស្ត្រាចារ្យណែនាំ និង ជាសាស្ត្រាចារ្យបង្រៀនដែលបានយកចិត្តទុកដាក់ពន្យល់ណែនាំ និង ផ្តល់គំនិតល្អៗដល់ការស្រាវជ្រាវ និង ចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយកែលម្អស្នាដៃនេះ ជាបន្តបន្ទាប់រហូតបានទទួលជោគជ័យ។

លោក Jan Erick-Wan ប្រធានអង្គការ ហ្វ៊ូរ៉ូមស៊ីដ អាស៊ីអាគ្នេយ៍ ប្រចាំនៅប្រទេសកម្ពុជា ដែលបានរួមចំណែកផ្តល់ថវិកាសម្រាប់ការសិក្សានេះទទួលបានជោគជ័យ។

លោក បណ្ឌិត Robin Biddulph សាស្ត្រាចារ្យប្រចាំនៅសាកលវិទ្យាល័យ Gutenberg ដែលបានរួមចំណែកកែសម្រួលផ្នែកភាសាអង់គ្លេស។

លោក **វុឌ្ឍី វណ្ណារ៉ា** ប្រធានលេខាធិការដ្ឋាន គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដែលបានផ្តល់ទាំងឯកសារ ព្រមទាំងមតិយោបល់ល្អៗសម្រាប់ការសិក្សាស្រាវជ្រាវនេះ។

លោក **ម៉ៅ សុវឌ្ឍនា** ប្រធាននាយកដ្ឋានស៊ើបអង្កេត និង អធិការកិច្ច អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដែលតែងតែផ្តល់ឯកសារដែលមានសារសំខាន់ៗ និង ផ្តល់ពេលវេលាឱ្យខ្ញុំមានឱកាសជួបពិភាក្សាទៅលើខ្លឹមសារនៃស្នាដៃនេះ។

សាស្ត្រាចារ្យបង្រៀនមាន៖ បណ្ឌិត រស់ ចន្ត្រាបុត្រ បណ្ឌិត ឯក ឆេងហួត បណ្ឌិត អ៊ូ វ៉េឌី បណ្ឌិត នូ ចាន់សុភី បណ្ឌិត សៅ ស៊ីសុវណ្ណា បណ្ឌិត សាយ បូរី បណ្ឌិត ព្រំ ទេវី បណ្ឌិត ហ្វ្រង់ស័រ អ៊ឹម និងបណ្ឌិត នេត បារ៉ុម ដែលបានបង្រៀន និងផ្តល់យោបល់ណែនាំនានាទាក់ទងនឹងនិក្ខេបបទនេះ។

អរគុណចំពោះ៖ លោក Shaun Williams លោក Robin Biddulph លោក Wayne Gum លោក សុង វណ្ណស៊ីន លោក ឃួន សុនមជ្ឈឹម លោក ហាក់ សារុំ លោក យិន ដារ៉ា អ្នកស្រី ងិន ណារីរៈ អ្នកស្រី យន ឱនរ៉ាវី ដែលជាសហការី និង ជាមិត្តរួមការងារកាលពី១០ឆ្នាំមុន នៅក្នុងគម្រោងសិក្សាដីធ្លីនៅកម្ពុជា។ រាល់ការសន្ទនារបានជំរុញ និង លើកទឹកចិត្តដល់ខ្ញុំ ឱ្យបាននឹកគិតទៅដល់វិស័យដីធ្លី និង សិទ្ធិលើដីធ្លី។

ខ្ញុំបាទក៏សូមថ្លែងអំណរគុណចំពោះក្រុមគ្រួសាររបស់ខ្ញុំ ជាពិសេស ភរិយា សយ សុភា កូនស្រី ទ្រី ធីតា និង ទ្រី ធីនា និង អ្នកម្តាយ ហេង យីន ព្រមទាំងមិត្តភក្តិ ប្រិយមិត្តទាំងអស់ ដែលជួយស្វែងរកឯកសារ និង សម្រួលដល់ការសិក្សាជ្រាវជ្រាវគ្រប់ទីកន្លែង និង គ្រប់ពេលវេលា ព្រមទាំងផ្តល់ប្រឹក្សាយោបល់ថែមទៀតផងដែរ។

បើគ្មានការជួយណែនាំ កែលម្អ ការតម្រង់ទិស ការផ្តល់កិច្ចសម្ភាសន៍ និង ការទំនុកបម្រុង ពីលោក បណ្ឌិតសាស្ត្រាចារ្យ ឥស្សរជននយោបាយ និងញាតិមិត្ត ដូចដែលបានរៀបរាប់ខាងលើនេះទេ ការស្រាវជ្រាវ និង ការរៀបចំស្នាដៃស្តីពី " វិវាទដីធ្លីនៅកម្ពុជា២០០១-២០០៩ " នេះ ពិតជាមិនអាចលេចជារូបរាង និង សម្រេចជោគជ័យបានឡើយ។ គុណបំណាច់ និង ការជួយឧបត្ថម្ភទាំងអស់នេះ មិនគ្រាន់តែមានតម្លៃ សម្រាប់ការស្រាវជ្រាវនេះប៉ុណ្ណោះទេ តែវាមានតម្លៃសម្រាប់អ្នកស្រាវជ្រាវក្រោយៗទៀតផងដែរ។

# អំណះអំណាង

ខ្ញុំបាទសូមធានា និង ទទួលខុសត្រូវទាំងស្រុងថា ខ្លឹមសារនៃនិក្ខេបបទនេះ គឺជាស្នាដៃដែលបានស្រាវជ្រាវផ្ទាល់របស់ខ្ញុំបាទ ដោយគ្មានពាក់ព័ន្ធជាមួយនឹងនិក្ខេបបទអ្នកផ្សេងឡើយ។ លទ្ធផលនៃការស្រាវជ្រាវដែលបានលើកឡើងនៅក្នុងអត្ថបទនេះគឺ ថ្មី ដោយពុំមានការលួចចម្លងលើអត្ថន័យ និង ខ្លឹមសារពីក្នុងនិក្ខេបបទរបស់បុគ្គលណាម្នាក់ឡើយ។

# អក្សរកាត់

(ប្រើក្នុងនិក្ខេបបទនេះ)

| | | |
|---|---|---|
| ក្រ. | | ក្រឹត្យ |
| គ.ស.ជ | | គណៈកម្មការសុរិយោដី |
| គ.ស.ជ | | គណៈកម្មការសុរិយោដីថ្នាក់ជាតិ |
| អ.ជ.ដ | | អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី |
| ដ.ឯ.ម | | ដូចឯកសារមុន |
| -ដ- | | ដដែល |
| អ.ន.ក្រ. | | អនុក្រឹត្យ |
| អ.ស.ប | | អង្គការសហប្រជាជាតិ |
| អ៊ុនតាក់ | | អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា |
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ASEAN | Association of South East Asian Nation | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CAS | Center for Advance Study | មជ្ឈមណ្ឌលសម្រាប់សិក្សាស្រាវជ្រាវជាន់ខ្ពស់ |
| CCC | Cooperation Committee for Cambodia | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា |
| CDRI | Cambodia Development Resource Institute | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CEDAC | Centre de l' Etude et de Development Agricole Cambodgien | មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| CFI | Community Forestry International | សហគមន៍ព្រៃឈើអន្តរជាតិ |
| CHRAC | Cambodian Human Right Action Committee | គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការ-សមាគមន៍ ការពារសិទ្ធិមនុស្សនៅកម្ពុជា |
| CMAC | Cambodian Mine Action Center | មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា |
| DANIDA | Danish International Development Agency | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក |
| DAP | DAP Media Center | មជ្ឈមណ្ឌលព័ត៌មានដើមអំពិល |
| EWMI | East West Management Institutes | វិទ្យាស្ថានគ្រប់គ្រងសម្រាប់តំបន់អាស៊ីបូព៌ា |
| GDP | Gross Domestic Product | កំណើនផលិតផលដុលក្នុងស្រុក |

| | | |
|---|---|---|
| GRET | Group de Reserche et de l' echanges Technologique | ក្រុមស្រាវជ្រាវ និងការផ្លាស់ប្តូរបច្ចេកវិទ្យា |
| LASED | Land Allocation for Socio-Economic Development | ការផ្តល់ដីសម្រាប់គោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម |
| LICADHO | Cambodian League for Defense of Human Rights | សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីការដូ |
| LMAP | Land Management and Administration Project | គម្រោងគ្រប់គ្រង និងរដ្ឋបាលដីធ្លី |
| MDGs | Millennium Development Goals | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| MRC | Mekong River Commission | គណកម្មការទន្លេមេគង្គ |
| MLMUPC | Ministry of Land Management Urban Planning and Construction | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| NALDR | National Authority of Land Dispute Resolution | អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី |
| NGO Forum | Non Governmental Organization Forum | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| Oxfam | Oxford Famine People's Relief Committee | គណៈកម្មការសម្រាប់ការផ្តល់ជំនួយដល់ ប្រជាពលរដ្ឋអត់ឃ្លានប្រចាំទីក្រុងអុកស្វ៊ត |
| RFA | Radio Free Asia | វិទ្យុអាស៊ីសេរី |
| RFI | Radio France International | វិទ្យុបារាំងអន្តរជាតិ |
| SES | Socio Economic Survey | ការស្ទង់មតិអំពីសេដ្ឋកិច្ច និងសង្គម |
| TA | Technical Assistance | ជំនួយបច្ចេកទេស |
| SUPF | Solidarity Urban Poor Fund | មូលនិធិសាមគ្គីភាពសម្រាប់ជនក្រីក្រ |
| UNDP | United Nations Development Program | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| UNESCO | United Nations Educational, Scientific and Cultural Organization | អង្គការសហប្រជាជាតិ ដើម្បីការអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌ |
| USAID | United States Agency for International Development | ជំនួយសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍ អន្តរជាតិ |
| WAC | Women Agenda for Change | កម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ |
| WB | World Bank | ធនាគារពិភពលោក |

# មូលន័យសង្ខេប

និក្ខេបបទនេះ ផ្តោតជាសំខាន់ទៅលើទំនាក់ទំនងរវាងបញ្ហាវិវាទដីធ្លីនៅកម្ពុជាបច្ចុប្បន្នធៀបទៅនឹងលិខិតបទដ្ឋានគតិយុត្តជាធរមាន ពោលគឺ ទៅលើការអនុវត្តរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងការដោះស្រាយបញ្ហាដីធ្លី ថាតើចំណាត់ការចំពោះបញ្ហានេះត្រូវបានធ្វើឡើងដោយសមស្រប ឬមិនសមស្របតាមនីតិវិធីច្បាប់ ហើយទទួលបានប្រសិទ្ធភាពកម្រិតណាដែរ។

ការសិក្សាស្រាវជ្រាវនេះបានរៀបចំឡើង ជាពីរដំណាក់កាលសំខាន់ៗ។ ដំណាក់កាលទី ១ គឺការស្វែងយល់អំពីទិដ្ឋភាពនៃវិវាទដីធ្លីកំពុងកើតពេលបច្ចុប្បន្ន អំពីអសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងលិខិតបទដ្ឋានគតិយុត្តនៅក្នុងបរិបទនៃការផ្តល់ការដោះស្រាយវិវាទដីធ្លី ប្រកបទៅដោយប្រសិទ្ធភាព។ ការតភ្ជាប់ដ៏មានសារសំខាន់ទៅតាមផ្នែកនីមួយៗ ត្រូវពិនិត្យឡើងវិញដើម្បីកំណត់ថាតើវាមានទំនាក់ទំនងទៅកម្រិតកំណើន ឬថយចុះនៃចំនួនវិវាទដីធ្លី។ ការណ៍នេះតម្រូវឱ្យសិក្សាស្រាវជ្រាវ និងវិភាគលើឯកសារសំខាន់ៗរបស់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធដែលបានធ្វើការលើវិស័យនេះ។

តែទោះបីជាយ៉ាងណា ការវិភាគអំពីគោលនយោបាយដីធ្លី អំពីលិខិតបទដ្ឋានគតិយុត្តទៅនឹងការអនុវត្តត្រឹមកម្រិតទ្រឹស្តី នៅមិនទាន់ច្បាស់លាស់ជាស្ថាពរនោះទេ។ ដូច្នេះ ការស្រាវជ្រាវសម្រាប់ធ្វើជាឧទាហរណ៍មកសំអាង ដើម្បីឱ្យបានយល់ដឹងកាន់តែច្បាស់ អំពីទំនាក់ទំនងរវាងមនុស្សទៅនឹងដីធ្លីចំពោះការដោះស្រាយវិវាទ គឺមានសារសំខាន់។ ករណីសិក្សានៅសហគមន៍ដីក្រហម រាជធានីភ្នំពេញត្រូវលើកយកមកសិក្សានៅក្នុងដំណាក់កាលទី២។ ករណីសិក្សាបានឆ្លុះបញ្ចាំអំពីបញ្ហាវិវាទ អំពីបញ្ហាច្បាប់ និងការអនុវត្តច្បាប់។ ការសិក្សាជាក់ស្តែងបានធ្វើឱ្យយល់កាន់តែច្បាស់នូវភាពស្មុគស្មាញជុំវិញទំនាក់ទំនងសង្គមលើការរៀបចំ ការគ្រប់គ្រងដីធ្លី និងទំនៀមទម្លាប់នៃការផ្ទេរដីដោយខុសច្បាប់។ ទំនាក់ទំនងរវាងមនុស្សទៅនឹងដីធ្លីតាមប្រពៃណី និង ក្រៅផ្លូវការបានបង្ហាញអំពីទំនៀមទម្លាប់ និងជាឧទាហរណ៍នៃការប្រើប្រាស់ដី និង ការទទួលបានដីធ្លី។

ករណីវិវាទសហគមន៍ដីក្រហម ដែលបានផ្តល់ជាសម្បទានដីសង្គមកិច្ចដោយរាជរដ្ឋាភិបាលកម្ពុជា ត្រូវបង្វែរទៅឱ្យក្រុមហ៊ុនឯកជន។ តួអង្គសំខាន់ដែលពាក់ព័ន្ធក្នុងបញ្ហានេះ បានចូលរួមយ៉ាងសកម្មដើម្បីជួយសម្រួលក្នុងការធ្វើឯកសារខុសច្បាប់។ ប៉ុន្តែមិនមានអ្នកណាម្នាក់ត្រូវបានទទួលកំហុសដោយសារទង្វើទាំងនោះឡើយ។

ការសិក្សាស្រាវជ្រាវបង្ហាញថា វិវាទដីធ្លីនៅតែបន្តកើនឡើង និង មានលក្ខណៈកាន់តែស្មុគស្មាញឡើងៗ។ នេះដោយសារវិវាទដីធ្លីមានទំហំធំធេង តែការឆ្លើយតបរបស់អាជ្ញាធរមានសមត្ថកិច្ចនៅមានកម្រិត ទាំងការទប់ស្កាត់ និង ការដោះស្រាយវិវាទ។ ម្យ៉ាង ដោយសារសង្គមពឹងផ្អែកតែទៅលើទង្វើទៅតាមតែទម្លាប់ជាក់ស្តែង និង ធនធាននៅមានកម្រិត។ ម្យ៉ាងវិញទៀត ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ដោយអាជ្ញាធរក្នុងការទប់ស្កាត់ និង ដោះស្រាយវិវាទនៅមានកម្រិត។ ការឆ្លុះបញ្ចាំងនៃរបកគំហើញនេះ គឺសម្រាប់ការពិភាក្សា ការស្រាវជ្រាវលើការបង្កើត និង កែសម្រួលគោលនយោបាយច្បាប់សម្រាប់ថ្ងៃអនាគត។

ABSTRACT

This thesis focus into the relationship between current land conflict in Cambodia and existing regulations framework versus the action of competent authorities to solve the problems.

This research was conducted in two main phases. The first phase explored the current issues, land tenure insecurity and land regulations frameworks in the context of delivering land conflict resolution with affective manners. Essential linkages between each of components were reviewed to determine how they relate to the degree of land conflict whether increase or decrease. This is require to search and analysis of materials from Government and relevant stakeholders working on this issues.

However analysis of land policy, land regulations versus land implementation at a theoretical level is not definitive. Empirical research was necessary to understand people to land relationships of conflict resolutions. Case Study in DeyKraham community in Phnom Penh were conducted as second phase of research. The case study reflecting on conflict issues, legal issues and law enforcement. Field study illustrated complexities surrounding social-derived tenure arrangement and illegal land transactions. Informal and customary people to land relationships underpin traditional land use and access patterns.

DeyKraham community was granted as Social Land Concession from Royal Government of Cambodia was turned to private company. Key actors that active participated in these issues for helping proceed the papers illegal documents. However there are no wrong doers were punished.

The research shows that the conflicts would continue to increase and to become more complicated. Due to the Number of land dispute were huge, but limit of responses from competent authorities in term of prevent and solving problems. On one hand the societies depend on socially derived practices and have limit resources. On the other hand authorities are usually unable to apply the law. This lead to limit of law enforcement. The implications of this finding for future policy-law reviewed/making and research are discussed.

# សង្ខេបនិក្ខេបបទ

ចាប់តាំងពីការធ្វើឯកជនូបនីយកម្មរបស់រាជរដ្ឋាភិបាលលើវិស័យដីធ្លី គេសង្កេតឃើញថា វិវាទដីធ្លីក៏បានចាប់ផ្តើមផងដែរ។ វិវាទដីធ្លីជាបញ្ហាក្តៅគគុក និង រសើបដែលអាចនាំឱ្យកើតអន្តិសុខសង្គម។ ដីធ្លីគឺជាប្រភពនៃទ្រព្យ និង ក៏ជាប្រភពនៃជម្លោះផងដែរ ។ ក្នុង១៥គ្រួសារ មាន១គ្រួសារពាក់ពន្ធ័នឹងវិវាទដីធ្លី។ ពិតមែនតែពុំទាន់មានភស្តុតាងពិតប្រាកដណាមកបញ្ជាក់ក៏ដោយ តាមការសង្កេតនៃកំណើនឯកជនូបនីយកម្មលើដីធ្លីធំៗ ក្នុងដៃមនុស្សមួយចំនួនតូច លេចឡើងគួរឱ្យកត់សំគាល់។ ទន្ទឹមគ្នានេះ កំណើនប្រជាសាស្ត្រ និង ការអភិវឌ្ឍកំពុងកើន នាំឱ្យមានអត្រាកំណើនអ្នកគ្មានដីធ្លី កាន់តែកើនចំនួន២%ប្រចាំឆ្នាំ តែផ្ទុយទៅវិញទំហំដីនៅតែដដែល។

ដីមានសារៈសំខាន់ដែលមិនអាចខ្វះបាន និង ជាធាតុដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋកម្ពុជាច្រើនជាង៨០ ភាគរយ ពឹងអាស្រ័យដើម្បីចិញ្ចឹមជីវិត។ ប្រជាពលរដ្ឋកើនឡើង តម្រូវការដីធ្លីក៏កើនឡើងជាលំដាប់ផងដែរ តែដីធ្លីមិនកើនទេ ដូច្នេះវិវាទដីធ្លីមិនអាចជៀសវាងបានឡើយនៅកម្ពុជា។ ជាការពិត ហេតុបណ្តាលឱ្យកើតវិវាទដីធ្លី ដោយសារកត្តានយោបាយ កត្តាសេដ្ឋកិច្ច កត្តាប្រវត្តិសាស្ត្រ កត្តាសង្គម និង កង្វះចំណេះដឹងផ្នែកច្បាប់ដីធ្លីជាដើម។

វិវាទដីធ្លី កើនឡើងជាបន្តបន្ទាប់ និងបានក្លាយទៅជាបញ្ហាសង្គមកាន់តែស្មុគស្មាញឡើងៗ។ ផ្អែកតាមរបាយការណ៍របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ វិវាទដីធ្លីកើនឡើងខ្ពស់ជាលំដាប់ទៅតាមឆ្នាំនិមួយៗគឺពីចំនួន១២៤៥ ករណី ក្នុងឆ្នាំ ២០០៣ រហូតដល់ចំនួន ៥០៣៨ ករណី ឆ្នាំ ២០០៨ និងកើនឡើងដល់ចំនួន៥១៩៣ ករណី នៅឆ្នាំ ២០០៩។ វិវាទដីធ្លីបង្កឱ្យកើតមានឡើងនូវអំពើហិង្សា បង្ករបួសស្នាម និងបណ្តាលឱ្យស្លាប់មនុស្សដែលពុំធ្លាប់មានពីមុនមក។ ទង្វើទាំងនោះភាគច្រើនកើតឡើងដោយសារកងកំលាំងប្រដាប់អាវុធដែលការពារដីទៅលើ ប្រជាពលរដ្ឋក្រីក្រដែលជាជនរងគ្រោះ នៅទីកន្លែងដែលមានទំនាស់ស្រួចស្រាល់។ ជាទូទៅគេកម្រឃើញមានការផ្តន្ទាទោស ឬ ការចាត់វិធានការដល់អ្នកប្រព្រឹត្តល្មើស ដើម្បីឱ្យទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការសម្លាប់ ឬការបាញ់ប្រហារទាំងនោះទេ។ តែផ្ទុយទៅវិញ ប្រជាពលរដ្ឋរងគ្រោះកាន់តែច្រើនឡើងៗដែលជាប់ពាក់ព័ន្ធនឹងវិវាទដីធ្លីត្រូវបានចាប់ខ្លួន តាមរយៈដីការបស់តុលាការ និងជាងនេះទៀត ពួកគេត្រូវបង្ខំឱ្យចាកចេញពីទីកន្លែងដីទំនាស់ ដើម្បីជាថ្នូរក្នុងការដោះលែងពួកគេពីការឃុំឃាំង។ ដោយឃើញបញ្ហាទាំងនេះ ប្រមុខនៃរាជរដ្ឋាភិបាលក៏ធ្លាប់មានប្រសាសន៍ដោយ បានអំពាវនាវឱ្យអាជ្ញាធរប្រគល់ដីឱ្យរាស្ត្រវិញ ប្រសិនបើដីនោះជាប់មានទំនាស់ រវាងរាស្ត្រ នឹងអាជ្ញាធរ។

វិវាទដីធ្លីបណ្តាលមកពីមូលហេតុជាច្រើនដូចជា កង្វះសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និង ដោយសារប្រជាពលរដ្ឋភាគច្រើនមិនមានប័ណ្ណកម្មសិទ្ធិដីធ្លី។ តាមរបាយការណ៍របស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា បានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋ៧៥ ភាគរយ ដែលកាន់កាប់ដីកសិកម្ម មិនខ្វល់ខ្វាយនឹងដាក់ពាក្យសុំសិទ្ធិកាន់កាប់ដីធ្លីឡើយ។ ប្រជាពលរដ្ឋ

ប្រហែល ១០ ភាគរយ មានប័ណ្ណកាន់កាប់ដីធ្លីស្របច្បាប់។ ឧបសគ្គរាំងដល់ការធ្វើប័ណ្ណកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ដោយសារការធ្វើប័ណ្ណមានតម្លៃខ្ពស់ និង នីតិវិធីស្មុគស្មាញ។ រួមផ្សំនឹងការអនុវត្តច្បាប់នៅមានកម្រិត ប្រជាពលរដ្ឋបន្តការផ្ទេរសិទ្ធិលើដីធ្លី តាមតែទម្លាប់ដោយមានការឃុបឃិតគ្នាជាមួយជនខិលខូចមួយចំនួនតូចក៏បង្កឱ្យមានវិវាទដីធ្លីដែរ។

ក្របខ័ណ្ឌគតិយុត្តទាក់ទងនឹងដីធ្លី ជាពិសេស ការកសាងឯកសារគតិយុត្តសម្រាប់អនុវត្តច្បាប់ភូមិបាលឆ្នាំ២០០១ មានការរីកចម្រើនគួរឱ្យកត់សំគាល់។ តែទោះជាយ៉ាងណា ការអនុវត្តច្បាប់ទាំងនោះមិនទាន់ល្អប្រសើរនៅឡើយ។ មានករណីមួយចំនួន ទោះមានច្បាប់ជាធរមានហើយក៏ដោយ តែច្បាប់ទាំងនោះមិនបានឱ្យនិយមន័យ បានច្បាស់លាស់នាំដល់ការបកស្រាយយកច្រើនបែបផ្សេងៗគ្នា ជនរងគ្រោះពីហេតុការណ៍នេះភាគច្រើនអ្នកក្រីក្រដែលជាជនងាយរងគ្រោះ។ ចំណុចដែលមានការបម្រោងចម្រាស់ខ្លាំងបំផុត គឺភាពមិនច្បាស់លាស់នៃការកំណត់ព្រំប្រទល់ និង អត្តសញ្ញាណដីឯកជន និង ដីសាធារណៈរបស់រដ្ឋ។ នាពេលបច្ចុប្បន្ន រដ្ឋពុំទាន់មានការកំណត់អត្តសញ្ញាណដីថាតើកន្លែងណាជាដីសាធារណៈរបស់រដ្ឋ និង កន្លែងណាជាដីឯកជនរបស់រដ្ឋឱ្យមហាជនបានដឹងនៅឡើយ។ ទោះបី ដីតំបន់ត្រូវការពារទេសភាព តំបន់ការពារធម្មជាតិ ដីធ្វើអាជីវកម្មសាធារណៈលើដីសាធារណៈរបស់រដ្ឋ និង ការផ្តល់ដីសម្បទាន ជួល ឬ ផ្ទេរ លើដីឯកជនរបស់រដ្ឋ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ក៏គ្មានការគូសវាស់ព្រំប្រទល់ឱ្យបានច្បាស់លាស់នោះដែរ។ ជាវិបាកវិវាទដីធ្លីកើតមានឡើងគ្មានទីបញ្ចប់។ ជាងនេះទៀតមកដល់ពេលបច្ចុប្បន្ន មិនមានឯកសារផ្លូវការណាមួយមកបញ្ជាក់ថាអ្វីជាដីសាធារណៈរបស់រដ្ឋដើម្បីឱ្យសាធារណៈជនបានដឹង ហេតុដូច្នេះហើយបានជាវិវាទដីធ្លីនៅបន្តកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

ជាទូទៅការដោះស្រាយវិវាទដីធ្លីនៅកម្ពុជាមានពីរបែបៈ ទីមួយតាមបែបរដ្ឋបាល និងទីពីរតាមបែបតុលាការ។ ដំណោះស្រាយតាមបែបរដ្ឋបាលមានពីរជាផ្លូវការៈ ទីមួយ គណៈកម្មការសុរិយោដី និង ទីពីរអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។ ដំណើរការដោះស្រាយវិវាទរបស់គណៈកម្មការសុរិយោដីចាប់ពីឆ្នាំ២០០២ រហូតដល់ឆមាសទី១ ឆ្នាំ២០០៩ ក្នុងចំណោមវិវាទសរុបចំនួន ៥១៩៣ ករណី ក្នុងនោះវិវាទចំនួន១៨១០ ករណី ត្រូវបានដោះស្រាយប្រកបដោយជោគជ័យ ចំណែកឯករណីវិវាទចំនួន ១៣៦៩ ត្រូវបានច្រានចោល រីឯករណីវិវាទចំនួន៩៧ ត្រូវបានប្តឹងទៅតុលាការ និងករណីវិវាទចំនួន ២៧២ ត្រូវបានភាគីសុំដកបណ្តឹងវិញ ហើយករណីវិវាទចំនួន១៧៤២ កំពុងដោះស្រាយ។ ផ្អែកតាមលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ករណីវិវាទភាគច្រើន ដែលត្រូវបានដោះស្រាយប្រកបដោយជោគជ័យជាវិវាទ ដែលពាក់ព័ន្ធនឹងភាគីតូចតាច និងចំនួនគ្រួសារតិច។ គណៈកម្មការសុរិយោដីដោះស្រាយវិវាទតិចតួច ដែលពាក់ព័ន្ធនឹងអាជ្ញាធរមានឋានៈខ្ពស់ ឬវិវាទមានច្រើនគ្រួសារ។ ចំណែកអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី គិតមកត្រឹមឆមាសទី១ ឆ្នាំ២០០៩ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី (អ.ជ.ដ) ទទួលពាក្យបណ្តឹងផ្ទាល់ពីប្រជាពលរដ្ឋ និងពីស្ថាប័នផ្សេងៗចំនួន១១៩២ ករណី ក្នុងនោះករណីដោះស្រាយបានជោគជ័យមាន ចំនួន ៣៨ ករណី។ ចំណែកករណីវិវាទចំនួន៩៤៧ ករណី អគ្គលេខាធិការដ្ឋានបានបង្វែរទៅឱ្យស្ថាប័នជំនាញដើម្បីជម្រុញឱ្យពិនិត្យ និង តាមដានដោះស្រាយ។ ការបង្វែរបណ្តឹងធ្វើឱ្យភាគីដែលទទួលរងដំណោះ

ស្រាយពីអាជ្ញាធរជាតិជួបឧបសគ្គ ដែលទីបំផុតរកបានស្ថាប័នដោះស្រាយដ៏សមស្រប តែមិនត្រូវបានដោះស្រាយទៅវិញ។

ទោះបីមានស្ថាប័នជាច្រើនហើយក៏ដោយ ក៏បញ្ហាជាច្រើននៅមិនទាន់បានដោះស្រាយ ដែលបញ្ហាទាំងនេះ ក្លាយទៅជាបញ្ហាសង្គមដែលមានលក្ខណៈស្មុគស្មាញ និងធ្ងន់ធ្ងរ វាទាមទារឱ្យមាននូវដំណោះស្រាយជាច្រើន។ ក៏ប៉ុន្តែ ដំណោះស្រាយពុំអាចឈានទៅដល់ការលុបបំបាត់ចោលទាំងស្រុងនូវវិវាទដីធ្លីនោះទេ។ បញ្ហាប្រឈមមុខចំពោះស្ថាប័ន ធ្វើឱ្យជួបការលំបាកក្នុងការផ្តល់ដំណោះស្រាយវិវាទដីធ្លី ឱ្យមានប្រសិទ្ធិភាពមានដូចជា កង្វះខាតសមត្ថភាព និងធនធានមនុស្ស កត្តាកង្វះខាតការទទួលបានព័ត៌មាន ការអន្តរាគមន៍មិនត្រឹមត្រូវ និងកង្វះខាតថវិកាក្នុងការបំពេញកិច្ចការរបស់សមត្ថកិច្ច។ ចំណុចជាឧបសគ្គផ្សេងទៀត ទាក់ទងទំនៅនៃការគោរពបទបញ្ញាធំជាងច្បាប់បានបន្តរលេចឡើងដែរ ដូចជា ស.ជ.ណ. (សេចក្តីជូនដំណឹង) វានៅតែមានឥទ្ធិពលខ្លាំងជាងច្បាប់ទៅទៀត។ ទោះបីថ្នាក់ដឹកនាំអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ខិតខំដើម្បីកាត់បន្ថយក៏ដោយ ដូចជាពេលខ្លះសូម្បីតែសេចក្តីសម្រេចរបស់តុលាការតាំងពីសាលាតំបូងរហូតដល់តុលាការកំពូល តែនៅមិនស្មើ ស.ជ.ណ របស់សាលារាជធានី និងស.ជ.ណ របស់ទីស្តីការគណៈរដ្ឋមន្ត្រីដែរ។

នេះបង្ហាញថា ការបែងចែកអំណាច នៅមានលក្ខណៈមិនទាន់ស៊ីជម្រៅដែលបង្កលក្ខណៈងាយស្រួលដល់ អំណាចនីតិប្រតិបត្តិមានឱកាសច្រើនជាង។ ម្យ៉ាងវិញទៀត បុគ្គល និងស្ថាប័នដោះស្រាយទំនាស់មិនទាន់បែងចែកឱ្យបានច្បាស់លាស់ ដូចមាននៅក្នុងឧបសម្ព័ន្ធនៃនិក្ខេបទនេះ បុគ្គលនៃស្ថាប័នយុត្តិធម៌ទាំងតុលាការរាជធានី និង តុលាការកំពូលមានតួនាទីផ្សេងទៀតស្ថិតនៅក្រោមអំណាចនៃនីតិប្រតិបត្តិ និងគណបក្សនយោបាយជាដើម។

ករណីសិក្សានៃវិវាទដីធ្លីនៅតំបន់ដីក្រហម បានឆ្លុះបញ្ចាំងអំពីករណីវិវាទផ្សេងៗទៀតនៅកម្ពុជា។ ការវិភាគផ្លូវច្បាប់ នៃវិវាទដែលសិក្សានៅក្នុងនិក្ខេបបទនេះ ករណីវិវាទក្រោមរូបភាពនៃការដោះដូរដីធ្លី ធ្វើឡើងដោយខុសច្បាប់។ តួអង្គដែលជាប់ពាក់ព័ន្ធក្នុងរឿងនេះបានចូលរួមចំណែកក្នុងទង្វើខុសច្បាប់ទៅតាមតួនាទី និង ជំនាញរៀងៗខ្លួន។ កម្មវិធីសម្បទានដីសង្គមកិច្ចដែលរាជរដ្ឋាភិបាលបានសម្រេចឱ្យដីប្រជាពលរដ្ឋបែទៅជាប្រែក្លាយដីនោះ ឱ្យទៅជាកម្មសិទ្ធិរបស់ក្រុមហ៊ុនដោយខុសច្បាប់។ ការណ៍នេះបានបង្ហាញយ៉ាងច្បាស់ថា អាជ្ញាធរមួយចំនួនស្ថិតក្រោមឥទ្ធិពលនៃឈ្មួញ។ ម្យ៉ាងទៀតវាស្តែងឱ្យឃើញថា អាជ្ញាធរមានភាពលំអៀងទៅអ្នកមានប្រាក់ ឬ ឈ្មួញ។ ទោះបីជាមានទង្វើខុសច្បាប់ធ្ងន់ធ្ងរក៏ដោយ ក៏មិនមានអ្នកប្រព្រឹត្តខុសណាម្នាក់បានទទួលទណ្ឌកម្មទៅតាមកំហុសខ្លួនឡើយ ជួនកាលមានករណីខ្លះត្រូវបានឡើងបុណស័ក្តិថែមទៀតផង ទាំងនេះវាស្តែងឱ្យឃើញនូវទំនៀមទម្លាប់លើកស្ទួយនូវវប្បធម៌នៃនិទណ្ឌភាព។

របកគំហើញ និងការរៀបចំគោលនយោបាយ៖

- បញ្ហាដីធ្លីនៅតែបន្តជារឿងរសើបសម្រាប់កម្ពុជាងាយធ្វើឱ្យប្រទេស ធ្លាក់ក្នុងអសន្តិសុខដែលរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ខ្ពស់។
- វិវាទដីធ្លីកើនឡើងជានិច្ចចាប់តាំងពីឆ្នាំ២០០៣-បច្ចុប្បន្ន ចំនួនវិវាទនឹងបន្តកើនឡើងនាពេលអនាគត។

- ករណីវិវាទភាគច្រើនដែលត្រូវបានដោះស្រាយ ជាវិវាទដែលពាក់ព័ន្ធនឹងគ្រួសារចំនួនតិច និងវិវាទតូចតាច។ ដំណោះស្រាយមានភាពផុយស្រួយវិវាទអាចកើតឡើងវិញ ដោយសារដីដែលបានដោះស្រាយទាំងនោះមិនត្រូវបានចុះបញ្ជី។
- គោលនយោបាយ និងច្បាប់ព្រមទាំងលិខិតបទដ្ឋានគតិយុត្តនានា មានការរីកចម្រើនគួរឱ្យកត់សំគាល់ តែការអនុវត្តនៅមានកម្រិត។
- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមានមិនស៊ីចង្វាក់ និងមិនស្របគ្នាទៅតាមឋានានុក្រមនៃច្បាប់។
- មានភាពស្រពិចស្រពិលនៃដែនសមត្ថកិច្ចដោះស្រាយវិវាទ រវាងគណៈកម្មការសុរិយោដីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និង តុលាការជាដើម។
- តុលាការយកសេចក្ដីសម្រេចរបស់រដ្ឋាភិបាលមកអនុវត្ត ជាជាងយកច្បាប់មកអនុវត្តក្នុងរឿងវិវាទដីធ្លី។
- បុគ្គលបម្រើឱ្យស្ថាប័នតុលាការជាប់ពាក់ព័ន្ធនឹងគណបក្សនយោបាយ និងមានតួនាទីនៅក្នុងរដ្ឋាភិបាល។
- ស.ជ.ណ (សេចក្ដីជូនដំណឹង) បន្តមានឥទ្ធិពលខ្លាំងជាងច្បាប់។
- អាជ្ញាធរដោះស្រាយបញ្ហាដីធ្លី ដើរតួជំនួសឱ្យភាគីក្រុមហ៊ុនឯកជន និងលំអៀងទៅភាគីម្ខាង។
- ករណីមួយចំនួន អាជ្ញាធរថ្នាក់ក្រោមមិនអនុវត្តតាមសេចក្ដីសម្រេចផ្នែករដ្ឋបាលរបស់អាជ្ញាធរថ្នាក់លើ។
- ទង្វើខុសច្បាប់ជាកំហុសរដ្ឋបាលក្ដី និង ជាបទល្មើសព្រហ្មទណ្ឌក្ដី មិនត្រូវបានអនុវត្ត។

ផ្អែកលើលទ្ធផល និង ការវិភាគនៃនិក្ខេបបទនេះ យើងអាចទាញសេចក្ដីសន្និដ្ឋានបានថា វិវាទដីធ្លីនៅតែជាបញ្ហាក្ដៅ និង រសើបសម្រាប់កម្ពុជា។ វិវាទនឹងបន្តកើនឡើង និង ក្លាយជាបញ្ហាស្មុគស្មាញឡើងៗ។ វិវាទដីធ្លីមានទំហំធំ តែការឆ្លើយតបរបស់រដ្ឋក្នុងការទប់ស្កាត់ និង ដោះស្រាយនៅមានកម្រិត។ និក្ខេបបទនេះដាក់ចេញនូវសំណើអាទិភាពគោលនយោបាយមួយចំនួនដើម្បីឆ្លើយតបចំពោះបញ្ហាខាងលើះ

ទីមួយះ កំណត់តំបន់ប្រើប្រាស់ដីធ្លីសម្រាប់ទីប្រជុំជនឱ្យបានច្បាស់លាស់ ចំពោះដីប្រភេទណាដែលអាចសាងសង់បាន និងដីប្រភេទណាមិនត្រូវសាងសង់។ ត្រូវគ្រប់គ្រងឱ្យបានតឹងរឹង ករណីមានការសាងសង់ខុសច្បាប់ ត្រូវចាត់វិធានការភ្លាមៗដើម្បីជៀសវាងកុំឱ្យរឿងកាន់តែធំ។

ទីពីរះ បង្កើតឱ្យមានសម្បទានដីសង្គមកិច្ច នៅក្នុងសម្បទានដីសេដ្ឋកិច្ច ដើម្បីកាត់បន្ថយទំនាស់ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋដែលងាយរងគ្រោះ និងពន្លឿនការកំណត់តំបន់ និងការផ្ដល់សម្បទានដីសង្គមកិច្ចជូនដល់ប្រជាពលរដ្ឋក្រីក្រគ្មានដី និង ខ្វះដីធ្លី។ ពង្រឹងបន្ថែមការចាត់វិធានការលើក្រុមហ៊ុនសម្បទានទាំងឡាយណាដែលមិនអនុវត្ត និង អនុវត្តល្មើសនឹងច្បាប់ ដោយមិនបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌនៃកិច្ចសន្យាសម្បទានរបស់ខ្លួន និង បន្តលុបចោលកិច្ចសន្យាអំពីសម្បទានតទៅទៀត។

ទីបី៖ ពន្លឿន និងពង្រឹងការចុះបញ្ជីដីធ្លីជាប្រព័ន្ធ ដោយពង្រីកការចុះបញ្ជីដីទូទាំងប្រទេសរាប់បញ្ចូលតំបន់ដាច់ស្រយាល និងតំបន់ងាយមានជម្លោះ និងជាពិសេសដីជនជាតិដើមភាគតិច និងពន្លឿនការចុះបញ្ជីដីសាធារណៈ និង ដីឯកជនរបស់រដ្ឋ ដើម្បីទប់ស្កាត់ការទន្ទ្រានចូលកាន់កាប់ខុសច្បាប់លើដីរដ្ឋ និងពង្រឹងបន្ថែមការផ្ទេរដីក្រៅប្រព័ន្ធសុរិយោដី ដូចជាតាមរយៈមេភូមិ មេឃុំ អភិបាលស្រុក ដែលជាហេតុធ្វើឱ្យជួបការលំបាកលើប្រព័ន្ធចុះបញ្ជីដីធ្លី និង កើតមានទំនាស់នាពេលអនាគត។
ទីបួន៖ ពន្លឿនការប្រមូលពន្ធលើដីមិនប្រើប្រាស់ ដើម្បីកាត់បន្ថយការបង្កកដីទុកលក់ពេលឡើងថ្លៃ ដែលនាំឱ្យពិបាកដល់ការវិនិយោគពិតប្រាកដ និង កំណើនប្រជាពលរដ្ឋគ្មានដី និងខ្វះដីធ្លី។ អត្រាពន្ធលើការចុះបញ្ជីដីធ្លីបច្ចុប្បន្ន ៤ភាគរយ នៃតម្លៃលក់ គួរបន្ថយឱ្យបានសមស្របជៀសវាងការគេចពន្ធខាតបង់ដល់រដ្ឋ។
ទីប្រាំ៖ ផ្តល់អាទិភាពដល់ស្ថាប័នដោះស្រាយវិវាទដីធ្លី ដូចជាគណៈកម្មការសុរិយោដី អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងតុលាការជាដើម ដោយដាក់បន្ថែមថវិកាជាតិទៅក្នុងខ្ទង់ចំណាយចំពោះការដោះស្រាយវិវាទដីធ្លី៕

SUMMARY

Since the government's privatization of the land sector started, the numbers of land conflicts has increased. Land conflicts have become a simmering and highly sensitive issue, which could lead to social instability and conflict since land is a prominent source of wealth. In Cambodia, one out of 15 families is engaged in a land-related conflict. Even though there has not yet been any concrete evidence, increased privatization of large tracts of land, often into the hands of a small number of already wealthy people has been noticed. At the same time, population growth and an amplified development has led to landlessness growing at a rate of 2 percent per annum. On the other hand, land itself does not naturally increase or expand.

Land is crucial for 80% of the Cambodian people who depend on it for their livelihood. The increasing demand for land results in competition which make land conflicts very likely in Cambodia. Land conflicts can be caused by social, historical, economic and political factors as well as a lack of knowledge of the land law.

Land conflicts have gradually increased and become more complex. According to a report by the National Cadastral Commission, there were 1.245 cases of land conflicts in 2003, which gradually increased to 5.038 in 2008 and up to 5.193 cases in 2009. Land conflicts have caused violence, physical assaults and even killings in Cambodia. Violent acts have mostly been committed by armed security guards on poor people at the peak of confrontations over private land. It is rare to see punishment or Government official take any action against an offender in order to hold them accountable before the law for their crime. However, more and more poor people in land conflicts have been arrested by warrant of courts, moreover people have been forced to move out from land under conflict if they want to avoid detention. In response to these issues, the Head of Government has appealed to authorities to give back land to the citizens in cases where there was conflict between citizens and authorities.

The causes of land conflicts are various. A prominent one is land tenure insecurity since most people do not have land titles. In a report from Cambodia's Development and Research Institute (CDRI) it is stated that 75 percent of the population with agricultural land hasn't applied for land titles. Only about 10 percent of the population have legal land titles. Barriers to getting land titles in term of sporadic land registration include very high fees and complicated procedures. With very limited law enforcement, citizens continued to transfer rights to control their land through habitual routines by colluding with corrupt officials; this in itself could also lead to conflicts.

A legal framework has been developed to support the implementation of the Land Law from 2001; which lately has been noticeably advanced. However law enforcement is limited. In some cases, laws in effect did not provide clear definitions. This led to different interpretations which often made victims of already vulnerable and poor people. The most controversial point was the lack of clarity regarding identification of private and public land. Up until now, the state has not made a specific identification of state public land and state private land and this is also the case in protected areas; public commercial land on state public land, land concessions, lease or transfer on state private land for economic development. As a consequence land conflicts have been unceasing. In addition, up until now there has not been any

official document mentioning what state public land is, That is a reason why cases of land conflicts keep increasing from year to year.

There are two mechanisms for land conflict resolution in Cambodia. They are administrative resolution and court resolution. The administrative solution is provided through the offices of the Cadastral Commission and National Authority on Land Dispute Resolution and the Court. Of the 5193 cases submitted to the Cadastral Commission between 2003 and 2009; 1810 cases were solved successfully, 1396 case were dismissed; 97 cases were appealed to the court of first instant; 272 cases were revoked by parties and 1742 cases are still in process. According to the secretariat of National Cadastral Commission most of cases which were resolved successfully were those cases involving few parties and a small number of families in each party. So far, the Cadastral Commission has solved few cases involving high ranking officials or large numbers of families. Regarding the outcomes of National Authority of Land Dispute Resolution (NALDR) until first semester of 2009, secretariat of NALDR received 1192 cases, of those 38 cases were solved successfully, while 947 cases were transferred to other competent authorities for resolution. The issues of transferring the case were challenges for the party which finally found appropriate institution, however the cases were unsolved.

Even though there have been many institutions, many land conflicts remain unsolved, which has become a complicated and severe social issue; it therefore requires a lot of attention in order to find solutions. However, no resolutions have yet been able to put a complete end to land issues. The government is still facing many issues in relation to land matters such as limited capacity, human resources, lack of access to information, improper interventions and the lack of financial means for authorities to fulfill their duties. Some other constraints like the trends of respecting orders rather than laws have also been clear. Though announcements (SAR.CHOR.NOR) are not the same as legal regulations they often have a powerful leverage over what is actually done. Even verdicts from first the instance court to the Supreme Court have been less effective than announcements from a municipality or the Council of Ministers.

This reflects a distribution of power that is unbalanced in favour of executive organs. Also, there has not been a clear-cut mandate of responsible institutions to deal with conflicts. As detailed in an annex to this dissertation, individuals in municipal courts and Supreme Court have other roles under executive power and political parties.

A case study of land conflict from the Dey Kraham area in Phnom Penh was very complicated and in this and other ways it is representative of other conflicts in Cambodia. In this case study, the exchange for land in various forms was illegal. Those involved in the case have taken part in illegal activities when they were supposed to be carrying out their duties. A government programme providing Social Land Concession to poor people was instead used to give land to a private company. This reflects the fact that some of the members of the authorities were under influence of the company. It was obvious that authorities were biased in favor of those with money and power. No matter how severely illegal it was, no “wrong-doers” were punished, demonstrating overwhelmingly a culture of impunity.

Finding and policy development

. Land issues are still a very sensitive issue in Cambodia, which could easily lead the country into instability and therefore they remain an issue the government should put high on their agenda.

. Land conflicts continued increasing from 2003 to now (2012) and it seems likely that the number of conflicts will continue to rise in the future.

. Most conflicts that have been resolved were family-related and/or minor conflicts. These conflicts are likely to happen again since the land under dispute was not registered during the resolution process.

. Policies and laws as well as rules and regulations have been improved noticeably, but implementation is still very limited.

. Existing laws and legal regulations in effect were not consistent and in compliance with the hierarchy of law.

. Ambiguities regarding the authorities' mandate to resolve the conflicts between and among cadastral commission and national authorities for land conflict resolution and courts.

. Courts implement government decisions rather than enforcing laws in land conflicts.

. Officials working in judicial institutions have close relations to political parties and had positions in the government.

. Announcements (SAR.CHOR.NOR), despite not being legal regulations, still continue to have strong leverage.

. Land conflict resolution authorities were biased towards companies.

. In some cases, authorities at lower levels did not implement administrative decisions made by a higher level.

. Illegal acts including administrative or criminal offenses were not addressed.

By analyzing the results of this dissertation we may conclude that land conflicts still are a simmering and sensitive issues in Cambodia. Conflicts will continue to increase and become even more complicated and infected. Land conflicts are a huge problem but the response from the state is very limited. This thesis suggests the development of the following policies in order to respond to the above issues:

First: Clearly identify land use zones in urban areas so that it is clear which land is available for residential developments and which is not. There must then be strict and immediate action in cases where new illegal construction is initiated otherwise it will become a big problems.

Second: Establish mechanism of Social Land Concession into Economic Land Concession to reduce conflict and reduce poverty. Speed up land identification for Social Land Concession for landless and land poor. There must be action in any cases where a concession is not implemented: either the concession contract is followed or it must be canceled.

Third: Speed up and re-enforce systematic land registration by increasing coverage to countrywide including remote, conflicted areas and especially land occupied by indigenous people. Speed up state public and private land registration in order to prevent land grabbing. Take action against unofficial land transactions, such as transfers of land through village chiefs, commune chiefs or district governors which cause problems to the current land registration system and can lead to further land conflict in future.

Four: Speed up tax collection on unused land, this can reduce land speculation. Consider also reducing the current tax on land transaction from 4% to an appropriate amount in order to reduce tax evasion which results in a loss of state income.
Five: Encourage land conflict resolution institutions such as Cadastral Commission, National Authority of Land Dispute Resolution and the Court by devoting more of the national budget to those institutions.

# មាតិកា

ទំព័រ

ឧទ្ទិសស្នាដៃ......i
សេចក្តីថ្លែងអំណរគុណ......ii
អំណះអំណាង......iv
អក្សរកាត់(ប្រើក្នុងនិក្ខេបបទនេះ)......v
មូលន័យសង្ខេប......vii
Abstract......viii
សង្ខេបនិក្ខេបបទ......ix
Summary......xiv
មាតិកា......xviii
អារម្ភកថា......xxiii
**សេចក្តីផ្តើម**......១
១. លំនាំបញ្ហានៃការស្រាវជ្រាវ......១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ......៥
៣. គោលបំណងនៃការស្រាវជ្រាវ......៥
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ......៥
៥. វិធីសាស្ត្រស្រាវជ្រាវ......៦
៦. សារប្រយោជន៍នៃការស្រាវជ្រាវ......៧
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ......៧
**ជំពូកទី១៖ ប្រវត្តិ និងទិដ្ឋភាពទូទៅនៃវិវាទដីធ្លី**......៩
១.១ ប្រវត្តិនៃការគ្រប់គ្រងដីធ្លី......៩
១.១.១ សម័យបុរាណ (មុន១៨៨៤)......១០
១.១.២ សម័យអាណានិគមនិយមបារាំង (១៨៨៤-១៩៥៣)......១១
១.១.៣ សម័យឯករាជ្យ (១៩៥៣-១៩៧០)......១៣
១.១.៤ សម័យសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)......១៤
១.១.៥ សម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)......១៤
១.១.៦ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៨០-១៩៨៩)......១៥
១.១.៧ សម័យរដ្ឋកម្ពុជា (១៩៨៩-១៩៩២)......១៦
១.១.៨ ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន (ក្រោយ ១៩៩៣)......១៦
១.២ ទិដ្ឋភាពទូទៅនៃវិវាទដីធ្លី......១៧

១.២.១ វិស័យដីធ្លីនៅកម្ពុជា.......................................................................................................១៨
១.២.២ វិសមភាពនៃការកាន់កាប់ដី...............................................................................................១៩
១.២.៣ ការផ្ទេរសិទ្ធិលើដី...........................................................................................................២១
១.៣ វិវាទដីធ្លី.........................................................................................................................២៣
១.៣.១ ប្រភេទវិវាទដីធ្លីជាទូទៅ...................................................................................................២៩
១.៣.២ វិវាទពាក់ព័ន្ធនឹងបុគ្គលឯកជន...........................................................................................៤២
១.៣.៣ វិវាទពាក់ព័ន្ធនឹងអាជ្ញាធរ.................................................................................................៤៧
១.៤ មូលហេតុវិវាទដីធ្លី...........................................................................................................៥១
១.៤.១ សិទ្ធិស្របច្បាប់លើដីធ្លី.....................................................................................................៥២
១.៤.២ សិទ្ធិភោគៈ និងកម្មសិទ្ធិ...................................................................................................៥៥
១.៤.៣ ការធ្វើប័ណ្ណកម្មសិទ្ធិ........................................................................................................៥៦
១.៤.៤ ការផ្ទេរសិទ្ធិដោយមិនស្របច្បាប់........................................................................................៥៩
១.៤.៥ ការរំលោភ និងចាប់ដីខុសច្បាប់..........................................................................................៦២
**ជំពូកទី២៖ ក្របខ័ណ្ឌគតិយុត្តដីធ្លី**.............................................................................................៦៧
២.១ ប្រវត្តិក្របខ័ណ្ឌគតិយុត្តដីធ្លី.................................................................................................៦៧
២.១.១ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា...............................................................................៦៧
២.១.២ សម័យរដ្ឋកម្ពុជា............................................................................................................៦៨
២.១.៣ ព្រះរាជាណាចក្រកម្ពុជា...................................................................................................៦៩
២.២ បញ្ហាគ្រប់គ្រងដីធ្លី............................................................................................................៧៣
២.២.១ បញ្ហាភោគៈ.................................................................................................................៧៣
២.២.២ ការចុះបញ្ជីដីធ្លី............................................................................................................៧៧
២.២.៣ ចំណាត់ថ្នាក់ដីរដ្ឋ..........................................................................................................៨១
២.២.៤ សម្បទានដី..................................................................................................................៨៣
២.៣ យន្តការដោះស្រាយវិវាទដីធ្លី..............................................................................................៨៥
២.៣.១ គណៈកម្មការសុរិយោដី...................................................................................................៨៨
២.៣.២ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី...................................................................................៩០
**ជំពូកទី៣៖ ការដោះស្រាយវិវាទដីធ្លី**.........................................................................................៩៥
៣.១ ការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ.........................................................................៩៥
៣.១.១ ការជ្រើសរើសអ្នកសម្រុះសម្រួល.......................................................................................៩៧
៣.១.២ ការជ្រើសរើសដំណោះស្រាយ...........................................................................................៩៩
៣.១.៣ ការដោះស្រាយតាមគណៈកម្មការរដ្ឋបាល.........................................................................១០០
៣.១.៤ ការដោះស្រាយតាមគណៈកម្មការសុរិយោដី......................................................................១០២

៣.១.៥ ការដោះស្រាយតាមអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី....................................១១៨
៣.២ ការដោះស្រាយវិវាទដីធ្លីតាមប្រព័ន្ធតុលាការ..............................................................១២៣
៣.២.១ សមត្ថកិច្ចផ្អែកតាមរដ្ឋធម្មនុញ្ញ.................................................................................១២៣
៣.២.២ សមត្ថកិច្ចផ្អែកតាមប្រកាសអន្តរក្រសួង.....................................................................១២៤
៣.២.៣ បញ្ហាផ្លូវច្បាប់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ.....................................................១២៧
៣.២.៤ វិភាគលើការដោះស្រាយ........................................................................................១២៩
**ជំពូកទី៤៖ ការវាយតម្លៃ**..........................................................................................១៤១
៤.១ ករណីវិវាទដីក្រហម..................................................................................................១៤១
៤.១.១ ប្រវត្តិរឿង...............................................................................................................១៤១
៤.១.២ ការវិភាគផ្លូវច្បាប់...................................................................................................១៦៣
**សន្និដ្ឋាន និងអនុសាសន៍**...........................................................................................១៥៥
**គន្ថនិទ្ទេស**..............................................................................................................១៥៩
**ឧបសម្ព័ន្ធ**...................................................................................................................១
ឧបសម្ព័ន្ធ១៖ ព្រះរាជក្រឹត្យតែងតាំងឯកឧត្តម ជីវ កេង.....................................................១
ឧបសម្ព័ន្ធ២៖ ឯកឧត្តម ជីវ កេង ប្រធានសាលាដំបូងរាជធានី............................................២
ឧបសម្ព័ន្ធ៣៖ ឯកឧត្តម ឌិត មន្ទី ជាប្រធានតុលាការកំពូល...................................................៣
ឧបសម្ព័ន្ធ៤៖ ឯកឧត្តម ឌិត មន្ទី ជាគណៈអចិន្ត្រៃយ៍គណបក្ស.............................................៤
ឧបសម្ព័ន្ធ៥៖ សារាចរណែនាំ ស្តីពីចំណាត់ការ និងនីតិវិធីពាក់ព័ន្ធដីរដ្ឋ...................................៥
ឧបសម្ព័ន្ធ៦៖ សេចក្តីប្រកាស ស្តីពីមោឃភាពលិខិតបញ្ជាក់កាន់កាប់ដី.....................................៨
ឧបសម្ព័ន្ធ៧៖ ប្រកាសអន្តរក្រសួង ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ
និងគណៈកម្មការសុរិយោដី.............................................................................................១០
ឧបសម្ព័ន្ធ៨៖ ដីកាសម្រេចរបស់តុលាការខេត្តបាត់ដំបង.....................................................១២
ឧបសម្ព័ន្ធ៩៖ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលផ្តល់សម្បទានដីសង្គមកិច្ច..........................១៣
ឧបសម្ព័ន្ធ១០៖ លិខិតមេធាវី...........................................................................................១៤
ឧបសម្ព័ន្ធ១១៖ របាយការណ៍ ស្តីពីការអភិវឌ្ឍនៅនឹងកន្លែង.................................................១៦
ឧបសម្ព័ន្ធ១២៖ ពាក្យបណ្តឹងទៅក្រសួងមហាផ្ទៃ..................................................................១៩
ឧបសម្ព័ន្ធ១៣៖ ពាក្យបណ្តឹងទៅជំទាវ ម៉ែន សំអន...............................................................២១
ឧបសម្ព័ន្ធ១៤៖ ពាក្យបណ្តឹងទៅអយ្យការរាជធានី.................................................................២៣
ឧបសម្ព័ន្ធ១៥៖ លិខិតពីតំណាងរាស្ត្រជូនអភិបាលរាជធានី....................................................២៥
ឧបសម្ព័ន្ធ១៦៖ សេចក្តីសុំប្តឹងតវ៉ារបស់អយ្យការរាជធានី.....................................................២៦
ឧបសម្ព័ន្ធ១៧៖ លិខិតជូនដំណឹងរបស់អយ្យការរាជធានី.......................................................២៧
ឧបសម្ព័ន្ធ១៨៖ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ.........................................................២៨

# តារាងរូបភាព


រូបភាពទី១៖ ករណីវិវាទដីធ្លីរបស់គណៈកម្មការសុរិយោដី ២០០៣-២០០៩..............................២៤
រូបភាពទី២៖ បម្រែបម្រួលនៃករណីវិវាទដីធ្លី១៩៩០-២០០៤..............................................២៦
រូបភាពទី៣៖ តួលេខនៃប្រភេទដីដែលជាប់វិវាទ.................................................................២៨
រូបភាពទី៤៖ អ្នករងការចោទប្រកាន់លើវិវាទដីធ្លី...............................................................២៩
រូបភាពទី៥៖ តារាងដំណើរការដោះស្រាយវិវាទដីធ្លីដោយគណៈកម្មការសុរិយោដី...................១១០
រូបភាពទី៦៖ ករណីវិវាទដីធ្លីដែលបានដោះស្រាយដោយគណៈកម្មការសុរិយោដី....................១១២
រូបភាពទី៧៖ ករណីវិវាទដីធ្លីដែលភាគីបានស្នើសុំដកពាក្យបណ្ដឹង.......................................១១៣
រូបភាពទី៨៖ ករណីវិវាទដីធ្លីដែលបានប្ដឹងសេចក្ដីសម្រេចរបស់
គណៈកម្មការសុរិយោដីទៅតុលាការ...............................................................................១១៤
រូបភាពទី៩៖ ករណីវិវាទដីធ្លីដែលបានច្រានចោលដោយគណៈកម្មការសុរិយោដី......................១១៦
រូបភាពទី១០៖ ករណីវិវាទដីធ្លីដែលកំពុងដោះស្រាយដោយគណៈកម្មការសុរិយោដី.................១១៧
រូបភាពទី១១៖ លទ្ធផលដោះស្រាយបានគិតមកត្រឹមឆមាសទី១ ឆ្នាំ២០០៩..........................១២២
រូបភាពទី១២៖ អន្តរាគមន៍ខុសនីតិវិធីដោយតុលាការ.......................................................១៣៦
រូបភាពទី១៣៖ ករណីវិវាទដីធ្លីនៅខណ្ឌដង្កោ រាជធានីភ្នំពេញ............................................១៣៧
រូបភាពទី១៤៖ ប័ណ្ណទទួលដីសម្បទានសង្គមកិច្ច.............................................................១៥១
រូបភាពទី១៥៖ អ្នកទទួលផលពីការអភិវឌ្ឍតំបន់សហគមន៍ដីក្រហម....................................១៥៤

# តារាងតួលេខ

តារាងទី១៖ ប្រវត្តិនៃការកាន់កាន់កាប់ដីធ្លីរបស់កម្ពុជា........................................................១៧
តារាងទី២៖ ចំណែកផ្ទៃដីប្រើប្រាស់នៅកម្ពុជាឆ្នាំ១៩៩៨......................................................១៩
តារាងទី៣៖ ការប៉ាន់ប្រមាណការកាន់កាប់ប្រើប្រាស់ដីនៅកម្ពុជា...........................................២០
តារាងទី៤៖ ទំហំដី និងភាគរយនៃចំនួនគ្រួសារកាន់កាប់ដី....................................................២១
តារាងទី៥៖ អំពីប្រភេទ និងអនុប្រភេទនៃវិវាទដីធ្លី..............................................................៣១
តារាងទី៦៖ ដំណើរការផ្ទេរកម្មសិទ្ធិដីធ្លី ខេត្តព្រះសីហនុ ឆ្នាំ២០០៧.......................................៦១
តារាងទី៧៖ ស្ថាប័នដោះស្រាយវិវាទដីធ្លីនៅសកលលោក......................................................៨៦
តារាងទី៨៖ ការដោះស្រាយវិវាទដីធ្លីរបស់គណៈកម្មការសុរិយោដីឆ្នាំ២០០៣-២០០៩............១១១
តារាងទី៩៖ លទ្ធផលដោះស្រាយគិតមកត្រឹមត្រីមាសទី២ ឆ្នាំ២០០៩..................................១២១

# អារម្ភកថា

មនុស្ស និងដីធ្លីគឺមានទំនាក់ទំនងនឹងគ្នា ហើយមានលក្ខណៈស្មុគស្មាញ និង ប្លែកៗគ្នា។ ដីគឺជាវត្ថុដ៏មានតម្លៃ និង មិនអាចខ្វះបានសម្រាប់ប្រជាកសិករខ្មែរ ជាពិសេស នៅតាមជនបទ។ មនុស្សប្រើប្រាស់ដីដើម្បីទាញយកផលិតផលកសិកម្ម តាំងពីយូរយារណាស់មកហើយក្នុងការចិញ្ចឹមជីវិត និងភាពសុខដុមរមនានៃសហគមន៍របស់ពួកគេទាំងមូល។ គេសង្កេតឃើញថា ប្រហែល ៨៥% នៃប្រជាពលរដ្ឋ និង ៩០% នៃគ្រួសារក្រីក្រដែលរស់នៅតាមតំបន់ជនបទ សកម្មភាពបង្កបង្កើនផល គឺជាប្រភពយ៉ាងសំខាន់នៃប្រាក់ចំណូលរបស់ពួកគាត់ ។

ជាទូទៅ ការគ្រប់គ្រង និង ការប្រើប្រាស់ដីផ្អែកជាចម្បងលើការប្រើប្រាស់ជាក់ស្តែងសម្រាប់បម្រើផលិតកម្ម ហើយការទទួលស្គាល់ និង ការអនុវត្តសិទ្ធិនេះត្រូវបានធ្វើដោយគោរពទៅតាមទំនៀមទម្លាប់ប្រពៃណីនៅតាមតំបន់នីមួយៗ។ ក៏ប៉ុន្តែក្រោយមានការបើកទូលាយខាងសេដ្ឋកិច្ចមកដីត្រូវបានគេយកមកប្រើប្រាស់បន្តិចម្តងៗ ដើម្បីបម្រើវិស័យពាណិជ្ជកម្ម។ ដូច្នេះហើយធ្វើឱ្យដីកាន់តែមានតម្លៃខាងផ្នែកសេដ្ឋកិច្ច។ សិទ្ធិប្រើប្រាស់ និង ការគ្រប់គ្រងដីធ្លី កាន់តែផ្អែកច្រើនឡើងៗទៅលើមធ្យោបាយខាងផ្លូវច្បាប់ ព្រោះគេយល់ថា ច្បាប់ផ្តល់នូវការការពារសិទ្ធិលើដីធ្លីមួយរឹងមាំល្អជាងទំនៀមទម្លាប់ប្រពៃណី។ ការផ្លាស់ប្តូរនិន្នាការនៃការប្រើប្រាស់ដីធ្លីពីការផលិតគ្រាន់តែគ្រប់ហូបមកជាការផលិតបែបពាណិជ្ជកម្មនេះ ធ្វើឱ្យមានការផ្លាស់ប្តូរទស្សនៈរបស់ប្រជាពលរដ្ឋលើរឿងសិទ្ធិខាងដីធ្លី និង ជាពិសេសការផ្លាស់ប្តូរនេះបានធ្វើឱ្យមានការលេចឡើងនូវវិវាទដីធ្លីច្រើនបែបច្រើនយ៉ាង។

វិវាទដីធ្លីជាបញ្ហាធំមួយនៅកម្ពុជាពីព្រោះ ដីធ្លីគឺជាប្រភពនៃភោគទ្រព្យផង និង ក៏ជាប្រភពនៃជម្លោះផងដែរ[១]។ ក្នុង១៥គ្រួសារមាន១គ្រួសារ ពាក់ព័ន្ធនឹងវិវាទដីធ្លី[២]។ ពិតមែនតែពុំទាន់មានភស្តុតាងពិតប្រាកដណាមកបញ្ជាក់ក៏ដោយ តែបើតាមការសង្កេតជាទូទៅ កំណើនឯកជនូបនីយកម្ម លើដីធ្លីធំៗក្នុងដៃមនុស្សមួយចំនួនតូច បានលេចរូបរាងឡើងគួរឱ្យកត់សំគាល់។ ទន្ទឹមគ្នានេះកំណើនប្រជាពលរដ្ឋ និង ការអភិវឌ្ឍកំពុងកើនឡើង ដែលនាំឱ្យអត្រាកំណើនអ្នកគ្មានដីធ្លីកាន់តែកើនឡើងដែរ[៣]។

ការស្រាវជ្រាវបានឱ្យដឹងថា ប្រជាពលរដ្ឋកម្ពុជា ១២-១៥% ជាអ្នកគ្មានដី[៤] ពោលគឺស្មើនឹងមនុស្សជាង ១លាននាក់។ យុវជនដល់អាយុចូលក្នុងទីផ្សារការងារមានជាង ២០០.០០០នាក់ ក្នុងមួយឆ្នាំ ឯលទ្ធភាពបង្កើតការងារធ្វើក្រៅពីវិស័យកសិកម្មនៅមានកម្រិត។ តាមការធ្វើបច្ចុប្បន្នភាពលើភាពគ្មានដីធ្លីរបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិឃើញថា កម្រិតនៃប្រជាពលរដ្ឋគ្មានដីធ្លីកើន

[១] ហ៊ុន សែន: *សុន្ទរកថាវេទិកាដីធ្លីថ្នាក់ជាតិ* នៅវិមានរាជរដ្ឋាភិបាល ភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ទំព័រ៥។

[២] អុកស្វាម: *វិវាទដីធ្លីនៅកម្ពុជា ភ្នំពេញ ឆ្នាំ ២០០៥ ទំព័រ១៤។*

[៣] Robin Biddulph: *ការបង្ហាញឱ្យកាន់តែឃើញពីភាពក្រីក្រ* អុកស្វាម ភ្នំពេញ ឆ្នាំ២០០០ ទំព័រ២៧។

[៤] ហ៊ុន សែន: *សុន្ទរកថាវេទិកាដីធ្លីថ្នាក់ជាតិ* -ដ.ឯ.ម-ទំព័រ៣។

ឡើងដល់១៩%[៥] និងអ្នកមានដីធ្លីតិចតួចមានចំនួន២៩% និង ៨០%ក្នុងចំណោមនេះមានដីតិចជាង ៣ហិកតា។

ការលើកយកប្រធានបទបញ្ហាដីធ្លីមកសិក្សា គឺដោយសាររឿងវិវាទដីធ្លីនៅកម្ពុជា ជាបញ្ហាធំមួយក្នុងចំណោមបញ្ហាធំៗមួយចំនួនដែលងាយធ្វើប្រទេសកម្ពុជាធ្លាក់ក្នុងភាពអសន្តិសុខ។ បញ្ហាធំៗដទៃទៀតមានដូចជា បញ្ហាកាត់ទោសមេខ្មែរក្រហម និងបញ្ហាជម្លោះព្រំដែនខ្មែរ-ថៃជាដើម។ ការសិក្សាក្នុងន័យឈ្វេងយល់ឱ្យបានស៊ីជម្រៅពីបរិបទនៃបញ្ហា ដើម្បីជាបទពិសោធន៍សម្រាប់ជំនួយស្មារតីដល់អ្នកពាក់ព័ន្ធវិស័យនេះ យកទៅពិចារណា។ ក្រៅពីការស្រាវជ្រាវនេះ ក៏មានការគួបផ្សំជាមួយបទពិសោធន៍ការងារជាអ្នកស្រាវជ្រាវនូវ "គម្រោងសិក្សាដីធ្លីនៅកម្ពុជា" នៅអង្គការអុកស្វាមអង់គ្លេសអស់រយៈពេល១០ឆ្នាំ បានបង្កលក្ខណៈងាយស្រួលដល់ការសន្សំឯកសារ និងបន្តការសិក្សានូវបញ្ហាដីធ្លីនេះ។ ទោះបីជាយ៉ាងណា ការលំបាកនៅតែជួបប្រទះ ទាក់ទងការទទួលបានឯកសារផ្លូវការរបស់រាជរដ្ឋាភិបាល និង ឯកសារមួយចំនួនជាភាសាបរទេសដែលការយល់ដឹងរបស់ខ្ញុំនៅមានកម្រិតជាដើម។ ដូច្នេះខ្ញុំសង្ឃឹមថា ស្នាដៃនេះគឺជាសមិទ្ធផលមួយដែលកើតឡើងដោយសារការព្យាយាមយ៉ាងស្វិតស្វាញ និង ផ្ចិតផ្ចង់បំផុតសម្រាប់ទុកជាជំនួយដល់អ្នកសិក្សាស្រាវជ្រាវនាពេលបច្ចុប្បន្ន និងទៅអនាគត។

[៥] Oxfam GB: ***Re-analyzing of Survey Data from the Oxfam Land Holding Survey 2006***: Consulting report Assessment, Selective Analysis and Interpretation of Survey Data, Phnom Penh, 2008, page 7.

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រជាពលរដ្ឋដែលមានប័ណ្ណកាន់កាប់ដីធ្លីមានមិនដល់២០%ទេ ហើយកង្វះខាតនេះបណ្ដាលឱ្យមានទំនាស់ដីធ្លីកើនឡើងជាលំដាប់ ពីព្រោះ ម្ចាស់ប័ណ្ណពុំទាន់មានទំនុកចិត្តខ្លាំងលើប័ណ្ណកម្មសិទ្ធិ ដោយការធានានៅមានកម្រិតផ្ទុយទៅវិញការធ្វើប័ណ្ណមានតម្លៃខ្ពស់[៦]។ បញ្ហានេះពុំទាន់បានរាប់បញ្ចូលនូវអត្រាអ្នកគ្មានដីធ្លីជាច្រើនដែលបណ្ដាលមកពីការដេកហូត ឬការបំពានទន្ទ្រានរឹបអូសយកដោយការរំលោភបំពានពីសំណាក់ជនខិលខូចមួយចំនួនតូចនៅឡើយទេ។ វិវាទដីធ្លីចាប់ផ្ដើមកើតឡើងក្នុងរវាងឆ្នាំ ១៩៩១ ដល់ ២០០៤ ដោយមានការរំលោភយកដីរបស់ប្រជាកសិករពីសំណាក់មន្ត្រីខិលខូចមួយចំនួន[៧]។ ប្រជាពលរដ្ឋជាច្រើនបានមកតវ៉ា និង ប្ដឹងទាមទារដីធ្លីរបស់ពួកគេនៅគ្រប់ស្ថាប័នពាក់ព័ន្ធនានា ដោយបានចោទប្រកាន់មន្ត្រីខិលខូចមួយចំនួនថា ជាអ្នកដែលបាននិងកំពុងរំលោភយកដីធ្លីដែលជាតម្រូវការចាំបាច់ដើម្បីចិញ្ចឹមជីវិតរបស់ពួកគេ ។

ឆ្លើយតបនឹងវិបត្តិដីធ្លី រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មការជាតិដោះស្រាយបាតុភាពដីធ្លី នៅខែមីនា ឆ្នាំ១៩៩៩ គណៈកម្មការខេត្ត ក្រុងដោះស្រាយបាតុភាពដីធ្លី បានបង្កើតជាហូរហែនៅគ្រប់ខេត្ត ក្រុង។ ជាលទ្ធផលយោងតាមការសិក្សាបានបង្ហាញថា ដំណើរការនៃការដោះស្រាយជម្លោះរបស់គណៈកម្មការនោះហាក់ដូចជានៅមានកម្រិត។ ផ្អែកតាមប្រភពនានាបង្ហាញថា វិវាទដីធ្លីរាប់រយករណីមិនទាន់បានដោះស្រាយនៅឡើយ ទាំងការដោះស្រាយតាមប្រព័ន្ធតុលាការ និង តាមគណៈកម្មការដោះស្រាយបាតុភាពដីធ្លី ។ មិនតែប៉ុណ្ណោះ កំណើនវិវាទដីធ្លីចេះតែកើនឡើងថែមទៀតដែលនេះធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្រីក្រ អសន្តិសុខសង្គម និងលើសពីនេះទៀត ក៏បណ្ដាលឱ្យជនរងគ្រោះមួយចំនួនបានខកចិត្តយ៉ាងខ្លាំង និង អស់ក្ដីសង្ឃឹមក្នុងជីវិតសម្រេចចិត្តបោះបង់បណ្ដឹងចោលលែងតវ៉ា ដោយមូលហេតុបានលើកឡើងថា៖ "ប្ដឹងទៅអ្នកណាក៏ដូចតែគ្នា ប្ដឹងទៅណាក៏ជាគ្នាគេ មិនបានផលអ្វីឡើយ "[៨] ។

មានការប៉ុនប៉ងជាច្រើនដើម្បីឆ្លើយតបបញ្ហាខាងលើ ពីសំណាក់ក្រុមអង្គការសង្គមស៊ីវិលសហគមន៍ផ្ដល់ជំនួយអន្តរជាតិនានា និងរដ្ឋាភិបាល។ ជាក់ស្ដែង នៅប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយ និង ក្របខណ្ឌច្បាប់នានា ដូចជាច្បាប់ភូមិបាល ឆ្នាំ ២០០១ និង អនុក្រឹត្យមួយចំនួនដើម្បីដោះស្រាយបញ្ហាវិបត្តិខាងលើទាំងនេះ។ ក្រោយមកទៀតមានការបង្កើតគណៈកម្មការសុរិយោដីតាមរយៈអនុក្រឹត្យលេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។ នេះជាយន្តការថ្មីមួយ

---

[៦] Shaun Williams: *ជម្លោះកម្មសិទ្ធិដីធ្លីនៅកម្ពុជា* ការសិក្សាស្ដីអំពីសមត្ថភាពដោះស្រាយដីធ្លីនៅ៥ខេត្ត ភ្នំពេញ ឆ្នាំ ២០០០ ទំព័រ២។

[៧] Oxfam GB: *វិវាទដីធ្លីនៅកម្ពុជា* ភ្នំពេញ ឆ្នាំ២០០៥ ទំព័រ២។

[៨] Ibit. ទំព័រ៣។

ដើម្បីដោះស្រាយវិវាទដីធ្លី ដែលគណៈកម្មការនេះមានបេសកកម្ម និងតួនាទីជាអ្នកសម្រេចចំពោះវិវាទដីភោគៈមុនបញ្ជូនទៅតុលាការ។

ប៉ុន្មានឆ្នាំកន្លងមកនេះ នៅពេលដែលដំណើរការកែទម្រង់ដីធ្លីកំពុងឆ្ពោះទៅមុខ គេសង្កេតឃើញថា មានបែបផែននៃការរឹបអូសយកដីធ្លី ដោយកងកម្លាំងប្រដាប់អាវុធបណ្តេញប្រជាពលរដ្ឋចេញពីលើដីធ្លី ដែលពួកគាត់បានកាន់កាប់អស់រយៈពេលយូរឆ្នាំមកហើយ ពេលគឺតាមរយៈការប្រើប្រាស់ប្រព័ន្ធតុលាការដោយភាគីម្ខាងជាមន្ត្រីរាជការ។ តាមរយៈការមកប្តឹងតវ៉ារបស់ជនរងគ្រោះឬតាមបណ្តាញសារព័ត៌មាននានា និង ការត្អូញត្អែរដង្ហោយហៅរកអន្តរាគមន៍ផ្ទាល់ពីសំណាក់ជនរងគ្រោះនោះបានបង្ហាញឱ្យឃើញថា ករណីវិវាទដីធ្លីនៅតែជាបញ្ហានៅឡើយ ។

បញ្ហាទីផ្សារដីឡើងថ្លៃ ធ្វើឱ្យជនខិលខូចមួយចំនួនតូច បានឆ្លៀតឱកាសរំលោភយកដីធ្លីខណៈដែលប្រជាពលរដ្ឋក្រីក្រខ្វះលទ្ធភាពធ្វើប័ណ្ណដីធ្លី។ វិវាទដីធ្លី កើនឡើងជាបន្តបន្ទាប់ និង ក្លាយជាបញ្ហាសង្គមស្មុគស្មាញឡើងៗ។ តាមរបាយការណ៍រាជរដ្ឋាភិបាល វិវាទដីធ្លីកើនឡើងជាលំដាប់ប្រចាំឆ្នាំពីចំនួន១២៤៥ ករណី ក្នុងឆ្នាំ ២០០៣ រហូតដល់ចំនួន ៥០៣៨ ករណី ឆ្នាំ ២០០៨ និងចំនួន ៥១៩៣ ករណី នៅឆ្នាំ ២០០៩។ វិវាទដីធ្លីបង្កឱ្យកើតមានឡើងនូវអំពើហិង្សាបង្ករបួសស្នាមនិងស្លាប់មនុស្ស។ ទង្វើទាំងនោះភាគច្រើនកើតឡើងដោយសារ កងកម្លាំងប្រដាប់អាវុធការពារដីឯកជនទៅលើប្រជាពលរដ្ឋក្រីក្រដែលជាជនរងគ្រោះ នៅទីកន្លែងដែលមានទំនាស់ក្តៅ។ ប្រមុខនៃរាជរដ្ឋាភិបាលក៏ធ្លាប់មានប្រសាសន៍ដោយបានអំពាវនាវឱ្យអាជ្ញាធរប្រគល់ដីឱ្យរាស្ត្រវិញ ប្រសិនបើដីនោះជាប់មានទំនាស់រវាងរាស្ត្រ នឹងអាជ្ញាធរ។

វិវាទដីធ្លីមានដូចជា វិវាទពាក់ព័ន្ធនឹងភាគីឯកជន វិវាទតូចតាចដែលកើតឡើងក្នុងរង្វង់គ្រួសារ អ្នកជិតខាង ម្ចាស់បំណុល។ វិវាទប្រភេទនេះទាក់ទងនឹងការបិទផ្លូវដើរ ព្រំប្រទល់ដីមិនច្បាស់លាស់ កេរតមត៌ក និងបំណុល ហើយភាគីទីពីរមិនសុខចិត្ត បើទាក់ទងនឹង បំណុលគឺ ម្ចាស់បំណុលរឹបអូសយកដីកូនបំណុល។ វិវាទស្ថិតក្នុងចង្កោមភាគីឯកជន តែមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋនៅស្ទើរគ្រប់កន្លែង ក្នុងប្រទេសគឺ ទំនាស់ជាមួយក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច។ ប្រជាពលរដ្ឋជាង ១០,០០០ គ្រួសារ ដែលបានទាមទារតវ៉ាពីផលប៉ះពាល់មកលើដីធ្លី របស់ខ្លួនដោយសារការផ្តល់ដីសម្បទានសេដ្ឋកិច្ច ដែលមិនមានការសិក្សាពីផលប៉ះពាល់ខាងសង្គមឱ្យបានត្រឹមត្រូវល្អ។ វិវាទមួយសណ្ឋានទៀត ពាក់ព័ន្ធជាមួយអាជ្ញាធរជាវិវាទមានលក្ខណៈក្តៅ។ តាមការសិក្សារបស់អង្គការអុកស្វាម ៧៥ ភាគរយ នៃអ្នកដែលត្រូវគេចោទប្រកាន់ថាយកដីរបស់ពួកគេគឺអាជ្ញាធរមានឋានៈខ្ពស់។ មានការដេកហូតយកដីដោយបង្ខំ ដើម្បីធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន។ ពេលខ្លះមិនមានភាពច្បាស់លាស់រវាងតួនាទីរដ្ឋ និងឯកជន ដោយសារមន្ត្រីរដ្ឋាភិបាលបានចូលរួម ដោយផ្ទាល់នៅក្នុងសកម្មភាពផ្នែកឯកជន និង ដើរតួក្នុងរូបភាពសហការយ៉ាងជិតស្និទ្ធជាមួយអ្នកវិនិយោគទុន។

មូលហេតុដែលនាំឱ្យកើតឡើងនូវវិវាទដីធ្លី បណ្តាលមកពីហេតុជាច្រើនដូចជា ការមិនមានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងប្រជាពលរដ្ឋជាច្រើនមិនមានប័ណ្ណកម្មសិទ្ធិដីធ្លី។ តាមរបាយការណ៍របស់វិទ្យាស្ថាន បណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឃើញថា ប្រជាពលរដ្ឋ ៧៥

ភាគរយ ដែលកាន់កាប់ដីកសិកម្ម មិនខ្វល់ខ្វាយនឹងដាក់ពាក្យសុំសិទ្ធិកាន់កាប់ដីធ្លីឡើយ។ ប្រជាពលរដ្ឋប្រហែល ១០ ភាគរយ មានប័ណ្ណកាន់កាប់ដីធ្លីស្របច្បាប់។ ការប្រឈមក្នុងការធ្វើប័ណ្ណកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ដោយសារការធ្វើប័ណ្ណមានតម្លៃខ្ពស់ និងនីតិវិធីស្មុគស្មាញ។ ប្រជាពលរដ្ឋបន្តការផ្ទេរសិទ្ធិលើដីធ្លី តាមតែទម្លាប់ដោយមានការឃុបឃិតគ្នាជាមួយជនពុករលួយមួយចំនួនតូចក៏បង្កឱ្យមានវិវាទដីធ្លី។

បញ្ហាប្រឈមក្នុងការគ្រប់គ្រង និង ដោះស្រាយវិវាទដីធ្លីប្រទេសកម្ពុជា ក៏ស្រដៀងគ្នាជាមួយប្រទេសចំនួនទៀត ដូចជាប្រទេសថៃ នេប៉ាល់ និងទុយនីស៊ី។ ភាពចន្លោះប្រហោងក្នុងការគ្រប់គ្រងរបស់រដ្ឋាភិបាលលើការអនុវត្តច្បាប់លើវិស័យដីធ្លី វាបានបង្កលក្ខណៈងាយស្រួលដល់បុគ្គលខិលខូចមួយចំនួនឆក់ឱកាសកេងចំណេញពីស្ថានការណ៍ ដោយបន្លំយកដីរដ្ឋមកធ្វើការកម្មសិទ្ធិឯកជន។ ការណ៍នេះធ្វើឱ្យវិវាទដីធ្លីនៅតែបន្តកើតឡើង និងដោះស្រាយមិនចេះចប់។ ទាំងនេះដោយសារដីធ្លីជាប្រភពចំបងនៃអំណាច ទ្រព្យ និង នាំមកនូវជម្លោះ។ ចំណុចដែលសំខាន់គឺពាក់ព័ន្ធនឹងឆន្ទៈនយោបាយរបស់ថ្នាក់ដឹកនាំរបស់ប្រទេសនីមួយៗក្នុងការដោះស្រាយបញ្ចប់វិវាទ។

បញ្ហាក្របខ័ណ្ឌគតិយុត្តទាក់ទងនឹងដីធ្លី ជាពិសេស សិក្សាទៅលើការកសាងឯកសារគតិយុត្តសម្រាប់អនុវត្តច្បាប់ភូមិបាល ឆ្នាំ ២០០១ មានលក្ខណៈរីកចម្រើន។ ក៏ប៉ុន្តែដោយសារកេរដំណែលជាប្រវត្តិសាស្ត្រនៃការផ្លាស់ប្តូរគោលនយោបាយដីធ្លី បានបន្សល់ទុកឱ្យសង្គមកម្ពុជាបច្ចុប្បន្ននៅតែប្រឈមនឹងបញ្ហាជាច្រើនដែលទាក់ទងនឹងដីធ្លី ជាពិសេស វិវាទដីធ្លីនៅជាបញ្ហាធំមួយនៅកម្ពុជា[៥]។ ការខិតខំរបស់រាជរដ្ឋាភិបាលសហការណ៍ជាមួយដៃគូអភិវឌ្ឍន៍ បានស្វែងរកវិធីដោះស្រាយដែលដំណោះស្រាយជាដំបូងគឺ ការបង្កើតគោលនយោបាយដីធ្លី។ គោលបំណងនៃគោលនយោបាយនេះមានបង្កប់នៅក្នុងច្បាប់ និង នៅក្នុងគោលដៅនៃកិច្ចការគម្រោងសាកល្បង និង ជួយដោះស្រាយភាពមិនច្បាស់លាស់។ ប្រការនេះនឹងធ្វើឱ្យការប្រើប្រាស់ធនធានដើម្បីដោះស្រាយបញ្ហាដីធ្លីកាន់តែមានប្រសិទ្ធភាព និង ខិតទៅជិតនៃគោលនយោបាយកំណែទម្រង់ដីធ្លីរបស់រដ្ឋ។

បញ្ហាច្បាប់ និងនីតិវិធីពាក់ព័ន្ធមិនទាន់មានគ្រប់គ្រាន់ ទាមទារឱ្យមាន ក្របខ័ណ្ឌច្បាប់ច្បាស់លាស់ ស្តីពីសិទ្ធិលើអចលនទ្រព្យ អំពីការផ្ទេរការប្រើប្រាស់ដីរដ្ឋ និង ដីឯកជនព្រមទាំងអំណាចតាមច្បាប់របស់រដ្ឋលើការប្រើប្រាស់ដីធ្លី។ អវត្តមានច្បាប់ចាំបាច់មួយចំនួនធ្វើឱ្យការដោះស្រាយមានការយឺតយ៉ាវ។ កង្វះខាតនៃច្បាប់ធ្វើឱ្យមតិមួយចំនួន បានចោទប្រកាន់មន្ត្រីអនុវត្តច្បាប់ថារំលោភច្បាប់ និងរំលោភសិទ្ធិមនុស្ស ភាគច្រើន ដែលគេបានដឹងករណីនេះ គឺពាក់ព័ន្ធលើការផ្លាស់លំនៅដ្ឋានប្រជាពលរដ្ឋ។

រហូតមកដល់បច្ចុប្បន្នរដ្ឋពុំទាន់មានការកំណត់អត្តសញ្ញាណដី ថាតើកន្លែងណាជាដីសាធារណៈរបស់រដ្ឋ និងកន្លែងណាជាដីឯកជនរបស់រដ្ឋ។ ទោះបីដីតំបន់ត្រូវការពារ ដីធ្វើអាជីវកម្មសាធារណៈលើដីសាធារណៈរបស់រដ្ឋ និងការផ្តល់ដីសម្បទាន ជួល ឬផ្ទេរលើដីឯកជនរបស់រដ្ឋ សម្រាប់ការ

---

[៥] រាជរដ្ឋាភិបាលៈ *ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី* ឯកសារបឋម បានអនុម័តពីគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០២ ទំព័រ៧។

អភិវឌ្ឍសេដ្ឋកិច្ច ក៏គ្មានការកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់នោះដែរ។ ដូច្នេះទើបគេឃើញមានការតវ៉ារឿងដីធ្លី ពីសំណាក់ប្រជាពលរដ្ឋមានការកើនឡើង ករណីខ្លះ ឈានដល់កើតមានអំពើហិង្សាទៀតផង។ ម្យ៉ាងវិញទៀតប្រជាពលរដ្ឋរាប់ម៉ឺននាក់ប្រឈមនឹងឧបសគ្គក្នុងការទទួលស្គាល់ឱ្យបានត្រឹមត្រូវ ចំពោះភោគៈស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១។

រាជរដ្ឋាភិបាលនៅតែប្រឈមនឹងបញ្ហាជាច្រើន ដែលទាក់ទងនឹងដីធ្លី ជាពិសេសវិវាទដីធ្លីចេះតែកើនឡើង។ ឆ្លើយតបបញ្ហានេះ រាជរដ្ឋាភិបាលខិតខំដោះស្រាយ ទោះបីជាតាមផ្លូវរដ្ឋបាល ឬតុលាការក្តីដោយទទួលបានជោគជ័យច្រើនតែនៅមានកម្រិត។ ច្បាប់ និងក្របខ័ណ្ឌគតិយុត្តនានាមិនទាន់ច្បាស់លាស់ និង មានភាពស្របគ្នាទៅតាមឋានានុក្រមក្នុងការគ្រប់គ្រង់ និងដោះស្រាយទំនាស់ដីធ្លី។ បញ្ហានេះធ្វើឱ្យមន្ត្រីអនុវត្តច្បាប់ភាន់ច្រឡំ ដោយមិនដឹងត្រូវដើរតាមផ្លូវណាដែលកត្តានេះងាយធ្វើឱ្យពួកគេ ត្រូវរើសយកវិធីដែលមិនស្របច្បាប់មកប្រើ ជាវិបាកតុលាការត្រូវបានចោទប្រកាន់ថាមិនឯករាជ្យ។ ម្យ៉ាងអវត្តមានច្បាប់និង បទដ្ឋានច្បាប់ចាំបាច់មួយចំនួនបានធ្វើឱ្យសមត្ថកិច្ចមានភាពស្រពិចស្រពិលលើការដោះស្រាយទាំងបែបរដ្ឋបាល និងតុលាការ។ ម្យ៉ាងទៀតទន្ទឹមនឹងការជួបប្រទះនូវភាពមិនច្បាស់លាស់ ទាំងនេះហើយក៏ដោយក៏រដ្ឋាភិបាលប្រឈមនឹងបញ្ហាជាច្រើនដូចជា កត្តាមធ្យោបាយធ្វើដំណើរ កត្តាសមត្ថភាព ធនធានមនុស្ស និងកត្តាថវិកាមិនគ្រប់គ្រាន់ជាដើម។

ករណីវិវាទដីធ្លីមួយនៅតំបន់ដីក្រហមរាជធានីភ្នំពេញ។ ករណីនេះមានភាពស្មុគស្មាញហើយវាបានឆ្លុះបញ្ចាំង អំពីករណីវិវាទផ្សេងៗទៀតនៅកម្ពុជា។ ការវិភាគផ្លូវច្បាប់លើករណីនេះករណីវិវាទនៅតំបន់ដីក្រហម ការដោះដូរដីធ្លីដែលបានកើតឡើងក្រោមរូបភាពផ្សេងៗគឺផ្ទុយនឹងច្បាប់។ ការអង្កេតស៊ីជម្រៅនៃករណីនេះ អាជ្ញាធររាជធានីនិងអ្នកពាក់ព័ន្ធមួយចំនួននៅមានការខ្វះចន្លោះក្នុងការអនុវត្តច្បាប់ ហើយពេលខ្លះបានដើរតួជាភាគីទំនាស់ជំនួសមុខឱ្យភាគីម្ខាងទៅវិញ។

វិវាទដីធ្លីកាន់តែរីករាលដាលមានលក្ខណៈស្មុគស្មាញ និង តម្រូវឱ្យស្ថាប័នជំនាញយកចិត្តទុកដាក់ដើម្បីដោះស្រាយឱ្យបានទាន់ពេលវេលា។ ដំណោះស្រាយអាចប្រព្រឹត្តទៅបានល្អលុះត្រាតែមានគោលនយោបាយ ច្បាប់នៅនឹងកន្លែងស្រាប់ ហើយស្ថាប័នអនុវត្តច្បាប់ទាំងនោះត្រូវមានធនធានមនុស្ស សម្ភារៈ និង ថវិកាគ្រប់គ្រាន់ ព្រមទាំងមានឆន្ទៈក្នុងការដោះស្រាយផងនោះ ទើបវិវាទដីធ្លីនឹងត្រូវថយចុះ។

វិស័យដីធ្លីជាបញ្ហាធំទូលាយ ស្មុគស្មាញ ទោះបីជាយ៉ាងណាក៏មិន អាចសរសេរឱ្យបានអស់នោះដែរមានចំណុចនៅសេសសល់ជាច្រើនទៀត សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្តដូចជា៖

តើករណីវិវាទដីធំៗដែលអូសបន្លាយច្រើនឆ្នាំ និងភាគីជាអ្នកមានខ្នងជាមន្ត្រីជាន់ខ្ពស់ តើត្រូវដោះស្រាយយ៉ាងដូចម្តេច?

តើបញ្ហាវិវាទដែលបន្តកើនឡើង និងមានលក្ខណៈហិង្សា វាអាចធ្វើឱ្យកម្ពុជាកើតបដិវត្តន៍ ឬយ៉ាងណា?

តើកត្តាអ្វីខ្លះរារាំងមិនឱ្យស្ថាប័នមានសមត្ថកិច្ចដោះស្រាយវិវាទដីធ្លី ជូនប្រជាពលរដ្ឋ ? មើលកត្តារចនាសម្ព័ន្ធ ឬទំនាក់ទំនងអំណាច?

តើវិវាទដីធ្លីនៅតែបន្តកើតឡើង ទោះបីដីនោះត្រូវបានចុះបញ្ជី ហើយក៏ដោយ?

ហេតុអ្វីតុលាការដែលជាអ្នកប្រកាន់អំណាច ឯករាជ្យដែលធានាដោយរដ្ឋធម្មនុញ្ញ បែជាយកសេចក្តីសម្រេចរបស់រដ្ឋាភិបាលមកអនុវត្តជំនួសច្បាប់ទៅវិញក្នុងរឿងវិវាទដីធ្លី?

តើវិវាទដែលមិនបានដោះស្រាយ ឬត្រូវអូសបន្លាយទាំងនោះ វាប៉ះពាល់ដល់ជីវភាពប្រជាពលរដ្ឋកម្រិតណា? និងដូចម្តេច?

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សានេះ នឹងស្វែងរកហេតុផលទាំងឡាយនាំឱ្យកើតបញ្ហាប្រឈមដែលកើតមានវិវាទដីធ្លីនៅកម្ពុជា។ ជាមួយនោះដើម្បីស្វែងរកយន្តការក្នុងការដោះស្រាយវិវាទដីធ្លីឱ្យមានប្រសិទ្ធភាព និង និរន្តរភាពក្នុងការចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋដែលចំណុចទាំងនោះរួមមានដូចជា៖

១. តើកត្តាអ្វីដែលជាបុព្វហេតុប្រឈមនាំដល់កើតមានវិវាទដីធ្លីបច្ចុប្បន្ន?

២. តើចំណាត់ការគ្រប់គ្រងរបស់រដ្ឋដែលកំពុងអនុវត្តមានប្រសិទ្ធភាពដែរឬទេ?

៣. តើមានវិធីសាស្ត្របែបណាដើម្បីដោះស្រាយវិវាទដីធ្លីទាំងនោះ?

៤. តើប្រសិទ្ធភាពក្នុងការដោះស្រាយវិវាទដីធ្លីមានលក្ខណៈយ៉ាងណាដែរ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសិក្សាស្វែងយល់អំពី ហេតុផលដែលជាបច្ច័យអវិជ្ជមានដែល ជាឧបសគ្គដល់ការដោះស្រាយវិវាទដីធ្លី និង រកឱ្យឃើញនូវចំណុចខ្លាំង ចំណុចខ្សោយ និង ផ្តល់ជាអនុសាសន៍មួយចំនួនសម្រាប់ជាអត្ថប្រយោជន៍ ដើម្បីចូលរួមចំណែកក្នុងការចែករំលែកដល់ស្ថាប័នទទួលបន្ទុកដោះស្រាយទំនាស់ដីធ្លី និង ភាគីពាក់ព័ន្ធនានាផងដែរ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

និក្ខេបបទនេះ គឺជាយន្តការសិក្សាបញ្ចេញមតិឬទស្សនៈតាមការវិភាគ ស្រាវជ្រាវ ប្រៀបធៀបទៅតាមបែបផែនទ្រឹស្តី ព្រមជាមួយការអនុវត្តជាក់ស្តែង ដើម្បីស្វែងរកទិន្នន័យក្នុងការអនុវត្តយន្តការច្បាប់គ្រប់គ្រងវិវាទដីធ្លីឱ្យមានប្រសិទ្ធភាព និង បម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និង ប្រទេសជាតិ ឱ្យមានភាពជាក់លាក់ និង ចីរភាព។ ដែនកំណត់នៃការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើទ្រឹស្តីមូលដ្ឋាននៃវិវាទដីធ្លី និង គោលការណ៍ នីតិវិធីដោះស្រាយនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន និងអាចទៅអនាគតតាមលក្ខណៈច្បាប់នៃការគ្រប់គ្រងក្នុងការដោះស្រាយវិវាទដីធ្លី។ ជាពិសេស ការសិក្សាស្រាវជ្រាវនេះធ្វើនៅក្នុងប្រទេសកម្ពុជា ដោយមានការចូលរួមសិក្ខាសាលានានា និង មានការជែកញែកជាមួយអ្នកឯកទេស អ្នកជំនាញច្បាប់ដីធ្លី និង អ្នកស្រាវជ្រាវនៃបណ្តាប្រទេសមួយចំនួន ដែលមានទំនាក់ទំនងនៅក្នុងយន្តការច្បាប់នៃការដោះស្រាយវិវាទ។

ចំពោះវិសាលភាពនៃការសិក្សាស្រាវជ្រាវនេះ គឺមានបំណងលើកឡើងនូវការអនុវត្តយន្តការច្បាប់ក្នុងការដោះស្រាយវិវាទដីធ្លីនៅព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន និង ទៅអនាគតដោយផ្តោតលើទិដ្ឋភាពរួមនៃការដោះស្រាយវិវាទដោយស្ថាប័នរដ្ឋ និង ទំនាក់ទំនងជាសារវន្តទៅនឹងគោលនយោបាយដីធ្លី ព្រមទាំងយន្តការច្បាប់ពាក់ព័ន្ធទៅនឹងការដោះស្រាយ។ ករណីសិក្សាមួយត្រូវបានប្រើ

ដើម្បីធ្វើការឆ្លុះបញ្ចាំងអំពីបរិបទនៃស្ថានភាពវិវាទដីធ្លីនៅកម្ពុជា អំពីគោលនយោបាយ អំពីបទដ្ឋានគតិយុត្តនានា និង ការអនុវត្តជាក់ស្តែងរបស់ស្ថាប័នមានសមត្ថកិច្ច។ ផ្អែកតាមករណីសិក្សានេះនឹងបង្ហាញឱ្យឃើញកាន់តែច្បាស់ពីភាពខុសគ្នានៃបទដ្ឋានគតិយុត្ត និង ការអនុវត្តជាក់ស្តែង។

ជាងនេះទៀត គឺសិក្សាស្រាវជ្រាវក្នុងដែនកំណត់ និង វិសាលភាពដែលមាននៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ដោយសិក្សាស្រាវជ្រាវពីឆ្នាំ២០០១ ដល់ ឆ្នាំ២០០៩ ដោយកត្តាដីធ្លីធ្វើជាគោលការណ៍ដើម្បីជាយុទ្ធសាស្ត្រក្នុងការវិភាគរកបរិបទថ្មី ដែលមានការពាក់ព័ន្ធនឹងយន្តការច្បាប់ដោះស្រាយវិវាទដីធ្លី។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាសិក្សាស្រាវជ្រាវនិក្ខេបបទថ្នាក់បណ្ឌិតនេះ ធ្វើស្របទៅតាមលក្ខណៈវិទ្យាសាស្ត្រ និង ស្របទៅតាមនីតិវិធី គោលការណ៍ស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិតរបស់រាជបណ្ឌិត្យសភាកម្ពុជា។ មានការប្រើប្រាស់វិធីសាស្ត្របែបពិពណ៌នាវិភាគផង វិធីអនុមាណរួមផង វិធីអនុមាណញែកផង និង ការសាកសួរសំណួរមួយចំនួន សម្រាប់ជាមូលដ្ឋានក្នុងការវិភាគទិន្នន័យដែលមានដូចខាងក្រោម៖

អថេរឯករាជ្យ ជាអថេរដែលមានភាពជាម្ចាស់ដោយខ្លួនឯង វាមិនទទួលរងឥទ្ធិពលពីកត្តាខាងក្រៅ ហើយកត្តាជាច្រើនដែលនាំឱ្យកើតមានឡើងបញ្ហាទំនាស់ដីធ្លីនៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន។ នៅក្នុងការសិក្សានេះអថេរឯករាជ្យ ត្រូវបានជ្រើសយកធ្វើជាកត្តាចម្បងចំនួន៤ (ទី១) កត្តាច្បាប់ (ទី២) កត្តាបរិយាកាសសង្គម (ទី៣) កត្តាសេដ្ឋកិច្ច និង(ទី៤) កត្តាប្រជាពលរដ្ឋ និង ភាពក្រីក្រ។

ចំពោះអថេរមិនឯករាជ្យ វាជាអថេរមានលក្ខណៈប្រែប្រួលទៅតាមកត្តាជាច្រើនដែលមានឥទ្ធិពលមកលើវា។ អថេរមិនឯករាជ្យនេះ វាពឹងផ្អែកទាំងស្រុងទៅលើអថេរឯករាជ្យ។ និក្ខេបបទនេះបានកំណត់យក "វិវាទដីធ្លីនៅកម្ពុជា ២០០១-២០០៩" ជាអថេរមិនឯករាជ្យ។

ការសាកសួរព័ត៌មាននឹងអង្កេតផ្ទាល់ខ្លួន ពិគ្រោះយោបល់ជាមួយមន្ត្រីតាមក្រសួងពាក់ព័ន្ធមួយចំនួន ដូចជាគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងការផ្លាស់ប្តូរយោបល់រវាងអ្នកពាក់ព័ន្ធក្នុងវិស័យនេះ និង ទទួលមតិសំខាន់ៗពីសាស្ត្រាចារ្យដឹកនាំ។ ជាមួយគ្នានេះដែរ ធ្វើការសិក្សាអង្កេតដល់ទីកន្លែង ដើម្បីសាកសួរប្រជាពលរដ្ឋដីក្រហមទាក់ទងវិវាទរបស់គេជាមួយក្រុមហ៊ុន គួបផ្សំនឹងការបញ្ចេញទស្សនៈ និង សំណូមពរមួយចំនួនរបស់ប្រជាពលរដ្ឋរងគ្រោះព្រមទាំងមតិ និង យោបល់របស់ដៃគូអភិវឌ្ឍន៍ដែលបានដឹងករណីវិវាទនេះ។

ច្បាប់ជាតិ និង ច្បាប់អន្តរជាតិ ព្រមទាំងឯកសារដែលផ្តល់ដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និង អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីនៃទីស្តីការគណៈរដ្ឋមន្ត្រី និងស្ថាប័នពាក់ព័ន្ធ ឯកសាររបស់អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ឯកសារដែលទទួលបានតាមរយៈការសិក្សាកន្លងមក និង ឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធ (តាមបណ្ណាល័យ ឯកសារពីគេហទំព័រសារព័ត៌មាន វិទ្យុ ទស្សនាវដ្តី និងខ្សែភាពយន្តជាដើម)។

សារសំខាន់នៃការវិភាគទិន្នន័យ គឺធ្វើឡើងតាមការវិភាគខ្លឹមសារនៃអត្ថបទបច្ចេកទេសផ្លូវការនានា និង បទសម្ភាសន៍ គ្រប់មជ្ឈដ្ឋានសង្គម ដោយស្វែងរកបដិសំយោគ និង បម្រើផលប្រយោជន៍ទូទៅរបស់មនុស្សនៅក្នុងសង្គម ហើយប្រការដែលចាំបាច់នោះ គឺធ្វើការបកស្រាយឱ្យបានច្បាស់លាស់ពីហេតុផល និង ការកើតមានឡើងនូវបញ្ហាវិវាទដីធ្លី។ ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងដោយផ្អែកទៅលើការវិភាគតាមវិធីសាស្ត្របែបគុណភាព (Qualitative Analysis) ក្នុងការបកស្រាយវែកញែកមកបង្ហាញនូវហេតុផលផ្សេងៗ។

## ៦. សារប្រយោជន៍នៃការស្រាវជ្រាវ

ប្រធានបទស្តីពី " វិវាទដីធ្លីនៅកម្ពុជា " គឺមានសារសំខាន់សម្រាប់ជាប្រយោជន៍ដល់ការស្វែងយល់នូវចំណុចសំខាន់ៗនូវយន្តការគ្រប់គ្រង និងដោះស្រាយវិវាទដីធ្លីនៅកម្ពុជា ដែលស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ជាពិសេស វាមានអត្ថប្រយោជន៍ក្នុងការពង្រឹងវិស័យច្បាប់តាមគោលការណ៍នីតិរដ្ឋនៅកម្ពុជា។ លើសពីនេះទៀត ការសិក្សានេះគឺមានបំណងឱ្យអ្នកអានបានយល់ដឹងនូវ ទ្រឹស្តី នីតិវិធី គោលការណ៍ផ្សេងៗ នៃដំណោះស្រាយវិវាទដើម្បីជំរុញឱ្យមានការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព និង មានលក្ខណៈសុក្រឹតសម្រាប់ជាផលប្រយោជន៍ដល់ប្រជាពលរដ្ឋ ជាពិសេស ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះ។

លទ្ធផលដែលស្តែងចេញចំពោះការស្រាវជ្រាវនេះ និង ប្រើប្រាស់ជាផលប្រយោជន៍ដល់ការចូលរួមវិភាគទានលើចំណេះដឹង ក៏ដូចជាទស្សនៈវិស័យខ្លះៗបន្ថែមសម្រាប់អ្នកចូលរួមពាក់ព័ន្ធលើវិស័យដីធ្លីនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានដូចជា រាជរដ្ឋាភិបាល វិនិយោគគិន អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ផ្នែកឯកជន ប្រជាពលរដ្ឋ ជាពិសេស ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី គណៈកម្មការសុរិយោដីគ្រប់ជាន់ថ្នាក់ និង អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីជាដើម បានទទួលនូវព័ត៌មាន និង ទិន្នន័យមូលដ្ឋានសម្រាប់ធ្វើការត្រិះរិះពិចារណាដល់ដំណើរការរៀបចំផែនការ និងសកម្មភាពអនុវត្តដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការដោះស្រាយវិវាទដីធ្លីនៅកម្ពុជានាពេលបច្ចុប្បន្ន និង ទៅអនាគត។

សារសំខាន់ជាពិសេសមួយទៀត គឺបង្កើនឯកសារស្រាវជ្រាវជាភាសាខ្មែរ និងលើកស្ទួយដល់ភាសាជាតិសម្រាប់ជាឯកសារសិក្សាស្រាវជ្រាវដល់កូនខ្មែរប្រុសស្រីជំនាន់ក្រោយ បានសិក្សាស្វែងយល់និងធ្វើការវិភាគពិចារណាតទៅទៀតដើម្បីភាពរីកចម្រើនរបស់ប្រទេសជាតិទៅថ្ងៃមុខ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

និក្ខេបបទនេះរៀបចំឡើងជាភាសាខ្មែរចែកជា៤ជំពូក ដែលមានទំព័រសរុបចំនួន១៥៨ ក្នុងនោះមានតារាងរូបភាពចំនួន១៦ និងតារាងតួលេខចំនួន៩។

សេចក្តីផ្តើម

ជំពូកទី១៖ ប្រវត្តិ និងទិដ្ឋភាពទូទៅនៃវិវាទដីធ្លី

ជំពូកទី២៖ ក្របខ័ណ្ឌគតិយុត្តដីធ្លី

ជំពូកទី៣៖ ការដោះស្រាយវិវាទដីធ្លី

ជំពូកទី៤៖ ការវាយតម្លៃ
សន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី១
# ប្រវត្តិ និងទិដ្ឋភាពទូទៅនៃវិវាទដីធ្លី

# ជំពូកទី១
# ប្រវត្តិ និងទិដ្ឋភាពទូទៅនៃវិវាទដីធ្លី

នៅក្នុងជំពូកនេះចំណុចសំខាន់ៗមួយចំនួននឹងត្រូវលើកឡើងដែលជា ទ្រឹស្តីពាក់ព័ន្ធវិវាទ និង ការសិក្សាស្រាវជ្រាវវិភាគបែបលក្ខណៈវិទ្យាសាស្ត្រ អំពីទិដ្ឋភាពទូទៅពាក់ព័ន្ធពីទំនាក់ទំនងរវាង មនុស្សនឹងដីធ្លី ផ្អែកលើសារសំខាន់ និង ភាពចាំបាច់នៃដី វិសមភាពនៃការកាន់កាប់ និង ការផ្ទេរសិទ្ធិលើដី។ ចំណុចទីពីរគឺ ដកស្រង់អំពីទំនោរនៃវិវាទដីធ្លីដ៏ស្មុគស្មាញនាពេលបច្ចុប្បន្ន និង ពីបម្រែបម្រួលរបស់វា។ បន្ទាប់មក យើងមើលទៅលើប្រភេទនៃវិវាទដីធ្លី ដែលកើតឡើងរវាងភាគីពាក់ព័ន្ធនឹងបុគ្គលឯកជន ដូចជា វិវាទក្នុងរង្វង់វញ្ញាតិលោហិត អ្នកជិតខាង រវាងម្ចាស់បំណុល និងកូនបំណុល និង វិវាទដែលពាក់ព័ន្ធ រវាងប្រជាពលរដ្ឋជាមួយអាជ្ញាធរ និងអង្គភាពយោធាជាដើម។

ជំពូកនេះ នឹងលើកឡើងពីប្រវត្តិនៃការគ្រប់គ្រងដីទៅតាមសម័យកាលនីមួយៗ និង ក៏បានកំណត់ពីមូលហេតុជាច្រើនដែលនាំឱ្យកើតមានវិវាទដីធ្លី ដោយមើលទៅលើសុវត្ថិភាពនៃការកាន់កាប់ដី ការមិនមានឯកសារផ្លូវច្បាប់មកសំអាងឱ្យបានច្បាស់លាស់ ការយល់ច្រឡំ ចំពោះភោគៈ និងកម្មសិទ្ធិ បញ្ហាអលទ្ធភាពក្នុងការធ្វើប័ណ្ណកាន់កាប់ដី និងចំណុចសំខាន់មួយទៀតទាក់ទង ទៅនឹងការអនុវត្តច្បាប់មិនទាន់បានត្រឹមត្រូវចំពោះការផ្ទេរសិទ្ធិលើកម្មសិទ្ធិ។ ផ្នែកបន្ទាប់ធ្វើអង្កេតស៊ីជម្រៅ លើការរំលោភយកដីដោយខុសច្បាប់ពីសំណាក់ជនខិលខូចមួយចំនួន ទៅលើប្រជាពលរដ្ឋក្រីក្រទន់ខ្សោយ និង ការចូលកាន់កាប់ដីដោយខុសច្បាប់ ដោយសារភាពធូរលុងនៃការគ្រប់គ្រងជាដើម។

## ១.១ ប្រវត្តិនៃការគ្រប់គ្រងដីធ្លី

យើងអាចឃើញដីជាលក្ខណៈរូប ដូចជាផែនដីដែលយើងដើរលើវា ។ បើជានយោបាយវិញ យើងអាចឃើញដូចជា ការប្រឆាំងដើម្បីទាមទារបូរណៈភាពដែនដី។ បើជាថវិកា ឃើញដូចជា ទីកន្លែងអភិវឌ្ឍន៍ ឬ ក៏ជាធនធានដែលគេពឹងអាស្រ័យលើ ដូចជាការធ្វើស្រែចំការជាដើម។ អ្នកសេដ្ឋកិច្ចរបស់ធនាគារពិភពលោកបានលើឡើងថា៖

> "ស្ទើរតែគ្រប់ប្រទេសទាំងអស់ ផលប្រយោជន៍ពីដីធ្លី មានរហូតដល់ទៅបីភាគបួននៃទ្រព្យសម្បត្តិរបស់ជាតិទាំងមូល"[៩០]។

សេដ្ឋវិទូសតវត្សទី១៨ ជនជាតិអេកូសលោក អាដាម ស្មីត បាននិយាយថា "ដីជាប្រភពដើមបង្កើនភោគទ្រព្យជាតិ" ហើយដែលសេដ្ឋវិទូជំនាន់ក្រោយៗមកបកស្រាយថា ដីជាដង្ហើមសេដ្ឋកិច្ចជាតិ ជាសុខុមាលភាពជាតិ និងជាអាយុជីវិតនៃប្រជាជាតិមួយ[៩៩]។ ដីជាធាតុដ៏សំខាន់ និង ចាំបាច់ជាទីបំផុតសម្រាប់ទ្រទ្រង់ជីវិតរបស់មនុស្សគ្រប់រូប។ ដីធ្លីមិនត្រឹមតែមានតម្លៃសំខាន់ក្នុងការប្រើប្រាស់ប៉ុណ្ណោះទេ វាថែមទាំងមានតម្លៃផ្នែកសេដ្ឋកិច្ចទៀតផង។ ផ្នែកសេដ្ឋកិច្ចដីធ្លី មានតម្លៃជាពិសេសទាក់ទងទៅលើ

---

[៩០] Kate Dalrymple: ***Expending Rural Land Tenures to Alleviate Poverty***, PhD thesis, University of Melbourne, 2005, page 45: in (World Bank page 87, 1989).

[៩៩] RFA: see also <http://www.rfa.org/khmer/program/economic/feature-KH0816-ECO07-0819200>, accessed dated 8/21/2009.

ទឹកប្រាក់ ពោលគឺគេអាចយកមកធ្វើជាកម្មវត្ថុនៃការលក់-ទិញក្នុងតម្លៃកំណត់ណាមួយ។ ចំណែកតម្លៃចំពោះការប្រើប្រាស់វិញ គេប្រើប្រាស់ដីធ្លីសម្រាប់ការសាងសង់លំនៅឋាន ធ្វើស្រែចំការ ធ្វើការដាំដុះដំណាំរួមផ្សំ និងធ្វើការបង្កបង្កើនផលជាដើម។

ផែនដី និងសង្គមមនុស្សគឺ មានការផ្លាស់ប្តូរ វិវឌ្ឍន៍ និងប្រែប្រួលឥតឈប់ឈរចាប់តាំងពីរាប់លានឆ្នាំកន្លងមកហើយ។ ផ្ទៃផែនដី គឺកើតចេញពីមណ្ឌលបរិយាកាស មណ្ឌលសិលា មណ្ឌលទឹក និងមណ្ឌលជីវៈ[១២]។ ផែនដីបានរងនូវបាតុភូតធម្មជាតិ និងទទួលរងនូវផលវិបាកយ៉ាងធ្ងន់ធ្ងរពីសំណាក់មនុស្ស មានជាអាទ៍ ការជីកយករ៉ែ ពេជ្យ មាស ត្បូង ថ្មមាប ឧស្ម័ន ប្រេងកាត មាស ការហូរច្រោះរញ្ជួយដី និងបន្ទុះភ្នំភ្លើង ការកាប់ឆ្ការ រុករាន និងការចាប់យកដីធ្លីធ្វើកសិកម្ម ឬធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ។ល។ ដីធ្លីជាធនធានរបស់ប្រទេសដ៏មានសារសំខាន់ដែលមិនអាចខ្វះបាន និង ជាធាតុសំខាន់ដែលជាអត្ថិភាពរបស់រដ្ឋ។ គ្រប់ទង្វើ និង ការអភិវឌ្ឍរបស់មនុស្សអាចបានចម្រើនឡើង ដោយបានប្រព្រឹត្តទៅនៅលើដីធ្លី ហេតុដូច្នេះហើយ ទើបដីធ្លីគឺជាមូលដ្ឋានគ្រឹះសម្រាប់ជីវិតរបស់សង្គម និង សេដ្ឋកិច្ចជាតិ។

ប្រទេសកម្ពុជា ជាប្រទេសមួយដែលធនធានដី និង ធនធានធម្មជាតិ មាននៅក្នុងដៃរបស់រដ្ឋច្រើនជាងគេនៅអាស៊ីរហូតដល់ ៨០% នៃធនធានទាំងមូល[១៣]។ សិទ្ធិលើកម្មសិទ្ធិដីធ្លី និងការប្រើប្រាស់នៅលើធនធានដូចជាដីធ្លី គឺចេញមកពីការវិវឌ្ឍន៍នៃចំណាត់ការជាប្រវត្តិសាស្ត្ររបស់សង្គមមនុស្ស ហើយជួនកាលសិទ្ធិនេះត្រូវបានកំណត់យ៉ាងច្បាស់លាស់ ឬ មិនច្បាស់លាស់នាំឱ្យមានការទំនាស់គ្នាលើសិទ្ធិនេះកើតមានឡើង។ ការកំណត់សិទ្ធិលើដី ការប្រើប្រាស់ បែងចែក និងការទទួលខុសត្រូវលើធនធានដីធ្លី ជាការចាំបាច់សម្រាប់ការអភិវឌ្ឍរបស់ប្រទេសជាតិ។

ទោះបីជាកំណើនមនុស្សច្រើនឡើងយ៉ាងខ្លាំងក្នុងពិភពលោក ចាប់តាំងពីពាក់កណ្តាលសតវត្សទី១៩ រហូតមកដល់សព្វថ្ងៃ ជាពិសេស អត្រាកំណើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នានាដូចជា ប្រទេសចិន ឥណ្ឌា និងប្រទេសនៅទ្វីបអាហ្វ្រិក និងអាស៊ីអគ្នេយ៍ ដូចជាឥណ្ឌូណេស៊ី និងកម្ពុជាជាដើម ក៏ដីមិនមានការកើនឡើងដែរ។ កំណើនប្រជាពលរដ្ឋយ៉ាងឆាប់រហ័សនេះបានជះឥទ្ធិពលយ៉ាងខ្លាំងនាំឱ្យមានបញ្ហាដីធ្លី។ តាមការសិក្សាបញ្ហាប្រឈមចំពោះដីធ្លី គឺបណ្តាលមកពីកត្តាជាច្រើនដូចជា កត្តានយោបាយ កត្តាសេដ្ឋកិច្ច កត្តាកំណើនមនុស្ស កត្តាបែងចែកដីធ្លីជាដើម។ កំណើនសេដ្ឋកិច្ច និង កំណើនមនុស្សបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការគ្រប់គ្រង បែងចែក និង ប្រើប្រាស់ដីធ្លីតាមប្រទេសនីមួយៗក្នុងពិភពលោក។

### ១.១.១ សម័យបុរាណ (មុន១៨៨៤)

តាមប្រវត្តិសាស្ត្រប្រទេសកម្ពុជា សិទ្ធិលើកម្មសិទ្ធិដីធ្លីមានលក្ខណៈផ្សេងៗគ្នាទៅតាមការផ្លាស់ប្តូរនៃរបបនីមួយៗ។ តាមឯកសារស្តីពីប្រវត្តិសាស្ត្រកម្ពុជាដីធ្លីទាំងអស់ស្ថិតនៅក្រោមការគ្រប់គ្រង

---

[១២] អ៊ូ រ៉ៃ: *ទស្សនវិជ្ជាភូមិវិជ្ជា* ឯកសារថ្នាក់បណ្ឌិត ទីស្តីការគណៈរដ្ឋមន្ត្រី-រាជបណ្ឌិត្យសភា ភ្នំពេញ ឆ្នាំ ២០០៨ ទំព័រ២។
[១៣] ហ៊ុន សែន: *សន្ទរកថាវេទិកាដីធ្លីថ្នាក់ជាតិ* នៅវិមានរាជរដ្ឋាភិបាល ភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ទំព័រ២។

និងជាកម្មសិទ្ធិរបស់ព្រះមហាក្សត្រ[១៤]។ ប៉ុន្តែតាមការអនុវត្តជាក់ស្តែង ដីធ្លីទាំងនេះជារបស់ប្រជាពលរដ្ឋ ដែលកាន់កាប់ដាំដំណាំលើដីធ្លីនោះ ពោលគឺកសិករទៅវិញទេដែលជាម្ចាស់លើដីនោះ។ ក្នុងអំឡុងពេលនោះ សង្គមខ្មែរត្រូវបែងចែកជាវណ្ណៈផ្សេងៗគ្នា។ ក្រៅពីញាតិវង្សានុវង្ស គឺមានវណ្ណៈក្នុងសង្គមផ្សេងៗទៀត រួមមានក្សត្រា (អ្នកចំបាំង) សមាជិកនៃក្រុមសាសនាផ្សេងៗ (ព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនា សាសនាតៅ) អ្នកដែលមានសេរីភាព និងទាសាទាសី។ ការបែងចែកវណ្ណៈក្នុងសង្គមបានធ្វើឱ្យប្រជាជនមានសិទ្ធិខុសគ្នាអាស្រ័យទៅតាមវណ្ណៈរបស់ពួកគេ។ ដូច្នេះ នៅពេលនិយាយសំដៅសិទ្ធិរបស់បុគ្គលក្នុងការកាន់កាប់ដីធ្លី យើងមិនអាចសន្និដ្ឋានបានថា បុគ្គលគ្រប់រូបមានសិទ្ធិដូចគ្នានោះទេ។ សិទ្ធិកាន់កាប់ដីធ្លី អាចមានចំពោះតែសមាជិកនៃវណ្ណៈមួយចំនួនក្នុងសង្គមខ្មែរតែប៉ុណ្ណោះ[១៥]។

ម៉្យាងវិញទៀតនៅក្នុងប្រទេសកម្ពុជាមុនការកាន់កាប់របស់បារាំងកម្មសិទ្ធិគឺជាសិទ្ធិ"ចល័ត"[១៦]។ ម្ចាស់ដីដែលកំពុងធ្វើកសិកម្មអាចចាកចោលពីតំបន់មួយទៅចាប់ធ្វើកសិកម្មលើតំបន់មួយទៀត និងធ្វើម្ចាស់ដីនោះតាមឆន្ទៈ និង មិនចាំបាច់មានទម្រង់ការណាមួយឡើយ។ ប្រព័ន្ធជាប្រពៃណីនោះបានបន្តមត៌ករបស់ជាតិ តាមលក្ខខណ្ឌនៃធនធានធម្មជាតិពីការធ្វើអាជីវកម្មដោយអ្នកដែលមកពីខាងក្រៅ ការណ៍នេះបានលើកស្ទួយផងដែរ ដល់ការប្រើប្រាស់ដីធ្លីនៅក្នុងសង្គមកសិកម្មក្សត់ខ្សោយដ៏លើសលុបមួយពោលគឺ ភាពដែលអាចផ្លាស់ប្តូរតាមកាលៈទេសៈ និង គ្មានទម្រង់ការនៃកម្មសិទ្ធិបានអនុញ្ញាតឱ្យមនុស្សជាច្រើន ធ្វើការលើដីធ្លីតាមឱកាសហុចឱ្យពេលណាក៏បាន។

### **១.១.២ សម័យអាណានិគមនិយមបារាំង** (**១៨៨៤-១៩៥៣**)

ឆ្លើយតបទៅសេចក្តីស្នើសុំរបស់ព្រះមហាក្សត្រកម្ពុជា បារាំងបានដាក់អាណានិគមរបស់ខ្លួនមកលើប្រទេសកម្ពុជាក្នុងឆ្នាំ១៨៦៣។ បារាំងបាននាំមកនូវទស្សនៈនៃរបបកម្មសិទ្ធិឯកជន[១៧]។ ដើម្បីឱ្យកិច្ចការពាណិជ្ជកម្ម និង ការវិនិយោគដំណើរការទៅបាននោះ ពួកគេត្រូវការធានាថា ដីធ្លីដែលពួកគេកាន់កាប់នោះគឺមានកិច្ចការពារជាផ្លូវការដោយរដ្ឋ។ ដូច្នេះគំនិតស្តីពីកម្មសិទ្ធិដីធ្លីបានមកជាមួយបារាំងដែលគំនិតនេះ ត្រូវបានគេស្គាល់នៅក្នុងបណ្តាប្រទេសភាគច្រើននៅសម័យឥឡូវនេះ។

ក្នុងឆ្នាំ ១៨៨៤ ជាលើកដំបូងបារាំងបានប្រកាសឱ្យប្រើនូវច្បាប់ដីធ្លីមួយនៅកម្ពុជា[១៨]។ ប៉ុន្តែការផ្លាស់ប្តូរទាំងនេះ បានជួបប្រទះនូវការតស៊ូប្រឆាំងតបយ៉ាងធ្ងន់ធ្ងរ ក្នុងចំណោមប្រជាជនកម្ពុជាជាពិសេស ក្នុងចំណោមវីរជន។ ដោយសារតែមានចលនាតស៊ូរបស់កសិករកម្ពុជា ទើបបានជាការ

---

[១៤] ស៊ិក បូរ័ក្ស និងសុខ ហាច: *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០ ការផ្តោតលើ បញ្ហាដីធ្លី កម្លាំងពលកម្ម និង ការចិញ្ចឹមជីវិតនៅជនបទ* វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា ភ្នំពេញ ឆ្នាំ ២០០២ នៅក្នុងសៀវភៅតាមទ្រឹស្តីព្រះមហាក្សត្រមានសិទ្ធិផ្តាច់ការនៅលើដីធ្លី (Meijers, 1994:3) ទំព័រ២៥។

[១៥] East-West Management Institute: *គោលការណ៍ណែនាំច្បាប់ភូមិបាលជាមូលដ្ឋានសម្រាប់សិស្ស និងអ្នកអនុវត្តច្បាប់* ភ្នំពេញ ឆ្នាំ ២០០៣ ទំព័រ២១។

[១៦] Jeffrey s. Brand: ***Cambodia Property law*** , Khmer Version 4 k, Faculty of Public Management in Cooperation with The University of San Francisco Project to Strengthen the Faculty of Business, Phnom Penh, (1998), p 8.

[១៧] Maneth Hun: ***Is Market-Assist Land Reform an Appropriate Choice for Cambodia at the Present Time*** New York University, New York City, 2001, New York, page 9.

[១៨] ស៊ិក បូរ័ក្ស និងសុខ ហាច: *ប្រទេសកម្ពុជាឆ្នាំ១៩៩៩ -២០០០ ការផ្តោតលើ បញ្ហាដីធ្លី កម្លាំងពលកម្ម និង ការចិញ្ចឹមជីវិតនៅជនបទ* .ដ.ឯ.ម. ទំព័រ២៦។

កែទម្រង់ដីធ្លី មិនត្រូវបានគេអនុវត្តយ៉ាងពេញលេញមុនឆ្នាំ១៩១២។ ក្នុងចំណោមរឿងដទៃៗទៀតនោះ បារាំងចង់បានការផលិត និង កាន់កាប់ត្រួតត្រាដ៏រឹងមាំថែមទៀត មកលើប្រជាពលរដ្ឋកម្ពុជា។ ជាងនេះទៅទៀតនោះ តំបន់ទំនេរគ្មានការកាន់កាប់ទាំងអស់ បានប្រែក្លាយទៅជាអាចលក់ដូរបាន។ ដោយថាហេតុ រឿងនេះបាននាំទៅរកការបង្កើតឱ្យមានឡើងនូវចំការដំណាំខ្នាតធំខ្លះ។

ហេតុនេះ ទើបគោលការណ៍ច្បាស់លាស់នៃកម្មសិទ្ធិដីធ្លី ក៏ត្រូវបានគេបង្កើតឡើងតាមរយៈក្រមរដ្ឋប្បវេណីឆ្នាំ១៩២០[១៩]។ ក្រមនេះ បានចែងឱ្យមាននូវការបញ្ជាក់ដោយលិខិត និង ការកត់ត្រានៃក្បាលដីជាក់លាក់។ ក្រោមប្រព័ន្ធនេះ ប័ណ្ណកម្មសិទ្ធិត្រូវបានគេចុះបញ្ជីជាប្រយោជន៍របស់កសិករម្នាក់ៗជាភស្តុតាងនៃកម្មសិទ្ធិ។ មកដល់ឆ្នាំ១៩៣០ ដីភាគច្រើនបានចែកជាដុំៗមានទំហំមិនលើសពីប្រាំ ហិកតា ហើយចំការដំណាំធំៗត្រូវបានបង្កើតឡើង[២០]។ ការបង្ហាញអ្នកណាម្នាក់ជាម្ចាស់ដី គឺមានសំអាងគ្រប់គ្រាន់ ដូចជាការដៅព្រំប្រទល់ដី និង ធ្វើសកម្មភាពលើដីឡូត៍ជាក់ស្តែងនាអំឡុងពេលគ្រប់គ្រង និង ចាត់ទុកជាភស្តុតាងកម្មសិទ្ធិគ្រប់គ្រាន់។

អំឡុងពេលនៃអាណានិគម ប្រទេសកម្ពុជាបានអនុម័តយកជាធរមាននូវប្រព័ន្ធនៃការស្ទង់មើលភូមិសាស្ត្រ និងការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីធ្លី។ ទោះជាមានប្រព័ន្ធចុះបញ្ជីឈ្មោះជាផ្លូវការក៏ដោយក៏គោលការណ៍ចាស់របស់កម្ពុជាស្តីពី "វត្ថុដែលបានមកដោយនង្គ័ល"[២១] នៅតែជាប្រព័ន្ធរបៀបកាន់កាប់ដីធ្លី ដែលអាចយកជាការបាននៅក្នុងតំបន់ជនបទដែលគ្មានការស្ទង់មើល និង ដែលមានប្រជាពលរដ្ឋតិចតួចរស់នៅ។ តាមពិតក្រមរដ្ឋប្បវេណី បានចែងយ៉ាងជាក់លាក់ពីលទ្ធកម្មនៃកម្មសិទ្ធិដីធ្លីចំពោះដីដែលមិនបានចុះបញ្ជី ភោគីណាដែលកាន់កាប់ដោយ សន្តិភាព សុចរិត មានការដឹង ឮ ជាសាធារណៈ ឥតព្រលាំ ហើយដីនោះជាដីទំនេរគ្មានបញ្ជីការ និង បានកាន់កាប់ជាប់ៗគ្នាសម្រាប់រយៈពេលប្រាំ ឆ្នាំ[២២] ភោគីនោះនឹងក្លាយជាកម្មសិទ្ធិករនៃដីនោះដោយធម្មានុរូប។

គំនិតស្របច្បាប់ថ្មីៗនៃកម្មសិទ្ធិដីធ្លី បានអនុញ្ញាតឱ្យមានច្រើនឡើងៗនូវទ្រព្យសម្បត្តិដែលប្រាស់មកវិញនោះ បាននាំទៅរកការបែងចែកយ៉ាងធំសម្បើមនៃដីកសិដ្ឋាន ឱ្យទៅជាក្បាលដីតូចៗសម្រាប់អ្នកក្រ។ ប៉ុន្តែ គោលនយោបាយស្តីពីរបៀបកាន់កាប់ដីធ្លីនេះ បានហុចលទ្ធផលទៅរកការធ្វើឱ្យចុះខ្សោយនូវរបៀបរៀបចំកសិកម្មកម្ពុជាសម័យបុរាណ និង ក្នុងករណីដែលដីឡូត៍ជាច្រើនមិនអាចនឹងទ្រទ្រង់ការរស់នៅសម្រាប់ម្ចាស់ដីតទៅទៀតបាន ហើយប្រព័ន្ធនេះបានបង្កើតនៅមនុស្សប្រភេទថ្មីមួយគឺ អ្នកក្រីក្រជនបទគ្មានដីធ្លី[២៣]។

---

[១៩] Serge Thoin: ***Watching Cambodia: Ten Paths to Enter the Cambodia Tangle*** White Lotus, Bangkok, Thailand, (1993), Page 29.

[២០] ស៊ិក បូរ័ក្ស និងសុខ ហាច: *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០ ការផ្តោតលើ បញ្ហាដីធ្លី កម្លាំងពលកម្ម និង ការចិញ្ចឹមជីវិតនៅជនបទ* វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា ភ្នំពេញ ឆ្នាំ២០០២ នៅក្នុង សៀវភៅ **(Greve, 1993)** ទំព័រ២៦។

[២១] គឺរបៀបនៃការកាន់កាប់ដីបែបភោគៈ- Jeffrey s. Brand: ***Cambodia Property law*** -.op.cit. p 9.

[២២] *ក្រមរដ្ឋប្បវេណី:* ឆ្នាំ១៩៦៧ មាត្រា ៧២៣។

[២៣] Jeffrey s. Brand: ***Cambodia Property law***-.op.cit. p 10.

### ១.១.៣ សម័យឯករាជ្យ( ១៩៥៣-១៩៧០ )

គំនិតកម្មសិទ្ធិរបស់បរទេស គឺនៅតែមាននៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីប្រទេសនេះបានទទួលឯករាជ្យពីបារាំង ឆ្នាំ ១៩៥៣[២៤] ហើយនៅចុង ឆ្នាំ១៩៦០ បញ្ហាជាច្រើននៅជនបទនៃប្រទេសកម្ពុជា មានកាន់តែធ្ងន់ធ្ងរឡើងៗ តាមរយៈចំនួនកំណើននៃកសិករដែលជាប់បំណុលគេ និងជាយថាហេតុនោះគឺការគ្មានដីធ្លី[២៥]។ ទោះជាយ៉ាងណា ក៏វាមិនដូចពីមុនឡើយ ព្រោះកសិករក្រីក្រត្រូវខ្ចីប្រាក់ទិញស្រូវក្នុងតម្លៃថ្លៃ សម្រាប់សាបព្រួសលើដីស្រែរបស់ពួកគេ។ អ្នកក្រមិនមានច្រកទៅរកប្រព័ន្ធឱ្យខ្ចីប្រាក់ជាផ្លូវការឡើយ ដូចជា ធនាគារជាដើម។ ដូច្នេះពួកគេត្រូវខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជនដែលយកថ្លៃអត្រាការប្រាក់ប្រចាំខែយ៉ាងខ្ពស់រហូតដល់៣០% ហើយជួនកាលដល់ទៅ ១០០-២០០% ក្នុងមួយរដូវ[២៦]។ សម្រាប់កសិករដែលក្រីក្រជាងគេបំផុត បញ្ហាខាងហិរញ្ញវត្ថុ គឺកាន់តែធ្ងន់ធ្ងរឡើងៗ ពីព្រោះពួកគេត្រូវលក់ស្រូវទាំងអស់ទៅឱ្យអ្នកដែលគេឱ្យខ្ចីប្រាក់ដើម្បីសងបំណុលរបស់ខ្លួន។ តាមរបៀបនេះគ្មានស្រូវនៅសល់ដើម្បីចិញ្ចឹមគ្រួសារឡើយ ដោយហេតុនេះ បានបង្ខំឱ្យពួកគេខ្ចីប្រាក់បន្ថែម និង ទិញស្រូវត្រឡប់មកវិញ។ ប្រាក់កំចីត្រូវសងបន្ទាប់ពីផលដំណាំលើកក្រោយ។ កសិករមួយចំនួននៅទីបំផុត ត្រូវលក់ដីដើម្បីសងបំណុលគេ ហើយក៏ក្លាយជាអ្នកគ្មានដី[២៧]។ បច្ចាមិត្តរបស់អ្នកស្រែកម្ពុជា គឺអាចនិយាយបានថា ជាឈ្មួញទីក្រុងជាជាងម្ចាស់ដី។

នៅពាក់កណ្តាលឆ្នាំ១៩៦០ សម្តេចនរោត្តម សីហនុ បានចាប់ផ្តើមអនុវត្តព្រះរាជតម្រិះរបស់ព្រះអង្គស្តីពី "សង្គមនិយមតាមបែបព្រះពុទ្ធសាសនា" ក្នុងន័យដើម្បីឆ្លើយតបទៅនឹងសត្រូវខាងសេដ្ឋកិច្ចទាំងនេះ។ ព្រះអង្គមានជំនឿផងដែរថា ប្រជារាស្ត្រខ្មែរចូលចិត្តរស់នៅជាសមូហភាពដោយផ្អែកលើប្រព័ន្ធមួយនៃការជួយគ្នាទៅវិញទៅមក។ កាលដែលព្រះរាជតម្រិះជាលាយល័ក្ខណ៍អក្សរក្លាយទៅជាគោលនយោបាយជាក់ស្តែង ហើយសម្តេច ព្រះនរោត្តម សីហនុ បានបង្កើតចេញនូវ "រាជសហករណ៍"[២៨] ដើម្បីជួយដល់កសិករ និង បានធ្វើជាគួបនីយកម្មលើផ្នែកអាហារណ៍ និងនីហារណ៍នៅកម្ពុជា។ ប៉ុន្តែ ព្រះអង្គមិនបានអនុម័តយកសង្គមនិយមទាំងស្រុងឡើយ ហើយព្រះអង្គបញ្ឈប់ភ្លាមៗនូវសមូហនិយម និង កម្មសិទ្ធិរដ្ឋ។ ជាជំនួសមកវិញ ព្រះអង្គបានយកគោលការណ៍ព្រះពុទ្ធសាសនា ស្តីពី សង្គមស្មើភាពគ្នាមួយមកប្រើ ដោយការធ្វើឱ្យឆ្ពោះទៅមុខនូវសុខុមាលភាពរបស់ប្រជារាស្ត្រក្រីក្រ និងការអប់រំរបស់ជាតិ ។

---

[២៤] ស៊ិក បូកែ្ស និងសុខ ហាច: *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០ ការផ្តោតលើ បញ្ហាដីធ្លី កម្លាំងពលកម្ម និង ការចិញ្ចឹមជីវិតនៅជនបទ* -ជ.ឯ.ម- ទំព័រ ២៦។

[២៥] Jeffrey s. Brand: ***Cambodia Property law***-.op.cit. p 10 .

[២៦] ស៊ិក បូកែ្ស និងសុខ ហាច: *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០ ការផ្តោតលើ បញ្ហាដីធ្លី កម្លាំងពលកម្ម និង ការចិញ្ចឹមជីវិតនៅជនបទ* -ជ.ឯ.ម- ទំព័រ ២៦។

[២៧] ស៊ិក បូកែ្ស និងសុខ ហាច: *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០ ការផ្តោតលើ បញ្ហាដីធ្លី កម្លាំងពលកម្ម និង ការចិញ្ចឹមជីវិតនៅជនបទ* -ជ.ឯ.ម- ទំព័រ ២៦។

[២៨] វាមានលក្ខណ:ស្រដៀងនឹងសមាគមកសិករបច្ចុប្បន្ន Jeffrey s. Brand: ***Cambodia Property law***-.op.cit. p. 10.

អាស្រ័យតាមព្រះរាជតម្រិះរបស់ព្រះអង្គ សង្គមនិយមតាមបែបព្រះពុទ្ធសាសនាដែលផ្ទុយទៅនឹងលទ្ធិម៉ាក់និយម បានប្រានចោលនូវគំនិតរឹបអូសទ្រព្យសម្បត្តិដោយបង្ខំ និង ឱ្យប្រជារាស្ត្រគ្រប់រូបជាម្ចាស់ផលនៃការងាររបស់ខ្លួន។ អ្នកមានទ្រព្យសម្បត្តិគ្រាន់តែមានការបញ្ចុះបញ្ចូលឱ្យបោះបង់ចោលនូវភាពប្រសើរជាងខាងហិរញ្ញវត្ថុរបស់ខ្លួន នៅពេលនោះ ពួកគេបានទទួលនូវគុណសម្បត្តិក្នុងការផ្តល់ទាន។ មុនរដ្ឋប្រហារបណ្តេញព្រះអង្គក្នុងឆ្នាំ១៩៧០ ព្រះអង្គបានសារភាពថា សង្គមនិយមតាមព្រះពុទ្ធសាសនាមិនដំណើរការ។ ការយកចិត្តទុកដាក់លើភាពអហិង្សា អព្យាក្រឹតភាព និងមេត្តាករុណាបានបង្ហាញនូវដំណោះស្រាយមិនគ្រប់គ្រាន់ឡើយដើម្បីទប់ជម្ងឺរបស់ប្រជាជាតិ។

### **១.១.៤ សម័យសាធារណរដ្ឋខ្មែរ**(**១៩៧០-១៩៧៥**)

សាធារណរដ្ឋខ្មែរត្រូវបានប្រកាសឡើង បន្ទាប់ពីសម្តេច នរោត្តម សីហនុ ត្រូវបានគេទម្លាក់ពីតំណែងដោយរដ្ឋប្រហារយោធា នៅថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៧០[២៩]។ កម្មសិទ្ធិទ្រព្យសម្បត្តិឯកជនត្រូវបានបន្តទទួលស្គាល់ដោយរបបសាធារណរដ្ឋខ្មែរ[៣០]។ កំឡុងពេលនៃប្រវត្តិសាស្ត្រកម្ពុជាពេលនោះបានក្លាយជាល្បីល្បាញថា ជាការទទួលការញ៉ាំញីយ៉ាងខ្លាំង ដោយអំពើពុករលួយដែលបានជ្រាបចូលគ្រប់ស្រទាប់អាជ្ញាធររដ្ឋ និង រដ្ឋបាល។ ជាការកត់សំគាល់គឺថា អត្រាការប្រាក់ប្រចាំខែដែលទាមទារដោយអ្នកឱ្យខ្ចីប្រាក់ឯកជននៅកន្លែងជាច្រើនលើសពី៣០%[៣១] ។

នៅពេលនោះកម្ពុជា ស្ថិតនៅក្រោមគោលនយោបាយនាយទុន បានជួបប្រទះនូវវិបត្តិខ្វះស្បៀងអាហារ ដោយសារតែតម្រូវការផ្គត់ផ្គង់អាហារច្រើន នៅពេលដែលផលិតផលស្រូវថយចុះ។ តាមទិន្នន័យ ជាចំនួនតួលេខដោយលោក Porter and Hildebrand ការកាត់បន្ថយតំបន់ផលិតកម្មជាសរុបចំនួន ២.៤ លានហិកតា ក្នុងឆ្នាំ១៩៦៩ ទៅប្រហែលជាចំនួន ៥០០.០០០ ហិកតានៅក្នុងឆ្នាំ១៩៧៤។ ប្រជាពលរដ្ឋចំនួន ២លាននាក់ បោះបង់ចោលភូមិ និង ដីស្រែរបស់ពួកគេស្វែករកការជ្រកកោណនៅទីក្រុង។ ប្រជាពលរដ្ឋនៅភ្នំពេញកើនពី៥០០.០០០ នាក់ នៅឆ្នាំ១៩៧០ ដល់ ២លាននាក់នៅឆ្នាំ១៩៧៤-៧៥។ គេជឿថា ចំនួនប្រជាពលរដ្ឋមានចំនួនជិត ៣លាន នាក់ ពីព្រោះជនភៀសខ្លួនទាំងនោះមិនបានចុះបញ្ជី ហើយកាលនោះសហរដ្ឋអាមេរិកជាអ្នកផ្គត់ផ្គង់ស្បៀងដ៏សំខាន់ គិតជាប្រាក់ប្រហែលជិត ១.៩ ពាន់លានដុល្លារអាមេរិក[៣២]។

### **១.១.៥ សម័យកម្ពុជាប្រជាធិបតេយ្យ**(**១៩៧៥-១៩៧៩**)

ខ្មែរកុម្មុយនីស្តដែលគេស្គាល់ថា ជាខ្មែរក្រហម បានដណ្តើមអំណាចពី លន់ នល់ និង បានប្រកាសយក ឆ្នាំ១៩៧៥ ជាឆ្នាំសូន្យ[៣៣]។ អង្គការ គឺជាម្ចាស់ទឹកម្ចាស់ដី។ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជាមានរដ្ឋធម្មនុញ្ញដែលប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី០៥ ខែមករា ឆ្នាំ

---

[២៩] Ros Chantrabot**: *La Republique Khmere***, L'Harmattan, ប្រែសម្រួលដោយៈ ទីឃាយុ ទំព័រ៥។

[៣០] ***រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ*** ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧២ មាត្រា ១៤។

[៣១] Jeffrey s. Brand: ***Cambodia Property law***-.op.cit. p 11.

[៣២] Solieng Mak: ***Rain fed Lowland Rice Farming in Cambodia: A Study of Agriculture Change, op.cit***. p38. ( in Porter and Hildebrand 1976:2).

[៣៣] ស៊ិក បូរ័ក្ស និងសុខ ហាចៈ *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០ ការផ្តោតលើ បញ្ហាដីធ្លី កម្លាំងពលកម្ម និង ការចិញ្ចឹមជីវិតនៅជនបទ* -ដ.ឯ.ម-ទំព័រ២៦។

១៩៧៦។ ប៉ុន្តែ រដ្ឋធម្មនុញ្ញនាពេលនោះ បានលុបបំបាត់ចោលនូវរាល់របបកម្មសិទ្ធិឯកជន ដែលបាន បន្សល់ទុកដោយបារាំង នៅក្នុងពាក់កណ្តាលសតវត្សទី១៩។ ជាងនេះទៅទៀតនោះគឺថា រដ្ឋបុរស កម្ពុជាប្រជាធិបតេយ្យថ្មីបានអួតថា របបថ្មីនេះ ចាត់ជាចុងបញ្ចប់មួយសម្រាប់ "ប្រវត្តិសាស្ត្រ២០០០ ឆ្នាំ"[៣៤] ។ រដ្ឋធម្មនុញ្ញបានដាក់ជាសមូហភាពនូវ "មធ្យោបាយផលិតកម្មសំខាន់ៗទាំងអស់"[៣៥] រដ្ឋធម្មនុញ្ញ មាត្រា២ បានចែងថា "កម្ពុជាប្រជាធិបតេយ្យអនុវត្តគោលការណ៍សមូហភាព ក្នុងភាព ជាអ្នកនាំមុខ និង ក្នុងការងារ"។ ការពន្យល់អំពីរដ្ឋធម្មនុញ្ញពីសប្តាហ៍មុនការប្រកាសឱ្យប្រើ ខៀវ សំផន បានចុះបញ្ជីនូវវត្ថុដែលត្រូវដាក់ជាសមូហភាព ដូចជា "ដីស្រែ ចំការឈើផ្លែ ដីកសិដ្ឋាន រោងចក្រ រទេះភ្លើង រថយន្ត កប៉ាល់ និង កាណូត" ដោយបន្សល់ទុកត្រឹមតែសំលៀកបំពាក់ ប្រដាប់ប្រើប្រាស់ ផ្ទាល់ខ្លួន (ប៉ុន្តែមិនមែនគ្រឿងអលង្ការទេ) និងឧបករណ៍ក្នុងដៃផ្ទាល់ខ្លួន ដូចនេះកម្មសិទ្ធិទ្រព្យសម្បត្តិ និងសិទ្ធិកាន់កាប់ដីធ្លីត្រូវបានគេដកចេញ។ សិទ្ធិសំខាន់របស់ប្រជាពលរដ្ឋដែលគេឱ្យតាមអត្ថបទនោះ គឺ "សិទ្ធិធ្វើការងារ" ។

## ១.១.៦ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា(១៩៨០-១៩៨៩)

អាជ្ញាធរថ្មីដែលបានផ្តួលរំលំរបបខ្មែរក្រហម និង ឡើងកាន់អំណាចនៅក្នុងឆ្នាំ១៩៧៩ បាន ប្រកាសប្រទេសកម្ពុជាជា " សាធារណរដ្ឋប្រជាមានិតកម្ពុជា "។ របបនេះបានបន្តនូវមាគ៌ានៃកម្មសិទ្ធិ ទ្រព្យសម្បត្តិសមូហភាព[៣៦] ចំណែកឯដី និង ផ្ទះសំបែងគឺមានជាប់ពាក់ព័ន្ធ ស្រដៀងគ្នានឹងរបបខ្មែរ ក្រហមដែរ គេបានបែងចែកប្រជាពលរដ្ឋទៅជាកម្លាំងការងារសមូហភាពនោះគឺ ក្រុមសាមគ្គី[៣៧]។

ក្រុមសាមគ្គីមានគ្នាពី១០ ទៅ ១៥គ្រួសារ ហើយតាមទ្រឹស្តី ក្រុមសាមគ្គីត្រូវបានគេធ្វើសមូហ ភាវូបនីយកម្មយ៉ាងពេញលេញជាកងការងារកសិកម្ម ធ្វើការលើកសិដ្ឋានរួមគ្នាលើដីធ្លីដែលគេបានលៃ ទុកដោយឡែកសម្រាប់ពួកគេ។ ក្រុមសាមគ្គី ត្រូវបានគេចាត់តាំងឱ្យធ្វើការងារដទៃៗទៀត ដូចជាការ នេសាទ និង ឧស្សាហកម្មខ្នាតតូចជាដើម។ ប៉ុន្តែប្រព័ន្ធនេះ បានធ្លាក់ជាច់ចេញពីគ្នាយ៉ាងឆាប់រហ័ស ហើយ ក៏បានបំបែកចេញជាកសិដ្ឋានពឹងផ្អែកលើគ្រួសារជាមួយនឹងក្រុមសាមគ្គីដែលស្ម័គ្រចិត្ត។

ទោះបីនៅពេលនោះដីទាំងអស់ គឺជារបស់រដ្ឋក៏ដោយក៏ម្តងម្កាលគេសង្កេតឃើញដីលំនៅឋាន ខ្លះៗត្រូវបានប្រជាជនផ្ទេរចុះឡើងជាលក្ខណៈក្រៅផ្លូវការតាមការព្រមព្រៀងគ្នាទៅវិញទៅមក[៣៨]។ នៅ ចុងឆ្នាំ១៩៨៨ មន្ត្រីស្រុកជាច្រើនបានបង្ហាញពីការលំបាកខ្លាំងក្នុងការថែទាំផលិតកម្មជាសមូហភាព។ អាជ្ញាធរសាធារណរដ្ឋប្រជាមានិតកម្ពុជានៅពេលនោះ បានចាប់ផ្តើមសារជាថ្មីឡើងវិញនូវកម្មសិទ្ធិ

---

[៣៤] ស៊ិក បូកែ្ស និងសុខ ហាចៈ *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០ ការផ្តោតលើ បញ្ហាដីធ្លី កម្លាំងពលកម្ម និង ការចិញ្ចឹមជីវិតនៅជនបទ* -ដ.ឯ.ម-ទំព័រ១១។

[៣៥] *រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ* ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦ មាត្រា២។

[៣៦] ស៊ិក បូកែ្ស និងសុខ ហាចៈ *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០ ការផ្តោតលើបញ្ហាដីធ្លី កម្លាំងពលកម្ម និង ការចិញ្ចឹមជីវិតនៅជនបទ* -ដ.ឯ.ម-ទំព័រ២៧។

[៣៧] Jeffrey s. Brand : ***Cambodia Property law***-.op.cit. p12.

[៣៨] ស៊ិក បូកែ្ស និងសុខ ហាចៈ *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០ ការផ្តោតលើបញ្ហាដីធ្លី កម្លាំងពលកម្ម និង ការចិញ្ចឹមជីវិតនៅជនបទ* -ដ.ឯ.ម-ទំព័រ ២៧។

ឯកជននៃដីធ្លីនៅឆ្នាំ១៩៨៩និងស្របពេលនោះដែរ គេក៏ជំរុញឱ្យក្រុមសាមគ្គីរក្សាទុកសម្រាប់ខ្លួនឯងនូវមធ្យោបាយផលិតកម្មដែលបានកាន់កាប់ជាសមូហភាព។

តាមអនុក្រឹត្យ លេខ ៣១ អនក្រ ឆ្នាំ១៩៨៩ បានបង្កើតស្ថាប័នដីធ្លីដំបូង ដោយផ្ទេរនាយកដ្ឋានគ្រប់គ្រង គោលនយោបាយសេដ្ឋកិច្ច កសិកម្មនៃក្រសួងរុក្ខាប្រមាញ់ និងនេសាទ ឱ្យទៅជានាយកដ្ឋានសុរិយោដីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សិទ្ធិសមូហភាពលើលំនៅឋានត្រូវបានកែប្រែយ៉ាងច្រើន ដោយបានផ្តល់ប័ណ្ណកម្មសិទ្ធិលើផ្ទះសំបែងដល់បុគ្គលម្នាក់ៗ[៣៩] ហើយប័ណ្ណនេះអាចធ្វើការផ្ទេរតាមរយៈមតកសាសន៍ ឬការលក់។

## ១.១.៧ សម័យរដ្ឋកម្ពុជា (១៩៨៩-១៩៩២)

ក្រោយជំនួបរវាង សម្តេច ហ៊ុន សែន និង សម្តេច សីហនុ នៅខែធ្នូ ឆ្នាំ១៩៨៧ និង ខែមករា ឆ្នាំ១៩៨៨ "ការប្រជុំក្រៅផ្លូវការនៅទីក្រុងហ្សាការតា" ប្រទេសឥណ្ឌូណេស៊ី នាំឱ្យមានការរួបរួមរវាងភាគីទំនាស់ទាំងអស់នៅកម្ពុជា ដែលអំពាវនាវឱ្យមានការផ្សះផ្សាជាតិ។ នាកិច្ចប្រជុំវិសាមញ្ញនៅថ្ងៃទី២៩-៣០ ខែមេសា ឆ្នាំ១៩៨៩ រដ្ឋសភាបានធ្វើវិសោធនកម្មមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញ ដោយប្តូរឈ្មោះប្រទេសកម្ពុជាទៅជា "រដ្ឋកម្ពុជា"[៤០]។ ក្រោយពីមានកិច្ចព្រមព្រៀងស្តីពី ដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជាហៅកាត់ថា "អ៊ុនតាក់" ត្រូវបានបង្កើតឡើងដើម្បីរៀបចំការបោះឆ្នោតដោយសេរី និង យុត្តិធម៌។ រដ្ឋសភាបានអនុម័តច្បាប់ភូមិបាលថ្មីឆ្នាំ១៩៩២។ របបកម្មសិទ្ធិឯកជនត្រូវផ្តល់ឱ្យតែទៅលើដីលំនៅឋានតែមួយគត់ ហើយដីដែលស្ថិតនៅតំបន់ទីក្រុងត្រូវបានបញ្ញត្តិតាមច្បាប់ដោយឡែក។ តាមច្បាប់នេះ របបកម្មសិទ្ធិអាចផ្ទេរបានតាមរយៈសន្តតិកម្ម មតកសាសន៍ កិច្ចសន្យានៃការលក់ ដោយប្រទានកម្ម និងដោយភោគៈ[៤១]។ ភោគៈត្រូវបានទទួលស្គាល់អនុលោមតាមផ្នែកទី២ (មាត្រា៦១-៧៦) នៃច្បាប់ភូមិបាលឆ្នាំ១៩៩២ និង អនុញ្ញាតឱ្យមានកម្មសិទ្ធិតាមរយៈភោគៈ។ ដើម្បីក្លាយទៅជាកម្មសិទ្ធិករនៃដី ភោគីត្រូវតែបង្ហាញថា ខ្លួនបានកាន់កាប់ដោយ សន្តិវិធី ដោយសុចរិតដោយមានការដឹងឮជាសាធារណៈ ដោយមិនមានការអាក់ខាន និង ដោយគ្មានការបន្លំអស់រយៈពេលប្រាំឆ្នាំយ៉ាងតិច[៤២]។

## ១.១.៨ ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន (ក្រោយ ១៩៩៣)

នៅក្នុងឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញថ្មីមួយត្រូវប្រកាសថា កម្ពុជាក្លាយទៅជា "ព្រះរាជាណាចក្រកម្ពុជា" និង បង្កើតឱ្យមានរដ្ឋាភិបាលថ្មីមួយ។ មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញ បានបញ្ជាក់អះអាងសាជាថ្មីស្តីពីសិទ្ធិក្នុងការធ្វើម្ចាស់លើដីធ្លី ប៉ុន្តែ ការកំណត់សិទ្ធិនេះ គឺចំពោះជនជាតិខ្មែរតែប៉ុណ្ណោះ។ ដំណើរការសើរើច្បាប់ភូមិបាល ឆ្នាំ១៩៩២ និង ការតាក់តែងច្បាប់ថ្មីត្រូវបានធ្វើឡើងជាបន្តបន្ទាប់។

---

[៣៩] អនុក្រឹត្យៈ លេខ២៥អនក្រ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩ ***ស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា*** មាត្រា១ និង មាត្រា២។

[៤០] ក្រុមប្រឹក្សារដ្ឋ លេខ២២៩ក្រ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ ***ស្តីពីរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា*** ៖មាត្រា ១។

[៤១] ក្រឹត្យច្បាប់ លេខ១០០ ក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ ***ស្តីពីច្បាប់ភូមិបាល*** ៖មាត្រា ២៣។

[៤២] ក្រឹត្យច្បាប់ លេខ១០០ ក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ ***ស្តីពីច្បាប់ភូមិបាល*** ៖មាត្រា ៦២។

សេចក្តីព្រាងច្បាប់ថ្មីមួយដើម្បីជំនួសច្បាប់ភូមិបាល ឆ្នាំ ១៩៩២ ត្រូវបានរៀបរៀងឡើងដោយផ្អែកភាគច្រើន លើច្បាប់ភូមិបាលឆ្នាំ១៩៩២ និងបានដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងខែតុលា ឆ្នាំ ១៩៩៨[៤៣]។ មានការជំទាស់យ៉ាងច្រើនគួរឱ្យកត់សំគាល់ទៅលើសេចក្តីព្រាងច្បាប់នេះ ទើបជំរុញឱ្យមានសេចក្តីព្រាងច្បាប់ថ្មីមួយទៀត។ ថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ ច្បាប់ភូមិបាលថ្មីត្រូវបានប្រកាសឱ្យប្រើជាការប្រញាប់ដោយព្រះមហាក្សត្រសម្តេចព្រះនរោត្តម សីហនុ[៤៤]។ ច្បាប់នេះមិនទទួលស្គាល់កម្មសិទ្ធិមុនឆ្នាំ ១៩៧៩។ មាត្រា២៧ នៃច្បាប់នេះចែងថា "គ្មានជនណាម្នាក់អាចទាមទារសិទ្ធិលើកម្មសិទ្ធិចាស់មុនឆ្នាំ១៩៧៩ លើដីធ្លីបានទេ"[៤៥]។ ខាងក្រោមជាតារាងសង្ខេបអំពីប្រវត្តិនៃការគ្រប់គ្រង និង ការកាន់កាប់ដីធ្លីនៅកម្ពុជា៖

តារាងទី១ ប្រវត្តិនៃការគ្រប់គ្រងដីធ្លីនៅកម្ពុជា៖

| របបសក្តិភូមិ | របបអាណានិគមនិយម / រាជានិយម សាធារណរដ្ឋ | របបប៉ុលពត | របបសង្គមនិយម | ប្រព័ន្ធទីផ្សារ / ប្រជាធិបតេយ្យតំណាង | |
|---|---|---|---|---|---|
| ផលុបភោគ | សម្បត្តិឯកជនបារាំង | សម្បត្តិរួមខ្មែរក្រហម | សម្បត្តិសមូហភាព | ច្បាប់ដីធ្លី ១៩៩២ | ច្បាប់ដីធ្លី ២០០១ |
| ភោគៈតាមរយៈការប្រើប្រាស់ | | គ្មានភោគៈឯកជន | ភោគៈតាមការប្រើប្រាស់ | ភោគៈមុនពេលទទួលបានកម្មសិទ្ធិ | |
| មិនតម្រូវឱ្យមានការចុះបញ្ជីផ្លូវការ | ចាប់ផ្តើមចុះបញ្ជីផ្លូវការ | ឯកសារដីធ្លីត្រូវបំផ្លាញ | | ការចុះបញ្ជីផ្លូវការតម្រូវឱ្យមានភោគៈ/កម្មសិទ្ធិ | |
| ពន្ធលើផលដំណាំ | ពន្ធលើដីធ្លី | | | ពន្ធលើដីធ្លីអនុវត្តដោយកន្លែង | |

## ១.២ និដ្ឋភាពទូទៅនៃវិវាទដីធ្លី

## ១.២.១ វិស័យដីធ្លីនៅកម្ពុជា

វិស័យកសិកម្ម គឺស្ថិតនៅលេខរៀងទីមួយ ក្នុងចំណោមគោលនយោបាយអាទិភាពទាំង ១០[៤៦]។ បន្ទាប់ពីបានឯករាជ្យពីបារាំងមក កម្ពុជាបានផ្តោតអារម្មណ៍យ៉ាងខ្លាំងលើការបង្កើនផលិត

[៤៣] East-West Management Institute-EWMI: *គោលការណ៍ណែនាំច្បាប់ភូមិបាលជាមូលដ្ឋានសម្រាប់សិស្ស និងអ្នកអនុវត្តច្បាប់* ភ្នំពេញ ឆ្នាំ២០០៣ ទំព័រ២៧។

[៤៤] ព្រះរាជក្រម លេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ***ស្តីពីច្បាប់ភូមិបាល*** ៖មាត្រា ២៦៨។

[៤៥] ព្រះរាជក្រម លេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ***ស្តីពីច្បាប់ភូមិបាល*** ៖មាត្រា ២៧។

[៤៦] (ទី១) កសិកម្ម (ទី២)ទឹក និងប្រព័ន្ធស្រោចស្រព (ទី៣)ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ទី៤)អគ្គិសនី (ទី៥) ការអភិវឌ្ឍធនធានមនុស្ស (ទី៦)ឧស្សាហកម្មអតិពលកម្ម និង ឧស្សាហកម្មផលិតទំនិញនាំចេញ (ទី៧) ទេសចរណ៍ (ទី៨)អាជីវកម្មប្រេងកាត ឧស្ម័នធម្មជាតិ និងធនធានរ៉ែឯទៀត (ទី៩)ព័ត៌មានវិទ្យា និង ទូរគមនាគមន៍ និង

ផលស្រូវ។ មន្ត្រីសុរិយោដីបានប៉ាន់ស្មានថា ក្នុងឆ្នាំ ១៩៦២ ដីជិត ៣ លានហិកតា គឺជាដីស្ថិតនៅទម្រង់នៃការបង្កើនផល ហើយ ២,២ លានហិកតា ជាដីសម្រាប់ធ្វើស្រែ។ នៅឆ្នាំ១៩៦៧ ដីធ្វើស្រែកើនឡើងដល់ ២,៥លានហិកតា។ ដោយសារសង្គ្រាមរាំរ៉ៃធ្វើឱ្យកម្លាំងពលកម្មសម្រាប់បង្កបង្កើនផលថយចុះ។ នៅឆ្នាំ១៩៧៤ ដីធ្វើស្រែថយចុះរហូតដល់ ៥០០,០០០ ហិកតា ហើយផលិតផលក៏បានតិចតួចដែរ។ នៅឆ្នាំ១៩៩៤ ដី ១,៨ លានហិកតា ត្រូវបានប្រើប្រាស់ដើម្បីធ្វើស្រែ។ នៅឆ្នាំ ១៩៩៧ ដីស្រែកើនឡើងរហូតដល់ ១,៨ លានហិកតា។ តាមឯកសាររបស់អង្គការសេដាក ឆ្នាំ ២០០៦ ទំហំដីធ្វើស្រែកើនឡើងដល់ ២,៤ លានហិកតា និងឆ្នាំ២០១០ កើនដល់ ២.៦១ លានហិកតា។ ទោះបីជាមានការកើនឡើងក៏ដោយ នៅតែមិនអាចប្រៀបធៀបនឹងទំហំដីស្រែក្នុងទសវត្សរ៍ទី៦០នៅឡើយ[៤៧]។

នៅប្រទេសកម្ពុជា ផលិតភាពដែលបានមកពីដីធ្លី មានកម្រិតទាបជាងគេបំផុតបើប្រៀបធៀបជាមួយប្រទេសនានាក្នុងតំបន់[៤៨]។ ទិន្នផលដំណាំតែងតែទាបដូច្នេះតាំងពីដើមមក ឧទាហរណ៍ នៅឆ្នាំ១៩៥០ និង ១៩៦០ តៃវ៉ាន់ កូរ៉េខាងត្បូង ហ្វីលីពីន និងឥណ្ឌូណេស៊ីមានទិន្នផលស្រូវលើសពី ៣-៣,៥ តោនក្នុង១ ហិកតា រីឯកម្ពុជាមិនដែលបានលើសពី ២ តោនក្នុង ១ហិកតាទេ[៤៩]។ ពីឆ្នាំ ១៩៨០-១៩៩៤ ទិន្នផលស្រូវកម្ពុជាដែលជាមធ្យមគឺ ០,៩ ដល់ ១,៤ តោនក្នុងមួយហិកតា និងពីឆ្នាំ១៩៩៥-១៩៩៩ ទិន្នផលកើនពី ១,៦-២ តោនក្នុងមួយហិកតា។ តែរហូតមកដល់ឆ្នាំ២០០៨[៥០] ទិន្នផលជាមធ្យម ២,៦ តោន ក្នុងមួយហិកតា និង ២.៧ តោនក្នុងមួយហិកតា ឆ្នាំ២០១០ ។ ប៉ុន្តែទោះជាយ៉ាងណា តួលេខនេះនៅតែទាបជាងទិន្នផលនៅប្រទេស វៀតណាម ឥណ្ឌូណេស៊ី និង ហ្វីលីពីនដែលបានលើសពី ៣ តោនក្នុងមួយហិកតា[៥១]។

---

(ទី១០)ពាណិជ្ជកម្ម របស់រាជរដ្ឋាភិបាលដើម្បីបន្តជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម តាមរយៈការលើកទឹកចិត្តវិស័យឯកជនឱ្យចូលរួម ក្នុងការអភិវឌ្ឍកសិកម្ម កសិ-ឧស្សាហកម្ម កសិ-ពាណិជ្ជកម្ម និងឧស្សាហកម្មកែច្នៃម្ហូបអាហារ ជំរុញនឹងលើកទឹកចិត្តឱ្យដាំដុះដំណាំដោយប្រើប្រាស់ដីធម្មជាតិ។

[៤៧] Oxfam GB: Workshop ***Reports, Revised Land Law***, Approaches to Reducing Landlessness, Institutional Cooperation about Resolving Land Dispute in Cambodia, Volume 3, Phnom Penh, 1999, page 5.

[៤៨] Brett Ballard and So Sovannarith: ***Cambodia Land Titling Program: Baseline Survey Project***, Final Report Phase I, Cambodia Development Resource Institute in collaboration with the Ministry of Land Management, Urban Planning, and Construction (MLMUPC), Phnom Penh, Cambodia, 2004: In Sophal Chan, Kim Seadara, and Sarthi Acharya (CDRI, 2003), page 5.

[៤៩] ច័ន្ទ សុផល និង Sarthi Acharya *បញ្ហាប្រឈមចំពោះ ការចិញ្ចឹមជីវិតនៅជនបទៈ* ករណីសិក្សាលើភូមិចំនួន៩ នៅកម្ពុជា ឯកសារពិភាក្សា លេខ ២៥ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ ភ្នំពេញ ឆ្នាំ ២០០៣ ទំព័រ៣៧។

[៥០] រាជរដ្ឋាភិបាលកម្ពុជាៈ *របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០០៨ ស្តីពី ការអនុវត្តផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ* ២០០៦-២០១០ ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ៤៥។

[៥១] ច័ន្ទ សុផល និង Sarthi Acharya *បញ្ហាប្រឈមចំពោះ ការចិញ្ចឹមជីវិតនៅជនបទៈ* -ដ.ឯ.ម- ទំព័រ១១។

ផ្ទៃដីប្រមាណជា ១៦,៤៨% នៃផ្ទៃដីរបស់ប្រទេសកម្ពុជាគឺជាផ្ទៃដីកសិកម្ម ហើយស្រូវដែលជាអាហារសំខាន់សម្រាប់ប្រជាពលរដ្ឋកម្ពុជា និងជាមុខព្រួញនៃសេដ្ឋកិច្ច បានដណ្ដើមយកផ្ទៃដីអស់ ១៣,៧៦% នៃផ្ទៃដីប្រទេស ហើយក៏ជាទំនិញនាំចេញសំខាន់មួយដែរ។ ប្រជាពលរដ្ឋពាក់កណ្ដាលក្នុងចំណោមប្រជាពលរដ្ឋ ១១ លាននាក់ ចាប់យករបរកសិកម្ម។ នយោបាយរបស់រាជរដ្ឋាភិបាលគឺបានផ្ដោតជាអាទិភាពសំខាន់នៅលើវិស័យកសិកម្ម ដែលមានសក្ដានុពលកម្រិត៤០% នៃផលិតផលសរុបក្នុងស្រុក (GDP) ហើយផ្នែកនេះមានកម្លាំងផលិតទៅដល់ ៨៥% នៃប្រជាជនទូទាំងប្រទេស។ ប៉ុន្តែ កសិករដែលជាម្ចាស់ផលិតផលបានជួបវិបត្តិ ដោយគ្មានទីផ្សារ ហើយសម្ដែងនូវក្ដីកង្វល់ និងទទូចសុំឱ្យរាជរដ្ឋាភិបាល ជាពិសេស ក្រសួងកសិកម្ម និង ស្ថាប័នពាក់ព័ន្ធចូលរួមដោះស្រាយបញ្ហារបស់ពួកគេដែលកំពុងជួបប្រទះ[៥២]។

## ១.២.២ ទិសមនាពនៃការកាន់កាប់ដីធ្លី

នៅប្រទេសកម្ពុជាមិនទាន់មានស្ថិតិអំពីការកាន់កាប់ និង ប្រើប្រាស់ដីធ្លីឱ្យបានជាក់លាក់នៅឡើយ ហើយការសិក្សាតាមឯកសារពីប្រភពនានា ឃើញថា ទិន្នន័យមួយចំនួនមានលក្ខណៈខុសប្លែកគ្នា។ ខាងក្រោមគឺជាលទ្ធផលការសិក្សាដោយអង្គការអុកស្វាមអង់គ្លេសនៅកម្ពុជា៖

តារាងទី២ ចំណែកផ្ទៃដីធ្លីប្រើប្រាស់នៅកម្ពុជាឆ្នាំ ១៩៩៨៖

| ផ្ទៃដីធ្លីប្រើប្រាស់ | ចំនួនជាហិកតា |
|---|---|
| ផ្ទៃដីព្រៃសម្បទាន[៥៣] | ៨.០០០.០០០ |
| ផ្ទៃដីតំបន់ការពារ[៥៤] | ៣.៣០០.០០០ |
| ផ្ទៃដីដាំដំណាំ[៥៥] | ២.៧០០.០០០ |
| ផ្ទៃដីតំបន់ឡូតិ៍នេសាទ[៥៦] | ១.០០០.០០០ |
| ផ្ទៃដីទីប្រជុំជន ហេដ្ឋារចនាសម្ព័ន្ធ[៥៧] | ១.០០០.០០០ |
| ផ្ទៃដីតំបន់មានមីន[៥៨] | ២០០.០០០ |
| ផ្ទៃដីសរុប | ១៨.០០០.០០០ |
| ផ្ទៃដីសរុបដែលប្រើប្រាស់ | ១៦.៣៦០.០០០ |
| តំបន់ដីមិនប្រើប្រាស់ ដីទំនេរ ដីនៅសល់ | ១.៦៤០.០០០ |

[៥២] ***ទស្សនាវដ្តីប្រជាជនៈ*** ជំរុញផលិតផលស្រូវស្រូវអង្ករដើម្បីនាំចេញ លេខ៧ ភ្នំពេញ ខែធ្នូ ឆ្នាំ២០០១ ទំព័រ១៧។

[៥៣] Ministry of Environment: ***Cambodia National Environmental Action Plan***, Phnom Penh, 1998, page 5.

[៥៤] ibit. page5.

[៥៥] Ahmed, Mahfuzuddin et all: ***Social-Economic Assessment of Freshwater Capture Fisheries of Cambodia-Report on Household Survey***, Mekong River Commission, Phnom Penh, 1998, Page4.

[៥៦] Swift Peter: ***Developing a Research Framework for the Fishing Lot System in Cambodia***, MRC, DANIDA, Department of Fishery, Phnom Penh, 1997, page 1.

[៥៧] Lim Voan: ***Land Issues and Village Administration Law***, Central Land Department, Phnom Penh, 1998, Page10.

[៥៨] CMAC: ***Registered Mine Location***, Database, Phnom Penh, 1998, page1.

តាមការសិក្សារបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាបង្ហាញថា ប្រទេសកម្ពុជាមានការកាន់កាប់ដីទាំងអស់ប្រមាណ ១៨.១០លានហិកតា (រួមទាំងបឹង និងទន្លេ) ដែលមានចែកទៅតាមផ្នែកដូចមាននៅតារាងខាងក្រោម៖

តារាងទី៣ ការប៉ាន់ប្រមាណការកាន់កាប់-ប្រើប្រាស់ដីនៅកម្ពុជា៖

| ផ្ទៃដី | ចំនួន (លានហិកតា) | %នៃចំណែក |
|---|---|---|
| ផ្ទៃដីដាំដំណាំ | ២.៧១ | ១៤.៩៧ |
| ផ្ទៃដីទីប្រជុំជន ហេដ្ឋារចនាសម្ព័ន្ធ | ១.០០ | ៥.៥២ |
| ផ្ទៃដីតំបន់មានមីន | ០.១០ | ០.៥៥ |
| ផ្ទៃដីគ្មានដើមឈើ កូនឈើតូចៗ | ១.៧៣ | ៩.៥៦ |
| ផ្ទៃដីព្រៃមិនស្ថិតក្រោមសម្បទាន | ៣.២៥ | ១៧.៩៦ |
| ផ្ទៃដីព្រៃសម្បទាន | ៤.២១ | ២៣.២៦ |
| ផ្ទៃដីតំបន់ការពារ | ៣.២៧ | ១៨.០៧ |
| ផ្ទៃដីសម្បទានកសិកម្ម | ០.៨៣ | ៤.៥៩ |
| ផ្ទៃដីតំបន់ឡូត៍នេសាទ | ១.០០ | ៥.៥២ |
| ផ្ទៃដីសរុប | ១៨.១០ | ១០០.០០ |

Sources: World Bank: Project Appraisal Document on a Propossed Credit to the Kingdom of Cambodia for a Land Management and Adnimistration Project, Report No: 22869-KH.

វិសមភាពដីធ្លីនៅក្នុងសង្គមកសិករត្រូវបានគេលើកយកមកពិចារណាដោយសារប្រជាពលរដ្ឋកើនឡើងតែដីមិនកើនឡើងទេ។ វាមានលក្ខណៈកាន់តែជាក់ស្តែងថែមទៀតព្រោះប្រជាពលរដ្ឋពឹងពាក់លើវិស័យកសិកម្មដើម្បីចិញ្ចឹមជីវិត។ ស្ទើរគ្រប់ការអង្កេតធំៗទាំងអស់ គឺប្រមូលបានទិន្នន័យអំពីវិសមភាពដីធ្លី។ ចំណុចគួរឱ្យកត់សំគាល់ ក្នុងចំណោមប្រជាពលរដ្ឋទាំងនោះ ពួកគេមានដីលើស១ហិកតា។ ការអង្កេតរបស់គណៈកម្មាធិការទន្លេមេគង្គ MRC-95-96 បង្ហាញថា ២១% នៃគ្រួសារថ្នាក់លើ (អ្នកមាន) កាន់កាប់ដី ៦៥% ការអង្កេតសេដ្ឋកិច្ចសង្គមរបស់វិទ្យាស្ថានជាតិស្ថិតិ SES-97 (ជនបទ) បង្ហាញថា ២៣% នៃគ្រួសារទាំងនេះ កាន់កាប់ដី ៧០% ការអង្កេតសេដ្ឋកិច្ចសង្គម SES-99 (ជនបទ) បង្ហាញថា ៤៤% នៃគ្រួសារធូរធារ កាន់កាប់ដី ៨៨% ការអង្កេតសេដ្ឋកិច្ចសង្គម SES-99 (សរុបទូទាំងប្រទេស) បង្ហាញថា ៥២% នៃគ្រួសារ ធូរធារកាន់កាប់ដី ៨២% ការអង្កេតសេដ្ឋកិច្ចសង្គមជាមូលដ្ឋានរបស់អង្គការស្បៀងអាហារពិភពលោក និង អង្គការយូនីសេហ្វ Baseline-98 បង្ហាញថា គ្រួសារធូរធារ ២៣% កាន់កាប់ដី ៥៦% ការអង្កេតដោយធ្វើបច្ចុប្បភាព-២០០០ បង្ហាញថា គ្រួសារធូរធារ ២៨% កាន់កាប់ដី ៦២% ការអង្កេតមុខសញ្ញាសង្គ្រោះ រយៈពេលយូរឆ្នាំ PTE-98 បង្ហាញថា គ្រួសារធូរធារ ៣៦% កាន់កាប់ដី ៦៩%[៥៩]។

[៥៩] ច័ន្ទ សុផល ទេព សារី និង Sarthi Acharya: ***ការកាន់កាប់ដីនៅកម្ពុជា*** ការវិភាគលើទិន្នន័យចុងក្រោយ ឯកសារពិភាក្សាលេខ១៩ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ភ្នំពេញ ឆ្នាំ២០០១ ទំព័រ៥៧។

កសិករកាន់កាប់ដីដែលមានទំហំតូចជាង ១០ ហិកតា ប្រកបមុខរបរបង្កបង្កើនផលជាចម្បងផ្នែកស្រែចំការ។ ចំណែកដីដែលធំជាង១០ ហិកតា កាន់កាប់ដោយអ្នកមាន មន្ត្រីរដ្ឋាភិបាល និងមន្ត្រីជាន់ខ្ពស់ ដែលបានទិញដីនោះពីភូមិ ឃុំ ឬ ចាប់យកដីរដ្ឋធ្វើជាដីរបស់ខ្លួន។ មានទំនោរថាអ្នកកាន់កាប់ដីតូចមានលក្ខណៈល្អ និងផលិតភាពខ្ពស់។ ប្រជាពលរដ្ឋប្រហែល ៨០% កាន់កាប់ដីតិចជាង ៣ ហិកតា និង ២៩% នៃគ្រួសារទាំងអស់នៅក្នុង ១៤៣ ភូមិ គឺជាគ្រួសារក្រីក្រ[៦០]។

តារាងទី៤៖ ទំហំដី និងភាគរយនៃចំនួនគ្រួសារកាន់កាប់ដី

| ទំហំដីកាន់កាប់គិតជាហិកតា | ចំនួនគ្រួសារ | %នៃគ្រួសារ |
|---|---|---|
| ០-០,៥ | ១៨,៥៣៤ | ២៩,១៧ |
| ០,៥-១ | ១៤,២៣៦ | ២២,៤០ |
| ១- ៣ | ១៩,០៦៨ | ២៨,៤៣ |
| ៣-៥ | ៩,២២៨ | ១៤,៥២ |
| ៥-១០ | ២,៥៦៤ | ៤,០៣ |
| ១០-៣០ | ៦១៤ | ០,៩៧ |
| ៣០-៥០ | ១៨១ | ០,២៨ |
| ៥០-១០០ | ៧៧ | ០,១២ |
| ១០០-៥០០ | ៤៥ | ០,០៧ |

Source: Oxfam GB Re-analysis of Survey Data from the Oxfam Land Holding Survey 2006, Assessment, Selective Analysis and Interpretation of Survey data, Phnom Penh, 2008, page 44-45.

### ១.២.៣ ការផ្ទេរសិទ្ធិលើដីធ្លី

ចាប់តាំងពីរដ្ឋាភិបាលកម្ពុជា ធ្វើឯកជនូបនីយកម្មមក ចលនាដោះដូរ និងលក់ ទិញដីធ្លីចាប់ដំណើរការធ្វើឱ្យដីមានតម្លៃខុសធម្មតាពីមួយកន្លែងទៅមួយកន្លែង។ ថ្លែងក្នុងពិធីសន្និសីទមួយសម្តេចនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា៖

"នៅឆ្នាំ១៩៧៩-១៩៨០ តម្លៃដីនៅភ្នំពេញស្មើសូន្យ ព្រោះអី ឱ្យទទេក៏អត់យកដែរ ស្មើនឹងសូន្យមានអ្នកយក? តែឥឡូវនេះឡើងដូចមាស គេថានៅតំបន់នេះប្រមាណ ៧០០-៨០០ ដុល្លារអាមេរិក តែឥឡូវនេះ ១០០០ ដុល្លារអាមេរិកក្នុងមួយម៉ែត្រការ៉េ"[៦១]។

តម្លៃដីកើនឡើងយ៉ាងខ្លាំង ក្នុងមួយរយៈពេលកន្លងមកនេះ ដោយសារបាយប្រជាជនកើនឡើង ហើយហេដ្ឋារចនាសម្ព័ន្ធត្រូវបានកែលំអ។ គេចាំថាដីមានតម្លៃថោកនៅក្នុងទស្សវត្សរ៍ទី៨០ ពីព្រោះគ្រប់គ្នាមានដីចំនួនដូចគ្នា ប៉ុន្តែក្លាយជាថ្លៃឡើងៗដោយសារកំណើនប្រជាជន។ ស្រដៀងគ្នានេះដែរដីដែលស្ថិតនៅតំបន់ពាណិជ្ជកម្មលើផ្លូវសំខាន់ៗ ដូចជានៅទីក្រុងភ្នំពេញតម្លៃដីគឺពិតជាខ្ពស់ពី

---

[៦០] Oxfam GB: ***Re-analysis of Survey Data from the Oxfam Land Holding Survey 2006***, Assessment, Selective Analysis and Interpretation of Survey data, Phnom Penh, 2008, page 44-45

[៦១] ហ៊ុន សែន: ***សន្ទរកថាក្នុងពិធីបើកសន្និសីទជាតិស្តីពីមីក្រូហិរញ្ញវត្ថុកម្ពុជា*** ភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ ទំព័រ២៧។

២៧០-៤០០ ដុល្លាអាមេរិកក្នុងមួយម៉ែត្រការ៉េ ហើយនៅទីរួមខេត្តខ្លះអាចលក់បានក្នុងតម្លៃ ២០០-៤០០ ដុល្លាអាមេរិកក្នុងមួយម៉ែត្រការ៉េ។ ហើយដីនៅជាយខេត្ត ឬ ដីលំនៅឋានអាចលក់បានថោកជាងពី២០-៤០ ដងអាស្រ័យតាមតំបន់ជាប់ផ្លូវថ្នល់ ផ្លូវជាតិ ដីដែលមានប្រព័ន្ធប្រឡាយទឹកគ្រប់គ្រាន់ និងដីអាចធ្វើអាជីវកម្មបាន[៦២]។

តម្លៃដីនៅតែបន្តកើនឡើងរហូតមកដល់ ឆ្នាំ១៩៩៩ និង ចាប់ផ្តើមឡើងថ្លៃខ្លាំងនៅឆ្នាំ ២០០០ និង ឡើងខ្ពស់បំផុតនៅចុងឆ្នាំ២០០៧ មុននឹងធ្លាក់មកវិញនៅដើមឆ្នាំ២០០៨[៦៣]។ នាពេលបច្ចុប្បន្ននេះ តម្លៃដីបានធ្លាក់ចុះពី១០-២០%។ មានន័យថា បើដីកន្លែងខ្លះតម្លៃ ១០០ ដុល្លាអាមេរិកក្នុងមួយម៉ែត្រការ៉េ ឥឡូវនៅសល់តែ ៩០-៨០ ដុល្លាអាមេរិកតែប៉ុណ្ណោះ។ តម្លៃនេះអាចនឹងធ្លាក់ចុះតទៅទៀត ប្រសិនបើ វិបត្តិមួយចំនួនមិនទាន់បានដោះស្រាយរួចរាល់នោះទេ។ កត្តាសំខាន់បី ដែលបណ្តាលឱ្យតម្លៃដីធ្លាក់ចុះនៅកម្ពុជា។ (ទីមួយ) វិបត្តិហិរញ្ញវត្ថុពិភពលោកដែលប្រៀបដូចជាចំហាយទើបតែសាយភាយមកដល់កម្ពុជា តែវិបត្តិនេះនៅតែជាផលប៉ះពាល់មួយនៃវិស័យនេះ (ទីពីរ) ជម្លោះព្រំដែនខ្មែរ-ថៃ ក៏បានធ្វើឱ្យប្រជាជន ក៏ដូចជាទីផ្សារដីធ្លី នៅតាមជាយដែនត្រូវបានរាំងស្ទះស្ទើរតែទាំងស្រុង និងបានធ្វើឱ្យអ្នកវិនិយោគព្រួយបារម្ភ ឬក៏ពន្យាពេលធ្វើវិនិយោគ។ និងចំណែក (ទីបី) ស្ថាប័នធនាគារក៏ដូចជាក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានចាត់វិធានការរាំងខ្ទប់សាច់ប្រាក់ឈប់ឱ្យក្រុមហ៊ុនអចលនទ្រព្យខ្ចីប្រាក់ និងការចេញប្រកាសមួយចំនួនដើម្បីគ្រប់គ្រង និង ត្រួតពិនិត្យអ្នកវិនិយោគវិស័យអចលនទ្រព្យ។

សព្វថ្ងៃ មិនទាន់មានកម្រងទិន្នន័យដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយល្អសម្រាប់ការស្រាវជ្រាវពីទំហំនៃការលក់ដូរដីធ្លីនៅកម្ពុជានៅឡើយ[៦៤]។ អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអ្នកកាន់កាប់កំណត់ត្រានៃការលក់ដូរដីធ្លីផ្លូវការគ្រប់ប្រភេទនៅក្នុងប្រទេសកម្ពុជា។ មានការលក់ដូរដីក្រៅផ្លូវការ ទោះជាដីនោះមានការចុះបញ្ជី ឬមិនទាន់ចុះបញ្ជីក៏ដោយ ដោយភាគច្រើនប្រតិបត្តិការនេះមានការឯកភាពពីមេឃុំ។ អាជ្ញាធរសុរិយោដីស្រុកបានទទួលឱ្យថ្នាក់ឃុំ រាយការណ៍អំពីការលក់ដូរដីធ្លីទាំងអស់ដល់ខ្លួន ទោះបីតាមគោលការណ៍គឺទាល់តែការលក់ដូរជាផ្លូវការនូវដីដែលមានប័ណ្ណកម្មសិទ្ធិទើបត្រូវរាយការណ៍ជាផ្លូវការក៏ដោយ។ នៅពេលខ្លះ ការលក់ដូរដីធ្លី ដែលមានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវហើយ ក៏មិនបានអនុវត្តដូចមានចែងក្នុងច្បាប់ដែរ ពីព្រោះអ្នកទិញមិនចង់បង់ពន្ធប្រថាប់ត្រា ព្រមទាំងចង់រំលងនីតិវិធីផ្សេងៗផង។

ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិដីធ្លីត្រូវកំណត់ដោយច្បាប់គឺស្មើនឹង ៤% នៃថ្លៃដីដែលលក់ ផ្អែកតាមមាត្រា២ នៃច្បាប់ស្តីពី ការបង្កើតពន្ធប្រថាប់ត្រា ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០១។ ការអនុវត្តជាក់ស្តែង មានការគេចពន្ធមួយចំនួនធំ គឺធ្វើឡើងតាមវិធីរាយការណ៍បន្ទាបថ្លៃដី។ ទំហំ

---

[៦២] ហ៊ុន សែនៈ ***សន្ទរកថាក្នុងពិធីបើកសន្និសីទជាតិស្តីពីមីក្រូហិរញ្ញវត្ថុកម្ពុជា*** .ដ.ឯ.ម. ទំព័រ១៨។

[៦៣] លី ម៉េងហួរៈ: ***វិបត្តិអចលនៈវត្ថុនៅកម្ពុជាអូសបន្លាយពេលទៅមុខទៀត*** វិទ្យុបារាំង RFI accessed dated 07 Mar 2009. <http://www.rfi.fr/actukm/articles /114/article_2041.asp>.

[៦៤] ច័ន្ទ សុផល និង Sarthi Acharya: ***ការលក់ដូរដីធ្លីនៅកម្ពុជា*** ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី ឯកសារពិភាក្សាលេខ ២២ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ភ្នំពេញ ឆ្នាំ២០០២ ទំព័រ i។

នៃការលក់ផ្ទេរដីប្រែប្រួលពីខេត្តមួយទៅខេត្តមួយ ហើយជាមធ្យមក្នុងឯកសារផ្លូវការ គេកត់ត្រាប្រហែលតែ៤០% នៃថ្លៃដីពិត ដូច្នេះប្រាក់ពន្ធត្រូវបាត់ប្រហែល ៦០%[៦៥]។ ការរាយការណ៍ថ្លៃដីធ្វើឡើងតាមការឃុបឃិតគ្នារវាងភាគី ដែលជាប់ពាក់ព័ន្ធផ្សេងៗ ហើយទង្វើនេះត្រូវបានសម្រួលតាមរយៈការបង់ប្រាក់កម្រៃក្រៅផ្លូវការ។ នៅពេលឯកភាពគ្នារួចហើយ មន្ត្រីសុរិយោដីធ្វើការគណនាបញ្រាសវិញដើម្បីរកថ្លៃដី ដែលត្រូវផ្តល់ប្រាក់ពន្ធចំនួន ៤% ឱ្យស្មើនឹងទឹកប្រាក់ជាក់ស្តែងដែលគេបានបង់ចូលរតនាគារខេត្ត។ មានការទទួលស្គាល់ជាទូទៅថា ប្រជាពលរដ្ឋជាច្រើនមិនចង់ធ្វើប័ណ្ណកម្មសិទ្ធិដីធ្លីទេ ដោយដីធ្លីដែលបានចុះបញ្ជីពិបាកលក់ ព្រោះត្រូវជាប់ពន្ធប្រថាប់ត្រា និង ម៉្យាងវិញទៀត ត្រូវចំណាយប្រាក់ច្រើនក្នុងការចុះបញ្ជី[៦៦]។

## ១.៣ វិវាទដីធ្លី

ពាក្យថា "វិវាទ" តាមវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ទំព័រទី ១១៩៩ មានន័យថា ជំណើរទាស់ទែងគ្នា ជំណើរឈ្លោះប្រកែកគ្នា។ ចំណែកពាក្យថា "ទំនាស់" វចនានុក្រមដដែលទំព័រទី៤៥៨ មានន័យថា អំពើទាស់ ដែលផ្ទុយគ្នា ដែលទីទៃពីគ្នា។ រីឯពាក្យ "ជម្លោះ" ត្រង់ទំព័រទី២៥១ មានន័យថា វិវាទ ដំណើរឈ្លោះ កើតជម្លោះ។ សរុបមកឃើញថា អត្ថន័យនៃពាក្យ វិវាទ ទំនាស់ និងជម្លោះ មានន័យ ស្រដៀងគ្នា។

ចំពោះការប្រើពាក្យ "វិវាទ" និង "ទំនាស់" របស់រដ្ឋាភិបាលមានន័យខុសគ្នា គឺថាវិវាទមានលក្ខណៈស្រាលជាងទំនាស់ នេះបើផ្អែកតាម មាត្រា ៣នៃអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី និង មាត្រា៣នៃព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដោយឱ្យអំណាចទៅអាជ្ញាធរជាតិដោះស្រាយទំនាស់ទាំងឡាយណា ដែលហួសសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ដែលគណៈកម្មការនេះដោះស្រាយវិវាទទាក់ទងនឹងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីសុរិយោដី។

ចំណែកលោក Barringer បានឱ្យនិយមន័យនៃពាក្យ "វិវាទ" នេះមានអត្ថន័យខុសគ្នាអំពីវចនានុក្រមភាសាខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត។ ន័យរបស់ពាក្យ "វិវាទ" "ទំនាស់" និង "ជម្លោះ" របស់ខ្មែរ គឺស្មើនឹងពាក្យ Dispute ជាអំពើទាស់ទែងនូវកម្រិត (ទីមួយ) ជាពាក្យសំដី។ ចំណែកវិវាទឈានដល់កម្រិតធ្ងន់ (ទីពីរ) គេប្រើពាក្យ Conflict ដែលយើងតែងបកប្រែមកខេមរភាសាថាជា "ទំនាស់ ឬ វិវាទ" ដដែលនោះ តែតាមពិត វាមានន័យធ្ងន់ជាង គឺជាការប្រឆាំងតបជាសកម្មភាពយ៉ាងខ្លាំងក្លា។ ចំណែកឯវិវាទកម្រិត (ទីបី) វិញគេប្រើពាក្យ Hostilities គឺ ជាសកម្មភាពប្រឆាំងដោយប្រើអំពើហិង្សា ឬសកម្មភាពឈានដល់សង្គ្រាម[៦៧]។ វិវាទដីធ្លីនៅកម្ពុជាបាននឹងកំពុងកើតឡើងឥតឈប់ឈររវាងប្រជាកសិករក្រីក្រជាមួយនឹងមន្ត្រីរាជការ ដែលនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ រាជរដ្ឋាភិបាលដែលដឹកនាំដោយ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន

---

[៦៥] ច័ន្ទ សុផល និង Sarthi Acharya: ***ការលក់ដូរដីធ្លីនៅកម្ពុជា***.ដ.ឯ.ម.ទំព័រ iii។

[៦៦] ការផ្ទេរសិទ្ធិនេះនៅតែជួបការលំបាក ពីព្រោះត្រូវចំណាយពេលវេលានិង ថវិកាច្រើន ទោះបី ដីនោះមានប័ណ្ណកម្មសិទ្ធិ ឬមិនទាន់មានប័ណ្ណក៏ដោយ។

[៦៧] Paul Munro-Faure: ***Land Reform: Land Settlement and Cooperatives***, FAO, 2002/2, page9: In Barringer 1972.

សែន បានដាក់បញ្ហាវិវាទដីធ្លី ចូលទៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាល ទី ២ របស់រាជរដ្ឋាភិបាល។ ដូចបានបញ្ជាក់នៅក្នុងសុន្ទរកថាខាងក្រោម៖

"ភាពអាណាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ និង បទបញ្ញត្តិការរំលោភយកដីរដ្ឋ ការកាន់កាប់រានទន្ទ្រានដីព្រៃក្នុងតំបន់ការពារធម្មជាតិទៅធ្វើជាកម្មសិទ្ធិឯកជន និង ការកាប់ឈើដោយខុសច្បាប់នៅតែមានជាអន្លើៗនៅឡើយ។ ទន្ទឹមនឹងនេះ ភាពក្រីក្រ និង បាតុភូតចំណាកស្រុកទៅរានដីថ្មីល្មើសនឹងច្បាប់បានធ្វើឱ្យធនធានធម្មជាតិរងសម្ពាធនៃការបំផ្លាញ[៦៨]" ។

ផ្អែកតាមទិន្នន័យរបស់អគ្គលេខាធិការនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ វិវាទដីធ្លីកើនឡើងជាលំដាប់ដូចដែលបានបង្ហាញនៅក្នុងតារាងរូបភាពដូចខាងក្រោម។

រូបភាពទី១ ករណីវិវាទដីធ្លីទទួលបានរបស់គណៈកម្មការសុរិយោដី ២០០៣-២០០៩៖




ប្រភព៖ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិនៃរបាយការណ៍ប្រចាំឆ្នាំផ្លូវការរបស់គណៈកម្មការសុរិយោដីចាប់ពីឆ្នាំ ២០០៣ រហូតដល់ឆ្នាំ ២០០៩ គិតមកត្រឹមត្រីមាសទី១ ។

វិវាទដីធ្លីបង្កឱ្យកើតមានឡើងនូវ អំពើហិង្សា បង្ករបួសស្នាម និង អាចឈានទៅដល់ការសម្លាប់មនុស្សទៀតផង។ ពេលខ្លះអំពើហិង្សានេះ បានប្រព្រឹត្តឡើងដោយកងកម្លាំងប្រដាប់អាវុធទៅលើប្រជាពលរដ្ឋក្រីក្រ ដែលជាជនរងគ្រោះនៅកន្លែងដែលមានជម្លោះស្រួចស្រាល់ខ្លះ។ ជាងនេះទៅទៀត ពេលខ្លះអ្នកប្រព្រឹត្តមិនត្រូវបានផ្តន្ទាទោសក្នុងការទទួលខុសត្រូវរបស់ខ្លួនលើការបង្កឱ្យមានរបួស ឬ ស្លាប់មនុស្សនោះទេ។ តែផ្ទុយទៅវិញ ប្រជាពលរដ្ឋរងគ្រោះមួយចំនួន ដែលជាប់ពាក់ព័ន្ធនឹងវិវាទដីធ្លីត្រូវបានចាប់ខ្លួនតាមរយៈដីការបស់តុលាការ និង ក្នុងករណីមួយចំនួន ពួកគេត្រូវបង្ខំឱ្យចាកចេញពីទីកន្លែងដីទំនាស់ ដើម្បីជាថ្នូរក្នុងការដោះលែងពួកគេពីការឃុំឃាំង[៦៩]។

[៦៨] ហ៊ុន សែនៈ *សន្ទរកថាស្តីពីយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី២* ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ សម្រាប់អាណត្តិទី៤ នៃរដ្ឋសភា នៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ ទំព័រ១៣។

[៦៩] សមាគមអាដហុកៈ *ស្ថានភាពសិទ្ធិមនុស្សឆ្នាំ ២០០៥* សមាគមអដាហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា លេខ៥ ឆ្នាំទី៥ ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រ៣។

ប្រជាពលរដ្ឋភាគច្រើនកាន់កាប់ដីតាមទម្លាប់ដោយមិនមានប័ណ្ណកម្មសិទ្ធិ ពីព្រោះពួកគាត់មិនមានលទ្ធភាពបង់ថ្លៃធ្វើប័ណ្ណ។ ក៏ប៉ុន្តែ តាមច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៣០ ក្នុងករណីដែលពួកគាត់រស់នៅលើដីនោះដោយសន្តិភាព លើសពីប្រាំឆ្នាំមុនច្បាប់នេះចូលជាធរមាន ពួកគាត់ទទួលបានសិទ្ធិកម្មសិទ្ធិលើដីស្របច្បាប់។ ការប្រើអំពើហិង្សាដើម្បីដកហូតអចលនវត្ថុដោយអាជ្ញាធរ អចលនវត្ថុនោះត្រូវប្រគល់មកវិញ ហើយមិនអាចជាកម្មវត្ថុនៃការកាន់កាប់ថ្មីទេ[៧០]។

ករណីវិវាទដីធ្លីនៅឃុំជីក្រែង ស្រុកជីក្រែង ខេត្តសៀមរាប ជម្លោះមានរយៈពេល៥ឆ្នាំ លើផ្ទៃដីទំហំ៤៧៥ ហិកតា បានកើតកាន់តែខ្លាំងកាលពីខែធ្នូ ឆ្នាំ ២០០៨។ ការដោះស្រាយបានធ្វើឡើងដោយមិនប្រព្រឹត្តទៅតាមច្បាប់ និង នីតិវិធីជាធរមានដែលជាហេតុបណ្តាលឱ្យកើតហិង្សា។ ជាក់ស្តែងនៅអំឡុងពេលប៉ះទង្គិចគ្នារវាងប្រជាពលរដ្ឋ និង យោធា កាលពីថ្ងៃទី២២ ខែមិនា ឆ្នាំ២០០៩ កសិករ៤នាក់ ត្រូវបានបាញ់ឱ្យរងរបួស និង ៤៣នាក់ទៀតត្រូវចាប់ខ្លួន។ អ្នកភូមិជីក្រែងនិយាយថា ពួកគាត់បានកាប់ឆ្ការ និង ធ្វើកសិកម្មលើដីធ្លីនេះចាប់តាំងពីឆ្នាំ១៩៨០[៧១] ហើយដីធ្លីទាំងនេះត្រូវដកហូតពីពួកគេវិញ ក្រោយពេលប្រព័ន្ធស្រោចស្រពត្រូវបានកែលំអ។ ពួកគេត្រូវបានរំខានយាយី និង បំភិតបំភ័យកាន់តែខ្លាំងឡើងៗពីសំណាក់នគរបាល និង យោធា។

តាមការស្រាវជ្រាវ និង យល់ដឹងជាសកល បញ្ហាអំពើហិង្សានៃវិវាទដីនេះ កើតមានក្រោយរដ្ឋាភិបាលអនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជនលើដីធ្លី តាមរយៈនេះមន្ត្រីខិលខូចជាស៊ីវិលនិង យោធាមួយចំនួនបានឆ្លៀតឱកាសពីភាពចន្លោះប្រហោងនៃការគ្រប់គ្រងរបស់រដ្ឋាភិបាលរឹបអូសយកដីធ្លីកសិករ។ ការណ៍នេះបណ្តាលឱ្យចំនួនប្រជាពលរដ្ឋបាត់បង់អ្វីៗទាំងអស់។ ម្យ៉ាងទៀត ប្រព័ន្ធយុត្តិធម៌មិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយ[៧២]។ ការប្រឆាំងតបរបស់ប្រជាពលរដ្ឋជាច្រើនករណីវាអាចជារឿងដែលបង្កប់នូវអំពើអយុត្តិធម៌ បើមិនមានការដោះស្រាយឱ្យបានទាន់ពេលវេលាទេនោះនឹងអាចនាំឱ្យកើតនូវអសន្តិសុខសង្គមផងដែរ។ ម៉្យាងវិញទៀត គម្លាតខ្ពស់រវាងអ្នកមាននឹងអ្នកក្រ និងស្ថានភាពប្រឈមមុខនៃភាពក្រីក្ររបស់ប្រជាពលរដ្ឋធ្លាប់ជាមូលហេតុមួយនៃការកើតភាពកោលាហល។ ដូចដែលតាមការសិក្សាស្រាវជ្រាវរបស់លោក ណាយ៉ាន ចិន្តា (ទំព័រទី ៦៣) ព្រឹត្តិការណ៍នៅសំឡូត ខេត្តបាត់ដំបង ឆ្នាំ១៩៦៧ ខ្មែរក្រហមបានឆ្លៀតឱកាសពីស្ថានភាពប្រឈមទាំងនេះ។ ដោយរំលឹកអំពីមូលហេតុនៃសង្គ្រាម និងសោកនាដកម្មកាលពីអតីតកាលបានពិពណ៌នាថា៖

---

[៧០] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ***ស្តីពីច្បាប់ភូមិបាល*** មាត្រា ៣៣។

[៧១] គណៈកម្មការប្រព្រឹត្តកម្មនៃអង្គការ សមាគមនការពារសិទ្ធិមនុស្សកម្ពុជា: ***កំពុងបាត់បង់ដីធ្លី*** ការបណ្តេញចេញ ដោយបង្ខំ និងការគំរាមគំហែងនៅកម្ពុជា -ដ.ឯ.ម- ទំព័រ២១។

[៧២] ហ្វ្រង់ស្វ័រ ប៉ុងសូដ៍: ***ប្រវត្តិសង្ខេបនៃប្រទេសកម្ពុជា*** ភ្នំពេញ ឆ្នាំ២០០៧ ទំព័រ១៥៣។

"តាមព្រឹត្តិការណ៍កើតឡើងជាបន្តបន្ទាប់របស់កសិករប្រឆាំងនឹងការរំលោភបំពានលើដីធ្លីរបស់ប្រជាពលរដ្ឋពីសំណាក់អាជ្ញាធរគាំទ្រដោយក្រុមយុវជន ក្នុងខែកុម្ភៈ - មិនា ឆ្នាំ១៩៦៧ នៅសំឡូតប៉ុលពតបានសម្រេចបង្កើតមូលដ្ឋានបដិវត្តន៍យោធា និង ធ្វើការចាប់ផ្តើមបំពាក់អាវុធវាយប្រហារបកប្រឆាំងនឹងរបបសីហនុ"[៧៣]។

បញ្ហាការច្បាមយកដីដោយអ្នកជំនួញ និង មន្ត្រីខិលខូចមួយចំនួនតូចបានដកហូតដីសាធារណៈ និង ឯកជនរបស់រដ្ឋដោយខុសច្បាប់ ដែលជាដើមហេតុកើតមានតាំងពីយូរហើយ។ ម្យ៉ាងបញ្ហាថ្មីដែលកើតឡើងថ្មីៗនៅក្នុងសង្គមកម្ពុជា ជាសង្គមប្រពៃណីកម្ពុជាដែលមិនប្រុងប្រៀបទប់ទល់នឹងបញ្ហាថ្មីទាំងនោះទេ។ អ្នករស់នៅទីប្រជុំជន និង អ្នកជនបទស្រែចំការរស់នៅតាមរបៀបកាន់តែខុសប្លែកពីគ្នាឡើងៗ ជាដើមកំណើតនៃចលនាខ្មែរក្រហមកាលពីមុន[៧៤]។ ប្រមុខរដ្ឋាភិបាលកម្ពុជាក៏ធ្លាប់មានប្រសាសន៍ដោយបានអំពាវនាវឱ្យអាជ្ញាធរប្រគល់ដីឱ្យរាស្ត្រវិញ ប្រសិនបើនោះជាទំនាស់រវាងរាស្ត្រ និង អាជ្ញាធរ។ ចំណុចដែលគួរសិក្សាបន្ថែមទាក់ទងនឹងវិវាទដីធ្លីធំៗកើតអំពើហិង្សា និងកម្រិតនៃការតវ៉ា កត្តាជំរុញដែលនាំឱ្យកើតមានបដិវត្តន៍ឬ យ៉ាងណា?។ តើរដ្ឋាភិបាលត្រូវដោះស្រាយទំនាស់ដីធ្លីនឹងបញ្ហាប្រឈមទាំងនេះតាមរបៀបណាជាដើម?។

## ក បម្រែបម្រួលនៃវិវាទដីធ្លី

តាមទិន្នន័យដែលបានប្រមូលដោយអង្គការមិនមែនរដ្ឋាភិបាលក្នុង២៣ ខេត្ត-ក្រុងនៃប្រទេសកម្ពុជា ដោយគិតពីឆ្នាំ១៩៩០ មកដល់ ឆ្នាំ២០០៤ មានវិវាទចំនួន ១,៥៥១ ករណី បានកើតឡើងរវាងប្រជាពលរដ្ឋសាមញ្ញជាមួយមន្ត្រីរាជការថ្នាក់ខ្ពស់ លើទំហំដី ចំនួន៣៨១,៤០៦ ហិកតា ដែលប៉ះពាល់ដល់ប្រជាកសិករចំនួន ១៦២,២៧៧ គ្រួសារ (៦.៤% នៃចំនួនគ្រួសារទាំងមូលក្នុងប្រទេស)។ ក្នុងចំណោម ១៦២,២៧៧ គ្រួសារ មានស្ត្រីចំនួន ១៧,០៦១ (១០.៥ %) ជាមេគ្រួសារបានទទួលរងនូវការរំលោភដីធ្លី[៧៥]។

រូបភាពទី២ បម្រែបម្រួលនៃករណីវិវាទដីធ្លី ១៩៩០-២០០៤៖




ប្រភព៖ អុកស្វាមដីប៊ីៈ វិវាទដីធ្លីនៅកម្ពុជា ភ្នំពេញ ឆ្នាំ២០០៤ ទំព័រ៤។

[៧៣] Hanne Sophie Greve: ***Land Tenure and Property Rights in Cambodia***, Phnom Penh, 1993, page 8.

[៧៤] ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ៈ *ប្រវត្តិសង្ខេបនៃប្រទេសកម្ពុជា* ភ្នំពេញ ឆ្នាំ២០០៧ ទំព័រ ១៥០-១៥១។

[៧៥] អុកស្វាមដីប៊ីៈ ***វិវាទដីធ្លីនៅកម្ពុជា*** ភ្នំពេញ ឆ្នាំ២០០៤ ទំព័រ៤។

ករណីវិវាទបានកើនឡើងយ៉ាងខ្លាំងក្នុងឆ្នាំ២០០០ បើធៀបទៅនឹងវិវាទក្នុងឆ្នាំ១៩៩៩ មានការកើនឡើង៥០%។ កំណើននេះបានថយចុះវិញ ៥០% បើធៀបទៅនឹងឆ្នាំ២០០១ និង ៦០% បើធៀបនឹងឆ្នាំ២០០៣។ ប៉ុន្តែកំណើនវិវាទបានឡើង ៥០%វិញ ក្នុងឆ្នាំ២០០៤ បើធៀបនឹងឆ្នាំ ២០០៣ ។ នេះដោយហេតុថា ក្នុងឆ្នាំ២០០១ ជាតំណាក់កាលកំណែទម្រង់ដីធ្លីយ៉ាងសំខាន់មួយបានកើតឡើង៖ (ទីមួយ) ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ទើបតែបានបង្កើតឡើងថ្មី និង (ទីពីរ) ការអនុម័តច្បាប់ភូមិបាលថ្មីនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ។ ក្នុងរយៈពេលនោះគេសង្កេតឃើញថា ករណីរំលោភដីធ្លីបានស្ងប់ស្ងាត់មួយអន្លើ ម៉្យាងទៀត ប្រជាពលរដ្ឋក៏ដូចជាស្ថាប័នមានសមត្ថកិច្ចសង្ឃឹមថា ច្បាប់ភូមិបាលថ្មីនេះនឹងត្រូវបានយកមកអនុវត្តប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀត ច្បាប់នេះបានដាក់កម្រិតទោសយ៉ាងធ្ងន់ដល់អាជ្ញាធរមានសមត្ថកិច្ច និង ជនទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់កម្មសិទ្ធិសាធារណៈ ឬ ឯកជន[៧៦] ។

ផ្ទុយទៅវិញ ការអនុវត្តច្បាប់ភូមិបាលហាក់ដូចជា មិនទាន់ទទួលបាននូវប្រសិទ្ធភាព ដែលហាក់បីដូចជា បើកឱកាសឱ្យករណីរំលោភដីធ្លីបានងើបឡើងម្តងទៀត បន្ទាប់ពីភាពស្ងប់ស្ងាត់អស់មួយរយៈ។ ទន្ទឹមនឹងនេះ បែបបទនៃការបណ្តេញប្រជាពលរដ្ឋចេញពីដីធ្លី ដោយប្រើអំពើហិង្សារបស់កងប្រដាប់អាវុធតាមរយៈសាលក្រមស្ពាលរបស់តុលាការ ដោយភាគីចុងបណ្តឹងបានប្រើប្រាស់ប័ណ្ណសំគាល់ការកាន់កាប់ចេះតែកើតមានឡើង។ គោលបំណងនៃការប្រើប្រាស់ប័ណ្ណនេះ ភាគច្រើនគឺដើម្បីគេចវេះពីការប្រើប្រាស់ប្រព័ន្ធដោះស្រាយតាមគណៈកម្មការសុរិយោដី។ គិតមកត្រឹមចុងខែមេសា ឆ្នាំ២០០៦ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិបានទទួលករណីវិវាទចំនួន៣,៩៣៩[៧៧]។ ក្នុងចំណោមករណីវិវាទទាំងនេះ ករណីវិវាទ ចំនួន១,១៤៦ ត្រូវបានដោះស្រាយដោយជោគជ័យ ករណីវិវាទ ចំនួន៧៧៣ ត្រូវបានច្រានចោល និង ករណីចំនួន៧០ ត្រូវបានដកទៅវិញ និង ករណីចំនួន១,៩៦០ កំពុងដោះស្រាយ។

តាមស្ថិតិឆ្នាំ២០០៥ បង្ហាញថា វិវាទដីធ្លីចំនួន៦០០ ករណី មិនទាន់បានដោះស្រាយជាវិវាទដែលពាក់ព័ន្ធនឹងភាគីម្ខាងជាអាជ្ញាធរមានឋានៈខ្ពស់។ តួលេខទាំងនេះ រាយការណ៍បិទបាំងការពិតដែលថា ករណីវិវាទប្រភេទនេះជាច្រើនមិនត្រូវបានប្តឹងទៅគណៈកម្មការសុរិយោដីទេ បើទោះបីតាមលក្ខណៈបច្ចេកទេស ករណីវិវាទប្រភេទនេះ ត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់គណៈកម្មការសុរិយោដីក៏ដោយ។ ផ្អែកលើការប៉ាន់ប្រមាណមានគ្រួសារប្រមាណពី ១៥០,០០០ ទៅ ២០០,០០០ គ្រួសារ បានពាក់ព័ន្ធទៅនឹងវិវាទដីធ្លីប្រភេទនេះ[៧៨]។

---

[៧៦] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល***៖ មាត្រា ២៥១ ដល់ ២៦៥។

[៧៧] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់: ***កសាងស្ថាប័នយុត្តិធម៌?*** ការពិនិត្យមើលទៅលើការងាររបស់គណៈកម្មការសុរិយោដីនៅកម្ពុជាទាក់ទងនឹងការ ដោះស្រាយវិវាទដីធ្លី សហការជាមួយ ក្រសួងរៀបចំដែនដីនគរូបនីយ កម្ម និងសំណង់ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ភ្នំពេញ ឆ្នាំ២០០៦ ទំព័រ១៩។

[៧៨] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់: ***កសាងស្ថាប័នយុត្តិធម៌ ?*** -ដ.ឯ.ម-ទំព័រ១៩។

## ខ ប្រភេទនៃដីធ្លីជាប់មានវិវាទ និង អ្នកជាប់ពាក់ព័ន្ធ

ដីធ្លីមួយចំនួនត្រូវបានយកមកប្រើប្រាស់ក្នុងវិស័យកសិកម្ម ដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ វិស័យកសិកម្មនៅកម្ពុជា មានលក្ខណៈតូចសម្រាប់តែបំពេញនូវតម្រូវការហូបចុកប្រចាំថ្ងៃតែប៉ុណ្ណោះ។ ក៏ប៉ុន្តែ ដោយមានការបើកឱ្យទូលាយខាងសេដ្ឋកិច្ចដីត្រូវបានគេយកមកប្រើប្រាស់បន្តិចម្តងៗ ដើម្បីបម្រើវិស័យពាណិជ្ជកម្ម។ ការណ៍នេះ ធ្វើឱ្យដីកាន់តែមានតម្លៃខាងផ្នែកសេដ្ឋកិច្ច។ តាមគំហើញដោយអង្គការអុកស្វាម ជាទូទៅប្រភេទដីវិវាទមានច្រើនសណ្ឋាន ជាពិសេស ភាគច្រើនទៅលើដីចំការ ដីស្រែ និង ដីសាងសង់។ តាមតួលេខក្នុងសំណាកបានឱ្យដឹងថា ដីចំការ៣៦% (២៨៤ ករណី) ដីស្រែ ៣២% (២៥៧ កណើ) ដីសម្រាប់សាងសង់ ២៦ (២១១ ករណី) និងផ្សេង ៦% (៤៥ ករណី)។

រូបភាពទី៣ តួលេខនៃប្រភេទដីដែលជាប់វិវាទ៖




<u>ប្រភព</u>៖ អុកស្វាមជីប៊ី: វិវាទដីធ្លីនៅកម្ពុជា ភ្នំពេញ ឆ្នាំ២០០៤ ទំព័រ១៦។

សិទ្ធិប្រើប្រាស់ និងគ្រប់គ្រងដីធ្លីកាន់តែផ្អែកច្រើនឡើងៗ ទៅលើមធ្យោបាយខាងផ្លូវច្បាប់ ព្រោះគេយល់ថាច្បាប់ផ្តល់នូវការការពារសិទ្ធិលើកម្មសិទ្ធិដីធ្លី មួយរឹងមាំល្អជាងទំនៀមទម្លាប់ប្រពៃណី។ ការផ្លាស់ប្តូរនិន្នាការនៃការប្រើប្រាស់ដីធ្លីពីការផលិតគ្រាន់តែគ្រប់ហូបមកជាការផលិតបែបពាណិជ្ជកម្ម នេះធ្វើឱ្យមានការផ្លាស់ប្តូរទស្សនៈរបស់ប្រជាពលរដ្ឋខ្មែរ អំពីរឿងរាវសិទ្ធិលើដីធ្លី និងជាពិសេសទៅទៀតនោះការផ្លាស់ប្តូរនេះ បានធ្វើឱ្យមានការលេចឡើងនូវវិវាទដីធ្លីច្រើនបែបច្រើនយ៉ាង។ តាមការសង្កេតលើករណីវិវាទដីធ្លី ដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជាបានក្លាយជាបញ្ហាមួយដ៏ធ្ងន់ធ្ងរនាពេលបច្ចុប្បន្ន ពិសេស រវាងឈ្មួញដី និង អាជ្ញាធរមានសមត្ថកិច្ចដែលខិលខូចមួយចំនួនដែលបានរំលោភយកដីធ្លីរបស់ប្រជាពលរដ្ឋក្រោមរូបភាពការដណ្តើមដីធ្លី តាមរយៈការក្លែងបន្លំលិខិតស្នាមរហូតដល់ធ្វើប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីធ្លី នៅលើដីប្រជាពលរដ្ឋស្លូតត្រង់បណ្តាលឱ្យប្រជាពលរដ្ឋបាត់បង់ដីធ្លី ព្រមទាំងប៉ះពាល់ដល់ជីវភាពរបស់ពួកគេដែលកំពុងក្រីក្រស្រាប់ផង។ គេសង្កេតឃើញថា មានករណីវិវាទជាច្រើនដែលកើតមានឡើងរវាងប្រជាពលរដ្ឋ និង ប្រជាពលរដ្ឋ ប្រជាពលរដ្ឋ និងយោធា ប្រជាពលរដ្ឋ និង អាជ្ញាធរដែនដី ឬ អាជ្ញាធរមានឋានៈខ្ពស់ ប្រជាពលរដ្ឋ និង ក្រុមហ៊ុនវិនិយោគទុនជាដើម។

តាមការសិក្សារបស់អង្គការអុកស្វាមអង់គ្លេសនៅកម្ពុជា ក្នុងចំណោមករណីវិវាទសរុបចំនួន ១៩៥០ មាន៧៩៧ ករណី ដែលជនរងគ្រោះតែងតែបានចោទប្រកាន់ថា អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធ ក្រុមហ៊ុន និង អ្នកមានប្រាក់ដែលមានខ្នងបង្អែក ជាមួយបុគ្គលមានឥទ្ធិពលជាអ្នកដែលរំលោភយកដីធ្លីរបស់ពួកគាត់។ តាមសំណាកបានបង្ហាញថា ៣០៦ករណី (៣៩%) ពាក់ព័ន្ធជាមួយអាជ្ញាធរ ចំនួន២៤០ករណី (៣០%) ជាមួយកងកម្លាំងប្រដាប់អាវុធ ២០ ករណី (៣%) ជាមួយក្រុមហ៊ុន ជាមួយអ្នកមានប្រាក់ ១២៩ករណី (១៦ %) និង ផ្សេងៗ ៩៩ករណី (១២%)។

រូបភាពទី៤ អ្នករងការចោទប្រកាន់លើវិវាទដីធ្លី៖




ប្រភព៖ អុកស្វាមជីប៊ីៈ វិវាទដីធ្លីនៅកម្ពុជា ភ្នំពេញ ឆ្នាំ២០០៤ ទំព័រ១៨។

## ១.៣.១ ប្រភេទវិវាទដីធ្លីជាទូទៅ

ជាទូទៅនៅក្នុងសកលលោក វិវាទដីធ្លីចែកជា ៤ផ្នែក ហើយផ្នែកនីមួយៗបែងចែកជា៣៥ ប្រភេទ និង ក្នុងប្រភេទទាំងនេះបែងចែកជា ៥០អនុប្រភេទទៀត។ ប្រព័ន្ធនៃចំណាត់ថ្នាក់វិវាទដីនេះកើតឡើងពាក់ព័ន្ធលើដីរដ្ឋ ដីឯកជន ឬ ដីសហគមន៍[៧៩]។

វិវាទដែលកើតឡើងលើគ្រប់ប្រភេទនៃទ្រព្យដែលមានជាអាទិ៍ដូចខាងក្រោម៖

១ វិវាទព្រំប្រទល់
២ វិវាទលើកេរមត៌ក
៣ វិវាទលើកម្មសិទ្ធិដោយសារច្បាប់ (ភាពផ្ទុយគ្នារវាងច្បាប់នឹងប្រពៃណី)
៤ វិវាទលើកម្មសិទ្ធិដោយសារមិនមានការចុះបញ្ជីដីធ្លី
៥ វិវាទរវាងដីកម្មសិទ្ធិរបស់រដ្ឋ និងដីឯកជន
៦ ការលក់ដីច្រើនលើក
៧ អលទ្ធភាពទទួលបានដីដោយសារច្បាប់ ប្រពៃណី ឬការអនុវត្តមានការរើសអើង
៨ លទ្ធកម្មដីក្រៅផ្លូវការដោយមិនមានការបណ្តេញ
៩ លទ្ធកម្មដីដោយអំពើហិង្សា រួមទាំងការប៉ះទង្គិច និងសង្គ្រាមដីធ្លី

[៧៩] Bebette Wehrmann: ***Land Conflicts: A practical guide to dealing with land disputes***, GTZ, Eschborn 2008, page 14-15.

១០ ការបណ្ដេញចេញដោយម្ចាស់ដី

១១ ការបណ្ដេញចេញដោយខុសច្បាប់ដោយអាជ្ញាធររដ្ឋធ្វើសកម្មភាពដោយគ្មានកំណត់ពេល។

១២ ការបណ្ដេញចេញតាមទីផ្សារ និងកើនតម្លៃទីផ្សារដីក្នុងតំបន់

១៣ វិវាទលើការបង់ថ្លៃសម្រាប់ការប្រើប្រាស់ ទិញដី

១៤ វិវាទលើតម្លៃដី

១៥ វិវាទរវាងការប្រើប្រាស់របស់មនុស្ស វប្បធម៌ និងធម្មជាតិ

១៦ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ

វិវាទពិសេសលើទ្រព្យសម្បត្តិឯកជនៈ

១៧ ការដកហូតដីដោយគ្មានសំណងពីរដ្ឋ

១៨ លក់អចលនៈទ្រព្យដែលមិនមែនជារបស់ខ្លួន

១៩ ជួល ឱ្យខ្ចីលើទ្រព្យដែលមិនមែនជារបស់ខ្លួន

២០ ការដកហូតដីដោយមិនមានលក្ខណៈត្រឹមត្រូវតាមច្បាប់ដោយធនាគារ

២១ វិវាទដីធ្លីដោយសារដីជាប់ពាក់ព័ន្ធលើការកែទម្រង់ដីកសិកម្ម

២២ វិវាទលើការទាមទារដីក្នុងស្ថានភាពក្រោយសង្គ្រាម

២៣ ការប្រើប្រាស់ដីឯកជនដោយខុសច្បាប់

២៤ វិវាទរវាងគ្រួសារ និងគ្រួសារ ជាពិសេសករណីលើភាពមានប្ដី ឬ ប្រពន្ធច្រើន

វិវាទពិសេសលើទ្រព្យរួមៈ

២៥ ការប្រជែងគ្នាប្រើប្រាស់លើទ្រព្យរួម

២៦ ការប្រើប្រាស់ទ្រព្យរួមដោយខុសច្បាប់

២៧ ការលក់ទ្រព្យរួមដោយគ្មានការអនុញ្ញាត

២៨ វិវាទលើការបែងចែកដីនៃចំណូលពីដីតាមប្រពៃណី

វិវាទពិសេសលើទ្រព្យរដ្ឋៈ

២៩ ការប្រើប្រាស់ដីរដ្ឋដោយខុសច្បាប់

៣០ ការប្រជែងគ្នាលើការប្រើប្រាស់សិទ្ធិលើទ្រព្យរបស់រដ្ឋ

៣១ ការចាប់យកដីដោយខុសច្បាប់ដោយមន្ត្រីជាន់ខ្ពស់សាធារណៈ

៣២ លក់ដីរដ្ឋខុសច្បាប់

៣៣ ជួលដីរដ្ឋខុសច្បាប់ (រួមទាំងសម្បទានដីធ្លី ព្រៃឈើ និងរ៉ែ)

៣៤ វិវាទលើផលចំណូលនៃរដ្ឋពីការជួល លក់ និងផ្ទេរការប្រើប្រាស់ដីរដ្ឋ

៣៥ ការធ្វើឯកជនូបនីយកម្មមិនត្រឹមត្រូវ (ឧ. ការបែងចែកដី ឬការផ្ដល់ប័ណ្ណមិនត្រឹមត្រូវ)

តារាងទី៥៖ អំពីប្រភេទ និងអនុប្រភេទនៃវិវាទដីធ្លី

| ប្រភេទ | អនុប្រភេទ |
|---|---|
| | វិវាទដីធ្លីលើគ្រប់ប្រភេទទាំងអស់ |
| វិវាទព្រំប្រទល់ | -រវាងបុគ្គលលើដីឯកជន<br>-រវាងក្រុមលើដីរួមលើព្រំប្រទល់ជាប្រពៃណី<br>-រវាងដែនរដ្ឋបាល ភូមិ ឃុំ ស្រុក រាជធានី<br>-រវាងដីឯកជននឹងដីរដ្ឋ |
| វិវាទលើកម្មសិទ្ធិកេរមត៌ក | -វិវាទកេរមត៌កក្នុងគ្រួសារ<br>-វិវាទកេរមត៌កនៅក្នុងក្រុម |
| វិវាទលើកម្មសិទ្ធិដោយសារច្បាប់ច្រើនផ្សេងៗគ្នា | -ភាពផ្ទុយគ្នានៃសិទ្ធិដោយសារច្បាប់ផ្ទុយគ្នា (ផ្ទុយគ្នារវាងប្រពៃណី និង ច្បាប់រដ្ឋ)។ |
| វិវាទលើកម្មសិទ្ធិដោយសារមិនមានការចុះបញ្ជីដីធ្លី | -មនុស្សច្រើនទាមទារលើដីតែមួយដោយសារ-គ្មានការចុះបញ្ជីដី-ស្ថិតក្នុងស្ថានភាពអាក្រក់-មានការបំផ្លិចបំផ្លាញ។<br>-ការផ្តល់សិទ្ធិដោយគ្មានការចុះបញ្ជី<br>-វិសមភាពចំណេះដឹង និងថវិកាមានតែអ្នកមានទើបអាចចុះបញ្ជីដី |
| វិវាទរវាងដីកម្មសិទ្ធិរបស់រដ្ឋ និង ដីឯកជន | -ភាពមិនច្បាស់លាស់ និង មិនមានតម្លាភាពនៃការកំណត់ដីរដ្ឋក្នុងបំណងកេងយកចំណេញជាបុគ្គល និងក្រុម។<br>-ករណីពិសេសវិវាទដោយសារការសន្ធនាមិនត្រឹមត្រូវ<br>ការដាក់ដីកសិកម្មរួមចូលទៅក្នុងដីរដ្ឋសម្រាប់ការសាងសង់ |
| ការលក់ដីច្រើនលើក | -ការលក់ដីច្រើនលើកដែលជាទ្រព្យឯកជនរបស់អ្នកដទៃ<br>-ការលក់ទ្រព្យរួមគ្នាច្រើនដង<br>-ការផ្តល់ប័ណ្ណដីដូចគ្នាដោយមន្ត្រីចុះបញ្ជីដីដោយអំពើពុករលួយ ឬប័ណ្ណក្លែងក្លាយ។<br>-ភាពជាន់គ្នានៃការផ្តល់ប័ណ្ណដីដោយស្របច្បាប់ពីស្ថាប័នផ្សេងគ្នា<br>-ការលក់ដីរដ្ឋច្រើនដងដោយមន្ត្រីសាធារណៈ |
| អលទ្ធភាពទទួលបានដីដោយសារច្បាប់ប្រពៃណី ឬ ការអនុវត្តច្បាប់<br>មានការរើសអើង | -ស្ត្រីតែងទទួលសិទ្ធិលើដីតាមរយៈញាតិជាបុរស ធ្វើឱ្យរងគ្រោះក្នុងករណីលែងលះ ឬ ម៉េម៉ាយ។<br>-ជនជាតិដើមភាគតិចតែងទទួលការរើសអើងពីច្បាប់ ឬ ការអនុវត្តច្បាប់<br>-កូនកំព្រាមិនត្រូវបានគេរាប់បញ្ចូលក្នុងមត៌កនៃទ្រព្យឪពុកម្តាយ |
| សន្តិភាព | -ការកាន់កាប់ដីរដ្ឋ ឯកជន និង ដីរួមគ្នាដោយខុសច្បាប់ |

| | |
|---|---|
| លទ្ធកម្មដីក្រៅផ្លូវការ ដោយមិនមានការបណ្តេញ | -ការពង្រីកទ្រព្យឯកជនលើដីអ្នកជិតខាង ដីរដ្ឋ និង ដីរួមគ្នា<br>-ទីផ្សារដីជីកមុខនាំដល់ការផ្លាស់ទីដែលពាក់ព័ន្ធអ្នកកេងយកកម្រៃ ឬអ្នកអភិវឌ្ឍន៍សងតិចជាងតម្លៃទីផ្សារពិតប្រាកដ។ |
| លទ្ធកម្មដីដោយអំពើហិង្សា | -ការវាយប្រហាដោយអំពើហិង្សាលើម្ចាស់ទ្រព្យរួមទាំងបណ្តេញចេញដោយប្រើអំពើឧក្រិដ្ឋ - ជាទូទៅ អតីតទាហាន នគរបាល ។ល។<br>-ការកាន់កាប់ដីរួមដោយខុសច្បាប់ពីបុគ្គលឬក្រុមហ៊ុនសម្រាប់ប្រើប្រាស់ជាឯកជនដែលជានិច្ចជាកាលគាំទ្រដោយមន្ត្រីពុករលួយ។ |
| បណ្តេញចេញដោយម្ចាស់ដី | -បណ្តេញចេញនៃលំនៅស្របច្បាប់ពាក់កណ្តាល (លំនៅដែលរំលោភបទបញ្ញា) ពីរដ្ឋ ឯកជន ឬពីទ្រព្យរួមគ្នា។<br>-បណ្តេញអ្នករស់នៅសំណង់ខុសច្បាប់ (អ្នកមិនមានសិទ្ធិស្របច្បាប់លើដី) ពីរដ្ឋ ឯកជន ឬពីទ្រព្យរួមគ្នា។<br>-កិច្ចសិន្យាមិនចែងច្បាស់លាស់នៃអ្នកកាន់កាប់ អ្នកជួលដោយម្ចាស់ដី |
| បណ្តេញចេញតាមទីផ្សារ និងកើនតម្លៃទីផ្សារដីក្នុងតំបន់ | -អ្នកក្រមិនមានលទ្ធភាពរស់នៅលើដីដោយសារដីឡើងថ្លៃ និងមិនអាចបង់ពន្ធ។ |
| វិវាទលើការបង់ថ្លៃសម្រាប់ការប្រើប្រាស់ទិញដី | -មិនបង់ថ្លៃចំពោះការជួលដីរដ្ឋ<br>-មិនបង់ថ្លៃចំពោះការជួលដីឯកជន<br>-ការមិនព្រមរវាងម្ចាស់ និង អ្នកជួលដីលើការបង់ផលដំណាំក្នុងករណីប្រវាស់គ្នា។<br>-មិនព្រមបង់ថ្លៃពេញករណីលក់ទិញដីធ្លី រួមទាំងការឆបោក (ឧ. ប្រើមូលបត្រអស់សុពលភាព)។ |
| វិវាទលើតម្លៃដី | -រវាងរដ្ឋ និងប្រជាពលរដ្ឋ ក្នុងករណីសំណង់ ឬ បង់ពន្ធ<br>-រវាងបុគ្គលឯកជន (ឧ. ការកំណត់សំណងចំពោះបងប្អូនករណីកេរមត៌ក) |
| វិវាទរវាងការប្រើប្រាស់របស់មនុស្ស វប្បធម៌ និងធម្មជាតិ | -ការប្រើមិនត្រឹមត្រូវ ឬប្រើហួសប្រមាណនៃដីកសិកម្ម<br>-ដីមានចម្លងរោគ<br>-ប្រើដីមិនមានចីរភាព ដូចជាប្រែក្លាយដីព្រៃទៅដីសំណង់ ឬតាំងលំនៅថ្មីនៅតំបន់មានគ្រោះថ្នាក់។<br>-វិវាទរវាងការការពារធម្មជាតិ និង ការធ្វើដំណាំ ឬការជីករ៉ែ<br>-វិវាទរវាងសត្វព្រៃ និងអ្នកស្រែចំការ។ |
| ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ | -ការវាយប្រហាដោយហិង្សាលើដី (ការបំផ្លាញដីស្រែចំការ) |

| | |
|---|---|
| | -ការបំផ្លាញអគារដោយម្ចាស់ទ្រព្យ<br>-ការបំផ្លាញអគារដោយខុសច្បាប់ |
| វិវាទដីធ្លីលើទ្រព្យសម្បត្តិឯកជន | |
| ការដកហូតដីដោយគ្មានសំណងពីសំណាក់រដ្ឋ | -ការដកហូតដីដោយគ្មានសំណងសមរម្យដើម្បីយកដីក្នុងបំណងប្រើប្រាស់សាធារណៈ។<br>-ការដកហូតដីដោយគ្មានសំណងសមរម្យដើម្បីយកដីក្នុងបំណងប្រើប្រាស់ឯកជន។<br>-បណ្តេញម្ចាស់ដីដោយផ្តល់ដីថ្មីឱ្យបានសមរម្យ។ |
| លក់អចលនៈទ្រព្យដែលមិនមែនជារបស់ខ្លួន | -បុគ្គលឯកជនលក់ដីដែលមិនមែនជារបស់ខ្លួន។ |
| ជួល ឬឱ្យខ្ចីលើទ្រព្យដែលមិនមែនជារបស់ខ្លួន | - បុគ្គលឯកជនឱ្យខ្ចី ឬជួលដីដែលមិនមែនជារបស់ខ្លួន។ |
| ការដកហូតដីដោយមិនមានលក្ខណៈត្រឹមត្រូវតាមច្បាប់ពីធនាគារ | -អ្នកក្រចងការប្រាក់ពីធនាគារដោយការប្រាក់ខ្ពស់ពេកអ្នកក្រគ្មានលទ្ធភាពសង។ |
| វិវាទដោយសារការកែទម្រង់ដីកសិកម្ម | -កសិករធំៗមិនព្រមបោះបង់ដី<br>-ការស្នើដកហូតដីពីកសិករដើម្បីជាសំណាង ឬការដកហូតខុសច្បាប់<br>-កសិករទទួលដីដោយគ្មានសុវត្ថិភាព គ្រាន់តែជាប័ណ្ណបណ្តោះអាសន្ន<br>-ការជ្រើសរើសអ្នកទទួលផលមិនយុត្តិធម៌នៃការកែទម្រង់ដីធ្លី |
| វិវាទលើការទាមទារដីក្នុងស្ថានភាពក្រោយសង្គ្រាម | -ការទាមទារពីជនមាតុភូមិនិវត្តន៍ និង ជនភៀសខ្លួនជំទាស់នឹងជនផ្សេងៗទៀតដែលកាន់កាប់ដីគ្មានការអនុញ្ញាត។<br>-ការទាមទារពីម្ចាស់ដីចំពោះជនមាតុភូមិនិវត្តន៍ និង ជនភៀសខ្លួនដែលកាន់កាប់ដីរបស់គេដោយគ្មានការអនុញ្ញាត។<br>-វិវាទដោយសារអតីតដីជនមាតុភូមិនិវត្តន៍បានឱ្យផ្តល់ដោយអតីតរដ្ឋាភិបាលទៅអ្នកផ្សេងពេលគេអវត្តមាន។ |
| ការប្រើប្រាស់ដីឯកជនដោយខុសច្បាប់ | -ប្រើប្រាស់ដីអ្នកដទៃ (ឧ. កន្លែងចត ទីធ្លារ វាលស្មៅ...)<br>-ម្ចាស់ដីឯកជនធ្វើមិនដឹងមិនឮចំពោះបទបញ្ហាការប្រើប្រាស់ដីលើទ្រព្យរបស់ខ្លួន (ឧ. ការប្រើដីធ្វើពាណិជ្ជកម្មនៅតំបន់សម្រាប់លំនៅឋាន)<br>-ការបំបែកប័ណ្ណជាតូចៗដោយខុសច្បាប់ |

| | |
|---|---|
| | -សាងសង់អគារលើសពីកំពស់ដែលច្បាប់កំណត់<br>-ទុកដីទំនេរសម្រាប់បំណងឡើងថ្លៃ (វាជាវិវាទបើច្បាប់ហាម)<br>-ឈ្លានពានលើទ្រព្យសម្បត្តិអ្នកដទៃ |
| វិវាទរវាងគ្រួសារ | -ប្រពន្ធទាស់ចិត្ត និង កូនដែលទទួលបានដីមិនស្មើភាពគ្នា។ |
| វិវាទដីលើទ្រព្យរួមគ្នា | |
| ការប្រជែងគ្នាប្រើប្រាស់លើទ្រព្យរួមគ្នា | -វិវាទផលប្រយោជន៍ក្នុងដីរួមគ្នាដោយកសិករ និង អ្នកស្រែចំការ ឬរវាងអ្នកប្រើប្រាស់ព្រៃ ដូចជា កសិករខ្នាតតូចធ្វើកសិកម្មពនេចរ ដាំកាហ្វេ អ្នករកអុស និងអ្នកដទៃ។<br>-ការផ្ដល់ដីមិនស្មើគ្នា |
| ការប្រើប្រាស់ទ្រព្យរួមដោយខុសច្បាប់ | -ក្បាលដី និង ការផ្ដល់ដីរួមគ្នាដើម្បីប្រើប្រាស់ធ្វើសំណង់ (ឧ. នៅប្រទេសម៉ិចស៊ិក) |
| ការលក់ទ្រព្យរួមដោយគ្មានការអនុញ្ញាត | -ការលក់ដីប្រពៃណីដោយគ្មានការអនុញ្ញាតពីប្រធានភូមិ<br>-ការលក់ដីរួមដោយគ្មានការអនុញ្ញាតពីប្រធានភូមិ<br>-ការជួល ឬលក់ដីដោយអ្នកជួលដីរួម |
| វិវាទលើការបែងចែកដីនៃចំណូលពីដីតាមប្រពៃណី | -ករណីពិសេសនៅប្រទេសហ្គាណាដែលអ្នកគ្រប់គ្រងរដ្ឋប្រមូលចំណូលដីរួមពីដីប្រពៃណី ដីសហគមន៍។ |
| វិវាទដីធ្លីលើទ្រព្យរដ្ឋ | |
| ការប្រើប្រាស់ដីរដ្ឋដោយខុសច្បាប់ | -ការប្រើបំណងឯកជនលើដីរដ្ឋដោយខុសច្បាប់<br>-ការជួលដីរដ្ឋបន្តដោយខុសច្បាប់<br>-ការប្រើដីរដ្ឋជាសាធារណៈដោយខុសច្បាប់(ឧ.បើឱ្យចាក់សំរាម) |
| ការប្រជែងគ្នាលើការប្រើប្រាស់សិទ្ធិលើទ្រព្យរបស់រដ្ឋ | -ភាពមិនច្បាស់លាស់ការទទួលខុសត្រូវលើដីរដ្ឋអាជ្ញាធរផ្សេងគ្នាទាមទារកម្មសិទ្ធិ។<br>-វិវាទផលប្រយោជន៍លើដីរដ្ឋ ដោយកសិករ ឬអ្នកជួលដីសម្បទាន (ឧ. ព្រៃឈើ កសិកម្ម)។<br>-ការផ្ដល់ដីដែលស្ថិតនៅក្នុងតំបន់ការពារ។ |
| ការចាប់យកដីដោយខុសច្បាប់ | -ចុះបញ្ជីដីរដ្ឋដោយដាក់ឈ្មោះផ្ទាល់ខ្លួន ឬសមាជិកគ្រួសារ និងមិត្តភ័ក្រដោយមន្ត្រីសាធារណៈជាន់ខ្ពស់។ |
| លក់ដីរដ្ឋខុសច្បាប់ | -លក់ដីរដ្ឋខុសច្បាប់ចំពោះដីទំនេរពីសំណាក់បុគ្គលឯកជន<br>-លក់ដីរដ្ឋខុសច្បាប់ចំពោះដីទំនេរពីសំណាក់មន្ត្រីសាធារណៈ<br>-លក់ដីរដ្ឋខុសច្បាប់ចំពោះដីប្រើប្រាស់ពីសំណាក់មន្ត្រីសាធារណៈ<br>-លក់ដីរដ្ឋខុសច្បាប់ចំពោះដីប្រើប្រាស់ស្របច្បាប់ជាឯកជនពី |

| | |
|---|---|
| | សំណាក់មន្ត្រីសាធារណៈ។<br>-លក់ដីរដ្ឋខុសច្បាប់ចំពោះដីប្រើប្រាស់ខុសច្បាប់ជាឯកជនពីសំណាក់មន្ត្រីសាធារណៈ |
| ជួលដីរដ្ឋខុសច្បាប់ (រួមទាំងសម្បទានដីធ្លី ព្រៃឈើ និងរ៉ែ) | -ជួលដីរដ្ឋខុសច្បាប់ចំពោះដីទំនេរពីសំណាក់បុគ្គលឯកជន<br>-ជួលដីរដ្ឋខុសច្បាប់ចំពោះដីទំនេរពីសំណាក់មន្ត្រីសាធារណៈ<br>-ជួលដីរដ្ឋខុសច្បាប់ចំពោះដីប្រើប្រាស់ពីសំណាក់មន្ត្រីសាធារណៈ<br>-ជួលដីរដ្ឋខុសច្បាប់ចំពោះដីប្រើប្រាស់ស្របច្បាប់ជាឯកជនពីសំណាក់មន្ត្រីសាធារណៈ។<br>-ជួលដីរដ្ឋខុសច្បាប់ចំពោះដីប្រើប្រាស់ខុសច្បាប់ជាឯកជនពីសំណាក់មន្ត្រីសាធារណៈ។ |
| វិវាទលើផលចំណូលរដ្ឋពីការជួល លក់ និងផ្ទេរការប្រើប្រាស់ដីរដ្ឋ | -រវាងស្ថាប័នសាធារណៈនៅកម្រិតស្មើគ្នា<br>-រវាងស្ថាប័នសាធារណៈនៅកម្រិតខុសគ្នា<br>-រវាងរដ្ឋ និងមន្ត្រីរដ្ឋ<br>-រវាងអាជ្ញាធរប្រពៃណី និងអាជ្ញាធរសាធារណៈ |
| ការធ្វើឯកជនូបនីយកម្មមិនត្រឹមត្រូវ | -ការទាមទារដីជាន់គ្នានៅពេលរៀបចំស្ថាប័នឡើងវិញ<br>-ភាពមិនប្រក្រតីនៅពេលបែងចែកដី<br>-ការដាក់ពាក្យស្នើសុំដីមិនត្រូវតាមច្បាប់<br>-ការបែងចែកប័ណ្ណមិនមានយុត្តិធម៌ |

បញ្ហាវិវាទដីធ្លី គឺជារបៀបវារៈដែលមានការយកចិត្តទុកដាក់បំផុត ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីជៀសវាងនូវវិបត្តិ ឬបដិវត្តន៍ដីធ្លីកើតមានឡើង។ ការគិតគូរបញ្ហានេះ យោងទៅតាមប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ វប្បធម៌ ប្រពៃណី ច្បាប់ និងប្រព័ន្ធនយោបាយផ្សេងៗគ្នា។

ប្រទេសនេប៉ាល់ជាប្រទេសដែលមានភ្នំខ្ពស់ជាងគេលើពិភពលោកគឺ ភ្នំហេម៉ាឡៃយ៉ាឬភ្នំហែមពាន្ត។ ប្រទេសនេះសំបូរទៅដោយធនធាន និងបរិស្ថានល្អ។ ប្រជាជនសរុបប្រហែល១៩ លាននាក់ ឆ្នាំ១៩៩៧ និង ជិត ២៤ លាននាក់ នៅឆ្នាំ២០០១ (តាមស្ថិតិជំរឿនឆ្នាំ២០០១) ក្នុងនោះប្រជាជនច្រើនជាង ៨០%[៨០] ពឹងផ្អែកលើវិស័យកសិកម្ម ដែលផលពីវិស័យនេះផ្តល់ដល់ ៥៥ ភាគរយនៃចំណូលផលទុនជាតិនៃផលិតផលសរុបក្នុងស្រុក។ ចំណូលប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់ប្រហែល ១៩០ដុល្លារ ប្រជាជន ៤០ ភាគរយ ស្ថិតក្រោមខ្សែបន្ទាត់ភាពក្រីក្រ។ ដោយសារប្រជាជនភាគច្រើនពឹងផ្អែកលើដីធ្លីសម្រាប់ការចិញ្ចឹមជីវិត ដីគឺជាវត្ថុដ៏ចាំបាច់បំផុតសម្រាប់ប្រជាជននេប៉ាល់ វាក៏ជាប្រភពនៃទ្រព្យសម្បត្តិ និង អំណាចផងដែរ។ យោងតាមគណៈកម្មាធិការជាតិប្រទេសនេប៉ាល់ឆ្នាំ១៩៩៨

[៨០] Foods and Agriculture Organizations of United Nations: ***Gender and Participation in Agricultural Development Planning***, Lessons From Nepal, Kathmandu and Rome, 1997, page3.

កសិករជាង ៧០%[៨១] កាន់កាប់ដីកសិកម្មតិចជាងមួយហិកតា ក្នុងនោះស្ត្រីមានតែ ១០,៨ % ទេដែលមានដីធ្លី។

ស្ថាប័នសេដ្ឋកិច្ចសង្គមបានរៀបចំការបែងចែកមិនស្មើភាព ចំពោះទ្រព្យសម្រាប់ផលិតកម្មរវាងម្ចាស់ដី និងកសិករ។ ភាពជាម្ចាស់នៃផលិតផលគឺជាប្រភពនៃអំណាចនយោបាយ និង សេដ្ឋកិច្ចនៅប្រទេសនេប៉ាល់។ ហេតុនេះទើបកើតមានឡើងនូវវិសមភាពធ្ងន់ធ្ងរចំពោះការផ្តល់ដីធ្លី។ នេះដោយសារការប្រមូលផ្តុំអំណាចនៅតែក្នុងដៃម្ចាស់ដីធំៗ ចំនួន ៤%[៨២]។ ម្ចាស់ដីត្រួតត្រាមិនត្រឹមតែសេដ្ឋកិច្ចនៅតាមជនបទប៉ុណ្ណោះទេ តែត្រួតត្រាដល់នយោបាយ និង អាយុជីវិតសង្គមដែលមានទំហំធំធេងគឺចាប់ពីថ្នាក់ភូមិដល់ថ្នាក់ជាតិទៀតផង។ ក្នុងចំណោមប្រជាជន ៤,២ លានគ្រួសារ នៅនេប៉ាល់មាន ១,៣ លាន នាក់គ្មានដីធ្លី ឬមានដីតិចតួច។ គ្រួសារមានដីតិចតួច និង គ្មានដីមិនមានជម្រើសសម្រាប់ចិញ្ចឹមជីវិតទេ លើកលែងទៅស៊ីឈ្នួលឱ្យម្ចាស់ដី។ អ្នកទាំងនោះតំណាងឱ្យប្រជាជន ២៥ % នៃប្រជាជនសរុបនៅក្នុងប្រទេស។ បើមើលនៅក្នុងស្ថិតិប្រជាជនគឺ ២១៧,០០០ គ្រួសារ មិនមានដីធ្លីទាល់តែសោះសូម្បីតែដីសម្រាប់សង់លំនៅឋានក៏គ្មាន[៨៣]។

ជាធម្មតាម្ចាស់ដីនៅតែបណ្តេញអ្នកជួលដីធ្លី ឬកសិករគ្មានដីជារៀងរាល់ថ្ងៃ។ នៅឆ្នាំ១៩៦៤ រដ្ឋាភិបាលបានបង្កើតច្បាប់ដីធ្លី លើកដំបូងបានចែងអំពីសិទ្ធិកាន់កាប់សម្រាប់អ្នកជួលដី ពេលនោះប្រជាកសិករ ចំនួន១,៨១៨,៩៧៥ នាក់ បានដាក់ពាក្យស្នើសុំសិទ្ធិកាន់កាប់សម្រាប់អ្នកជួលដី និងប្រជាកសិករចំនួន១,៥៤៦,៧៣៤ នាក់ បានទទួលប័ណ្ណដីធ្លីបណ្តោះអាសន្ន។ ប៉ុន្តែមានតែម្ចាស់ដីចំនួន៣១៨,៥៩៦ ត្រូវបានចុះបញ្ជីថាជាអ្នកជួលដីគេ។ ច្បាប់ដីធ្លីនេះ បានផ្តល់សិទ្ធិពេញលេញសម្រាប់ម្ចាស់ដី ក្នុងការបណ្តេញអ្នកជួលដីនៅពេលណាដែលគេចង់ធ្វើ។ ក្រោយចលនាប្រជាជននៅឆ្នាំ១៩៩០ គណៈកម្មការជាច្រើនត្រូវបង្កើតឡើងដោយអ្នកកាន់អំណាច។

ច្បាប់ដីធ្លី ឆ្នាំ១៩៦៤ បានធ្វើវិសោធនកម្មលើកទី៤ ក្នុងឆ្នាំ១៩៩៦។ ការធ្វើវិសោធនកម្មនេះបានផ្តល់សិទ្ធិដល់កសិករអ្នកជួលដីដែលបានចុះបញ្ជី មានសិទ្ធិទាមទារយកដីដែលគេបានដាំដំណាំចំនួន៥០%។ ប៉ុន្តែ ការទាមទារដីនេះត្រូវធ្វើក្នុងរយៈពេល ៦ ខែ ចាប់ពីពេលច្បាប់ប្រកាសឱ្យប្រើ តែបើហួសរយៈពេលនេះ អ្នកជួលដីត្រូវបាត់សិទ្ធិទាមទារ។ នៅពេលនោះ អ្នកជួលដីជាច្រើនបានបង្ហាញភស្តុតាងដែលគេបានកាន់កាប់អំឡុងពេលការស្ទង់មតិសុរិយោដី និង ការស្ទង់មតិពីដីធ្លីបន្ទាប់ពីមានច្បាប់ដីធ្លីឆ្នាំ១៩៦៤ តែពួកគេមិនបានចុះបញ្ជីជាផ្លូវការជាអ្នកជួលដីគេនោះទេ។ ដោយគ្មានឯកសារចុះបញ្ជីផ្លូវការពួកគេមិនមានលទ្ធភាពដើម្បីទាមទារដីដែលកំណត់ដោយច្បាប់ដើម្បីធ្វើកម្មសិទ្ធិបានឡើយ។

ទាក់ទងវិវាទដីធ្លីជាទូទៅ នៅប្រទេសនេប៉ាល់គឺ ជាប់ពាក់ព័ន្ធនឹងព្រំប្រទល់ ការវាស់វែង ការផ្លាស់ប្តូរកម្មសិទ្ធិ ការលួច និង បំផ្លាញផលដំណាំ សិទ្ធិអ្នកជួលដី និងសិទ្ធិបណ្តេញអ្នកជួលដី រួមជាមួយការសាងសង់ផ្លូវ ប្រលាយ និង ប្រព័ន្ធទឹកស្អាតប៉ះលើដីប្រជាជន ការចាប់ដីដោយខុសច្បាប់

---

[៨១] Land Watch Asia and Community Self Reliance Center: ***Land Tenure Security in Nepal***, Kathmandu, Nepal, January 2008, page9.

[៨២] Land Watch Asia and Community Self Reliance Center: ***Land Tenure Security in Nepal***, ibit. p10.

[៨៣] ibit page10.

ការបញ្ចាំ ចំណាត់ថ្នាក់គុណភាពដី ការចុះបញ្ជី ការលក់ក្លែងក្លាយ និងអំណោយជាដើម។ លើសពីនេះទៀត ការផ្លាស់ប្តូរនយោបាយសេដ្ឋកិច្ចដ៏ឆាប់រហ័ស បដិវត្តន៍វិស័យព័ត៌មាន បច្ចេកវិជ្ជាទំនើប និងដំណើរការអន្តរាគមន៍ផ្នែកទីផ្សារមិនត្រឹមតែកើននូវ ទំនើបកម្មយ៉ាងលឿនប៉ុណ្ណោះទេនៅនេប៉ាល់ ប៉ុន្តែវាថែមទាំងកើនឡើងនូវវិវាទដ៏ធំសម្បើមទៀតផង។ ធនធានដីធ្លីមិនគ្រាន់តែផ្តល់ឱកាសការងារច្រើនជាង ៨០ % នៃប្រជាជនសរុបក្នុងប្រទេសនោះទេ (ក្នុងវិស័យកសិកម្ម) ប៉ុន្តែ វាថែមទាំងបានផ្តល់ឱ្យមានវិវាទកើតឡើងដ៏សំបូរបែប[៨៩]។ អ្នកមានអំណាច នៅតាមតំបន់តែងតែប្រើប្រាស់ដីជាមធ្យោបាយដើម្បីរក្សាអំណាចក្នុងទំនាក់ទំនងមិនស្មើភាពនៅក្នុងភូមិ។ ស្រដៀងគ្នានេះដែរកសិករ និងសកម្មជនដីធ្លីក៏បានប្រើប្រាស់ដីធ្លីជាមធ្យោបាយ ក្នុងការផ្លាស់ប្តូរទំនាក់ទំនងសង្គមចំពោះវិសមភាពជាប់ទាក់ទងនឹងដីធ្លី។

វិវាទកើតឡើងនៅក្នុងសង្គមណាមួយដែលដីធ្លី គឺជាប្រភពសំខាន់សម្រាប់ការចិញ្ចឹមជីវិត និងជាប្រភពនៃអំណាច ឬជាកិត្យានុភាពផងដែរ។ វិវាទដីធ្លីនៅក្នុងសង្គមមួយបានជះឥទ្ធិពលដោយបរិបទសង្គម ដូចជាការរៀបចំរចនាសម្ព័ន្ធសង្គម (អាចំកំបាំងជាច្រើននៃវិវាទដីធ្លីក្នុងសង្គមសក្តិភូមិ) អន្តរកម្មគំរូ ដូចជាទំនាក់ទំនងនាយចៅហ្វាយ វិសមភាពរចនាសម្ព័ន្ធអំណាចដូចជាម្ចាស់ដី និង អ្នកគ្មានដី។ វិវាទដីធ្លីកើតឡើងតាមកម្រិតផ្សេងៗគ្នា ឧទាហរណ៍ វិវាទកើតនៅក្នុងរង្វង់គ្រួសារ និងគ្រួសារ រវាងសហគមន៍ និងសហគមន៍។ ជាមូលដ្ឋានការប្រើប្រាស់ និងគ្រប់គ្រងជារបៀបវារៈចម្បងនៃវិវាទដីធ្លីដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់ការរៀបចំនូវសិទ្ធិអចលនៈទ្រព្យនៅតាមតំបន់។ ដូច្នេះ សិទ្ធិលើអចលនៈទ្រព្យជាបញ្ហាស្នូលក្នុងវិវាទដីធ្លី។ ប្រជាជនទទួលបានសិទ្ធិលើដីធ្លីរបស់ពួកគេ ទោះជាតាមរយៈការប្រើប្រាស់ជាសមាគម ឬ ការអនុវត្តជាប្រពៃណី ឬ ទៅតាមច្បាប់។ តាមដំណើរការកែទម្រង់ដីធ្លីនៅប្រទេសនេប៉ាល់ វាមិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ គឺទំនាក់ទំនងរវាងម្ចាស់ដី និង កសិករមានលក្ខណៈប្រាកដនិយម។ ចំនួនដ៏ច្រើនលើសលុបនៃវិវាទដីធ្លីបានងើបឡើងនៅអំឡុងពេលផ្លាស់ប្តូរនយោបាយពោលគឺ នៅពេលដែលម្ចាស់ដីចុះខ្សោយ។ ដូច្នេះអ្នកជួលដី និង កសិករងើបឡើងប្រឆាំងនឹងការធ្វើនំឥតម្សៅដោយម្ចាស់ដី។

ដោយហេតុថា ការខិតខំប្រឹងប្រែងរបស់អ្នកជួលដី ដើម្បីជាប្រយោជន៍ដោយឥតសង្ស័យក្នុងការផ្លាស់ប្តូរទំនាក់ទំនងសង្គម។ គេសង្កេតឃើញថា វិវាទដីធ្លីមិនបានប្រែក្លាយទៅជាអំពើហិង្សាទេ គឺដោយសារមានភាពអត់ឱនរបស់ភាគីមានជម្លោះ។ ភាគីជម្លោះដីធ្លី មានទំនាក់ទំនងគ្នានៅក្នុងសង្គមរបស់ពួកគេមិនបានកាត់ផ្តាច់ឡើយ នេះដោយសារមានការពឹងអាស្រ័យគ្នាទៅវិញទៅមក។ ទំនាក់ទំនងទាំងនេះ បានជួយដល់ពួកគេយ៉ាងច្រើនដើម្បីនាំដល់ការចចារគ្នា។ ថ្វីបើវិវាទកើនឡើងច្រើនក៏ដោយ ក៏មានការស្រុះស្រួល និង ចុះសម្រុងគ្នាក្នុងសង្គមនាំដល់ជោគជ័យក្នុងភូមិ ហើយអាចទប់ស្កាត់វិវាទដីធ្លីមិនឱ្យប្រែក្លាយទៅជាកើតអំពើហិង្សាធំធេង។

[៨៩] Bishnu Raj Upreti: ***Understanding Land Conflicts: Some basic issues in Nepal***, Unpublished paper, Nepal, 2001, page2.

ដីមិនគ្រាន់តែជាមធ្យោបាយកាត់បន្ថយភាពក្រីក្រ ជានិមិត្តរូបនៃអំណាច និង កិត្យានុភាព ប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានន័យកំណត់នូវទំនាក់ទំនងសង្គម និង ជាហេតុនាំឱ្យសង្គមមានការផ្លាស់ប្តូរផងដែរ។ បើក្រឡេកមើលនយោបាយសេដ្ឋកិច្ច ធនធានដីនៅប្រទេសនេប៉ាល់គេអាចនិយាយបានថា ច្បាប់ និងគោលនយោបាយ មិនបានជោគជ័យក្នុងការធានាសិទ្ធិរបស់អ្នកជួលដី និងសន្តិសុខដីធ្លីដល់កសិករទេ។ ដីធ្លីគឺ ជាប្រភពចម្បងនៃជម្លោះ និង ជានិមិត្តរូបនៃរបបសក្តិភូមិ។ តែទោះជាយ៉ាងណា ដីធ្លីជាគ្រឹះនៃរចនាសម្ព័ន្ធ អំណាចមូលដ្ឋាន វាបានផ្លាស់ប្តូរគោលនយោបាយ និងកំណើននៃការរៀបចំអង្គការកសិករដើម្បីបង្កើតនូវសិទ្ធិរបស់ពួកគេ។ ការរៀបចំប្រព័ន្ធច្បាប់គ្រប់គ្រងដីធ្លីបានផ្តល់ផលប្រយោជន៍ដល់ប្រជាកសិករ និង ធានានូវសុវត្ថិភាពនៃការកាន់កាប់ និង បង្កើនផលិតភាពលើដីធ្លី។

ប្រទេសថៃក៏ជួបបញ្ហាដីធ្លីយ៉ាងធ្ងន់ធ្ងរនាពេលបច្ចុប្បន្ន បើទោះបីជាប្រទេសនេះមិនធ្លាប់ជួបនូវរបបអាណានិគមនិយមក៏ដោយ។ ការកែទម្រង់ដីធ្លីនៅប្រទេសថៃ បានកើតមានវិបត្តិចាប់តាំងពីពីរទសវត្សរ៍មុនមកម្លេះ។ ឧបសគ្គចំពោះការកែទម្រង់ដីធ្លី គឺកើតមានចំពោះដីកសិកម្ម និង ការអភិវឌ្ឍជនបទយ៉ាងហោចណាស់មានកត្តាបួន ដែលបានកើតឡើងប្រឈមមុខនឹងកំណែទម្រង់ដីធ្លីគឺៈ(ទី១) ការផ្ទេរសិទ្ធិកម្មសិទ្ធិ (ទី២)វិវាទកំណែទម្រង់ដីធ្លី (ទី៣) បញ្ហាការបែងចែកដីធ្លី និង (ទី៤) បញ្ហាការចុះអនុវត្ត[៩៥]។

កត្តាទី១កើតឡើងនៅឆ្នាំ១៩៧៥ នៅពេលដែលច្បាប់ដីធ្លីត្រូវដាក់ឱ្យប្រើប្រាស់ និងចូលជាធរមាន។ ច្បាប់នេះមានផលប៉ះពាល់ដល់វិស័យកសិកម្មចេញពីអត្រាទំនោរខ្ពស់ និងភាពគ្មានដីធ្លីនៅក្នុងតំបន់ទំនាបកណ្តាលនៃប្រទេសថៃ។ ក្រោយមានការគាបសង្កត់ធ្ងន់ធ្ងរ ទៅលើដីឯកជនបន្ទាប់មករដ្ឋាភិបាលថៃក៏បានយល់ជ្រួតជ្រាបអំពី បញ្ហាការរំលោភយកដីធ្លីជាច្រើនដែលជាដីរបស់រដ្ឋ ឬជាដីសាធារណៈ។ នៅពេលដែលមានការផ្ទេរសិទ្ធិលើដីរដ្ឋចេះតែបន្តទៅឱ្យឯកជនអាជ្ញាធរគ្រប់គ្រងដីធ្លីជួបការលំបាកទ្វេឡើងក្នុងការបែងចែកដីធ្លីទៅឱ្យអ្នកគ្មានដី និងទៅអ្នកជួលដី។ នៅចន្លោះរវាងឆ្នាំ១៩៩២ និង ឆ្នាំ១៩៩៣ គោលនយោបាយដីធ្លីជាតិ ដែលរដ្ឋាភិបាលបានធ្វើការប្រកាសនៅក្នុងសភាប្រទេសថៃនូវគម្រោងការរបស់រដ្ឋដែលមានបំណងផ្ទេរដីព្រៃជាច្រើនទៅឱ្យប្រជាកសិករ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏មិនអាចដោះស្រាយបានទាំងស្រុង ចំពោះវិបត្តិដីធ្លីដែលបានកើតឡើងដែរ។ ទាក់ទងវិវាទលើការកែទម្រង់វិញ ទោះបីជា នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៩៣ គណៈរដ្ឋមន្ត្រីបានផ្តល់នូវអនុសាសន៍ ដែលគាំទ្រគោលនយោបាយដីធ្លីរបស់រដ្ឋាភិបាលទៅលើការយកដីព្រៃធ្វើជាកម្មសិទ្ធិ ដើម្បីបែងចែកដីមួយចំនួនធំឱ្យទៅអ្នកគ្មានដីធ្លី ឬអ្នកជួលដីធ្លី បញ្ហាវិវាទគ្នានៅក្នុងរដ្ឋាភិបាលចេះតែបន្ត។ បើតាមច្បាប់ដីធ្លីរបស់ថៃ បរិមាណចំពោះការកាន់កាប់ដីធ្លីត្រូវបានបែងចែកយ៉ាងច្បាស់លាស់ ហើយបានអនុវត្តស្របច្បាប់ទៅលើប្រភេទដីទាំងអស់នៅក្នុងតំបន់កំណែទម្រង់។ ដោយទំនាស់ដីធ្លីនៅតែបន្ត ទោះបីជាមានអនុសាសន៍ជាដំណោះស្រាយពីរដ្ឋាភិបាល

[៩៥] សូមមើលនៅក្នុង <http://www/seameo.org/vl/landreform/ir6.html>.

ក៏ដោយ និង ដោយមានសម្ពាធពីសាធារណៈជន រដ្ឋាភិបាលថៃក៏បានកោះអញ្ជើញក្រុមប្រឹក្សារដ្ឋ ឬ ក្រុមប្រឹក្សាតុលាការឱ្យមកបំភ្លឺបញ្ហាទាំងឡាយដោយ គោរពតាមច្បាប់កំណែទម្រង់ដីធ្លី។

នៅប្រទេសថៃមានកម្មវិធីចុះបញ្ជី ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជាច្រើនសម្រាប់ប្រជាជន។ ក៏ប៉ុន្តែ កម្មវិធីទាំងនោះទទួលការរិះគន់ជាច្រើនពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន ។ ជាឧទាហរណ៍ ប្រជាជនបានទទួលវិញ្ញាបណ្ណបត្រលើដីដែលមិនទាំងដឹងថាតើដីនោះនៅទីណានោះទេ[៨៦]។ នៅក្នុងឆ្នាំ១៩៨០ រដ្ឋាភិបាលថៃ និង ធនាគារពិភពលោកបានចាប់ផ្តើមកម្មវិធីចុះបញ្ជីដីធ្លីដ៏ធំជាងគេទាំងអស់លើពិភពលោក[៨៧]។ ការចុះបញ្ជីនេះ ក៏មានការរិះគន់ដែរ គឺមិនបានដោះស្រាយដល់ប្រជាជនដែលកំពុងរស់នៅតំបន់ព្រៃឈើ ហើយពួកគេនៅតែមិនទទួលបានប័ណ្ណកម្មសិទ្ធិ[៨៨]។ គួររំលឹកដែរថាកាលពី ៤០ឆ្នាំមុន ប្រទេសថៃគ្របដណ្តប់ទៅដោយព្រៃឈើចំនួន ៤០ ភាគរយ តែនៅពេលបច្ចុប្បន្ននៅសល់តែ ២០ភាគរយ នៃផ្ទៃប្រទេស[៨៩]។

ការបែងចែកដីធ្លីនៅប្រទេសថៃ គឺដីដែលជាកម្មសិទ្ធិឯកជនត្រូវបានដោះដូរ ឬផ្ទេរពីម្ចាស់ដីទៅឱ្យម្ចាស់ជួលដី និង អ្នកមានកសិដ្ឋានតូចៗ។ ករណីនេះហើយដែលការបែងចែកដីដែលបានកើតឡើងពីចំណែកដីរបស់រដ្ឋដែលបានចាត់ទុកថាស្របច្បាប់ គឺត្រូវតែធ្វើតាមរយៈរដ្ឋាភិបាលពោលគឺការចែកដីពីរដ្ឋាភិបាលទៅឱ្យប្រជាកសិករ ក៏ប៉ុន្តែការអនុវត្តជាក់ស្តែង វាគ្រាន់តែជាទង្វើនៃការធ្វើឱ្យស្របច្បាប់ចំពោះបញ្ហាម្ចាស់កម្មសិទ្ធិម្នាក់ៗនៅក្នុងតំបន់រំលោភដីព្រៃដែលនៅក្នុងប្រទេសថៃ ដែលគេចាត់ទុកថា ជាកម្មសិទ្ធិរបស់រដ្ឋ[៩០]។ កសិករជាច្រើន នៅតែបន្តប្រពៃណីកាប់ឆ្ការរានព្រៃយកដីដោយខុសច្បាប់ដូចពីមុនដែរ។ ការបែងចែកជាដីឡូត៍តូចៗ ត្រូវបានអនុញ្ញាតឱ្យគ្រួសារជាច្រើន ហើយទំហំដីទៀតសោតធំជាងការកំណត់របស់ច្បាប់រដ្ឋ។ រីឯការសម្រេចចិត្តក្នុងសកម្មភាពធ្វើស្រែចំការ និង ការបែងចែកដីគឺអាស្រ័យលើមេគ្រួសារ។ ប្រជាពលរដ្ឋកម្របោះបង់ចោលដីធ្លីរបស់ពួកគេណាស់ ដូច្នេះហើយការបែងចែកដីធ្លីជាកត្តាសំខាន់ក្នុងការកែទម្រង់ដីធ្លី។

ទាក់ទងនឹងការអនុវត្តចំពោះការផ្តល់នូវតម្លៃដីធ្លី និង ការផ្ទេរសិទ្ធិលើដី រដ្ឋាភិបាលថៃបានបោះពុម្ពតារាងវាយតម្លៃដីធ្លីទៅតាមប្រភេទដីខុសៗគ្នា។ ការផ្តល់តម្លៃដីគឺ ផ្អែកទៅតាមតារាងដីធ្លីរបស់រដ្ឋ និងជាគោលចំពោះការសងជាសំណងជម្ងឺចិត្ត។ ចំណែកការផ្ទេរសិទ្ធិជាបញ្ហាសំខាន់ទាក់ទងនឹងការឱ្យតម្លៃដីដែលកើតឡើងក្នុងអំឡុងការផ្ទេរដីធ្លី។ ចំពោះតម្លៃដីវិញ វាមិនដូចគ្នានឹងតម្លៃដែលបានទិញនោះទេ។ តម្លៃដីថ្មីគឺ មិនឱ្យខ្ពស់ជាងតម្លៃទីផ្សារ ឬ ថោកជាងពេកទេ។ ក្នុងករណីតម្លៃដីកសិករ

---

[៨៦] Anneli Nordling: ***Environment and Human Rights in Thailand***, Interim Report for Forum Syd's Environment and Human Rights Study in the Mekong Region, Forum Syd, January 2005, page13.

[៨៧] Anneli Nordling: ***Environment and Human Rights in Thailand***, ibit. page13/ cited in Leonard & Narintarakul 2003.

[៨៨] ការចុះបញ្ជីដីធ្លីនៅថៃចំណាយពេលជិត ២០ឆ្នាំ និងប្រាក់កំចីពីធនាគារពិភពលោកចំនួន១៨៣.១ លានដុល្លារសហរដ្ឋអាមេរិក តាមបីតំណាក់កាល រហូតមកដល់ឆ្នាំ២០០៤ ប័ណ្ណចំនួន ១១.៦៥ លាន បានចែកជូនដល់ប្រជាជន (ស្បូន រីលៀម ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០០៣)។ កម្មវិធីចុះបញ្ជីដីធ្លីនេះក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ តែទីបញ្ចប់គឺគ្រាន់តែជាការផ្ទេរដី ដ៏ធំធេងនៅតាមជនបទពីអ្នកក្រទៅអ្នកមាន អ្នកវិនិយោគ អ្នកទិញដីទុកយកចំណេញ និងបង្កឱ្យរីករាលដាលទំនាស់ដីធ្លីនៅតំបន់ជនបទ។

[៨៩] Anneli Nordling: ***Environment and Human Rights in Thailand***-*op.cit.* page16.

[៩០] op.cit. page13.

ខ្ពស់ជាងតម្លៃទីផ្សារ គោលនយោបាយកំណែទម្រង់ដីរបស់រដ្ឋបានផ្តល់ប្រយោជន៍ដល់ប្រជាកសិករ មានន័យថា រដ្ឋទិញដីកសិករវិញក្នុងតម្លៃខ្ពស់ជាងតម្លៃទីផ្សារ។ ប្រជាជនថៃ ៨០០,០០០ គ្រួសារ ដែលពឹងផ្អែកលើផ្នែកកសិកម្មមានដីតិចតួចបំផុតក្នុង ឆ្នាំ២០០២ ហើយចំនួននេះបន្តកើនឡើង[៩១]។ ពួកគេទាំងនោះប្រឈមមុខនឹងការលក់ដីធ្លីដោយសារជំពាក់បំណុលគេយ៉ាងច្រើន។ ប្រជាជនចំនួន ១៥លាននាក់ គឺប្រហែលជា ២៣% នៃប្រជាជនសរុបមានចំណូលក្រោម២ដុល្លារអាមេរិកក្នុងមួយថ្ងៃ[៩២]។ ជារឿយៗ ពួកគេត្រូវបានលើកទឹកចិត្តឱ្យខ្ចីបុលដើម្បីបង្កើនការងារផលិតកម្មដែលមិនបានផលត្រឡប់មកវិញ។ ដីធ្លីត្រូវទិញដោយអ្នកមានកសិដ្ឋានធំៗ ដែលបានធ្វើឡើងជាច្រើនឆ្នាំមកហើយ ដែលអាចឱ្យគេប្រមូលដីពីទ្រង់ទ្រាយតូចប្រែក្លាយទៅធំ ។

ជារួមបញ្ហាដីធ្លីនៅប្រទេសថៃ ទោះជារដ្ឋាភិបាលខិតខំដោះស្រាយក៏នៅតែមានបញ្ហាកើតមានឡើងបន្តរហូតដល់សព្វថ្ងៃ។ ចំណុចសំខាន់ គឺជាប់ពាក់ព័ន្ធនឹងធន្ទះនយោបាយដែលមិនស្របគ្នា ឬស្ថានភាពមិននឹងនរ។ ការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកន្លងមក គឺគ្រាន់តែដោះស្រាយបញ្ហាដីមួយផ្នែកទៅឱ្យប្រជាកសិករ ជាពិសេស ក្នុងតំបន់ដែលរំលោភយកដីព្រៃរដ្ឋតែប៉ុណ្ណោះ។ បញ្ហានេះក៏ជាប់ទាក់ទងនឹងការយល់ដឹងនូវច្បាប់ដីធ្លីផងដែរ។

ប្រទេសទុយនីស៊ី ស្ថិតនៅទ្វីបអាហ្វ្រិកភាគខាងជើង ក្នុងចំណោមប្រទេសដែលកាន់សាសនាអ៊ីស្លាម។ ក្រោយពីទទួលបានឯករាជ្យពីប្រទេសបារាំងនៅក្នុងឆ្នាំ១៩៥៦ រដ្ឋាភិបាលបានចាត់ចែងរបៀបគ្រប់គ្រងដីធ្លីតាម ២ របៀប៖ (ទី១) លុបចោលនូវកម្មសិទ្ធិអចលនៈទ្រព្យជាដីធ្លី និងប្រគល់ដីទៅឱ្យមូលនិធិសាសនា គ្រួសារនានា និង បុគ្គលទាំងឡាយជាសម្បទាន។ (ទី២)ប្រែក្លាយទ្រព្យសម្បត្តិទាំងអស់ ដែលកាន់កាប់ដោយជនជាតិបារាំង មកជាទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់តាមរយៈច្បាប់ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ១៩៦៤។ តាមរយៈច្បាប់នេះ ធ្វើឱ្យរដ្ឋាភិបាលមានឥទ្ធិពលយ៉ាងខ្លាំងលើទ្រព្យសម្បត្តិដូចជាដីធ្លី។ គិតមកត្រឹមដើម ឆ្នាំ១៩៧០ រដ្ឋបានគ្រប់គ្រងផ្ទៃដីចំនួន៦៥% ជាដីកសិកម្មបើប្រៀបធៀបជាមួយដីឯកជនដែលមាន ចំនួនតែ ៣៥% នេះបើផ្អែកតាមរបាយការណ៍របស់ក្រសួងកសិកម្មរបស់ប្រទេសទុយនីស៊ី។

គេសង្កេតឃើញថា មានការកេងប្រវ័ញ្ច និង បន្លំយកដីរដ្ឋដោយខុសច្បាប់ក្នុងការបែងចែកដីធ្លីហើយបន្តកើតមានដដែលៗ។ មានហេតុផលយ៉ាងតិចចំនួនបី ទាក់ទងអំពើក្នុងការបន្លំយកដីរដ្ឋក្រោយឆ្នាំ ១៩៧០ (ទី១) ការមិនអើពើរបស់រដ្ឋាភិបាលក្នុងការចុះបញ្ជីដីឱ្យបានត្រឹមត្រូវ (ទី២) ហាមមិនឱ្យធ្វើការត្រួតពិនិត្យចំពោះការផ្ទេរដីធ្វើឡើងដោយអភិបាលខេត្ត (ទី៣) ការកាន់កាប់ដីមួយចំនួនមិនសមស្រម។ តាមរយៈហេតុផលទាំងបីនេះ ការទទួលបានដីរដ្ឋដោយខុសច្បាប់ បានបង្ហាញពីភាពមិនច្បាស់លាស់ក្នុងការកាន់កាប់ដីដែលមិនបានចុះបញ្ជីឱ្យបានត្រឹមត្រូវ[៩៣] និង បណ្តាលឱ្យមាន

---

[៩១] Anneli Nordling: ***Environment and Human Rights in Thailand***, op.cit page12/ cited in Leonard & Narintarakul 2003.

[៩២] World Bank, East Asia: ***Country Analysis Paper***, Thailand National Change Strategic Workshop, Boeng Kok ,17-18 June 2008, , page2.

[៩៣] ការស្ទង់មតិឆ្នាំ១៩៧០ ឃើញថា ក្នុងចំណោមដីទំហំ ១, ៥៨៧ ហិកតា ក្នុងតំបន់ដាច់ស្រយាលចំនួន ១០ កន្លែង មាន៦៨ ភាគរយ នៃដីឡូត៍មិនបានចុះបញ្ជីដីធ្លីទេ។

ទំនាស់ដីធ្លីដ៏ធំនៅប្រទេសនេះ។ ភាពខ្សោយនៃច្បាប់ដីធ្លី និង ឥទ្ធិពលប្រវត្តិសាស្ត្រនៃការគ្រប់គ្រងដីរដ្ឋនៅក្រោយសម័យអាណានិគមនិយមបារាំង ជាមួយនឹងការបម្រែបម្រួលនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាឧបសគ្គសំខាន់ផងដែរ។ ការកេងបន្លំយកដីរដ្ឋដោយមិនខ្លាចច្បាប់ និង ការរួមគំនិតគ្នារបស់មន្ត្រីពុករលួយមួយចំនួនបង្កើតជាបញ្ហាដល់ការគ្រប់គ្រងដីធ្លីរបស់រដ្ឋ។ អ្នកមានឥទ្ធិពល និងមានអំណាចក្នុងជួររដ្ឋាភិបាលបានឆ្លៀងឱកាសកេងយកចំណេញតាមរយៈការដោះដូរ និង លក់ទិញដីធ្លីធ្វើឱ្យសង្គមកើតវឹកវរ និង អ្នកក្របាត់បង់ដីធ្លី និង លំនៅឋាន។

តាមច្បាប់ដីធ្លីប្រទេសទុយនីស៊ី ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ១៩៦៤ មាត្រា ២៨ និងមាត្រា ៣៨ ចែងថា ពលរដ្ឋមានសិទ្ធិកាន់កាប់នូវដីទំនេរជាឯកជនបាន និង ផ្តល់សិទ្ធិឱ្យធ្វើជាម្ចាស់ដីយ៉ាងសមស្របដល់ប្រជាជនដែលគ្មានដី[៩៤]។ ដីដែលនៅទំនេរមិនទាន់បានចុះបញ្ជី និងតាមរយៈសាក្សី និងភស្តុតាងចំពោះអ្នកដែលបានកាន់កាប់លើដីនោះត្រូវបានទទួលដោយស្របច្បាប់ អ្នកទាំងនោះមានដូចជា អង្គការសាសនា និងបុគ្គលមួយចំនួន ដែលជាទូទៅគេសង្កេតឃើញថា ជាទម្រង់ការបែងចែកដីធ្លីដោយបន្លំ។ បញ្ហាដីធ្លីនៅប្រទេសទុយនីស៊ី ដោយសារច្បាប់ដីធ្លីមានការបកស្រាយផ្សេងៗគ្នា ក្នុងការអនុវត្ត ហើយអត្ថន័យរបស់ច្បាប់មិនច្បាស់លាស់បង្កឱ្យជនឆក់ឱកាសមួយចំនួនកេងយកចំណេញលើប្រជាពលរដ្ឋ និងសង្គមទាំងមូល។ ការផ្តល់សម្បទានដីធ្លីទៅឱ្យអង្គការចាត់តាំងណាមួយ ក្នុងករណីមានការផ្លាស់ប្តូររបបគ្រប់គ្រង និង បណ្តាលឱ្យជួបវិបត្តិដីធ្លីដោយសារក្រុមមនុស្សមួយចំនួនដែលមានកម្មសិទ្ធិដីច្រើនមហិមា និង ក្រុមមហាជនដែលគ្មានដី និងមានដីតិចតួច។ បញ្ហាទាំងនេះវាអាចកើតមានឡើង មិនថានៅតែប្រទេសទុយនីស៊ីប៉ុណ្ណោះទេ ប៉ុន្តែ វាក៏អាចកើតមានឡើងនៅប្រទេសកំពុងអភិវឌ្ឍន៍នានាផងដែរ។

សរុបមកយើងឃើញថា ការបន្លំយកដីរដ្ឋធ្វើកម្មសិទ្ធិឯកជន របស់ខ្លួនតាមរយៈការធ្វើសម្បទានសម្រាប់អភិវឌ្ឍន៍បណ្តាលឱ្យមានវិបត្តិសង្គម។ គម្រោងអភិវឌ្ឍន៍ នៅតាមជនបទរបស់ក្រុមហ៊ុនក្នុងស្រុក និង បរទេសបណ្តាលឱ្យដីឡើងថ្លៃ និងជាមុខសញ្ញានៃការផ្លាស់ប្តូរលំនៅឋាន និងការបាត់បង់ដីធ្លីផលិតកម្មរបស់ប្រជាជន។ រីឯទីក្រុងកើតឡើងនូវទីក្រុងរណប ផ្ទះល្វែង សណ្ឋាគារ និង សំណង់ពាណិជ្ជកម្ម បណ្តាលឱ្យមានការខ្វះខាតដីសម្រាប់អ្នកនៅទីក្រុង និង ធ្វើឱ្យប៉ះពាល់សុខុមាលភាពរបស់ប្រជាជននៅទីក្រុង ជាពិសេស ជនក្រីក្រងាយរងគ្រោះ។ សំណង់ជនក្រីក្រនៅទីក្រុងកើនឡើង និង វិសមភាពសង្គមបង្កឱ្យអសន្តិសុខជាដើម។ ឆ្លងតាមការលើកឡើងជាបន្តបន្ទាប់ខាងលើឃើញថា វិវាទដីធ្លីនៅតែកើតមានឡើងមិនចេះចប់។ បញ្ហាទាំងនេះ មិនត្រឹមតែទើបនឹងកើតពេលបច្ចុប្បន្ននេះទេ វាកើតឡើងតាំងពីយូរយាណាស់មកហើយ គឺចាប់តាំងពីមនុស្សចេះបង្កើតបានជាសហគមន៍ ជាសង្គម រហូតដល់មានការបង្កើតជារដ្ឋដែលមានប្រព័ន្ធដឹកនាំនយោបាយផ្សេងៗគ្នា។ ចាប់តាំងពីសម័យរបបជាម្ចាស់ និងទាសករ របបសក្តិភូមិ របបមូលធននិយម របបផ្តាច់ការ របបសង្គម

---

[៩៤] ប៉ែន សុផល: *ការគ្រប់គ្រងដីធ្លីប្រកបដោយចីរភាព និងសមធម៌* -ដ.ឯ.ម-ទំព័រ១៧- នៅក្នុង Morched Chabbi: The Private Sub-developer: New form of Land Developer in Tunis in The City by Pacone, M..(2002), (ed), London: Routledge, Vol. 5, P. 397.

និយម និង របបប្រជាធិបតេយ្យបច្ចុប្បន្ន រាល់របបនីមួយៗគឺមានទម្រង់បែបបទដឹកនាំផ្សេងៗគ្នា និងមានគោលនយោបាយគ្រប់គ្រងខុសៗគ្នា។

មានតែឈរលើគោលការណ៍រួមមួយ ដើម្បីរក្សាការពារសន្តិសុខសង្គម រក្សាសណ្តាប់ធ្នាប់សាធារណៈ ការពារផលប្រយោជន៍សាធារណៈ និង ការពារជាតិទេ ទើបធ្វើឱ្យសង្គមមានលក្ខណៈកាន់តែល្អប្រសើរ។ ប្រទេសកំពុងអភិវឌ្ឍន៍រហូតមកដល់ពេលនេះ មិនទាន់មានប្រទេសណាមួយទទួលបានសេចក្តីសុខសុភមង្គលតាមរយៈការដឹកនាំដ៏ល្អប្រពៃចំពោះប្រទេសរបស់ខ្លួននោះទេ បញ្ហាជាច្រើននៅតែកើតឡើងជាបន្តបន្ទាប់។ ជាពិសេសប្រទេសដែលចាកចេញផុតពីនឹមអាណានិគមនិយម មិនថាស្ថិតនៅក្រោមអាណានិគមបារាំង ឬ អង់គ្លេស បញ្ហាជម្លោះដីធ្លីនៅតែកើតមាន ដូចជាប្រទេសស៊ីមបាវ៉េនៅអាហ្វ្រិកជាដើម ដែលប្រទេសនេះបានរួចផុតអាណានិគមនិយមអង់គ្លេសនៅតែមានជម្លោះដីធ្លីដ៏ធ្ងន់ធ្ងរ។

ដោយឡែកវិវាទដីធ្លីនៅកម្ពុជាយើងអាចបែងចែកជាពីរបែបធំៗ គឺវិវាទពាក់ព័ន្ធលើដីឯកជន និងវិវាទពាក់ព័ន្ធលើដីសាធារណៈរបស់រដ្ឋ។ យើងនឹងធ្វើការសិក្សាជាបន្តបន្ទាប់នៅក្នុងនិក្ខេបបទនេះ។

## ១.៣.២ វិវាទដីធ្លីពាក់ព័ន្ធនឹងបុគ្គលឯកជន

ការបែងចែកចំពោះវិវាទដីធ្លី ដែលមាននៅក្នុងរបាយការណ៍របស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ដែលបានធ្វើការសិក្សាលើខេត្ត ក្រុងចំនួនប្រាំមួយបានបែងចែកវិវាទដីធ្លីដោយផ្អែកលើអត្តសញ្ញាណនៃភាគីវិវាទ។ វិវាទដែលទាក់ទងនឹងបុគ្គលឯកជន និង ឯកជន យើងនឹងធ្វើការសិក្សាជាបន្តបន្ទាប់ទៅលើវិវាទ ដែលកើតឡើងរវាងអ្នកជិតខាង វិវាទនៅក្នុងរង្វង់គ្រួសារ វិវាទកើតឡើងជាមួយនឹងម្ចាស់បំណុល និងវិវាទរវាងអ្នកភូមិ និងក្រុមហ៊ុន ឬបុគ្គលឯកជន[៥៥] ។

វិវាទមួយចំនួនកើតឡើងដូចជាប្រជាពលរដ្ឋសាមញ្ញបិទផ្លូវសាធារណៈ និង ខ្លះទៀតសង់ផ្ទះរំលោភយកដីចំណីផ្លូវធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ធ្វើឱ្យប៉ះពាល់ប្រជាពលរដ្ឋផ្សេងទៀតដែលធ្លាប់ប្រើប្រាស់ផ្លូវរួមដែលបណ្តាលឱ្យច្រកផ្លូវនោះតូចចង្អៀតមានការលំបាកធ្វើដំណើរចេញចូល។ ឧទាហរណ៍[៥៦] ប្រជាពលរដ្ឋប្រមាណជាង ៤៥គ្រួសារ ដែលមានទីលំនៅក្នុងក្រុមទី៧ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ បាននាំគ្នាផ្តិតមេដៃប្តឹងតវ៉ា សុំឱ្យអាជ្ញាធរខណ្ឌជួយអន្តរាគមន៍ទៅលើប្រជាពលរដ្ឋមួយគ្រួសារដែលបានសង់ផ្ទះរំលោភយកដីចំណីផ្លូវមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន។

### ក វិវាទដីធ្លីនៅក្នុងរង្វង់គ្រួសារ

ជាទំនាស់អំពីសាច់ញាតិ ឬ បងប្អូន ដែលបែកគ្នាក្នុងរបបប៉ុលពត ហើយពេលជួបគ្នាដោយសារមានផ្ទះធំ ហើយស្ងាត់ផងក៏ហៅបងប្អូនមករស់នៅជាមួយព្រោះផ្ទះជារបស់រដ្ឋ និង ធ្វើបញ្ជីគ្រួសារ

---

[៥៥] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់: ***កសាងស្ថាប័នយុត្តិធម៌ ?*** -ដ.ឯ.ម-ទំព័រ១៥-១៦។

[៥៦] DAP: ***ការរំលោភយកដីចំណីផ្លូវ*** សូមមើល <http://www.dap-news.com/index.php?option=com_content&view=article&id=2227%3Aefvipthrme lapykdicmnipouvsafarns-rbcablrdaenamknabtwggacjafrxnecatkargtecj&catid=1%3Adap-news&Ite mid=75&lang=en>. accessed dated 2 August 2009-AM.

ផ្សេងគ្នាជាពីគ្រួសារដោយចែកដី ឬ ឱ្យខ្ចីដីធ្វើស្រែបង្កបង្កើនផលក៏មាន នៅពេលផ្ទះឡើងថ្លៃក៏កើតរឿងឈ្លោះប្រកែកគ្នា។ លិខិតខ្ចីក៏គ្មាន ឬ លិខិតឱ្យស្នាក់នៅក៏គ្មាន ដោយសំអាងថាបងប្អូន ហើយខ្លួនក៏បានស្នាក់នៅ ឬ កាន់កាប់ដែលគូភាគីម្ខាងៗយកអនុក្រឹត្យ[៩៧] ដូចគ្នាមកអនុវត្តន៏ដោយយល់ថាយុត្តិធម៌ចំពោះខ្លួនគេម្នាក់ៗ។ តែបើតុលាការកាត់ឱ្យភាគីណាមួយចាញ់ ក៏កើតមានគំនុំរហូតដល់មានការកាប់សម្លាប់គ្នាក៏មាន។

វិវាទដីធ្លីទាក់ទងនឹងដីមត៌កដែលបងប្អូនបង្កើត និង សមាជិកផ្សេងៗក្នុងគ្រួសារតែមួយដណ្តើមគ្នា។ នេះក៏ព្រោះតែការពុំបានយល់ដឹងច្បាស់អំពីបញ្ហាមត៌ក។ ម៉្យាងទៀត ភាគីតែងតែគិតថាការធ្វើបណ្តាំមត៌កអាចនាំឱ្យមានការបែកបាក់សាមគ្គីនៅក្នុងគ្រួសារ នៅពេលដែលមានការបែងចែកចំណែកមត៌កមិនស្មើគ្នា។ ការរៀបចំបន្ទមត៌កមានលក្ខណៈខុសគ្នាពីមួយកន្លែងទៅមួយកន្លែង និងផ្អែកទៅតាមការសម្រេចចិត្ត និង ការចចាររបស់ឪពុកម្តាយក្នុងចំណោមសមាជិកគ្រួសារ។ ប្រជាពលរដ្ឋខ្មែរភាគច្រើន ពុំសូវយកចិត្តទុកដាក់ក្នុងការធ្វើបណ្តាំមត៌កជាលាយល័ក្ខណ៍អក្សរនោះទេ។ អនក្ខរភាពក៏ជាមូលហេតុចម្បងមួយផងដែរនៃការមិនធ្វើបណ្តាំមត៌ក។ ឧទាហរណ៍ជាក់ស្តែងគ្រួសារកសិករជនបទនៅតែផ្ទេរមត៌កទៅតាមទំនៀមទម្លាប់របស់ពួកគេដូចករណីខាងក្រោម៖

> "លោក អៀង យី មានកូន៥ រស់នៅភូមិគោកត្រាច ឃុំកូនត្នោត ស្រុកពួក។ អំឡុងពេលរដ្ឋបានបែងចែកដី កាលនោះកូនគាត់ពីនាក់ទទួលបានចំណែកដីនៅពេលនោះដែរ។ គ្រួសារទទួលដីសរុបចំនួន ០,២០ ហិកតា។ លើសពីនេះ គាត់បានទិញដីបន្ថែមចំនួន២ហិកតា។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ កូនទីមួយទទួលមត៌កដីចំនួន ០,៨០ហិកតា និងកូនទីពីរទទួលដីបានចំនួន០,៦០ហិកតា។ ឪពុកម្តាយគឺជាអ្នកធ្វើសេចក្តីសម្រេចចិត្តចំពោះការផ្ទេរមត៌កនេះ ហើយការផ្ទេរមត៌កនេះ មិនធ្វើតាមកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរទេ"[៩៨]។

ទោះបីជាច្បាប់ពុំបានតម្រូវឱ្យមានបណ្តាំមត៌កត្រូវតែធ្វើ ជាលាយលក្ខណ៍អក្សរក៏ដោយ ប៉ុន្តែដើម្បីជៀសវាងវិវាទដណ្តើមដីមត៌ករវាងសហព័ទ្ធនៃទាយាទ មតកជនគួរតែរៀបចំឱ្យមានបណ្តាំមត៌កជាលាយល័ក្ខណ៍អក្សរឱ្យបានត្រឹមត្រូវមុនពេលដែលខ្លួនស្លាប់។ ជាគោលការណ៍មត៌កត្រូវបង្កើតអនុភាពចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព[៩៩]។

វិវាទនៃការបែងចែកដីមត៌ក ជាបញ្ហាមួយដែលពិបាកក្នុងការដោះស្រាយហើយតុលាការមានការលំបាកក្នុងការកំណត់ឱ្យបានច្បាស់ នូវសុចន្ទៈចុងក្រោយរបស់មតកជន។ វិវាទមួយទៀតដែលកើតមានច្រើនដែរ គឺវិវាទដែលកើតនៅលើដីដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់បុគ្គលណាម្នាក់ តែត្រូវបានប្រើប្រាស់ដោយសាច់ញាតិ ឬ អ្នកដទៃផ្សេងទៀតនៃបុគ្គលនោះ។ ឧទាហរណ៍នៅស្រុក

---

[៩៧] អនុក្រឹត្យលេខ២៥ អនក្រ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩ ***ស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា*** ៖ មាត្រា២។

[៩៨] Pel Sokha, Pierre-Yeves Le Meur, Sam Vitou, and all: : ***Land Transactions in Rural Cambodia: A Synthesis of Findings from Research on Appropriation and Derived Rights to Land-*** op.cit. page 31.

[៩៩] ព្រះរាជក្រមលេខ នស រកម ១២០៧ ០៣០ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ស្តីពី ***ក្រមរដ្ឋប្បវេណី*** មាត្រា១១៩៤ (ច្បាប់គ្រោងដាក់ឱ្យអនុវត្តនៅចុងឆ្នាំ២០១១)។

ស្អាងគ្រួសារមួយដែលមកពីភូមិដទៃបានសុំប្រើប្រាស់ដីរបស់គ្រួសារមួយទៀត ដែលមិនមែនជាសាច់ញាតិលោហិតនឹងគ្នា[១០០]។ ក្រោយពីបានដាំដំណាំលើដីមួយរយៈមកគ្រួសារសុំដីនោះបានរៀបចំសំណុំបែបបទសុំកាន់កាប់ដីដោយផ្អែកលើការដាំដុះរបស់ខ្លួននៅលើដីនោះ។

**ខ វិវាទរវាងអ្នកជិតខាង**

តាមទំនៀមទម្លាប់ប្រពៃណី ការរស់នៅជាប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋតែងប្រើប្រាស់របង ឬបង្គោលព្រំសម្រាប់បញ្ជាក់ពីទំហំដីដែលខ្លួនមាន។ ការប្រើប្រាស់ និង ការកាន់កាប់ជាកម្មសិទ្ធិហើយការអនុវត្តសិទ្ធិលើដីធ្លីទៅតាមទម្លាប់របស់មូលដ្ឋាន ដែលប្រជាពលរដ្ឋនៅក្នុងសហគមន៍បានទទួលស្គាល់។ នៅក្នុងករណីខ្លះទៀត ព្រំប្រទល់រិតតែមើលមិនឃើញច្បាស់ទៅទៀត ប៉ុន្តែព្រំប្រទល់នេះមានការដឹងឮ ពីអ្នកនៅភូមិផងរបងជាមួយ។ ដូចនេះកំណត់ថា សិទ្ធិប្រើប្រាស់ដីនៅកន្លែងណាមួយមិនបានកំណត់ឱ្យបានជាក់លាក់ល្អទេ ពោលគឺគ្រាន់តែមានការដឹងឮពីសំណាក់អ្នកជិតខាងប៉ុណ្ណោះ។ ជាកត្តាសត្យានុម័តទម្លាប់នៃការកំណត់ព្រំប្រទល់ដី មិនច្បាស់លាស់រវាងអ្នកជិតខាងរបៀបនេះ អាចនឹងបង្កឱ្យមានទំនាស់ ឬ វិវាទ។ វិវាទដីធ្លីរវាងអ្នកជិតខាងបែបនេះ តែងតែកើតមានជាញឹកញាប់នៅក្នុងសង្គម ជាពិសេស នៅតាមតំបន់ដែលតម្លៃដីមានការកើនឡើងខ្ពស់។

គេសង្កេតឃើញទំនាស់លើការប្រើប្រាស់ ឬកាន់កាប់ដីជាទូទៅ ត្រូវបានដោះស្រាយវិវាទតាមទំនៀមទម្លាប់ភូមិ[១០១] តាមរយៈការចចាររវាងអ្នកជិតខាងដោយផ្អែកទៅតាមប្រពៃណី និង ទំនៀមទម្លាប់ក្នុងសហគមន៍ដោយមានការអនុគ្រោះគ្នាទៅវិញទៅមក និង មានការប៉ះប៉ូវខ្លះតាមការឯកភាពគ្នារវាងភាគីពាក់ព័ន្ធ។ ក្នុងករណីខ្លះ ប្រធានភូមិ ឬមេឃុំ អាចជួយសម្រុះសម្រួលឱ្យមានការព្រមព្រៀងគ្នាបាននៅពេលណាដែលភាគីទាំងសងខាងមិនឯកភាពគ្នា ។

វិវាទព្រំដីរវាងអ្នកជិតខាងបានប្រែប្រួលចរិតរបស់វានៅពេលដែលដីឡើងថ្លៃ និងមានការលក់ដូរច្រើនជាងមុន។ ឧទាហរណ៍ នៅក្នុងពេលដែលដីឡើងថ្លៃ ប្រជាពលរដ្ឋមួយចំនួនព្យាយាមទាមទារយកដីឱ្យបានច្រើនជាងមុន ដោយធ្វើការបង្ខិតបង្គោលរបងចូលទៅក្នុងដីរបស់អ្នកជិតខាង។ មានករណីខ្លះទៀត ប្រជាពលរដ្ឋបានដាក់ពាក្យសុំប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីជាន់គ្នា។ ការអះអាងកម្មសិទ្ធិជាន់គ្នាគឺជាបញ្ហាធំមួយនៅក្នុងបរិបទនៃការលក់ដូរដី។ ជាពិសេស វិវាទព្រំដីរវាងអ្នកជិតខាងកើតមានឡើងនៅពេលដែលការលក់ដីទៅឱ្យអ្នកនៅក្រៅសហគមន៍ចេះតែកើនឡើង។ កាលពីមុនអ្នកជិតខាងគ្នានៅក្នុងភូមិតែមួយពឹងផ្អែកលើរបៀបរបបប្រពៃណីដើម្បីដោះស្រាយវិវាទ។ ប៉ុន្តែឥឡូវនេះជាញឹកញាប់ការដោះស្រាយវិវាទមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋានផង និង ពីប្រជាពលរដ្ឋក្រៅមូលដ្ឋានផង។ វិវាទជាច្រើនបានកើតឡើងនៅពេលដែលអ្នកមកពីក្រៅសហគមន៍ទិញដី ហើយធ្វើរបង

[១០០] So Sovannarith and All: ***Social Assessment of Land In Cambodia: A Field Study***, Working Paper No 20, Cambodia Development Resource Institute, Phnom Penh, 2001, page 34.

[១០១] ស្ទីវិន អែម អូស្ទើមើឡឺរ ៖ ***ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ*** ប្រទេសកម្ពុជា East-West Management Institute -EWMI, New York, JSRC Printing House ឆ្នាំ២០០៩ ទំព័រ៣។

ដើម្បីពង្រឹងកម្មសិទ្ធិលើដីរបស់ខ្លួន។ វិវាទអាចកើតឡើងពីព្រំដីជាក់ស្តែង និងការបិទផ្លូវដើរសាធារណៈ ហើយវិវាទក៏កើតមានផងដែរ នៅពេលដែលភាគីម្ខាងធ្វើការរុះរើរបងមួយចំណែកចេញក្នុងករណីនេះ ការបោះរបងដើម្បីបង្កើត ឬបញ្ជាក់សិទ្ធិលើដីណាមួយជាមូលហេតុនៃវិវាទផង និង ជាមធ្យោបាយសម្រាប់ដោះស្រាយ ឬជៀសវាងវិវាទក្នុងពេលអនាគតផង ។

**គ វិវាទជាមួយម្ចាស់បំណុល**

កង្វះខាតក្នុងជីវភាពបានបង្ខំឱ្យប្រជាពលរដ្ឋទីទាល់ក្រខ្ចីបុលប្រាក់កាសពីឈ្មួញដើម្បីយកទៅប្រកបរបររកស៊ីដើម្បីចិញ្ចឹមជីវិត។ ជារឿយៗគេសង្កេតឃើញថា ការខ្ចីបុលរបៀបនេះមានការប្រាក់ខ្ពស់ ហើយតម្រូវឱ្យប្រជាពលរដ្ឋក្រីក្រយកដីទៅដាក់បញ្ចាំ។ តាមការសិក្សាស្រាវជ្រាវ សកម្មភាពឥណទានមិនសមស្របជាមូលហេតុបណ្តាលឱ្យប្រជាពលរដ្ឋបាត់បង់ដីធ្លីចំនួន២៦%[១០២] ករណីមួយចំនួនក្រោយមកកូនបំណុលក្លាយជាអ្នកសុំទាន។ ការអធិប្បាយខាងក្រោមជាឧទាហរណ៍បង្ហាញអំពីរឿងរ៉ាវពិតចំពោះមូលហេតុដែលស្ត្រីម្នាក់បានក្លាយជាអ្នកសុំទាន៖

> "មូលហេតុដែលយើងមកសុំទាននៅក្រុងភ្នំពេញ គឺមានបំណងរកប្រាក់ដើម្បីលោះដីទំហំ០,៤ ហិកតា ពីម្ចាស់បំណុលដែលខ្ញុំបានបញ្ចាំដីនោះឱ្យគេ ក្នុងតម្លៃ៤ជីមាស(ប្រហែល២០០ដុល្លាសហរដ្ឋអាមេរិក)។ មូលហេតុនៃកម្ចីគឺដើម្បីយកទៅព្យាបាលប្តីរបស់ខ្ញុំដែលកំពុងមានជម្ងឺ។ ឥឡូវម្ចាស់បំណុលកំពុងធ្វើស្រែលើដីរបស់ពួកយើង។ គេបានប្រាប់យើងថា នៅពេលយើងមានប្រាក់គឺអាចលោះយកដីនោះមកកាន់កាប់វិញ។ រាល់ឆ្នាំការចិញ្ចឹមជីវិតរបស់យើងពឹងផ្អែកលើផលស្រូវដែលប្រមូលក្នុងរដូវច្រូតកាត់ ហើយខ្ញុំពឹងពាក់ទៅលើប្តីរបស់ខ្ញុំដែលធ្វើការជាកម្មករសំណង់។ ប៉ុន្តែគាត់ឈឺ ហើយគាត់បាត់បង់ការងារ និង ឥឡូវយើងមិនអាចរកអ្វីបានទេ"[១០៣]។

ជាញឹកញាប់ដើម្បីអាចបង្វិលការប្រាក់សងម្ចាស់បំណុលវិញបាន កូនបំណុលត្រូវខិតខំធ្វើការយ៉ាងខ្លាំង នៅពេលខ្លះលើសពីកម្លាំងខ្លួនក៏មាន។ ការណ៍នេះ ធ្វើឱ្យពួកគេធ្លាក់ខ្លួនឈឺ ម៉្យាងដោយការខំប្រឹងធ្វើការខ្លាំងពេក ម៉្យាងទៀត ដោយកង្វះអាហាររូបត្ថម្ភដែលមានជីវជាតិគ្រប់គ្រាន់។ ជាងនេះទៅទៀតប្រព័ន្ធសេវាសាធារណៈ ជាពិសេស ខាងផ្នែកសុខាភិបាលនៅទន់ខ្សោយនៅឡើយពោលគឺ គ្មានគុណភាពហើយថែមទាំងត្រូវចំណាយប្រាក់ច្រើនទៀតផង។ ដូច្នេះ សភាពការណ៍បង្ខំឱ្យប្រជាពលរដ្ឋទទួលយកសេវាសុខាភិបាលផ្នែកឯកជន ដែលមានតម្លៃខ្ពស់ហួសប្រមាណ បើប្រៀបធៀបទៅនឹងជីវភាព និង ចំណូលប្រចាំថ្ងៃរបស់ពួកគេ។ ការប្រើប្រាស់សេវាសុខាភិបាលរបៀបនេះ ធ្វើឱ្យប្រជាពល

---

[១០២] រ៉ូប៊ីន ប៊ីដុលៈ *តើដីធ្លីត្រូវបាត់ទៅណា?* ការបង្ហាញឱ្យកាន់តែឃើញពីភាពក្រីក្រ របាយការណ៍ស្តីពីការស្រាវជ្រាវនូវភាពគ្មានដីធ្លី និងការអភិវឌ្ឍ អុកស្វាមអង់គ្លេស គម្រោងសិក្សាដីធ្លីនៅកម្ពុជា លេខ៤ ភ្នំពេញ ឆ្នាំ ២០០០ ទំព័រ៣០។

[១០៣] Women Agenda for Change-WAC: ***I come to back in the city because...***Phnom Penh, 2002, page 50

រដ្ឋទីទាល់ក្របង្ខំចិត្តយកដីស្រែ ឬ ចំការ ដ៏តិចតួចដែលនៅសេសសល់យកទៅ បញ្ចាំ ឬ លក់ ដើម្បីព្យាបាលជំងឺ។

លទ្ធផលនៃជំងឺ និងភាពគ្មានដីធ្លីបណ្តាលឱ្យគ្រួសារ៦០% ជំពាក់បំណុលគេបន្ទាប់ពីឈឺ[១០៤]។ បន្ទុកថ្មីក៏បានកើតមានឡើង ហើយបានបន្ថែមទម្ងន់ទៅលើបន្ទុកចាស់ដែលមានស្រាប់ ពោលគឺប្រជាពលរដ្ឋទីទាល់ក្រទាំងនោះ មិនមានលទ្ធភាពសងបំណុលចាស់ពេលធ្លាក់ខ្លួនឈឺ និង ក្លាយជាកូនបំណុលនៃម្ចាស់បំណុលដដែល ឬ ថ្មីផ្សេងទៀត។ វិវាទក៏កើតឡើងនៅពេលដែលម្ចាស់បំណុលទាមទារឱ្យប្រជាពលរដ្ឋទីទាល់ក្រដែលជាកូនបំណុលទាំងនោះ ផ្ទេរនូវកម្មសិទ្ធិដីទាំងមូល ឬ មួយចំណែកមកឱ្យខ្លួន[១០៥]។

**ឃ វិវាទរវាងប្រជាពលរដ្ឋ និងក្រុមហ៊ុន**

ក្នុងចន្លោះឆ្នាំ១៩៩៣ និងឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលបានផ្តល់ដីសម្បទានជាងមួយភាគបីនៃដីធ្លីដែលឱ្យដីជាតិល្អជាងគេទៅឱ្យក្រុមហ៊ុនឯកជននានា ដើម្បីអភិវឌ្ឍន៍ពាណិជ្ជកម្មក្នុងនោះរួមមានៈ តំបន់មានរ៉ែ កន្លែងទេសចរណ៍ និង នេសាទ។ រាជរដ្ឋាភិបាលក៏បានប្រគល់ដីឱ្យយោធាដើម្បីធ្វើការអភិវឌ្ឍ។ ដីសម្បទានដែលផ្តល់ទៅឱ្យក្រុមហ៊ុនឯកជនមានចំនួន៧១ ក្រុមហ៊ុនក្នុងឆ្នាំ២០០៨ គឺចំនួន ២២៥,០៩០ហិកតា[១០៦]។ ប្រជាពលរដ្ឋច្រើនជាង១០,០០០គ្រួសារដែលបានទាមទារ តវ៉ាពីការប៉ះពាល់ មកលើដីធ្លីរបស់ពួកគេ ដោយសារការផ្តល់ដីសម្បទានសេដ្ឋកិច្ច ដែលមិនមានការសិក្សាពីផលប៉ះពាល់ខាងសង្គមឱ្យបានត្រឹមត្រូវល្អ ហើយមានប្រជាពលរដ្ឋមួយចំនួនធំទៀតពុំទាន់បានដឹងពីផលប៉ះពាល់ នៃដីសម្បទានសេដ្ឋកិច្ចទៅលើដីពួកគេនៅឡើយទេ។ ព្រោះក្រុមហ៊ុនខ្លះពុំទាន់បានចុះទៅធ្វើអាជីវកម្មនៅលើដីទាំងនោះនៅឡើយ[១០៧] ។ តាមរយៈការសិក្សាឆ្នាំ២០០៨ របស់អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ការទាមទារដី ចំនួន៤៧,២៧ភាគរយ[១០៨] ទាក់ទិននឹងដីសម្បទានសេដ្ឋកិច្ចដែលមានគម្រោងធ្វើចំការដំណាំ និង ដំណាំកសិឧស្សាហកម្មផ្សេងៗ។ ឧទាហរណ៍ក្នុងស្រុកភ្នំស្រួចប្រជាពលរដ្ឋមួយក្រុមមាន១០៨គ្រួសារ បានរាយការណ៍ថា ខ្លួនបាត់បង់ដីដោយយោធារំលោភយកដីពួកគាត់ទៅលក់ឱ្យក្រុមហ៊ុនកូរ៉េមួយសម្រាប់ដាំដំណាំកសិកម្ម[១០៩]។ ក្រុមប្រជាពលរដ្ឋរួមទាំងប្រធានភូមិបានដាក់ពាក្យបណ្តឹងទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ដែលបណ្តឹង

---

[១០៤] រ៉ូប៊ីន ប៊ីដុលៈ ***តើដីធ្លីត្រូវបាត់ទៅណា?*** -ដ.ឯ.ម- ទំព័រ២៣។

[១០៥] So Sovannarith and All: ***Social Assessment of Land in Cambodia: a Field Study***. op.cit. p 34.

[១០៦] លេខាធិការដ្ឋានទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិមនុស្សប្រចាំកម្ពុជាៈ ***សម្បទានដីគោលដៅសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា*** ទស្សនវិស័យខាងសិទ្ធិមនុស្សៈ ភ្នំពេញ ឆ្នាំ២០០៤ ទំព័រ៤-៥។

[១០៧] សមាគមអាដហុកៈ ***ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៨*** លេខ៨ ឆ្នាំទី៨ ចេញផ្សាយខែមករា ឆ្នាំ២០០៩ ទំព័រ២។

[១០៨] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាៈ ***ដី និង ជីវិត*** ព្រឹត្តិប័ត្រប្រចាំត្រីមាស បណ្តាញសកម្មភាពដីធ្លីដើម្បីអភិវឌ្ឍន៍ឆ្នាំ ទី១ លេខ ១០ ខែតុលា-ធ្នូ ឆ្នាំ២០០៨ ទំព័រ៩។

[១០៩] So Sovannarith and All: ***Social Assessment of Land in Cambodia: a Field Study.*** op.cit. p 35.

ត្រូវបានបញ្ជូន បន្តទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត បន្ទាប់មកបន្តទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ នៅខេត្តរតនៈគិរី ប្រជាពលរដ្ឋក្នុង៣ភូមិ នៃស្រុកបរកែវបានដាក់ពាក្យបណ្តឹងទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុកលើវិវាទដី ដោយបានចោទថា ភាគីម្ខាងបានរត់ការធ្វើឯកសារឱ្យបុគ្គលម្នាក់ទៀតក្នុងបំណងយកដីរបស់ពួកគាត់តាមមធ្យោបាយក្លែងបន្លំ[១១០]។ ឧទាហរណ៍មួយចំនួនបានបង្ហាញ និង បញ្ជាក់ឱ្យឃើញច្បាស់ពីវិវាទដីធ្លីដែលតែងតែកើតឡើងរវាងអ្នកភូមិ និងក្រុមហ៊ុន ឬ បុគ្គលឯកជន (ដែលអាចជាមន្ត្រីមានឋានៈខ្ពស់)។ ក្នុងករណីវិវាទរបៀបនេះ ប្រជាពលរដ្ឋនៅតាមសហគមន៍ច្រើនតែជាអ្នកទទួលរងគ្រោះ ជួនកាលដោយការរំលោភបំពានរបស់ក្រុមហ៊ុនឯកជន។ ពេលខ្លះប្រជាពលរដ្ឋព្រមទទួលយកនូវសំណងប៉ះប៉ូវដើម្បីដោះស្រាយវិវាទ។ ពេលខ្លះទៀត ប្រជាពលរដ្ឋត្រូវបាត់បង់ដីដោយគ្មានសំណងអ្វីឡើយ។ វិវាទដីធ្លី មិនត្រឹមតែពាក់ព័ន្ធទៅនឹងបុគ្គលឯកជនប៉ុណ្ណោះទេ វាក៏ទាក់ទងទៅនឹងអាជ្ញាធររដ្ឋផងដែរ ។

## ១.៣.៣ វិវាទពាក់ព័ន្ធនឹងអាជ្ញាធរ

### ក វិវាទរវាងអ្នកភូមិ និងអាជ្ញាធរមូលដ្ឋាន

ការចូលកាន់កាប់ដីដោយកងកម្លាំងប្រដាប់អាវុធ ដោយយោងតាមតម្រូវការក្នុងកាលៈទេសៈមានសង្គ្រាមប្រជាពលរដ្ឋត្រូវបានកងកម្លាំងប្រដាប់អាវុធ ឬ ករណីខ្លះដោយអាជ្ញាធរមូលដ្ឋានយកដីប្រជាពលរដ្ឋ ដែលកំពុងបង្កបង្កើនផលធ្វើជាទីតាំងឈរជើង ឬ ធ្វើជាទីស្នាក់ការ តែក្រោយមកត្រូវប្តូរទីតាំងដោយមិនបានប្រគល់ដីឱ្យប្រជាពលរដ្ឋ ដែលធ្វើឱ្យប្រជាពលរដ្ឋចោទប្រកាន់ថា យកដីនោះទៅលក់ ឬ ចែកគ្នាជាហេតុកើតមានទំនាស់ដីធ្លី[១១១]។ ផ្អែកតាមឯកសារស្រាវជ្រាវឯករាជ្យជាច្រើនដែលបានរកឃើញស្រដៀងៗគ្នា ប្រជាពលរដ្ឋដែលរងគ្រោះដោយសារវិវាទដីធ្លី គឺបានចោទប្រកាន់ទៅលើអាជ្ញាធរ ដែលវាក្លាយទៅជារឿងសាមញ្ញ ដូចជាទស្សនៈមួយបានលើកឡើងដូចខាងក្រោម៖

> "គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ជាង៧៥% នៃអ្នកដែលត្រូវចោទប្រកាន់ថា បានយកដីគេគឺជាអាជ្ញាធរមានឋានៈខ្ពស់"[១១២]។

វិវាទភាគច្រើនដែលពាក់ព័ន្ធជាមួយអាជ្ញាធរ ដែលបានបណ្តេញប្រជាពលរដ្ឋចេញពីដីណាមួយដោយអះអាងថាជាដីរដ្ឋ[១១៣]។ នៅតំបន់ជាច្រើនមានដីបម្រុងដែលគេចាត់ទុកជាដីសមូហភាព។ ដីបម្រុងនេះជួនកាល គេបែងចែកទៅឱ្យអតីតយុទ្ធជនដែលមកពីសមរភូមិ ឬ យុទ្ធជនពិការ។ ពេលដីឡើងថ្លៃត្រូវបានទារយកមកវិញ ដោយសំអាងថាជាដីរបស់ភូមិ ឃុំ មានកងកម្លាំងប្រដាប់អាវុធជួយខាងរដ្ឋអំណាចដើម្បីដកហូតទីតាំងនោះធ្វើជារបស់ពួកគេ។ មួយផ្នែកទៀត ដីដែលធ្វើការបែងចែក

---

[១១០] op.cit. P 36.
[១១១] op.cit. P 39
[១១២] Oxfam Great Britain: ***Workshop Reports, Revised Land Law, Approaches to Reduce Landlessness***, Institutional Cooperation about Resolving Land Disputes in Cambodia, Volume 3, Cambodia land Study Project, Phnom Penh, 1999, page 13.
[១១៣] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់: ***កសាងស្ថាប័នយុត្តិធម៌?*** .ដ.ឯ.ម. ទំព័រ១៦។

ដល់យុទ្ធជនបានពីដីបម្រុងដែលនៅសល់ពីដីសមូហភាព រដ្ឋអំណាចភូមិ ឃុំ យកជាកម្មសិទ្ធិ និង បានបែងចែកគ្នា ដើម្បីជាប្រយោជន៍បក្សពួកខ្លួន និង បំភាន់ភ្នែកសមាជិកតូចតាចដោយគេដាក់ឈ្មោះកូនចៅ សាច់ញាតិ បងប្អូនជាម្ចាស់កម្មសិទ្ធិ។

ចំណុចនៃវិវាទទាក់ទងនឹងអាជ្ញាធរនេះ គឺកើតមានឡើងរវាងអ្នកភូមិ និង រដ្ឋអំណាចមូលដ្ឋាន ។ ចំណែកកងកម្លាំងប្រដាប់អាវុធ ជាពិសេស យោធាក៏ត្រូវប្រជាពលរដ្ឋប្តឹងថា បានយកដីរបស់ពួកគាត់ដែរ។ ក្រៅពីនេះក៏មានរឿងកើតឡើងផងដែរ នៅពេលដែលអាជ្ញាធរផ្សេងៗទៀតដែលមាននិន្នាការនយោបាយផ្សេងៗគ្នា ដើម្បីប្រើប្រាស់យុត្តាធិការរបស់ខ្លួនចំពោះវិវាទដីនោះ។ ឧទាហរណ៍[១១៤] អតីតមេខ្មែរក្រហមមានការអះអាងរបស់ខ្លួន ហើយដែលការអះអាងនោះ មិនត្រូវបានទទួលស្គាល់ដោយប្រព័ន្ធរដ្ឋបាលធម្មតា។ ករណីខ្លះទៀត វិវាទកើតឡើងរវាងអ្នកភូមិ និង រដ្ឋបាលព្រៃឈើដែលចោទរដ្ឋបាលព្រៃឈើរំលោភយកដីដែលជាកម្មសិទ្ធិរបស់ពួកគាត់។ ករណីប្រជាពលរដ្ឋ ចំនួន៣០០គ្រួសារ នៅភូមិទួលគគីរ ស្រុកមណ្ឌលសីមា ខេត្តកោះកុង[១១៥]។ ប្រជាពលរដ្ឋប្តឹងដល់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យជួយអន្តរាគមន៍ដល់ពួកគាត់ ។ ករណីវិវាទស្រដៀងគ្នាមួយទៀត រវាងមន្ត្រីផ្នែកសង្គមកិច្ច និង ប្រជាពលរដ្ឋ។ "មន្ត្រីសង្គមកិច្ចចុះមកបោះបង្គោល ហើយថាជាដីរបស់រដ្ឋ និង បញ្ជាឱ្យប្រជាពលរដ្ឋចាកចេញពីដីនោះ"[១១៦]។ ករណីវិវាទនៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម។

វិវាទដីធ្លីដែលទាក់ទងនឹងអ្នកភូមិ និង រដ្ឋអំណាចមូលដ្ឋានមានច្រើនរូបភាព។ រូបភាពទី១៖ វិវាទកើតមានឡើងនៅពេលដែលប្រធានភូមិ និងប្រធានឃុំបានលក់ដីភូមិទៅឱ្យក្រុមហ៊ុន ឬបុគ្គលនៅក្រៅសហគមន៍ ឧទាហរណ៍នៅខេត្តកំពត មានរបាយការណ៍ដែលថា មេឃុំ និងប្រធានភូមិបានលក់ដីភូមិដោយគ្មានការពិគ្រោះយោបល់ជាមួយអ្នកភូមិ ឬការផ្តល់សំណងប៉ះប៉ូវអ្វីឡើយ[១១៧]។ នៅក្នុងករណីនេះរដ្ឋអំណាចមូលដ្ឋានទទួលផលចំណេញផ្ទាល់ពីការលក់ ចំណែកឯ អ្នកភូមិត្រូវបាត់បង់លទ្ធភាពប្រើប្រាស់ដីភូមិ។ ករណីខ្លះទៀតវិវាទកើតចេញពីការចោទប្រកាន់ពាក់ព័ន្ធគណបក្សនយោបាយធ្វើឡើងដោយប្រធានភូមិ បង្ខំឱ្យប្រជាពលរដ្ឋផ្តិតមេដៃប្រគល់ដីឱ្យគេ បើមិនគាំទ្រគណបក្សរបស់ខ្លួន។ ឧទាហរណ៍ ប្រជាពលរដ្ឋមួយគ្រួសារនៅភូមិអង្រ្គង ខេត្តបាត់ដំបង បានចោទប្រកាន់មេភូមិអំពីការ

---

[១១៤] -ដ.ឯ.ម.- ទំព័រ១៦។

[១១៥] DAP: *រដ្ឋបាលព្រៃឈើរំលោភយកដីប្រជាពលរដ្ឋ* សូមមើល < http://www.dapnews.com/index.php?option= com_content&view=article&id=2296%3Arbcacnrbman cag-330rkysar-enaxmutylkkir-smusemtcnay krdaemrnti-hun-esn-cyygntrakmn&catid=1%3Adap news&Itemid =75&lang=en.>. Accessed dated 12 August 2009, AM.

[១១៦] RFA: *មន្ត្រីសង្គមកិច្ចរំលោភយកដីប្រជាពលរដ្ឋ* សូមមើល <http://www.rfa.org/khmer/indepth/villagers-protest-land-grabbing-in-kgcham-0311200904> Accessed dated 3/23/2009-PM.

[១១៧] So Sovannarith and All: ***Social Assessment of Land in Cambodia: a Field Study-*** op.cit. page 35.

បង្ខំឱ្យផ្ដិតមេដៃប្រគល់ដីស្រែ ទំហំប្រាំហិកតា ទៅឱ្យមេភូមិកាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៩[១១៨]។ រូបភាពទី២ ៖ វិវាទបានកើតនៅពេលប្រជាពលរដ្ឋ ចាប់យកដីសាធារណៈដែលរដ្ឋអំណាចមូលដ្ឋាន ឬ អាជ្ញាធរស្រុកបានអះអាងថាជាកម្មសិទ្ធិរបស់រដ្ឋ ។ ឧទាហរណ៍ នៅស្រុកស្អាង ខេត្តកណ្ដាល វិវាទមួយបានកើតឡើងទាក់ទងនឹងជនមាតុភូមិនិវត្តន៍មួយក្រុម ដែលកាលពីឆ្នាំ១៩៩២ បានទៅតាំងទីលំនៅតាមមាត់ព្រែកដែលត្រូវបានចាត់ទុកជាដីសាធារណៈដោយរដ្ឋអំណាចមូលដ្ឋាន។ ករណីនេះមន្ត្រីស្រុកបានបញ្ជាឱ្យនគរបាលមូលដ្ឋានដេញជនមាតុភូមិនិវត្តន៍ចេញ ព្រោះគេបានចាត់ទុកថាតាំងទីលំនៅដោយខុសច្បាប់នៅលើដីវិវាទ។ បញ្ហាបែបនេះកាន់តែស្មុគស្មាញនៅពេលដែលព្រំប្រទល់រវាងភូមិ និង ការគ្រប់គ្រងដីសាធារណៈនៅក្នុងសហគមន៍ មិនត្រូវបានកំណត់ឱ្យបានច្បាស់លាស់។

**ខ វិវាទពាក់ព័ន្ធសមត្ថកិច្ចមូលដ្ឋាន**

ករណីវិវាទមួយចំនួន ភាគីដាក់ពាក្យបណ្ដឹងទៅអាជ្ញាធរជាច្រើនផ្សេងៗគ្នាដោយមិនយកចិត្តទុកដាក់អំពីនីតិវិធីច្បាប់។ ពេលខ្លះអាជ្ញាធរមានសមត្ថកិច្ចដោះស្រាយរឿង ខ្វះការសម្របសម្រួលគ្នាក៏បណ្ដាលកើតវិវាទ។ នៅស្រុកភ្នំស្រួចខេត្តកំពង់ស្ពឺ ប្រធានភូមិបានកសាងសំណុំបែបបទសុំប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីក្នុងភូមិមួយផ្សេងទៀត។ នៅខេត្តរតនគិរីប្រជាពលរដ្ឋក្នុងភូមិមួយបានទាមទារយកដីកំពុងប្រើប្រាស់ ដោយអ្នកភូមិក្នុងភូមិផ្សេងដែលស្ថិតក្នុងស្រុកមួយផ្សេងទៀត។ ភាគីម្ខាងអះអាងថា ពួកគេបានប្រើប្រាស់ដីនេះតាំងពីសម័យរបបប៉ុលពត។ ភាគីម្ខាង បានដាក់ពាក្យបណ្ដឹងទៅអាជ្ញាធរថ្នាក់ស្រុក ចំណែកភាគីម្ខាងទៀត ធ្វើការតវ៉ាទៅអាជ្ញាធរខេត្ត[១១៩]។ ករណីខ្លះបណ្ដឹងនៅក្នុងដៃរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ឬគណៈកម្មការសុរិយោដីមិនទាន់បានដោះស្រាយផងស្រាប់តែតុលាការទទួលបណ្ដឹងដដែលពីភាគីម្ខាងទៀត ហើយចាត់វិធានការដោះស្រាយមុន។ ចំណាត់ការនេះ វាខុសទៅនឹងប្រកាសអន្តរក្រសួង អំពីការកំណត់ភារកិច្ចរវាងតុលាការ និង គណៈកម្មការសុរិយោដី គឺតុលាការដោះស្រាយលើវិវាទទាំងឡាយណា ដែលដីនោះមានប័ណ្ណសំគាល់សិទ្ធិចេញដោយរដ្ឋបាលសុរិយោដី[១២០]។ ការណ៍នេះធ្វើឱ្យអ្នកសង្កេតរឿងវិវាទដីធ្លីមានការសង្ស័យថាតុលាការមានភាពលំអៀងពាក់ព័ន្ធនឹងផលប្រយោជន៍។

ករណីទំនាស់ដីធ្លីនៅភូមិ១ ឃុំទំនប់រលកថ្មី ខេត្តព្រះសីហនុ ដែលភាគីម្ខាងជាជនសាមញ្ញជាមួយនឹងអាជីវករលើដី ចំនួន៦០ហិកតា។ តុលាការខេត្តបានចាប់ខ្លួនបុរសបួននាក់ដែលអ្នកទាំងបួនត្រូវបានតុលាការចោទប្រកាន់ពីបទប្រើអំពើហិង្សាលើម្ចាស់អចលនទ្រព្យ និង ញុះញង់ឱ្យប្រព្រឹត្តបទល្មើស។ ករណីវិវាទនេះ ត្រូវបានគណៈកម្មការសុរិយោដីថ្នាក់ជាតិ និង អាជ្ញាធរមូលដ្ឋានបាន

---

[១១៨] RFA: *មេភូមិបង្ខំឱ្យប្រជាពលរដ្ឋផ្ដិតមេដៃប្រគល់ដីស្រែ* សូមលើល <http://www.rfa.org/khmer/indepth/bbang-villagers-accused-village-chief-03062009230011>. Accessed dated 3/23/2009-PM.

[១១៩] So Sovannarith and All: ***Social Assessment of Land in Cambodia: a Field Study*** op.cit. page 35.

[១២០] ប្រកាសអន្តរក្រសួង: លេខ០២ ប្រករ ០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ***ស្ដីពី ការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដី*** ៖ ប្រការ១។

ដោះស្រាយចប់ហើយ តែតុលាការបែជា កោះហៅប្រជាពលរដ្ឋយកទៅឃុំក្នុងពន្ធនាគារទៅវិញ។ ករណីទាំងនេះបង្ហាញឱ្យឃើញពីភាពមិនច្បាស់លាស់ នៃការកំណត់ដែនសមត្ថកិច្ចរវាងរដ្ឋបាល និង តុលាការដែលជាប្រភពនៃវិវាទដែនសមត្ថកិច្ចនៅមូលដ្ឋានព្រមទាំងជាឧបសគ្គដល់ការដោះស្រាយវិវាទ ទាំងនេះទៀតផង ។

**គ វិវាទពាក់ព័ន្ធនឹងអង្គភាពយោធា**

រឿងមួយដែលលេចធ្លោជាងគេបំផុត គឺការកាន់កាប់ដីដោយយោធា នៅពេលមានសង្គ្រាម ជាមួយខ្មែរក្រហម។ រាជរដ្ឋាភិបាលបានបញ្ជាឱ្យមេបញ្ជាការយោធាក្នុងតំបន់ រកមើលដីសម្រាប់ការតាំង ទីលំនៅសម្រាប់ទាហានរំសាយ។ កិច្ចការនេះ ត្រូវបានអនុវត្តដោយមេបញ្ជាការយោធាតាមរយៈការ បង្កើតតំបន់អភិវឌ្ឍន៍ធំៗសម្រាប់ទាហានទាំងនោះ ដោយមិនបានទទួលនូវការយល់ព្រមពីម្ចាស់ដើម នៃ ដីនោះទេ។ តាមរបាយការណ៍របស់មន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទថា ចំនួនប្រជាពលរដ្ឋបាត់បង់ ឬគ្មាន ដីធ្លី មានដល់ទៅ ៣០,០០០នាក់ នៅក្នុងខេត្តបន្ទាយមានជ័យទាំងមូល។ ដីធ្លីរបស់ប្រជាពលរដ្ឋមួយ ចំនួនដែលបានបាត់បង់ដោយសារទាហានរំលោភយក[១២១]។ ជាក់ស្តែងនៅក្នុងសិក្ខាសាលាមួយទាក់ទង ការដោះស្រាយវិវាទដីធ្លី នាយទាហានម្នាក់ដែលជាសិក្ខាកាមបានលើកឡើង ដូចខាងក្រោម៖

"មានកម្លាំងប្រដាប់អាវុធខ្លះ គូសផែនទីយកដីតែម្តង។ បញ្ហាដីធ្លីបើទុកយូរនឹងក្លាយជាសង្គ្រាម ដីធ្លី គួរមានការសហការគ្នាចាប់ពីថ្នាក់លើដល់ថ្នាក់ក្រោម"[១២២]។

ប្រជាពលរដ្ឋមួយចំនួនបានបង្ខំឱ្យយោធាប្រគល់ដី ដែលបានខ្ចីយកទៅធ្វើសំណង់យោធា ក្នុង ពេលសង្គ្រាម និងដីដែលនៅសេសសល់ពីសំណង់យោធាមកឱ្យពួកគេវិញ ពីព្រោះសន្តិសុខប្រទេសបាន ប្រសើរឡើងហើយ។ យោធាភូមិភាគ៤ បានស្នើសុំដីមួយកន្លែងដើម្បីសាងសង់បន្ទាយ រីឯបញ្ជាការ យោធាខេត្ត ក៏បានស្នើសុំដីមួយកន្លែងដើម្បីសាងសង់តំបន់អភិវឌ្ឍន៍សម្រាប់យោធារំសាយនៅក្នុងស្រុក អង្គជុំ ខេត្តសៀមរាប។ ទីកន្លែងណាដែលគេគិតថា ជាដីទំនេរ ទោះជាពេលខ្លះមានជាប់ពាក់ព័ន្ធនឹងដី ប្រជាពលរដ្ឋក៏ដោយ វាផ្តល់ឱកាសច្រើនសម្រាប់យោធាក្នុងការចាប់យកដីនោះ។ ដូចដែលឯកសាររបស់ លោក ស្សុន រីលៀម ឆ្នាំ១៩៩៩ បានសរសេរថា នៅខេត្តសៀមរាបគ្មានផែនទីកំណត់ព្រំដែនដី របស់យោធាទេ[១២៣]។ វិវាទដីធ្លីពាក់ព័ន្ធការរំលោភដោយយោធាមាន៣០% នៅខេត្តសៀមរាប[១២៤] ។

ក្រោយពេលដែលខ្មែរក្រហមធ្វើសមាហរណកម្មក្នុងឆ្នាំ១៩៩៧ សន្តិភាព និង សន្តិសុខបាន កើតឡើង ប៉ុន្តែ ខាងយោធានៅតែបន្តគ្រប់គ្រងលើតំបន់នោះដដែល។ វិវាទដីធ្លីរវាងប្រជាពលរដ្ឋ មូលដ្ឋាន និងយោធា កើតមានឡើងនៅពេលដែលប្រជាពលរដ្ឋចាប់ផ្តើមដាំដុះនៅលើដីដែលទុកចោល ឱ្យនៅទំនេរ។ ដូចជាករណីមួយពាក់ព័ន្ធនឹងដីប្រហែល១០ហិកតា ដែលប្រជាពលរដ្ឋ ៤០គ្រួសារ

---

[១២១] ស្សុន រីលៀម: ***ជំលោះកម្មសិទ្ធិដីធ្លីនៅកម្ពុជា*** ការសិក្សាស្តីអំពី សមត្ថភាពដោះស្រាយទំនាស់ដីធ្លី នៅ ៥ ខេត្ត គម្រោងសិក្សាដីធ្លីនៅកម្ពុជា អុកស្វាម ភ្នំពេញ ឆ្នាំ២០០០ ទំព័រ១០។

[១២២] Oxfam Great Britain: ***Workshop Reports, Revised Land Law, Approaches to Reduce Landlessness***, op.cit. page 71.

[១២៣] op.cit. page 22.

[១២៤] op.cit. page 26

អះអាងថា ជារបស់ខ្លួនដីនេះត្រូវទុកចោលឱ្យនៅទំនេរចាប់តាំងពីឆ្នាំ១៩៩៥។ រឿងមួយទៀតនៅក្នុងខេត្តកំពង់ស្ពឺ អ្នកភូមិបានទាមទារយកដីដែលយោធាកំពុងប្រើប្រាស់សម្រាប់ហ្វឹកហ្វឺនបាញ់កាំភ្លើងធំ តែគណៈកម្មការដោះស្រាយបាតុភាពដីធ្លីខេត្តបានសម្រេចប្រគល់ដីទៅឱ្យយោធា[១២៥]។ វិវាទមួយប្រភេទទៀត គឺទាហានក្នុងឋានៈជាបុគ្គលឯកជន បានទាមទារយកដីដែលគ្រប់គ្រងដោយអង្គភាពយោធា។ ករណីនេះអង្គភាពយោធាបានប្រាប់សមាជិកទាហានទាំងនោះថា ពួកគេរួមទាំងក្រុមគ្រួសារត្រូវប្រគល់ដីដែលខ្លួនបានតាំងទីលំនៅត្រឡប់មកវិញក្នុងពេលអនាគត។ ទាហានជាបុគ្គល តាំងខ្លួនប្ដឹងទៅអាជ្ញាធរមូលដ្ឋានដើម្បីយកដីនោះធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ប៉ុន្តែ អាជ្ញាធរបានបញ្ជាក់មកវិញថាខ្លួនគ្មានសមត្ថកិច្ចដោះស្រាយលើដីធ្លីដែលត្រួតត្រាដោយយោធានោះទេ ។

## ១.៤ មូលហេតុនៃវិវាទដីធ្លី

មូលហេតុនៃវិវាទដីធ្លីកើតឡើងដោយសារកត្តា ប្រវត្តិសាស្ត្រ នយោបាយ សង្គម និងសេដ្ឋកិច្ច ដែលក្នុងនោះរួមមានកង្វះលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងដីធ្លី កំណើនប្រជាពលរដ្ឋ កំណើនសេដ្ឋកិច្ច និង តម្រូវការដីធ្លីកើនឡើង[១២៦]។ តាមការយល់ឃើញរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី គឺថាបញ្ហាទំនាស់ដីធ្លីនៅតែបន្តកើតមាននេះបានកើតចេញពីការមិនយល់ច្បាប់ជាពិសេស កម្រិតនៃទណ្ឌកម្មដែលមានចែងក្នុងទោសបញ្ញត្តិនៃច្បាប់នីមួយៗ[១២៧]។ ទោះបីជាយ៉ាងណា វាមានកត្តារួមផ្សំជាច្រើនទៀត ដែលបណ្ដាលឱ្យកើតមានវិវាទដីធ្លី។ ផ្អែកតាមអ្នកជំនាញផ្នែកដីធ្លីនៅបស្ចិមប្រទេស លោក Shaun Williams បានលើកឡើងថា៖

> "រួមផ្សំដោយច្បាប់ភូមិបាលគ្មានប្រសិទ្ធភាព ការចាប់ផ្ដើមទីផ្សារសេរីមិនបានល្អ និងការធ្វើឱ្យទៅជាឯកជនូបនីយកម្មលក់ដុំនូវអ្វីដែលជាធនធានធ្លាប់បានប្រើប្រាស់ពីមុនមក ដូចជា ព្រៃឈើ និងតំបន់លិចទឹកដែលបណ្ដាលឱ្យភាពគ្មានដីធ្លីនៅជនបទបានកើនឡើង២០% នៃប្រជាពលរដ្ឋនៅតាមជនបទ។ ជម្លោះដីធ្លីដែលកើតឡើងពីការរំលោភបំពានដោយអំណាច និងដោយសារការគ្មានផែនទីប្រព័ន្ធសុរិយោដី កំពុងបង្អាក់ដំណើរការតុលាការ និងបណ្ដាលឱ្យមានបញ្ហាប្របូកប្របល់កើតឡើងឥតឈប់ឈរ"[១២៨]។

នៅពេលទទួលបានសន្តិភាពដីកាន់តែមានហាងឆេង ធ្វើឱ្យការចាប់ដីលក់ក្លាយទៅជាមុខរបរងាយស្រួលប្រមូលប្រាក់ធ្វើឱ្យទំនាស់ដីធ្លីកាន់តែមានភាពស្មុគស្មាញ ហើយកន្លែងខ្លះឈានទៅដល់ការ

---

[១២៥] So Sovannarith and All: ***Social Assessment of Land in Cambodia: a Field Study***, op.cit, page 35.

[១២៦] អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីៈ ***កម្រងសំណួរ-ចំម្លើយពាក់ព័ន្ធនឹងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មការសុរិយោដី*** ភ្នំពេញ ឆ្នាំ២០០៧ ទំព័រ៤។

[១២៧] អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីៈ ***ស្វែងយល់អំពីទោសបញ្ញត្តិ ស្ដីពី បទល្មើសពាក់ព័ន្ធនឹងច្បាប់ភូមិបាល ច្បាប់ស្ដីពីព្រៃឈើ ច្បាប់ស្ដីពីជលផល និងច្បាប់ ស្ដីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ*** ភ្នំពេញ ឆ្នាំ២០០៧ ទំព័រ x។

[១២៨] Oxfam Great Britain: ***Workshop Report, Revised Land Law, Approaches to reducing landlessness institutional cooperation about resolving land disputes in Cambodia, 1999***, Volume III, , page 68.

ដោះស្រាយដោយការបង្ហូរឈាមទៀតផង។ ដោយសារដីធ្លី ជាទ្រព្យសម្បត្តិដ៏មានតម្លៃតែមួយគត់សម្រាប់ប្រជាពលរដ្ឋខ្មែរភាគច្រើនលើសលុប ហេតុនេះ នៅពេលដីរបស់ពួកគេត្រូវបាត់បង់ដោយការរំលោភបំពានឬ ដោយប្រការណាមួយនោះមានន័យថា មធ្យោបាយរបស់ពួកគាត់ត្រូវបានដកហូត។ នេះគឺជាស្ថានភាពទាល់ច្រកមួយមិនថាអ្នកណាម្នាក់ឡើយ ហើយកម្រិតប្រតិកម្ម គឺមិនអាចប៉ាន់ស្មានបាន។

ក្នុងសុន្ទរកថាមួយនាសិក្ខាសាលានៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអំពាវនាវក្នុងន័យ ប្រគល់ដីឱ្យរាស្ត្រវិញ ប្រសិនបើនោះជាទំនាស់រវាងរាស្ត្រ និងអាជ្ញាធរ[១២៩]។ បន្ទាប់ពីប្រសាសន៍របស់ប្រមុខដឹកនាំប្រទេសមក ក្រុមអ្នកសង្កេតការណ៍បានធ្វើការកត់សំគាល់ថា ក្រោយពេលនោះភ្លាម ការតវ៉ាអំពីទំនាស់បញ្ហាដីធ្លី ដែលមានស្រាប់បានឈានដល់កម្រិតពុះកញ្ជ្រោល ស្ទើរគ្រប់ទីកន្លែង។ ប្រជារាស្ត្របាននាំគ្នាជាក្រុមៗមកកាន់មន្ទីរ ព្រឹទ្ធសភា រដ្ឋសភា ព្រះបរមរាជវាំង ក្រសួងមហាផ្ទៃ ដើម្បីទាមទារការបាត់បងដីធ្លីរបស់ពួកគេ។ តែទោះបីជាយ៉ាងណាក៏ដោយ អ្វីៗដែលកើតឡើង គឺសុទ្ធតែមានមូលហេតុរបស់វា។ ទោះយ៉ាងណា វិវាទដីធ្លីទាំងអស់ដែលបង្កើតជាបញ្ហាចាក់ស្រេះក្នុងសង្គមកម្ពុជា ក៏មានមូលហេតុរបស់វាផ្ទាល់ដែរ។ វិវាទដីធ្លីអាចបណ្តាលមកពីមូលហេតុច្រើនយ៉ាង តែមូលហេតុចម្បងគឺទាក់ទងទៅនឹងកង្វះសុវត្ថិភាពក្នុងការកាន់កាប់ដី និងកង្វះការអនុវត្តលិខិតបទដ្ឋានគតិយុត្តឱ្យបានត្រឹមត្រូវ។

## ១.៤.១ សិទ្ធិស្របច្បាប់លើដីធ្លី

ជាទូទៅនៅពេលដែលមិនទាន់មានតម្រូវការដីធ្លី ដីមានតម្លៃទាបដោយសារប្រជាពលរដ្ឋមិនសូវមានចលនាផ្លាស់ប្តូរកន្លែង និង មិនសូវមានប្រាក់សម្រាប់ទិញដីធ្លី។ នៅក្នុងបរិយាកាសបែបនេះ កម្មសិទ្ធិដីធ្លី និង ការគ្រប់គ្រងដីធ្លីហាក់មានន័យស្រដៀងគ្នា និងការផ្សារភ្ជាប់ទៅនឹងការប្រើប្រាស់ដីសម្រាប់ផលិតកម្ម ហើយត្រូវបានទទួលស្គាល់ តាមរបៀបជាទំនៀមទម្លាប់ពីសំណាក់អ្នករស់នៅជិតខាង និងពីអាជ្ញាធរមូលដ្ឋាន។ ជាក់ស្តែង ការធ្វើឯកជនូបនីយកម្មដីធ្លី នៅឆ្នាំ១៩៨៩ បានឆ្លុះបញ្ចាំងនូវទំនាក់ទំនងជាមូលដ្ឋានរវាងសិទ្ធិប្រើប្រាស់ និង សិទ្ធិគ្រប់គ្រងលើកម្មសិទ្ធិ ពីព្រោះគ្រួសារនីមួយៗបានទទួលកម្មសិទ្ធិដីធ្លីជាផ្លូវការដោយផ្អែកតាមចំនួនសមាជិកគ្រួសារ និង ការប្រើប្រាស់ផ្ទៃដីណាមួយសម្រាប់ធ្វើផលិតកម្ម[១៣០]។

ការប្រើប្រាស់ដីធ្លី បានប្រែប្រួលព្រមគ្នានឹងកំណើនតម្រូវការដីធ្លី មកពីប្រភពខាងក្រៅសហគមន៍ បុគ្គល ក្រុមហ៊ុនឯកជន និងស្ថាប័នរដ្ឋ។ ឧទាហរណ៍ នៅស្រុកស្អាង និងស្រុកភ្នំស្រួចកសិករជាច្រើននាក់បានលក់ដីលំនៅឋាន និងដីកសិកម្មឱ្យទៅអ្នកមកពីភ្នំពេញដែលមានប្រយោជន៍ពាណិជ្ជកម្ម ឬ អ្នកទិញផ្សេងទៀត។ នៅស្រុកភ្នំស្រួចកសិករបានលក់ដីទៅឱ្យអ្នកធ្វើពាណិជ្ជកម្មធំៗ

---

[១២៩] Oxfam Great Britain: ***Workshop Reports, Revised Land Law, Approaches to Reduce Landlessness***, ibit, page 26.
[១៣០] So Sovannarith and All: ***Social Assessment of Land In Cambodia: A Field Study***,op.cit, page 10.

ពួកឈ្មួញដី ឬក្រុមហ៊ុនឯកជន។ នៅខេត្តរតនគិរី ប្រជាពលរដ្ឋលក់ដីទៅឱ្យជនចំណាកស្រុកមកពីខេត្តដទៃ ហើយអ្នកទាំងនោះបានចាប់ផ្តើមប្រើប្រាស់ដីធ្លី ក្នុងលក្ខណៈអតិផលខុសពីការដាំដុះដោយផ្លាស់ទី។ នៅស្រុកភ្នំស្រួច ក្រុមហ៊ុនឯកជនបានទទួលដីកសិកម្មពីយោធា តាមរយៈការផ្តល់សម្បទានដីសេដ្ឋកិច្ច។ ដូចនេះប្រភពមួយទៀតនៃតម្រូវការដីគឺសម្បទានចំពោះការធ្វើចំការ ឬផលិតកម្មសម្រាប់បម្រើពាណិជ្ជកម្ម។

នៅភ្នំពេញលំនាំនៃការប្រើប្រាស់ដីធ្លីក៏ប្រែប្រួលយ៉ាងខ្លាំងដែរ។ កាលពីមុនគេចាត់ទុកភ្នំពេញជារាជធានីមួយ ក្នុងចំណោមរាជធានី ដែលមានសោភ័ណភាពល្អបំផុតនៅអាស៊ីអគ្នេយ៍[១៣១]។ ប៉ុន្តែសព្វថ្ងៃនេះ មានប្រជាពលរដ្ឋរស់នៅច្រើនជាងពីរដង នៃកម្រិតដែលបានគ្រោងទុកក្នុងប្លង់ចាស់។ មួយភាគធំនៃប្រជាពលរដ្ឋកើនថ្មីបានទៅរស់នៅតាមដងទន្លេ មាត់បឹង ដីសាធារណៈ ចិញ្ចើមថ្នល់ និងនៅតាមដីជុំវិញរាជធានី។ តម្រូវការដីរាជធានីភាគច្រើនមានដំណោះស្រាយជាការចាប់យក ការលក់ទិញដីដោយខុសច្បាប់ និង ការផ្ទេរការប្រើប្រាស់ដីធ្លីពីដីកសិកម្មទៅជាដីលំនៅឋាន ។

ការផ្លាស់ប្តូរនិន្នាការនៃការប្រើប្រាស់ដីធ្លី ធ្វើឱ្យមានការផ្លាស់ប្តូរទស្សនៈរបស់ប្រជាពលរដ្ឋពីរឿងសិទ្ធិខាងដីធ្លី។ ជាទូទៅ នៅក្នុងលក្ខខណ្ឌនៃការដាំដំណាំដែលមានតម្លៃថោក ការគ្រប់គ្រងដីធ្លីផ្អែកជាសំខាន់លើការប្រើប្រាស់ដីជាក់ស្តែងបម្រើផលិតកម្មហើយការទទួលស្គាល់ និង ការអនុវត្តសិទ្ធិនេះត្រូវបានគេធ្វើឱ្យស្របតាមទំនៀមទម្លាប់ប្រពៃណីនៅមូលដ្ឋាន[១៣២]។ ប៉ុន្តែ នៅពេលដីមានតម្លៃខ្ពស់ និងក្លាយជាកម្មវត្ថុនៃការលក់ដូរ សិទ្ធិគ្រប់គ្រងកាន់តែផ្អែកច្រើនឡើងទៅលើមធ្យោបាយខាងផ្លូវច្បាប់ដែលរដ្ឋបានទទួលស្គាល់ និង ដាក់ឱ្យអនុវត្ត។ អ្នកដែលទទួលស្គាល់សារសំខាន់នៃការមានឯកសារសម្រាប់បញ្ជាក់សិទ្ធិលើដីធ្លី មិនអាចទិញដោយមិនមានក្រដាសស្នាមត្រឹមត្រូវបានឡើយ ហើយពួកគាត់បានខិតខំកសាងលិខិតភស្តុតាងផ្សេងៗ ដែលគេធ្លាប់បានអនុវត្តតាមបែបប្រពៃណី ប៉ុន្តែការអនុវត្តបែបនេះនៅតែមិនទាន់ត្រឹមត្រូវតាមច្បាប់នៅឡើយទេ។

ទោះបីជាយើងសង្កេតឃើញថា បន្ទាប់ពីពេលចាប់ផ្តើមឯកជនូបនីយកម្មដីធ្លី នៅឆ្នាំ១៩៨៩ កសិករ និង អ្នកទីក្រុងជាច្រើនបានទទួលបង្កាន់ដៃទទួលពាក្យសុំកាន់កាប់ក៏ដោយ ប៉ុន្តែនាយកដ្ឋានសុរិយោដី និង ភូមិសាស្រ្តបានឱ្យដឹងថា ក្នុងចំណោមអ្នកដាក់ពាក្យសុំ ៤ ទៅ ៥ លាននាក់ គឺមានប្រហែលតែ១៣-១៤% ប៉ុណ្ណោះដែលបានទទួលប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុ[១៣៣] ។ ម៉្យាងវិញទៀត នៅក្រោយពេលការចេញបង្កាន់ដៃនេះ ដីធ្លីត្រូវបានផ្ទេរ និងពុះច្រៀកជាច្រើនលើក។ ប្រតិបត្តិការនេះមិនសុទ្ធតែត្រូវបានរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចរាល់ៗលើកនោះទេ។ ការផ្ទេរដោយមិនរាយការណ៍នេះ បានកើតមានចំពោះដីកសិកម្មនៅជនបទច្រើនជាងចំពោះដីលំនៅឋាន ឬដីនៅតាមតំបន់ទីក្រុង។

---

[១៣១] ibit, page 16.

[១៣២] ibit page 16.

[១៣៣] So Sovannarith and All: ***Social Assessment of Land In Cambodia: A Field Study***,op.cit, page 13.

ព្រមជាមួយគ្នានឹងការមកដល់នៃប្រព័ន្ធទីផ្សារ មត៌កប្រវត្តិសាស្ត្រដែលជាប្រពៃណីនេះបានបង្កឱ្យមានអសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី។ បទពិសោធន៍ជាក់ស្តែងបានបង្ហាញថា សុវត្ថិភាពក្នុងការកាន់កាប់ដីមានសារសំខាន់ណាស់ ដើម្បីលើកទឹកចិត្តឱ្យកសិករ ធ្វើវិនិយោគក្នុងមធ្យោបាយធ្វើកសិកម្មប្រកបដោយចីរភាព។ កសិករនៅកម្ពុជាភាគច្រើនគ្មានប័ណ្ណដែលជាភស្តុតាង ដើម្បីបញ្ជាក់ពីភាពស្របច្បាប់នៃការកាន់កាប់ដីធ្លីរបស់ខ្លួននោះទេ ជាពិសេស សម្រាប់ដីធ្លីដែលគេធ្វើការដាំដំណាំ[១៣៤]។ ប្រជាពលរដ្ឋកម្ពុជា ដែលរស់នៅតាមទីជនបទដាច់ស្រយាល មិនបានចាប់អារម្មណ៍ ដើម្បីធ្វើប័ណ្ណកម្មសិទ្ធិដីធ្លីរបស់ពួកគេទេ។ ពួកគេចំនួន៨០%កាន់កាប់ដីដោយមិនមានប័ណ្ណសំគាល់សិទ្ធិដីធ្លី។ ការសិក្សារបស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍រកឃើញថា៖

"៧៥% នៃប្រជាពលរដ្ឋដែលកាន់កាប់ដីធ្វើកសិកម្មបច្ចុប្បន្ន ពុំដែលខ្វល់ខ្វាយដាក់ពាក្យសុំកាន់កាប់សិទ្ធិភោគៈឡើយ"[១៣៥]។

ភស្តុតាងដែលអាចបញ្ជាក់ពីសិទ្ធិស្របច្បាប់លើដីរបស់ប្រជាពលរដ្ឋ គឺជាឯកសារដែលមានអានុភាពក្នុងការការពារសិទ្ធិស្របច្បាប់លើដីធ្លីរបស់ប្រជាពលរដ្ឋគ្រប់រូប។ ឯកសារទាំងនោះសំដៅជាពិសេស ទៅលើប័ណ្ណសំគាល់សិទ្ធិកាន់កាប់លើអចលនវត្ថុ ឬប័ណ្ណកម្មសិទ្ធិស្ថាពរ។ កត្តារួមផ្សំដែលរារាំងមិនឱ្យប្រជាពលរដ្ឋមិនទៅធ្វើប័ណ្ណសំគាល់សិទ្ធិលើដីរបស់ពួកគេ គឺបណ្តាលមកពីកត្តាជីវភាពក្នុងគ្រួសារ និង ការស្នើសុំធ្វើត្រូវចំណាយពេលយូរ ស្មុគស្មាញ និង អស់ថវិកាច្រើនដែលពួកគេគ្មានលទ្ធភាព។ ម៉្យាងវិញទៀត ដោយសារអំពើពុករលួយរបស់មន្ត្រីរាជការមួយចំនួន និង មានការវិនិយោគទុនតិចតួចក្នុងការចុះបញ្ជីសុរិយោដីដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាតាំងពី ឆ្នាំ១៩៩៣ និង កម្រិតនៃការអប់រំទាប បានធ្វើឱ្យរាំងស្ទះដល់ការបង្កើននូវប្រសិទ្ធិភាពនៃប្រពន្ធ័សុរិយោដីតាមផ្លូវច្បាប់។ កសិករជនបទកម្ពុជាតិចជាង២៥%ដែលមានឯកសារសុរិយោដី[១៣៦]។ ប្រជាពលរដ្ឋប្រហែល១០% មានប័ណ្ណកាន់កាប់ដីធ្លីស្របច្បាប់[១៣៧]។ ទោះបីជាយ៉ាងណា មានប្រជាកសិករដែលមានប័ណ្ណហើយ នៅតែមិនទាន់ធានាបាននូវសិទ្ធិរឹងមាំលើដីធ្លី ដែលពួកគេបានកាន់កាប់ និង ធ្វើកសិកម្មនៅឡើយ។ ខណៈដែលរដ្ឋាភិបាលបានបង្កើតឱ្យមានកម្មសិទ្ធិលើទ្រព្យសម្បត្តិឯកជនក៏ដោយ តែរដ្ឋនៅតែកាន់កាប់ដីធ្លីច្រើនជាង ៨០% នៃដីធ្លីទូទាំងប្រទេស[១៣៨]។ ច្បាប់ភូមិបាលនៅមិនទាន់មានលក្ខណៈសមស្របចំពោះការកំណត់នូវសិទ្ធិទ្រព្យសម្បត្តិឯកជនសម្រាប់ប្រជាពលរដ្ឋកម្ពុជា ដែលអ្នកទាំងនោះភាគច្រើនកំពុងរស់នៅតំបន់ជនបទ ហើយមានសិទ្ធិលើដីត្រឹមសិទ្ធិភោគៈតែប៉ុណ្ណោះ[១៣៩]។

---

[១៣៤] So Sovannarith and All, ***Social Assessment of Land In Cambodia: A Field Study***, Working Paper No 20: In Shaun Williams 1999, page 13.

[១៣៥] ibit. page4.

[១៣៦] So Sovannarith and All, ***Social Assessment of Land In Cambodia: A Field Study***, Working Paper No 20: In Shaun Williams 1999 .ibit. page3.

[១៣៧] ibit, page3.

[១៣៨] So Sovannarith and All, ***Social Assessment of Land In Cambodia: A Field Study*** .op.cit. page 4.

[១៣៩] ibit, page4.

## ១.៤.២ សិទ្ធិភោគៈ និងកម្មសិទ្ធិ

ដោយការយល់ដឹងខុសៗគ្នាអំពីភោគៈ និង កម្មសិទ្ធិ ការខ្វែងគំនិតទាំងនេះមិនមែនកើតមានឡើង តែទៅលើប្រជាពលរដ្ឋទូទៅប៉ុណ្ណោះទេ វាកើតមានផងដែររវាងអ្នកដែលមានតួនាទីអនុវត្ត និងផ្សព្វផ្សាយច្បាប់។ ការអនុវត្តជាក់ស្តែងធ្វើឱ្យមានការភាន់ច្រឡំទៅលើសញ្ញាណនៃភោគៈ និង កម្មសិទ្ធិនេះ។ ហេតុនេះ យើងចាំបាច់ត្រូវតែធ្វើការបង្ហាញឱ្យបានច្បាស់លាស់ដើម្បីជៀសវាងការភាន់ច្រឡំទៅលើសញ្ញាណទាំងពីរខាងលើនេះ ។

ភោគៈ[១៤០] គឺជាសភាពការណ៍មួយដែលមានន័យថា កិរិយាកាន់កាប់នូវវត្ថុអ្វីមួយយ៉ាងផ្តាច់មុខតែឯង និងបំពេញចំពោះវត្ថុនោះនូវកិច្ចការទាំងឡាយដូចដែលកម្មសិទ្ធិករបានបំពេញហើយដែរ។ រីឯកម្មសិទ្ធិ[១៤១] គឺជាសិទ្ធិដែលច្បាប់បើកឱ្យកម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យរបស់ខ្លួនផ្តាច់មុខ និង ទូលំទូលាយកុំឱ្យតែយកទ្រព្យនោះ ទៅប្រើប្រាស់ក្នុងរូបភាពណាមួយដែលច្បាប់បានហាមឃាត់។ ភាពខុសគ្នាទាំងនេះគឺថា ភោគៈជាសភាពការណ៍ដែលជាកិរិយាកាន់កាប់វត្ថុអ្វីមួយរីឯកម្មសិទ្ធិជាសិទ្ធិស្របច្បាប់ដែលកម្មសិទ្ធិករមានលើវត្ថុ។ ប៉ុន្តែភាពខុសគ្នាដ៏ចម្បងគឺការកាន់កាប់ក្នុងរយៈពេល៣ឆ្នាំជាប់ៗគ្នា បើភោគីបោះបង់ចោល ដីត្រូវធ្លាក់ទៅជាទ្រព្យសម្បត្តិឯកជននៃរដ្ឋ[១៤២]។ ចំណែកឯកម្មសិទ្ធិ ជាសិទ្ធិដ៏ផ្តាច់មុខពោលគឺ គ្មានអាជ្ញាយុកាលកំណត់ដែលត្រូវផុតរលត់ទេ មានន័យថា កម្មសិទ្ធិមិនអាចបាត់បង់ដោយសារតែការទុកដីចោលមិនប្រើប្រាស់នោះទេ។ ការទុកដីចោលឱ្យនៅទំនេររបៀបនេះក៏ជាផ្នែកមួយនៃការអនុវត្តសិទ្ធិប្រើប្រាស់របស់កម្មសិទ្ធិករដែរ ។

មាត្រា១៨ នៃច្បាប់ភូមិបាលឆ្នាំ១៩៩២ បានចែងថា អចលនវត្ថុចុះបញ្ជីដែលម្ចាស់អចលនវត្ថុមិនបានបង់ពន្ធ ឬអាករ ឬឈ្នួលតាមកាល និងអត្រាកំណត់របស់រដ្ឋក្នុងរយៈពេលប្រាំឆ្នាំជាប់ៗគ្នា ត្រូវក្លាយមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ មាត្រានេះមិនស៊ីសង្វាក់គ្នាជាមួយមាត្រាផ្សេងក្នុងច្បាប់តែមួយដែលបានអះអាងថា កម្មសិទ្ធិជាសិទ្ធិផ្តាច់មុខ និង ផ្តាច់ការនោះ។ គេអាចសន្និដ្ឋានបានថា បទបញ្ញត្តិនេះបានបញ្ចូលអាជ្ញាយុកាលផុតរលត់មួយចំពោះសិទ្ធិកម្មសិទ្ធិអចលនវត្ថុ។ ដូចនេះ សិទ្ធិកម្មសិទ្ធិត្រូវបាត់បង់សិទ្ធិនៅពេលដែល កម្មសិទ្ធិករមិនបានបង់ពន្ធដីធ្លីក្នុងរយៈពេលប្រាំឆ្នាំជាប់ៗគ្នា ដែលជាបទបញ្ញត្តិមានលក្ខណៈជាទណ្ឌកម្ម ។

ភាពមិនច្បាស់លាស់ក៏បានកើតមានឡើង ក្នុងការបែងចែកភោគៈអចលនវត្ថុ និង កម្មសិទ្ធិអចលនវត្ថុឱ្យបានដាច់ស្រឡះពីគ្នា ដោយហេតុថា កម្មសិទ្ធិករត្រូវបាត់បង់សារជាតិនៃសិទ្ធិរបស់ខ្លួនដោយការមិនបានបង់ពន្ធដីធ្លីរបស់ខ្លួនក្នុងរយៈពេលប្រាំឆ្នាំជាប់ៗគ្នា ចំណែកឯភាគីត្រូវបាត់បង់សិទ្ធិ

---

[១៤០] ក្រឹត្យច្បាប់លេខ១០០ក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ *ច្បាប់ភូមិបាល* ៖មាត្រា ៦១។

[១៤១] មាត្រា ៨៥ ច្បាប់ភូមិបាល ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ និង មាត្រា ១៩ *ច្បាប់ភូមិបាល* ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ បានចែងដូចគ្នាស្តីពីកម្មសិទ្ធិលើដីធ្លី។

[១៤២] ក្រឹត្យច្បាប់ លេខ ១០០ ក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ ស្តីពី *ច្បាប់ភូមិបាល* ៖មាត្រា៧៦។

កណ្ដិករបស់ខ្លួនដោយការបោះបង់ចោលដីធ្លីនោះក្នុងរយៈពេលបីឆ្នាំជាប់ៗគ្នា។ ដូចច្នេះទាំងសិទ្ធិកម្មសិទ្ធិ ទាំងសិទ្ធិភោគៈគឺ ត្រូវស្ថិតក្នុងស្ថានភាពអសុវត្ថិភាពគតិយុត្តដូចគ្នា ។ ក៏ប៉ុន្តែ ច្បាប់ភូមិបាលថ្មីដែលបានអនុម័តនៅឆ្នាំ២០០១ បានប្រគល់សុវត្ថិភាពគតិយុត្តជូនដល់សិទ្ធិកម្មសិទ្ធិនេះវិញដោយលុបបំបាត់ចោលនូវអាជ្ញាយុកាលផុតរលត់នៃសិទ្ធិកម្មសិទ្ធិដីធ្លី និង បានបញ្ចប់ការចូលកាន់កាប់បែបភោគៈលើអចលនវត្ថុ[១៤៣] ចាប់ពីច្បាប់នេះចូលជាធរមាន ។

## ១.៤.៣ ការធ្វើប័ណ្ណកម្មសិទ្ធិ

បច្ចុប្បន្ននេះសៀវភៅគោលបញ្ជីដីធ្លីកំពុងត្រូវបានកសាងឡើងវិញ តាមរយៈការចុះបញ្ជីដែលពុំទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយ។ រហូតមកដល់ឆ្នាំ២០០៨ ប័ណ្ណអចលនវត្ថុដែលបានចេញហើយមានប្រមាណជាង ៨១០.០០០[១៤៤] នៃចំណែកក្បាលដីដែលមានរហូតដល់ទៅ ៦-៧ លានឯណោះ[១៤៥] បច្ចុប្បន្នភាពនៃការចុះបញ្ជីដីដល់ឆមាសទី១ឆ្នាំ២០០៩ បានចំនួន១.៦៦៤.២៩៧ ប័ណ្ណ[១៤៦] ។ ហេតុដូចម្ដេចបាននៅកម្ពុជា ប័ណ្ណអចលនវត្ថុដែលបានចេញ ហើយមានចំនួនតិចយ៉ាងនេះបើប្រៀបទៅនឹងចំនួនក្បាលដីដែលកាន់កាប់ និង ប្រើប្រាស់ដោយប្រជាពលរដ្ឋ?

ដើម្បីឆ្លើយនូវសំណួរនេះ យើងគួរគប្បីយកចិត្តទុកដាក់កំណត់ឱ្យបានច្បាស់លាស់អំពីអត្ថន័យប័ណ្ណកម្មសិទ្ធិស្ថាពរ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ និង បង្កាន់ដៃទទួលពាក្យសុំកម្មសិទ្ធិជាមុនសិន។ បង្កាន់ដៃទទួលពាក្យសុំ សិទ្ធិកាន់កាប់លើដីគ្រាន់តែជាលិខិតដែលបញ្ជាក់ថាអ្នកកាន់បង្កាន់ដៃនេះ បានដាក់ពាក្យសុំនៅការិយាល័យភូមិបាលស្រុកតែប៉ុណ្ណោះ ប៉ុន្តែគ្មានតម្លៃគតិយុត្តដើម្បីអះអាងពីសិទ្ធិកម្មសិទ្ធិឡើយ។ ចំណែកឯ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់លើអចលនវត្ថុវិញគឺជាប័ណ្ណដែលបញ្ជាក់ថា ភោគីបានចុះបញ្ជីភោគៈអចលនវត្ថុរបស់ខ្លួន នៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ចដើម្បីរង់ចាំការរៀបចំឡើងវិញនូវប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លីតែប៉ុណ្ណោះ[១៤៧]។ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុនេះ មានតម្លៃគតិយុត្តត្រឹមតែជាភស្តុតាងមួយក្នុងចំណោមភស្តុតាងផ្សេងទៀតតែប៉ុណ្ណោះ។ ចំណែកឯ ប័ណ្ណកម្មសិទ្ធិអចលនវត្ថុ ឬវិញ្ញាបនបត្រសំគាល់ម្ចាស់

---

[១៤៣] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្ដីពី ***ច្បាប់ភូមិបាល*** ៖មាត្រា ២៩។

[១៤៤] Sar Sovan: ***Experiences of Land Management in Cambodia:*** International Conference: Policy meets land management: Contributions to the Achievement of the MDGs, where?, 17-18 April 2008, slide No 11.

[១៤៥] World Bank: ***Land Management and Administration Project,*** Project Appraisal Document on a Proposed credit in the amount of SDR 19.3 Million (US $24.3 million equivalent) to the Kingdom of Cambodia, 2002, Report No: 22969-KH, page 7.

[១៤៦] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់៖ លេខ២៣ ជនស អរប ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ ស្ដីពី *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩ ដល់២០១៣* ។

[១៤៧] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្ដីពី ***ច្បាប់ភូមិបាល*** ៖មាត្រា ៤០។

អចលនវត្ថុវិញ[១៤៨] គឺជាប័ណ្ណស្ថាពរនៃកម្មសិទ្ធិជំទាស់លែងបាន ដែលចេញដោយរដ្ឋបាលសុរិយោដី ស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១[១៤៩]។

ចំពោះអាជ្ញាធរមានសមត្ថកិច្ចក្នុងការចេញប័ណ្ណកម្មសិទ្ធិនេះ មានការប្រែប្រួលច្រើនលើកច្រើនសារទៅតាមសម័យកាល។ នៅចន្លោះឆ្នាំ១៩៩០ ដល់ ១៩៩៥ នាយកដ្ឋានសុរិយោដីស្ថិតនៅក្រោមក្រសួងកសិកម្ម។ មន្ត្រីសុរិយោដីខេត្ត និងស្រុកនៃនាយកដ្ឋានសុរិយោដីទទួលអនុវត្តការងារចុះបញ្ជីដីធ្លី ហើយអភិបាលខេត្ត គឺជាអាជ្ញាធរចុងក្រោយបង្អស់ក្នុងការចេញប័ណ្ណសម្រាប់ដីកសិកម្ម និងដីលំនៅឋាន[១៥០]។ នៅចន្លោះឆ្នាំ១៩៩៥ ដល់ ១៩៩៨ ដែលនាយកដ្ឋានសុរិយោដីត្រូវបានផ្ទេរមកក្រុមប្រឹក្សារដ្ឋមន្ត្រីជាអ្នកសម្រេចចុងក្រោយក្នុងការចេញប័ណ្ណកម្មសិទ្ធិ គឺជារបស់ប្រធាននាយកដ្ឋានសុរិយោដី។ តែចាប់ពីឆ្នាំ១៩៩៨ នាយកដ្ឋាននេះត្រូវបានផ្ទេរមកឱ្យស្ថិតនៅក្រោមក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហើយបានប្តូរឈ្មោះជាអគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ។ គួររំលឹកថា មុនពេលមាននាយកដ្ឋានសុរិយោដី ឆ្នាំ១៩៨៩ ពុំទាន់មានប័ណ្ណសំគាល់សិទ្ធិលើដីធ្លីទេ បើរាប់គឺចាប់ពីឆ្នាំ១៩៧៥មកទល់ឆ្នាំ១៩៨៩ មានន័យថា នៅមុនខែមេសា ឆ្នាំ ១៩៨៩ ឬមុនការបង្កើតនាយកដ្ឋានសុរិយោដី ដីធ្លីទាំងអស់នៅកម្ពុជាពុំទាន់ត្រូវបានចុះបញ្ជីសុរិយោដីទេ[១៥១]។

ក្នុងដំណាក់កាលចុងក្រោយ ក្រសួងថ្មីនេះគឺ ជាអាជ្ញាធរមានសមត្ថកិច្ចចុងក្រោយបង្អស់ក្នុងការចុះបញ្ជីដីធ្លី និងចេញប័ណ្ណកម្មសិទ្ធិដីធ្លីទាំងអស់នៅប្រទេសកម្ពុជា។ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដែលជារដ្ឋបាលសុរិយោដីថ្នាក់កណ្តាលមានតួនាទីត្រឹមតែជាអ្នកសម្របសម្រួល និងត្រួតពិនិត្យរាល់ប្រតិបត្តិការកសាងប្លង់សុរិយោដី និងបញ្ជីឈ្មោះកម្មសិទ្ធិករ កសាងសៀវភៅគោលបញ្ជីដីធ្លី និងសម្របសម្រួលដល់ការចេញវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុតែប៉ុណ្ណោះ[១៥២]។

ចំណែករដ្ឋបាលសុរិយោដីរាជធានី ខេត្ត ក្រុង ឬស្រុក ខណ្ឌស្ថិតក្រោមការណែនាំពីរដ្ឋបាលសុរិយោដីថ្នាក់កណ្តាលដើម្បីធ្វើសម្រង់សុរិយោដីដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និងកាន់កាប់សៀវភៅគោលបញ្ជីដែលត្រូវធ្វើចន្តការជាប្រចាំ[១៥៣]។ ជាចុងក្រោយរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវ

---

[១៤៨] ជាពាក្យ "ចំណងជើងនៃប័ណ្ណកម្មសិទ្ធិជាក់ស្តែង" ចេញដោយរដ្ឋបាលសុរិយោដី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្រោមច្បាប់ភូមិបាលឆ្នាំ២០០១។

[១៤៩] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល* ៖មាត្រា ២២៦។

[១៥០] ច័ន្ទ សុផល និង Sarthi Acharya ***ការលក់ដូរដីធ្លីនៅកម្ពុជា*** ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូដីធ្លី ឯកសារពិភាក្សាលេខ២២ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ភ្នំពេញ ឆ្នាំ២០០២ ទំព័រ៩។

[១៥១] អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី: ***កម្រងសំណួរ-ចំម្លើយពាក់ព័ន្ធនឹងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណ:កម្មការសុរិយោដី*** ភ្នំពេញ ខែមិនា ឆ្នាំ២០០៧ ទំព័រ៤២-៤៣។

[១៥២] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល* ៖មាត្រា ២៣១។

[១៥៣] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល* ៖មាត្រា ២៣២ និង២៣៣។

ធ្វើច្បាប់ចម្លងនៃសម្រង់ឯកសារសុរិយោដីដល់ឃុំ ឬ សង្កាត់ ដែលពាក់ព័ន្ធ។ មេឃុំ ឬ ចៅសង្កាត់ ត្រូវរាយការណ៍ទៅរដ្ឋបាលសុរិយោដី ស្រុក ខណ្ឌ នូវរាល់ការផ្លាស់ប្តូរដែលទាក់ទងនឹងស្ថានភាពនៃកម្មសិទ្ធិ និងកម្មសិទ្ធិករនៅក្នុងមូលដ្ឋានរបស់ខ្លួន។

បានានុក្រមដ៏ស្មុគស្មាញនៃមន្ត្រីរដ្ឋាភិបាល និង អ្នកតំណាងជ្រើសតាំងតាមការបោះឆ្នោតគឺជាអ្នកមានសមត្ថកិច្ចគ្រប់គ្រងដីធ្លី។ ការស្នើសុំធ្វើប័ណ្ណសំគាល់សិទ្ធិមួយត្រូវឆ្លងកាត់ យ៉ាងតិច ៨ ទៅដល់១០ ការិយាល័យចាប់ពីថ្នាក់ភូមិ ឃុំ ស្រុក ខេត្ត ដល់ក្រសួងថ្នាក់ជាតិ[១៥៤]។ ការសង្កេត និងវាស់វែងប្រើពេលអស់ច្រើន ហើយដំណើរការរឹតតែអូសបន្លាយ ដោយសារកង្វះខាតធនធានមនុស្ស និងសំភារៈ។ ប្រជាពលរដ្ឋនៅតាមជនបទទាំងកសិករ ទាំងមិនមែនកសិករមិនសូវជឿជាក់នឹងប្រព័ន្ធរដ្ឋបាលក្នុងការចុះបញ្ជីដីធ្លីទេ។ ពួកគេតែងតែជៀសវាងប្រព័ន្ធផ្លូវការ ដោយបែរទៅប្រើបែបបទតាមប្រពៃណី និងទំនៀមទម្លាប់វិញ និងដោយទាក់ទងតែជាមួយស្ថាប័ននៅមូលដ្ឋានប៉ុណ្ណោះ។ ប៉ុន្តែក៏មានមនុស្សមួយចំនួនដែលគេចវេសពីប្រព័ន្ធផ្លូវការដោយសារមិនចង់បង់ពន្ធត្រឹមត្រូវជូនរដ្ឋ។

តួអង្គក្នុងជួររដ្ឋាភិបាល ជាពិសេសនៅថ្នាក់ក្រោម(ដូចជាប្រធានភូមិ និងឃុំ)គឺជាអ្នកចូលរួមចំណែកធ្វើឱ្យការអនុវត្តច្បាប់ និងអ្នកជាប់ពាក់ព័ន្ធមានការយល់ដឹងខុសគ្នាអំពី ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អលនវត្ថុ និង ប័ណ្ណកម្មសិទ្ធិស្ថាពរ ហើយស្ថាប័នពាក់ព័ន្ធក៏ពុំមានការយល់ដឹងច្បាស់លាស់អំពីច្បាប់ និង បទបញ្ញត្តិផ្សេងៗដូចគ្នាដែរ។ ដូចច្នេះតាមលក្ខណៈជាក់ស្តែង ចំពោះបែបបទនៃការអនុវត្តខុសគ្នាក្នុងការគ្រប់គ្រងដីធ្លី បានធ្វើឱ្យច្បាប់ពិតប្រាកដអនុវត្តមិនបានពេញលេញ។ បទបញ្ញត្តិជាច្រើនមានន័យមិនច្បាស់លាស់ បានរួមចំណែកធ្វើឱ្យអំពើពុករលួយបានកើនឡើង ហើយម្យ៉ាងទៀត បញ្ហាប្រាក់បៀវត្សរ៍របស់មន្ត្រីរាជការនាំឱ្យបញ្ហានេះរិតតែធ្ងន់ធ្ងរថែមទៀត។ ក្នុងតំបន់ជាច្រើន ប័ណ្ណកម្មសិទ្ធិមួយត្រូវចំណាយដល់ទៅ ៣០០-៤០០ដុល្លារអាមេរិក[១៥៥] ដែលសឹងតែទាំងអស់ជាការបង់ប្រាក់ក្រៅផ្លូវការឱ្យទៅមន្ត្រី និងអ្នកតំណាងនៅតាមមន្ទីរក្រសួងផ្សេងៗ។ ដូចច្នេះ យើងអាចស្មានបានថាប្រជាពលរដ្ឋក្រីក្រមិនមានប័ណ្ណត្រឹមត្រូវ ធ្វើជាភស្តុតាងការពារសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់បានទេ ហើយក៏ពុំមានធនធាន ដើម្បីដោះស្រាយរំលងច្បាប់បានដែរ ។

ដំណើរការដ៏ស្មុគស្មាញ និងតម្លៃខ្ពស់ក្នុងការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់ជាកត្តាចម្បងដែលជំរុញឱ្យប្រជាពលរដ្ឋកម្ពុជាដែលធ្លាប់តែប្រកាន់យកនូវប្រព័ន្ធកម្មសិទ្ធិបែបប្រពៃណី សម្រេចចិត្តចាត់ចែងសិទ្ធិដែលខ្លួនមានលើដីធ្លីក្រៅប្រព័ន្ធច្បាប់ មានន័យថា សម្រេចចិត្តផ្ទេរសិទ្ធិលើដីធ្លីនៅក្រៅប្រព័ន្ធច្បាប់។ វិសមភាពនៅក្នុងសង្គមដែលបង្កលក្ខណៈឱ្យអ្នកមានធនធានបុណ្យស័ក្តិធ្វើការរំលោភយកដីធ្លីរបស់អ្នកដទៃ ឬ របស់រដ្ឋ បានធ្វើឱ្យប្រជាពលរដ្ឋក្រីក្រក្លាយជាជនរងគ្រោះបាត់បង់នូវដីធ្លីដែលខ្លួនធ្លាប់មាន និង បង្ខំចិត្តទៅចាប់យកដីដែលជាសម្បត្តិរដ្ឋ។ ប្រជាពលរដ្ឋកម្ពុជាភាគច្រើន

---

[១៥៤] So Sovannarith and All: ***Social Assessment of Land in Cambodia***, Working paper 20, Phnom Penh, November 2001, page2.

[១៥៥] ibit, page2.

ជាកសិករ ហើយប្រជាពលរដ្ឋ ៣៥%[១៥៦] រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ។ គួបផ្សំនឹងការដែលពួកគាត់ខ្វះខាតនូវចំណេះដឹងមូលដ្ឋានផ្នែកច្បាប់ផងនោះ ធ្វើឱ្យការអនុវត្តបទដ្ឋានគតិយុត្តប្រព្រឹត្តទៅពុំសូវបានល្អ និងត្រឹមត្រូវនោះទេ។

ក្នុងស្ថានភាពមិនច្បាស់បែបនេះ ទំនាស់ដីធ្លីគឺមិនអាចជៀសផុតបានឡើយ ជាពិសេសនៅពេលដែលដីចាប់ផ្តើមឡើងថ្លៃ ដោយវិស័យវិនិយោគពាណិជ្ជកម្មមានការលូតលាស់លឿន។ ផ្ទុយទៅវិញ ការអនុវត្តតាមប្រព័ន្ធកម្មសិទ្ធិបែបប្រពៃណីនេះ ជាមូលហេតុមួយដ៏ចម្បងនៃវិវាទដីធ្លីនៅប្រទេសកម្ពុជា ដោយហេតុថា ផ្ទៃដីនីមួយៗ ដែលអះអាងដោយភាគីនោះពុំត្រូវបានកំណត់ដោយជាក់លាក់ និងពុំមានភស្តុតាងបញ្ជាក់ពីទំហំដីកាន់កាប់ដែលជាកម្មវត្ថុនៃភោគៈ និងគ្មានការទទួលស្គាល់ជាផ្លូវការដោយអាជ្ញាធរមានសមត្ថកិច្ចលើវិស័យនោះ។ ចំពោះសាក្សីដែលជាអ្នកជិតខាងវិញ ជាធាតុដ៏សំខាន់ក្នុងការដោះស្រាយវិវាទដីធ្លីប្រភេទនេះ។ គេតែងតែឃើញភាគីទាំងសងខាងមានសាក្សីដូចគ្នា ហើយស្ថាប័នមានសមត្ថកិច្ចដោះស្រាយជួបការលំបាកក្នុងការសម្រេចសេចក្តី។

## ១.៤.៤ ការផ្ទេរសិទ្ធិដោយមិនស្របច្បាប់

ការទិញ លក់ដីធ្លីកើតមានឡើង ចាប់តាំងពីមានគោលនយោបាយឯកជនូបនីយកម្មដែលរាជរដ្ឋាភិបាលបានធ្វើនាឆ្នាំ១៩៨៩។ ការលក់អចលវត្ថុ គឺជាកិច្ចសន្យាដែលអនុញ្ញាតឱ្យផ្ទេរសិទ្ធិជាកម្មសិទ្ធិនៃអចលនវត្ថុពីអ្នកលក់ទៅឱ្យអ្នកទិញ ដោយអ្នកទិញត្រូវបង់ប្រាក់ថ្លៃអចលនវត្ថុនោះទៅឱ្យអ្នកលក់[១៥៧]។ ដូច្នេះអ្នកលក់អចលនវត្ថុអាចផ្ទេរសិទ្ធិទៅអ្នកទិញបាន។ ការផ្ទេរសិទ្ធិនេះមិនអាចជំទាស់បានពីតតិយជន លុះត្រាតែកិច្ចសន្យាលក់អចលនវត្ថុនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរតាម ឬ ទម្រង់លិខិតយថាភូត ដោយអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី[១៥៨]។ កិច្ចសន្យាលក់តែឯកឯងមិនអាចចាត់ទុកថា ជាការផ្ទេរកម្មសិទ្ធិទ្រព្យនោះបានឡើយ។ ដូចនេះ ការផ្ទេរកម្មសិទ្ធិតាមលក្ខណៈច្បាប់ និង តតិយជនជំទាស់លែងបាន គឺនៅពេលដែលកិច្ចសន្យាលក់ត្រូវបានធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូត និង ត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី ។

ការអនុវត្តជាក់ស្តែង គេសង្កេតឃើញថា ភាគច្រើននៃការលក់អចលនវត្ថុនៅប្រទេសកម្ពុជាគឺមិនត្រូវបានគេគោរពទៅតាមវិធានរបស់ច្បាប់ភូមិបាលដែលបានលើកឡើងខាងលើនេះទេ ពោលគឺមិនបានធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់យថាភូតនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច និងមិនបានទៅចុះបញ្ជីនៅអង្គភាពសុរិយោដីនោះទេ។ យ៉ាងនេះ ក៏ព្រោះតែពួកគាត់មិនចង់ចំណាយប្រាក់ទៅលើការបង់ពន្ធថ្លៃប្រថាប់ត្រា និងការចំណាយផ្សេងៗទៀត។

---

[១៥៦] ធនាគារពិភពលោក អាស៊ីបូព៌ា និងប៉ាស៊ីហ្វិកៈ *កម្ពុជាភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេនាឆ្នាំ ២០១៥* ? ឯកសារវាយតម្លៃភាពក្រីក្រឆ្នាំ២០០៦ ភ្នំពេញ ឆ្នាំ២០០៦ page i.

[១៥៧] ចំណុចនេះមានចែងនៅក្នុងមាត្រា ៦៤ ច្បាប់ភូមិបាល ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ និងមាត្រា ៥១៥ ក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[១៥៨] -ដ- មាត្រា ៦៥ និងមាត្រា ១៣៤ ក្រមរដ្ឋប្បវេណី ២០០៧។

ទោះបីច្បាប់ភូមិបាលចាស់ឆ្នាំ១៩៩២ និងច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ មានហើយក៏ដោយក៏ការអនុវត្ត និងការផ្សព្វផ្សាយច្បាប់មិនបានស៊ីជម្រៅ និងទូលំទូលាយនៅឡើយ។ ដោយការអនុវត្តនៅខ្សោយទើបមានការកេងយកផលប្រយោជន៍ពីបញ្ហាដីធ្លីបច្ចុប្បន្ន ដូចជា មានការប្រមូលទិញដីស្រែចំការពីកសិកររាប់រយហិកតា ដោយតម្លៃទាបរួចធ្វើរបងហ៊ុំព័ទ្ធ ឬបោះបង្គោលទុកមិនធ្វើអ្វីទាំងអស់ ឬមួយចាក់ដីខ្លះ ឬឈូសឆាយបន្តិចបន្តួច ធ្វើផ្លូវក្បាទុកលក់ដោយទុកទំនេរចោលមិនដាំដុះ ឬធ្វើអ្វីលើដីនេះឡើយ។ មិនតែប៉ុណ្ណោះ ការអនុវត្តលើការយកពន្ធលើដីដែលមិនបានប្រើប្រាស់ក៏អនុវត្តមិនបានលេញនោះដែរ។ អាជ្ញាធរមូលដ្ឋាននៅកន្លែងមួយចំនួនមិនបានគ្រប់គ្រងប្រជាពលរដ្ឋ ដោយធ្វើការចុះបញ្ជីឱ្យបានត្រឹមត្រូវច្បាស់លាស់នៅមូលដ្ឋានរបស់ខ្លួនទេ។ ការខ្វះចន្លោះទាំងនេះបង្កឱ្យកើតវិវាទ។

ទោះជារាជរដ្ឋាភិបាលបន្តអនុវត្តគោលនយោបាយមិនយកពន្ធ លើដីធ្លីកសិកម្មរបស់កសិករដែលបង្កបង្កើនផលលក្ខណៈគ្រួសារក៏ដោយ[159] ក៏ប៉ុន្តែ ក្នុងគោលបំណងដើម្បីទប់ស្កាត់ការទិញដីទុកឡើងថ្លៃកេងយកចំណេញ ដោយគ្មានការអភិវឌ្ឍនឹងបាត់បង់ចំណូលជាតិ រដ្ឋាភិបាលបង្កើនការត្រួតពិនិត្យប្រមូលពន្ធលើដីមិនប្រើប្រាស់ ដែលមានចែងក្នុងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ១៩៩៤ នៅជំពូក៣ ផ្នែកទី១[160]។ ការគណនាពន្ធប្រភេទនេះគឺ តាមអត្រា២ ភាគរយនៃតម្លៃដីតាមទីផ្សារដោយប៉ាន់តម្លៃទៅតាមថ្លៃដី ក្នុងមួយម៉ែត្រការ៉េ និងគិតទៅតាមខេត្ត ក្រុង និងតំបន់នីមួយៗដែលកំណត់ជារៀងរាល់ឆ្នាំ ដោយគណៈកម្មការវាយតម្លៃដីមិនប្រើប្រាស់។ នៅឆ្នាំ២០០១ ពន្ធលើផ្នែកនេះប្រមូលបានពីពាន់លានរៀល(ប្រហែល៥ សែនដុល្លាអាមេរិក) គឺស្មើនឹង១០ ភាគរយនៃពន្ធសរុប[161]។ ចំណូលពន្ធលើដីមិនប្រើប្រាស់ នៅមានកម្រិត បើគិតពីវិសាលភាពនៃដីមិនប្រើប្រាស់បច្ចុប្បន្ន។ ដូច្នេះ ការអនុវត្តច្បាប់ជាកត្តាសំខាន់ បើរដ្ឋអនុវត្តច្បាប់នោះ ដីមិនប្រើប្រាស់ជាច្រើនដែលមិនបានបង់ពន្ធនឹងត្រូវក្លាយជាទ្រព្យសម្បត្តិរបស់រដ្ឋ។ ម៉្យាងម្ចាស់ដីត្រូវទទួលរងនូវបទល្មើសព្រហ្មទណ្ឌទាក់ទងការប្រព្រឹត្តអំពើ គេចវេសពន្ធ និងត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ១០,០០០,០០០ រៀល (ដប់លានរៀល)ដល់ ២០,០០០,០០០ (ម្ភៃលានរៀល) ឬ ជាប់ពន្ធនាគារពី ១ ឆ្នាំដល់ ៥ ឆ្នាំ ឬទោសទាំងពីរនេះ[162]។

[159] រាជរដ្ឋាភិបាលៈ *កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនៃនីតិកាលទី៤* នៃរដ្ឋសភា ភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ទំព័រ៨។

[160] ហ៊ុន សែន *សន្ទរកថាស្តីពីការរីកចម្រើនរបស់ប្រជាពលរដ្ឋ តាមរយៈសមិទ្ធិផលនានា នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ឆ្នាំ២០០៤-២០០៧* ថ្លែងក្នុងពិធីបិទ សន្និសីទជាតិ នៅសាលសន្និសីទចតុមុខ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៨ ទំព័រ៣៦។

[161] ប៉ែន សុផលៈ *ការគ្រប់គ្រងដីធ្លីប្រកបដោយចីរភាព និងសមធម៌* នៅព្រះរាជាណាចក្រកម្ពុជា និក្ខេបបទបណ្ឌិត សាកលវិទ្យាល័យចម្រើនពហុបច្ចេកវិទ្យា ភ្នំពេញ ឆ្នាំ២០០៧ ទំព័រ៧៧-៧៨។

[162] ព្រះរាជក្រម លេខ នស រកម ០២៩៧.០៣ ចុះថ្ងៃទី២៤ ខែកម្ភៈ ឆ្នាំ១៩៩៧ ស្តីពី *សារពើពន្ធ* ៖មាត្រា ១៣៥។

ទាក់ទងនឹងអាជ្ញាធរមានសមត្ថកិច្ច គឺមានការលំបាកក្នុងការកំណត់ឱ្យបានច្បាស់ថា អាជ្ញាធរណាដែលមានសមត្ថកិច្ចពិតប្រាកដ។ ជាក់ស្តែង ការលក់ ច្រើនធ្វើនៅចំពោះមុខប្រធានភូមិ ឬ មេឃុំ ហើយ កម្រធ្វើឡើងនៅចំពោះមុខសមត្ថកិច្ចមន្ត្រីសុរិយោដី។ ការលក់ដូរដីធ្លី ដែលច្រើនតែត្រូវបានធ្វើឡើងនៅរដ្ឋបាលកម្រិតទាប តាមរយៈការប្តូរឈ្មោះលើចុងសន្លឹកសុំកាន់កាប់ដីធ្លី ឬក៏ការធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរអមរវាងអ្នកទិញ និង អ្នកលក់បែបនេះ គឺមិនស្របតាមច្បាប់ឡើយ។ ការអនុវត្តបែបនេះ ជាប្រភពដ៏ធំមួយនៃវិវាទដីធ្លី ដោយហេតុថា វាពុំបាននាំមកនូវការផ្ទេរកម្មសិទ្ធិតាមផ្លូវច្បាប់នោះទេ ហើយក៏ធ្វើឱ្យគេអាចលក់អចលនវត្ថុតែមួយទៅឱ្យអ្នកទិញច្រើនបន្តបន្ទាប់គ្នាបាន។

តាមការសិក្សាស្រាវជ្រាវរបស់អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល និងគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ទៅលើការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងការតាក់បន្ថយភាពក្រីក្រនៅសង្កាត់ពីរខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ខែវិច្ឆិកា ឆ្នាំ២០០៧ បានរកឃើញថា ការលក់ដូរដីធ្លីខុសច្បាប់នៅតែបន្តបើទោះបីជា ដីនោះបានចុះបញ្ជីជាប្រព័ន្ធដោយគម្រោងគ្រប់គ្រងនិង រដ្ឋបាលដីធ្លី ហើយប្រជាពលរដ្ឋទទួលបានប័ណ្ណកម្មសិទ្ធិស្ថាពរហើយក៏ដោយ។ កិច្ចសន្យាលក់ចំនួន៥៤% ធ្វើការបញ្ជាក់ពីការផ្ទេរសិទ្ធិត្រឹមថ្នាក់សង្កាត់។ តារាងខាងក្រោមជាតួលេខដែលបានរកឃើញ៖

តារាងទី៦ ដំណើរការផ្ទេរកម្មសិទ្ធិដីធ្លី ឆ្នាំ២០០៧

| | ការលក់ពីមុនពេលមាន-LMAP | | ការលក់ដីដោយមានប័ណ្ណ-LMAP | | ការទិញដី | |
|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| ប្តូរឈ្មោះម្ចាស់ដីដោយធ្វើ៖ | | | | | | |
| កិច្ចសន្យាលក់ត្រឹមថ្នាក់ភូមិ | ១៣ | ៣២ | ១៤ | ២៤ | ៦៣ | ៣២ |
| កិច្ចសន្យាលក់ត្រឹមថ្នាក់សង្កាត់ | ២៩ | ៥២ | ៣២ | ៥៤ | ១០០ | ៥១ |
| កិច្ចសន្យាលក់ត្រឹមថ្នាក់ខ័ណ្ឌ | ២ | ៤ | - | - | - | - |
| កិច្ចសន្យាលក់ត្រឹមថ្នាក់ក្រុង | - | - | ១ | ២ | ២ | ១ |
| ផ្សេងៗ | ១២ | ២១ | ១២ | ២០ | ២៩ | ១៥ |
| | N*=៥៦ ក្បាលដី | | N=៥៩ ក្បាលដី | | N=១៩៤ក្បាលដី | |

N*=ចំនួនសរុបនៃការផ្ទេរកម្មសិទ្ធិ

<u>ប្រភព៖</u> NGO Forun on Cambodia និង CCC: ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងការកាត់បន្ថយភាពក្រីក្រ ការស្រាវជ្រាវនៅក្នុងសង្កាត់ពីរ នៃខណ្ឌព្រៃនប់ ក្រុមព្រះសីហនុ ក្រុមគម្រោងវិភាគបញ្ហាអភិវឌ្ឍន៍ និងសិក្ខាកាមស្រាវជ្រាវសហការជាមួយមជ្ឈមណ្ឌលព័ត៌មានដីធ្លី ភ្នំពេញ ឆ្នាំ២០០៧ ទំព័រ៥០។

ឧទាហរណ៍ "ក" បានលក់ដីរបស់គាត់មួយកន្លែងឱ្យ "ខ"។ ឧបមាថាការលក់នេះពុំត្រូវបានធ្វើឡើងតាមទម្រង់យថាភូត និងចុះបញ្ជីនៅអង្គភាពសុរិយោដី។ ដូចនេះការលក់នេះពុំបាននាំមកនូវការផ្ទេរកម្មសិទ្ធិតាមលក្ខណៈច្បាប់នោះទេ។ ក្រោយមកទៀត "ក" បានលក់ដីដដែលនេះទៅឱ្យ "គ"។

តែម្តងនេះ ការលក់ត្រូវបានធ្វើឡើងក្រោមទម្រង់ជាលិខិតយថាភូត និងចុះបញ្ជីនៅអង្គភាពសុរិយោដី។ ដូច្នេះការលក់លើកទីពីរនេះ នាំមកនូវការផ្ទេរកម្មសិទ្ធិពេញលេញតាមលក្ខណៈច្បាប់។ វិវាទក៏កើតមានឡើងនៅពេលដែល "ខ" (អ្នកទិញទី១) បង្ខំឱ្យ "ក" អនុវត្តកិច្ចសន្យាលក់លើកទី១ដែល "ក" បានបង្កើតជាមួយនឹងខ្លួន។ វិវាទក៏អាចកើតមានស្រដៀងគ្នានេះដែរ ចំពោះការលក់ដីភោគៈ។

## ១.៤.៥ ការរំលោភ និងការចាប់ដីខុសច្បាប់

ការរំលោភយកដីធ្លីតែងតែកើតមានជាញឹកញាប់ និង ជាបញ្ហាធ្ងន់ធ្ងរដែលកម្ពុជាជួបប្រទះនាពេលបច្ចុប្បន្ន។ ករណីទាំងនេះច្រើនជាប់ពាក់ព័ន្ធនឹងបុគ្គលឯកជន ឬក្រុមហ៊ុនមកពីក្រៅសហគមន៍ ឬមន្ត្រីយោធា និងអាជ្ញាធរមានឋានៈខ្ពស់[១៦៣]។ ឧទាហរណ៍ករណីរំលោភយកដីធ្លីប្រជាពលរដ្ឋនៅខេត្តព្រៃវែង។ តាមព័ត៌មាន RFA ថ្ងៃទី២៣ ខែមិនា ឆ្នាំ២០០៩ បានដកស្រង់សំដីប្រជាពលរដ្ឋដែលតវ៉ាពីការរំលោភដីដូច្នេះថា៖

> "ដីរបស់យើងបានកាន់កាប់ជាង២០ឆ្នាំ មកហើយស្រាប់តែនគរបាល និង អាជ្ញាធរបានមកបង្ខំឱ្យផ្តិតមេដៃដើម្បីប្រគល់ដីនេះទៅឱ្យពួកគេ" [១៦៤]។

ការរំលោភយកដីធ្លី អាចកើតមានក្រោមរូបភាពជាច្រើន ផ្សេងៗគ្នាទៅតាមករណីនីមួយៗ។ ការរំលោភយកដីច្រើនតែកើតមាននៅក្នុងតំបន់ធ្វើកសិកម្មផ្លាស់ទី។ ការណ៍នេះ ដោយសារដីរដ្ឋភាគច្រើនមិនទាន់បានធ្វើអត្តសញ្ញាណកម្មឱ្យបានច្បាស់លាស់មិនថា ដីឯកជនរបស់រដ្ឋ ឬដីសាធារណៈរបស់រដ្ឋភាគច្រើន មិនបានចុះបញ្ជីតាមលក្ខណៈបច្ចេកទេស[១៦៥]។ ដីប្រភេទនេះគេទុកចោលទំនេរ ប៉ុន្តែនៅមូលដ្ឋានគេទទួលស្គាល់ថា វាជាទ្រព្យសម្បត្តិរបស់កសិករ និង សហគមន៍របស់ពួកគេ។ ប៉ុន្តែចំពោះអ្នកមកពីខាងក្រៅដីទុកចោលទំនេរគ្មានការផលិតបែបនេះ គេគិតថាអាចចាប់យកបាន ។ ការរំលោភយកដីអាចកើតមានឡើងផងដែរ នៅលើដីដែលអ្នកស្រុកកំពុងប្រើប្រាស់ជាក់ស្តែង ប៉ុន្តែគ្មានប័ណ្ណបញ្ជាក់ពីសិទ្ធិស្របច្បាប់របស់ខ្លួន។ ឧទាហរណ៍ មួយនៃអំពើរំលោភយកដីបែបនេះ គឺក្រុមហ៊ុនកូរ៉េមួយបានទទួលដីនៅស្រុកភ្នំស្រួចពីយោធា។ ក្រុមហ៊ុនបានពង្រីកតំបន់គ្រប់គ្រងរបស់ខ្លួនដោយរំលោភយកដីកំពុងដាំដំណាំរបស់ប្រជាពលរដ្ឋ១០៨គ្រួសារ ដែលមានទាំងដីរបស់ប្រធានភូមិផងដែរ[១៦៦]។

---

[១៦៣] អនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ***ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*** ៖ មាត្រា១០។

[១៦៤] RFA: ***នគរបាលបង្ខំឱ្យប្រជាពលរដ្ឋប្រគល់ដី*** សូមមើល <http://www/rfa.org/khmer/indepth/land-dispute-in-preyveng-03102009230305.html> ; Accessed dated March 23, 2009-AM.

[១៦៥] ព្រហ្ម វិចិត្រអក្ខរាៈ ***ឯកសារជំនួយស្មារតី*** សម្រាប់កិច្ចពិភាក្សារបស់និស្សិតក្នុង វេទិកានិស្សិតប្រកួតពិភាក្សាស្តីពី បញ្ហាដីធ្លី នាយកដ្ឋានទប់ស្កាត់ បង្ការ និង អប់រំ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ភ្នំពេញ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៨ ទំព័រ១០។

[១៦៦] So Sovannarith and All: ***Social Assessment of Land in Cambodia***, Working paper 20, Phnom Penh, November 2001, page17

ករណីមួយចំនួនអាជ្ញាធរមានឋានៈខ្ពស់ និងអ្នកមានទ្រព្យសម្បត្តិ ច្រើនតែប្រើឥទ្ធិពលដោយទាក់ទងឃុបឃិតជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីសម្រួលឯកសារឱ្យស្របតាមច្បាប់ ដែលនាំឱ្យមានការលំបាកក្នុងការដោះស្រាយវិវាទដីធ្លីនៅក្នុងប្រព័ន្ធតុលាការ[១៦៧]។ ករណីមួយនៃការរំលោភយកដីបានកើតមាននៅស្រុកស្អាង។ យ៉ាងហោចណាស់មានបុគ្គលម្នាក់ដែលគ្រប់គ្រងដីមួយកន្លែងរួចហើយបានសុំរំលងនីតិវិធីធម្មតាដែលត្រូវឆ្លងកាត់ប្រធានភូមិ ឃុំ ដើម្បីសុំលិខិតកាន់កាប់ដី ។ គេបានប្រាប់ថាបុគ្គលនេះមានលទ្ធភាពធ្វើឱ្យពួកមន្ត្រីនៅថ្នាក់លើឱ្យចេញប្រកាសថា ដីរបស់ខ្លួនមានទំហំធំជាងទំហំជាក់ស្តែងរបស់វាដើម្បីឱ្យខ្លួនអាចរំលោភយកដីរបស់អ្នកជិតខាងម្នាក់ទៀត[១៦៨]។ ដីធំជាងមុននេះត្រូវបានចុះបញ្ជីជាដីមួយប្លង់បានន័យថា មានការដកហូតដីមួយផ្នែក ឬទាំងអស់របស់អ្នកជិតខាងដែលមិនបានដឹងខ្លួន ។

ករណីមួយទៀតនៃការរំលោភយកដីបានកើតឡើងនៅពេលដែលម្ចាស់ដីមួយកន្លែង បានទិញដីបម្រុងទុកជាពិសេសនៅតំបន់ដែលនឹងមានគម្រោងអភិវឌ្ឍន៍ និងដីនៅតំបន់រមណីយដ្ឋានមួយចំនួនហើយមិនបានថែរក្សា។ ដីទាំងនេះភាគច្រើនត្រូវបានជនឆ្លៀតឱកាសនាំគ្នាចូលធ្វើការកាន់កាប់យ៉ាងស្ងប់ស្ងាត់ហាក់ដូចជា ពួកគេប្រើប្រាស់លិខិត ឬឯកសារក្លែងក្លាយក្នុងដៃ។ ជាក់ស្តែងករណីនៅភូមិកែវផុស ឃុំជ្រោយស្វាយ ស្រុក ស្រែអំបិល ខេត្តកោះកុង មានម្ចាស់ដី ចំនួន៤៩គ្រួសារ រងការរំលោភយកដីពីសំណាក់ក្រុមជនខិលខូច ដែលមានមេក្លោងជាអ្នកដឹកនាំចូលធ្វើសកម្មភាពឈូសឆាយយកដីប្រជាពលរដ្ឋយ៉ាងអនាធិបតេយ្យ[១៦៩] ។ ករណីរំលោភលើដីធ្លីមួយទៀត កើតឡើងនៅឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល ប្រធានក្រុមហ៊ុនឯកជនមួយបានបញ្ជាឱ្យកម្មកររបស់ខ្លួនយកគ្រឿងចក្រឈូសកំទេចចោលលំនៅឋានរបស់ប្រជាពលរដ្ឋស្លូតត្រង់ ដែលមានឯកសារសំគាល់ត្រឹមត្រូវ ហើយអាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋានក៏បានអះអាងថាត្រឹមត្រូវផងដែរ[១៧០]។

ចាប់តាំងពីឆ្នាំ១៩៩២ នៅពេលដែលកម្ពុជាបានយកចិត្តទុកដាក់អនុវត្តច្បាប់ និងបទបញ្ជានានា ក្រុមប្រឹក្សារដ្ឋមន្ត្រីបានទទួលស្គាល់ថា ពិតជាមានជនល្មើសមួយចំនួនកំពុងតែរំលោភចូលទៅបោះបង្គោល ឬ ធ្វើសំណង់នៅលើដីសាធារណៈរបស់រដ្ឋ ហើយពួកក្រុមទុច្ចរិតទាំងនោះសុទ្ធសឹងតែ

---

[១៦៧] មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមៈ *កម្មវិធីវេទិកាអ្នកតំណាងរាស្ត្រ* ខែកក្កដា ឆ្នាំ២០០៤-ខែកក្កដា ឆ្នាំ២០០៥ របាយការណ៍វេទិកាអ្នកតំណាងរាស្ត្រ ក្នុងមណ្ឌលខេត្ត បន្ទាយមានជ័យ សៀមរាប ព្រៃវែង និងស្វាយរៀង ភ្នំពេញ ខែសីហា ឆ្នាំ២០០៥ ទំព័រ១៣។

[១៦៨] .ដ.ឯ.ម. ទំព័រ១៧។

[១៦៩] DAP: *សកម្មភាពឈូសឆាយដីប្រជាពលរដ្ឋយ៉ាងអាណាធិបតេយ្យ* សូមមើល <http://www.dap-news.com/index.php?option=com_content&view=article&id=2477%3Agnkpumiekvpusmance moahdicamyyecomepn-sumgacjafr catiedahrsayvivatdifoiptlyuttifm&catid=1%3Adap-news&Itemid=75&lang=en>.accessed on 20 Aug 2009-pm.

[១៧០] DAP: *ក្រុមហ៊ុនប្រើគ្រឿងចក្រឈូសកំទេចផ្ទះអ្នកស្រុក* សូមមើល <http://www.dap-news.com/index.php ?option=com_content&view=article&id=2186%3Arbfanrkumh unpangiumiucbbacakmmkr-ykerkogcrkq uspthrbcablrdae&catid=1&Itemid=75&lang=en> .accessed date 04 Aug 09 Am.

មានលំនៅឋានត្រឹមត្រូវរួចហើយ[១៧១]។ ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ និងការរំលោភយកដីរដ្ឋធ្វើជាកម្មសិទ្ធិឯកជននៅតែមានជាអន្លើៗនៅឡើយ ហាក់ដូចជាមានការចាត់តាំងពីមេបញ្ជាការដឹកនាំត្រឹមត្រូវដើម្បីធ្វើជាមុខរបររកស៊ី។ ម្យ៉ាងទៀតថ្វីបើភោគៈត្រូវបានបញ្ចប់[១៧២] ដោយច្បាប់ភូមិបាលឆ្នាំ២០០១ ប៉ុន្តែនៅតែមានប្រជាពលរដ្ឋបន្តធ្វើការរំលោភយកដីនៅឡើយ។ ទង្វើបែបនេះច្រើនកើតចេញពីពួកឈ្មួញ និងបុគ្គលមានអំណាចដែលប្រមូលផ្តុំដីធ្លី ដើម្បីបង្កើនប្រាក់ចំណូល និងពង្រីកឥទ្ធិពលរបស់ខ្លួន។

**ការចាប់យកដីធ្លីដោយខុសច្បាប់៖**

ការចាប់យកដីធ្លីច្រើនតែធ្វើឡើងដោយក្រុមប្រជាពលរដ្ឋក្រីក្រលើដីរដ្ឋ ឬ ដីរបស់ក្រុមហ៊ុនពាណិជ្ជកម្មធំៗ។ ប្រជាពលរដ្ឋសាមញ្ញភាគច្រើន គ្មានលំនៅពិតប្រាកដ ដោយសារបញ្ហាជីវភាពលំបាកខ្លាំងធ្វើឱ្យពួកគេប្រមូលផ្តុំគ្នាដើររកដីលំនៅឋាន នៅតំបន់ដែលអាចរកចំណូលបានច្រើនជាងមុន។ អាជ្ញាធរមានឋានៈខ្ពស់ និង ក្រុមហ៊ុនផ្សេងៗត្រូវបានរាយការណ៍ពីករណីជាច្រើន អំពីការចាប់យកដី ដែលអ្នកចូលមកកាន់កាប់ដោយបានអះអាងថាជាដីរបស់ខ្លួន។ នៅស្រុកស្អាង ជនមាតុភូមិនិវត្តន៍ឆ្នាំ១៩៩២ ដល់ ១៩៩៣ មួយក្រុមបានកាន់កាប់ដីធ្លី នៅតាមបណ្តោយព្រែកដឹកដែលជាដីសាធារណៈរបស់រដ្ឋ តែក្រោយមកត្រូវនគរបាលមូលដ្ឋានបណ្តេញចេញពីទីនោះទៅវិញ។ នៅស្រុកភ្នំស្រួចជនចំណាកស្រុកបានចូលកាន់កាប់ដីទំនេរដែលអ្នកភ្នំពេញបានទិញពីអ្នកភូមិជាដើម។

ការទន្ទ្រានកាន់កាប់ដីដោយខុសច្បាប់ ទៅលើតំបន់ការពារធម្មជាតិ ចំនួន ២៦ តំបន់ ដែលស្ថិតក្រោមការគ្រប់គ្រង និងទទួលខុសត្រូវដោយក្រសួងបរិស្ថាន បានគំរាមគំហែងដល់ជីវចំរុះ និងព្រៃការពារទីជម្រកសត្វព្រៃ។ ការទន្ទ្រានធ្វើឡើងពីសំណាក់ប្រជាពលរដ្ឋ ក្រុមហ៊ុនរុករករ៉ែ និងអាជ្ញាធរមានឋានៈខ្ពស់ ដោយមានកងកម្លាំងប្រដាប់អាវុធជាបង្អែក។ ប្រហែល ៣០% នៃតំបន់សរុបទាំងមូលបានរងនូវការគំរាមគំហែងយ៉ាងធ្ងន់ធ្ងរជាទីបំផុត[១៧៣] ។ មានករណីផ្សេងទៀត ការចាប់យកដីដូចជាការចាប់យកដីសម្រាប់ធ្វើកសិកម្មនៅតំបន់ព្រៃដែលរដ្ឋគ្រប់គ្រង និង ការចាប់យកដីដោយជនមាតុភូមិនិវត្តន៍ឧទាហរណ៍នៅខេត្តកំពត[១៧៤]។ ប៉ុន្តែករណីចាប់យកដី ដែលឮសុះសាយខ្លាំងជាងគេ បានកើន

---

[១៧១] ហ៊ុន សែនៈ *សន្ទរកថាស្តីពីការរីកចម្រើនរបស់ប្រជាពលរដ្ឋ តាមរយៈសមិទ្ធិផលនានានៃការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល* ឆ្នាំ២០០៤-២០០៧ នៅក្នុងពីធីបិទសន្និសីទជាតិនៅសាលសន្និសីទចតុមុខ ភ្នំពេញ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៨ ទំព័រ២៨-២៩។

[១៧២] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល* ៖មាត្រា ២៩។

[១៧៣] L. Lacerda, K. Schmitt, P. Cutter and S. Meas: *ការវាយតម្លៃប្រសិទ្ធភាពគ្រប់គ្រងនៃប្រព័ន្ធតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា* ដោយប្រើប្រាស់វិធីសាស្ត្រ ស្តីពីការវាយតម្លៃបន្ទាន់ និងការកំណត់អាទិភាពនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ របស់អង្គការមូលនិធិពិភពលោក សម្រាប់អភិរក្សធម្មជាតិ ក្រសួងបរិស្ថាន ភ្នំពេញ ឆ្នាំ២០០៤ ទំព័រ១១។

[១៧៤] So Sovannarith and All: ***Social Assessment of Land in Cambodia***, Working paper 20, Phnom Penh, 2001, page17.

ឡើងនៅក្នុងទីក្រុងភ្នំពេញ។ ចាប់តាំងពីទសវត្សរ៍ទី៨០ មកនៅរាជធានីភ្នំពេញ គឺជាគោលដៅនៃប្រជាពលរដ្ឋចំណាកស្រុកដើម្បីស្វែងរកកន្លែងប្រកបរបរចិញ្ចឹមជីវិត។ ជាងនេះទៀត ក្រោយបោះឆ្នោតជាសកលឆ្នាំ១៩៩៣ មកមានកំណើនប្រជាពលរដ្ឋចូលមកទីក្រុងដើម្បីរកការងារធ្វើ ពួកគេចូលកាន់កាប់ដីទំនេរដែលជាដីសាធារណៈរបស់រដ្ឋ។

ប្រជាពលរដ្ឋជាច្រើននាក់បានប្រមូលផ្តុំជាទីប្រជុំជន ខ្ទមតូចៗនៅលើដីសាធារណៈក្នុងទីក្រុង។ ការមកតាំងទីលំនៅភាគច្រើនពីឆ្នាំ១៩៩០ ដល់ ១៩៩៣ អាជ្ញាធរមិនបានធ្វើអន្តរាគមន៍ដោយសារទទួលបានផលប្រយោជន៍ពីពួកគេ។ ការតាំងទីលំនៅមុនគេមានចាប់តាំងពីឆ្នាំ១៩៨០ ដូចជានៅមន្ទីរពេទ្យមុនីវង្សជាដើម ហើយពួកគេភាគច្រើនមិនមានការអប់រំកម្រិតមូលដ្ឋានផង និង ភាគច្រើនជាអ្នកក្រីក្រ។ តាមអង្គការសាមគ្គីភាពដើម្បីសហព័ន្ធអ្នកក្រីក្រទីក្រុង (SUPF) បានប៉ាន់ស្មានថា នៅក្នុងឆ្នាំ២០០៣ មានប្រជាពលរដ្ឋ ចំនួន៥៦៩សហគមន៍ អ្នកក្រីក្រនៅភ្នំពេញ គឺស្មើនឹង៣០% នៃប្រជាពលរដ្ឋសរុបនៅភ្នំពេញ ដែលរស់នៅក្នុងតំបន់តាំងទីលំនៅខុសច្បាប់[១៧៥]។ ការប្រទាំងប្រទើសចាប់កើតមាននៅពេលសេរីភាវូបនីយកម្មផ្នែកទីផ្សារនាំឱ្យកើតតម្លៃដីធ្លី ធ្វើឱ្យមានការបែងចែកតំបន់ពាណិជ្ជកម្ម និង ការធ្វើឱ្យទីក្រុងមានសោភ័ណភាពជាដើម។ ការអភិវឌ្ឍទាំងនេះ បានប៉ះទង្គិចជាមួយអ្នកតាំងទីលំនៅខុសច្បាប់ ដោយពួកគេប្រឹងប្រែងរក្សាទីលំនៅដែលជាហេតុបង្កើតបានជាវិវាទមួយដ៏គួរឱ្យព្រួយបារម្ភ។

ជារួមដីមានសារសំខាន់ដែលមិនអាចខ្វះបាន និង ជាធាតុសំខាន់សម្រាប់ប្រជាពលរដ្ឋកម្ពុជាច្រើនជាង៨០ ភាគរយ ពឹងអាស្រ័យដើម្បីចិញ្ចឹមជីវិត។ វិវាទដីធ្លីនៅតែជាបញ្ហានៅកម្ពុជា។ ជាការពិតហេតុបណ្តាលឱ្យកើតមានវិវាទដីធ្លី គឺដោយសារកត្តា នយោបាយ កត្តាសេដ្ឋកិច្ច កត្តាប្រវត្តិសាស្ត្រ កត្តាសង្គម និង កង្វះចំណេះដឹងច្បាប់ដីធ្លីជាដើម។ ការកើនឡើងនូវតម្លៃដី ធ្វើឱ្យជនមួយក្រុមតូចឆ្លៀតឱកាសរំលោភយកដីធ្លី ខណៈដែលប្រជាពលរដ្ឋក្រីក្រគ្មានលទ្ធភាពធ្វើប័ណ្ណ ដើម្បីធានានូវសុវត្ថិភាពដីធ្លីរបស់ពួកគេ។ វិវាទដីធ្លីកើនឡើងជាបន្តបន្ទាប់ និង ក្លាយជាបញ្ហាស្មុគស្មាញឡើងៗ។ ផ្អែកតាមទិន្នន័យរបស់គណៈកម្មការសុរិយោដីជាតិ វិវាទដីធ្លី ឆ្នាំ២០០៣ មានចំនួន១,២៤៥ ករណីវាកើនឡើងជាលំដាប់ប្រចាំឆ្នាំរហូតដល់ចំនួន៥,០៣៨ ករណី នៅឆ្នាំ២០០៨។ វិវាទដីធ្លីបង្កឱ្យកើតមានឡើងនូវអំពើហិង្សា បង្ករបួសស្នាម និង ស្លាប់មនុស្ស។

វិវាទដីធ្លីកើតឡើងមានច្រើនសណ្ឋានដែលគេអាចនិយាយជារួមមានពីរសំខាន់ គឺវិវាទពាក់ព័ន្ធនឹងបុគ្គលឯកជន និងវិវាទពាក់ព័ន្ធនឹងអាជ្ញាធរ។ ប្រជាពលរដ្ឋរាប់ពាន់គ្រួសាររងផលប៉ះពាល់ពីវិវាទដីធ្លី ដោយសារការផ្តល់ដីសម្បទានសេដ្ឋកិច្ច ដែលមិនមានការសិក្សាពីផលប៉ះពាល់ខាងសង្គមឱ្យបានត្រឹមត្រូវល្អ។ វិវាទដែលជាប់ពាក់ព័ន្ធជាមួយអាជ្ញាធរ ច្រើនតែជាវិវាទមានលក្ខណៈក្តៅ។ ពេលខ្លះមិនមានភាពច្បាស់លាស់រវាងតួនាទីរដ្ឋ និងឯកជន ដោយសារមន្ត្រីរដ្ឋខ្លះបានចូលរួមដោយផ្ទាល់នៅក្នុងសកម្មភាពផ្នែកឯកជន និង ដើរតួក្នុងរូបភាពសហការយ៉ាងជិតស្និទជាមួយអ្នកវិនិយោគទុន។

---

[១៧៥] Center for Advance Studies: ***Land, Development and Conflict: Urban & Peri-Urban Phnom Penh***, Justice for the Poor, Phase II, Draft, 20 February 2008, Page37.

មូលហេតុដែលនាំឱ្យកើតឡើងនូវវិវាទដីធ្លី បណ្តាលមកពីកត្តាជាច្រើនដូចជា មិនមានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និង ប្រជាពលរដ្ឋជាច្រើនមិនមានប័ណ្ណកម្មសិទ្ធិដីធ្លី។ ប្រជាពលរដ្ឋតែ ២០ % តែប៉ុណ្ណោះមានប័ណ្ណកាន់កាប់ដីធ្លីស្របច្បាប់។ ឧបសគ្គរាំងដល់ការធ្វើប័ណ្ណកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ដោយសារការធ្វើប័ណ្ណមានតម្លៃខ្ពស់ និង នីតិវិធីស្មុគស្មាញ។ រួមផ្សំនឹងការអនុវត្តច្បាប់នៅមានកម្រិត ប្រជាពលរដ្ឋបន្តការផ្ទេរសិទ្ធិលើដីធ្លី តាមតែទម្លាប់ដោយមានការឃុបឃិតគ្នាជាមួយជនពុករលួយមួយចំនួនក៏បង្កឱ្យមានវិវាទដីធ្លី។

បញ្ហាការគ្រប់គ្រង និង បញ្ហាវិវាទដីធ្លីនៅប្រទេសកម្ពុជា ក៏ស្រដៀងគ្នាជាមួយប្រទេសចំនួនដូចជាប្រទេសថៃ នេប៉ាល់ និងទុយនីស៊ី។ ភាពខ្វះចន្លោះក្នុងការគ្រប់គ្រងរបស់រដ្ឋាភិបាលក្នុងការអនុវត្តច្បាប់លើវិស័យដីធ្លី វាបានបង្កលក្ខណៈងាយស្រួលដល់បុគ្គលខិលខូចមួយចំនួនឆក់ឱកាសកេងចំណេញពីស្ថានការណ៍ ដោយបន្លំយកដីឯកជន និងដីរដ្ឋ មកធ្វើការកម្មសិទ្ធិផ្ទាល់ខ្លួន។ ការណ៍នេះធ្វើឱ្យវិវាទដីធ្លីនៅតែបន្តកើតឡើង និង ដោះស្រាយមិនចេះចប់។ ទាំងនេះដោយសារ ដីធ្លីជាប្រភពចម្បងនៃអំណាច ទ្រព្យសម្បត្តិ និងក៏នាំមកនូវជម្លោះផងដែរ។ ចំណុចដែលសំខាន់គឺ ពាក់ព័ន្ធនឹងឆន្ទៈនយោបាយរបស់ថ្នាក់ដឹកនាំរបស់ប្រទេសនីមួយៗក្នុងការដោះស្រាយបញ្ចប់វិវាទ។ នៅជំពូក ទី២ យើងនឹងសិក្សាទៅលើក្របខ័ណ្ឌគតិយុត្តទាក់ទងវិវាទដីធ្លីនៅកម្ពុជា។

# ជំពូកទី២
# ក្របខ័ណ្ឌគតិយុត្តដីធ្លី

# ជំពូកទី២
# ក្របខ័ណ្ឌគតិយុត្តដីធ្លី

ចំណុចស្នូលនៃការរៀបចំ និង គ្រប់គ្រងដីធ្លីទាមទារឱ្យមានការកំណត់ជាបទដ្ឋានមួយច្បាស់លាស់។ បទដ្ឋានច្បាប់នានាលើវិស័យដីធ្លីដែលជាគោលការណ៍ត្រូវមានភាពស្របគ្នា។ ដូច្នេះគោលបំណងសំខាន់នៃជំពូកនេះ គឺដើម្បីបង្ហាញអំពីក្របខ័ណ្ឌច្បាប់ជាតិ អន្តរជាតិ និង បទដ្ឋានក្រោមច្បាប់ ដូចជា អនុក្រឹត្យ ប្រកាស សារាចរ សេចក្តីសម្រេច បទបញ្ជាដែលជាប់ទាក់ទង និង វិវាទដីធ្លីនៅកម្ពុជា។ ការពន្យល់អំពីគោលការណ៍ទូទៅប្រៀបធៀបទៅនឹងច្បាប់ និង ការប្រមើលមើលប្រព័ន្ធច្បាប់ផ្សេងៗ។ លើសពីនេះ ជំពូកនេះក៏ស្វែងរកនៅភាពខ្វះចន្លោះ និង ធ្វើបច្ចុប្បន្នភាពនៃច្បាប់ទាក់ទងដីធ្លីនៅកម្ពុជាបច្ចុប្បន្ន។

បន្ទាប់មកយើងវិភាគលើក្របខណ្ឌគតិយុត្ត(ចំណុច២.១) និងបញ្ហាការគ្រប់គ្រងនៃសិទ្ធិលើកម្មសិទ្ធិដីធ្លីនៅពេលការចាប់ផ្តើមបង្កើតកម្មសិទ្ធិឯកជន។ យើងក៏ផ្តល់ការវិភាគលើបញ្ហាភោគៈ បញ្ហាចំណាត់ថ្នាក់លើដីរដ្ឋ បញ្ហាការចុះបញ្ជី និង បញ្ហាសម្បទានដីក៏បានលើកឡើងនៅក្នុងជំពូកនេះផងដែរ(ចំណុច២.២)។ ចុងក្រោយគឺ លើកឡើងអំពីយន្តការក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺ(ទី១)គណៈកម្មការសុរិយោដី និង(ទី២) អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(ចំណុច២.៣)។

## ២.១ ប្រវត្តិក្របខ័ណ្ឌគតិយុត្តដីធ្លី

### ២.១.១ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា

សិទ្ធិលើកម្មសិទ្ធិឯកជន មិនត្រូវបានទទួលស្គាល់ដោយច្បាប់ទេ នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ មុនការអនុម័តធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ ក្រុមប្រឹក្សារដ្ឋមន្ត្រី បានផ្តល់ការអនុញ្ញាតដល់ប្រជាពលរដ្ឋនូវសិទ្ធិកម្មសិទ្ធិ លើផ្ទះជូនពលរដ្ឋកម្ពុជានៅរាជធានីភ្នំពេញ[១៧៦]។ មាត្រា ១៥ នៃរដ្ឋធម្មនុញ្ញរបស់រដ្ឋកម្ពុជាចែងថា "ប្រជាពលរដ្ឋកម្ពុជាមានសិទ្ធិពេញលេញក្នុងការកាន់កាប់ប្រើប្រាស់ដីធ្លី និងមានសិទ្ធិតំណមត៌កលើដីធ្លីដែលរដ្ឋប្រគល់ឱ្យសម្រាប់រស់នៅ និង ធ្វើអាជីវកម្ម"[១៧៧]។ ប្រភេទនៃកម្មសិទ្ធិជាសមូហភាពលើលំនៅឋាន ត្រូវបានកែប្រែដោយបែងចែកឱ្យជាកម្មសិទ្ធិផ្ទាល់ខ្លួនតាមរយៈប័ណ្ណកម្មសិទ្ធិជូនបុគ្គលម្នាក់ៗ និង ម្ចាស់ប័ណ្ណកម្មសិទ្ធិនេះ អាចធ្វើការផ្ទេរតាមរយៈមត៌ក លក់ ដូរជាដើម។

បន្ទាប់មកអនុលោមតាម សេចក្តីសម្រេចចិត្តរបស់សន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី២ នាខែមេសា ឆ្នាំ១៩៨៩ ក្រុមប្រឹក្សារដ្ឋមន្ត្រី បានចេញសេចក្តីណែនាំនៃគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ហើយបានទទួលស្គាល់សិទ្ធិកម្មសិទ្ធិលើដីធ្លីនៅទូទាំងប្រទេស[១៧៨]។ សេចក្តីណែនាំនេះ មិនមានចែងអំពីលក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់កម្មសិទ្ធិដល់ប្រជាជនទេ។ សិទ្ធិភោគៈត្រូវបាន

---

[១៧៦] គណៈកម្មការប្រជាជនរដ្ឋធានីភ្នំពេញៈ សារាចរ លេខ ០៥.ស.រ.ច ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៨៩ ស្តីពីការអនុវត្តអនុក្រឹត្យ ស្តីពី ***ផ្តល់កម្មសិទ្ធិលើផ្ទះ ជូនប្រជាពលរដ្ឋនៅរដ្ឋធានីភ្នំពេញ*** -ចំណុចទី២។

[១៧៧] ក្រុមប្រឹក្សារដ្ឋ លេខ ២៩ ក្រ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ ស្តីពី ***រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា*** ៖មាត្រា១៥។

ទទួលស្គាល់លើដីស្រែ ដីកសិកម្ម ចំពោះជនដែលកាន់កាប់ និង ប្រើប្រាស់ជាក់ស្តែងលើដីនោះតែប៉ុណ្ណោះ។

សិទ្ធិភោគៈត្រូវបានទទួលស្គាល់ចំពោះដីស្រែ និង ដីកសិកម្ម ដែលមិនឱ្យលើសពីប្រាំហិកតា[១៧៩]។ ដីដែលផ្តល់ឱ្យមានទំហំលើសប្រាំហិកតា ជាដីសម្រាប់បង្កបង្កើនផល សម្រាប់ដាំដំណាំសំខាន់ៗបម្រើឱ្យសេដ្ឋកិច្ចជាតិ។ ការផ្តល់ដីធំៗបែបនេះគឺ ស្ថិតក្រោមទម្រង់ជាសម្បទានដែលមានកំណត់រយៈពេលប្រើប្រាស់ច្បាស់លាស់ដោយកំណត់ទៅតាមអាយុនៃដំណាំនីមួយៗ។ រដ្ឋមន្ត្រីក្រសួងកសិកម្មជាអ្នកចេញប័ណ្ណសិទ្ធិកាន់កាប់ដីសម្បទាន គេអាចកត់សំគាល់ឃើញថា ការចេញសេចក្តីណែនាំនេះមានគោលបំណងដើម្បីបង្កើតឡើងនូវប្រព័ន្ធមួយសម្រាប់ការប្រកាស និង ការចុះបញ្ជីភោគៈ។

## ២.១.២ សម័យរដ្ឋកម្ពុជា

អំឡុងកិច្ចប្រជុំវិសាមញ្ញ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ សភាជាតិនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដោយផ្លាស់ឈ្មោះប្រទេសពី "សាធារណរដ្ឋប្រជាមានិតកម្ពុជា" ទៅ "រដ្ឋកម្ពុជា" វិញ។ ជាមួយនឹងការផ្លាស់ប្តូរនេះ រដ្ឋាភិបាលរដ្ឋកម្ពុជាបានឱ្យមានរបបកម្មសិទ្ធិឯកជនថ្មីមួយឡើង ដែលបានចែងយ៉ាងច្បាស់នៅក្នុងមាត្រា១៤ " ទ្រព្យសម្បត្តិរបស់រដ្ឋមានដីធ្លី ព្រៃឈើ សមុទ្រ ទន្លេ បឹង ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌មូលដ្ឋាន ការការពារប្រទេស និងសំណង់ផ្សេងៗទៀតរបស់រដ្ឋ" ។ មាត្រា១៥ នៃរដ្ឋធម្មនុញ្ញដដែលបានផ្តល់សិទ្ធិលើដីធ្លីពេញលេញដល់ប្រជាពលរដ្ឋ គឺថា ពលរដ្ឋកម្ពុជាមានសិទ្ធិពេញទីក្នុងការកាន់កាប់ប្រើប្រាស់ដីធ្លីនិងមានសិទ្ធិតំណមត៌កលើដីធ្លី ដែលរដ្ឋប្រគល់ឱ្យសម្រាប់រស់នៅនិង ធ្វើអាជីវកម្ម។ រដ្ឋាភិបាលមិនត្រឹមតែផ្តល់សិទ្ធិលើកម្មសិទ្ធិប៉ុណ្ណោះទេ ថែមទាំងបានហាមឃាត់ក្នុងន័យមិនឱ្យមានការចាប់យកដីរដ្ឋដើម្បីកេងយកចំណេញ ដែលចែងក្នុងមាត្រា១៦ " រដ្ឋហាមឃាត់ការចាប់ដីទំនេរទុកសម្រាប់លក់ និង ជួលឱ្យអ្នកដទៃ។ ជនណាក៏ដោយមិនអាចប្រើប្រាស់ដីធ្លីកសិកម្មដីព្រៃដោយចិត្តឯង ក្នុងគោលបំណងផ្សេងៗទៀតបានឡើយ បើគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច"។ លើសពីនេះ រដ្ឋថែមទាំងបានការពារកម្មសិទ្ធិឯកជនពីការរំលោភបំពាន មាត្រា១៨ ចែងថា " កម្មសិទ្ធិឯកជននៃពលរដ្ឋលើកម្រៃការងារ លើកម្រៃស្របច្បាប់ និង ទ្រព្យសម្បត្តិស្របច្បាប់ផ្សេងទៀត ត្រូវបានច្បាប់ការពារ។ ការរឹបអូសទ្រព្យសម្បត្តិរបស់ពលរដ្ឋ ដោយរំលោភត្រូវហាមឃាត់ជាដាច់ខាត"។

ជាងនេះទៀតរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជាបានទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស។ ប្រជាពលរដ្ឋមានសិទ្ធិសេរីភាព ឥតប្រកាន់ភេទ ជំនឿសាសនា ឬឋានៈសង្គម។ សិទ្ធិសេរីភាពក្នុងការដើរហើរ និងការតាំងទីលំនៅរបស់ពលរដ្ឋត្រូវបានគោរព។ ប្រជាពលរដ្ឋមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទាមទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ[១៨០]។ យោងមាត្រា១៧ រដ្ឋធម្មនុញ្ញរដ្ឋកម្ពុជាអនុញ្ញាតឱ្យមានច្បាប់មួយដោយឡែកក្នុងការកំណត់សិទ្ធិលើកម្មសិទ្ធិ និង

[១៧៨] ក្រុមប្រឹក្សារដ្ឋមន្ត្រីៈ សេចក្តីណែនាំអនុវត្ត លេខ០៣ សណន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ ស្តីពី ***គោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី*** ។

[១៧៩] ក្រុមប្រឹក្សារដ្ឋមន្ត្រីៈ សេចក្តីណែនាំអនុវត្ត លេខ ០៣ សណន -ដ-។

សិទ្ធិប្រើប្រាស់ដីធ្លី។ ច្បាប់ភូមិបាលឆ្នាំ១៩៩២ ឱ្យអត្ថន័យនៃកម្មសិទ្ធិដោយផ្អែកតាមក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០។ កម្មសិទ្ធិ មានន័យថា ជាសិទ្ធិអាស្រ័យផល និង មានសិទ្ធិលក់ទ្រព្យនោះ។ សិទ្ធិនេះមានលក្ខណៈផ្ដាច់មុខដាច់ខាត តែត្រូវអនុវត្តក្នុងព្រំដែនដែលច្បាប់បានកំណត់។

ច្បាប់ភូមិបាលនេះ បានបង្កើតឱ្យមានកម្មសិទ្ធិឯកជនពេញលេញមួយ។ សិទ្ធិនេះគេអាចផ្ទេរពីជនម្នាក់ទៅជនម្នាក់ទៀតបានតាមរយៈសន្តតិកម្ម ឬកិច្ចសន្យា។ ម៉្យាងទៀត គេអាចធ្វើភោគៈឱ្យទៅជាកម្មសិទ្ធិបានតាមការប្ដូររូបភាពប្រើប្រាស់ដី ហើយដែលបានចុះក្នុងសៀវភៅកម្មសិទ្ធិអចលនវត្ថុរួចហើយ[១៨១]។ ភោគីត្រូវទទួលស្គាល់តាមរយៈការកាន់កាប់នូវភោគៈ និង អាចឈានទៅក្លាយជាម្ចាស់កម្មសិទ្ធិលើដីនោះ។ ដើម្បីបានក្លាយទៅជាកម្មសិទ្ធិករនៃដី ភោគីត្រូវតែបង្ហាញថាភោគៈរបស់ពួកគេបានមកតាមរយៈវិធី ដូចមាន រៀបរាប់ខាងក្រោម[១៨២]៖

១ ដោយឥតប្រើអំពើហិង្សា

២ ដោយសុចរិត

៣ ដោយឱ្យដឹងឮជាសាធារណៈ

៤ ដោយឥតអាក់ខាន

៥ ដោយឥតព្រលាំ

ការកាន់កាប់លក្ខណៈភោគៈនេះ ត្រូវតែមានរយៈពេលយ៉ាងហោចណាស់ប្រាំឆ្នាំ ដើម្បីទទួលបានកម្មសិទ្ធិ។ ច្បាប់ភូមិបាលក៏តម្រូវឱ្យភោគីត្រូវជូនដំណឹងដល់មេឃុំ ឬចៅសង្កាត់ នៅកន្លែងទីតាំងអចលនវត្ថុនោះ ហើយភោគីត្រូវបង់ពន្ធជាទៀងទាត់[១៨៣]។ ទោះបីជាយ៉ាងណាការអនុវត្តច្បាប់ភូមិបាលនាពេលនោះនៅមានកម្រិតដូចជា មានការពិបាកក្នុងការផ្ដល់ព័ត៌មានដល់ប្រជាពលរដ្ឋ ទាក់ទងនឹងកាតព្វកិច្ចតាមផ្លូវច្បាប់ស្ដីពី ការជូនដំណឹងអំពីភោគៈ និង ការបង់ពន្ធជាដើម។ ពេលនោះកម្រមានការចេញប័ណ្ណជូនប្រជាពលរដ្ឋដែលបានចូលកាន់កាប់ភោគៈលើដីនោះណាស់។ ជាងនេះទៅទៀតប្រជាពលរដ្ឋបានធ្វើការផ្លាស់ប្ដូរទីកន្លែងជាច្រើនដង និង មន្ត្រីមានសមត្ថកិច្ចមិនមានលទ្ធភាពចូលទៅកាន់តំបន់មួយចំនួនដើម្បីរៀបចំប័ណ្ណកម្មសិទ្ធិ ការណ៍នេះធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តច្បាប់ភូមិបាលឱ្យបានត្រឹមត្រូវ។

## ២.១.៣ ព្រះរាជាណាចក្រកម្ពុជា

ប្រទេសកម្ពុជាឆ្លងចូលដំណាក់កាលឯកភាពជាតិ ក្រោយពីការបែកបាក់ដោយសារសង្គ្រាមជាងបីទសវត្សរ៍។ ភាគីវិវាទបានចរចារជាច្រើនលើក ទីបញ្ចប់ឈានដល់កិច្ចព្រមព្រៀងសន្តិភាពមួយ។ អំឡុងនៃដំណាក់កាលស្វែងរកសន្តិភាព គឺចាប់ផ្ដើមពីឆ្នាំ១៩៨៨ ដល់ឆ្នាំ ១៩៩១ ប្រទេសកម្ពុជាកើត

[១៨០] ក្រុមប្រឹក្សារដ្ឋ លេខ ២៩ ក្រ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ ស្ដីពី *រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា* ៖មាត្រា៣០. មាត្រា.៣៦. មាត្រា.៣៩។

[១៨១] ក្រឹត្យច្បាប់ លេខ ១០០ ក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ ស្ដីពី *ច្បាប់ភូមិបាល* ៖មាត្រា៥៩។

[១៨២] ក្រឹត្យច្បាប់ លេខ ១០០ ក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ ស្ដីពី *ច្បាប់ភូមិបាល* ៖មាត្រា៦២។

[១៨៣] ក្រឹត្យច្បាប់ លេខ ១០០ ក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ ស្ដីពី *ច្បាប់ភូមិបាល*៖មាត្រា៦៦។

មានព្រឹត្តិការណ៍សំខាន់បី[១៩៤]៖ (ទី១)ការចាប់ផ្តើមដំណើរការស្វែងរកសន្តិភាពតាមរយៈកិច្ចប្រជុំរវាងសម្តេចព្រះនរោត្តម សីហនុ និងសម្តេច ហ៊ុន សែន និង កិច្ចប្រជុំបន្ទាប់បន្សំមួយចំនួន (ទីពីរ) ការដកទ័ពវៀតណាមចេញពីប្រទេសកម្ពុជា និង (ទីបី) ការកែទម្រង់ផ្ទៃក្នុង ជាពិសេសកិច្ចដំណើរការផ្លោះទៅកាន់សេដ្ឋកិច្ចទីផ្សារសេរី។ កិច្ចព្រមព្រៀងស្តីពី ដំណោះស្រាយនយោបាយរួមមួយ នៃជម្លោះកម្ពុជាចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានអនុម័តនូវលិខិតូបករណ៍ដ៏មានសារសំខាន់មួយចំនួនដូចតទៅ[១៩៥]៖

១. កិច្ចព្រមព្រៀងស្តីពី ដំណោះស្រាយរួមមួយនៃជម្លោះកម្ពុជា បានកំណត់ភារកិច្ចរបស់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា "អ៊ុនតាក់" ការដកកងកម្លាំង ការឈប់បាញ់ និងវិធានពាក់ព័ន្ធការបោះឆ្នោត ការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា និងបណ្តាគោលការណ៍សម្រាប់រដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជា។

២. កិច្ចព្រមព្រៀងទាក់ទងទៅនឹងអធិបតេយ្យភាព ឯករាជ្យ បូរណភាព និង ភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹត្យភាព និង ឯកភាពជាតិកម្ពុជា។

៣. សេចក្តីថ្លែងការណ៍ស្តីពីការស្តារ និង ការកសាងប្រទេសកម្ពុជាឡើងវិញ។

ក្រោយការអនុវត្តលិខិតូបករណ៍ខាងលើ រដ្ឋធម្មនុញ្ញថ្មីមួយកើតឡើងដោយប្តូរឈ្មោះប្រទេសពី "រដ្ឋកម្ពុជា" ទៅជា "ព្រះរាជាណាចក្រកម្ពុជា"[១៩៦]។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ចែងថា " រដ្ឋទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង កតិការសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស ។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សមាត្រា១៧ ចែងថា៖(១) ជនណាក៏ដោយទោះជាបុគ្គលក្តី ឬសមូហភាពក្តីមានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ (២) គ្មានជនណាម្នាក់ត្រូវបានហាមឃាត់មិនឱ្យមានកម្មសិទ្ធិឯកជន។

សេចក្តីប្រកាសជាសកលក៏បានទទួលស្គាល់នូវសេចក្តីថ្លៃថ្នូររបស់មនុស្សផងដែរ។ ដែលទាំងនេះគឺជាមូលដ្ឋានគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពនៅក្នុងពិភពលោក។ បុគ្គលម្នាក់ត្រូវមានករណីកិច្ចក្នុងការជួយអភិវឌ្ឍន៍សង្គមឱ្យបានរីកចម្រើន។ ចំណុចសំខាន់នេះមានចែងក្នុង មាត្រា២៩ ថា៖ (១)មនុស្សម្នាក់ៗមានករណីកិច្ចចំពោះសហគមន៍ ព្រោះថាមានតែនៅក្នុងសហគមន៍តែប៉ុណ្ណោះដែលបុគ្គលិកលក្ខណៈរបស់គេអាចអភិវឌ្ឍន៍ចម្រើនឡើងដោយសេរី និងយ៉ាងពេញលេញ។ (២) ក្នុងការប្រតិបត្តិសិទ្ធិសេរីភាពទាំងឡាយ និង ក្នុងការក្រេបរស់ជាតិនៃសេរីភាពរបស់គេមនុស្សម្នាក់ៗគ្រាន់តែស្ថិតក្នុងព្រំដែនដែលច្បាប់ បានកំណត់ផលប្រយោជន៍ឱ្យមានការទទួលស្គាល់ និងគោរពដល់សិទ្ធិ

---

[១៩៤] Hun Sen: ***Speech of Address at the 30th Anniversary of the partnership Between the Royal Government, Non Governmental Organizations and the People of Cambodia 1979-2009 at the National Institute of Education***, November24, 2009. Page 5. < http://www.cnv.gov.kh/> ; accessed dated on 5 January 2010-AM

[១៩៥] កិច្ចព្រមព្រៀង: ***ស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា*** ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បោះពុម្ពដោយអ៊ុនតាក់។

[១៩៦] ***រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*** ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ៖មាត្រា១។

និងសេរីភាពរបស់អ្នកដទៃ និងដើម្បីឆ្លើយតបនឹងការតម្រូវទាមទារដ៏ពិសិដ្ឋនៃសីលធម៌ នៃរបៀបរបប សាធារណៈ និង សុខុមាលភាពទូទៅ នៅក្នុងសង្គមប្រជាធិបតេយ្យ។ (៣)នៅក្នុងករណីណាក៏ដោយ សិទ្ធិ និង សេរីភាពទាំងអស់នេះ មិនអាចត្រូវគេយកទៅប្រើដោយផ្ទុយទៅនឹងគោលបំណង និងគោលការណ៍របស់សហប្រជាជាតិឡើយ។

គោលការណ៍ច្បាប់អន្តរជាតិដែលបានលើកឡើងទាំងអស់អំពីសិទ្ធិ និង កាតព្វកិច្ចអាចត្រូវពន្យល់ដូចមានចែងនៅអនុសញ្ញាសហរដ្ឋអាមេរិក ស្តីពីសិទ្ធិមនុស្ស Pact of San Jose, Costa Rica ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩[១៨៧]។ ខ្លឹមសារនៃអនុសញ្ញានោះត្រូវបានបញ្ជ្រាបចូលទៅក្នុងប្រព័ន្ធច្បាប់ស្តីពីអចលនទ្រព្យនៅកម្ពុជា ដែលមានអត្ថន័យដូចជា មាត្រា២១ សិទ្ធិលើទ្រព្យសម្បត្តិ (១) បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ និង សិទ្ធិលើទ្រព្យសម្បត្តិរបស់គេ។ ច្បាប់ត្រូវស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់សង្គម។ (២)គ្មានជនណាមួយត្រូវបានគេដកហូតទ្រព្យសម្បត្តិលើកលែងតែផ្តល់សំណងសមរម្យយុត្តិធម៌សម្រាប់គោលដៅជាសាធារណៈ ឬសម្រាប់ផលប្រយោជន៍សង្គម និង ក្នុងករណីមានច្បាប់តម្រូវ។ (៣)កិច្ចចងការប្រាក់ និង រាល់ទម្រង់នៃការកេងយកផលប្រយោជន៍ពីអ្នកដទៃត្រូវច្បាប់ហាមឃាត់។

ផ្អែកទៅតាមលិខិតបទដ្ឋានអន្តរជាតិទាក់ទងនឹងសិទ្ធិទ្រព្យសម្បត្តិ និង ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់នៅក្នុងច្បាប់ជាតិ ទើបរដ្ឋសភាពបានស្រង់យកចំណុចសំខាន់មួយចំនួន បញ្ចូលក្នុងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ដែលមានចែងនៅ មាត្រា៤៤ ថា ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។ កម្មសិទ្ធិឯកជនស្របច្បាប់ស្ថិតនៅក្រោមការគាំពារនៃច្បាប់។ ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែ ប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និង យុត្តិធម៌។

ច្បាប់កំពូលថ្មីបានទទួលស្គាល់សិទ្ធិកម្មសិទ្ធិដ៏ទូលំទូលាយ បានផ្លាស់ប្តូររបបសេដ្ឋកិច្ចកម្ពុជាពីសេដ្ឋកិច្ចផែនការប្រមូលផ្តុំផ្អែកលើគោលការណ៍សង្គមនិយម ទៅជាសេដ្ឋកិច្ចទីផ្សារសេរីដោយផ្អែកតាមប្រព័ន្ធលិទ្ធិប្រជាធិបតេយ្យ[១៨៨]។ សិទ្ធិលើកម្មសិទ្ធិ បានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងរដ្ឋធម្មនុញ្ញ តែសិទ្ធិទាំងនេះផ្តល់ចំពោះពលរដ្ឋដែលមានសញ្ជាតិខ្មែរតែប៉ុណ្ណោះ[១៨៩]។ ច្បាប់ភូមិបាលឆ្នាំ១៩៩២ ត្រូវបានពិនិត្យមើលឡើងវិញ ដើម្បីកែប្រែឱ្យស្របរដ្ឋធម្មនុញ្ញ។ សេចក្តីព្រាងច្បាប់ភូមិបាលថ្មីមួយបានបង្កើតឡើងដាក់ជូនគណៈរដ្ឋមន្ត្រី។ ការកែប្រែច្បាប់ភូមិបាលនេះ ស្ថិតក្រោមលក្ខខណ្ឌនៃការផ្តល់កម្ចីដែលមានទឹកប្រាក់ចំនួន២៥លានដុល្លាអាមេរិក ពីធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ផ្តល់ឱ្យរដ្ឋាភិបាលកម្ពុជា លើកម្មវិធីផ្នែកកសិកម្មសម្រាប់ទ្រទ្រង់ជីវភាព[១៩០]។ សេចក្តីព្រាងនេះ មានការ

---

[១៨៧] Hanne Sophie Grave: ***land Tenure and Property Rights in Cambodia***, Phnom Penh, 1993, page 34.

[១៨៨] ***រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*** ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ៖មាត្រា៥៦។

[១៨៩] ***រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*** ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ៖មាត្រា៤៤។

[១៩០] Oxfam Great Britain: ***Approach to Reducing Landlessness, Institution Cooperation about Resolving Land Disputes in Cambodia***, Volume3, Phnom Penh, 1999, page6.

ជំទាស់គួរឱ្យកត់សំគាល់ ទើបជំរុញឱ្យមានការតាក់តែងសេចក្តីព្រាងថ្មីមួយទៀត[១៩១]។ សេចក្តីព្រាងនេះ ធ្វើជាភាសាបារាំងនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០០ បានដាក់ជូនក្រុមប្រឹក្សាអ្នកច្បាប់នៅទីស្តីការគណៈរដ្ឋមន្ត្រី។ បន្ទាប់មកសេចក្តីព្រាងត្រូវបានពិគ្រោះជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា និងអ្នកពាក់ព័ន្ធផ្សេងៗដែលមានជំនាញនៅក្នុងផ្នែកនេះ។ ក្រោយមកក្រុមប្រឹក្សាអ្នកច្បាប់បានធ្វើការកែសម្រួលលើចំណុចមួយចំនួន។

ចំណុចសំខាន់ដែលមិនធ្លាប់មានជាច្រើនជំនាន់មកហើយគឺសិទ្ធិជនជាតិដើមភាគតិចត្រូវបានគេដាក់បញ្ចូលក្នុងច្បាប់។ ជនជាតិដើមទាំងនេះមានសិទ្ធិអនុវត្តតាមទំនៀមទម្លាប់ចំពោះការដាំដុះតាមមូលដ្ឋានជាសមូហភាពនៅក្នុងសហគមន៍ជាជាងធ្វើទៅតាមលក្ខណៈកម្មសិទ្ធិឯកជន។ សហគមន៍ជនជាតិដើមអាចកាន់កាប់បន្ត និង ប្រើប្រាស់តំបន់ដែលបានកំណត់តាមការប្រើប្រាស់ដើម្បីសាងសង់លំនៅឋាន។ នៅក្នុងសហគមន៍ជនជាតិដើមភាគតិច ប្រព័ន្ធកាន់កាប់ដីធ្លី តាមប្រពៃណីត្រូវបានគោរពតាមរយៈការកំណត់ដែនដី កម្រិតការលាតសន្ធឹងដីដែលត្រូវប្រើប្រាស់សម្រាប់ដាំដុះ ដោយសមាជិកនានានៅក្នុងសហគមន៍។ ប្រព័ន្ធនេះ ត្រូវបានគេទទួលស្គាល់ជាអន្តរជាតិដោយសមាជិកទាំងឡាយរបស់សហគមន៍នីមួយៗ។ ការអនុវត្តការកាន់កាប់ដីតាមប្រពៃណី ធ្វើឱ្យមានផលប្រយោជន៍ច្រើនសម្រាប់ប្រទេសជាតិមានជាអាទិ៍៖

១. រក្សាបានសន្តិសុខស្បៀងក្នុងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋមូលដ្ឋាន

២. ការការពារបរិស្ថានដោយការរក្សាបរិស្ថានព្រៃឈើ និងជីវសាស្ត្រផ្សេងៗ សត្វព្រៃ ការតាំងទីលំនៅឋាន ការការពារទីជម្រាល។

៣. រក្សាការជ្រើសរើសការអភិវឌ្ឍសេដ្ឋកិច្ចដែលមានស្ថេរភាព (តាមរយៈទេសចរណ៍ ការមិនកេងប្រវ័ញ្ច ការពារព្រៃឈើ និងរក្សាការកាប់ទីជម្រាល។ល។)។

សេចក្តីព្រាងច្បាប់នេះត្រូវបានដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី បន្ទាប់ពីគណៈរដ្ឋមន្ត្រីបានអនុម័តយល់ព្រមលើសេចក្តីព្រាងហើយសេចក្តីព្រាងនេះត្រូវបានដាក់ជូនរដ្ឋសភា។ គណៈកម្មការទី០៧ (អប់រំ យុវជន កីឡា កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍) នៃរដ្ឋសភាជាតិបានជួបប្រជុំជាច្រើនលើកជាមួយអគ្គនាយក និង អគ្គនាយករងនៃអគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីកែសម្រួល និង បំភ្លឺនូវចំណុចមួយចំនួន។ ការជួបគ្នាជាច្រើនលើកនេះ គឺចំណាយពេលជាច្រើនខែចាប់ពីខែកញ្ញា ឆ្នាំ ២០០០ ដល់ ខែមិនា ឆ្នាំ២០០១។ ចុងក្រោយច្បាប់នេះត្រូវបានរដ្ឋសភាអនុម័ត ហើយដាក់ជូនព្រះមហាក្សត្រសម្តេចព្រះនរោត្តម សីហនុ បានឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើ ហើយច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់[១៩២] និង ចូលជាធរមាននៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។

ច្បាប់ភូមិបាល ឆ្នាំ ២០០១ បានកំណត់អំពីចំណាត់ថ្នាក់ដី រួមមានដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ និង ដីរបស់បុគ្គលឯកជន។ ដីកម្មសិទ្ធិរបស់សមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចក៏បាននិយាយផងដែរ។ ច្បាប់នេះមានបំណងការពារជនជាតិដើម ដោយឱ្យនិយមន័យ

---

[១៩១] ប៉ែន សុផលៈ *ការគ្រប់គ្រងដីធ្លីប្រកបដោយចីរភាព និងសមធម៌*. ដ.ឯ.ម. ទំព័រ៣៦។

[១៩២] ក្រឹត្យច្បាប់ លេខ ១០០ ក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ ស្តីពី *ច្បាប់ភូមិបាល* ៖មាត្រា២៦៨។

ច្បាស់លាស់ដូចជាថា "សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុសង្គមវប្បធម៌ និង សេដ្ឋកិច្ចប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និង ដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព"[១៩៣]។ ផ្អែកតាមនិយមន័យនេះ ជនជាតិខ្មែរក្រៅពីជនជាតិដើមមិនអាចទៅដណ្តើមដីរបស់ពួកគេបានទេ តែជាក់ស្តែងដីធ្លីជាច្រើនត្រូវបានគេបំពានយក និងជនជាតិដើមមួយចំនួនកំពុងក្លាយជាអ្នកគ្មានដីធ្លី[១៩៤]។

## ២.២ បញ្ហាគ្រប់គ្រងដីធ្លី

### ២.២.១ បញ្ហាភោគៈ

បញ្ហាភោគៈ នៅតែបន្តអនុវត្តចាប់តាំងពីរដ្ឋាភិបាល បានចាប់ផ្តើមធ្វើឯកជនូបនីយកម្មពីដំបូងឆ្នាំ១៩៨៩ រហូតដល់ច្បាប់ភូមិបាលឆ្នាំ១៩៩២ ត្រូវបានប្រកាសឱ្យប្រើដោយបញ្ចូលនូវសញ្ញាណភោគៈសារជាថ្មី។ ពាក្យថាភោគៈ គឺមិនមែនមានន័យថា ប្រជាពលរដ្ឋណាម្នាក់មានសិទ្ធិកាន់កាប់ដីណាមួយបានតាមអំពើចិត្តនោះទេ។ គេត្រូវបំពេញលក្ខខណ្ឌ៥យ៉ាង ដែលមានចែងនៅក្នុងច្បាប់គឺ កាន់កាប់ដោយឥតប្រើហិង្សា ដោយសុចរិត ដោយមានការដឹង ឮជាសាធារណៈដើម្បីឱ្យក្លាយជាភោគីស្របច្បាប់។ ជននោះត្រូវតែជូនដំណឹងអំពីការចូលកាន់កាប់លើដីទំនេរ ហើយត្រូវប្តឹងទៅប្រធានភូមិ ឬចៅសង្កាត់ដែលអចលនវត្ថុនោះតាំងនៅ ដោយប្រាប់ពីទំហំដី ប្រភេទដី និង ព្រំប្រទល់ដីដើម្បីផ្ទៀងផ្ទាត់ថាតើដីដែលជាកម្មវត្ថុនៃការដាក់ពាក្យសុំនោះបានចុះបញ្ជីអចលនវត្ថុរួចហើយ ឬនៅ។ ប្រសិនបើ ដីនោះត្រូវបានចុះបញ្ជីអចលនវត្ថុរួចហើយ អ្នកសុំកាន់កាប់ថ្មីនោះមិនអាចទទួលបានភោគៈលើដីនោះបានទេ[១៩៥]។ បញ្ហាស្ថិតនៅត្រង់ថា ការអនុវត្តយន្តការនៃការចុះបញ្ជីអចលនវត្ថុនេះ ប្រព្រឹត្តទៅមិនបានត្រឹមត្រូវល្អដែលនាំឱ្យគ្មានសុវត្ថិភាពគតិយុត្ត សម្រាប់ដីភោគៈ។

ឧទាហរណ៍ ជាក់ស្តែងដីតែមួយកន្លែងត្រូវអាជ្ញាធរមានសមត្ថកិច្ច បានចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដល់ទៅពីរលើកនៅក្រុងព្រះសីហនុឆ្នាំ១៩៩៣និងមួយទៀតនៅឆ្នាំ១៩៩៥[១៩៦]។ ពិនិត្យឃើញបញ្ហានេះហើយ បានជារាជរដ្ឋាភិបាលបានចេញនូវសេចក្តីប្រកាសមួយ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការទន្ទ្រានកាន់កាប់ដី[១៩៧]។ ប្រកាសនេះមិនមានប្រសិទ្ធភាព ពីព្រោះអាជ្ញាធរមាន

---

[១៩៣] ក្រឹត្យច្បាប់ លេខ ១០០ ក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ ស្តីពី *ច្បាប់ភូមិបាល* ៖មាត្រា២៣។

[១៩៤] បទសម្ភាសន៍របស់បេក្ខជនបណ្ឌិត នាកិច្ចពិភាក្សាជាក្រុមជាមួយជាជាតិដើមភាគតិច លើប្រធានបទបញ្ហា ដីធ្លីរបស់ជនជាតិដើម ពួកគាត់បានរាយការណ៍ថា ២០ភាគរយ គ្មានដីលំនៅឋាន និងដីកសិកកម្ម ករណីនេះកើតឡើងនៅភូមិ បាតាង ឃុំបាតាង ស្រុកលំផាត់ ខេត្តរតនគីរី (នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩)។

[១៩៥] ក្រឹត្យច្បាប់ លេខ ១០០ ក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ ស្តីពី *ច្បាប់ភូមិបាល* ៖ មាត្រា៦៦ និង៦៧។

[១៩៦] សំណុំរឿងរដ្ឋប្បវេណីៈ សាលដីការបស់តុលាការកំពូល លេខ ១៤៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០២។

[១៩៧] រាជរដ្ឋាភិបាលៈ ចេក្តីប្រការលេខ ០៦ ប្រក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៩ ***ស្តីពី វិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី។***

សមត្ថកិច្ចលើអចលនវត្ថុមិនអាចគ្រប់គ្រង បាន ថាតើមានអចលនវត្ថុប៉ុន្មានដែលមានភោគៈរួចហើយ។ ម៉្យាងទៀត ការកំណត់ទ្រព្យសម្បត្តិសាធារណៈឬឯកជនរបស់រដ្ឋនៅពុំទាន់មានប្រសិទ្ធភាពនៅឡើយ។

សេចក្តីប្រកាស បានអនុញ្ញាតឱ្យមានការចូលរួមអន្តរាគមន៍ ពីសំណាក់អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ ប្រសិនបើមានការរំលោភបំពានយកដីធ្លីធូរ។ ការណ៍នេះធ្វើឱ្យមានភាពងាយស្រួលដល់មន្ត្រីខិលខូចមួយចំនួនដែលប្រើកងកម្លាំងសាធារណៈមកធ្វើជាខ្នងបង្អែក ដើម្បីការពារផលប្រយោជន៍ឯកជនរបស់ពួកគេ។ លើសពីនេះទៅទៀត សេចក្តីប្រកាសនេះមានអានុភាពគតិយុត្តក្នុងការលុបចោលភោគៈ ដោយសារតែការគ្រប់គ្រងលើបញ្ហាដីធ្លី ធ្វើឡើងដោយគ្មានប្រសិទ្ធភាព។ ដូចនេះ មូលហេតុនៃវិវាទដីធ្លីដែលកើតឡើងស្ថិតនៅលើកង្វះខាតបច្ចេកទេសនៃការគ្រប់គ្រងលើបញ្ជីអចលនវត្ថុ និង ការអនុវត្តច្បាប់ភូមិបាលនៅមានកម្រិត។ ផ្ទុយទៅវិញ បែរជាមិនគិតថាមូលហេតុនៃទំនាស់កើតឡើងពីបញ្ហាទាំងអស់នេះទេ ហើយបែជាគិតថា វិវាទដីធ្លីកើតចេញពីអនាធិបតេយ្យនៃការចូលកាន់កាប់ដីទៅវិញ។

ច្បាប់ភូមិបាលឆ្នាំ២០០១ បានចែងអំពីការចូលកាន់កាប់ភោគៈត្រូវបានបញ្ចប់នៅពេលដែលច្បាប់នេះចូលជាធរមាន[១៩៨]។ មានន័យថា ច្បាប់ភូមិបាលបានសម្រេចលុបចោលភោគៈហើយទន្ទឹមនេះរដ្ឋាភិបាលថែមទាំងបានចេញសេចក្តីជូនដំណឹង ស្តីពីការបញ្ចប់ការចូលកាន់កាប់ភោគៈលើអចលនវត្ថុក្នុងន័យទប់ស្កាត់ទំនាស់ដីធ្លី[១៩៩] ។ ទោះបីជាយ៉ាងណា ច្បាប់ភូមិបាលមិនបានដកហូតសិទ្ធិភោគៈដែលមានមុនច្បាប់នេះចូលជាធរមានទេ មានន័យថា អ្នកដែលមានសិទ្ធិភោគៈដោយសុចរិត និងស្របច្បាប់អាចបន្តអាស្រ័យផលលើសិទ្ធិរបស់ខ្លួន និងរហូតដល់គ្រប់រយៈពេល៥ឆ្នាំ គេអាចស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរបាន។ ច្បាប់ភូមិបាលថ្មីនេះ បានផ្តល់ភាពងាយស្រួលដល់បុគ្គលដែលជាភោគីស្របច្បាប់ក្នុងការសុំប័ណ្ណកម្មសិទ្ធិ ទោះបីជាគាត់មិនបានចុះបញ្ជីភោគៈស្របច្បាប់របស់ខ្លួនក៏ដោយ[២០០] ។ លើសពីនេះទៀត វាអាចជួយដល់ភោគីស្របច្បាប់ដែលមិនបានដឹង ឬមានការធ្វេសប្រហែសមិនបានចុះបញ្ជីភោគៈរបស់ខ្លួន ច្បាប់នេះការពារជននោះតាមអំណាចនៃ មាត្រា ២៩ មាត្រា ៣០ និងមាត្រា ៣១ ជាដើម។

បញ្ហាចាស់នៅតែបន្តកើតមានឡើងដដែល ដោយសារដីរបស់រដ្ឋទាំងសាធារណៈរបស់រដ្ឋទាំងដីឯកជនរបស់រដ្ឋភាគច្រើនមិនបាន៖ ធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទីកំណត់ទីតាំង ព្រំប្រទល់ច្បាស់លាស់ ធ្វើចំណាត់ថ្នាក់ និង ចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីនៅឡើយ។ ដូច្នេះ ការចូលកាន់កាប់ដីតាមរយៈភោគៈមិនអាចអនុវត្តបានល្អនោះទេ។ បញ្ហានេះធ្វើឱ្យឈ្មួញដីធ្លី ឬ ជនឆ្លៀត

---

[១៩៨] ព្រះរាជក្រម លេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល***៖ មាត្រា២៩។

[១៩៩] រាជរដ្ឋាភិបាលកម្ពុជា: លេខ៤៣ ស.ជ.ណ. កបច ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០១ ស្តីពី ***ការបញ្ចប់ការចូលកាន់កាប់ភោគៈលើអចលនវត្ថុ។***

[២០០] ព្រះរាជក្រម លេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល***៖ មាត្រា៤១។

ឱកាស និងបុគ្គលខិលខូចមួយចំនួនចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់តាមរូបភាពផ្សេងៗ[២០១]។ ឆ្លើយតបបញ្ហានេះរាជរដ្ឋាភិបាលបានចេញសារាចរឆ្នាំ២០០៧ ដើម្បីឱ្យអាជ្ញាធរកាន់កាប់ដីរដ្ឋចេញលិខិតទាមទារដីរដ្ឋមកវិញដោយបានកំណត់នីតិវិធីដកហូតផងដែរ។ អាជ្ញាធរកាន់កាប់ដីរដ្ឋទុករយៈពេល ៣០ថ្ងៃ គិតពីថ្ងៃបិទប្រកាសដើម្បីឱ្យអ្នកកាន់កាប់ដីរដ្ឋឆ្លើយតប ផុតកំណត់រយៈពេលនេះ ដីនោះត្រូវប្រគល់ឱ្យរដ្ឋវិញដោយឥតលក្ខខណ្ឌ។ ការអនុវត្តសារាចរនេះ មានប្រសិទ្ធភាពទៅតាមតំបន់ជាក់ស្តែង ដូចជានៅខេត្តបន្ទាយមានជ័យមានការដកហូតដីព្រៃបានចំនួន ៣៥,០៦៦ ហិកតា[២០២]។

ច្បាប់ភូមិបាលបង្កើតនូវភាពជាម្ចាស់នៃដី ដោយអនុញ្ញាតឱ្យអ្នកកាន់កាប់ភោគៈត្រឹមត្រូវតាមច្បាប់ អាចបន្តរយៈពេលកាន់កាប់ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិស្ថាពរ។ ភោគីដែលកាន់កាប់ដីដោយសន្តិវិធីមិនមានការជំទាស់ចាប់ពី៥ឆ្នាំ យ៉ាងតិចគិតពីច្បាប់ភូមិបាលប្រកាសឱ្យប្រើ អាចស្នើសុំប័ណ្ណកម្មសិទ្ធិ[២០៣]។ ក៏ប៉ុន្តែ មិនអនុញ្ញាតឱ្យមានការចូលកាន់ភោគៈថ្មី ដោយចែងក្នុងលក្ខខណ្ឌថា ក្រោយពីច្បាប់ភូមិបាលចូលជាធរមាន គេមិនអាចចាប់ផ្តើមភោគៈថ្មីដោយស្របច្បាប់បានទេ[២០៤]។ ចំពោះដីដែលប្រជាពលរដ្ឋបានកាន់កាប់ មុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ មិនត្រូវបានចាត់ទុកថា គេបានកាន់កាប់លើដីរដ្ឋទេ។ ជនដែលទាមទារថា ខ្លួនជាអ្នកកាន់កាប់ភោគៈដោយស្របច្បាប់ ត្រូវតែបង្ហាញភស្តុតាងថា ខ្លួនបានកាន់កាប់ដីនោះ បានចាប់ផ្តើមឡើងនៅមុនពេលច្បាប់ភូមិបាលចូលជាធរមាន ។ ក្រៅពីនេះភោគីដែលចូលកាន់កាប់ក្រោយថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ គឺជាភោគៈខុសច្បាប់[២០៥] និងវាជាកម្មវត្ថុនៃបទល្មើសព្រហ្មទណ្ឌ ហើយត្រូវផ្តន្ទាទោសតាមច្បាប់ទៀតផង។

ការកាន់កាប់ភោគៈមិនមែនមានន័យត្រឹមតែជាការកាន់កាប់ជារូបវន្ត ដូចជាលំនៅឋាននោះទេ វាក៏គ្របដណ្តប់ទៅលើដីដែលគេប្រើប្រាស់ដើម្បីដាំដំណាំផងដែរ ដូចជាដីសម្រាប់ធ្វើកសិកម្ម។ ទោះជាយ៉ាងណាក៏ដោយ ក៏ភោគៈទាំងនោះត្រូវតែជាភោគៈស្របច្បាប់ដាច់ខាត។ ដើម្បីឱ្យភោគីទៅជាភោគៈដោយស្របច្បាប់បាននោះ គឺត្រូវបំពេញនូវលក្ខខណ្ឌទាំងប្រាំគឺការកាន់កាប់[២០៦]៖

១ ដោយពិតប្រាកដ

២ ដោយគ្មានហិង្សា

៣ ដោយដឹង ឮជាសាធារណៈ

៤ ដោយឥតអាក់ខាន

៥ ដោយសុចរិត

---

[២០១] សារាចរ លេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពី *ការកាន់កាប់ដីធ្លីដោយខុសច្បាប់* ។

[២០២] បទអន្តរាគមន៍របស់លោក ឱម ចាន់ថា នាយខុទ្ទកាល័យសាលាខេត្តបន្ទាយមានជ័យ នៅក្នុងមហាសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០០៩ និងទិសដៅបន្តការងារឆ្នាំ២០១០ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០។

[២០៣] ក្រឹត្យច្បាប់លេខ១០០ក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ ស្តីពី *ច្បាប់ភូមិបាល*៖មាត្រា៣០។

[២០៤] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល*៖ មាត្រា២៩។

[២០៥] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល*៖ មាត្រា ២៩។

[២០៦] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល*៖ មាត្រា ៣៨។

ក្នុងករណីភោគីបំពេញតាមលក្ខខណ្ឌទាំងប្រាំនេះបាន ភោគៈស្របច្បាប់នេះបង្កើតបានជាសិទ្ធិភណ្ឌិកលើអចលនវត្ថុ ភោគីមានសិទ្ធិដូចគ្នាជាមួយកម្មសិទ្ធិករដោយស្របច្បាប់ដែលនេះមានន័យថា កម្មសិទ្ធិករអាចផ្ទេរកម្មសិទ្ធិដោយសេរី អាចយកទៅដាក់បញ្ចាំដើម្បីទទួលបានប្រាក់កម្ចីពីស្ថាប័នផ្សេងៗ។ ភោគីដែលស្របច្បាប់មានសិទ្ធិដាក់ដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ តែច្បាប់មិនបានបញ្ជាក់ពីរយៈពេលសម្រាប់ការទទួលបានប័ណ្ណនោះទេ[២០៧]។ ជាការឆ្លើយតប មន្ត្រីរដ្ឋាភិបាលតែងតែថា រដ្ឋាភិបាលគ្មានកាតព្វកិច្ចចេញប័ណ្ណសំគាល់កម្មសិទ្ធិជូនភោគីទេ[២០៨]។ ជាក់ស្តែង ភោគីស្របច្បាប់នៃអចលនវត្ថុដែលមានតម្លៃ និងនៅតំបន់សំខាន់ៗមួយចំនួន ហើយជាកន្លែងត្រូវអភិវឌ្ឍន៍ ឬធ្វើអាជីវកម្មតែងតែត្រូវបដិសេធទទួលស្គាល់តាមផ្លូវច្បាប់។ បើសិនជា ភោគីស្របច្បាប់ណាម្នាក់ដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិ ត្រូវបានបដិសេធមិនចេញប័ណ្ណសំគាល់កម្មសិទ្ធិឱ្យទេ ដោយសារដីនោះកំពុងជាប់មានវិវាទមិនទាន់បានដោះស្រាយចប់ជាស្ថាពរជាដើម។

**ភោគីដែលមិនបានកាន់កាប់**

លក្ខខណ្ឌមួយក្នុងចំណោមប្រាំខាងលើចំពោះភោគៈស្របច្បាប់ គឺការកាន់កាប់ដោយគ្មានការអាក់ខាន។ នេះមិនមែនមានន័យថា កម្មសិទ្ធិករត្រូវតែរស់នៅលើដី ឬបានប្រើប្រាស់ដីនោះ ១០០ភាគរយនោះទេ។ ផ្ទុយទៅវិញគេត្រូវតែប្រើប្រាស់ដីនោះក្នុងលក្ខណៈជាធម្មតា ដូចអ្នកប្រើប្រាស់ទូទៅ[២០៩]។ ករណីទុកដីចោលដោយមិនប្រើប្រាស់ក្នុងរដូវប្រាំង ឬទុកដីកសិកម្មចោលមួយរយៈដើម្បីស្តារដីឱ្យមានជីវជាតិឡើងវិញ មិនមែនជាហេតុនាំឱ្យមានការប្រានចោលភោគៈស្របច្បាប់ទេ។ ការយល់ដឹងមិនច្បាស់លាស់នេះធ្វើឱ្យកើតឡើងនូវវិវាទមិនចេះចប់។ មកដល់ពេលបច្ចុប្បន្ន មានករណីជាច្រើន ជាពិសេស នៅតាមតំបន់ជនបទ មានបុគ្គលមួយចំនួនបានធ្វើការទាមទារដីដោយសំអាងថាខ្លួនមានឯកសារចាស់ៗដើម្បីបញ្ជាក់ថាជាភោគីស្របច្បាប់។ មានសញ្ញាណជាច្រើនដែលថាការអះអាងនេះមិនមែនជាភោគៈស្របច្បាប់ ប៉ុន្តែអ្នកខ្លះថា ប្រជាពលរដ្ឋបានទទួលឯកសារបញ្ជាក់ភោគៈខុសច្បាប់តាំងពីដំបូងចេញដោយអាជ្ញាធរមូលដ្ឋាន[២១០]។

ជួនកាលប្រជាពលរដ្ឋដែលរស់នៅលើតំបំន់មានវិវាទ មិនដែលធ្លាប់ឃើញអ្នកដែលមានលិខិតបញ្ជាក់ភោគៈទាល់តែសោះ គឺថាដីភោគៈជារបស់ជនដែលនៅតំបន់ខាងក្រៅ និង មិនមែនជាអ្នកកាន់កាប់ជាប់លាប់ ដោយគ្មានការអាក់ខានទេ ដោយទុកដីនោះចោលនៅទំនេរជាច្រើនឆ្នាំ ហើយមិនស្របតាមការប្រើប្រាស់តាមលក្ខណៈធម្មតា។ ការកាន់កាប់ធ្វើឡើងដោយអ្នកខាងក្រៅបែបនេះដោយមិនមានការដឹងឮជាសាធារណៈ ព្រមទាំងមិនមានលក្ខណៈច្បាស់លាស់ទៀតផង។ ការណ៍នេះវាផ្ទុយទៅនឹងច្បាប់ភូមិបាល មាត្រា៣៨ អំពីលក្ខខណ្ឌនៃការចូលកាន់កាប់ភោគៈ តែបង្ហាញឱ្យដឹងច្បាស់ថាការកាន់កាប់ធ្វើឡើងដោយលួចលាក់ទៅវិញ។ មុនឆ្នាំ ២០០១ មានលិខិតបញ្ជាក់ភោគៈចាស់ៗ

---

[២០៧] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល*** ៖ មាត្រា ៣០.និង មាត្រា៣៩។

[២០៨] CHRAC: ***Losing Ground*** , Forced Evictions and Intimidation in Cambodia, Phnom Penh, 2009, page 65.

[២០៩] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល*** ៖មាត្រា ៣៨។

[២១០] CHRAC: ***Losing Ground*** , op.cit , page67.

ជាច្រើន ហើយលិខិតបែបនេះជាច្រើនជាលិខិតខុសច្បាប់ និង លិខិតដូចគ្នាជាច្រើនទៀតលែងមានសុពលភាព ដោយសារបុគ្គលដែលមានលិខិតបញ្ជាក់នោះ មិនបានបំពេញលក្ខខណ្ឌប្រាំយ៉ាងដែលច្បាប់ភូមិបាលបានកំណត់។

## ២.២.២ ការចុះបញ្ជីដីធ្លី

ច្បាប់ភូមិបាលក៏បានបង្កើតឡើងនូវប្រព័ន្ធចុះបញ្ជីដីធ្លីកម្រិតជាតិ លើដីធ្លីទាំងអស់នៅកម្ពុជា។ ការចុះបញ្ជីដីធ្វើឡើងមានលក្ខណៈដាច់ដោយដុំ និងមានលក្ខណៈជាប្រព័ន្ធ[២១១]។ ភាពខុសនៃការចុះបញ្ជីទាំងពីនេះគឺ ការចុះបញ្ជីដាច់ដោយដុំ អាចប្រព្រឹត្តទៅបានតាមរយៈការស្នើសុំពីកម្មសិទ្ធិករនៃដី និងកម្មសិទ្ធិករត្រូវចំណាយថវិកាច្រើន ចំណែកឯការចុះបញ្ជីជាប្រព័ន្ធវិញ ធ្វើឡើងដោយរដ្ឋនៅក្នុងមួយភូមិ ឬឃុំទាំងមូល ហើយកម្មសិទ្ធិករចំណាយថវិកាមានកម្រិតទាប។ កម្មសិទ្ធិទាំងអស់ត្រូវបានកត់ត្រានៅក្នុងសៀវភៅគោលបញ្ជី ដែលមានឈ្មោះ និង ទំហំក្បាលដីច្បាស់លាស់។ មានតែប័ណ្ណសំគាល់កម្មសិទ្ធិជាផ្លូវការតែប៉ុណ្ណោះ ដែលអាចបញ្ជាក់បានយ៉ាងពេញលេញអំពីកម្មសិទ្ធិស្របច្បាប់។ តាមច្បាប់ភូមិបាល កម្មសិទ្ធិករទោះជាស្របច្បាប់ក៏ដោយ ក៏មិនអាចធ្វើអ្វីតាមតែចិត្តបានទេ ត្រូវស្ថិតក្នុងព្រំដែនកំណត់។ ឧទាហរណ៍ ច្បាប់ហាមមិនឱ្យដាំដំណាំដែលបានហាមឃាត់ដោយច្បាប់ និងបទបញ្ញាផ្សេងៗមួយចំនួនទៀត[២១២]។ កម្មសិទ្ធិករក៏ត្រូវគោរពតាមច្បាប់ដទៃផ្សេងៗ ទៀតផងដែរ ដូចជាច្បាប់ព្រៃឈើ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងក្រមព្រហ្មទណ្ឌជាដើម។

ការចុះបញ្ជីដោយផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី គឺផ្អែកលើការរំពឹងទុកថា នឹងធ្វើឱ្យប្រសើរឡើងនូវសិទ្ធិលើទ្រព្យសម្បត្តិដែលជាអចលនទ្រព្យរបស់ប្រជាពលរដ្ឋ វាមានឥទ្ធិពលវិជ្ជមានលើការប្រើប្រាស់ និងផលិតភាព។ បន្ទាប់ពីការអនុម័តច្បាប់ភូមិបាលឆ្នាំ២០០១ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានបង្កើតគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) នៅក្នុងឆ្នាំ២០០២[២១៣]។ គម្រោង LMAP មានបំណងធ្វើឱ្យមានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ពង្រឹងប្រព័ន្ធរដ្ឋបាលដីធ្លី និងលើកកម្ពស់ ការបង្កើតទីផ្សារដីធ្លីប្រកបដោយប្រសិទ្ធភាព។ មុនមានការចុះបញ្ជីដីធ្លី ការទិញលក់ដីដោយខុសច្បាប់ កើតមានឡើងយ៉ាងច្រើននៅទូទាំងប្រទេស ដោយមិនបានគិតគូរពីការចុះបញ្ជីសុរិយោដីឡើយ។ ទង្វើខុសច្បាប់ចំពោះការលក់ដូរដីធ្លីនេះ ធ្វើឡើងដោយខ្លះមានកិច្ចសន្យា និងខ្លះទៀតដោយមិនមានកិច្ចសន្យា ភាគីមិនបានផ្តល់ដំណឹងទៅអាជ្ញាធរ។ ការចុះបញ្ជីដីធ្លីគឺ ដើម្បីឆ្លើយតបនឹងការរាលដាលនូវប្រតិបត្តិការលក់ទិញដីធ្លីខុសច្បាប់។ គម្រោង LMAP ស្ថិតក្រោមឥណទានពីធនាគារពិភពលោកតាមរយៈភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ រយៈពេល ៥ឆ្នាំ ដំបូង ២០០២-២០០៧ នូវថវិកាចំនួន២៨.៨៣ លាន ដុល្លាអាមេរិកនៃថវិកាសរុបសម្រាប់ការចំណាយលើគម្រោង

---

[២១១] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល* ៖ មាត្រា ២២៩។

[២១២] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល* ៖ មាត្រា ២៥៦។

[២១៣] NGO Forum & CCC: *ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងការកាត់បន្ថយភាពក្រីក្រ* ការស្រាវជ្រាវនៅក្នុងសង្កាត់ទីពីរនៃខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ក្រុមគម្រោងវិភាគបញ្ហាអភិវឌ្ឍន៍ និងសិក្ខាកាមស្រាវជ្រាវ សហការជាមួយមជ្ឈមណ្ឌលព័ត៌មានដីធ្លី ភ្នំពេញ ឆ្នាំ២០០៧ ទំព័រ៦។

ចំនួន៣៨.៤៣លានដុល្លារអាមេរិក [២១៤]។ គម្រោងនេះ ត្រូវបានព្យួរដោយធនាគារពិភពលោកម្តងនៅខែមិថុនា ឆ្នាំ២០០៦ ក្នុងការត្រួតពិនិត្យ និងស៊ើបអង្កេតលើភាពមិនប្រក្រតីមួយចំនួន។ តែក្រោយមកការព្យួរត្រូវលើកវិញនៅខែកុម្ភៈ ឆ្នាំ២០០៧ នៅពេលដែលគម្រោងត្រូវចប់នៅខែធ្នូ ឆ្នាំ ២០០៧[២១៥]។ បន្ទាប់មក គម្រោងត្រូវបន្ត២ឆ្នាំដោយផ្តែកលើការរីកចម្រើននៃការអនុវត្ត។ រយៈពេលបញ្ចប់គម្រោងរំពឹងថានឹងចប់នៅខែធ្នូ ឆ្នាំ២០០៩ ក៏ប៉ុន្តែ រដ្ឋាភិបាលកម្ពុជាបានលុបចោលការទទួលឥណទានចុងក្រោយពីធនាគារពិភពលោកនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩[២១៦]។ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីបានប្រកាសបញ្ចប់កម្មវិធីចុះបញ្ជីដីធ្លីជាមួយធនាគារពិភពលោកដោយថ្លែងថា "ធនាគារពិភពលោកបានដាក់លក្ខខណ្ឌសាំញ៉ាំយ៉ាងច្រើនមកលើរដ្ឋាភិបាលលើកម្មវិធីចុះបញ្ជីដីធ្លី" ការថ្លែងនេះក្នុងឱកាសពិធីបង្ហាញលទ្ធផលទីបញ្ចប់នៃជំរឿនប្រជាពលរដ្ឋឆ្នាំ២០០៨នៅសាលសន្និសីទចតុមុខ។

លទ្ធផលនៃការចុះបញ្ជីដីធ្លីក្រោមគម្រោង LMAP មកត្រឹមខែកញ្ញា ឆ្នាំ ២០០៩ សម្រេចបានចំនួន១.១លានក្បាលដី[២១៧]។ គួរឱ្យសោកស្តាយដោយគម្រោងនេះត្រូវបញ្ចប់ឆាប់ពេក ព្រោះគម្រោងមាន រយៈពេលដល់១៥ឆ្នាំ។ ការប៉ាន់ស្មានចុះបញ្ជីដីនៅទូទាំងប្រទេសនូវក្បាលដីប្រហែលពី៦ ទៅ ៧ លាន ក្បាលដី[២១៨]។ ប៉ុន្តែ ឆ្លងតាមការអនុវត្តជាក់ស្តែង ចំនួនក្បាលដីអាចមានដល់ចំនួន ១០ ទៅ ១៤ លាន ក្បាលដី[២១៩]។ ការចុះបញ្ជីនេះ មានសារសំខាន់ខ្លាំងណាស់សម្រាប់ប្រជាពលរដ្ឋក្រីក្រ វាអាចជួយទប់ស្កាត់ការរំលោភយកដីធ្លី ពីសំណាក់ជនខិលខូចមួយចំនួន ដូចមានការចុះផ្សាយជាសាធារណៈជារៀងរាល់ថ្ងៃនៅតាមប្រព័ន្ធសារព័ត៌មាន។ ម្យ៉ាងវិញទៀតវាក៏ផ្តល់នូវសុវត្ថិភាព យុត្តិធម៌ និងតម្លាភាពដីធ្លី ដែលជាមធ្យោបាយ ដើម្បីដោះស្រាយវិវាទដីធ្លី និង ការតាំងទីលំនៅឋានថ្មីដែលប្រទេសកម្ពុជាជួបប្រទះនាពេលបច្ចុប្បន្ន។ ប្រជាពលរដ្ឋដែលមិនមានសុវត្ថិភាពចំពោះការកាន់កាប់ដីធ្លី ឬមិនមានប័ណ្ណកម្មសិទ្ធិ ពួកគេទំនងជារស់នៅស្ថិតក្នុងភាពក្រីក្រជាង អ្នកដែលមានសុវត្ថិភាពនៃការកាន់កាប់ដីធ្លី។ សុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី គឺជាការចូលរួមចំណែកដ៏ធំធេងក្នុងការកាត់បន្ថយភាពក្រីក្រ[២២០]។

---

[២១៤] NGO Forum & CCC: *ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងការកាត់បន្ថយភាពក្រីក្រ* -ដ- ទំព័រ៧។

[២១៥] World Bank: ***The Inspection Panel Report and Recommendation on the Request for Inspection,*** Re: Request for Inspection Cambodia: Land Management and Management Project (Credit No.3650-kh), WB, 2010, page1.

[២១៦] Xinhua News Agency: see also < http:/ki-media.blogspot.com/2009/09/cambodia-terminates-land-titling-html> ; Assessed on 5 February 2010-AM.

[២១៧] WB: see also on <http://web.worldbank.org/WBSITE/EXTERNAL/COUNTERIES/EASTASIAPACIFIC12/28/2009>. Page1.

[២១៨] World Bank: <***Land Management and Administration Project***>, Project Appraisal Document on a propose credit in the amount of SDR 19.3 million (US$24.3 million equivalent) to the Kingdom of Cambodia, Document of The World Bank, Report No:22869-kh, 2002, page7.

[២១៩] Jouni ANTTONEN: <***Systematic Registration of one million parcel in five year***> developing a successful Modern Cadastral the Cambodian Way, FIG Working Week 2008 Stockholm, Sweden, 14-19 June 2008 page5.

[២២០] WB: see also< http://web.worldbank.org/WBSITE/EXTERNAL/COUNTRIES/EASTASIAPACIFI C12/28/2009>. PAGE1

ការចុះបញ្ជីដីធ្លីមានបំណងតែមួយគត់ គឺបង្កើតឱ្យមានប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។ ច្បាប់ភូមិបាលឆ្នាំ២០០១ ក្នុងការរង់ចាំបង្កើតឡើងវិញនូវប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិចេញត្រឹមតែប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប៉ុណ្ណោះ[២២១]។ បន្ទាប់មកអនុក្រឹត្យពីរត្រូវបានបង្កើត(ទី១) ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលដីបញ្ជីដីធ្លី (ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ) និង (ទី២) អនុក្រឹត្យ ស្តីពីការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំត្រូវបានប្រកាសឱ្យប្រើ ។ ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធត្រូវធ្វើឡើងទៅតាមតំបន់វិនិច្ឆ័យដែលមាននៅតាម រាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា។ ការចុះបញ្ជីរបៀបនេះមានលក្ខណៈយឺតយ៉ាវពីព្រោះដើម្បីអាចចុះបញ្ជីដីធ្លីបាន ប្រជាពលរដ្ឋត្រូវរង់ចាំទាល់តែមានការប្រកាសពីតំបន់វិនិច្ឆ័យនៅទីតាំងដីរបស់ខ្លួន។ ហេតុដូចនេះ បានជាយើងឃើញមានអនុក្រឹត្យណែនាំពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ដើម្បីឱ្យមានភាពងាយស្រួល និងឆាប់រហ័សសម្រាប់ម្ចាស់ដីនានា។ យើងឃើញថា អនុក្រឹត្យទាំងពីរនេះមានលក្ខណៈដូចគ្នាត្រង់ថា នៅពេលដែលដីត្រូវបានចុះបញ្ជីរួចហើយរដ្ឋបាលសុរិយោដីត្រូវចេញវិញ្ញាប័នបត្រសំគាល់ម្ចាស់អចលនវត្ថុ ឱ្យកម្មសិទ្ធិករដែលបានចុះបញ្ជី ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុឱ្យភាគីដែលបានចុះបញ្ជី។ ដូចគ្នានេះដែរ នីតិវិធីទាំងពីរនេះបានដាក់ឱ្យមានការប្រកាសផ្សាយជាសាធារណៈនូវឯកសារ នៃការវិនិច្ឆ័យដែលរួមមានប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីដែលជាកម្មវត្ថុដ៏សំខាន់មួយក្នុងការតវ៉ា និងអាចឈានទៅរកការដោះស្រាយភ្លាមៗ ។

កន្លងមកការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដោយគំរោងគ្រប់គ្រង និងរដ្ឋបាលដីធ្លី LMAP ទទួលបានជោគជ័យលើសពីការគ្រោងទុកដែលកំណត់ចំនួន១លានប័ណ្ណក្នុងរយៈពេលប្រាំឆ្នាំដំណាក់កាលទី១[២២២]។ មុនមានគម្រោងកម្មវិធីនេះ ការចុះបញ្ជីដីនៅទូទាំងប្រទេសធ្វើឡើងដាច់ដោយដុំ មូលហេតុដោយសារគម្រោង LMAP មិនបានគ្របដណ្តប់នៅទូទាំងប្រទេស។ ខេត្តមួយចំនួននៅតែរក្សាការចុះបញ្ជីដីតាមប្រព័ន្ធចាស់គឺការចុះបញ្ជីដីដាច់ដោយដុំដដែល។ ហេតុដូច្នេះ នៅតំបន់ដែលអនុវត្តប្រព័ន្ធចាស់ បញ្ហាចាស់ក៏នៅតែបន្តដដែល ដូចជាសោហ៊ុយចំណាយខ្ពស់ តម្លៃក្រោមតុ និងការបង់ប្រាក់ក្រៅផ្លូវការជាដើម។ ប្រព័ន្ធចាស់ប្រជាពលរដ្ឋ ក្រីក្រមិនមានលទ្ធភាពក្នុងការធានាសន្តិសុខលើដីរបស់ពួកគេបានទេ។

ទោះបីប្រឈមនឹងបញ្ហាលំបាកមួយចំនួនក៏ដោយរដ្ឋាភិបាលសម្រេចបាន ការចុះបញ្ជីដីទាំងពីរប្រភេទចំនួន ១,៩០០,០០០ ប័ណ្ណ ក្នុងនោះការចុះបញ្ជីដាច់ដោយដុំមានចំនួន ២៨៨,០០០ ប័ណ្ណ ធ្វើឡើងនៅ ក្នុងទូទាំងឃុំចំនួន២៦៣ និង លើសង្កាត់ចំនួន៤៨ គិតមកត្រឹមឆ្នាំ២០០៩[២២៣]។ ទទឹម

[២២១] ព្រះរាជក្រម លេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល*៖ មាត្រា៤០។

[២២២] Mark Grimsditch and Nick Henderson: <***Untitled, Tenure Insecurity and Inequality in the Cambodia Land Sector***>, under Bridges Across Borders, COHRE and JSR, Phnom Penh, 2009, page34.

[២២៣] អ៊ឹម ឈុនលឹម: *មតិស្វាគមន៍ និងរបាយការណ៍របស់រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* ក្នុងឱកាសសន្និបាតបូកសរុបការងារឆ្នាំ ២០០៩ និងទិសដៅបន្តរបស់ក្រសួង ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១០ ទំព័រ៣។

នឹងលទ្ធផលវិជ្ជមានទាំងនេះ រដ្ឋាភិបាលក៏នៅសេសសល់បញ្ហាប្រឈមមួយចំនួន។ ជាបទពិសោធន៍នៃបណ្តាប្រទេសមួយចំនួនការកសាងប្រព័ន្ធគ្រប់គ្រងដីធ្លីមួយរឹងមាំ និង គ្រប់ជ្រុងជ្រោយតែងទាមទារនូវពេលវេលាមួយគ្រប់គ្រាន់ដើម្បីចងក្រងគោលនយោបាយ និង ក្របខណ្ឌគតិយុត្តមួយសមស្របដែលត្រូវបានជ្រួតជ្រាបដល់គ្រប់អ្នកពាក់ព័ន្ធ និង ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ការកសាងប្រព័ន្ធចុះបញ្ជីដីធ្លីមួយគ្រប់ជ្រុងជ្រោយ ទាំងការចុះបញ្ជីដំបូងដល់ការចុះបញ្ជីបន្ត ជាបន្តបន្ទាប់ និងត្រូវបានប្រជាពលរដ្ឋទូទៅជឿទុកចិត្ត និង ក្លាយទៅជា "វប្បធម៌ចុះបញ្ជី" វាទាមទារការខិតខំជាច្រើនថែមទៀត។ នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លីរបស់រដ្ឋាភិបាល ក៏បានលើកអំពីភាពមិនទាន់ច្បាស់លាស់នៃការគ្រប់គ្រងដីរដ្ឋ ដោយបញ្ជាក់ថា៖

> "ដីរដ្ឋមិនបានធ្វើអត្តសញ្ញាណកម្មច្បាស់លាស់ ហើយការគ្រប់គ្រងមិនបានត្រឹមត្រូវបន្ទាប់ពីដំណើរការអន្តរកាលដែលនាំទៅរកការបង្កើនល្បឿននៃការរំលោភយកដី និងការកាប់បំផ្លាញព្រៃឈើ"[២២៤]។

ផ្អែកតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ២០០៥ ដីរដ្ឋទាំងអស់ត្រូវចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ នៅក្នុងសៀវភៅគោលបញ្ជីដីធ្លី[២២៥]។ នៅក្នុងផ្ទៃដីសរុបចំនួន ១៨,១ លានហិកតា ផ្ទៃដីដែលគ្រប់គ្រងដោយរដ្ឋមាន១៤,៥ លានហិកតា ឬស្មើនឹង៨០ភាគរយ ចំណែកផ្នែកឯកជនគ្រប់គ្រងចំនួន៣,៦ លានហិកតា ឬស្មើនឹង២០ ភាគរយ[២២៦]។ ការចុះបញ្ជីដីរដ្ឋជាបញ្ហាធំហើយស្មុគស្មាញ កិច្ចការនេះត្រូវការពេលវេលា ធនធានមនុស្ស និងថវិកាច្រើន។ រដ្ឋាភិបាលបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តែការតាមដានរបស់ដៃគូអភិវឌ្ឍន៍ចំពោះការចុះបញ្ជីដីរដ្ឋរហូតមកដល់ពេលបច្ចុប្បន្ន មិនមានភាពជឿនលឿននោះទេ[២២៧]។ ការមិនមានភាពច្បាស់លាស់លើការគ្រប់គ្រងដីរដ្ឋ ធ្វើឱ្យការទន្ទ្រានដីរដ្ឋខុសច្បាប់ ការប្រមូលដីបង្កកទុកក្នុងដៃក្រុមមនុស្សមួយក្តាប់តូចនឹងនៅតែបន្តដែលការណ៍នេះ ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន និង ធនធានធម្មជាតិ។ ការគ្រប់គ្រងដីរដ្ឋជាផ្នែកគន្លឹះដែលបានកំណត់ នៅក្នុងគម្រោង LMAP ប៉ុន្តែផ្អែកតាមរបាយការណ៍របស់ធនាគារពិភពលោក ក្រៅពីការចេញប្រកាសស្តីពី ការធ្វើអត្តសញ្ញាណកម្ម ការធ្វើដែនទី និងការធ្វើចំណាត់ថ្នាក់ដី គឺមិនមានការរីកចម្រើនទេក្នុងផ្នែកនេះ[២២៨]។ កង្វះដំណើរការនៃការគ្រប់គ្រង

---

[២២៤] រាជរដ្ឋាភិបាលៈ *ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី* ឯកការបឋម អនុម័តដោយគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០២ ទំព័រ១០។

[២២៥] អនុក្រឹត្យ លេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពី *ការគ្រប់គ្រងដីរដ្ឋ* ៖ មាត្រា៣។

[២២៦] ព្រះរាជក្រម លេខ នស រកម ០៦១០ ០១២ ស្តីពី *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩ -២០១៣* ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ ទំព័រ៥៨។

[២២៧] Medicam, NGO Forum, CCC: <***NGO Position Papers on Cambodia's Development in 2009-2010 to the 3rd Cambodia Development Cooperation Forum***>, published by NGO Forum on Cambodia, Phnom Penh, 2010, page54.

[២២៨] Medicam, NGO Forum, CCC: <***NGO Position Papers on Cambodia's Development in 2009-2010 to the 3rd Cambodia Development Cooperation Forum***>, published by NGO Forum on Cambodia, Phnom Penh, 2010, page54. In World Bank (2009) Cambodia Land Management and Administration project, Enhanced Review mission.

ដីរដ្ឋពេញលេញធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គោលបំណងរបស់រាជរដ្ឋាភិបាល ដើម្បីលើកស្ទួយសុវត្ថិភាពនៃការកាន់កាប់ ការចេញប័ណ្ណកម្មសិទ្ធិនៅទូទាំងប្រទេសលើការគ្រប់គ្រង និងការពារបរិស្ថាន និងធនធានធម្មជាតិ។

តែទោះបីជាយ៉ាងណា រាជរដ្ឋាភិបាលបានកំពុងជំរុញដំណើរការចុះបញ្ជីដីរដ្ឋ នាពេលអនាគតដោយបានដាក់បញ្ចូលកិច្ចការនេះ ទៅក្នុងទាំងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និង ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ របស់ប្រទេសជាតិទាំងមូលដែលក្លាយទៅជាច្បាប់ប្រកាសឱ្យប្រើតាមព្រះរាជក្រម នស រកម០៦១០ ០១២ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០។ ជាក់ស្តែងផ្ទៃដីសរុបចំនួន ៣៦,៩១៧ ហិកតា នៅក្នុងខេត្តចំនួន១២ រាជរដ្ឋាភិបាលបានកំណត់មុខសញ្ញារួចហើយ[២២៩]។ ចំនួននេះបើប្រៀបធៀបដីរដ្ឋទាំងមូលចំនួន ៨០ ភាគរយ គឺការចុះបញ្ជីដីរដ្ឋមានចំនួនតិចតួចបំផុត។ ម៉្យាងវិញទៀត រវាងផែនការនៅលើក្រដាស់ និង ការអនុវត្តជាក់ស្តែងវាខុសគ្នាច្រើន។ ដូច្នេះប្រវត្តិនៃបញ្ហាដ៏រាំរ៉ៃដែលកើតឡើងជាងពីទសវត្សរ៍ និង ដែលរដ្ឋាភិបាលដោះស្រាយមិនចេះចប់នឹងនៅតែបន្តទៅទៀតនាពេលអនាគត។

## ២.២.៣ ចំណាត់ថ្នាក់ដីរដ្ឋ

ច្បាប់ភូមិបាលឆ្នាំ២០០១ បែងចែកដីនៅកម្ពុជាជាប្រាំប្រភេទគឺ (ទី១)ដីកម្មសិទ្ធិឯកត្តជន (ទី២)ដីកម្មសិទ្ធិវត្ត (ទី៣)ដីកម្មសិទ្ធិសមូហភាពជនជាតិដើមភាគតិច (ទី៤)ដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ និង (ទី៥)ដីកម្មសិទ្ធិឯកជនរបស់រដ្ឋ។ ដីឯកត្តជន ជាដីរបស់អ្នកកាន់កាប់មានប័ណ្ណសំគាល់កម្មសិទ្ធិស្របតាមច្បាប់ និងជាផ្លូវការ ឬជាដីភោគៈស្របច្បាប់អ្នកកំពុងកាន់កាប់ត្រូវបង្ហាញភស្តុតាងថា ពួកគេរស់នៅលើដីនោះ ចាប់តាំងពីមុនពេលច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវបានអនុម័ត និងបង្ហាញថា ពួកគេបានបំពេញលក្ខខណ្ឌប្រាំយ៉ាងអំពីភោគៈស្របច្បាប់។ ទ្រព្យជាកម្មសិទ្ធិឯកជនអាចជាកម្មសិទ្ធិរបស់បុគ្គលម្នាក់ ក្រុមហ៊ុន ឬកម្មសិទ្ធិរួមដែលមានគ្នាច្រើនលើសពីម្នាក់[២៣០]។ ដីរដ្ឋដែលបានប្រើប្រាស់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ហៅថា ដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ។ ដីប្រភេទនេះរួមមាន ដីដែលមានលក្ខណៈពីធម្មជាតិ ដូចជាទន្លេ បឹងបួរ ព្រៃក ស្ទឹង ដីសម្រាប់ការប្រើប្រាស់ក្នុងការផ្តល់សេវាកម្ម ឬផ្តល់ផលប្រយោជន៍ដល់សាធារណៈ ដូចជាផ្លូវថ្នល់សួនច្បារ មន្ទីរពេទ្យ និងសាលារៀនរបស់រដ្ឋ ដីតំបន់ភូមិសាស្រ្តសម្រាប់ស្រាវជ្រាវវត្ថុបុរាណឬតំបន់ដែលមានតម្លៃបេតិកភ័ណ្ឌ។ ដីទាំងអស់នេះមិនមានអ្នកណាម្នាក់អាចយកធ្វើជាកម្មសិទ្ធិ ឬជាភោគៈបានទេ លើកលែងរដ្ឋតែមួយគត់ទើបមានសិទ្ធិ[២៣១]។

---

[២២៩] ព្រះរាជក្រម លេខ នស រកម ០៦១០ ០១២ ស្តីពី *ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩ -២០១៣* ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ ទំព័រ៥៨។

[២៣០] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល*៖ មាត្រា ១០។

[២៣១] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល*៖ មាត្រា ១៥-១៦។

មានភាពខុសគ្នាចំពោះកម្មសិទ្ធិសមូហភាព រវាងដីកម្មសិទ្ធិសមូហភាពជនជាតិដើមភាគតិច និង ដីកម្មសិទ្ធិរបស់វត្ត។ ដីកម្មសិទ្ធិរបស់វត្ត មានលក្ខណៈសាមញ្ញ និងជាអចលនវត្ថុដែលស្ថិតនៅក្នុងបរិវេណវត្ត ដែលជារបស់ពុទ្ធសាសនិកដែលតាមច្បាប់ភូមិបាលនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការវត្ត[២៣២]។ កម្មសិទ្ធិប្រភេទនេះមិនមែនជារបស់បុគ្គលណាម្នាក់ទេ និងមិនអាចផ្ទេរបានឡើយ។ ដូចគ្នានេះដែរ ដីសហគមន៍ជនជាតិដើមភាគតិច សិទ្ធិកម្មសិទ្ធិសំដៅលើសមូហភាពតាមរយៈការកាន់កាប់តាមបែបប្រពៃណីរបស់សហគមន៍។ នៅពេលដែលបានចុះបញ្ជីរួច ដីកម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច នឹងក្លាយជាដីកម្មសិទ្ធិស្របច្បាប់របស់សហគមន៍ ជាមួយគ្នានេះដែរ សហគមន៍មានសិទ្ធិជាកម្មសិទ្ធិករឯកជន ទោះបីត្រូវអនុវត្តតាមច្បាប់ប្រពៃណីរបស់សហគមន៍ក៏ដោយ។ មកដល់ចុងឆ្នាំ២០១០ នេះហើយ ការចុះបញ្ជីកម្មសិទ្ធិសមូហភាពជនជាតិដើមភាគតិច នៅតែមិនមានដំណើរការនៅឡើយ។ តែទោះបីជាយ៉ាងណា ច្បាប់ភូមិបាលឆ្នាំ២០០១ មានមាត្រាមួយចំនួនបានចែងការពារជាបណ្តោះអាសន្ន ដោយបញ្ជាក់ថា ដីរាបណានៅមិនទាន់ចុះបញ្ជីទេ សហគមន៍ជនជាតិដើមភាគតិចគប្បីត្រូវបន្តគ្រប់គ្រងដីរបស់ខ្លួនតាមប្រពៃណី[២៣៣]។

ដីឯកជនរបស់រដ្ឋជាដីទាំងឡាយណាដែលជារបស់រដ្ឋ ហើយមិនស្ថិតនៅក្រោមលក្ខខណ្ឌនៃដីសាធារណៈរបស់រដ្ឋ ឬជាដីដែលមិនមែនជាកម្មសិទ្ធិ ឬកាន់កាប់ស្របច្បាប់ជាលក្ខណៈឯកជន ឬសមូហភាព ទៅតាមច្បាប់ភូមិបាលឆ្នាំ២០០១។ ដីកម្មសិទ្ធិឯកជនរបស់រដ្ឋមិនដូច ដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋទេ ព្រោះថាដីកម្មសិទ្ធិឯកជនរបស់រដ្ឋ វាអាចជាកម្មវត្ថុនៃការលក់ ការផ្លាស់ប្តូរ ការបែងចែក ឬផ្ទេរសិទ្ធិបាន[២៣៤]។ ដីឯកជនរបស់រដ្ឋពុំទាន់មានការកំណត់អត្តសញ្ញាណ និងពុំទាន់មានផែនទី និងការចុះបញ្ជីដីរដ្ឋទេ ដូចគ្នានេះដែរ ក៏មិនទាន់មានការកំណត់ច្បាស់លាស់នូវដីជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋដែរ។ តាមការអនុវត្តជាក់ស្តែង គេមិនឃើញមានការទទួលស្គាល់សិទ្ធិភោគៈរបស់ប្រជាពលរដ្ឋ តាមរយៈការមិនចេញប័ណ្ណកម្មសិទ្ធិដល់អ្នកស្នើសុំ ដោយសំអាងថា រស់នៅលើដីរបស់រដ្ឋដោយខុសច្បាប់[២៣៥]។ ហេតុផលដែលរដ្ឋបដិសេធសិទ្ធិភោគៈ ស្របច្បាប់របស់អ្នកកាន់កាប់ គឺដោយសំអាងថា ដីនោះជាដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ឬមិនមែន ដែលនេះមិនអាចបញ្ជាក់បានទេ ពីព្រោះពុំមានព័ត៌មានជាក់ឱ្យមើលឃើញជាសាធារណៈដែលអាចបញ្ជាក់ថា ដីនោះជាកម្មសិទ្ធិសាធារណៈ និងមិនមែនជាដីកម្មសិទ្ធិសាធារណៈ។ ម៉្យាងវិញទៀត មកដល់ពេលនេះពុំមានឯកសារផ្លូវការណាមួយ បញ្ជាក់អះអាងថា អ្វីជាដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ដែលដាក់បង្ហាញឱ្យសាធារណៈជនបានឃើញ។ ប្រជាពលរដ្ឋមិនអាចតវ៉ាចំពោះការអះអាងរបស់រដ្ឋ ដែលសហគមន៍កំពុងរស់នៅដោយខុសច្បាប់លើដីរដ្ឋ[២៣៦]។ ហេតុដូចនេះទើប ប្រជាពលរដ្ឋខ្មែររាប់ម៉ឺននាក់ ប្រឈមនឹងឧបសគ្គយ៉ាងខ្លាំង ក្នុងការទទួលស្គាល់ឱ្យបានត្រឹមត្រូវចំពោះភោគៈស្របច្បាប់របស់ពួកគេ។

---

[២៣២] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល*៖ មាត្រា ២១-២២។

[២៣៣] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល*៖ មាត្រា ២៣។

[២៣៤] អនុក្រឹត្យ លេខ ១១៨ អនក្រ បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពី ***ការគ្រប់គ្រងដីរដ្ឋ***៖មាត្រា ៥។

[២៣៥]ជ CHRAC: ***Losing Ground,*** *ibit*, page 67.

[២៣៦] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល*៖ មាត្រា ១៨-១៩។

## ២.២.៤ សម្បទានដី

សម្បទានដីសេដ្ឋកិច្ច គឺជាការចុះកិច្ចសន្យាជួលដីឯកជនរបស់រដ្ឋ ឬការបែងចែកដីប្រភេទនេះដោយរដ្ឋាភិបាលទៅឱ្យក្រុមហ៊ុន ឬប្រជាពលរដ្ឋ។ សម្បទានដីសេដ្ឋកិច្ចត្រូវរដ្ឋផ្តល់ទៅឱ្យក្រុមហ៊ុនជាច្រើនកន្លែងក្នុងគោលបំណងឆ្លើយតបនឹងប្រយោជន៍សង្គម ឬទៅនឹងប្រយោជន៍សេដ្ឋកិច្ច។ ការផ្តល់ដីតាមរយៈកិច្ចសន្យាជួលដីដើម្បីធ្វើអាជីវកម្មកសិឧស្សាហកម្មសម្រាប់រយៈពេលវែង[២៣៧]។ រដ្ឋាភិបាលអាចផ្តល់សម្បទានដីសេដ្ឋកិច្ចបានចំពោះតែដីកម្មសិទ្ធិរបស់រដ្ឋតែមួយគត់[២៣៨] និងទំហំដីច្រើនបំផុតត្រឹមតែ ១០,០០០ ហិកតា[២៣៩]។ សម្បទានដីនេះមានរយៈពេលកំណត់ត្រឹមតែ៩៩ឆ្នាំ[២៤០]។ សម្បទានិកត្រូវតែចាប់ធ្វើអាជីវកម្មលើដីសម្បទាននេះក្នុងរយៈពេល១២ខែ ក្រោយពីបានទទួលដី[២៤១]។ រាល់សម្បទានទាំងឡាយណាដែលមិនគោរពតាមច្បាប់ភូមិបាលត្រូវចាត់ទុកជាមោឃៈ[២៤២]។

អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចបានបន្ថែមលក្ខខណ្ឌពិសេសមួយចំនួន សម្រាប់ការអនុវត្ត និង ការផ្តល់សម្បទានដីសេដ្ឋកិច្ច។ លក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ចមានដូចជា[២៤៣]៖

១. ដីដែលបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ ស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លីឬអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។ នៅចំណុចនេះ គេអាចមើលឃើញថាមានសម្បទានដីជាច្រើន នៅតាមតំបន់ដែលស្ថិតនៅក្នុងនិយមន័យដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ និងអាជ្ញាធរដែលផ្តល់ដីសម្បទាន បានទទួលរបាយការណ៍មិនពិតអំពីការកំណត់នេះ ដោយគ្រាន់តែបញ្ជាក់ថា តំបន់នោះបានបាត់បង់ផលប្រយោជន៍សាធារណៈ ហើយត្រូវធ្វើចំណាត់ថ្នាក់ដីឡើងវិញថាជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ[២៤៤]។

២. ដីដែលមានផែនការប្រើប្រាស់ដី អនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត ក្រុង ហើយការប្រើប្រាស់មានលក្ខណៈស្របតាមផែនការ។

៣. ដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចំពោះការប្រើប្រាស់ និងការអភិវឌ្ឍដីសម្រាប់គម្រោងសម្បទាន។

៤. ដីដែលមានដំណោះស្រាយចំពោះបញ្ហាតាំងទីលំនៅថ្មី ស្របតាមលក្ខខណ្ឌគតិយុត្ត និងនីតិវិធីជាធរមាន។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធានាថា មិនមានការបង្ខំឱ្យធ្វើការតាំងទី

[២៣៧] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល*** ៖ មាត្រា ៤៩។
[២៣៨] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល*** ៖ មាត្រា ១៧-៤៨។
[២៣៩] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល*** ៖ មាត្រា ៥៩។
[២៤០] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល*** ៖ មាត្រា ៦១។
[២៤១] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល*** ៖ មាត្រា ៦២។
[២៤២] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល*** ៖ មាត្រា ១៨។
[២៤៣] អនុក្រឹត្យ លេខ១៤៦ អនក្រ បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពី ***សម្បទានដីសេដ្ឋកិច្ច*** ៖ មាត្រា ៤។
[២៤៤] CHRAC: <***Losing Ground***>,page 68.

លំនៅថ្មីដោយគ្មានការស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និង ត្រូវជានាចំពោះការគោរពសិទ្ធិមានច្រកចេញចូលទៅកាន់ដីឯនជន។ និង

៥. ដីដែលមានការពិគ្រោះយោបល់ជាសាធារណៈអំពីគម្រោងឬសំណើសម្បទានដីសេដ្ឋកិច្ចជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលនៅក្នុងតំបន់។

ចំពោះអ្នកមានសិទ្ធិផ្តល់ដីសម្បទានសេដ្ឋកិច្ច គឺរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ទទួលខុសត្រូវក្នុងការផ្តល់ដីសម្បទាន ដែលមានទុនវិនិយោគចាប់ពី ១០,០០០,០០០,០០០ (ដប់ពាន់)លានរៀលឡើង ឬមានទំហំដីសម្បទានចាប់ពី ១,០០០ ហិកតា[២៤៥] តែទោះបីជាយ៉ាងណាមិនឱ្យលើសពីចំនួន ១០,០០០ ហិកតា[២៤៦]។ អភិបាលខេត្ត ក្រុងមានសិទ្ធិ និងទទួលខុសត្រូវក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច ដែលមាន ទុនវិនិយោគក្រោម ១០,០០០,០០០,០០០ (ពាន់លាន)រៀល និងមានទំហំដីសម្បទានក្រោម ១,០០០ ហិកតា[២៤៧]។ ក៏ប៉ុន្តែសិទ្ធិ អំណាចថ្នាក់ខេត្តក្រុងត្រូវលប់ចោលនៅឆ្នាំ២០០៨[២៤៨] មូលហេតុ គឺដោយសារវិវាទដីធ្លីកើតឡើងពីបញ្ហាសម្បទានសេដ្ឋកិច្ចនេះច្រើនពេក។ នាពេលបច្ចុប្បន្ននេះ មានតែក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទតែមួយគត់ជាអ្នកមានសិទ្ធិផ្តល់នូវសម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា។

សម្បទានដីសង្គមកិច្ច គឺជាយន្តការផ្ទេរដីឯកជនរបស់រដ្ឋតាមផ្លូវច្បាប់សម្រាប់គោលបំណងសង្គមកិច្ចដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅឋាន និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ[២៤៩]។ តាមការបញ្ជាក់នៃច្បាប់ភូមិបាល រដ្ឋផ្តល់សម្បទានសម្រាប់គោលបំណងបម្រើផលប្រយោជន៍សង្គម[២៥០] ដែលនេះគឺជាប្រភេទនៃសម្បទានដីសង្គមកិច្ច។ សម្បទានដីនេះ មិនដូចសម្បទានដីផ្សេងៗទៀតទេ បុគ្គលដែលទទួលបានដីអាចត្រូវក្លាយជាម្ចាស់កម្មសិទ្ធិ បើពួកគេបានបំពេញតាមលក្ខខណ្ឌកំណត់ដោយច្បាប់[២៥១]។ ជាការពិតរដ្ឋមានបំណងផ្តល់កម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋក្រីក្រតាមរយៈយន្តការសម្បទានដីសង្គមកិច្ចនេះ។ ការកំណត់លក្ខខណ្ឌមួយចំនួនមានដូចគ្នានឹងសម្បទានដីសេដ្ឋកិច្ចដែរ នីតិវិធីនៃការផ្តល់សម្បទានដីសង្គមកិច្ចនេះ មានចែងលក្ខខណ្ឌតម្រូវនានា សម្រាប់ដំណាក់កាលនីមួយៗដែលមានផែនការប្រើប្រាស់ដី ការវាយតម្លៃវត្តមានហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន ការកំណត់អត្តសញ្ញាណទីតាំងបច្ចុប្បន្ន ព័ត៌មានលំអិត ដំណើរការដាក់ពាក្យសុំ ការប្រើប្រាស់ និងការត្រៀមបំរុងទុកអំពីក្រុមគោលដៅដែលទទួលដីសម្បទាន និងការវាយតម្លៃផលប៉ះពាល់

---

[២៤៥] អនុក្រឹត្យ លេខ១៤៦ អនក្រ បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពី ***សម្បទានដីសេដ្ឋកិច្ច*** ៖ មាត្រា ២៩។

[២៤៦] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល*** ៖ មាត្រា ៥៩។

[២៤៧] លេខ១៤៦ អនក្រ បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពី ***សម្បទានដីសេដ្ឋកិច្ច*** ៖ មាត្រា ២៩។

[២៤៨] អនុក្រឹត្យ លេខ ១៣១ អនក្រ បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ***ការកែសម្រួលនៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច*** ៖ មាត្រា១។

[២៤៩] អនុក្រឹត្យ លេខ ១៩ អនក្រ បក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៣ ស្តីពី ***សម្បទានដីសង្គមកិច្ច*** ៖មាត្រា ២។

[២៥០] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល*** ៖ មាត្រា ៤៩។

[២៥១] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល*** ៖ មាត្រា ១៨ និង៥២។

សេដ្ឋកិច្ចសង្គមនិងបរិស្ថានជាដើម[២៥២]។ រដ្ឋាភិបាលផ្តល់ដីសម្បទានសង្គមកិច្ច សម្រាប់សង់លំនៅឋាន ឬ សម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ឬសម្រាប់គោលដៅទាំងពីរ[២៥៣]។

នៅពេលសម្បទានដីត្រូវរៀបចំសម្រាប់គោលដៅសាងសង់លំនៅឋាន ក្នុងករណីមិនមានហេដ្ឋារចនាសម្ព័ន្ធនៅនឹងកន្លែងទេ មុខសញ្ញាទទួលដីត្រូវតែសាងសង់យ៉ាងហោចណាស់នូវចំណែកណាមួយនៃជម្រកស្នាក់នៅអចិន្ត្រៃយ៍ ក្នុងរយៈពេល៣ខែ និងបន្ទាប់ពីបានទទួលដី ហើយសមាជិកនៃគ្រួសារនោះត្រូវរស់នៅពិតប្រាកដ និងជាអចិន្ត្រៃយ៍លើដីនោះឱ្យបាន៦ខែក្នុងមួយឆ្នាំ។ អ្នកទទួលដីត្រូវធ្វើកសិកម្មជាលក្ខណៈគ្រួសារ ត្រូវធ្វើកសិកម្មជាក់ស្តែងក្នុងរយៈពេល១២ខែ បន្ទាប់ពីទទួលដីសម្បទាន។ ប្រសិនបើលក្ខខណ្ឌនៃសម្បទានត្រូវបានបំពេញ ឬអនុវត្តបានរយៈពេលប្រាំឆ្នាំ ម្ចាស់ដីសម្បទានមានសិទ្ធិទទួលបានកម្មសិទ្ធិលើដីនេះ និង អាចស្នើសុំប័ណ្ណសំគាល់កម្មសិទ្ធិពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ នៅអំឡុងប្រាំឆ្នាំនេះ អ្នកទទួលដីមិនអាចលក់ ដូរ ជួល ឬធ្វើអំណោយដីសម្បទានបានទេ។ បើសិនជាអ្នកទទួលដីខកខានមិនបានបំពេញតាមលក្ខខណ្ឌនេះទេ ដីនេះនឹងត្រូវវិលមកជាដីរបស់រដ្ឋវិញដើម្បីធ្វើការបែងចែកសារជាថ្មី[២៥៤]។

កម្មវិធីបែងចែកដីធ្លីដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមរបស់រាជរដ្ឋាភិបាលមានលក្ខណៈរីកចម្រើនផ្អែកទៅតាមការលើកឡើងរបស់អង្គការមិនមែនរដ្ឋាភិបាល[២៥៥]។ គម្រោងធ្វើការបែងចែកដីជូនប្រជាពលរដ្ឋក្រីក្រមានដីតិចតួច ឬខ្វះដីតាមរយៈយន្តការសម្បទានដីសង្គមកិច្ច។ គម្រោងនេះគឺជាគម្រោងសាកល្បងអនុវត្តនៅឃុំជំក្រវៀន នៅខេត្តកំពង់ចាម និងឃុំសំបុក និងឃុំឆោមក្រុង ស្រុកឆ្លូង ខេត្តក្រចេះ។ មូលនិធិសម្រាប់ការអនុវត្តគម្រោងសាកល្បងនេះ ទទួលពីធនាគារពិភពលោកចំនួន១១.៥ លានដុល្លាអាមេរិក[២៥៦] និង ជំនួយបច្ចេកទេសពីប្រទេសអាល្លឺម៉ង់នៅក្នុងខែមេសា ឆ្នាំ២០០៨។ ការអនុវត្តគម្រោង បើមិនមានគោលការណ៍គ្រប់គ្រាន់សម្រាប់អនុវត្តទេនោះ រដ្ឋអាចនឹងផ្តល់ដីសម្បទានសង្គមកិច្ចនេះប៉ះពាល់លើតំបន់ដែលមានអ្នកគ្រប់គ្រង ឬ អ្នកប្រើប្រាស់រួចហើយ[២៥៧] និង អាចបណ្តាលឱ្យមានការកើនឡើងនូវអ្នកគ្មានដីថែមទៀត។

## ២.៣ យន្តការដោះស្រាយវិវាទដីធ្លី

ជាទូទៅ ការដោះស្រាយវិវាទដីធ្លីនៅក្នុងប្រទេសជាច្រើន មានយន្តការដោះស្រាយតាមរបៀបផ្សេងៗគ្នាទៅតាមបរិបទ និង ការជ្រើសរើសរបស់អ្នកដឹកនាំប្រទេសនោះ។ តែជារួមទោះបីជាយកជំរើសតាមវិធីណាក៏ដោយ គេអាចនិយាយជាសង្ខេបបានថា វាស្ថិតនៅក្នុងតែរបៀបផ្លូវការ និង មិនផ្លូវ

---

[២៥២] អនុក្រឹត្យ លេខ ១៩ អនក្រ បក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៣ ស្តីពី ***សម្បទានដីសង្គមកិច្ច*** ៖មាត្រា ៩។

[២៥៣] អនុក្រឹត្យ លេខ ១៩ អនក្រ បក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៣ ស្តីពី ***សម្បទានដីសង្គមកិច្ច*** ៖មាត្រា ១៥

[២៥៤] អនុក្រឹត្យ លេខ១៩ អនក្រ បក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៣ ស្តីពី ***សម្បទានដីសង្គមកិច្ច*** ៖មាត្រា ១៨។

[២៥៥] CHRAC: ***Losing Ground***, op.cit. page 68.

[២៥៦] World Bank: ***World Bank helps Government with road and land for the poor***, Newsletter, Volume6, Number 6 and 7 page3.

[២៥៧] អង្គការអុកស្វាមអង់គ្លេសនៅកម្ពុជា បានធ្វើការសាកល្បងអនុវត្តយន្តការសម្បទានដីសង្គមកិច្ច ដោយចាប់ផ្តើមស្វែងរកដីទំនេរ។ ក្រោយពីអាជ្ញាធរខេត្តបានចង្អុលបង្ហាញទីតាំងដីទំនេរជាច្រើនកន្លែង បុគ្គលិកអង្គការនេះបានព្យាយាម ទៅដល់គ្រប់កន្លែងដែលបានប្រាប់ ក៏ប៉ុន្តែពេលដែលគេចុះដល់ទីកន្លែង ដីទាំងអស់នោះ មានអ្នកកាន់កាប់ជាច្រើនរួចជា ស្រេច ភាគច្រើនអ្នកកាន់កាប់ដីនោះសុទ្ធតែជាប្រជាពលរដ្ឋក្រីក្រដែលមកពីខេត្តនានាជាច្រើន។

ការដែលអាចឱ្យភាគីស្វែងរកផលប្រយោជន៍របស់ពួកគេ ដូចជាការដោះស្រាយតាមរបៀបដូចបានរៀបរាប់នៅខាងក្រោមនេះ៖[២៥៨]។

-តុលាការ -តុលាការពិសេសផ្នែកដីធ្លី

-រដ្ឋបាល -ស្ថាប័ននយោបាយ

-ប្រព័ន្ធគណៈបក្ស -ស្ថាប័នប្រពៃណី

-ស្ថាប័នសាសនា -សង្គមស៊ីវិល និង

-អ្នកសម្រុះសម្រួលវិស័យឯកជន

ស្ថាប័នទាំងអស់ខាងលើនេះ គឺដោះស្រាយទៅតាមកម្រិតខុសៗគ្នា ប្រទេសខ្លះកំណត់ត្រឹមកម្រិតបែបរដ្ឋបាល ប្រទេសខ្លះទៀតកំណត់កម្រិតបែបតុលាការ។ ស្ថាប័នខ្លះដោះស្រាយមានលក្ខណៈផ្លូវការ ហើយច្បាប់បានចែងទុកជាស្រេច នៅពេលដែលស្ថាប័នផ្សេងទៀត ដោះស្រាយក្រៅផ្លូវការ និង មិនមានច្បាប់ចែងទុក ដូចជា ការដោះស្រាយទៅតាមទំនៀមទម្លាប់ប្រពៃណីជាដើម។ ទោះបីជា ស្ថាប័នណាដោះស្រាយវិវាទដីធ្លីមានលក្ខណៈផ្លូវការ និង ក្រៅផ្លូវការក៏ដោយ និងជាពិសេសនៅថ្នាក់មូលដ្ឋាន ការដោះស្រាយមានលក្ខណៈផ្សេងគ្នា ពីប្រទេសមួយទៅប្រទេសមួយទៀត។ តារាងខាងក្រោមនេះ បង្ហាញអំពីភាពខុសគ្នានៃយន្តការស្ថាប័នដោះស្រាយវិវាទដីធ្លីមានកម្រិតខុសគ្នា និងតាមរយៈប្រព័ន្ធផ្សេងៗគ្នា។

តារាងទី៧៖ ស្ថាប័នដោះស្រាយវិវាទដីធ្លីនៅសកលលោក

| ប្រព័ន្ធ | ភូមិ សហគមន៍ អ្នកជិតខាង | ស្រុក ក្រុង | ខេត្ត | ជាតិ |
|---|---|---|---|---|
| តុលាការ | | -តុលាការ ស្រុក ក្រុង | -តុលាការ ខេត្ត រាជធានី | តុលាការ ជាន់ខ្ពស់ |
| តុលាការ ពិសេស | | -តុលាការដី ថ្នាក់ស្រុក | -តុលាការដី ថ្នាក់ខេត្ត រាជធានី | -តុលាការ ដីថ្នាក់ជាតិ<br>-គណៈកម្មាធិការ ដោះស្រាយ វិវាទប្លង់ដី<br>-គណៈកម្មការ ដោះស្រាយ វិវាទព្រំដី |
| រដ្ឋបាល | | -អាជ្ញាធរដីធ្លី ថ្នាក់ស្រុក<br>-គណៈកម្មការ | -អាជ្ញាធរដីធ្លី ថ្នាក់ខេត្ត<br>-គណៈកម្មការ | -ក្រសួងដីធ្លី<br>-គណៈកម្មការ សុរិយោដី |

[២៥៨] Betette Wehrmann: <***Land Conflicts, A Practical Guide to Dealing with Land Disputes***>, GTZ Land Management, 2008, ISBN 978-3-00-023940-3, page75-76.

| | | | | |
|---|---|---|---|---|
| | | សុរិយោដី | សុរិយោដី | |
| ស្ថាប័ន នយោបាយ | -ប្រធានភូមិ<br>-ក្រុមប្រឹក្សាភូមិ | -ចៅហ្វាយក្រុង<br>-អភិបាលស្រុក<br>-ក្រុមប្រឹក្សាស្រុក | -អភិបាលខេត្ត<br>-ក្រុមប្រឹក្សាខេត្ត<br>-រាជធានី | -ប្រធានាធិបតី<br>-នាយករដ្ឋមន្ត្រី<br>-ខុទ្ទកាល័យ រដ្ឋមន្ត្រី |
| ប្រព័ន្ធ គណៈបក្ស | -ភូមិ តំបន់ គណៈកម្មាធិការ គណៈបក្ស | -គណៈកម្មាធិការគណៈបក្ស ស្រុក | -គណៈកម្មាធិការ គណៈបក្សខេត្ត | -គណៈកម្មាធិការ គណៈបក្សថ្នាក់ កណ្តាល |
| ស្ថាប័ន ប្រពៃណី | -ប្រធានស្ថាប័ន ប្រពៃណី<br>-ប្រធានដី<br>-ក្រុមប្រឹក្សាចាស់ទុំ | | | |
| ស្ថាប័ន សាសនា | -បុព្វជិត គ្រឹះសាសនា<br>-លោកសង្ឃ<br>-ក្រុមប្រឹក្សាវិហារ ចាមមេដឹកនាំ-អ៊ីមុាំ<br>-អ្នកបង្រៀបច្បាប់ | | -សង្ឃរាជ ថ្នាក់ខេត្ត<br>-គ្រឹះសាសនា | |
| សង្គមស៊ីវិល និង ផ្នែកឯកជន | -អង្គការមិនមែន រដ្ឋាភិបាលមូលដ្ឋាន<br>-អង្គការសហគមន៍ មូលដ្ឋាន<br>-អ្នកសម្រុះសម្រួល មានវិជ្ជាជីវៈ<br>-ចាស់ទុំ<br>-អ្នកជិតខាង<br>-ប្រធានក្រុមប្រឹក្សា មូលដ្ឋាន<br>-គ្រូបង្រៀន | -អង្គការមិនមែន រដ្ឋាភិបាល ថ្នាក់ស្រុក<br>-សង្គមស៊ីវិល<br>-អ្នក សម្រុះសម្រួល មានវិជ្ជាជីវៈ | -អង្គការមិនមែន រដ្ឋាភិបាលថ្នាក់ខេត្ត<br>-សង្គមស៊ីវិល<br>-អ្នកសម្រុះសម្រួល មានវិជ្ជាជីវៈ | -អង្គការមិនមែន រដ្ឋាភិបាល ថ្នាក់ជាតិ<br>-សង្គមស៊ីវិល<br>-អ្នក សម្រុះសម្រួល មានវិជ្ជាជីវៈ |

## ២.៣.១ គណៈកម្មការសុរិយោដី

ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មការសុរិយោដី ដោយយោងទៅតាមច្បាប់ភូមិបាលមាត្រា៤៧ ដែលចែងថា "វិវាទរវាងភាគីចំពោះអចលនវត្ថុមួយនឹងត្រូវដាក់ឱ្យធ្វើការស៊ើបអង្កេត និង ដោះស្រាយតាមនីតិវិធីដែលបានកំណត់" ។ លទ្ធផលនៃការស៊ើបអង្កេតត្រូវដាក់ជូនគណៈកម្មការសុរិយោដី ដែលបង្កើតឡើងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គណៈកម្មការនេះត្រូវធ្វើសេចក្តីសម្រេចលើបដិវាទកម្មនោះ។ ក្នុងករណីមិនសុខចិត្តគូវិវាទ អាចប្តឹងទៅតុលាការបាន។ ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។ គណៈកម្មការនេះមានភារកិច្ចដើម្បីដោះស្រាយ តែវិវាទដីធ្លីណាដែលមិនទាន់ចុះបញ្ជី វិវាទនោះកើតនៅក្រៅតំបន់វិនិច្ឆ័យ និង វិវាទទាំងឡាយណាដែលមិនអាចសម្រុះសម្រួលបានដោយគណៈកម្មការរដ្ឋបាល។ ការសម្រុះសម្រួលវិវាទត្រូវអនុវត្តតាមទម្លាប់ប្រពៃណី និង បច្ចេកទេសសុរិយោដី[២៥៩]។

គណៈកម្មការសុរិយោដីមានរចនាសម្ព័ន្ធដូចតទៅ (ទី១)គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ (ទី២) គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង[២៦០] និង(ទី៣)គណៈកម្មការសុរិយោដីថ្នាក់ជាតិ។ គណៈកម្មការនេះមានលេខាធិការដ្ឋាន និង អង្គភាពស៊ើបអង្កេតរបស់ខ្លួន។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌមានសិទ្ធិប្រើប្រាស់ត្រារបស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងភូមិបាលស្រុកខណ្ឌ។ ចំណែកថ្នាក់ខេត្តមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត និងថ្នាក់ជាតិមានសិទ្ធិប្រើត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់[២៦១]។ ក្រោយដាក់ឱ្យអនុវត្តមួយរយៈឃើញថា គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដំណើរការទៅមិនមានប្រសិទ្ធភាពពីព្រោះគណៈកម្មការនេះមិនមានអភិបាលស្រុកចូលរួម ដូច្នេះគណៈកម្មការមិនមានឥទ្ធិពលក្នុងកិច្ចការរបស់ខ្លួន។ ដោយឃើញបញ្ហាដូចនេះ រដ្ឋាភិបាលក៏បានធ្វើការកែប្រែលើមាត្រា៥ និងមាត្រា២៨ ដើម្បីអនុញ្ញាតឱ្យអភិបាលស្រុកបានជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ ព្រមទាំងឱ្យប្រើប្រាស់ត្រាសាលាស្រុកទៀតផង[២៦២]។ នីតិវិធីលំអិតក្នុងការអនុវត្តត្រូវបានពន្យល់បន្ថែមនៅក្នុងប្រកាសស្តីពីគោលការណ៍ណែនាំ និង នីតិវិធីរបស់គណកម្មការសុរិយោដី[២៦៣]។ គណៈកម្មការសុរិយោដីស្រុក ខណ្ឌប្រសិនបើឃើញថា វិវាទមិនអាចដោះស្រាយបាន ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ ខេត្ត ក្រុង

---

[២៥៩] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី *ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការសុរិយោដី* ៖ មាត្រា៣ និងមាត្រា៦។

[២៦០] ឈ្មោះរបស់គណៈកម្មការសុរិយោដីមិនទាន់បានធ្វើបច្ចុប្បន្នភាពនៅឡើយ។ ផ្អែកតាមតាមច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា៤ និង៥ គឺថា ខេត្ត ក្រុង ស្មើគ្នានឹងបច្ចុប្បន្ន រាជធានី ខេត្ត ចំណែកស្រុកខណ្ឌស្មើគ្នានឹង ស្រុក ក្រុង។

[២៦១] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី *ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការសុរិយោដី* ៖មាត្រា២៨។

[២៦២] អនុក្រឹត្យ លេខ៣៤ អនក្រ បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ ស្តីពី ការកែប្រែមាត្រា៥ និងមាត្រា២៨ នៃអនុក្រឹត្យលេខ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី *ការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈកម្មការសុរិយោដី* ៖មាត្រា៥ថ្មី និងមាត្រា២៨ថ្មី។

ចំពោះករណីដូចជា៖ ទី១. ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃបណ្តឹងទាមទាររបស់ភាគីតូចតាចមួយចំនួន ទី២.ភាគីម្ខាងនៃវិវាទជាអាជ្ញាធរមានឋានៈខ្ពស់ ទី ៣. ករណីវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និង ទី៤. វិវាទដែលពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ[២៦៤]។

ក្នុងគោលបំណងបែងចែកភារៈកិច្ចឱ្យច្បាស់លាស់រវាងគណៈកម្មការសុរិយោដី និងតុលាការនៅកម្ពុជា ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញនូវប្រកាសអន្តរក្រសួង។ ប្រកាសនេះគូសបញ្ជាក់អំពីយុត្តាធិការរបស់តុលាការ និងគណៈកម្មការសុរិយោដី ដែលជារួមគណៈកម្មការសុរិយោដីត្រូវធ្វើការដោះស្រាយវិវាទទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងដីមិនទាន់ចុះបញ្ជីសុរិយោដី លើកលែងតែវិវាទអំពីការបែងចែកមត៌ក រវាងអ្នកទទួលមត៌ក និងវិវាទអំពីកិច្ចសន្យាទិញលក់ ជួល បញ្ចាំជាដើម ករណីវិវាទប្រភេទនេះស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ[២៦៥]។ ចាប់ពីប្រកាសនេះដាក់ឱ្យអនុវត្តតុលាការ ខេត្ត ក្រុង ត្រូវបញ្ឈប់ការទទួលបណ្តឹងវិវាទដីធ្លី មិនទាន់ចុះបញ្ជីដែលជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី[២៦៦]។ ចំណុចនេះ ធ្វើឱ្យកើតមានចម្ងល់មួយចំនួនចំពោះអ្នកច្បាប់ ថាតើវាអាចរំលោភលើអធិបតេយ្យភាពរបស់តុលាការដែរ ឬទេ ? ព្រោះអំណាចតុលាការជាអំណាចឯករាជ្យ[២៦៧]។

យុត្តាធិការរបស់គណៈកម្មកាសុរិយោដីមានបីថ្នាក់ ស្រុក ខណ្ឌ ខេត្ត ក្រុង និងថ្នាក់ជាតិ។ គណៈកម្មការថ្នាក់ ស្រុក ខណ្ឌ មានការទទួលខុសត្រូវធ្វើការសម្រុះសម្រួលវិវាទនៅដំណាក់កាលដំបូង។ វិវាទទាំងឡាយណាដែលមិនអាចសម្រុះសម្រួលនៅថ្នាក់ក្រោមនេះ នឹងត្រូវបញ្ជូនទៅថ្នាក់ខេត្តរហូតដល់ថ្នាក់ជាតិដើម្បីធ្វើសេចក្តីសម្រេច[២៦៨]។ សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិនេះ គឺជាសេចក្តីសម្រេចបែបរដ្ឋបាល ភាគីដែលមិនសុខចិត្តមានសិទ្ធិប្តឹងទៅតុលាការក្នុងរយៈពេល ៣០ថ្ងៃ ចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេច[២៦៩]។

រចនាសម្ព័ន្ធរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌមានសមាសភាពដូចខាងក្រោម៖

១-អភិបាលស្រុក ខណ្ឌ ជាប្រធាន

---

[២៦៣] ប្រកាស លេខ ១១២ ដនស ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី *គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី* ៖ប្រការ២០។

[២៦៤] អនុក្រឹត្យ លេខ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី *ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការសុរិយោដី* ៖មាត្រា១០។

[២៦៥] ប្រកាសអន្តរក្រសួង លេខ ០២ ប្រក ០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ស្តីពី *ការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿង វិវាទដីធ្លី* ៖ មាត្រា ៤។

[២៦៦] ប្រកាសអន្តរក្រសួង លេខ ០២ ប្រក ០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ស្តីពី *ការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿង វិវាទដីធ្លី* ៖ មាត្រា ៤។

[២៦៧] *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា* ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ៖មាត្រា១០៩។

[២៦៨] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី *ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការសុរិយោដី* ៖ មាត្រា២០។

[២៦៩] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី *ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី* ៖ មាត្រា២៣។

២-ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម
សំណង់ និងភូមិបាលស្រុក ខណ្ឌ ជាអនុប្រធាន
៣-គណៈកម្មការសុរិយោដីស្រុក ខណ្ឌ មានមន្ត្រីការិយាល័យ
រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ជាសមាជិក
៤-តំណាងអាជ្ញាធរដែនដីឃុំ សង្កាត់ ភូមិដែលពាក់ព័ន្ធឬ និងចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋាន ចូលរួមជាសមាជិកអាដហុក ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងមានសមាសភាពដូចខាងក្រោម៖

១-អភិបាល ឬអភិបាលរងខេត្ត ក្រុង ជាប្រធាន
២-ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រុង ជាសមាជិក
៣-តំណាងស្រុកខណ្ឌ ឃុំ សង្កាត់ ឬ មន្ទីរជុំវិញខេត្តក្រុងដែលពាក់ព័ន្ធចូលរួមសមាជិកអាដហុក។

គណៈកម្មការសុរិយោដីថ្នាក់ជាតិមានសមាសភាពដូចខាងក្រោម៖

១-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន
២-រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ជាសមាជិក
៣-រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក
៤-ក្រសួងស្ថាប័នពាក់ព័ន្ធចូលរួម ជាសមាជិកអាដហុក

## ២.៣.២ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

ក្នុងអត្ថន័យជំរុញបន្ថែមចំពោះការដោះស្រាយទំនាស់ដីធ្លី ដែលកំពុងតែកើតមានឡើងគួរឱ្យកត់សំគាល់ និងដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌ក្នុងការដោះស្រាយវិវាទដីធ្លី រដ្ឋាភិបាលបានបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីនេះឡើង។ អាជ្ញាធរនេះធ្វើកិច្ចការដើម្បីបំពេញបន្ថែមលើយន្តការដែលមានស្រាប់ ដូចជាគណៈកម្មការសុរិយោដី និងតុលាការជាដើម។ បេសកម្មរបស់អាជ្ញាធរនេះមានដូចខាងក្រោម៖

- ទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លីតាមការអប់រំ ផ្សព្វផ្សាយឱ្យសាធារណៈជនឱ្យយល់ដឹងអំពីផលវិបាកបណ្តាលមកពីទំនាស់ដីធ្លី និង មានវិធានការដាក់វិន័យចំពោះជនល្មើស ដែលបានរំលោភបំពានលើបញ្ហាដីធ្លីដោយខុសច្បាប់ជាធរមាន[២៧០]។
- ទទួលសំណុំរឿងទំនាស់ដីធ្លីដែលហួសពីសមត្ថកិច្ចគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងទទួលពាក្យ បណ្តឹងពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធទំនាស់ដីធ្លី។
- ស្វែងយល់ ស៊ើបអង្កេត និងដោះស្រាយទំនាស់ដីធ្លី។
- ឃ្លាំមើលការដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដី និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់។

---

[២៧០] ព្រះរាជក្រឹត្យ លេខ នស ០២០៦ ០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពី ***ការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*** ៖ មាត្រា ៣។

- ធ្វើរបាយការណ៍អំពីលទ្ធផលការងារ នៃការដោះស្រាយទំនាស់ដីធ្លី ជូនប្រមុខរាជរដ្ឋាភិបាល។
- ទទួល និង ពិនិត្យសំណុំរឿងពាក្យបណ្តឹង និង ចុះស្វែងយល់ ស៊ើបអង្កេត ហើយធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេត ពាក់ព័ន្ធនឹងបញ្ហាទំនាស់ដីធ្លី ដើម្បីដាក់ជូនប្រធានអាជ្ញាធរជាតិ ដោះស្រាយទំនាស់ដីធ្លី ពិនិត្យសម្រេចតាមតំណាក់កាល និងករណីនីមួយៗ[២៧១]។
- រៀបចំការប្រជុំ និងធ្វើកំណត់ហេតុអំពីអង្គប្រជុំរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។
- ចុះស្វែងយល់ ស៊ើបអង្កេត និង ឃ្លាំមើលសកម្មភាពរបស់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការដោះស្រាយទំនាស់ដីធ្លី តាមការបញ្ជាណែនាំរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។
- បញ្ជូនកំណត់ហេតុ និងភស្តុតាងទាំងអស់ទៅតុលាការ នៅពេលមានការប្តឹងតវ៉ាលើសេចក្តីសម្រេច របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីទៅតុលាការ។
- រៀបចំ និងតំកល់ទុកឯកសារពាក់ព័ន្ធទំនាស់ និងបណ្តឹងដីធ្លី។
- រៀបចំសេចក្តីព្រាងរបាយការណ៍ អំពីសកម្មភាពការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីជូនប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីតាមកាលកំណត់ ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។
- ផ្សព្វផ្សាយជូនសាធារណៈជនអំពីលទ្ធផលនៃការដោះស្រាយទំនាស់ដីធ្លី ដែលអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីបានដោះស្រាយចប់ជាស្ថាពរ។

សមាសភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានៈ

| | |
|---|---|
| ១ តំណាងនាយករដ្ឋមន្ត្រី | ជាប្រធាន |
| ២ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធានទី១ |
| ៣ រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៤ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៦ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៧ រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៨ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០ រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១១ រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១២ អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១៣ អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ | សមាជិក |

[២៧១] ព្រះរាជក្រឹត្យ លេខ នស ០២០៦ ០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពី ***ការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*** ៖មាត្រា ៥។

| | |
|---|---|
| ១៤ មេបញ្ជាការទ័ពជើងគោក | សមាជិក |
| ១៥ មេបញ្ជាការទ័ពជើងទឹក | សមាជិក |
| ១៦ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៧ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៨ អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ជាអគ្គលេខាធិការ | សមាជិក |
| ១៩ មេធាវីរាជរដ្ឋាភិបាល | សមាជិក |
| ២០ តំណាងគណៈបក្សសមរង្ស៊ី | សមាជិក |
| ២១ តំណាងគណៈបក្ស ហ៊្វុន ស៊ិន ប៉ិច | សមាជិក |
| ២២ តំណាងអង្គការក្រៅរដ្ឋាភិបាលសំខាន់ៗដែលពាក់ព័ន្ធ | សមាជិក |

សមាសភាពជាក់ស្តែង នឹងត្រូវកំណត់ដោយអនុក្រឹត្យ។

បច្ចុប្បន្នអគ្គលេខាធិការដ្ឋានរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានទីតាំងនៅអគារទីស្តីការគណៈរដ្ឋមន្ត្រី។ អគ្គលេខាធិការដ្ឋាននេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពេលបំពេញភារកិច្ច និង បេសកម្មរបស់ខ្លួន[២៧២]។ ដំណើរការដោះស្រាយទំនាស់ដីធ្លីរបស់អាជ្ញាធរនេះ គឺប្រើប្រាស់បុគ្គលិកនៃមុខងារសាធារណៈ ឬអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងចំពោះការចំណាយស្ថិតក្រោមបន្ទុកថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី[២៧៣]។

ដោយសារភាពអសកម្មនៅក្នុងការបំពេញភារកិច្ចរបស់ខ្លួននោះ រចនាសម្ព័ន្ធអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីត្រូវបានរដ្ឋាភិបាលធ្វើវិសោធនកម្ម ឆ្នាំ២០០៦។ តាមរយៈវិសោធនកម្មនេះ សមាសភាពមួយត្រូវដកចេញ ដូចជា តំណាងមកពីគណៈបក្សសមរង្ស៊ី តំណាងពីគណៈបក្សហ៊្វុនស៊ិនប៉ិច និង តំណាងជាអនុរដ្ឋលេខាធិការពីទីស្តីការគណៈរដ្ឋមន្ត្រីជាដើម និងបន្ថែមសមាជិកថ្មីមួយចំនួនដែលជាឥស្សរជនមួយចំនួន ជាអនុប្រធាន និង ជាអនុប្រធានប្រចាំការ[២៧៤]។

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានសមាសភាពដូតទៅៈ

| | |
|---|---|
| ១ តំណាងនាយករដ្ឋមន្ត្រី | ប្រធាន |
| ២ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធានទី១ |
| ៣ ឥស្សរជនមួយរូប | អនុប្រធានប្រចាំការ |
| ៤ ឥស្សរជនមួយចំនួន | អនុប្រធាន |
| ៥ រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |

[២៧២] អនុក្រឹត្យ លេខ៦៥ អនក្រ បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦ ស្តីពី *ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ ដីធ្លី* ៖ មាត្រា ៧។

[២៧៣] អនុក្រឹត្យលេខ៦៥ អនក្រ បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦ស្តីពី *ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី* ៖មាត្រា ១៦។

[២៧៤] មាត្រា១ថ្មី ព្រះរាជក្រឹត្យស្តីពី វិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ សន រកត ០២០៦ ០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី លេខ នស រកត ១០០៨ ១១០៦ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨។

៦ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
៧ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
៨ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
៩ រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក
១០ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
១១ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
១២ រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម សមាជិក
១៣ រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
១៤ អគ្គស្នងការនគរបាលជាតិ សមាជិក
១៥ អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ សមាជិក
១៦ មេបញ្ជាការទ័ពជើងគោក សមាជិក
១៧ មេបញ្ជាការទ័ពជើងទឹក សមាជិក
១៨ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
១៩ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
២០ មេធាវីរាជរដ្ឋាភិបាល សមាជិក
២១ តំណាងអង្គការក្រៅរដ្ឋាភិបាលសំខាន់ៗដែលពាក់ព័ន្ធ សមាជិក

សមាសភាពជាក់ស្តែង នឹងត្រូវកំណត់ដោយអនុក្រឹត្យ។

អគ្គលេខាធិការដ្ឋានរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានរចនាសម្ព័ន្ធដូចខាងក្រោម៖

-នាយកដ្ឋានទប់ស្កាត់ បង្ការ និងអប់រំ
-នាយកដ្ឋានស៊ើបអង្កេត និងអធិការកិច្ច
-នាយកដ្ឋានទទួល និងដោះស្រាយបណ្តឹង
-នាយកដ្ឋានបូកសរុប ព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ
-នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក។

ជាសរុបដំណើរការវិវឌ្ឍនៃការងារពាក់ព័ន្ធនឹងវិស័យដីធ្លី ជាពិសេស ការកសាងឯកសារក្របខ័ណ្ឌគតិយុត្តសម្រាប់អនុវត្តច្បាប់ភូមិបាលឆ្នាំ២០០១មានលក្ខណៈរីកចម្រើនគួរឱ្យកត់សំគាល់។ តែទោះជាយ៉ាងណា កេរដំណែលជាប្រវត្តិសាស្ត្រនៃការផ្លាស់ប្តូរគោលនយោបាយដីធ្លី បានបន្សល់ទុកឱ្យសង្គមកម្ពុជាបច្ចុប្បន្ន ប្រឈមនឹងបញ្ហាជាច្រើនដែលទាក់ទងនឹងដីធ្លី។ ឆ្លើយតបនឹងបញ្ហានេះ រាជរដ្ឋាភិបាលសហការណ៍ជាមួយដៃគូរអភិវឌ្ឍន៍បានខិតខំស្វែងរកវិធីដោះស្រាយ។ ដំណោះស្រាយជាដំបូងគឺការបង្កើតគោលនយោបាយដីធ្លី ។ គោលបំណងនៃឯកសារគតិយុត្តទាំងនេះមានបង្កប់នៅក្នុងច្បាប់ និងនៅក្នុងគោលដៅនៃកិច្ចការគម្រោងសាកល្បង និង ជួយដោះស្រាយភាពមិនច្បាស់លាស់។ ប្រការនេះនឹងធ្វើឱ្យការប្រើប្រាស់ធនធានដើម្បីដោះស្រាយបញ្ហាដីធ្លីកាន់តែមានប្រសិទ្ធភាព និង ខិតទៅជិតគំនិតផ្តួចផ្តើមក្នុងគោលនយោបាយកំណែទម្រង់ដីធ្លី។

ច្បាប់ និងនីតិវិធីពាក់ព័ន្ធមិនទាន់មានគ្រប់គ្រាន់ ទាមទារឱ្យមានក្របខ័ណ្ឌច្បាប់ច្បាស់លាស់ ស្តីពី សិទ្ធិលើអចលនទ្រព្យ អំពីការផ្ទេរ ការប្រើប្រាស់ដីរដ្ឋ និងដីឯកជនព្រមទាំងអំណាចតាមច្បាប់របស់រដ្ឋលើការប្រើប្រាស់ដីធ្លី។ អវត្តមានច្បាប់ចាំបាច់មួយចំនួនធ្វើឱ្យស្ថានភាពច្របូកច្របល់មិនអាចដោះស្រាយបាន។ កង្វះខាតនៃច្បាប់ធ្វើឱ្យមតិមួយចំនួន បានចោទប្រកាន់មន្ត្រីអនុវត្តច្បាប់ថារំលោភច្បាប់ និងរំលោភសិទ្ធិមនុស្ស ភាគច្រើនដែលគេបានដឹងករណីនេះ គឺពាក់ព័ន្ធលើការផ្លាស់លំនៅឋានប្រជាពលរដ្ឋ។ ក្របខ័ណ្ឌច្បាប់ រៀបចំដីធ្លីដែលរដ្ឋមិនទាន់បានអនុម័តមានដូចជា បទបញ្ញត្តិស្តីពីការកំណត់តំបន់ ក្រមសំណង់ ជាពិសេស លិខិតបទដ្ឋានក្រោមច្បាប់ស្តីពីអស្សាមិករណ៍ជាដើម។

មានករណីមួយចំនួន ទោះបីមានច្បាប់ជាធរមានហើយក៏ដោយ តែច្បាប់នេះមិនបានឱ្យនិយមន័យច្បាស់លាស់នាំដល់ការបកស្រាយយកតែផ្លូវត្រូវរៀងៗខ្លួន ជនរងគ្រោះពីហេតុការណ៍នេះភាគច្រើនអ្នកក្រីក្រដែលជាជនងាយរងគ្រោះ។ ចំណុចដែលមានការចម្រូងចម្រាស់ខ្លាំងបំផុតគឺភាពមិនច្បាស់លាស់នៃការកំណត់ព្រំដែនរវាងទ្រព្យណាជាសម្បត្តិសាធារណៈ ឬឯកជនរបស់រដ្ឋសម្រាប់ឱ្យសាធារណៈជនបានដឹង។ រហូតមកដល់ពេលនេះ រដ្ឋពុំទាន់មានការកំណត់អត្តសញ្ញាណ ថាតើកន្លែងណាជាដីសាធារណៈរបស់រដ្ឋ និងកន្លែងណាជាដីឯកជនរបស់រដ្ឋឱ្យបានច្បាស់លាស់នៅឡើយ។ ទោះបីដីតំបន់ត្រូវការពារ ដីធ្វើអាជីវកម្មសាធារណៈលើដីសាធារណៈរបស់រដ្ឋ និង ការផ្តល់ដីសម្បទាន ជួលឬផ្ទេរលើដីឯកជនរបស់រដ្ឋ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក៏គ្មានការគូសវាស់ព្រំប្រទល់ឱ្យបានច្បាស់លាស់នោះដែរ។ ហេតុនេះ បញ្ហាវិវាទដីធ្លីកើតមានឡើងមិនចេះចប់។ ម្យ៉ាងវិញទៀត មកដល់ពេលនេះពុំមានឯកសារផ្លូវការណាមួយបញ្ជាក់អះអាងថា អ្វីជាដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋដែលដាក់បង្ហាញឱ្យសាធារណៈជនបានឃើញ។ ដូចនេះ ទើបគេឃើញមានការតវ៉ារឿងដីធ្លីពីសំណាក់ប្រជាពលរដ្ឋមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ករណីខ្លះ ឈានដល់កើតមានអំពើហិង្សាទៀតផង។ ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋរាប់ម៉ឺននាក់ប្រឈមនឹងឧបសគ្គ ក្នុងការទទួលស្គាល់ឱ្យបានត្រឹមត្រូវចំពោះភោគៈស្របតាមច្បាប់ភូមិបាល។

នៅជំពូកទីបី យើងនឹងអង្កេតស៊ីជម្រៅទៅលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និង ការដោះស្រាយវិវាទដីធ្លី។

# ជំពូកទី៣
# ការដោះស្រាយវិវាទដីធ្លី

# ជំពូកទី៣
# ការដោះស្រាយវិវាទដីធ្លី

សិទ្ធិលើដីធ្លី គឺជាប្រធានបទដ៏ក្ដៅនៅកម្ពុជា។ មានមតិលើកឡើងដោយមន្ត្រីរដ្ឋាភិបាលថា " ការអនុវត្តច្បាប់ និងផ្សព្វផ្សាយច្បាប់ មិនទាន់ស៊ីជម្រៅ និង ទូលំទូលាយ។ មានការឃុបឃិតជាមួយរដ្ឋអំណាច និង អង្គការជំនាញធ្វើកម្មសិទ្ធិជាន់គ្នាលើដីរបស់ប្រជាពលរដ្ឋ "។ រដ្ឋាភិបាលបានយកចិត្តទុកដាក់ទៅលើបញ្ហាគ្រប់គ្រងដីធ្លី ដើម្បីទប់ស្កាត់មិនឱ្យមានបាតុភាពសង្គមទាក់ទងនឹងបញ្ហាទាំងនេះដោយបង្កើតជាលិខិតបទដ្ឋានគតិយុត្តជាច្រើន។ ទោះបី ជាមានលិខិតបទដ្ឋានគតិយុត្តជាច្រើនហើយក៏ដោយ វិវាទដីធ្លី នៅតែជាបញ្ហាចោទក្នុងការដោះស្រាយដដែល។ ការណ៍នេះ ដោយសារបទដ្ឋានទាំងនោះ និង នីតិវិធីពាក់ព័ន្ធក្នុងការគ្រប់គ្រង និង ដោះស្រាយវិវាទនៅមានកម្រិត និង ម៉្យាងភាពមិនច្បាស់លាស់នៃការកំណត់ដែនសមត្ថកិច្ចនិង នីតិវិធីនាំឱ្យការអនុវត្តកាន់តែចោទជាបញ្ហាថែមទៀត។ ម៉្យាងវិញទៀត ការមិនស៊ីចង្វាក់នៃបទដ្ឋានគតិយុត្ត ពីមួយទៅមួយក៏ធ្វើឱ្យតួអង្គដែលដោះស្រាយទំនាស់ដីធ្លី ជួបការពិបាកផងដែរក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ។

ជំពូកនេះនឹងពន្យល់អំពីការដោះស្រាយវិវាទដីធ្លីតាមបែបរដ្ឋបាល និង តុលាការ។ លើសពីនេះ យើងនឹងស្វែករកនៅភាពខ្វះចន្លោះ និងការមិនស៊ីចង្វាក់គ្នារវាងច្បាប់ពាក់ព័ន្ធដែលកំណត់ដែនសមត្ថកិច្ច និងបញ្ហាជាច្រើនដែលត្រូវបាន ជួបប្រទះមានជាអាទិ៍ៈ ភាពមិនច្បាស់លាស់រវាងសមត្ថកិច្ចនៃគណៈកម្មការសុរិយោដីនឹងតុលាការ និង អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និង គណៈកម្មការសុរិយោដីជាដើម។ ការវិភាគលំអិតទៅលើក្របខណ្ឌគតិយុត្ត និងភាពស្រប និងផ្ទុយគ្នាទៅនឹងច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា លើបទដ្ឋានក្រោមច្បាប់មួយចំនួនពាក់ព័ន្ធដីធ្លី ដូចជាព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អនុក្រឹត្យស្តីពីគណៈកម្មការសុរិយោដី និង ប្រកាសអន្តរក្រសួងដើម្បីរំលេចឱ្យឃើញកាន់តែច្បាស់។ បន្ទាប់មកធ្វើការវិភាគស៊ីជម្រៅលើកត្តាទាំងឡាយ ដែលរារាំងដល់ដំណោះស្រាយវិវាទដីធ្លី និង ចុងក្រោយគឺធ្វើការសរុបខ្លឹមសារក្នុងជំពូកទាំងមូល។

## ៣.១ ដំណោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ

និយមន័យនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺសំដៅដល់បច្ចេកទេសផ្សេងៗដែលត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយវិវាទក្រៅពីការដាក់បណ្តឹងទៅតុលាការ។ ការស្វែងរកដំណោះស្រាយក្រៅប្រព័ន្ធតុលាការតាមរយៈអ្នកសម្រុះសម្រួលដែលមានជាទូទៅ ដូចជាការលើករឿងវិវាទទៅឱ្យអ្នកមានមុខមាត់ក្នុងសង្គមជួយដោះស្រាយជាដើម។ ការសម្រុះសម្រួល ឬសន្ទានកម្ម mediation កើតមានស្ទើរតែចាប់តាំងពីពេលកកើតសង្គមមនុស្សមកម្ល៉េះ[២៧៥]។ សម័យមុនគេដោះស្រាយតាមរយៈ

[២៧៥] ស្ទីវិន អ៊ែម អូស្ទើមីឡើរ៍ *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា* សៀវភៅសិក្សា ស្តីពីទស្សនាទានសំខាន់ៗ USAID Cambodia, East West Management Institute, Rule of Law Initiative ឆ្នាំ២០០៩ ទំព័រ៦៨ និង២១៨។

ព្រះសង្ឃ ឬព្រឹទ្ធាចារ្យជាអ្នកធ្វើអាជ្ញាកណ្តាល និងជាអ្នកសម្រេចសេចក្តី។ រហូតមកដល់បច្ចុប្បន្ននេះ យើងឃើញដំណោះស្រាយវិវាទដីធ្លី ក៏នៅតែមានវត្តមានព្រឹទ្ធាចារ្យដែរ ដែលគាត់ត្រូវបានប្រធានគណៈកម្មការសុរិយោដីអញ្ជើញឱ្យចូលរួមសមាជិកអាជហុក[២៧៦] ។

ពាក្យថា ការសម្រុះសម្រួល ឬសន្ធានកម្ម mediation និងពាក្យថា ការផ្សះផ្សាconciliation ត្រូវបានប្រើលាយឡំគ្នា អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដោយមជ្ឈដ្ឋានអ្នកសិក្សាក៏ដូចជាអ្នកប្រកបវិជ្ជាជីវៈផ្នែកច្បាប់ និងតុលាការ[២៧៧]។ សព្វថ្ងៃនេះពាក្យ "សម្រុះសម្រួល" និង ពាក្យ "ផ្សះផ្សា" ជាញឹកញាប់ត្រូវបានប្រើជំនួសគ្នាទៅវិញទៅមក សំដៅដល់ដំណើរការតែមួយ។ ទោះបីជាមានអ្នកខ្លះព្យាយាមគូសបង្ហាញពីភាពខុសគ្នារបស់វាក៏ដោយក៏មិនមានអាជ្ញាធរឬ ច្បាប់អន្តរជាតិរួមណាមួយកំណត់ថា តើពាក្យទាំងពីអាចមានភាពខុសគ្នាយ៉ាងដូចម្តេចឡើយ។ ផ្អែកតាមអនុក្រឹត្យស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីមាត្រា៩ ការប្រើពាក្យផ្លូវការជាភាសាខ្មែរ គណៈកម្មការមានសិទ្ធិសម្រុះសម្រួលវិវាទ។ ពាក្យថា "សម្រុះសម្រួល" ត្រូវគេបកប្រែជាភាសាអង់គ្លេសថា conciliation ដូចបានអធិប្បាយខាងលើ ពាក្យថា conciliation នេះ បានបកប្រែថាជាការផ្សះផ្សាទៅវិញទេ[២៧៨]។ ពាក្យ "ផ្សះផ្សា" តាមច្បាប់ខ្មែរ គេប្រើនៅតុលាការ ដែលពាក្យនេះមាននៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារឆ្នាំ១៩៨៩(មាត្រា៤៥) ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧(មាត្រា៩៨៤) និង ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦(មាត្រា៩៧)ជាដើម។ ចំណែកវចនានុក្រម អង់គ្លេស-ខ្មែរជាច្រើន ដូចជា Franklin E. Huffman and In Proum ទំព័រ១២២និង៣៦១ និង Orkida Dictionary ពាក្យ mediation និងពាក្យ conciliation បកប្រែថា "សម្រុះសម្រួល"។ តែទោះបីជាយ៉ាងណានៅកម្ពុជា គេប្រើភាសាខ្មែរជាផ្លូវការគឺពាក្យ "សម្រុះសម្រួល" និងម៉្យាងការប្រើនេះដើម្បីញែកឱ្យដាច់ពីគ្នារវាងការដោះស្រាយបែបរដ្ឋបាល និងពាក្យ "ផ្សះផ្សា" ប្រើសម្រាប់ជាការដោះស្រាយដោយតុលាការ។

តាមច្បាប់ភូមិបាលបានអនុញ្ញាតឱ្យមានស្ថាប័នមួយជាក់លាក់ ដើម្បីដោះស្រាយវិវាទដីធ្លី ពោលគឺអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ត្រូវបានបង្កើតឡើងដើម្បីជួយសម្រួលដល់ការដោះស្រាយវិវាទដីធ្លីឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។ ទោះបីជាមានស្ថាប័នស្របច្បាប់ក៏ដោយ ក៏ប្រជាពលរដ្ឋកម្ពុជា តែងតែរត់រកវិធីដោះស្រាយជម្លោះតាមបែបប្រពៃណីរបស់ខ្លួន[២៧៩]។ ការសម្រុះសម្រួលដោយអ្នកសម្រុះសម្រួលជាវិធីដែលគេតែងតែប្រើ ហើយនៅតំបន់ខ្លះ វិធីនេះនៅតែប្រើរហូតដល់សព្វថ្ងៃនេះ ដែលគេអញ្ជើញអ្នកពាក់ព័ន្ធឱ្យចូលរួមជាសមាជិកអាជហុក។ ជាពិសេស វិវាទអាចមានលក្ខណៈ

---

[២៧៦] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី *ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី* ៖មាត្រា១២។

[២៧៧] ស្ទីវិន អ៊ែម អូស្ទីមីឡឺរ៍ *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា* -ជ.ឯ.ម- ទំព័រ៨៤។

[២៧៨] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី *ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី* បកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសផ្សាយដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់៖ មាត្រា៩។

[២៧៩] កុយ នាម: *ដំណើរការក្តីនៅក្នុងតុលាការកម្ពុជា* Introduction Cambodian Justicial Process, អង្គការមូលនិធិអាស៊ី ភ្នំពេញ ឆ្នាំ១៩៩៨ ទំព័រ២៩។

ធូរស្រាលហើយមិនបង្ក ឬបណ្ដាលឱ្យខូចប្រយោជន៍ធ្ងន់ធ្ងរ។ ម៉្យាងទៀត ការផ្សះផ្សាតាមរយៈចាស់ទុំ ឬ អ្នកមានមុខម៉ាត់ក្នុង ភូមិ ឃុំ តាមសំណួមពររបស់គូភាគីជម្លោះច្រើនទទួលបានផលល្អគួរឱ្យកត់សំគាល់ផងដែរ។ ការណ៍នេះ បានសំដែងឱ្យឃើញថា ការជ្រើសរើសអ្នកសម្រុះសម្រួល និងអ្នកដោះស្រាយទំនាស់ដែលពួកគេយល់ថាមានលក្ខណៈសមរម្យ និងមិនបង្កឱ្យខាតប្រយោជន៍ធ្ងន់ធ្ងរ ។

## ៣.១.១ ការជ្រើសរើសអ្នកសម្រុះសម្រួល

ជាទូទៅអ្នកសម្រុះសម្រួលទាំងអស់ គឺជាអ្នកដឹកនាំដំណើរការសម្រុះសម្រួល។ អ្នកសម្រុះសម្រួលជួយដល់ភាគីវិវាទ ក្នុងការគិតរិះរកមធ្យោបាយដើម្បីអាចទទួលយកនូវដំណោះស្រាយ និងជ្រើសរើសយកដំណោះស្រាយណាមួយដែលល្អសម្រាប់ភាគី។ លើសពីនេះទៅទៀត ដូចដែលកំណត់ក្នុងប្រកាសលេខ ១១២ សម្រាប់អនុវត្តអនុក្រឹត្យលេខ៤៧ និងផ្នែកដែលទាក់ទងនឹងច្បាប់ភូមិបាលឆ្នាំ២០០១ ភាគីនៃវិវាទមានឱកាសជ្រើសរើសអ្នកសម្រុះសម្រួលសម្រាប់វិវាទរបស់ខ្លួន។ យោងតាមបទដ្ឋាននេះ ភាគីអាចជ្រើសរើសបុគ្គលណាមួយដែលខ្លួនទុកចិត្តឱ្យធ្វើជាអ្នកសម្រុះសម្រួល ប៉ុន្តែត្រូវគោរពតាមគោលការណ៍មួយចំនួន ដូចជា ក្នុងចំណោមអ្នកសម្រុះសម្រួលទាំងនេះយ៉ាងហោចណាស់ត្រូវមានម្នាក់ដែលធ្លាប់ទទួលការបណ្តុះបណ្តាលឬ មានបទពិសោធន៍ក្នុងការសម្រុះសម្រួលវិវាទនិងត្រូវមានអ្នកសម្រុះសម្រួលម្នាក់ដែលមានការយល់ដឹងអំពីសភាពការណ៍ និង ស្ថានភាពក្នុងតំបន់មូលដ្ឋាននោះ[២៨០]។ ក៏ប៉ុន្តែមនុស្សផ្សេងគ្នាឱ្យតម្លៃនិង យល់ឃើញទៅលើគុណភាពនៃអ្នកសម្រុះសម្រួលខុសៗគ្នា លើកលែងតែភាគីមានការយល់ព្រមលើកត្តាមួយចំនួន ចាំបាច់សម្រាប់អ្នកសម្រុះសម្រួលដែលល្អដូចជា ៖

-ភាគីត្រូវមានជំនឿជាក់ថា អ្នកសម្រុះសម្រួលមានឆន្ទៈ និងអាចផ្តល់ភាពយុត្តិធម៌ដល់គូវិវាទ

-ភាគីត្រូវមានឆន្ទៈ និងគោរពតាមយោបល់ ឬឱវាទរបស់អ្នកសម្រុះសម្រួល ទោះបីជាភាគីទាំងអស់មិនចាំបាច់ត្រូវតែឯកភាពតាមក៏ដោយ។ ប៉ុន្តែ ភាគីត្រូវយល់ថា អ្នកសម្រុះសម្រួលផ្តល់មតិយោបល់នេះក្នុងបំណងស្មោះស្ម័គ្រដើម្បីដោះស្រាយវិវាទនេះ ។

-ភាគីត្រូវទុកចិត្តលើជំនួយរបស់អ្នកសម្រុះសម្រួលដែលមានបទពិសោធន៍ក្នុងការដោះស្រាយវិវាទ។

-ភាគីអាចទុកចិត្តអ្នកសម្រុះសម្រួលតែក្នុងករណីដែលពួកគេដឹងថា អ្នកសម្រុះសម្រួលមិនប៉ុនប៉ងធ្វើឱ្យមានអំពើអយុត្តិធម៌។ អាស្រ័យហេតុនេះ ភាគីត្រូវតែមានការប្រាកដក្នុងចិត្តថាអ្នកសម្រុះសម្រួលមិនមានទំនាស់ផលប្រយោជន៍ក្នុងជម្លោះរបស់ពួកគេនោះទេ ។

[២៨០] ប្រកាស លេខ ១១២ ដនស ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី *គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី* ៖ ប្រការ២២។

ទោះបីជាយ៉ាងណា ការជ្រើសរើសអ្នកសម្រុះសម្រួលក្នុងការអនុវត្តជាក់ស្តែងភាគីមិនអាចជ្រើសរើសអ្នកសម្រុះសម្រួលដោយសេរីបានទេ។ ផ្អែកតាមការស្ទង់មតិ លើភាគីវិវាទមានតែ៤០% នៃអ្នកផ្តល់សម្ភាសន៍បានបញ្ជាក់ថា ពួកគេមានអារម្មណ៍ថាបានជ្រើសរើសអ្នកសម្រុះសម្រួលពិតប្រាកដមែន។ អ្នកសម្រុះសម្រួល ដែលត្រូវភាគីជ្រើសរើសញឹកញាប់ជាប្រធានអង្គសម្រុះសម្រួលក្នុងចំណោម ៨៣ ភាគរយនៃករណីវិវាទ មាន(៧៤%) ជារដ្ឋអំណាចថ្នាក់ស្រុកខណ្ឌ និង (៥៤%) ជាមេឃុំ ចៅសង្កាត់ និង តំណាងជាចៅអធិការវត្ត (មួយករណី) និង តំណាងជាចាស់ទុំមាន (៣ករណី)។ តំណាងមានចំនួនតិចពីសហគមន៍គឺដោយសារពួកគេមិនសូវមានសមត្ថភាព[២៨១]។

ដោយឡែកនៅកម្ពុជា ករណីដែលមានវិវាទកើតឡើង មេឃុំ ចាស់ព្រឹទ្ធាចារ្យ និងជនដទៃទៀត ដែលអ្នកគេគោរពដោយសារការចេះដឹង និង ភាពយុត្តិធម៌របស់ខ្លួនក្នុងស្ថានភាពសមស្រប អាចទទួលបាននូវការជ្រើសរើសជាអ្នកសម្រុះសម្រួល បញ្ហាដែលកើតមានឡើងនៅក្នុងតំបន់របស់ខ្លួន។ ម៉្យាងវិញទៀត អាជ្ញាធរអាចផ្តល់នូវការឯកភាព និងធ្វើឱ្យក្លាយទៅជាផ្លូវការនូវកិច្ចព្រមព្រៀងដែលអ្នកទាំងនោះបានជួយធ្វើតាមរយៈដំណើរការសម្រុះសម្រួលវិវាទដីធ្លី។ ដូច្នេះ ការជ្រើសរើសអ្នកសម្រុះសម្រួលដែលមានជំនាញ និងដែលអាចទុកចិត្តបានធ្វើឱ្យភាគីវិវាទចូលរួមក្នុងការសម្រុះសម្រួលដោយស្ម័គ្រចិត្ត និងព្យាយាមដោះស្រាយវិវាទរបស់ខ្លួនដោយរលូន។ ជាគោលការណ៍ អ្នកសម្រុះសម្រួលមិនមានសិទ្ធិអំណាចក្នុងការចាប់បង្ខំឱ្យទទួលយកដំណោះស្រាយណាមួយឡើយ។ ផ្ទុយទៅវិញ មានតែភាគីវិវាទទៅវិញទេដែលមានសិទ្ធិអំណាចក្នុងការសម្រេចថាតើខ្លួនចង់ ឬមិនចង់ដោះស្រាយ[២៨២]។ ការសម្រុះសម្រួលអាចប្រព្រឹត្តទៅបានតែក្នុងករណីដែលភាគីជឿថា អ្នកសម្រុះម្រួលមានភាពយុត្តិធម៌ ស្មោះត្រង់ និង មានជំនាញសម្រុះសម្រួល។ ជាងនេះទៅទៀត ការផ្តល់លទ្ធភាពឱ្យភាគីអាចជ្រើសរើសអ្នកសម្រុះសម្រួលដោយខ្លួនឯងបាន គឺជាការធ្វើឱ្យភាគីមានការទុកចិត្តលើដំណើរការដោះស្រាយនេះ។

ស្រដៀងគ្នានេះដែរ ការដោះស្រាយវិវាទតាមការសម្រុះសម្រួលនេះ ក្នុងករណីខ្លះនៅតែបន្តអនុវត្តមកដល់ពេលបច្ចុប្បន្ន ដូចជាការលែងលះ គណៈកម្មាធិការប្រជាជនមេឃុំ សង្កាត់ ត្រូវធ្វើការផ្សះផ្សាក្នុងរយៈ១៥ថ្ងៃ ក្រោយពីទទួលពាក្យបណ្តឹង។ បើផ្សះផ្សាមិនបានសម្រេចត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅតុលាការប្រជាជនខេត្តក្រុង[២៨៣]។ ចំពោះវិវាទការងារដែលកើតឡើងរវាងកម្មករនិយោជិត និង និយោជកត្រូវសម្រុះសម្រួលដោយនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ[២៨៤]។ រីឯវិវាទលើផ្នែកពាណិជ្ជកម្ម ភាគីអាចស្វែងរកការផ្សះផ្សានៅមជ្ឈមណ្ឌលជាតិនៃ

[២៨១] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់: *កសាងស្ថាប័នយុត្តិធម៌?* ការពិនិត្យមើលទៅលើការងាររបស់គណៈកម្មការសុរិយោដីនៅកម្ពុជា ទាក់ទងនឹងការដោះស្រាយវិវាទដីធ្លី ភ្នំពេញ ឆ្នាំ២០០៦ ទំព័រ៦៣ និង៦៤។
[២៨២] ស៊ីរិន អ៊ែម អូស្មើមីឡឺរ៍: *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា* -ដ.ឯ.ម- ទំព័រ៨៣។
[២៨៣] ក្រឹត្យច្បាប់ លេខ ៥៦ក្រ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៩ ច្បាប់ស្តីពី *អាពាហ៍ពិពាហ៍ និងគ្រួសារ* ៖ មាត្រា៤២។ និងមាត្រា ៩៨២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ (អនុម័តហើយតែមិនទាន់ដាក់ឱ្យអនុវត្ត)។

មជ្ឈត្តការ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងពាណិជ្ជកម្ម[២៨៥]។ ករណីវិវាទរដ្ឋប្បវេណីតូចតាចដូចជា បញ្ហាបំណុល កិច្ចសន្យា ព្រំប្រទល់ដីកសិដ្ឋាន ការបរិហារកេរ្តិ៍ និងអំពើហិង្សាដែលមិនបង្ករបួសស្នាម អាចត្រូវបានសម្រុះសម្រួលជាផ្លូវការ នៅត្រឹមកម្រិត ឃុំ សង្កាត់ នៅក្នុងមូលដ្ឋានតាមរយៈកម្មវិធីមជ្ឈមណ្ឌលសេវាយុត្តិធម៌របស់រាជរដ្ឋាភិបាល (ហៅកាត់ថា Maison da la Justice)[២៨៦]។

## ៣.១.២ ការជ្រើសរើសដំណោះស្រាយ

ដំណោះស្រាយតាមរយៈការសម្រុះសម្រួលគឺជាធម្មនិយម[២៨៧]។ ការជ្រើសរើសដំណោះស្រាយអាចធ្វើទៅបានដោយមិនមានភាពលំអៀងទៅលើភាគីវិវាទណាមួយ លុះត្រាតែអ្នកសម្រុះសម្រួលអាចដឹងនិង យល់ច្បាស់អំពីឫសគល់នៃវិវាទ ។ ដូច្នេះការទាញយកព័ត៌មានពីភាគីជម្លោះជាផ្នែកមួយយ៉ាងសំខាន់ក្នុងដំណើរការនៃការដោះស្រាយ។ អ្នកសម្រុះសម្រួលនឹងប្រើប្រាស់នូវភស្តុតាង និង ព័ត៌មានដែលផ្តល់ជូនដើម្បីជួយឱ្យភាគីស្វែងរកដំណោះស្រាយដែលសមស្របសម្រាប់ពួកគេ ជាពិសេសការបើកឱ្យមានការពិភាក្សា សម្រុះសម្រួលជាមួយភាគីទាំងឡាយដើម្បីចាប់ផ្តើមពិពណ៌នា និងស្វែងយល់អំពីវិវាទ។ ភាគីទាំងឡាយ និង អ្នកសម្រុះសម្រួលទាំងអស់ត្រូវតែមានការព្រមព្រៀងគ្នាលើប្រភេទនៃបញ្ហាវិវាទមុននឹងពួកគេអាចរកលទ្ធភាពដោះស្រាយនានា ។ ហេតុដូច្នេះ ការលើកវិវាទឱ្យភាគីទាំងសងខាងធ្វើការពិភាក្សាទល់មុខគ្នា អាចផ្តល់ភាពកាន់តែងាយស្រួល និង ទូលំទូលាយដល់អ្នកសម្រុះសម្រួល ដើម្បីប្រមូលយកនូវចំណុចដែលនាំឱ្យមានការទាស់ទែងរវាងអ្នកទាំងពីរ។

លើសពីនេះទៅទៀត វាអាចឱ្យអ្នកសម្រុះសម្រួលយល់កាន់តែច្បាស់អំពីការខ្វែងគំនិតគ្នានៃគូវិវាទ។ គេអាចធ្វើការណែនាំឱ្យភាគីឈានទៅរកនូវចំណុចស្របគ្នាដែលមិនប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍ទាំងសងខាងដែលជាគោលការណ៍សម្រាប់អ្នកសម្រុះសម្រួល ត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍[២៨៨]។ ក្រោយពីបានកំណត់បញ្ហាជាផ្លូវការ និង ប្រមូលបាននូវលទ្ធផលជាច្រើនពីកិច្ច

---

[២៨៤] ព្រះរាជក្រម លេខ ជស រកម ០៣៩៧ ០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ច្បាប់ស្តីពីការងារ ៖មាត្រា៣០០ ៣០១ ៣០២ និងប្រការ១ ប្រកាសស្តីពី *នីតិវិធីនៃការដោះស្រាយវិវាទការងាររួម* លេខ៣១៧ សកបយ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១។

[២៨៥] ព្រះរាជក្រម លេខ នស រកម ០៥០៦ ០១០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ច្បាប់ស្តីពី *មជ្ឈត្តការផ្នែក ពាណិជ្ជកម្ម* មាត្រា១០។

[២៨៦] ស្ទីវិន អ៊ែម អូស្ទើមីឡឺរៈ *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា* សៀវភៅសិក្សា ស្តីពី ទស្សនាទានសំខាន់ៗ USAID Cambodia, East West Management Institute, Rule of Law Initiative ឆ្នាំ២០០៩ ទំព័រ៨៨ នៅក្នុងប្រការ៣ និងប្រការ៤ ប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ លេខ៨៥ ឆ្នាំ២០០៦។

[២៨៧] ស្ទីវិន អ៊ែម អូស្ទើមីឡឺរៈ *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា* -ដ.ឯ.ម-ទំព័រ៨៧ នៅក្នុងមគ្គុទ្ទេសពាណិជ្ជកម្មតាមប្រទេសសម្រាប់កម្ពុជា ទំព័រ៥៣ (ឆ្នាំ២០០៦)។

[២៨៨] ប្រកាស លេខ ១១២ ជនស ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី *គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី* ៖ប្រការ២០។

ពិភាក្សានោះមក អ្នកសម្រុះសម្រួលធ្វើការជ្រើសរើសនូវដំណោះស្រាយ ដែលប្រសើរណាមួយដោយធ្វើការពន្យល់អំពីការជ្រើសរើសនោះ ឱ្យគូភាគីយល់ដើម្បីអាចទទួលបាននូវការសម្រុះសម្រួលដោយមានការព្រមព្រៀងតាមឆន្ទៈរបស់ពួកគេ ។

ដូច្នេះ នៅពេលទទួលបានការព្រមព្រៀងពីគូភាគីទំនាស់ អ្នកសម្រុះសម្រួលត្រូវសរសេរជាលាយលក្ខណ៍អក្សរនូវកិច្ចព្រមព្រៀងសម្រុះសម្រួល ដើម្បីរក្សាទុកជាភស្តុតាងអំពីការសះជា ហើយអាចស្នើសុំធ្វើការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចផ្នែកដីធ្លី មានជាអាទិ៍គណៈកម្មការសុរិយោដីជាដើម ដើម្បីជានាមិនឱ្យកើតមានវិវាទលើរឿងដដែលទៀត។ បន្ទាប់មកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌត្រូវចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួចនោះផ្អែកតាមប្រការ២៧នៃគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី។ ប៉ុន្តែករណីដែលពុំអាចទទួលបានការស្រុះស្រួលនៅថ្នាក់ឃុំ សង្កាត់ទេនោះ ភាគីអាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុកដែលទីតាំងទំនាស់ស្ថិតនៅឱ្យធ្វើការដោះស្រាយបន្ត។

### ៣.១.៣ ការដោះស្រាយតាមគណៈកម្មការរដ្ឋបាល

គណៈកម្មការរដ្ឋបាល គឺជាគណៈកម្មការមួយដែលបានបង្កើតឡើងដើម្បីដឹកនាំការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅតំបន់វិនិច្ឆ័យ។ ភារកិច្ចមួយរបស់គណៈកម្មការនេះ គឺធ្វើការដោះស្រាយវិវាទដីធ្លីដែលកើតមាននៅក្នុងពេលនៃការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ។ ហេតុដូច្នេះ នៅពេលដែលតំបន់វិនិច្ឆ័យត្រូវបានកំណត់ និង ប្រកាសឱ្យដឹង ឮជាសាធារណៈរួចហើយ អភិបាលខេត្ត ក្រុងនៃតំបន់ដែលត្រូវធ្វើការប្រកាសវិនិច្ឆ័យនោះត្រូវតែងតាំងគណៈកម្មការរដ្ឋបាលសម្រាប់តំបន់នោះ[២៨៩]។ មាត្រា ៣ អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ក៏បានកំណត់ផងដែរអំពីសមាសភាព និងជាពិសេសអំពីតួនាទីរបស់គណៈកម្មការរដ្ឋបាលដែលក្នុងនោះ ត្រូវធ្វើការបិទផ្សាយជាសាធារណៈនូវប្លង់បញ្ជីសុរិយោដីដែលមានដូចជាប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ជាដើម។

ម៉្យាងទៀត គណៈកម្មការនេះក៏ទទួលផងដែរនូវរាល់បណ្តឹងតវ៉ា ដោយធ្វើការស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង[២៩០]។ មានន័យថា គណៈកម្មការរដ្ឋបាលធ្វើការកោះអញ្ជើញគូភាគីក៏ដូច ជាសាក្សីដែលពាក់ព័ន្ធ ឱ្យមកធ្វើការស្រាយបំភ្លឺដើម្បីប្រមូលនូវព័ត៌មាន និងភស្តុតាងដែលអាចកំណត់ អំពីការដោះស្រាយវិវាទនេះបាន។ ក្រោយពេលដែលប្រមូលបាននូវព័ត៌មាន ភស្តុតាង និងសាក្សី គណៈកម្មការរដ្ឋបាលអាចធ្វើការសម្រេចលើវិវាទបាន ដោយមានការព្រមព្រៀងពីភាគីទាំង

---

[២៨៩] អនុក្រឹត្យ លេខ ៤៦អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ស្តីពី ***នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី*** ៖មាត្រា ៣ និងមាត្រា១២។

[២៩០] អនុក្រឹត្យលេខ ៤៦ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ស្តីពី ***នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី*** ៖មាត្រា ១២។

សងខាង។ បន្ទាប់ពីបានដោះស្រាយបញ្ហាដីធ្លីដែលមានក្នុងតំបន់វិនិច្ឆ័យ ក៏ដូចជា កំណត់បានច្បាស់លាស់នូវប្លង់សុរិយោដី គណៈកម្មការរដ្ឋបាលធ្វើការសន្និដ្ឋានផ្តល់យោបល់លើឯកសារនៃការវិនិច្ឆ័យ និងលើកសំណើផ្តល់សិទ្ធិលើដី ជូនអ្នកកាន់កាប់ជាកម្មសិទ្ធិករ ឬរក្សាទុកជាសម្បត្តិរដ្ឋ[២៩១]។ ឯកសារនៃការវិនិច្ឆ័យត្រូវរៀបចំ និង ធ្វើការប្រកាសផ្សាយជាសាធារណៈ។

ផ្ទុយទៅវិញ ក្នុងអំឡុងពេលនៃការបិទផ្សាយជាសាធារណៈជនដែលមានឈ្មោះក្នុងបញ្ជី ឬអ្នកមានផលប្រយោជន៍ពាក់ព័ន្ធលើដីណាមួយដែលបានចាត់ទុកថា ឯកសារនៃការវិនិច្ឆ័យ មិនជាក់លាក់ ឬមិនពេញលេញអាចផ្តល់ដំណឹងដល់គណៈកម្មការរដ្ឋបាលនូវការជំទាស់របស់ខ្លួន។ ក្រោយពីបានផ្តល់នូវកំណត់សំគាល់ដ៏សមហេតុផលដល់ជនគ្រប់រូបដែលពាក់ព័ន្ធនឹងការជំទាស់ និង បន្ទាប់ពីបានពិគ្រោះជាមួយនឹងអ្នកដែលធ្វើការជំទាស់ គណៈកម្មការរដ្ឋបាលត្រូវព្យាយាមធ្វើការដោះស្រាយតាមការព្រមព្រៀង ។ ប៉ុន្តែបើការជំទាស់ ឬវិវាទណាមួយដែលមិនអាចធ្វើការដោះស្រាយបានត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិដើម្បីធ្វើការដោះស្រាយជាបន្ត[២៩២]។ មានន័យថា ប្រសិនបើបញ្ហាវិវាទដែលកើតមានក្នុងតំបន់វិនិច្ឆ័យ ហើយគណៈកម្មការរដ្ឋបាលមិនអាចធ្វើការដោះស្រាយបានគេមិនចាំបាច់បញ្ជូនករណីវិវាទនេះទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬខេត្ត ក្រុងនោះទេ វិវាទនោះត្រូវបញ្ជូនដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យធ្វើការដោះស្រាយតែម្តង។ រីឯនីតិវិធីគឺធ្វើស្របទៅតាមអនុក្រឹត្យស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

វិវាទដីធ្លីដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មការរដ្ឋបាលកម្រនឹងជួបប្រទះណាស់ [២៩៣]។ ជាទូទៅគម្រោង LMAP ចុះបញ្ជីដីនៅតំបន់ណាដែលមិនសូវមានទំនាស់ដីធ្លី។ នេះដោយសារគម្រោង គ្រប់គ្រង និង រដ្ឋបាលដីធ្លី មិនបានផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ឱ្យដីណាដែលជាប់មានទំនាស់ក្នុងការកាន់កាប់ឡើយ។ វិវាទតូចតាច ដូចជាបញ្ហាទំនាស់ព្រំប្រទល់ដែលកើតមាននៅអំឡុងពេលនៃការវាស់វែង និង ធ្វើផែនទីដីត្រូវបានដោះស្រាយយ៉ាងឆាប់រហ័ស។ ករណីខ្លះទៀត ទោះបីជាអាជ្ញាធរខិតខំដោះស្រាយ តែនៅតែមិនបានសម្រេច វិវាទត្រូវបញ្ជូនពីគណៈកម្មការរដ្ឋបាលទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិដើម្បីដោះស្រាយ[២៩៤]។ ក្នុងចំណោម ១៦ ករណី វិវាទដីធ្លីមានតែ ពីរករណីត្រូវ

---

[២៩១] អនុក្រឹត្យលេខ ៤៦ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ***នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី*** ៖មាត្រា ៣។

[២៩២] អនុក្រឹត្យលេខ ៤៦ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ស្តីពី ***នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី*** ៖មាត្រា ១២។

[២៩៣] NGO Forum on Cambodia and CCC: ***ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងការកាត់បន្ថយភាពក្រីក្រ*** ការស្រាវជ្រាវនៅក្នុងសង្កាត់ពីរនៃខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ក្រុមគម្រោងវិភាគបញ្ហាអភិវឌ្ឍន៍ និងសិក្ខាកាមស្រាវជ្រាវសហការជាមួយមជ្ឈមណ្ឌលព័ត៌មានដីធ្លី ភ្នំពេញ ឆ្នាំ២០០៧ ទំព័រ៥៦។

[២៩៤] អនុក្រឹត្យ លេខ ៤៦ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ***នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី*** ៖មាត្រា១២។

បញ្ជូនទៅគណៈកម្មការថ្នាក់ជាតិដើម្បីធ្វើការវិនិច្ឆ័យ[២៩៥]។ មូលហេតុដែលបណ្តឹងមកថ្នាក់ជាតិមានចំនួនតិច ដោយសារភាគីមិនចង់អូសបន្លាយរឿង ហើយទទួលយកដំណោះស្រាយនៅថ្នាក់ក្រោមជាជាងមកថ្នាក់លើត្រូវចំណាយពេលវេលាច្រើន និង ចំណុចសំខាន់មួយទៀត ដីដែលកំពុងមានទំនាស់ LMAP មិនចេញប័ណ្ណឱ្យ ដូច្នេះកម្មសិទ្ធិករត្រូវបង្ខំចិត្តទទួលយកដំណោះស្រាយ ទោះបីជាមិនពេញចិត្តក៏ដោយ។

## ៣.១.៤ ការដោះស្រាយតាមគណៈកម្មការសុរិយោដី

គណៈកម្មការសុរិយោដីបង្កើតឡើងដើម្បីដោះស្រាយវិវាទ ដែលទាក់ទងនឹងអចលនវត្ថុមិនទាន់បានចុះបញ្ជីសុរិយោដី។ វិវាទដែលកើតឡើងនៅក្រៅតំបន់វិនិច្ឆ័យ និងវិវាទដែលកើតនៅក្នុងតំបន់វិនិច្ឆ័យមិនអាចសម្រុះសម្រួលបានដោយគណៈកម្មការរដ្ឋបាល។ ដូច្នេះ គណៈកម្មការសុរិយោដីមានសិទ្ធិសម្រេចមុនគេក្នុងការទទួលស្គាល់ភោគីស្របច្បាប់។ ផ្អែកតាមអនុក្រឹត្យលេខ ៤៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី បានបែងចែកគណៈកម្មការនេះជាបីថ្នាក់ ដើម្បីងាយស្រួលដល់ការងារដោះស្រាយវិវាទដីធ្លី ដែលក្នុងនោះមានគណៈកម្មការសុរិយោដី ថ្នាក់ស្រុក ខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់ ខេត្ត ក្រុង និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

### គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ

គណៈកម្មការនេះមានទីតាំងនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល ស្រុក ខណ្ឌ ក្រោមការដឹកនាំរបស់ប្រធានមួយរូបដែលជាប្រធានការិយាល័យរៀបចំដែនដីថ្នាក់ស្រុក ខណ្ឌ ព្រមទាំងមានមន្ត្រីនៃការិយាល័យនោះជាសមាជិក[២៩៦]។ ប៉ុន្តែប្រធានគណៈកម្មការនេះត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីដែលពាក់ព័ន្ធ ឬ ចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋាន ឱ្យចូលរួមជាសមាជិកអាដហុក[២៩៧] (Ad hoc)។ ករណីវិវាទភាគច្រើន មេភូមិជាបុគ្គលដែលភាគីវិវាទបានទាក់ទងមុនគេដើម្បីជួយដោះស្រាយវិវាទ។ នៅពេលថ្នាក់ភូមិមិនអាចដោះស្រាយបានបន្ទាប់មកភាគីវិវាទទាំងនោះក៏មកទាក់ទងឱ្យមេឃុំដើម្បីដោះស្រាយ។ ប្រធានគណៈកម្មការសុរិយោដីជាច្រើនបានបញ្ជាក់ថាវិវាទដីធ្លីភាគច្រើននៅថ្នាក់ស្រុក ខណ្ឌ ត្រូវបានដោះស្រាយដោយមេឃុំ ចៅសង្កាត់[២៩៨]។ លុះត្រាមេឃុំ

---

[២៩៥] Brett Ballard and So Sovannarith: <***Cambodia Land Titling Program: Baseline Survey Project, Final report, Rural Phase I***>, Cambodia Development Resource Institute in coolaboration with the Ministry of Land Management Urban Planning and Construction, Phnom Penh, Cambodia, 2004, page49.

[២៩៦] ចំណុចនេះបានលើកមកនិយាយរួចនៅផ្នែកមុន ប្រធានគណៈកម្មការសុរិយោដីត្រូវផ្លាស់ប្តូរពីប្រធានការិយាល័យរៀបចំដែនដីថ្នាក់ស្រុក ខណ្ឌ មកអភិបាលស្រុក ខណ្ឌ។

[២៩៧] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ***ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*** ៖មាត្រា៥។

[២៩៨] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់: ***កសាងស្ថាប័នយុត្តិធម៌?*** -ជ.ឯ.ម-ទំព័រ៥៣-៥៤។

មិនមានលទ្ធភាពដោះស្រាយបាន ទើបវិវាទបញ្ជូនទៅគណៈកម្មការសុរិយោដីស្រុក។ មាន ៨៨ភាគរយនៃភាគីវិវាទ ចំនួន១៧១ នាក់ បានរាយការណ៍ថា ពួកគេបានព្យាយាមដោះស្រាយវិវាទនៅថ្នាក់មូលដ្ឋាន[២៩៩]។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានភារកិច្ចសម្រុះសម្រួលវិវាទដីធ្លី ដែលកើតមានឡើងក្រៅតំបន់វិនិច្ឆ័យ។ ការសម្រុះសម្រួលនេះត្រូវអនុវត្តតាមទំនៀមទម្លាប់ប្រពៃណី និងបច្ចេកទេសសុរិយោដី មានន័យថា ត្រូវធ្វើការសម្រុះសម្រួលដោយមានការចូលរួមពីមន្ត្រីជំនាញខាងសុរិយោដី និងអ្នកដែលត្រូវជ្រើសរើសដោយភាគីវិវាទ ហើយអាចទុកចិត្តបានថាមានភាពយុត្តិធម៌ ដូចជាមេឃុំជាដើម។ នៅក្នុងដំណាក់កាលនៃការសម្រុះសម្រួល គណៈកម្មការថ្នាក់ស្រុក ខណ្ឌ ត្រូវពន្យល់អំពីនីតិវិធីនៃការសម្រុះសម្រួល ដើម្បីឱ្យភាគីទាំងសងខាង អាចសម្រេចព្រមព្រៀងលើដំណើរការនៃការសម្របសម្រួលនេះ ឬក៏ធ្វើការបដិសេធ[៣០០]។ ម្យ៉ាងវិញទៀត នៅក្នុងដំណើរការនៃការសម្រុះសម្រួលវិវាទដីធ្លីរបស់គណៈកម្មការសុរិយោដីថ្នាក់ ស្រុក ខណ្ឌ តម្រូវចាំបាច់ឱ្យមានការស៊ើបអង្កេតដើម្បីប្រមូលបានជាឯកសារបញ្ចូលទៅក្នុងសំណុំរឿង[៣០១]។

ដោយផ្អែកតាមការបកស្រាយខាងលើគណៈកម្មការសុរិយោដីថ្នាក់ ស្រុក ខណ្ឌ ជាអាជ្ញាធរសុរិយោដីថ្នាក់ដំបូង ដែលទទួលយករឿងវិវាទដីធ្លីមកដោះស្រាយ។ ប៉ុន្តែ យើងក៏បានដឹងដែរថា គណៈកម្មការនេះដឹកនាំដោយប្រធានមួយរូប ដែលជាប្រធានការិយាល័យរៀបចំដែនដី ជាហេតុធ្វើឱ្យដំណើរការនៃការដោះស្រាយវិវាទពុំសូវទទួលជោគជ័យ។ ប៉ុន្តែ រយៈពេលបួនឆ្នាំក្រោយប្រធានគណៈកម្មការនេះដូរមកឱ្យអភិបាលស្រុក ខណ្ឌវិញ[៣០២]។ នេះដោយសារតែការមិនគោរព ឬអើពើចំពោះឋានានុក្រម មានន័យថា ដោយសារតែអតីតប្រធានរបស់គណៈកម្មការនេះពុំសូវមានឥទ្ធិពលធ្វើឱ្យគូវិវាទមានការកោតខ្លាច។

លើសពីនេះទៀត សមត្ថកិច្ចរបស់គណៈកម្មការនេះ ត្រូវបានធ្វើការរឹតត្បិតដោយមិនត្រូវដោះស្រាយ ឬ សម្រុះសម្រួលវិវាទដីធ្លីដែលមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យលេខ ៤៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ដែលបានកំណត់ថា ក្រោយពីការស៊ើបអង្កេតប្រសិនបើឃើញថា វិវាទមិនអាចត្រូវបានដោះស្រាយដោយសមធម៌នៅថ្នាក់ ស្រុក ខណ្ឌ គណៈកម្មការ

---

[២៩៩] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់: ***កសាងស្ថាប័នយុត្តិធម៌?*** -ដ-ទំព័រ៥៤។

[៣០០] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ***ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*** ៖មាត្រា២០។

[៣០១] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ***ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*** ៖មាត្រា៨។

[៣០២] អនុក្រឹត្យ លេខ ៣៤ អនក្រ បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ ស្តីពី ការកែប្រែមាត្រា៥ និងមាត្រា២៨ នៃអនុក្រឹត្យលេខ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី***ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*** ៖ មាត្រា៥ថ្មី។

សុរិយោដីនេះ ត្រូវបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង តាមការយល់ឃើញផ្ទាល់របស់ប្រធាន ឬតាមសំណើរបស់គូវិវាទទាំងសងខាងចំពោះករណីដូចតទៅៈ

-ជនម្នាក់ទាមទារដីច្រើនដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភាគីតូចតាចមួយចំនួន។

-ភាគីម្ខាងនៃវិវាទជាអាជ្ញាធរមានឋានៈខ្ពស់។

-ករណីមានវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ។

-វិវាទដែលទាក់ទងនឹងដីសាធារណៈរបស់រដ្ឋ។

ទាំងនេះសុទ្ធតែបង្ហាញឱ្យយើងដឹងកាន់តែច្បាស់ អំពីសមត្ថកិច្ចនៃគណៈកម្មការនេះជាជាពិសេស ចំណុចទី២នៃមាត្រា១០ បានបញ្ជាក់អំពីភាគីនៃវិវាទដែលជាអាជ្ញាធរមានឋានៈខ្ពស់។ ករណីនេះហាក់បីដូចជា ចង់បង្ហាញឱ្យឃើញអំពីអស្ថេរភាពនៃការកាន់កាប់ដីធ្លី ព្រោះថា មិនចាំបាច់តែភាគីនៃវិវាទទេ សូម្បីតែអាជ្ញាធរដែលមានសមត្ថកិច្ចដោះស្រាយ ក៏ពុំអាចមានលទ្ធភាពក្នុងការសម្រុះសម្រួលវិវាទបានដែរ។ ក៏ប៉ុន្តែ បើសិនជាការដោះស្រាយអាចសម្រេចបានដោយមានការព្រមព្រៀងជាឯកច្ឆ័នពីភាគីវិវាទ គណៈកម្មការសុរិយោដីថ្នាក់ ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ជូនគណៈកម្មការសុរិយោដីថ្នាក់ ខេត្ត ក្រុង ហើយត្រូវចម្លងជូនការិយាល័យរៀបចំដែនដី ស្រុក ខណ្ឌ ដើម្បីចាប់ផ្តើមដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដី ដែលគេបានធ្វើការដោះស្រាយរួច[៣០៣]។ ប្រសិនបើការដោះស្រាយមិនអាចសម្រេចបាន គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបញ្ជូនវិវាទរួមជាមួយរបាយការណ៍ជាលាយលក្ខណ៍អក្សរ ស្តីពីការសម្រុះសម្រួលជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។ ករណីវិវាទដែលបានដោះស្រាយចប់ត្រូវធ្វើការចុះបញ្ជីក្បាលដី ដូចមានចែងក្នុងអនុក្រឹត្យស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី(មាត្រា២៤)។ តែការអនុវត្តជាក់ស្តែង ដីទាំងនោះមិនបានចុះបញ្ជីឡើយ[៣០៤]។ ការណ៍នេះអាចធ្វើឱ្យករណីវិវាទដដែលនឹងកើតឡើងជាថ្មីទៀត។

**គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត**

គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត មានភារកិច្ចសម្រុះសម្រួលវិវាទតាមមាត្រា ១០ នៃអនុក្រឹត្យដែលបានធ្វើការបកស្រាយខាងលើ។ ជាពិសេស ចំពោះទំនាស់ដីធ្លីទាំងឡាយណាដែលគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ពុំមានលទ្ធភាពអាចធ្វើការដោះស្រាយបាន។ សមាសភាពនៃគណៈកម្មការនេះត្រូវបានបែងចែកយ៉ាងច្បាស់ក្នុងមាត្រា ១២ នៃអនុក្រឹត្យលេខ ៤៧ ដែលក្នុងនោះមានអភិបាលរាជធានី ខេត្ត ជាប្រធាន ។

[៣០៣] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ***ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*** ៖មាត្រា១១។

[៣០៤] មិនមានឯកសារណាមួយអះអាងថាដីដែលបានដោះស្រាយចប់ត្រូវបានចុះបញ្ជីទេ-តាមការពិភាក្សាជាមួយមន្ត្រីដោះស្រាយវិវាទឆ្លើយថា ស្ទើរគ្រប់ករណីទាំងអស់មិនត្រូវបានចុះបញ្ជីទេ ដោយហេតុថាការចុះបញ្ជីជាបន្ទុករបស់ភាគី តែភាគីមិនមានលទ្ធភាពធ្វើ។

ដំណើរការនៃការដោះស្រាយវិវាទដោយគណៈកម្មការសុរិយោដីរាជធានី ខេត្ត តម្រូវឱ្យមាននីតិវិធីនៃការស៊ើបអង្កេតផងដែរ។ ក៏ប៉ុន្តែ នីតិវិធីនេះជាភារកិច្ចរបស់លេខាធិការដ្ឋានមួយដែលជាសេនាធិការរបស់គណៈកម្មការសុរិយោដីថ្នាក់ រាជធានី ខេត្ត ហើយមន្ត្រីបំពេញការងារនៅលេខាធិការដ្ឋាននេះ ជាមន្ត្រីមុខងារសាធារណៈដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់គណៈកម្មការសុរិយោដី។ រីឯភារកិច្ច និងមុខងារផ្សេងទៀតរបស់លេខាធិការដ្ឋាននេះ ត្រូវបានកំណត់ក្នុងមាត្រា ១៤ នៃអនុក្រឹត្យដែលមានដូចតទៅ៖

-ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងរាល់ពាក្យបណ្ដឹងទាក់ទងនឹង វិវាទដីធ្លី។

-ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត។

-ធ្វើកំណត់ហេតុ អំពីដំណើរការសម្រុះសម្រួល និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការសម្រុះសម្រួល។

-បញ្ជូនកំណត់ហេតុ និងរបាយការណ៍ទាំងនេះទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ ក្នុងករណីសម្រុះសម្រួលបានសម្រេចត្រូវផ្ញើលទ្ធផលនៃការសម្រុះសម្រួលទៅការិយាល័យរៀបចំដែនដី នគ រូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ។

-រៀបចំ និងតំកល់ទុកឯកសារ។

ក្នុងរយៈពេល៦០ថ្ងៃ ក្រោយពីទទួលបានសំណុំរឿងវិវាទ គណៈកម្មការនេះត្រូវរៀបចំកិច្ចប្រជុំរដ្ឋបាលរវាងគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត និងគូភាគីវិវាទដោយមានការចូលរួមពីអាជ្ញាធរដែនដី ឬមន្ត្រី ជុំវិញរាជធានី ខេត្តពាក់ព័ន្ធនានា ចូលរួមជាសមាជិកអាជហុកដើម្បីសម្រុះសម្រួលវិវាទ[៣០៥]។ ក្រោយពីបានស្ដាប់រឿងរ៉ាវវិវាទរបស់គូភាគី និងរបាយការណ៍ស៊ើបអង្កេតព្រមទាំងកំណត់ហេតុផ្សេងៗដែលរៀបចំឡើងដោយលេខាធិការដ្ឋានរួចមក គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្តត្រូវសម្រុះសម្រួលវិវាទជាបន្ទាន់តាមដែលអាចធ្វើទៅបាន។ ប៉ុន្តែគណៈកម្មការនេះពុំមានសិទ្ធិសម្រេចលើករណីទំនាស់ដីធ្លីណាមួយទេ លើកលែងតែទំនាស់នោះត្រូវបានបញ្ចប់ដោយមានការព្រមព្រៀងពីឆន្ទៈរបស់គូភាគី[៣០៦]។

នេះបង្ហាញឱ្យឃើញថា គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ពុំមានសមត្ថកិច្ចគ្រប់គ្រាន់ក្នុងការសម្រេចលើវិវាទណាមួយនោះទេ។ គណៈកម្មការនេះអាចត្រឹមតែធ្វើការសម្របសម្រួលដើម្បីឱ្យគូភាគីអាចយល់អំពីបញ្ហាវិវាទរបស់ខ្លួន ហើយធ្វើការផ្សះផ្សាដោយឆន្ទៈផ្ទាល់របស់ពួកគេ។ ដាងនេះ

---

[៣០៥] ប្រកាស លេខ ១១២ ជនស ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្ដីពី *គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី* ៖ ប្រការ៣១។

[៣០៦] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពី *ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី* ៖មាត្រា១៥។

ទៅទៀត វិវាទដែលពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការនេះ ត្រូវបញ្ជូនទៅឱ្យធ្វើការដោះស្រាយនៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ព្រោះបើសិនជាភាគីនៃវិវាទមានអំណាចនៅក្នុងដៃជាអ្នកដោះស្រាយវាពុំអាចឈានទៅរកយុត្តិធម៌បានឡើយ[៣០៧]។ ផ្ទុយទៅវិញ បើការសម្រុះសម្រួលអាចសម្រេចទៅបានគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវបញ្ជូនលទ្ធផលទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ដើម្បីចាប់ផ្ដើមរៀបចំដំណើរការអនុវត្តតាមនីតិវិធីនៃការចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួច[៣០៨]។ ប្រសិនបើ ការដោះស្រាយពុំអាចសម្រេចបានទេនោះគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវបញ្ជូនសំណុំរឿងវិវាទដោយភ្ជាប់ទៅជាមួយនូវរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការសម្រុះសម្រួលជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

**គណៈកម្មការសុរិយោដីថ្នាក់ជាតិ**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ជាអាជ្ញាធរសុរិយោដីមានសមត្ថកិច្ចចេញសេចក្ដីសម្រេចលើវិវាទដីភោគៈទាំងឡាយណាដែលគណៈកម្មការសុរិយោដីថ្នាក់ក្រោម និង គណៈកម្មការរដ្ឋបាលពុំអាចសម្រេចបាន។ ម៉្យាងវិញទៀត គណៈកម្មការសុរិយោដីថ្នាក់ជាតិមានយុត្តាធិការពេញលេញក្នុងការធ្វើសេចក្ដីសម្រេចទទួលស្គាល់ភោគី ឬកម្មសិទ្ធិករស្របច្បាប់[៣០៩]។ ទាំងអស់នេះ ក៏ដោយសារតែការដោះស្រាយមានការចូលរួមពីសំណាក់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ជាប្រធាន និង សមាជិកផ្សេងទៀត ក្នុងនោះមានរដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ និងរដ្ឋលេខាធិការនៃទីស្ដីការគណៈរដ្ឋមន្ត្រីផងដែរ[៣១០]។ ដូច្នេះ សមាសភាពនេះអាចធ្វើឱ្យភាគីមានការគោរព និងកោតខ្លាចព្រោះជាមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល។

គណៈកម្មការសុរិយោដីថ្នាក់ជាតិមានលេខាធិការដ្ឋានមួយជាសេនាធិការ ដូចជាគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្តដែរ ដែលមានតួនាទីដូចគ្នាក្នុងការស៊ើបអង្កេត និង ចុះបញ្ជីសំណុំរឿងវិវាទ។ បន្ទាប់ពីបានត្រួតពិនិត្យមើលឯកសារកំណត់ហេតុជាផ្លូវការនៃវិវាទរួចមកប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចសម្រេចធ្វើការសម្រុះសម្រួលបន្ថែមទៀត[៣១១]។ មានន័យថា ថ្វីត្បិតតែគណៈកម្មការនេះមានសិទ្ធិសម្រេចលើវិវាទទាមទារដីធ្លី ក៏ប៉ុន្តែមុនពេលធ្វើការសម្រេច ប្រធានគណៈកម្មការ

---

[៣០៧] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពី *ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*៖មាត្រា១៥។

[៣០៨] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពី *ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*៖មាត្រា១៦។

[៣០៩] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពី *ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*៖មាត្រា២០។

[៣១០] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពី *ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*៖មាត្រា១៧។

[៣១១] ប្រកាស លេខ ១១២ ដនស ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្ដីពី *គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី* ៖ប្រការ៤១។

នៅតែព្យាយាមតាមរយៈរបាយការណ៍ សម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីថ្នាក់ក្រោម ធ្វើការសម្រុះសម្រួលដើម្បីឱ្យភាគីអាចសះជានឹងគ្នាដោយឆន្ទៈ។ បើការសម្រុះសម្រួលមិនអាចសម្រេចបាន ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវកំណត់កាលបរិច្ឆេទសម្រាប់សវនាការរបស់ខ្លួន។

ករណីវិវាទទាំងឡាយណាដែលតម្រូវឱ្យមានការសម្រេចចិត្ត ឬដំណើរការដោះស្រាយវិវាទជាបន្ទាន់ (បណ្តឹងសុំឱ្យធ្វើអន្តរាគមន៍ជាបន្ទាន់) ដូចជាករណីមានការគំរាមគំហែង ឬការភ័យខ្លាចដោយមិនសមហេតុផលពី ការបង្កអគ្គីភ័យ ការប្រើកម្លាំង ឬការបំភិតបំភ័យ ភាគីវិវាទអាចស្នើទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឱ្យចាត់វិធានការបណ្តោះអាសន្ន ដើម្បីការពារផលប្រយោជន៍របស់គូភាគីនៅពេលដែលវិវាទកំពុងដោះស្រាយ[៣១២]។ ស្ថិតនៅក្នុងស្ថានភាពនេះ ភាគីវិវាទអាចប្តឹងដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឱ្យចេញសេចក្តីសម្រេចជាបណ្តោះអាសន្នដើម្បីធ្វើឱ្យមានស្ថានភាពនឹងនរហូតដល់មានការស៊ើបអង្កេត និង សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។ សេចក្តីសម្រេចបណ្តោះអាសន្នត្រូវមានខ្លឹមសារ ជាការរក្សាស្ថានភាពដដែល។ សេចក្តីសម្រេចនេះ ជាវិធានការដ៏ល្អដើម្បីអនុវត្ត និង ទទួលបាននូវការអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ចដូចជា នគរបាល និងកងរាជអាវុធហត្ថជាដើម។ អាជ្ញាធរមានសមត្ថកិច្ចដែលព្រងើយកន្តើយ ឬបណ្តាលឱ្យសាមញ្ញជនប្រព្រឹត្តដោយរំលោភលើសិទ្ធិរបស់ភាគីណាមួយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១-១០លានរៀល និង ត្រូវទទួលទោសរដ្ឋបាលថែមទៀត[៣១៣]។

ក្រោយពេលបើកសវនាការគណៈកម្មការនេះមិនតម្រូវឱ្យគោរពតាមវិធានភស្តុតាង ឬ នីតិវិធីទេ គ្រាន់តែធានាឱ្យភាគីវិវាទមានឱកាសបង្ហាញសក្ខីកម្ម និង ភស្តុតាងរបស់ខ្លួនដោយយុត្តិធម៌ និង សមធម៌ ។ មានន័យថា ភស្តុតាងដែលដាក់ជូននៅតែអាចបដិសេធដោយភាគីម្ខាង។ ផ្ទុយទៅវិញបើគ្មានការជំទាស់នឹងភស្តុតាង ឬ ព័ត៌មានផ្សេងទៀត ដែលភ្ជាប់មកជាមួយនឹងពាក្យបណ្តឹងនោះទេ គណៈកម្មការសុរិយោដីថ្នាក់ជាតិសន្និដ្ឋានខាងផ្លូវច្បាប់ និង មូលដ្ឋានអង្គហេតុដើម្បីចេញសេចក្តីសម្រេចរបស់ខ្លួន។ សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ និង ក្លាយជាស្ថាពរនៅក្រោយរយៈពេល៣០ថ្ងៃ បន្ទាប់ពីបានបញ្ជូនទៅគូភាគីវិវាទទាំងអស់។ មានន័យថា ភាគីវិវាទមានសិទ្ធិស្នើឱ្យមានការពិនិត្យឡើង វិញផ្នែកច្បាប់លើការសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដោយប្តឹងទៅតុលាការតាមរយៈពេលដែលបានកំណត់ បន្ទាប់ពីបានទទួលសេចក្តីសម្រេច។ បណ្តឹងជំទាស់ត្រូវដាក់ជូនទៅតុលាការក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបានបញ្ជូនដល់ភាគីវិវាទ[៣១៤]។ នៅពេលដែលសេចក្តីសម្រេចមាន

---

[៣១២] ប្រកាស លេខ ១១២ ដនស ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី *គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី* ៖ប្រការ៣៩។

[៣១៣] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល* ៖ មាត្រា ២៦៣។

[៣១៤] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី *ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី* ៖មាត្រា២៣។

សុពលភាពអាចអនុវត្តបាន គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ញើសេចក្តីសម្រេចនោះទៅឱ្យមន្ទីររៀបចំដែនដី នគរូប នីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ដើម្បីធ្វើការចាត់ចែងចុះបញ្ជីក្បាលដីតាមនីតិវិធីដែលបានកំណត់។

តាមមាត្រា២៣នៃអនុក្រឹត្យស្តីពីគណៈកម្មការសុរិយោដីមិនមានភាពច្បាស់លាស់ទេ ព្រោះថាក្នុងករណីភាគីណាមួយមិនសុខចិត្តនឹងសេចក្តីសម្រេច របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិនោះមានសិទ្ធិស្នើឱ្យមានការពិនិត្យឡើងវិញផ្នែកច្បាប់ លើការសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដោយប្តឹងទៅតុលាការក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីបានទទួលបានសេចក្តីសម្រេច[៣១៥]។ គ្រាន់តែពិនិត្យផ្នែកខាងលើនេះ ធ្វើឱ្យមានការយល់មិនច្បាស់លាស់លើចំណុចដែលស្នើឱ្យមានការពិនិត្យឡើងវិញផ្នែកច្បាប់ ចំណុចនេះជាការសំខាន់ណាស់ព្រោះថា ភាគីមានការមន្ទិលមិនដឹងថាតើពិនិត្យតែអង្គច្បាប់ ឬពិនិត្យឡើងវិញទាំងអង្គហេតុ និង អង្គច្បាប់។ ទោះបីជាបើកសិទ្ធិឱ្យពិនិត្យតែអង្គហេតុ ឬអង្គច្បាប់ក៏ដោយក៏ជាមិនបញ្ហាទេ ប៉ុន្តែ ភាគីមិនដឹងជាប្តឹងទៅសមត្ថកិច្ចតុលាការថ្នាក់ណា? បើពិនិត្យតែអង្គច្បាប់គឺប្តឹងទៅតុលាការកំពូល[៣១៦] តែបើពិនិត្យទាំងអង្គហេតុ និង អង្គច្បាប់គឺត្រូវប្តឹងទៅសាលាដំបូងរាជធានី ខេត្ត ជាមុនសិន ។

តែបើប្តឹងទៅសាលាដំបូងរាជធានី ខេត្ត ដដែលនោះ ធ្វើឱ្យការបង្កើតគណៈកម្មការសុរិយោដីហាក់បីដូចជាមិនសូវមានប្រយោជន៍ ដោយហេតុថា នីតិវិធីដោះស្រាយវិវាទ កាន់តែវែងឡើងៗព្រោះគណៈកម្មការសុរិយោដីមានបីថ្នាក់ ថែមអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមួយថ្នាក់ រួមទាំងតុលាការមានពីរជាន់ដែលមានបីថ្នាក់ទៀត សរុបស្មើ៧ថ្នាក់ ដែលជាហេតុធ្វើឱ្យមានការខូចប្រយោជន៍ដល់គូភាគីក៏ដូចជាបន្ទុកធ្ងន់ធ្ងរដល់ថវិការដ្ឋដែរ។ រីឯរយៈពេលនៃការប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិមានរយៈពេល៣០ថ្ងៃ ក្រោយពីថ្ងៃទទួលបានសេចក្តីសម្រេច ចំណុចនេះហាក់ដូចជាផ្តល់លទ្ធភាពឱ្យភាគីមិនស្មោះត្រង់ច្រើនពេក ។ មានន័យថា ៣០ថ្ងៃក្រោយពីថ្ងៃទទួលបានសេចក្តីសម្រេចនេះ បង្កលក្ខណៈឱ្យភាគីមិនស្មោះត្រង់អាចគេចវេសមិនព្រមទទួលសេចក្តីសម្រេចធ្វើឱ្យរយៈពេលប្តឹងជំទាស់កាន់តែអូសបន្លាយនាំឱ្យខាតផលប្រយោជន៍ដែលភាគីសុចរិត។ ចំណុចនេះគួរដាក់ថា ប្តឹងទៅតុលាការរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃទទួលបានដំណឹងពីសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីកុំឱ្យភាគីមិនស្មោះត្រង់មានឱកាសគេចវេសពន្យាពេល ព្រោះពេលវេលាសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ តែងមានវត្តមានរបស់គូភាគីវិវាទទាំងអស់ចូលរួម។

ការដោះស្រាយវិវាទដោយគណៈកម្មការសុរិយោដី ក៏មានការលើកទឹកចិត្តដល់គូភាគីដែលឈ្នះនៅគណៈកម្មការសុរិយោដីថ្នាក់ជាតិផងដែរ ដោយហេតុថា លេខាធិការដ្ឋានបានធានាការពារ

---

[៣១៥] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ***ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*** ៖មាត្រា២៣។

[៣១៦] ព្រះរាជក្រម លេខ នស រកម ០៨០៧ ០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ស្តីពី ***ក្រមនីតិវិធីព្រហ្មទណ្ឌ*** នៃព្រះរាជាណាចក្រកម្ពុជា ៖មាត្រា៤៣៦។

សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីនៅចំពោះមុខតុលាការ[៣១៧]។ ម្យ៉ាងទៀត សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ នៅពេលដែលភាគីមិនសុខចិត្តក៏ប្តឹងទៅតុលាការ ហើយបើតុលាការបញ្ជូនរឿងក្តីទៅគណៈកម្មការសុរិយោដីវិញ ដោយហេតុពិនិត្យឃើញថា គណៈកម្មការសុរិយោដីមិនបានអនុវត្តតាមនីតិវិធីសមស្រប ឬមានទំនាស់អំពីផលប្រយោជន៍ ឬក៏មិនផ្តល់ហេតុផលសមរម្យ ឬដោយអនុវត្តហួសពីសមត្ថកិច្ចរបស់ខ្លួននោះ គណៈកម្មការសុរិយោដីត្រូវចាត់វិធានការអនុវត្តតាមសំណូមពររបស់តុលាការ[៣១៨]។ ករណីនេះហាក់បីដូចជាគណៈកម្មកាសុរិយោដី ចាំតែធ្វើតាមសំណូមពររបស់តុលាការដែរ។ ជាងនេះទៅទៀត អនុក្រឹត្យស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីនេះ ហាក់បីដូចជាកម្រិតនីតិវិធីដាច់ខាតពេក អំពីពេលដែលភាគីស្នើសុំពិនិត្យឡើងវិញផ្នែកច្បាប់ ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីបណ្តឹងទៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ[៣១៩] ។

ក្រៅពីការដោះស្រាយសម្រុះសម្រួលតាមរយៈគណៈកម្មការសុរិយោដី និង ការដោះស្រាយដោយតុលាការហើយនោះ រដ្ឋាភិបាលកម្ពុជានៅមានដំណោះស្រាយផ្សេងទៀត ដោយលើកជាគោលយោបាយផ្សេងៗ។ ដូចជាកន្លងមក រដ្ឋាភិបាលបានបង្កើតនូវគោលនយោបាយចំពោះប្រជាពលរដ្ឋដែលបានរស់នៅក្នុងអគារសារធារណៈ និង តំបន់អាណាធិបតេយ្យ។ ក្នុងករណីដែលមានបញ្ហាដូចខាងលើរដ្ឋាភិបាល អាជ្ញាធរ ឬស្ថាប័នរដ្ឋ តែងតែប្រើនូវគោលនយោបាយដើម្បីធ្វើការដោះស្រាយដូចជាធ្វើការដោះស្រាយដូរដី ឬរកដីថ្មី សម្រាប់ឱ្យសង់លំនៅឋាន និងធ្វើការដោះស្រាយដោយឧបត្ថម្ភជាថវិកា ដើម្បីឱ្យពួកគេអាចរកលំនៅឋានថ្មីទៀតដែលគេពេញចិត្ត។ ប៉ុន្តែការដោះស្រាយបែបនេះពុំមែនជាដំណោះស្រាយដ៏ល្អឡើយ ព្រោះថា ប្រជាពលរដ្ឋទាំងនោះមានតែដីសម្រាប់សង់លំនៅឋានហើយមិនមានលទ្ធភាពអាចរកប្រាក់ចំណូលបានប្រចាំថ្ងៃ ដោយសារទីតាំងនៅឆ្ងាយពីទីប្រជុំជន។ ហេតុដូច្នេះ អ្នកទាំងនោះនឹងវិលត្រលប់មកនៅតំបន់អាណាធិបតេយ្យផ្សេងទៀត។

តាមការសិក្សាស្រាវជ្រាវបានបង្ហាញថា ក្រុមគ្រួសារដែលត្រូវបានរើតាំងលំនៅថ្មី ចំនួន៧០ % បានទុកដី និងផ្ទះចោល ហើយនាំគ្នាវិលត្រឡប់មកស្នាក់នៅរាជធានីភ្នំពេញវិញ[៣២០]។ ការវិលត្រឡប់មកទីតាំងចាស់គឺដើម្បីងាយស្រួលរកប្រាក់ចំណូលប្រចាំថ្ងៃ។ ជាក់ស្តែង ឯកសាររបស់អង្គការសហប្រជាជាតិចាប់ពី ឆ្នាំ ២០០០ មកមានប្រជាពលរដ្ឋជាង១០០,០០០ (ដប់ម៉ឺន)នាក់ត្រូវបានរើតាំងលំនៅឋានថ្មី នេះគិតតែនៅទីក្រុងភ្នំពេញមួយគត់ ហើយក៏មានយ៉ាងតិចណាស់ ១៥០,០០០

---

[៣១៧] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ស្តីពី ***ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*** ៖ មាត្រា២៣។

[៣១៨] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ស្តីពី ***ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*** ៖ មាត្រា២៥។

[៣១៩] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ស្តីពី ***ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*** ៖ មាត្រា២៣។

[៣២០] FRI: see also <http://www.rfi.fr/actukm/articles/112/article_4595.asp>; accessed date 3/18/2010-AM.

(ដប់ប្រាំម៉ឺន) នាក់ដែរដែលស្ថិតនៅក្រោមការប្រឈមនឹងការរើតាំងលំនៅថ្មី ហើយថាអាជ្ញាធរមានឋានៈខ្ពស់ដែលខិលខូចមួយចំនួនបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពដោះដូរដីធ្លីទាំងនោះ[៣២១]។

ការត្រួតពិនិត្យ និង ដោះស្រាយវិវាទត្រូវផ្អែកតាមអនុក្រឹត្យលេខ ៤៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីដែលដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ទាក់ទងការអនុវត្តអនុក្រឹត្យនេះ ក្រសួងបានរៀបចំប្រកាសលេខ១១២ដនស/ប្រក ស្តីពីគោលការណ៍ណែនាំ និង នីតិវិធីរបស់គណៈកម្មការសុរិយោដីដែលមានជាខ្លឹមសារសង្ខេបក្នុងការដោះស្រាយវិវាទដីធ្លីដូចមាននៅខាងក្រោម។

រូបភាពទី៥ តារាងដំណើរនៃនីតិវិធីដោះស្រាយវិវាទដីធ្លីរបស់គណៈកម្មការសុរិយោដីៈ




ប្រភព: ឯកសារអំពីនីតិវិធីដោះស្រាយវិវាទដីធ្លី រៀបរៀងដោយលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិឆ្នាំ២០០៣។

[៣២១] អង្គការសហប្រជាជាតិ លេខ E/C.12/KHM/CO/1 ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ *ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច* ការពិនិត្យពិចារណាលើរបាយការណ៍ដែលបានស្នើដោយ រដ្ឋភាគី ក្រោមមាត្រា ១៦ និងមាត្រា១៧ នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អត្ថបទដើមៈ ភាសាអង់គ្លេស ទំព័រ១៤។

**លទ្ធផលនៃគណៈកម្មការសុរិយោដី**

ចាប់ពីខែធ្នូ ឆ្នាំ២០០២ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិបានណែនាំគណៈកម្មការសុរិយោដីឱ្យចាប់ផ្តើមទទួល និងដំណើរការដោះស្រាយវិវាទ[៣២២]។ តាមស្ថិតិផ្តល់ដោយលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិបង្ហាញថា គណៈកម្មការសុរិយោដីបានទទួលវិវាទចំនួន៥១៩៣ គិតមកត្រឹមឆមាសទី១ ឆ្នាំ២០០៩។ ក្នុងចំណោមករណីវិវាទទាំងអស់ ករណីវិវាទចំនួន១៨១០ ត្រូវបានដោះស្រាយដោយជោគជ័យ ករណីវិវាទចំនួន១៣៦៩ ត្រូវបានច្រានចោល ករណីវិវាទចំនួន៩៧ ត្រូវបានប្តឹងទៅតុលាការ និងករណីវិវាទ ចំនួន ២៧២ ត្រូវបានសុំដកទៅវិញ ហើយករណីវិវាទចំនួន ១៧៤២ កំពុងដោះស្រាយ។ បើតាមលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ករណីវិវាទភាគច្រើនដែលត្រូវបានដោះស្រាយប្រកបដោយជោគជ័យ ជាវិវាទដែលពាក់ព័ន្ធនឹងគ្រួសារចំនួនតិច ឬវិវាទតូចតាច[៣២៣]។ សូមមើលតារាងខាងក្រោម៖

តារាងទី៨ ការដោះស្រាយវិវាទដីធ្លីរបស់គណៈកម្មការសុរិយោដី២០០៣ - ២០០៩

| ការដោះស្រាយវិវាទដីធ្លីដោយគណៈកម្មការសុរិយោដី២០០៣ -២០០៩ | | | | | | |
|---|---|---|---|---|---|---|
| ឆ្នាំ | ចំនួនវិវាទ ដែល ទទួលបាន | ចំនួនករណី ដោះស្រាយបញ្ចប់ | ចំនួនច្រាន ចោល | ប្តឹងតវ៉ាទៅ តុលាការ | កំពុង ដោះ ស្រាយ | សុំដក ពាក្យ |
| ២០០៣ | ១២៤៥ | ២៧១ | ៨២ | ២ | ៨៩០ | ០ |
| ២០០៤ | ២០៧៩ | ៥៥៣ | ១២៥ | ០ | ១៣១៩ | ០ |
| ២០០៥ | ៣៤៥៦ | ៤០២ | ៣៨២ | ០ | ១៨៦៣ | ៤៩ |
| ២០០៦ | ៤២៥៤ | ១២៤៦ | ៨៧១ | ៦១ | ២០៥៨ | ៧៩ |
| ២០០៧ | ៤៦៨៩ | ១៤៣៩ | ១០៦៦ | ៨០ | ២០៦០ | ១២៤ |
| ២០០៨ | ៥០៣៨ | ១៦៥៣ | ១២១៣ | ៨៤ | ១៩៥២ | ២២០ |
| ២០០៩ | ៥១៩៣ | ១៨១០ | ១៣៦៩ | ៩៧ | ១៧៤២ | ២៧២ |

ប្រភព: លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ របាយការណ៍ប្រចាំ ពីឆ្នាំ ២០០៣ ដល់ឆមាសទី១ ឆ្នាំ២០០៩ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩។

ករណីវិវាទដែលបានដោះស្រាយបញ្ចប់ជាស្ថាពរចំនួន១៨១០ករណី គឺស្មើនឹងចំនួនគ្រួសារ ៨៥៦០ គ្រួសារ និងផ្ទៃដីចំនួន៣០៥៧.២ ហិកតា។ បើប្រៀបធៀបល្បឿននៃការដោះស្រាយវិវាទពីមួយឆ្នាំទៅមួយឆ្នាំឃើញថា មានការកើនឡើង ចំនួន២០.២២ភាគរយ ជាពិសេសឆ្នាំ២០០៨ បន្ទាប់ពី

[៣២២] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់: ***កសាងស្ថាប័នយុត្តិធម៌?*** -ដ.ឯ.ម-ទំព័រ១៩។

[៣២៣] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់: ***កសាងស្ថាប័នយុត្តិធម៌ ?*** -ដ.ឯ.ម-ទំព័រ១៩។

ការបង្កើតឡើងក្រុមការងារចល័តដោះស្រាយវិវាទដីធ្លីនៅតាម ស្រុក ខណ្ឌ ដែលមានវិវាទកកស្ទះច្រើន[៣២៤]។ នៅអំឡុងនៃដំណើរការដោះស្រាយវិវាទដីធ្លីមានករណីវិវាទជាច្រើន ជារឿយៗបានជួបប្រទះ ករណីខ្លះនាំដល់កើតអំពើហិង្សា មានការគំរាមគំហែង និង ត្រូវចាប់ឃុំខ្លួន។ ផ្អែកតាមលទ្ធផលលើការវិភាគករណីវិវាទចំនួន២៣៦ ករណី មានករណីវិវាទចំនួន៤៥ ភាគរយ ការគំរាមគំហែងនិងស្ថានភាពអំពើហិង្សាកើនឡើង និងករណីចំនួនប្រហែល១៨ ភាគរយ នាំដល់មានការឃុំខ្លួន[៣២៥]។ ភាគច្រើននៃករណីវិវាទនេះជាប់ពាក់ព័ន្ធជាមួយសហគមន៍មូលដ្ឋាន និងគូអង្គដទៃជាច្រើនទៀតដូចជា តំណាងក្រុមហ៊ុនអភិវឌ្ឍន៍ស្ថាប័នរដ្ឋាភិបាល និងមន្ត្រីយោធា។

រូបភាពទី៦ ករណីវិវាទដីធ្លីដែលបានដោះស្រាយដោយគណៈកម្មការសុរិយោដី




ប្រភព: លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ របាយការណ៍ប្រចាំ ពីឆ្នាំ ២០០៣ ដល់ឆមាសទី១ ឆ្នាំ២០០៩ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩។

គណៈកម្មការសុរិយោដីខិតខំប្រឹងប្រែងបំពេញកិច្ចការរបស់ខ្លួន ដើម្បីដោះស្រាយវិវាទដីធ្លីតាមបែបរដ្ឋបាលនៅកម្ពុជា។ ជាទូទៅ ចំនួនករណីវិវាទដែលបានដោះស្រាយមានការកើនឡើងជាប្រចាំទៅតាមឆ្នាំនីមួយៗ។ នៅឆ្នាំ២០០៥ ចំនួនដំណោះស្រាយ ចុះថយទៅវិញបន្តិច ប៉ុន្តែ នៅឆ្នាំ២០០៦ រហូតដល់ ឆ្នាំ២០០៩ កម្រិតនៃការដោះស្រាយរបស់គណៈកម្មការសុរិយោដីកើនខ្លាំង គឺមានចំនួនលើស ២០០ ករណី ក្នុងមួយឆ្នាំៗ។ កំណើនចំណាត់ការដោះស្រាយវិវាទមានគួរឱ្យកត់សំគាល់

[៣២៤] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់: ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្ន*** ២០០៩-២០១៣ (ភយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣) របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លេខ: ដនស អរប ឆ្នាំ២០០៩ ទំព័រ២។

[៣២៥] NGO Forum on Cambodia: <***Statistical Analysis on Land Dispute Occuring in Cambodia 2009***>, Land Information Centre, 2010, Phnom Penh, page9.

លើសពីនេះ រដ្ឋាភិបាលបានបង្កលក្ខណៈងាយស្រួល ដោយធ្វើប្រតិភូកម្មមុខងារជូនអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត និង ជាប្រធានគណៈកម្មការរាជធានី ខេត្ត ដើម្បីសម្រេចលើករណីវិវាទដីធ្លី[៣២៦] និង បានបង្កើតក្រុមការងារដោះស្រាយវិវាទចល័តនៅតាម ខេត្តមួយចំនួនទៀតផងដូចជានៅខេត្តកំពង់ចាម តាមរយៈសេចក្ដីសម្រេចលេខ៩៦។ តៃដៃគូអភិវឌ្ឍន៍នៅតែមានការព្រួយបារម្ភអំពីប្រសិទ្ធភាពនៃយន្តការដោះស្រាយវិវាទនេះ និង មានការខកចិត្តដោយសារចំនួននៃករណីវិវាទដីធ្លីទាំងអស់មិនបានដាក់បញ្ចូលទៅក្នុងសុចនាករ សម្រាប់តាមដានចំពោះការរីកចម្រើនដែលទាក់ទងទៅនឹងបញ្ហាដ៏ចម្រូងចម្រាសនេះ[៣២៧]។ សហគមន៍ងាយរងគ្រោះដែលពាក់ព័ន្ធនឹងវិវាទដីធ្លីជាមួយអាជ្ញាធរមានឋានៈខ្ពស់ និង បុគ្គលដែលមានទំនាក់ទំនងល្អជាមួយ បានបន្តដាក់បណ្ដឹងរបស់ពួកគេទៅគណៈកម្មការសុរិយោដី តែមិនត្រូវបានលើកយកមកដោះស្រាយ ត្រូវប្រានចោល ឬ ត្រូវបំភ្លេចធ្វើឱ្យសហគមន៍អស់សង្ឃឹម និង ចាកចេញពីដំណើរការតាមផ្លូវច្បាប់។

រូបភាពទី៧ ករណីវិវាទដីធ្លីដែលភាគីបានស្នើសុំដកពាក្យបណ្ដឹង




<u>ប្រភព:</u> លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ របាយការណ៍ប្រចាំ ពីឆ្នាំ ២០០៣ ដល់ឆមាសទី១ ឆ្នាំ២០០៩ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩។

ចំនួនករណីវិវាទត្រូវបានភាគីស្នើសុំដកពាក្យបណ្ដឹង គឺចាប់ផ្ដើមពីឆ្នាំ២០០៥ រហូតដល់ឆ្នាំ ២០០៩ ពីចំនួន៤៩ ដល់ ២៧២ ករណី។ ដោយឡែកនៅឆ្នាំ២០០៣ និងឆ្នាំ២០០៤ មិនមានការ

---

[៣២៦] ប្រកាស លេខ ០៣២ ប្រក គសដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ ស្ដីពី ***ការធ្វើប្រតិភូកម្មមុខងារជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដី រាជធានី ខេត្ត*** ដើម្បីធ្វើសេចក្ដីសម្រេចលើសំណុំរឿងវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី ៖ប្រការ១។

[៣២៧] NGO Forum on Cambodia: <***NGO Position Papers on Cambodia’s Development in 2009-2010 to the 3rd Cambodia Development Cooperation Forum***>, Phnom Penh, May2010, page55.

ដកពាក្យបណ្តឹងទេ។ កម្រិតនៃការដកពាក្យកើនខ្លាំងចាប់ពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីចាប់ឱ្យដំណើរការ ដោយឡែកនៅឆ្នាំ២០០៨ កើនឡើង ចំនួន២២០ ករណី ករណីបើប្រៀបធៀបទៅនឹងឆ្នាំ២០០៧ មានចំនួន៩៦ ករណី។ ការសិក្សារបស់អង្គការអុកស្វាមឆ្នាំ២០០៤ ភាគីដែលជាជនរងគ្រោះបង្ខំចិត្តបោះបង់ចោលលែងរវីរវល់ នឹងវិវាទដីធ្លីរបស់ខ្លួន ក្នុងចំណោមករណីវិវាទចំនួន៤៩៥ ដែលមិនទាន់បានដោះស្រាយមាន១៣២ ករណី ស្មើនឹង ២៧%។[៣២៨] មានមូលហេតុសំខាន់ៗមួយចំនួនដែលនាំដល់ការដកពាក្យ ឬមិនរវីរវល់គឺដោយសារ (១)គ្មានជំនឿ និងអស់សង្ឃឹមនឹងប្រព័ន្ធដោះស្រាយវិវាទដីធ្លី (២)ខ្វះថវិកាតក្តី ការជាប់ជំពាក់យ៉ាងជ្រៅក្នុងបំណុល និងជីវភាពរស់នៅកំពុងគំរាមកំហែងដោយសេចក្តីខ្វះខាត (៣)សេចក្តីតក់ស្លុត និង ភិតភ័យដោយការគំរាមកំហែង និងអំពើហិង្សា។ ករណីខ្លះទៀត ការដកពាក្យបណ្តឹងធ្វើឡើងដោយបង្ខំ គឺភាគីត្រូវបានចាប់ខ្លួនដាក់ពន្ធនាគារមួយរយៈបន្ទាប់មកត្រូវតុលាការដោះលែងវិញ ដោយឱ្យផ្តិតមេដៃលើឯកសារយល់ព្រមបញ្ឈប់ការទាមទារលើករណីវិវាទនោះ។ ជាឧទាហរណ៍ ករណីវិវាទដីធ្លីរវាងប្រជាពលរដ្ឋ និងក្រុមហ៊ុនចំការកៅស៊ូបឹងកេត ខេត្តកំពង់ចាម ភាគីប្រជាពលរដ្ឋម្នាក់ត្រូវបានចាប់ខ្លួនដាក់ពន្ធនាគារអស់រយៈពេល៦ថ្ងៃដោយចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ (កាប់ឆ្ការព្រៃដែលអ្នកភូមិទាំងអស់អះអាងថាជាដីរបស់ពួកគេបាន ប្រើប្រាស់ចាប់តាំងពីឆ្នាំ១៩៨២រហូតដល់ឆ្នាំ១៩៩៧) តែជនត្រូវចោទមិនបានបំផ្លាញអ្វីទាំងអស់[៣២៩]។ ទោះបីជាការដោះលែងជាថ្នូរនឹងការសន្យាថា ដកពាក្យបណ្តឹងលើក្រុមហ៊ុនក៏ដោយក្នុងរបាយការណ៍នៅតែចោទប្រកាន់ ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈដដែល។ ការមិនលុបចោលបទចោទនេះ គេទុកប្រើប្រាស់នៅពេលវេលាណាមួយក៏បាន ដើម្បីគាបសង្កត់ភាគីនៅថ្ងៃខាងមុខ។

រូបភាពទី៨ ករណីវិវាទដីធ្លីដែលបានប្តឹងសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីទៅតុលាការ៖




---

[៣២៨] អុកស្វាមអង់គ្លេសៈ ***វិវាទដីធ្លីនៅឆ្នាំ ១៩៩១-២០០៤*** ភ្នំពេញ ឆ្នាំ២០០៤ ទំព័រ២២។

[៣២៩] LICADHO: ***ការវាយប្រហារ និងការគំរាមគំហែង*** អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៍សង្ខេប ភ្នំពេញ ឆ្នាំ២០០៦ ទំព័រ២០។

ប្រភព: លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ របាយការណ៍ប្រចាំ ពីឆ្នាំ ២០០៣ ដល់ឆមាសទី១ ឆ្នាំ២០០៩ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩។

ចំពោះការប្ដឹងទាស់សេចក្ដីសម្រេច របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទបានប្ដឹងឱ្យមានការពិនិត្យឡើងវិញផ្នែកច្បាប់ លើសេចក្ដីសម្រេចនេះទៅតុលាការចាប់តាំងពីពេលដាក់ឱ្យដំណើរការគណៈកម្មការសុរិយោដីនៅក្នុងឆ្នាំ២០០៣មក មានចំនួនតែ២ករណីប៉ុណ្ណោះ។ ជាទូទៅបណ្ដឹងទៅតុលាការមានការកើនឡើងជាលំដាប់ តែមានលក្ខណៈតិចតួចគិតចាប់តាំងពីឆ្នាំ២០០៦ រហូតដល់ឆ្នាំ២០០៩។ ដោយឡែកសម្រាប់ឆ្នាំ២០០៤ និង ឆ្នាំ២០០៥ មិនមានបណ្ដឹងទៅតុលាការទេ។ បណ្ដឹងលើសេចក្ដីសម្រេចកើនឡើងពីចំនួនសូន្យទៅចំនួន៦១ករណី នៅឆ្នាំ២០០៦ នៅពេលដែលចំនួនបណ្ដឹងនៅឆ្នាំ ២០០៧-២០០៨ មានចំនួនកំណើនតិចតួចគឺពីចំនួនរវាង ៨០-៨៤ករណី។

នៅពេលបណ្ដឹងដល់ដៃសាលាដំបូងរាជធានី ខេត្ត ដំណើរការត្រូវធ្វើទៅតាមនីតិវិធីរបស់តុលាការដោយផ្អែកទៅតាមក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ ការអនុវត្តមានលក្ខណៈស្មុគស្មាញ ភាគីដើមបណ្ដឹងត្រូវបង់ពន្ធលើកម្មវត្ថុនៃបណ្ដឹង និងពន្ធលើការដាក់ពាក្យសុំដោយធ្វើការគណនាតម្លៃជាប្រាក់គិតជាភាគរយនៃតម្លៃដីនៃកម្មវត្ថុបណ្ដឹង[៣៣០]។ ចំពោះភាគីដែលជាប្រជាពលរដ្ឋក្រីក្រវាំរែកមិនចង់ដាក់ពាក្យប្ដឹងទៅតុលាការ ពីព្រោះត្រូវចំណាយប្រាក់ច្រើន ការណ៍នេះ វាអាចជាកត្តាដែលជំរុញឱ្យពួកគាត់ទទួលយកដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ទោះបីបើពួកគេមិនពេញចិត្តក៏ដោយ។ បើទោះបីជា ច្បាប់បានអនុគ្រោះដល់ជនក្រីក្រ ដែលខ្វះខាតធនធានក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារ និងពុំបាច់បង់ប្រាក់ទៅតុលាការក៏ដោយ តែតម្រូវឱ្យមានលក្ខខណ្ឌពីរគឺ លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានអំពីស្ថានភាពក្រីក្រប្រាកដមែន និង បណ្ដឹងដែលដាក់មកតុលាការអាចនឹងមានលទ្ធភាពឈ្នះក្ដី[៣៣១]។ បញ្ហាកំណើននៃប្រាក់ប្រដាប់ក្ដីចំពោះបណ្ដឹងរដ្ឋប្បវេណីនៅតាមសាលាដំបូងរាជធានី ខេត្តពី ៧,៥០០ រៀល (ប្រហែល១,៧៨ ដុល្លារអាមេរិក) ដល់ ៥,៥០០០ រៀល (ប្រហែល១២,៥០ ដុល្លារអាមេរិក) វាជាឧបសគ្គដ៏ធំចំពោះសិទ្ធិទទួលបានយុត្តិធម៌ និង កំណើននេះក៏ធ្វើឱ្យប៉ះពាល់ចំនួននៃការដាក់ពាក្យបណ្ដឹងទៅតុលាការក្នុងរឿងវិវាទដីធ្លី។

[៣៣០] ព្រះរាជក្រម លេខ នស រកម ០៧០៦ ០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ស្ដីពី *ក្រមនីតិវិធីរដ្ឋប្បវេណី* ៖ មាត្រា៦០ និង៦១។

[៣៣១] ព្រះរាជក្រម លេខ នស រកម ០៧០៦ ០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ស្ដីពី *ក្រមនីតិវិធីរដ្ឋប្បវេណី* ៖ មាត្រា៦៩។

រូបភាពទី៩ ករណីវិវាទដីធ្លីដែលបានច្រានចោលដោយគណៈកម្មការសុរិយោដី៖




ប្រភព: លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ របាយការណ៍ប្រចាំ ពីឆ្នាំ ២០០៣ ដល់ឆមាសទី១ ឆ្នាំ២០០៩ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩។

ចំនួនករណីវិវាទដីធ្លី ដែលត្រូវច្រានចោលដោយគណៈកម្មការសុរិយោដីកើនឡើងជាលំដាប់ពីឆ្នាំ២០០៣-២០០៩ ពីចំនួន៨២ករណី ដល់១៣៦៩ករណី។ គណៈកម្មការសុរិយោដីស្រុក ខណ្ឌ អាចច្រានចោលបណ្តឹងទាមទារណាដែលមិនត្រឹមត្រូវ ឬគ្មានមូលដ្ឋាន ក្នុងករណីភាគីមិនសុខចិត្តអាចប្តឹងតវ៉ាទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង [៣៣២]។ ទោះបីជាយ៉ាងណា ការច្រានចោលត្រូវធ្វើឡើងក្រោយពេលស៊ើបអង្កេតត្រូវបានបញ្ចប់ បើឃើញថា ករណីវិវាទនោះមិនស្ថិតនៅក្រោមយុត្តាធិការរបស់គណៈកម្មការសុរិយោដីនោះទេ[៣៣៣]។ វិវាទត្រូវច្រានចោលចាប់កើនឡើងខ្លាំងនៅឆ្នាំ២០០៥ មានចំនួន៣៨២ ករណី បើប្រៀបធៀបនឹងឆ្នាំ២០០៤ មានតែចំនួន១២៥ករណី។ ជាទូទៅ ករណីវិវាទដែលច្រានចោលមានការកើនឡើងជាលំដាប់ គិតចាប់ពីពេលដំណើរការរបស់គណៈកម្មការរហូតដល់ឆ្នាំ២០០៩។

តាមរូបភាពនេះ និន្នាការនៃការច្រានចោលបណ្តឹងកើនឡើង។ ករណីដែលច្រានចោលភាគច្រើនធ្វើឡើងនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ដោយសារមានភាពស្ទាក់ស្ទើរក្នុងការបញ្ជូនវិវាទឡើងទៅលើ និងករណីខ្លះដែលបានបញ្ជូនទៅលើហើយ ច្រើនតែត្រូវបញ្ជូនត្រឡប់មកវិញព្រមជាមួយ

---

[៣៣២] ប្រកាស លេខ ១១២ ដនស ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី *គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី*៖ ប្រការ១៩។

[៣៣៣] ប្រកាស លេខ ១១២ ដនស ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី *គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី*៖ ប្រការ១៧។

នឹងការណែនាំឱ្យស៊ើបអង្កេតបន្ថែម ឬឱ្យព្យាយាមសម្រុះសម្រួលឡើងវិញ[៣៣៤]។ នេះដូចជាការដាក់សម្ពាធមកគណៈកម្មការសុរិយោដីថ្នាក់ក្រោមកាន់តែច្រើន ការណ៍នេះនាំឱ្យមានការច្រានចោលករណីវិវាទដែលជាវិធីមួយក្នុងការបញ្ចប់ករណីក្នុងបន្ទុករបស់ខ្លួន។ ជាគោលការណ៍ការច្រានចោលបណ្តឹងមិនមែនជាប្រការគួរលើកទឹកចិត្តឱ្យធ្វើនោះទេ លើកលែងតែក្នុងករណីចាំបាច់ ដើម្បីរារាំងភាពអយុត្តិធម៌តែប៉ុណ្ណោះ។ ការច្រានចោលវិវាទវាជាហេតុផលដ៏អាក្រក់ ប្រសិនបើជាហេតុបណ្តាលមកពីការបកស្រាយយ៉ាងចង្អៀតចង្អល់អំពីយុត្តាធិការរបស់គណៈកម្មការសុរិយោដី ដើម្បីគេចវេសមិនដោះស្រាយចំពោះវិវាទដែលពិបាកៗនោះ។

រូបភាពទី១០ ករណីវិវាទដីធ្លីដែលកំពុងដោះស្រាយដោយគណៈកម្មការសុរិយោដី៖




ប្រភព: លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ របាយការណ៍ប្រចាំ ពីឆ្នាំ ២០០៣ ដល់ឆមាសទី១ ឆ្នាំ២០០៩ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩។

ចំនួនករណីវិវាទដីធ្លី ដែលកំពុងដោះស្រាយដោយគណៈកម្មការសុរិយោដីកើនឡើងពីឆ្នាំ ២០០៣-២០០៧ ពីចំនួន៨៩០ករណីដល់២០៦០ករណី។ ចំនួនករណីដែលកំពុងដោះស្រាយថយចុះពីចំនួន២០៦០ ឆ្នាំ២០០៧ មកចំនួនករណីមក១៩៥២ នៅឆ្នាំ២០០៨។ តាមរូបភាពខាងលើនេះ ករណីវិវាទឆ្នាំ២០០៩ ចំនួន១៧៤២ករណី មើលទៅហាក់ដូចជាមានការថយចុះខ្លាំងនេះ គឺដោយសារទិន្នន័យដែលទទួលបានត្រឹមតែឆមាសទី១នៃឆ្នាំ២០០៩ តែប៉ុណ្ណោះ ចំនួនជាក់ស្តែងសម្រាប់រយៈពេលមួយឆ្នាំនឹងលើសពីនេះ។

---

[៣៣៤] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់: ***កសាងស្ថាប័នយុត្តិធម៌?*** ការពិនិត្យមើលទៅលើការងាររបស់គណៈកម្មការសុរិយោដីនៅកម្ពុជា ទាក់ទងនឹងការដោះស្រាយវិវាទដីធ្លី ភ្នំពេញ ឆ្នាំ២០០៦ ទំព័រ៤៦។

យុត្តាធិការរបស់គណៈកម្មការសុរិយោដី គឺការដោះស្រាយទំនាស់ដីធ្លីក្រៅប្រព័ន្ធតុលាការ ក្នុងន័យដោះស្រាយវិវាទលើដីដែលមិនទាន់បានចុះបញ្ជីសុរិយោដីរវាងភាគី និងភាគី។ លទ្ធផលខាងលើស្តែងឱ្យឃើញថា គណៈកម្មការបានពង្រីកការដោះស្រាយដោយប្រើប្រាស់តាមការដោះស្រាយវិវាទចល័តដែលកន្លងមកតាមរយៈក្រុមចល័តនេះ វិវាទដីធ្លីដែលមាននៅតាមក្រុង ស្រុក ខ័ណ្ឌ មួយចំនួនត្រូវបានដោះស្រាយរួចស្ទើរទាំងស្រុង[៣៣៥]។ ជាងនេះទៅទៀត គណៈកម្មការសុរិយោដីថ្នាក់ជាតិក៏បានធ្វើប្រតិភូកម្មមុខងារធ្វើសេចក្តីសម្រេចទៅឱ្យប្រធានគណៈកម្មការសុរិយោដីរាជធានី ខេត្ត រួមទាំងការណែនាំអនុវត្តផងដែរ។ ទោះបីជារដ្ឋខិតខំដោះស្រាយយ៉ាងខ្លាំងក្លាក៏ដោយ ក៏មិនអាចបញ្ចប់វិវាទឱ្យអស់ទាំងស្រុងនោះដែរ។

ទំនាស់ធំៗរវាង ប្រជាពលរដ្ឋច្រើនគ្រួសារដែលគ្មានអំណាច ជាមួយនឹងក្រុមហ៊ុនដែលជាអាជ្ញាធរមានឋានៈខ្ពស់ ឬមានខ្នងបង្អែកធំ នៅតែបង្ហាញឱ្យឃើញនូវភាពអយុត្តិធម៌កាន់តែធ្ងន់ធ្ងរថែមទៀត[៣៣៦]។ ជាពិសេស នៅពេលដែលភាគីក្រុមហ៊ុនប្រើអំពើហិង្សាឈូសឆាយរំលោភយកដីប្រជាពលរដ្ឋ ភាគីអ្នកគ្មានអំណាចបានទទួលរងនូវការចោទប្រកាន់ និង ចាប់ខ្លួនជាដើម។ ក្នុងរឿងទំនាស់នេះ អាជ្ញាធរមួយចំនួនបានដើរតួនាទីយ៉ាងសកម្ម និង ដោយចំហរធ្វើជាភាគីជំនួសឱ្យក្រុមហ៊ុន ក្នុងន័យការពារផលប្រយោជន៍ក្រុមហ៊ុនដោយចេញមុខជាភាគីទំនាស់ដោយផ្ទាល់ ជាមួយភាគីប្រជាពលរដ្ឋផង និង ដើរតួជាអ្នកដោះស្រាយផង។ ការណ៍នេះ ធ្វើឱ្យបាត់បង់ជំនឿលើយន្តការដោះស្រាយទំនាស់នៅថ្នាក់មូលដ្ឋាន ហើយភាគីប្រជាពលរដ្ឋចង់តែមកធ្វើការតវ៉ានៅថ្នាក់ជាតិ។ ទោះបីជាមកដល់ថ្នាក់ជាតិហើយក៏ដោយក៏មិនមានការដោះស្រាយចំពោះករណីវិវាទមួយចំនួន ដែលនេះគឺជាការព្រួយបារម្ភដ៏ធំរបស់ប្រជាពលរដ្ឋទទួលរងនូវការឈឺចាប់កើតចេញពីភាពអយុត្តិធម៌ទាំងនេះ។

## ៣.១.៥ ការដោះស្រាយតាមអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស រកត ០២០៦ ០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ដែលមានអគ្គលេខាធិការដ្ឋាន ជាសេនាធិការក្នុងការប្រតិបត្តិការងារប្រចាំថ្ងៃ ដើម្បីជួយដោះស្រាយទំនាស់ដីធ្លីដែលកំពុងតែកើតមាននៅកម្ពុជា[៣៣៧]។ យោងតាមព្រះរាជក្រឹត្យនេះ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដឹកនាំដោយតំណាងនាយករដ្ឋមន្ត្រី

[៣៣៥] អ៊ឹម ឈុនលឹមៈ ***សន្ទរកថាក្នុងឱកាសបិទសន្និបាតបូកសរុបការងារឆ្នាំ២០០៩*** និងលើកទិសដៅឆ្នាំ២០១០ របស់ក្រសួង រៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១០ ទំព័រ៣។

[៣៣៦] សមាគមអាដហុកៈ ***ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៩*** របាយការណ៍លេខ៩ ឆ្នាំទី៩ ភ្នំពេញ ខែមករា ឆ្នាំ២០១០ ទំព័រ៣។

[៣៣៧] ពាក្យ អាជ្ញាធរ គឺអ្នកកាន់អំណាច វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ទំព័រ១៧២២។

ជាប្រធាន និង រដ្ឋមន្ត្រី រដ្ឋលេខាធិការ ព្រមទាំងមានមន្ត្រីជាន់ខ្ពស់នៃ ក្រសួង ស្ថាប័ននានាជាសមាជិក[៣៣៨] ។

សមាជិកនៃអាជ្ញាធរនេះសុទ្ធសឹងតែជាមន្ត្រីជាន់ខ្ពស់ របស់រាជរដ្ឋាភិបាលដែលអាចឱ្យដំណើរការនៃការដោះស្រាយវិវាទដីធ្លីនៅកម្ពុជាប្រព្រឹត្តទៅបាន និងដោយមិនមានការគំរាមកំហែងពីសំណាក់ភាគីវិវាទ។ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានតួនាទីទប់ស្កាត់ និង កាត់បន្ថយទំនាស់ដីធ្លីតាមរយៈការផ្សព្វផ្សាយ អប់រំឱ្យសាធារណៈជន ឱ្យយល់ដឹងអំពីផលវិបាកដែលបណ្តាលមកពីទំនាស់ដីធ្លី និង តាមរយៈការដាក់ពិន័យចំពោះជនល្មើសដែលបានធ្វើការរំលោភបំពានលើដីធ្លីដោយខុសច្បាប់ជាធរមាន[៣៣៩]។ ជាងនេះទៀត អាជ្ញាធរនេះធ្វើការស្វែងយល់ស៊ើបអង្កេត និង ដោះស្រាយទំនាស់ដីធ្លីព្រមទាំងឃ្លាំមើលការដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដី និង អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ហើយធ្វើរបាយការណ៍អំពីលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាល។

អាជ្ញាធរដដែលនេះ ក៏មានរចនាសម្ព័ន្ធប្រហាក់ប្រហែលនឹងគណៈកម្មការសុរិយោដីដែលមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការមានតួនាទីជាអ្នកទទួល និង ពិនិត្យមើលសំណុំរឿងពាក្យបណ្តឹងព្រមទាំងធ្វើការស៊ើបអង្កេត និង ធ្វើរបាយការណ៍នៃការស៊ើបអង្កេតពាក់ព័ន្ធនឹងបញ្ហាទំនាស់ដីធ្លីដើម្បីដាក់ជូនប្រធានអាជ្ញាធរពិនិត្យ និង សម្រេចតាមដំណាក់កាលនីមួយៗ។ ភាគច្រើននៃកិច្ចព្រមព្រៀងបញ្ចប់វិវាទ ដោយផ្អែកតាមចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា[៣៤០]។ លើសពីនេះទៅទៀត អគ្គលេខាធិការដ្ឋាននេះមានតួនាទីបញ្ជូនកំណត់ហេតុ និង ភស្តុតាងទាំងអស់ទៅតុលាការនៅពេលមានការប្តឹងតវ៉ាលើសេចក្តីសម្រេចរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីទៅតុលាការ[៣៤១]។

សមត្ថកិច្ចរបស់អាជ្ញាធរជាតិនេះ មានការពាក់ព័ន្ធយ៉ាងខ្លាំងជាមួយនឹងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដែលមានយុត្តាធិការពេញលេញក្នុងការសម្រេចទទួលស្គាល់ភោគី ឬ កម្មសិទ្ធិករស្របច្បាប់ ហើយអាជ្ញាធរក៏មានសមត្ថកិច្ចធំធេងគ្របដណ្តប់លើទំនាស់ដីធ្លីទូទាំងប្រទេស និងថែមទាំងអាចទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋាន ដែលពាក់ព័ន្ធនឹងទំនាស់ដីធ្លីទាំងដីដែលបានចុះ ឬ ដីមិនទាន់ចុះបញ្ជីសុរិយោដីផងដែរ ។ នៅពេលមានវិវាទដីមិនទាន់ចុះបញ្ជីសុរិយោដីកើតឡើង តើគូ

---

[៣៣៨] ព្រះរាជក្រឹត្យ លេខ នស រកត ០២០៦ ០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពី *ការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*៖ មាត្រា១។

[៣៣៩] ព្រះរាជក្រឹត្យ លេខ នស រកត ០២០៦ ០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពី *ការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*៖ មាត្រា៣។

[៣៤០] លិខិត លេខ ១២៦២ សជណ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការជូនដំណឹងកិច្ចបញ្ចប់ករណីទំនាស់ដីធ្លីនៅភូមិដើមស្រល់ ឃុំមនោរម្យ ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគីរី ពីទីស្តីការគណៈរដ្ឋមន្ត្រី ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលខេត្តមណ្ឌលគីរី។

[៣៤១] ព្រះរាជក្រឹត្យ លេខ នស រកត ០២០៦ ០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពី *ការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*៖ មាត្រា៥។

ភាគីអាចប្ដឹងដោយផ្ទាល់ទៅអាជ្ញាធរនេះដោយរំលងចោលនីតិវិធីរបស់គណៈកម្មការសុរិយោដីបានដែរ ឬទេ? នៅពេលសេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ចេញមកហើយមានការជំទាស់ពីភាគី តើត្រូវប្ដឹងទៅអាជ្ញាធរជាតិ ឬមួយយ៉ាងណា ?ចាប់ពីពេលបង្កើតអាជ្ញាធរនៅឆ្នាំ២០០៦មកដល់បច្ចុប្បន្ន នៅតែមានភាពស្រពិចស្រពិលរវាងសមត្ថកិច្ចរបស់អាជ្ញាធរជាតិ និងគណៈកម្មការសុរិយោដីថ្នាក់ជាតិដោយសារមិនទាន់មានបទដ្ឋានគតិយុត្ត ដូចជាគោលការណ៍ណែនាំ និង នីតិវិធីណាមួយបានកំណត់អំពីដំណើរការនៃការប្រព្រឹត្តទៅ និង តួនាទីរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីឱ្យបានច្បាស់លាស់ដូចគណៈកម្មការសុរិយោដីនៅឡើយ។

ផ្អែកតាមមាត្រា៣ នៃព្រះរាជក្រឹត្យ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានភារកិច្ចដោះស្រាយវិវាទណាដែលហួសពីសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ។ ក៏ប៉ុន្តែ តើវិវាទប្រភេទណាដែលហួសពីសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ? មានតែទំនាស់ដីធ្លីដែលបានចុះបញ្ជីរួច? បើដូច្នេះមានតែសមត្ថកិច្ចរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីនេះ ជាន់គ្នាជាមួយនឹងសមត្ថកិច្ចរបស់តុលាការក្នុងការដោះស្រាយវិវាទដីធ្លី។ បញ្ហានេះ ធ្វើឱ្យគេអាចនិយាយបានថា មាត្រា៣ នៃព្រះរាជក្រឹត្យខាងលើបានផ្ដល់សមត្ថកិច្ចក្នុងការដោះស្រាយវិវាទដីធ្លី ដែលដីចុះបញ្ជីរួចទៅឱ្យអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដោយបញ្ចូលអាជ្ញាធរនេះ ជាស្ថាប័នមានសមត្ថកិច្ចថ្មី ក្នុងការដោះស្រាយវិវាទដីធ្លី បន្ថែមលើស្ថាបន័មានសមត្ថកិច្ចចាស់ដែលបានកំណត់រួចជាស្រេចដោយប្រកាសអន្តរក្រសួងលេខ០២ ប្រកអ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្ដីពីការកំណត់ភារៈកិច្ចរបស់តុលាការ និង គណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងវិវាទដីធ្លី។ មិនមានលិខិតបទដ្ឋានគតិយុត្តណាមួយបានធ្វើឡើង ដើម្បីកំណត់ភារកិច្ចរវាងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងតុលាការទេ។ តែអាជ្ញាធរនេះធ្វើជាអ្នកឃ្លាំមើលការដោះស្រាយទំនាស់ដីធ្លី របស់អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់[៣៤២]។ ជាវិបាកចាប់ពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីនេះមានដំណើរការ គេអាចដាក់ពាក្យបណ្ដឹងទាក់ទងវិវាទដីធ្លីចុះបញ្ជីរួចទៅអាជ្ញាធរជាតិផង និង ទៅតុលាការផង។ ជាក់ស្ដែងករណី វិវាទដែលបានទទួលសម្រាប់ត្រីមាសទី២ ឆ្នាំ២០០៩ ក្នុង ៥២ករណី មាន ១.៩២ % ជាបណ្ដឹងពីការអនុវត្តសាលក្រម និងសាលដីការបស់តុលាការ។

[៣៤២] ព្រះរាជក្រឹត្យ លេខនស រកត ០២០៦ ០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្ដីពី ***ការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*** ៖ មាត្រា៣។

តារាងទី៩ លទ្ធផលដោះស្រាយបានគិតមកត្រឹមឆមាសទី២៖ ២១.០៣.២០០៩-២០.០៩.២០០៩

| ការដោះស្រាយរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | | | |
|---|---|---|---|
| ដំណាក់ការបណ្តឹង | ពីថ្ងៃដំណើរការដល់ ថ្ងៃទី២១ មិនា ២០០៩ | ត្រីមាសទី២ | សរុប |
| ចំនួនបណ្តឹង | ១១៤០ | ៥២ | ១១៩២ |
| បណ្តឹងបង្វែ | ៩១៦ | ៣១ | ៩៤៧ |
| បានដោះស្រាយដោយអាជ្ញាធរ | ៣៤ | ៤ | ៣៨ |
| ដកពាក្យ | ១១ | ១ | ១២ |
| ច្រានចោល | ៣១ | ០ | ៣១ |
| កំពុងដោះស្រាយ | ០ | ១៦៥ | ១៦៥ |

ប្រភព: អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី របាយការណ៍ឆមាសទី២ ឆ្នាំ២០០៩ លេខ០០៣ របក អជដ ឆ្នាំ២០០៩

គិតមកត្រឹមឆមានសទី១ ឆ្នាំ២០០៩ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី (អ.ជ.ដ) ទទួលពាក្យបណ្តឹងផ្ទាល់ពីប្រជាពលរដ្ឋ និងពីស្ថាប័នផ្សេងៗចំនួន១១៩២ ករណី ក្នុងនោះ ករណីដោះស្រាយបានជោគជ័យមាន ចំនួន ៣៨ ករណី។ ចំណែកករណីវិវាទចំនួន៩៤៧ ករណី អគ្គលេខាធិការដ្ឋានបានបង្វែរទៅឱ្យស្ថាប័នជំនាញដើម្បីជំរុញឱ្យពិនិត្យ និង តាមដានដោះស្រាយ។ ដោយឡែកនៅត្រីមាសទី២ ឆ្នាំ២០០៩ នេះ អគ្គលេខាធិការដ្ឋានទទួលបណ្តឹងថ្មីចំនួន៥២ ករណី។

ក្នុងចំណោមបណ្តឹងថ្មីចំនួន៥២ករណី មានចំនួន៧១,១៥ ភាគរយ ករណីបណ្តឹងទាមទារដី ១១,៥៤ ភាគរយ ករណីបណ្តឹងអំពីការរំលោភសិទ្ធិលើដីធ្លី ១៣,៤៦ ភាគរយ ករណីបណ្តឹងសុំសិទ្ធិគ្រប់គ្រងដី១,៩២ ភាគរយ ករណីបណ្តឹងអំពីការអនុវត្តសាលក្រម និង សាលដីការតុលាការនិង ១,៩២ ភាគរយទៀត ករណីបណ្តឹងសុំផ្អាកការសាងសង់។ ទោះបីជាខិតខំប្រឹងប្រែងដោះស្រាយបានច្រើនហើយក៏ដោយនៅតែជួបបញ្ហាប្រឈមមួយចំនួន ដូចជា អាជ្ញាធរជាតិមិនទាន់បំពេញទៅតាមតម្រូវការជាក់ស្តែងដែលកើតឡើង ម្យ៉ាងទៀត សំណុំរឿងមានលក្ខណៈស្មុគស្មាញ និង ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីច្បាប់នៅមានកម្រិត។

រូបភាពទី១១ លទ្ធផលដោះស្រាយបានគិតមកត្រឹមឆមាសទី២ ឆ្នាំ២០០៩




ប្រភព: អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី របាយការណ៍ឆមាសទី២ ឆ្នាំ២០០៩ លេខ០០៣ របក អផដ ឆ្នាំ២០០៩

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មិនមែនដោះស្រាយរាល់គ្រប់បណ្តឹងទាំងអស់ដែលអាជ្ញាធរជាតិបានទទួលនោះទេ។ ករណីវិវាទជាច្រើន អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី បានធ្វើការបែងចែកទៅឱ្យស្ថាប័នជំនាញដើម្បីដោះស្រាយ ផ្អែកតាមរូបភាពខាងលើករណីបណ្តឹងសរុបចំនួន១១៩២ ករណី ក្នុងនោះមាន៩៤៥ករណី ហើយដែលផ្ទេរទៅឱ្យសមត្ថកិច្ចផ្សេងៗ។ សមត្ថកិច្ចដែលធ្លាប់ត្រូវបានផ្ទេរទៅឱ្យនោះមានជាអាទិ៍៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងសាលារាជធានី ខេត្តមួយចំនួន[៣៤៣]។ ទំនាស់ដីធ្លីដែលអាជ្ញាធរជាតិកំពុងដោះស្រាយមានចំនួន១៦៥ ករណី ចំណែកឯទំនាស់ ចំនួន១២ ករណីទៀតត្រូវភាគីដកពាក្យ និងករណីទំនាស់ចំនួន៣១ ត្រូវច្រានចោល។

អាជ្ញាធរជាតិធ្វើការដោះស្រាយលើទំនាស់ដីធ្លីធំៗ តាមរបាយការណ៍ឆមាសទី១ ឆ្នាំ២០០៧ លេខ: ១៩៨ ០៧ អ.ជ.ដ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី បានដោះស្រាយបញ្ចប់នូវទំនាស់ដែលបានអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំ ដូចជា ទំនាស់ដែលមានភាគីយោធា ភាគីជាក្រុមហ៊ុន ភាគីអាជ្ញាធរថ្នាក់ក្រោមជាតិ និងអាជ្ញាធរមានឋានៈខ្ពស់មួយចំនួនជាដើមដោយទទួលបានជោគជ័យ។ ជាទូទៅទំនាស់ធំៗទាំងនេះ តែងជួបនូវអំពើហិង្សា និងភាគីម្ខាងនៃគូទំនាស់ច្រើនត្រូវបានចោទប្រកាន់ ឬត្រូវចាប់ឃុំខ្លួនពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ លើករណីវិវាទផ្នែករដ្ឋប្បវេណី។ ជ្រាបបញ្ហានេះ រដ្ឋាភិបាលបានណែនាំឱ្យអាជ្ញាធរធ្វើការពិនិត្យ និង ធានាការដោះលែងប្រជាពលរដ្ឋដែលត្រូវចាប់

[៣៤៣] រាជរដ្ឋាភិបាល: *អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី របាយការណ៍* ឆមាសទី១ ឆ្នាំ២០០៧ តាមរយៈ <http://www.pressocm.gov.kh/authority/NALDR/6month_periad.php>; accessed on July07, 2009-PM

ឃុំឃាំងដោយសារទំនាស់ដីធ្លី ធ្វើតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី លើកលែងតែករណីបទល្មើសព្រហ្មទណ្ឌ[៣៤៤]។

ជាក់ស្តែងក្នុងជំនួបត្រីភាគី រវាងនាយករដ្ឋមន្ត្រី គណៈបក្សប្រឆាំង និង តំណាងសង្គមស៊ីវិល នៅថ្ងៃទី ១៥ ខែមិនា ឆ្នាំ២០០៦ នាយករដ្ឋមន្ត្រីបានឯកភាព ថានឹងដោះលែងអ្នកភូមិទាំងអស់ដែលត្រូវឃុំខ្លួនដោយសាររឿងវិវាទដីធ្លី[៣៤៥]។ ក្រោយសេចក្តីប្រកាសនេះ អ្នកជាប់ឃុំដោយសារទំនាស់ដីធ្លីជាច្រើនត្រូវបានដោះលែង តែនៅមានការគំរាមគំហែង។ ស្ទើរគ្រប់ករណីទាំងអស់នៃបទចោទនៅរក្សាដដែល វាធ្វើឱ្យអ្នករួចខ្លួននៅមានការភិតភ័យដដែល។ ការចាប់ឃុំខ្លួនដោយសារទំនាស់ដីធ្លីចាប់ផ្តើមបន្តសារជាថ្មី ករណីតុលាការខេត្តរតនគីរី ចាប់ខ្លួនសកម្មជនដីធ្លីនៅខែកញ្ញាឆ្នាំដដែលដោយមិនធ្វើតាមការណែនាំរបស់លោកនាយករដ្ឋមន្ត្រី។

## ៣.២ ការដោះស្រាយវិវាទដីធ្លីតាមប្រព័ន្ធតុលាការ

ផ្នែកនេះគឺធ្វើការវិភាគទៅលើការកំណត់សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការដោះស្រាយវិវាទដីធ្លីដែលបានកំណត់នៅក្នុងច្បាប់ និង បទបញ្ញាផ្សេងៗ។ ការកំណត់សមត្ថកិច្ចតាមរយៈប្រកាសអន្តរក្រសួងរវាងគណៈកម្មការសុរិយោដី និងតុលាការទាក់ទងនឹងការដោះស្រាយទំនាស់ជួបប្រទះនូវការខ្វែងគំនិតគ្នា។ ជាវិបាកនាំឱ្យមានការចោទប្រកាន់ថា មានការជ្រៀតជ្រែកដែនសមត្ថកិច្ចដោយភាគីម្ខាងសំអាងលើច្បាប់កំពូល និងភាគីម្ខាងទៀតសំអាងលើប្រកាសអន្តរក្រសួងនៅក្នុងការដោះស្រាយទំនាស់ដីដែលមាន ឬគ្មានប័ណ្ណកម្មសិទ្ធិដីធ្លី។

### ៣.២.១ សមត្ថកិច្ចផ្អែកតាមរដ្ឋធម្មនុញ្ញ

តាមមាត្រា ១២៨ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ របស់ព្រះរាជាណាចក្រកម្ពុជា អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។ មានន័យថា តុលាការមានសមត្ថកិច្ចទៅលើគ្រប់ប្រភេទរឿងក្តី មិនថារឿងក្តីនោះពាក់ព័ន្ធទៅនឹងវិវាទដីធ្លីដែលបានចុះ ឬមិនចុះបញ្ជីសុរិយោដីនោះទេ។ ការណ៍នេះ បានធ្វើឱ្យអ្នកដែលមានជំនឿទុកចិត្តទៅលើប្រព័ន្ធតុលាការសម្រេចចិត្តប្តឹងទៅតុលាការ បើទោះបីជា រឿងវិវាទរបស់ខ្លួនស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីក៏ដោយ។ ផ្អែកតាមប្រការ១ ប្រកាសអន្តរក្រសួងនេះ វិវាទដីធ្លីដែលមិនទាន់ចុះបញ្ជីសុរិយោដីពោលគឺដីធ្លីដែលមិនទាន់មានប័ណ្ណសំគាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដី ត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី។ សមត្ថកិច្ចដោះស្រាយដោយគណៈកម្មការនេះត្រូវបានកំណត់រួចជាស្រេចដោយអនុក្រឹត្យលេខ៤៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២។ អនុក្រឹត្យនេះ ផ្តល់សិទ្ធិឱ្យភាគីវិវាទ

[៣៤៤] រាជរដ្ឋាភិបាល: *អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី របាយការណ៍* ឆមាសទី១ ឆ្នាំ២០០៧ -ដ-ទំព័រ៦។

[៣៤៥] Cambodian League For The Promotion and Defense of Human Rights, LICADHO: *ការវាយប្រហារ និងការគំរាមគំហែងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ២០០៦* ទំព័រ១៨ -នៅក្នុង The Cambodia Daily ចុះផ្សាយថ្ងៃទី១៦ ខែមិនា ឆ្នាំ២០០៦ ក្រោមចំណងជើងថា: លោកនាយករដ្ឋមន្ត្រីដោះលែងអ្នកទោសទំនាស់ដីធ្លី។

ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្តឹងទៅតុលាការក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច[៣៤៦] ។

ដូច្នេះការប្តឹងដោយផ្ទាល់ទៅតុលាការអំពីវិវាទដីធ្លី ដែលមិនទាន់ចុះបញ្ជីសុរិយោដីត្រូវបានចាត់ទុកជាការរំលងនីតិវិធីដែលបានរៀបរាប់ខាងលើ។ ក៏ប៉ុន្តែការរំលងនីតិវិធីបែបនេះ អាចធ្វើទៅបានដោយឈរលើមូលដ្ឋាននៃមាត្រា១២៨ថ្មី នៃរដ្ឋធម្មនុញ្ញ។ ដោយសារតែរដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលរបស់រដ្ឋ យើងអាចនិយាយបានថា តុលាការពិបាកនឹងបដិសេធក្នុងការទទួលយកពាក្យបណ្តឹងរំលងនីតិវិធីរបៀបនេះណាស់ ដោយហេតុថា ប្រសិនបើគាត់មិនទទួលយកពាក្យបណ្តឹងរំលងនីតិវិធីនេះទេ មានន័យថា តុលាការទទួលស្គាល់អនុក្រឹត្យលេខ៤៧ ខាងលើមានតម្លៃគតិយុត្តខ្ពស់ជាងរដ្ឋធម្មនុញ្ញ។ តើអនុក្រឹត្យដែលកំណត់ពីនីតិវិធីក្នុងការដោះស្រាយវិវាទដីធ្លី និង ប្រកាសអន្តរក្រសួងដែលកំណត់ពីការបែងចែកសមត្ថកិច្ចរវាងគណៈកម្មការសុរិយោដី និងតុលាការ មានប្រយោជន៍ដែរ ឬទេ ? ប្រសិនបើគេអាចប្តឹងរំលងនីតិវិធី និង មិនគោរពទៅតាមការបែងចែកសមត្ថកិច្ចដោយស្របច្បាប់កំពូលរបស់កម្ពុជា ?

ស្ថាប័នដោះស្រាយទំនាស់ទាំងពីរៈ តុលាការ និងគណៈកម្មកាសុរិយោដីសុទ្ធតែមានច្បាប់ជាបង្អែកដូចគ្នា។ គណៈកម្មការសុរិយោដីផ្អែកតាមច្បាប់ភូមិបាលមាត្រា៤៧ និងអនុក្រឹត្យលេខ៤៧ អំពីគណៈកម្មការសុរិយោដី ចំណែកឯតុលាការវិញ ដោះស្រាយផ្អែកតាមរដ្ឋធម្មនុញ្ញ។ យោងតាមឋានានុក្រមនៃច្បាប់របស់កម្ពុជា រដ្ឋធម្មនុញ្ញមានតម្លៃគតិយុត្តខ្ពស់ជាងច្បាប់ ដូច្នេះធ្វើអ្វីអនុលោមតាមរដ្ឋធម្មនុញ្ញគឺត្រឹមត្រូវជាង។ ទោះបីជាយ៉ាងណា ទំនាស់ផ្នែកច្បាប់គេអាចដោះស្រាយបានដោយគ្រាន់តែធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញមាត្រា១២៨ថ្មី ឬក៏ត្រូវលុបចោលលិខិតបទដ្ឋានគតិយុត្តដែលផ្ទុយទៅនឹងច្បាប់កំពូលនេះជាការស្រេច។

## ៣.២.២ សមត្ថកិច្ចផ្អែកតាមប្រកាសអន្តរក្រសួង

តាមប្រការ១នៃប្រកាសអន្តរក្រសួង ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងវិវាទដីធ្លី រវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានបែងចែកសមត្ថកិច្ចក្នុងការដោះស្រាយវិវាទដីធ្លី ដែលបានចុះបញ្ជីសុរិយោដីរួចហើយ មានន័យថា ដីធ្លីដែលមានប័ណ្ណសំគាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដី។ ចំពោះប័ណ្ណដែលចេញដោយរដ្ឋបាលសុរិយោដី វាអាចជាប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ និងប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណកម្មសិទ្ធិស្ថាពរ[៣៤៧]។ ដូចនេះរាល់វិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជីសុរិយោដី មិនស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការឡើយ។

---

[៣៤៦] អនុក្រឹត្យ លេខ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី *ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*៖មាត្រា៣ និងមាត្រា៣០។

[៣៤៧] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល*៖មាត្រា ៤០។

ត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការ រាល់វិវាទអំពីកិច្ចសន្យា ពាក់ព័ន្ធនឹងដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដូចជា វិវាទអំពីការបែងចែកមត៌ក និងវិវាទអំពីកិច្ចសន្យា ទិញលក់ ជួល បញ្ចាំជាដើម[៣៤៨]។ ការកំណត់សមត្ថកិច្ចនេះហាក់ដូចជាមានលក្ខណៈផ្ទុយទៅនឹងប្រការ១ដែលបានកំណត់អំពីសមត្ថកិច្ចរបស់តុលាការលើដីធ្លីដែលបានចុះបញ្ជីសុរិយោដីរួច ព្រោះថា វាបានផ្តល់សមត្ថកិច្ចទៅឱ្យតុលាការក្នុងការដោះស្រាយវិវាទពាក់ព័ន្ធនឹងដីធ្លី ដែលមិនទាន់ចុះបញ្ជីសុរិយោដី។ តែបើយើងពិនិត្យឱ្យបានស៊ីជម្រៅ និងផ្អែកលើច្បាប់រដ្ឋធម្មនុញ្ញមាត្រា១០៩ នោះយើងនឹងឃើញថា លក្ខណៈផ្ទុយនេះនឹងបាត់ទៅវិញដោយហេតុថា ការដោះស្រាយវិវាទដែលទាក់ទងនឹងសិទ្ធិដែលមានចែងក្នុងច្បាប់ និង កិច្ចសន្យាគឺជាសមត្ថកិច្ចរបស់តុលាការ ទោះបីកិច្ចសន្យានោះ ពាក់ព័ន្ធនឹងដីធ្លីដែលបាន ឬ មិនបានចុះបញ្ជីសុរិយោដីហើយក៏ដោយ ។ តែផ្ទុយទៅវិញតុលាការខេត្តខ្លះ បានចេញដីការសម្រេចឈប់ទទួលចាត់ការដោះស្រាយវិវាទដីធ្លី ស្របតាមប្រកាសអន្តរក្រសួង ហើយឈប់ទទួលវិវាទដីដែលជាប្រភេទដីភោគៈ ដីមិនទាន់មានប័ណ្ណសំគាល់សិទ្ធិគ្រប់គ្រងកាន់កាប់អចលនៈវត្ថុ ឬប្លង់សុរិយោដី។ ឧទាហរណ៍ករណីតុលាការខេត្តបាត់ដំបង បានចេញដីការសំរេច លេខ៤៤៩ រប ២០០២ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០២គឺឈប់ទទួលវិវាទដីណាដែលមិនមានប័ណ្ណកម្មសិទ្ធិ។ ការណ៍នេះមានន័យថា តុលាការផ្អែកលើមូលដ្ឋានបទបញ្ញា(ប្រកាសអន្តរក្រសួង)ជាជាងច្បាប់កំពូល។

ជាគោលការណ៍វិវាទដែលពាក់ព័ន្ធនឹងការផ្ទេរ និងប្រគល់សិទ្ធិលើដីធ្លី តាមរយៈលិខិតលក់ ដូរ ឱ្យឬជំរះមត៌ក ដើម្បីឱ្យមានសុពលភាពលុះត្រាតែ ធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូតធ្វើដោយអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី[៣៤៩]។ តាមផ្លូវច្បាប់កាលណាបើ លិខិតដែលបញ្ជាក់អំពីទំនាក់ទំនងសិទ្ធិ ឬបង្កើតសិទ្ធិមិនស្របច្បាប់នោះ ទំនាក់ទំនងនៃសិទ្ធិដែលមានជាមូលដ្ឋានលើលិខិតទាំងនោះមិនអាចមានអានុភាពគតិយុត្តបានឡើយ។

ករណីមួយចំនួនដែលជាទំនាស់លើដីមិនមានប័ណ្ណកម្មសិទ្ធិ បែរជាតុលាការលើកយកមកដោះស្រាយដោយច្នៃឱ្យទៅជារឿងក្តីព្រហ្មទណ្ឌ ហើយចេញដីកាកោះ ដីកាបង្គាប់ឱ្យចូលខ្លួន ឬចេញដីកាចាប់ខ្លួន ប្រជាពលរដ្ឋរងគ្រោះដោយមិនបានស៊ើបអង្កេតស្រាវជ្រាវឱ្យច្បាស់លាស់ថា តើអ្នកណាជាម្ចាស់លើដីនោះពិត ។ ក្នុងទំនាស់រវាងប្រជាពលរដ្ឋ និងភាគីជាឈ្មួញ ឬថៅកែក្រុមហ៊ុន តុលាការតែងតែលំអៀងទៅខាងឈ្មួញ[៣៥០]។ មានករណីខ្លះប្រជាពលរដ្ឋបានរស់នៅលើដីនោះជាច្រើនឆ្នាំស្រាប់តែក្រុមហ៊ុនចង់បានដី គេព័ទ្ធបិទប្រកចេញចូល នៅពេលមានការទាមទារឱ្យបើករបងត្រូវតុលាការ

---

[៣៤៨] ប្រកាសអន្តរក្រសួង លេខ០២ ប្រករ ០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពី *ការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី* ៖ប្រការ៤។

[៣៤៩] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី *ច្បាប់ភូមិបាល* ៖មាត្រា ៦៥ និងមាត្រា២៤៤។

[៣៥០] សមាគមអាដហុក: *ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៨* របាយការណ៍ប្រចាំឆ្នាំ លេខ៨ ឆ្នាំទី៨ ផ្សាយខែមករា ឆ្នាំ២០០៩ ភ្នំពេញ ទំព័រ៣៦។

ចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់គេទៅវិញ។ ការអនុវត្តច្បាប់មិនប្រក្រតីបែបនេះបានធ្វើឱ្យប៉ះពាល់ដល់កិត្យានុភាពរបស់ប្រព័ន្ធតុលាការក៏ដូចជារដ្ឋាភិបាលកម្ពុជា លើវិស័យគ្រប់គ្រងដីធ្លី។ នេះដោយសារតុលាការ និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត មិនទាន់យកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តភារកិច្ចលើចំណាត់ការ និង ដោះស្រាយរឿងក្តីដែលមានកម្មវត្ថុពាក់ព័ន្ធនឹងដីធ្លី ជាពិសេសដីភោគៈ ឬកម្មសិទ្ធិ។ ឃើញបញ្ហាទាំងនេះរាជរដ្ឋាភិបាល ជាពិសេស ក្រសួងយុត្តិធម៌បានចេញសារាចរណែនាំមួយដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព[៣៥១]។

តាមប្រការ៣ របស់ប្រកាសអន្តរក្រសួងនេះ បណ្តឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដែលជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ហើយត្រូវបានតុលាការគ្រប់ថ្នាក់ទទួល និង កំពុងចាត់ការមុនថ្ងៃចេញប្រកាសនេះ តុលាការត្រូវចាត់ការបន្តរហូតចប់សព្វគ្រប់ជាស្ថាពរ។ មានន័យថា ទោះបីពាក្យបណ្តឹងអំពីវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដី ឬបានចុះបញ្ជីសុរិយោដីក៏ដោយ ឱ្យតែបណ្តឹងនោះកំពុងស្ថិតនៅក្នុងចំណាត់ការរបស់តុលាការមុនពេលប្រកាសនេះដាក់ឱ្យអនុវត្ត តុលាការនៅតែមានសមត្ថកិច្ចដោះស្រាយរឿងវិវាទនេះរហូតដល់ចប់សព្វគ្រប់ជាស្ថាពរដដែល។

ទោះបីជាយ៉ាងណា ការអនុវត្តនៅតែមិនទាន់មានការឯកភាពគ្នានៅឡើយ ទាក់ទងការទទួលបណ្តឹងលើរឿងវិវាទដីធ្លី។ ជាគោលការណ៍ តុលាការជាអ្នកអនុវត្តច្បាប់ មិនមែនអនុវត្តបទបញ្ជាឡើយ បើតុលាការអនុវត្តតាមបទបញ្ជា(ប្រកាសអន្តរក្រសួង) ធ្វើឱ្យតុលាការបាត់បង់ឯករាជ្យភាពរបស់ខ្លួន។ ដើម្បីធានាបានការគោរពច្បាប់ជាធំ ផ្អែកតាមមាត្រា១៩ នៃច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ភាគីវិវាទដែលបណ្តឹងរបស់គេនៅតុលាការអាចប្តឹងអំពីធម្មនុញ្ញភាពនៃច្បាប់ ឬ សេចក្តីសម្រេចរបស់ស្ថាប័នរដ្ឋនានា ដែលប៉ះពាល់លើខ្លួនជូនតុលាការ។ បើមានភស្តុតាងគ្រប់គ្រាន់តុលាការអាចលើកករណីនេះ ទៅតុលាការកំពូលក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរ។ ក្នុងរយៈពេល១៥ថ្ងៃ តុលាការកំពូលត្រូវបញ្ជូនសំណុំរឿងទៅក្រុមប្រឹក្សាធម្មនុញ្ញ[៣៥២]។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវធានានូវច្បាប់ និង សេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញដាច់ខាត[៣៥៣]។ ក្នុងរឿងក្តីប្រភេទនេះ តុលាការផ្ទាល់អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ចំណែកគូភាគីនៃរឿងក្តីអាចសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ និង សេចក្តីសម្រេចរបស់ស្ថាប័ន។

---

[៣៥១] សារាចរ លេខ ០១ សយ សរនន ០៧ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពី ***ចំណាត់ការ និងនីតិវិធីនៃការដោះស្រាយរឿងក្តីដែលមានពាក់ព័ន្ធនិងដីរដ្ឋ។***

[៣៥២] ព្រះរាជក្រម លេខ ជស រកម ០៤៩៨ ០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ នៃច្បាប់ស្តីពី ***ការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ*** ៖ មាត្រា១៩។

[៣៥៣] ***រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា*** ចុះថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩៩ ៖ មាត្រា១៥០ថ្មី និង ព្រះរាជក្រម លេខ ជស រកម ០៤៩៨ ០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ នៃច្បាប់ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ៖ មាត្រា១៩។

ជម្រើសមួយទៀត ករណីមានបណ្ដឹងពីភាគីលើភាពស្របច្បាប់នៃលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ដូចជាព្រះរាជក្រឹត្យ អនុក្រឹត្យ បទបញ្ជា ប្រកាស សារាចរ សេចក្ដីសម្រេច តុលាការ មានសិទ្ធិសម្រេចអាចលុបចោលលិខិតគតិយុត្តទាំងនោះ។ មានភាពស្មុគស្មាញរវាងស្ថាប័ននីតិប្រតិបត្តិ និង ស្ថាប័នតុលាការ ជួនកាលមន្ត្រីតុលាការមួយចំនួន មានតួនាទីនៅរដ្ឋាភិបាលក្នុងឋានៈជាទីប្រឹក្សារាជរដ្ឋាភិបាលជាដើម [៣៥៤]។

## ៣.២.៣ បញ្ហាផ្លូវច្បាប់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ

ក្នុងចំណោមគណៈកម្មការសុរិយោដីទាំងបីថ្នាក់ ដោយឡែកគណៈកម្មការសុរិយោដីថ្នាក់ជាតិមានសមត្ថកិច្ចដោះស្រាយវិវាទដីធ្លីដោយមានអំណាចចេញសេចក្ដីសម្រេច[៣៥៥]។ ហើយដែលសេចក្ដីសម្រេចនេះ អាចត្រូវបានក្លាយជាកម្មវត្ថុនៃការប្ដឹងទាស់ទៅតុលាការក្នុងរយៈពេល៣០ថ្ងៃ។ ប្រសិនបើគ្មានបណ្ដឹងក្នុងរយៈពេលកំណត់នេះទេ សេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវចាត់ទុកជាស្ថាពរ[៣៥៦]។

នៅពេលអនុវត្តនីតិវិធីនេះចប់សព្វគ្រប់ហើយប័ណ្ណកម្មសិទ្ធិកាន់កាប់អចលនវត្ថុនឹងត្រូវប្រគល់ជូនភាគីដោយរដ្ឋបាលសុរិយោដី ហើយតុលាការមិនអាចប្រកែកក្នុងការបង្គាប់ឱ្យភាគីម្ខាងទៀត ចាកចេញដើម្បីជាប្រយោជន៍ដល់ភាគីដែលបានបង្ហាញប័ណ្ណត្រឹមត្រូវ និង ពេញលេញចេញដោយរដ្ឋបាលខាងលើនេះទេ។ ក្នុងករណីនេះ សេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិក្លាយជាសេចក្ដីសម្រេចចុងក្រោយបិទផ្លូវតវ៉ា និង តុលាការមិនអាចជំទាស់ទៅនឹងសេចក្ដីសម្រេចដែលចូលជាស្ថាពររបស់គណៈកម្មការសុរិយោដីបានទេ ហើយការមិនគោរពតាមសេចក្ដីសម្រេចនេះដោយភាគីត្រូវជាកម្មវត្ថុនៃការប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំឱ្យអនុវត្ត។ មានតែអាជ្ញាធរមានសមត្ថកិច្ចក្នុងនាមរដ្ឋ និងនីតិបុគ្គលសាធារណៈប៉ុណ្ណោះ ដែលអាចបង្ខំឱ្យអ្នកកាន់កាប់អចលនវត្ថុគ្មានប័ណ្ណ ឬមានប័ណ្ណមិនគ្រប់គ្រាន់នោះចាកចេញពីទីតាំងអចលនវត្ថុនោះ[៣៥៧]។ ដូចនេះ សេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ក្រោយពីបានចូលជាស្ថាពរ មានអានុភាពបង្ខំឱ្យអនុវត្តដោយកម្លាំងសាធារណៈដែលសេចក្ដីសម្រេចនេះគ្មានអ្វីខុសពីសេចក្ដីសម្រេចរបស់តុលាការឡើយ។ គេអាចនិយាយបានថា គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហាក់ធ្វើការដោះស្រាយវិវាទដីធ្លីដោយប្រើប្រាស់អំណាចតុលាការ។

---

[៣៥៤] ព្រះរាជក្រឹត្យ លេខ នស រកត ០៥០៩ ៥៧១ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ស្ដីពី *ការតែងតាំងឯកឧត្តម ជីវ កេង* ជាទីប្រឹក្សាប្រធានក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្ដីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន។

[៣៥៥] អនុក្រឹត្យ លេខ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពី *ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី* ៖មាត្រា២០។

[៣៥៦] អនុក្រឹត្យ លេខ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពី *ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី* ៖មាត្រា២៣។

[៣៥៧] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្ដីពី *ច្បាប់ភូមិបាល* ៖មាត្រា ៣៥។

បើយើងប្រៀបធៀបសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលវិញ ទោះបីជាចូលជាស្ថាពរហើយក៏ដោយ ក៏សេចក្តីសម្រេចនេះពុំទាន់មានអានុភាពអនុវត្តដោយបង្ខំបានដែរ នៅពេលដែលមានការជំទាស់ពីភាគីណាមួយក្នុងការអនុវត្តសេចក្តីសម្រេចស្ថាពរនេះ[៣៥៨] មានន័យថា ដើម្បីឱ្យសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអានុភាពបង្ខំឱ្យអនុវត្ត លុះត្រាតែមានពាក្យបណ្តឹងទៅតុលាការដើម្បីបង្គាប់ឱ្យភាគីអនុវត្ត[៣៥៩]។ នេះបញ្ជាក់ឱ្យឃើញថា ថ្វីត្បិតតែក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទ ដោយចេញសេចក្តីសម្រេចដូចគណៈកម្មការសុរិយោដីថ្នាក់ជាតិក៏ដោយ ក៏ក្រុមប្រឹក្សានេះគ្មានអំណាចតុលាការ ដូចគណៈកម្មការសុរិយោដីថ្នាក់ជាតិ លើសេចក្តីសម្រេចអាចបង្ខំឱ្យអនុវត្តដោយមិនចាំបាច់សុំសេចក្តីបង្គាប់ពីតុលាការដែរ។

ផ្អែកលើមាត្រា១៣០ថ្មី (មាត្រា១១១ចាស់) នៃរដ្ឋធម្មនុញ្ញចែងថា " គ្មានអង្គការណាមួយនៃអំណាចនីតិប្រតិបត្តិ ឬនីតិបញ្ញត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ "។ ដោយសារតែគណៈកម្មការសុរិយោដីថ្នាក់ជាតិស្ថិតក្រោមចំណុះរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដូចនេះគណៈកម្មការនេះគឺជាអង្គការមួយនៃអំណាចនីតិប្រតិបត្តិ។ តាមការបញ្ជាក់ខាងលើយើងឃើញថា គណៈកម្មការនេះអាចប្រើប្រាស់អំណាចតុលាការបានយ៉ាងពេញលេញ[៣៦០]។ នៅក្នុងការដោះស្រាយវិវាទដីធ្លី យើងអាចនិយាយបានថា ជាការរំលោភបំពានទៅលើគោលការណ៍នៃការបែងចែកអំណាចដែលធានាដោយរដ្ឋធម្មនុញ្ញ ។

ការដោះស្រាយវិវាទដីធ្លីនានាដោយតុលាការ ធានាបាននូវការគោរពគោលការណ៍នៃការបែងចែកអំណាចនៅកម្ពុជា។ ច្បាប់កំពូលផ្តល់សមត្ថកិច្ចផ្តាច់មុខឱ្យចៅក្រមក្នុងការជំនុំជំរះក្តី[៣៦១]។ លើសពីនេះទៅទៀត អំណាចតុលាការធានារក្សាអនាគតិ និង ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ ប៉ុន្តែនីតិវិធីនៃការដោះស្រាយវិវាទដោយតុលាការមានលក្ខណៈស្មុគស្មាញ ធ្វើឱ្យចំណាយពេលវេលានិងប្រាក់ច្រើន។

ការផ្តល់សមត្ថកិច្ចឱ្យគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដោះស្រាយវិវាទដីធ្លីដោយប្រើអំណាចតុលាការ ជាការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់គោលការណ៍នៃការបែងចែកអំណាចក៏ពិតមែន ក៏ប៉ុន្តែគោលបំណងនៃការផ្តល់អំណាចនេះ គឺគ្រាន់តែចង់សម្រាលបន្ទុករបស់តុលាការក្នុងការដោះស្រាយវិវាទនិង ធានាឱ្យនីតិវិធីនៃការដោះស្រាយប្រព្រឹត្តទៅបានឆាប់រហ័ស និងងាយស្រួលតែប៉ុណ្ណោះ។ នេះ

---

[៣៥៨] Daniel Adler et all: *ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងដំណើរការដោះស្រាយវិវាទការងារនៅកម្ពុជា* ច្បាប់និងសេចក្តីអត្ថាធិប្បាយ បោះពុម្ពផ្សាយលើកទី២ លេខ ISBN: 978-99950-74-05-0, មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ឆ្នាំ២០០៧ ទំព័រ៣៥។

[៣៥៩] ប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពី *ក្រុមប្រឹក្សាអាជ្ញាកណ្តាល* ៖ ប្រការ៤៦។

[៣៦០] អនុក្រឹត្យ លេខ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី *ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី* ៖ មាត្រា២៣។

[៣៦១] *រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា* ចុះថ្ងៃទី០៦ ខែមិនា ឆ្នាំ១៩៩៩ ៖ មាត្រា១២៩ ថ្មី (១១០ ចាស់)។

ដោយសារថា ការដោះស្រាយវិវាទដីធ្លីទាមទារឱ្យមានអ្នកជំនាញច្បាស់លាស់ ហើយក្នុងន័យនេះ មានតែមន្ត្រីសុរិយោដីទេ ដែលមានជំនាញទាំងនេះ។ តែផ្ទុយទៅវិញ នីតិវិធីនេះបែរជាយឺតយ៉ាវទៅវិញ ដោយហេតុថា សេចក្តីសម្រេចរបស់គណៈកម្មការនេះ នៅតែអាចធ្វើជាកម្មវត្ថុនៃការសើរើនៅចំពោះមុខតុលាការដដែលក្នុងរយៈពេល៣០ថ្ងៃ[៣៦២]។

ផ្អែកលើការវិភាគខាងលើជម្រើសទាំងតុលាការ និង គណៈកម្មការសុរិយោដីថ្នាក់ជាតិ សុទ្ធតែមានគុណវិបត្តិដូចៗគ្នា។ ពិតជាមានជម្រើសដែលគ្មានគុណវិបត្តិ ជម្រើសទាំងនេះអាចបញ្ចៀសបាននូវភាពមិនស៊ីចង្វាក់គ្នានៃច្បាប់។ ដោយយកគំរូតាមការដោះស្រាយវិវាទការងារ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល គណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចធ្វើការដោះស្រាយវិវាទដីធ្លីដោយមិនប៉ះពាល់ដល់អំណាចតុលាការពោលគឺ ធានាបាននូវការគោរពគោលការណ៍នៃការបែងចែកអំណាច។ នេះជាមធ្យោបាយមួយដែលឱ្យគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដំណើរការបានស្របទៅតាមរដ្ឋធម្មនុញ្ញក្នុងការដោះស្រាយវិវាទដីធ្លីដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន។

## ៣.២.៤ ការវិភាគលើការដោះស្រាយ

### កត្តារចនាសម្ព័ន្ធ

គណៈកម្មការសុរិយោដីត្រូវរដ្ឋាភិបាលកែសម្រួលឡើងវិញ ដើម្បីដាក់ឱ្យអភិបាលស្រុកជាប្រធានជំនួសប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងភូមិបាលស្រុក ខណ្ឌ។ ការកែសម្រួលនេះ ក្រោយពីទទួលបានអនុសាន៍របស់នាយករដ្ឋមន្ត្រី នៅក្នុងមហាសន្និបាតរបស់ក្រសួងរៀបចំដែនដី នគរូប នីយកម្ម និងសំណង់នៅឆ្នាំ២០០៦។ ដំណាលគ្នាជាមួយនឹងការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ការអនុវត្តជាក់ស្តែង របៀបធ្វើការងាររបស់គណៈកម្មការសុរិយោដីទាំងបីថ្នាក់ និងការទទួលខុសត្រូវពុំទាន់ស៊ីចង្វាក់គ្នា ទំនាក់ទំនងការងារពុំបានល្អ ដោយសាររចនាសម្ព័ន្ធការងារមិនសូវច្បាស់លាស់។ ដូចជាគណៈកម្មការសុរិយោដីស្រុកខណ្ឌបានធ្វើការសម្រុះសម្រួលករណីមួយមិនបានដល់ការព្រមព្រៀង រួចបានបញ្ជូនករណីនោះទៅគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ។ គណៈកម្មការសុរិយោដីរាជធានី ខេត្ត សម្រុះសម្រួលមិនបានសម្រេចក៏បញ្ជូនសំណុំរឿងនោះឱ្យគណៈកម្មការសុរិយោដីស្រុក ខណ្ឌ វិញដើម្បីសម្រុះសម្រួល និងករណីខ្លះគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត បានបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិៗបង្វិលទៅខេត្តវិញ។ ការបញ្ជូនសំណុំរឿងចុះឡើងៗ យ៉ាងនេះធ្វើឱ្យមានការយឺតយ៉ាវ និង មិនអាចដោះស្រាយវិវាទដីធ្លីបានឡើយ។ ជាក់ស្តែងដូចជា នៅក្នុងករណីសិក្សានៃវិវាទដីធ្លីមួយ នៅស្រុកកំពុងរោទិ៍ ខេត្តស្វាយរៀង ភាគីដើមបណ្តឹងបានលើកឡើងថា៖

[៣៦២] អនុក្រឹត្យ លេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ***ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*** ៖មាត្រា២៣។

> ...ខ្ញុំដាក់ពាក្យប្តឹងនៅស្រុក តែស្រុកមិនដោះស្រាយឱ្យ។ ដូច្នេះខ្ញុំយកពាក្យបណ្តឹងទៅដាក់នៅសុរិយោដីខេត្ត ហើយខេត្តបញ្ជូនរឿងមកសុរិយោដីថ្នាក់ស្រុកវិញ ដោយដឹងថាស្រុកនឹងរកយុត្តិធម៌ឱ្យ...។ មានរកឯណានៅតែដដែល។

ការរុញចុះឡើងនៃករណីវិវាទនេះ គឺដើម្បីជៀសវាងការប្រឈមរវាងគណៈកម្មការសុរិយោដី និងភាគីវិវាទដែលជាប់ពាក់ព័ន្ធជាមួយអាជ្ញាធរមានឋានៈខ្ពស់ ឬអ្នកដែលមានខ្នងបង្អែកជាថ្នាក់ដឹកនាំដែលមានឋានៈខ្ពស់។ ប្រសិនបើ គណៈកម្មការហានសម្រេចលើវិវាទ គេខ្លាចបាត់បង់មុខតំណែង និងម្យ៉ាងភាគីវិវាទ មានឥទ្ធិពលខ្លាំងជាងអ្នកដោះស្រាយ។ បញ្ហានេះ ធ្វើឱ្យគណៈកម្មការសុរិយោដីបាត់បង់នូវភាពម្ចាស់ការ និងវិជ្ជាជីវៈរបស់ខ្លួន។ រដ្ឋាភិបាលយល់ច្បាស់បញ្ហានេះក៏បានបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដើម្បីបំពេញបន្ថែមលើមុខងាររបស់គណៈកម្មការសុរិយោដី។ តាមរយៈព្រះរាជក្រឹត្យបានផ្តល់ដល់អាជ្ញាធរនេះ ក្នុងការទទួលសំណុំរឿងទំនាស់ដីធ្លី ដែលហួសពីសមត្ថកិច្ចគណៈកម្មការសុរិយោដីជាតិ និងទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធនឹងទំនាស់ដីធ្លី ព្រមទាំងជាអ្នកឃ្លាំមើលការដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដី និង អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់[៣៦៣]។ ប៉ុន្តែ ជាក់ស្តែងមិនមានវិវាទដីធ្លីណាមួយដែលហួសពីសមត្ថកិច្ចគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងតុលាការនោះទេ។ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមិនមានវិធាន ឬនីតិវិធីដើម្បីដោះស្រាយទំនាស់ឱ្យបានច្បាស់លាស់នោះទេ។ ការដោះស្រាយធ្វើឡើងដោយផ្អែកទៅតាមច្បាប់ដែលមានជាធរមាន ដូចជាច្បាប់ភូមិបាល ច្បាប់ព្រៃឈើ ច្បាប់ជលផល ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និង ច្បាប់នានាជាច្រើនទៀត។

រចនាសម្ព័ន្ធរបស់អាជ្ញាធរមានសមាសភាពមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាល រួមទាំងមន្ត្រីជាន់ខ្ពស់នៃនគរបាលជាតិ និងយោធាដែលប្រវត្តិ និងមុខតំណែងរបស់មន្ត្រីជាន់ខ្ពស់ទាំងនោះ មិនសមនឹងតួនាទីដ៏ធំដែលធ្វើលើរឿងដ៏រសើបបែបនេះទេ ជាពិសេស ទាក់ទងលើរឿងរំលោភយកដីធ្លីធំៗ ដែលមន្ត្រីយោធាពាក់ព័ន្ធ។ ក្នុងចំណោមសមាសភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ចំនួន២២រូប មាន៧រូប ជាតំណាងស្ថាប័នយោធា និងនគរបាល[៣៦៤]។ ផ្អែកតាមរចនាសម្ព័ន្ធនេះឃើញថាអាជ្ញាធរនេះមានអំណាចខ្លាំងក្នុងការដោះស្រាយវិវាទធំៗបានប្រកបដោយជោគជ័យ តែផ្ទុយទៅវិញវិវាទដីធ្លី ធំៗដែលមានលក្ខណៈរសើបទាំងនោះកាន់តែកើនឡើងច្រើនថែមទៀត។ តាមរបាយការណ៍អង្គការសិទ្ធិមនុស្សមិនមែនរដ្ឋាភិបាលឆ្នាំ២០០៨ មានប្រជាពលរដ្ឋច្រើនជាង៣៥០០ គ្រួសារជាប់

---

[៣៦៣] ព្រះរាជក្រឹត្យ លេខ នស.រកត ០២០៦ ០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពី ***ការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*** ៖មាត្រា៣។

[៣៦៤] អនុក្រឹត្យ លេខ ១១៤៦ អនក្រ.តត ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ ស្តីពី ***ការតែងតាំងសមាសភាពអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*** មាត្រា១ និងមាត្រា១ នៃព្រះរាជក្រឹត្យ លេខ នស.រកត ១០០៨ ១១០៦ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ ស្តីពី វិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស រកត ០២០៦ ០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

ពាក់ព័ន្ធ នឹងវិវាទដីធ្លីដែលមានមន្ត្រីយោធា និង នគរបាលជាប់ពាក់ព័ន្ធ[៣៦៥]។ អាជ្ញាធរជាតិត្រូវបានរិះគន់ដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅមុនការបោះឆ្នោតសកល នៅខែកក្កដា ឆ្នាំ ២០០៨ ថាការដោះស្រាយវិវាទដីធ្លីរបស់អាជ្ញាធរនេះមិនមានប្រសិទ្ធភាព[៣៦៦]។

**កត្តាធនធានមនុស្ស**

នៅថ្នាក់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ បច្ចុប្បន្នមានមន្ត្រីក្របខណ្ឌរាជការសរុបចំនួន២.៤៥៤ នាក់ ក្នុងនោះមាននារី ចំនួន៣១៤ នាក់ (ស្មើនឹង១៣ភាគរយ)[៣៦៧]។ ការងារកសាងធនធានមនុស្សក្នុងឆ្នាំកន្លងមក តាមកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ឆ្លើយតបនឹងគោលនយោបាយរាជរដ្ឋាភិបាលស្តីពី ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មន្ត្រីជំនាញជាច្រើនត្រូវបានទទួលការបំប៉ន ជាពិសេស ជំនាញផ្នែកការងារដោះស្រាយទំនាស់ដីធ្លីក្រៅប្រព័ន្ធតុលាការផងដែរ។ ជាលទ្ធផលគិតមកត្រឹម ខែមេសាឆ្នាំ២០១០ មានមន្ត្រីទទួលបន្ទុកដោះស្រាយវិវាទដីធ្លីចំនួន ២៦៩៧ នាក់ ត្រូវបានទទួលការបណ្តុះបណ្តាលលើការអភិវឌ្ឍធនធានមនុស្ស មិនត្រឹមតែពង្រឹងសមត្ថភាពផ្ទៃក្នុងមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ប៉ុណ្ណោះទេ តែថែមទាំងបានជួយដល់ផ្នែកជំនាញពាក់ព័ន្ធផ្សេងទៀត ពិសេសបានជួយគាំទ្រដល់ថ្នាក់ក្រោមជាតិ ទាំងផ្នែកច្បាប់ ទាំងផ្នែកបច្ចេកទេសស្របតាមគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការរបស់រាជរដ្ឋាភិបាល[៣៦៨]។

តាមការអធិប្បាយខាងលើ គណៈកម្មការសុរិយោដីហាក់ដូចជាមានសមត្ថភាព និងធនធានមនុស្សគ្រប់គ្រាន់ តែទោះបីជាយ៉ាងណា សមត្ថភាពរបស់គណៈកម្មការសុរិយោដីពុំទាន់បានពង្រឹងគ្រប់គ្រាន់ ជាពិសេសនៅថ្នាក់ស្រុក ក្រុង និងខេត្ត រាជធានី ទាក់ទងទៅនឹងនីតិវិធីបច្ចេកទេស និងជំនាញដោះស្រាយដោយការសម្រុះសម្រួល។ មន្ត្រីដែលមានតីតភាពយូរហើយមានសមត្ថភាពត្រូវបានចូលនិវត្តន៍។ មន្ត្រីរបស់គណៈកម្មការសុរិយោដីមានចំនួនតិចតួច ហើយមានភារកិច្ចស្នូលច្រើនដូចជាការងាររៀបចំដែនដី ការចុះបញ្ជីសុរិយោដី ការងារសំណង់ និងការងារភូមិសាស្ត្រ។ លើសពីនេះ

---

[៣៦៥] គណៈកម្មាធិការប្រព្រឹត្តកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជាៈ ***កំពុងបាត់បង់ដី ការបណ្តេញចេញដោយ បង្ខំ និងការគំរាមគំហែងនៅកម្ពុជា*** ភ្នំពេញ ឆ្នាំ២០០៩ ទំព័រ៧១ ក្នុងកាសែតភ្នំពេញប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ ចំណងជើងថាៈ ឆ្នាំនេះប្រជាពលរដ្ឋ ៣៥០០ គ្រួសារ បានរងផលប៉ះពាល់ដោយសារការរំលោភយកដីធ្លី ដោយសារកងទ័ព។

[៣៦៦] -ដ- ទំព័រ៧១។

[៣៦៧] បែងចែកនៅថ្នាក់កណ្តាល ចំនួន ៦៦៩ នាក់ (ក្នុងនោះមាននារី ១២៣ នាក់) នៅរាជធានីខេត្ត ១.៧៨៥ នាក់ (ក្នុងនោះមាននារី ១៩១ នាក់)។ កម្រិតវប្បធម៌ និងជំនាញមានថ្នាក់បណ្ឌិតចំនួន ១៥ នាក់ (នារី ១ នាក់) ថ្នាក់អនុបណ្ឌិត ១០៤ នាក់ (នារី ៦ នាក់) ថ្នាក់វិស្វករ ៣០៩ នាក់ (នារី ១៦ នាក់) ស្ថាបត្យករ ១៩៨ នាក់ (នារី ១៧ នាក់) ថ្នាក់បរិញ្ញាបត្រ ៧៧ នាក់ (នារី ១៣ នាក់) ថ្នាក់មធ្យម និងក្រោមមធ្យម ៥១២ នាក់ (នារី ២៩ នាក់) ចំណេះទូទៅ និងជំនាញផ្សេងៗ ១.២៣៩ នាក់ (នារី ២៣៣ នាក់។

[៣៦៨] Sovann Sar: ***Land Reform in Cambodia*** <http://webcache.googleusercontent.com/search?q=cache:7G3CF5z9laMJ:www.fig.net/pub/fig2010/ paper/ts07j%255Cts07j_sovann_4633.pdf+land+legislative+dispute+in+cambodia&cd=11&hl=eg&ct=clnk> accessed on May10, 2010.

ទៀតមានករណីវិវាទដីធ្លីបានបញ្ជូនមកពីតុលាការ ជាវិវាទដែលប្រជាពលរដ្ឋប្ដឹងទៅអាជ្ញាធរខេត្តនិងស្ថាប័នពាក់ព័ន្ធជាច្រើន ដែលជំរុញឱ្យមន្ត្រីត្រូវបញ្ជូនទៅចូលរួមដោះស្រាយ[៣៦៩]។ ដោយសារកិច្ចខិតខំប្រឹងប្រែងនេះហើយ ទើបគណៈកម្មការសុរិយោដី ត្រូវបានលើកសរសើរពីសំណាក់នាយករដ្ឋមន្ត្រីមានប្រសាសន៍ថា៖

"គណៈកម្មការសុរិយោដីបានអនុវត្តការងារយ៉ាងសកម្មកន្លងមក និងបានរួមចំណែកជួយសម្រាលបន្ទុកផ្នែករដ្ឋបាលនិងតុលាការបានមួយចំណែកធំ។ តែទោះបីយ៉ាងណាយន្តការនេះនៅពុំទាន់មានលទ្ធភាពដោះស្រាយគ្រប់ទំនាស់នោះទេ ពិសេសការដោះស្រាយករណីវិវាទពាក់ព័ន្ធនឹងអ្នកមានអំណាច"[៣៧០]។

កង្វះខាតបុគ្គលិកនេះ ដោយសារកិច្ចការមិនត្រឹមដោះស្រាយវិវាទដីធ្លី ថែមទាំងមានការងារផ្សេងក្នុងការិយាល័យដែលមន្ត្រីសុរិយោដី ក៏ត្រូវបំពេញភារកិច្ចតាមការស្នើពីអភិបាលស្រុក។ ប្រឈមនឹងកិច្ចការជាច្រើនបែបនេះ ការបំពេញការងារដោះស្រាយវិវាទដីធ្លីមិនទាន់ឆ្លើយតបឱ្យទាន់ពេលវេលាទៅនឹងករណីវិវាទដែលបាននឹងកំពុងកើនឡើង។ ម្យ៉ាងទៀត ដោយខ្វះថវិកាក្នុងគម្រោងដោះស្រាយវិវាទដីធ្លី ញាំងឱ្យបុគ្គលិកទៅបំពេញភារកិច្ចថ្មីមួយទៀត ដែលមានថវិកាច្រើនជាង ជាពិសេសការងារចុះបញ្ជីដីធ្លី។ ទោះបីជាក្រសួងត្រូវការធនធានមនុស្សជាការចាំបាច់សម្រាប់បំពេញកង្វះខាតហើយក៏ដោយ តែរាជរដ្ឋាភិបាលកម្ពុជាកំពុងជួបនូវបញ្ហាប្រឈមផ្នែកថវិកា ម្លោះហើយការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីត្រូវផ្អាក[៣៧១]។ លើសពីនេះ មន្ត្រីក្រសួងត្រូវបង្កកការតម្លើង ឋានន្តរស័ក្តិ ដំឡើងថ្នាក់ និងប្រាក់បំណាច់មុខងារតាមតីតភាពការងាររយៈពេលមួយឆ្នាំក្នុងឆ្នាំ២០១០ និង ២០១១។ ការអនុវត្តកន្សោមអាទិភាពក៏ត្រូវបានបង្កកផងដែរ និងប្រាក់លាភការបន្ថែមសម្រាប់ឆ្នាំ២០១០ និង២០១១។

ស្រដៀងគ្នានេះដែរ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីក៏មិនមានបុគ្គលិកគ្រប់គ្រាន់ដោយសារមន្ត្រីដែលបម្រើការនៅក្នុងនាយកដ្ឋាននីមួយៗមានចំនួនតិច មិនទាន់ឆ្លើយតបទៅនឹងទំហំនៃការងារបច្ចុប្បន្ន។ ទន្ទឹមនេះអាជ្ញាធរមានតែមួយថ្នាក់ដែលទីតាំងនៅភ្នំពេញ ហើយមានភារកិច្ចដោះស្រាយវិវាទនៅទូទាំងប្រទេស។ ឃើញថា សមត្ថកិច្ចរបស់អាជ្ញាធរមានទំហំធំទូលំទូលាយពេក ធ្វើឱ្យវិវាទមួយចំនួនត្រូវបញ្ជូនទៅសមត្ថកិច្ចផ្សេងដើម្បីបន្តដោះស្រាយ ក្នុងនោះវិវាទមួយចំនួនបង្វែរទៅឱ្យ គណៈកម្មការសុរិយោដី។ ការណ៍នេះ រឹតតែធ្វើឱ្យមានការស្មុគស្មាញដល់ភាគីវិវាទ ជាពិសេសប្រជាពលរដ្ឋ

---

[៣៦៩] លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិៈ *របាយការណ៍ ស្ដីពី សកម្មភាពការងាររបស់គណៈកម្មការ សុរិយោដី* ប្រចាំឆ្នាំ២០០៩ ទំព័រ ៥។

[៣៧០] ហ៊ុន សែនៈ *សុន្ទរកថាថ្លែងនៅក្នុងវេទិកាដីធ្លីថ្នាក់ជាតិនៅវិមានរដ្ឋាភិបាល ភ្នំពេញ* ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ទំព័រ៥។

[៣៧១] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ៈ លេខ ០៣៧ ជនស ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ស្ដីពី *ការពង្រឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល* -យោងៈ សេចក្ដីជូនដំណឹងលេខ ១៤៣៧ សជណ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

ក្រីក្រ ទីបំផុតរកបានស្ថាប័នយុត្តិធម៌មួយបានហើយ ស្រាប់តែរត់ទៅតាមសំណុំរឿងរបស់ខ្លួននៅស្ថាប័នផ្សេងទៅវិញ។

**កត្តាព័ត៌មាន**

ការផ្សព្វផ្សាយអំពីតួនាទី ភារកិច្ច នីតិវិធីរបស់គណៈកម្មការសុរិយោដី និងសិទ្ធិផ្សេងៗទៅដល់ប្រជាពលរដ្ឋ ជាពិសេសគូភាគីវិវាទនៅពុំទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយ។ ការផ្សព្វផ្សាយនេះជាកត្តាសំខាន់ក្នុងការជំរុញ ក៏ដូចជាការលើកទឹកចិត្តឱ្យភាគីវិវាទចូលរួមក្នុងដំណើរការដោះស្រាយវិវាទដោយការសម្រុះសម្រួល។ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីបានផ្សព្វផ្សាយដោយផ្ទាល់តែទៅលើអ្នកមានតួនាទី ក្នុងការដោះស្រាយវិវាទដែលជាសរុបនៅទូទាំងប្រទេសក្នុងឆ្នាំ២០០៩ មានចំនួន ១២៧០ នាក់ ក្នុងនោះមាន១១៦ នាក់ជានារី[៣៧២]។ មានការផ្សាយនៅតាមសារព័ត៌មាននៅក្នុងស្រុកស្ទើរគ្រប់លេខ ចុះតែអំពីករណីវិវាទដីធ្លីតែប៉ុណ្ណោះ ប្រជាពលរដ្ឋគ្រាន់តែឮតែមិនដឹងពីវិធីដោះស្រាយ។

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានបេសកម្ម តួនាទី ភារកិច្ចក្នុងការទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លីតាមរយៈការអប់រំផ្សព្វផ្សាយ ឱ្យសាធារណៈជនយល់ដឹងអំពីផលវិបាកបណ្តាលមកពីទំនាស់ដីធ្លី។ ជាក់ស្តែងក្នុងឆ្នាំ២០០៩ មានការចុះបើកវគ្គអប់រំផ្សព្វផ្សាយទប់ស្កាត់ និង បង្ការបញ្ហាទំនាស់ដីធ្លីនៅរាជធានី ខេត្តទាំង២៤។ ការបើកវគ្គអប់រំផ្សព្វផ្សាយក្រោមការធ្វើបទឧទ្ទេសនាម កម្មវិធីសំណួរ-ចម្លើយ និង អនុសាសន៍ល្អរបស់ប្រធានអាជ្ញាធរជាតិ ទៅដល់គ្រប់ស្ថាប័នពាក់ព័ន្ធព្រមទាំងចែកសៀវភៅពីរប្រភេទដែលប្រភេទ(ទី១) កម្រងសំណួរ-ចម្លើយ ដែលពាក់ព័ន្ធនឹងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មការសុរិយោដី ចំណែកប្រភេទ(ទី២) ការស្វែងយល់ពីទោសប្បញ្ញត្តិ ស្តីពីបទល្មើសពាក់ព័ន្ធនឹងច្បាប់ភូមិបាល ច្បាប់ព្រៃឈើ ច្បាប់ជលផល និង ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ។ ការចែកផ្សាយឯកសារទាំងពីរនេះសរុបទាំងអស់ចំនួន ៨៧.៧៤៨ ក្បាល ជូនដល់អភិបាលរាជធានី ខេត្ត អភិបាលក្រុង ស្រុក ខណ្ឌនីមួយៗ ដើម្បីផ្សព្វផ្សាយបន្តជូនទៅអង្គភាពវិញ។ ដោយឡែក អាជ្ញាធរជាតិក៏បានបែងចែកសៀវភៅ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិជូនក្រសួង មន្ទីរ ស្ថាប័នពាក់ព័ន្ធ ជាពិសេស តំណាងក្រសួងបរិស្ថានដែលមានចំនួនសរុបចំនួន ៥០០ ក្បាល។

ជារួមយើងអាចនិយាយបានថា ភាគច្រើនកិច្ចការនេះធ្វើឡើងសម្រាប់តែមន្ត្រីជំនាញ និងមន្ត្រីមានសមត្ថកិច្ចក្នុងការដោះស្រាយទំនាស់តែប៉ុណ្ណោះ គឺមិនបានធ្វើឱ្យបានទូលំទូលាយដល់សាធារណៈជនដើម្បីបានយល់ដឹងច្បាស់លាស់ឡើយ។ ទោះបីជាមានការយល់ដឹងដូចគ្នាជាទូទៅថាការផ្សព្វផ្សាយទប់ស្កាត់ បង្ការទុកជាមុនគឺវាជាការសំខាន់ក៏ដោយ តែអាជ្ញាធរនៅតែមានកង្វះខាតក្នុងវិស័យនេះ។ ដោយឡែកសារព័ត៌មាន ដែលជាឧបករណ៍មួយសំខាន់សម្រាប់រាយការណ៍អំពីផលប៉ះពាល់នៃវិវាទដីធ្លីដល់សាធារណៈជន បែជាអ្នកសារព័ត៌មានមួយចំនួនមានភាពលំអៀងទៅភាគីម្ខាង ឬអ្នកដែលរំលោភ

---

[៣៧២] លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ: ***របាយការណ៍ ស្តីពី សកម្មភាពការងាររបស់គណៈកម្មការសុរិយោដីប្រចាំឆ្នាំ២០០៩*** ៖ ទំព័រ ៥។

ដីធ្លីទៅវិញ។ នៅកម្ពុជាគេដឹងជាទូទៅថា សារព័ត៌មានភាគច្រើនមិនសូវគោរពតាមក្រមសីលធម៌វិជ្ជាជីវៈជាអ្នកសារព័ត៌មាន ជាពិសេស សារព័ត៌មានផ្សាយជាភាសាខ្មែរ។ តែទោះបីជាយ៉ាងណា រវាងភាគីទំនាស់ដីធ្លីជាមួយនឹងអ្នកសារព័ត៌មានវាអាចជាមិត្ត និងសត្រូវនឹងគ្នាដែលភាគីមានការប្រុងប្រយ័ត្នក្នុងការធ្វើការជាមួយពួកគេ។ ជួនកាលតាមរយៈការផ្សាយតាមអត្ថបទសារព័ត៌មានធ្វើឱ្យភាគីជនងាយរងគ្រោះធ្លាក់ក្នុងសភាពគ្រោះថ្នាក់ថែមទៀត។ កង្វះឯករាជ្យភាព និង វិជ្ជាជីវៈធ្វើឱ្យវិស័យសារព័ត៌មានជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ និង ដែលធ្វើឱ្យអ្នកយកព័ត៌មានរស់បានដោយសារសំណូកជាជាងប្រាក់ខែ។ សាច់រឿងដែលសំខាន់មួយចំនួន ត្រូវផ្សាយឬ មិនផ្សាយផ្អែកទៅលើការបង់ ឬ មិនបង់ប្រាក់។

**កត្តាអន្តរាគមន៍**

ករណីវិវាទដីធ្លីមួយចំនួន មានការលំបាកក្នុងការដោះស្រាយនៅពេលដែលវិវាទនោះពាក់ព័ន្ធនឹងអាជ្ញាធរមានឋានៈខ្ពស់ ឬ ភាគីម្ខាងមានខ្នងជាអ្នកមានអំណាចគ្មានធន្ទះក្នុងការដោះស្រាយវិវាទដីធ្លី[៣៧៣]។ និន្នាការនេះ គេប្រទះឃើញលើស្ថាប័នដោះស្រាយទំនាស់ដីធ្លី ជាពិសេស ចំពោះគណៈកម្មការសុរិយោដី។ ភាគីវិវាទដែលជនរងគ្រោះបានចោទប្រកាន់ថា ជាអ្នករំលោភយកដីធ្លីរបស់ពួកគាត់ជានិច្ចកាលមិនចង់ចូលរួមអនុវត្តតាមនីតិវិធីរបស់គណៈកម្មការសុរិយោដី ក្នុងករណីខ្លះបានចាត់តាំងអ្នកតំណាងដែលមិនមានសិទ្ធិសម្រេចឱ្យចូលជំនួសទៅវិញ។ ភាគីទំនាស់ពុំសូវគាំទ្រដល់ដំណើរការដោះស្រាយរបស់គណៈកម្មការសុរិយោដីទេ។ ចំណែកស្ថាប័នខ្ពស់ជាងនេះ ដូចជាអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ក៏ជួបប្រទះនូវឧបសគ្គផងដែរ នេះដោយសារភាគីទំនាស់ ឬ ខ្នងបង្អែករបស់គេមានឋានៈខ្ពស់ជាងមន្ត្រីដែលទទួលបន្ទុកដោះស្រាយ។ ទាក់ទងបញ្ហានេះ សម្តេចនាយករដ្ឋមន្ត្រីក៏បានអះអាងដែរថា "រាល់បញ្ហាទាក់ទងដីធ្លី ស្ថិតនៅត្រង់ថាតើរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហានធ្វើ ឬមិនហានធ្វើតែប៉ុណ្ណោះ"[៣៧៤]។ ការណ៍នេះ បានឆ្លុះបញ្ចាំងឱ្យឃើញថា ក្រៅតែពីសម្តេចនាយករដ្ឋមន្ត្រី មិនមានអ្នកណាហានដោះស្រាយលើរឿងវិវាទដីធ្លីធំៗនោះឡើយ។

តុលាការវិញក៏ជួបបញ្ហាស្រដៀងគ្នានេះដែរ។ ទាក់ទងរឿងនេះ សម្តេចនាយករដ្ឋមន្ត្រីធ្លាប់ធ្វើការព្រមានដល់មន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ដោយបានប្រកាសជាសាធារណៈថា ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី ទាំងឡាយណាដែលពាក់ព័ន្ធនឹងបញ្ហាដីធ្លីត្រូវដកខ្លួនជាបន្ទាន់ ដោយប្រគល់ដីធ្លីទាំងនោះទុកជាទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីចែកជូនប្រជាពលរដ្ឋក្រីក្រដែលត្រូវការដីធ្លីសម្រាប់ដាំដុះចិញ្ចឹមជីវិត។ បើមិនដូច្នេះទេ អ្នកទាំងនោះនឹងត្រូវប្រឈមមុខចំពោះផល

---

[៣៧៣] ពាក្យ ខ្នង តាមន័យសាមញ្ញដើម្បីប្រៀបធៀបទៅនឹងខ្នងបង្អែក ដែលជួយឱ្យយើងមានលំនឹងមិនឱ្យដួល។ ន័យនេះគឺថាមានអ្នកជួយការពារដែលអាចជាចៅហ្វាយនាយ ជាបក្សពួក ឬអ្នកមានបុណ្យស័ក្តិធំដុំ មានអំណាច ឬមានឥទ្ធិពលខ្លាំង។

[៣៧៤] រស្មីកម្ពុជា: សម្តេច ហ៊ុន សែន *ប្រកាសធ្វើសង្គ្រាមនឹងការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់* ឆ្នាំទី១២ លេខ ៣៥០០ ថ្ងៃអង្គារ ទី១៩ ខែតុលា ឆ្នាំ២០០៤។

វិបាកដ៏ធ្ងន់ធ្ងរជាមិនខាន[៣៧៥]។ ទោះបីជា មានការព្រមានពីថ្នាក់ដឹកនាំកំពូលក៏ដោយ វិវាទដីធ្លីនៅតែកើតមានដដែល។ តាមការសង្កេតជារឿយៗ កម្រមានមន្ត្រីថ្នាក់ខ្ពស់ដែលប្រព្រឹត្តខុសទទួលទោសដោយសារកំហុសរបស់គេ ទោះបីជារកឃើញកំហុសម្តងៗ មិនត្រូវបានទទួលទោសព្រហ្មទណ្ឌតាមច្បាប់នោះទេ ដោយគ្រាន់តែត្រូវផ្លាស់ប្តូរមុខតំណែង។

ក្នុងរឿងទំនាស់ដីធ្លីធំៗ ភាគីដែលជាអង្គធរមានឋានៈខ្ពស់ តែងតែមានកងកម្លាំងប្រដាប់អាវុធដើម្បីការពារ។ កងកម្លាំងទាំងនោះមានដូចជា ទាហានប្រដាប់អាវុធ កងរាជអាវុធហត្ថ និង នគរបាល ត្រូវបានក្រុមហ៊ុនជួលឱ្យផ្តល់ការការពារ[៣៧៦]។ ករណីខ្លះទៀត ទាហ៊ានប្រដាប់អាវុធត្រូវបានបញ្ជូនពីនាយកដ្ឋានអភិវឌ្ឍន៍នៃកងយោធពលខេមរភូមិន្ទ ដើម្បីកិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុន គឺមកដោយមានលិខិតបេសកកម្មដែលចុះហត្ថលេខាដោយវរសេនីយទោយោធាថែមទៀតផង[៣៧៧]។ ការធ្វើអន្តរាគមន៍បែបនេះ ជារឿយៗកើតមានអំពើហិង្សាមកលើប្រជាពលរដ្ឋក្នុងទំនាស់ដីធ្លី ដោយមានការបាញ់បោះ និង វាយដំ។ ជាលទ្ធផលអ្នករងគ្រោះ គឺជាប្រជាពលរដ្ឋត្រូវបានចោទប្រកាន់ និង ចាប់ឃុំខ្លួន ចំណែកកងកម្លាំងប្រដាប់អាវុធការពារក្រុមហ៊ុនវិញ មិនត្រូវបានចោទប្រកាន់ចាប់ខ្លួនឡើយ សិទ្ធិការពារខ្លួនស្របច្បាប់ត្រូវបានរើសអើងចំពោះភាគីប្រជាពលរដ្ឋ។

---

[៣៧៥] កោះសន្តិភាព: *ប្រយ័ត្នបដិវត្តន៍កសិករ អ្នករំលោភយកដីរដ្ឋរាប់រយហិកតាប្រញាប់ដកខ្លួនជាបន្ទាន់* ឆ្នាំទី៣៧ លេខ ៥២៥២ ចេញផ្សាយថ្ងៃអង្គការ ទី១៩ ខែតុលា ឆ្នាំ២០០៤។

[៣៧៦] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា: *សម្បទានគោលដៅសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ទស្សនៈវិស័យខាងសិទ្ធិមនុស្ស* ភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០០៤ ទំព័រ៥១៖ នៅក្នុង លិខិតរបស់លោក វ៉ាំងសង់ ចាន់ ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០០៤ អំពី តំណាងក្រុមហ៊ុនគ្រីនរិច ផ្ញើជូនអភិបាលខេត្តកោះកុង ស្នើសុំបុគ្គលិកសន្តិសុខដើម្បីការពារដីសម្បទាន។

[៣៧៧] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា: *សម្បទានគោលដៅសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា* ទស្សនៈវិស័យខាងសិទ្ធិមនុស្ស-ដដ-ទំព័រ៤៩។

រូបភាពទី១២ ការអន្តរាគមន៍ខុសនីតិវិធីដោយតុលាការ



*ជនរងគ្រោះរបួសដោយសមត្ថកិច្ចបាញ់*

ទំនាស់ដីស្រែប្រាំង នៅទំនប់សួង ស្ថិតក្នុងឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប រវាងភាគី ប្រជាពលរដ្ឋ១៧៥ គ្រួសារ ជាមួយនឹងភាគីថៅកែអាងទឹក ដណ្តើមយកដីទំនាស់ទំហំ ៩២ហិកតា ចាប់ពីឆ្នាំ២០០៥ បានឈានដល់អំពើហិង្សា មានមនុស្ស ៤នាក់ ត្រូវកងកម្លាំងប្រដាប់អាវុធបាញ់បំបាក់ជើង មានមនុស្សសរុប៤៨នាក់ ត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ ក្នុងនោះមានតំណាង ប្រជាពលរដ្ឋចំនួន១៦ នាក់ បានជាប់ឃុំខ្លួន ក្នុងពន្ធនាគារ។

ករណីនេះស្ថិតនៅក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី តែផ្ទុយទៅវិញតុលាការខេត្តសៀមរាប បានចោទប្រកាន់ទៅលើប្រជាពលរដ្ឋ ដោយខុសនីតិវិធីច្បាប់ និងមិនមានមូលដ្ឋានភស្តុតាំងគ្រប់គ្រាន់ ដោយសំអាងទៅលើបណ្តឹងរបស់ពួកថៅកែអាងទឹកតែប៉ុណ្ណោះ។ កាលពី ថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ មានតំណាងប្រជាពលរដ្ឋ៣នាក់ ក្នុងចំណោម៨នាក់ ត្រូវទទួលរងនូវការចោទប្រកាន់ ពីបទញុះញង់ ទើបបណ្តាលឱ្យមានការតវ៉ាបែបហិង្សាមួយរបស់អ្នកភូមិ នៅមុខតុលាការខេត្តសៀមរាប ដោយមាន ទាំងដុតកង់ឡាន និងហ៊ុមព័ទ្ធតុលាការចាប់ពីថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ រហូតដល់ថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ក្រោយពីមានការដោះលែងតំណាង ៣នាក់នោះពីពន្ធនាគារ ជាបណ្តោះអាសន្ន។

ដោយសេចក្តីសម្រេចពីអាជ្ញាធរខេត្ត មានភាពលំអៀងទៅលើភាគីថៅកែអាងទឹក ទើបភាគីប្រជាពលរដ្ឋ ១៧៥គ្រួសារ បាននាំគ្នាចូលទៅច្រូតស្រូវ បណ្តាលឱ្យមានការប្រើអំពើហិង្សា កើតមានឡើងកាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៩ ក្នុងថ្ងៃនោះមាន កងកម្លាំងប្រដាប់អាវុធរាប់រយនាក់ ធ្វើការបាញ់រះ បាញ់បំបាក់ជើងព័ទ្ធដេញចាប់តំណាងប្រជាពលរដ្ឋ ចាប់ចងទុកឱ្យខ្សោះឈាម ធ្វើទារុណកម្ម វាយដំឱ្យមានរបួសយ៉ាងធ្ងន់ធ្ងរ។ បន្ទាប់ពីព្រឹត្តិការណ៍នេះ កងកម្លាំងប្រដាប់អាវុធ បានដាក់ពង្រាយ ព័ទ្ធជុំវិញ ភូមិប្រជាពលរដ្ឋ និងដីទំនាស់ ធ្វើឱ្យប្រជាពលរដ្ឋរាប់រយ នាក់រត់គេចខ្លួន មិនហ៊ានចូលផ្ទះ និងមិនបានបង្កបង្កើនផល ចិញ្ចឹមគ្រួសារទៀតផង។ ក្នុងថ្ងៃនោះ មានប្រជាពលរដ្ឋ៤នាក់ត្រូវកងកម្លាំងបាញ់ឱ្យមានរបួស និង៤៣នាក់ផ្សេងទៀតត្រូវចាប់ខ្លួន ក្នុងនោះប្រជាពលរដ្ឋ៩នាក់ត្រូវបានបញ្ជូន ទៅឃុំខ្លួនក្នុងពន្ធនាគារ ដោយចោទពីបទប្លន់ស្រូវ ។ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៩ តំណាងប្រជាពលរដ្ឋ ២នាក់ត្រូវបានចាប់ខ្លួនបន្ថែមទៀត ក្រោមបទចោទប្រកាន់ហ៊ុមព័ទ្ធតុលាការ។

ប្រភព សមាគមអាដហុកៈ ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៩ បោះពុម្ពផ្សាយនៅភ្នំពេញ លេខ ៩ ឆ្នាំទី៩ ខែមេសា ឆ្នាំ២០១០ ទំព័រ៣៥។

របនាសម្ព័ន្ធនៃអ្នកដឹកនាំដែលតាក់តែងឡើងនៅថ្នាក់មូលដ្ឋាន មិនបានជួយប្រជាពលរដ្ឋឱ្យបានសមស្របទេ។ ប្រព័ន្ធនាយថៅហ្វាយ និងប្រាក់បៀវត្សរ៍មិនគ្រប់គ្រាន់របស់មន្ត្រីរាជការ ត្រូវស្ថិតក្រោមឥទ្ធិពលនៃអំណាច និងទឹកប្រាក់ដើម្បីជាថ្នូរនឹងការទទួលបានសេវា។ ប្រព័ន្ធនេះ វាបង្កលក្ខណៈងាយស្រួលដល់ភាគីនៃវិវាទដីធ្លីដែលម្ខាងជាអ្នកមាន។ មន្ត្រីខិលខូចមួយចំនួនគឺសមគំនិតជាមួយអ្នករំលោភដីធ្លី ដោយទទួលបានផលប្រយោជន៍ ករណីខ្លះមន្ត្រីដើរតួជាភាគីវិវាទជំនួសឱ្យភាគីម្ខាងទៀតផង។ នេះស្តែងឱ្យឃើញថា មន្ត្រីខិលខូចមួយចំនួនរួមគំនិតប្រព្រឹត្តអំពើខុសច្បាប់។ អំពើនេះវាស្តែងឡើងតាមរយៈការចុះហត្ថលេខាលើលិខិតក្លែងក្លាយ បដិសេធឯកសារ ឬការមិនចាត់វិធានការលើអ្នករំលោភដីធ្លីជាដើម។ បញ្ហានេះធ្វើឱ្យប្រជាពលរដ្ឋមិនអាចរកយុត្តិធម៌បាននៅថ្នាក់ក្រោម ដូច្នេះពួកគេតែងតែស្វែងរកការជួយពីស្ថាប័នថ្នាក់ជាតិ ដូចជា រដ្ឋសភា ព្រឹទ្ធសភា គណៈរដ្ឋមន្ត្រី ឬក្រសួងណាមួយជាក់លាក់ ជាពិសេស ពីសម្តេចនាយករដ្ឋមន្ត្រី។ ប៉ុន្តែ ជួនកាលបណ្តឹងមិនត្រូវបានគេទទួលចាត់វិធានការដោះស្រាយឡើយ ដោយសារមនុស្សមួយចំនួននៅក្នុងស្ថាប័នមួយចំនួន ក៏ជាប់ពាក់ព័ន្ធ ឬមានចំណង ឬផលប្រយោជន៍នៅក្នុងការដោះស្រាយវិវាទ។ ទោះបីជាបណ្តឹងត្រូវបានទទួលក៏ដោយ ក៏

បណ្តឹងត្រូវបញ្ជូនបន្តទៅស្ថាប័នពាក់ព័ន្ធឱ្យដោះស្រាយ ដូចជាបណ្តឹងបានដាក់ជូនរដ្ឋសភា តែត្រូវបញ្ជូនទៅអភិបាលរាជធានីជាដើម(សូមមើលនៅឧបសម្ព័ន្ធ)។

ក្តីសង្ឃឹមចុងក្រោយក្នុងការដោះស្រាយទំនាស់ដីធ្លីដែលមានលក្ខណៈរាំរ៉ៃ និង ពាក់ព័ន្ធនឹងអ្នកមានប្រាក់ និងអាជ្ញាធរមានឋានៈខ្ពស់ គឺរកការអន្តរាគមន៍ពីសម្តេចនាយករដ្ឋមន្ត្រីដែលជាមនុស្សតែម្នាក់គត់ដែលគេគិតថា អាចផ្តល់យុត្តិធម៌បាន។ ពួកគេតែងតែមានក្តីស្រមៃចង់ជួបនាយករដ្ឋមន្ត្រីដោយផ្ទាល់។ អ្នកខ្លះនិយាយថា មានតែការអន្តរាគមន៍ពីនាយករដ្ឋមន្ត្រីទេ ទើបវិវាទរបស់គេត្រូវបានដោះស្រាយ។

ករណីវិវាទដីមួយចំនួនមេភូមិ មេឃុំ ចូលដៃក្នុងបទល្មើសដោយផ្ទាល់ដែលអាជ្ញាធរថ្នាក់ស្រុក ខេត្តមិនបានដឹង។ ករណីខ្លះទៀត មន្ត្រីថ្នាក់ក្រោមមិនបានដឹង ដូច្នេះគេអាចជួយប្រជាពលរដ្ឋរងគ្រោះ ប៉ុន្តែនៅតែខ្លាចមិនហានអន្តរាគមន៍ពីព្រោះដឹងថា ថ្នាក់លើរបស់គេនៅពីក្រោយខ្នងជនល្មើសជាដើម។ នេះវាបង្ហាញឱ្យឃើញពីទម្លាប់នៃការខ្លាចថ្នាក់លើដោយអ្នកនៅក្រោមបង្គាប់ ក្នុងការអនុវត្តជាក់ស្តែងតែងតែគោរពសេចក្តីណែនាំ ឬ ការបញ្ជារបស់ចៅហ្វាយខ្លាំងជាងច្បាប់ទៅទៀត ពីព្រោះអ្វីដែលចេញមកពីចៅហ្វាយក្នុងអារម្មណ៍របស់គេ គឺជាច្បាប់[៣៧៨]។

រូបភាពទី១៣ ករណីវិវាទដីធ្លីនៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ



*ពលរដ្ឋតវ៉ាទាមទារដល់ទីស្នាក់ការភូមិ*

កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៩ អភិបាលខណ្ឌដង្កោ បានចេញសេចក្តីជូនដំណឹង ចុះអនុវត្តដកយកដីស្នាក់ការ មានទីតាំង នៅភូមិដម្លូវ៉ែន សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ មានទំហំ (២៤ម x ២៤ម) រវាងប្រជាពលរដ្ឋ ជាអ្នកភូមិចំនួន៣៣០គ្រួសារ ជាមួយនឹងភាគីអ្នកមានម្នាក់ បណ្តាលឱ្យប្រជាពលរដ្ឋ មានការ ទាមទារ តវ៉ា ប្រឆាំងនឹងការសម្រេចរបស់អាជ្ញាធរខណ្ឌដង្កោ។

ទំនាស់ដីស្នាក់ការភូមិនេះ តុលាការតាំងពីសាលាដំបូង រហូតតុលាការកំពូលបានសម្រេចឱ្យភាគីប្រជាពលរដ្ឋជាអ្នកឈ្នះក្តី ហើយទុកដីនេះជាសម្បត្តិរួមភូមិដដែល។ អាជ្ញាធរខណ្ឌដង្កោបានចុះទៅកាន់ដីទំនាស់នោះដើម្បីអនុវត្តនូវលិខិត ស.ជ.ណ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងលិខិត ស.ជ.ណ របស់សាលារាជធានីភ្នំពេញ ដែលបានសម្រេចប្រគល់ដីនោះទៅឱ្យភាគីអ្នកមានម្នាក់មានសិទ្ធិ កាន់កាប់ជាកម្មសិទ្ធិផ្ទាល់ខ្លួន ព្រមទាំងបញ្ជាឱ្យដោះស្លាកទីស្នាក់ការភូមិចេញពីដីទំនាស់នោះទៀតផង ដោយផ្អែកពីសាលដីការបស់តុលាការកំពូល។

ប្រភព សមាគមអាដហុកៈ ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៩ បោះពុម្ពផ្សាយនៅភ្នំពេញ លេខ៩ ឆ្នាំទី៩ ខែមេសា ឆ្នាំ២០១០ ទំព័រ២៨។

ដោយជួបប្រទះការលំបាកជាច្រើនក្នុងការដោះស្រាយបញ្ហាទាក់ទងស.ជ.ណ. សម្តេចនាយករដ្ឋមន្ត្រីបានផ្តល់គោលការណ៍អំពីបញ្ហាទំនាស់ដីធ្លី គឺត្រូវឱ្យអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីជាអ្នកពិនិត្យវាយតម្លៃឱ្យបានច្បាស់លាស់មុននឹងចេញ ស.ជ.ណ. ក្នុងនាមរាជរដ្ឋាភិបាល។ ដូច្នេះការចេញ ស.ជ.ណ.មានតិចតួចនៅឆ្នាំ២០០៩ ។ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី សហការជាមួយអាជ្ញាធរ

[៣៧៨] សាយ បូរី: *វិទ្យាសាស្ត្ររដ្ឋបាល ភ្នំពេញ* បណ្ណាគារអង្គ បោះពុម្ពលើកទី១ ឆ្នាំ២០០៧ ទំព័រ១៨៧។

ថ្នាក់ក្រោមជាតិ ជាពិសេស នៅថ្នាក់រាជធានី ខេត្តក្នុងការដោះស្រាយទំនាស់ដីធ្លី គឺត្រូវអញ្ជើញរាជធានី ខេត្តដែលពាក់ព័ន្ធមកចូលរួមប្រជុំលើកយោបល់ដោះស្រាយរួមគ្នា ដើម្បីឱ្យថ្នាក់ក្រោមបានដឹងរួចចេញ ស.ជ.ណ.ហើយធ្វើការអនុវត្ត។ ក្នុងរបាយការណ៍ប្រចាំឆ្នាំ២០០៩ របស់អាជ្ញាធរជាតិដោះស្រាយ ទំនាស់ដីធ្លីបានលើកឡើងថា អាជ្ញាធរនេះមិនបានជ្រៀតជ្រែកដល់សមត្ថកិច្ចរបស់ស្ថាប័នផ្សេងៗនោះ ឡើយ។ អាជ្ញាធរជាតិតែងតែគោរព និងវាយតម្លៃខ្ពស់ចំពោះរាល់ការសម្រេចរបស់ស្ថាប័ន តុលាការ[៣៧៩]។ ចំណុចដែលបានលើកឡើងនេះ វាផ្ទុយគ្នាទៅនឹងការអនុវត្តជាក់ស្តែងរបស់អាជ្ញាធរ នេះ។

តុលាការត្រូវបានរិះគន់ពីភាពមិនមានឯករាជ្យ ឬអនាគតិ ក្នុងការដោះស្រាយទំនាស់ រួមទាំង ទំនាស់ដីធ្លីផងដែរ។ ការចោទប្រើនទាក់ទងនឹងបទល្មើសបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជនដែលរឿងក្តី នោះមិនទាន់ទាំងបានកំណត់ថាតើ ភាគីណាជាម្ចាស់ពិតប្រាកដលើដីនោះ។ បទចោទជារឿយៗមាន ដូចជាការដកបង្គោល ការញុះញង់ លួច ប្លន់ បង្កបួសស្នាម និងបរិហាកេរ្តិ៍ជាដើម។ ស្រដៀងគ្នានេះ បុគ្គលិកអង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធដីធ្លីលើកឡើងថា៖

> "ប្រជាពលរដ្ឋតែងតែដាក់ពាក្យបណ្តឹងទៅតុលាការប្រឆាំងក្រុមហ៊ុន ប៉ុន្តែតុលាការមិនចាត់ការ។ នៅពេលក្រុមហ៊ុនប្តឹងប្រជាពលរដ្ឋទៅតុលាការពីបទព្រហ្មទណ្ឌ តុលាការចាត់ការយ៉ាងរហ័ស... តុលាការមិនមែនបម្រើឱ្យប្រជាពលរដ្ឋទេ តុលាការបម្រើឱ្យរដ្ឋាភិបាល តុលាការបម្រើឱ្យក្រុមហ៊ុន"[៣៨០]។

## កត្តាថវិកា

ផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំចាប់ពីឆ្នាំ២០០៣-២០០៩ គណៈកម្មការសុរិយោដីបានជួប ប្រទះនូវបញ្ហាកង្វះខាតថវិកា ដោយពុំមានខ្ទង់ដើម្បីចំណាយលើប្រតិបត្តិការណ៍នានា និងខ្វះ មធ្យោបាយធ្វើដំណើរ និង សំភារៈបច្ចេកទេសមិនគ្រប់គ្រាន់ ក្នុងការឆ្លើយតបទៅនឹងតម្រូវការចាំបាច់ ដល់ដំណើរការដោះស្រាយវិវាទ។ ខ្ទង់ថវិកាជាតិក្នុងឆ្នាំ២០០៩-២០១០ រាជរដ្ឋាភិបាលបែងចែកតែ រវាង ០,៥៩-០,៦២ ភាគរយ ប៉ុណ្ណោះនៃថវិកាជាតិសរុបទៅដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់[៣៨១]។ ថវិកានេះសម្រាប់ក្រសួងទាំងមូល និង ត្រូវបែងចែកទៅលើផ្នែកផ្សេងៗថែមទៀត។ ដូច្នេះធ្វើឱ្យគណៈកម្មការសុរិយោដីជួបការលំបាកក្នុងការបំពេញកិច្ចការដ៏ធំរបស់ខ្លួន។ ឃើញបញ្ហានេះ ដៃគូអភិវឌ្ឍន៍ដែលគាំទ្រក្រសួង ដូចជាអង្គការជីជីហ្សែតរបស់ប្រទេសអាល្លឺម៉ង់ សហការរៀបចំបង្កើត ក្រុមដោះស្រាយវិវាទចល័តសាកល្បង។ ក្រុមចល័តត្រូវបាន ផ្តល់ប្រាក់ឧបត្ថមទៅតាមការបំពេញ ការងារ(ប្រាក់លើកទឹកចិត្ត)សម្រាប់ការដោះស្រាយវិវាទ។ ការដោះស្រាយនេះ បានជួយសម្រាល

[៣៧៩] សូមអានបន្ថែមនៅក្នុងរបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំ២០០៩ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី នៅក្នុងទំព័រ២៤។

[៣៨០] Kathleen o's Keefe: ***Land is Life, Land Conflict interventions in Cambodia, a review of case studies & NGO perceptions***, op.cit. page11.

[៣៨១] រាជរដ្ឋាភិបាល: *របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០០៨* ស្តីពី ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០០៨ ទំព័រ១០២។

ករណីវិវាទដែលកកស្ទះបានមួយចំនួននៅថ្នាក់ស្រុក តែនៅមានទំហំតូចនៅឡើយ និង មិនអាចឆ្លើយតបចំពោះករណីវិវាទនាពេលបច្ចុប្បន្ន។

ស្រដៀងគ្នានេះដែរ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ក៏ប្រឈមមុខកង្វះមធ្យោបាយធ្វើដំណើរ និងថវិកាដែលមិនអាចបំពេញបាននូវតម្រូវការ ដើម្បីដោះស្រាយទំនាស់ដីធ្លីឱ្យបានទាន់ពេលវេលា[៣៨២]។ ការចំណាយរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ស្ថិតក្រោមថវិកានៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាកន្លែងដែលទទួលថវិកាជាតិបានច្រើនបើប្រៀបធៀបនឹងក្រសួងមួយចំនួន តែទោះបីជាយ៉ាងណា ថវិកាទាំងនោះមិនមែនសម្រាប់តែអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីតែមួយមុខទេ។ ថវិកាទាំងនោះត្រូវបែងចែកទៅផ្នែកអាទិភាពជាច្រើនផ្សេងទៀត ដូច្នេះអាជ្ញាធរនេះមិនមានថវិកាគ្រប់គ្រាន់ដើម្បីអនុវត្តការងារ។ ចំណែកស្ថាប័នតុលាការវិញ ជាស្ថាប័នមួយយ៉ាងសំខាន់ និងអាចជានាមុខមាត់ប្រទេសកម្ពុជាក្នុងឆាកអន្តរជាតិ ជាប្រទេសមួយប្រកបដោយនីតិរដ្ឋ ក៏មិនមានថវិកាគ្រប់គ្រាន់ដើម្បីបំពេញមុខងាររបស់ខ្លួនដែរ។ ថវិកាជាតិក្នុងឆ្នាំ២០០៩ រាជរដ្ឋាភិបាលបានបែងចែកតែ០,៣ ភាគរយ ប៉ុណ្ណោះនៃថវិកាជាតិសរុបទៅដល់ក្រសួងយុត្តិធម៌[៣៨៣]។

ថវិកាក្រសួងមួយចំនួនត្រូវបែងចែកទៅវិស័យផ្សេងៗ រួមទាំងផ្នែកយុត្តិធម៌ផងដែរ។ ក្រសួងយុត្តិធម៌ត្រូវរាជរដ្ឋាភិបាលចាត់ជាអាទិភាពផងដែរ តែថវិការដ្ឋបែងចែកទៅឱ្យក្រសួងមានការថយចុះបើប្រៀបធៀបឆ្នាំមុន។ ថវិការដ្ឋផ្តល់ឱ្យក្រសួងនេះទាបជាងគេបំផុតបើប្រៀបធៀបទៅក្រសួងផ្សេងៗទៀត។ ជាទូទៅ មុនសម្រេចសេចក្តីតុលាការត្រូវចុះស៊ើបអង្កេតរកកស្តុតាងឱ្យបានគ្រប់ជ្រុងជ្រោយ ដោយសារខ្វះថវិកា លទ្ធផលនៃសេចក្តីសម្រេចមិនបានផ្តល់យុត្តិធម៌ឱ្យបានពេលលេញដល់ភាគីនោះទេ។ នេះមិនគិតដល់ដូចជា ការជ្រៀតជ្រែកផ្នែកនយោបាយ អាជ្ញាធរមានឋានៈខ្ពស់ និងអំណាចទឹកប្រាក់ផងទេ។

សរុបមកវិវាទដីធ្លីនៅកម្ពុជា ជាបញ្ហាសង្គមដែលមានលក្ខណៈស្មុគស្មាញ និង ធ្ងន់ធ្ងរដែលទាមទារឱ្យមាននូវដំណោះស្រាយជាច្រើន។ ក៏ប៉ុន្តែ ដំណោះស្រាយកន្លងមកនៅតែពុំអាចឈានទៅដល់ការលុបបំបាត់ចោលទាំងស្រុងនូវវិវាទដីធ្លីឡើយ។ ក្រោយពេលដែលវិវាទបានកើតឡើង ភាគីទាំងសងខាងតែងតែចង់ឈ្នះរៀងៗខ្លួនទោះបីត្រូវប្រើវិធីណាក៏ដោយ នេះក៏ព្រោះតែដើម្បីផលប្រយោជន៍។ ចេញពីសភាពការណ៍នេះ ទើបការដោះស្រាយតម្រូវឱ្យភាគីទាំងពីរ ក្រោយពីបានពិចារណាយ៉ាងល្អិតល្អន់រួចហើយធ្វើការសម្រុះសម្រួល និង ដោះស្រាយក្នុងន័យកុំឱ្យមានការខាតបង់កាន់តែធំធេងដែលអ្នកទាំងនោះសុទ្ធតែមិនចង់បាន។ ជួនកាល ដំណោះស្រាយអាចមានលក្ខណៈល្អប្រសើរនៅពេលដែលភាគីទាំងសងខាងធ្វើការស្វែងយល់ពីគ្នា ដោយមិនចាំបាច់បង្កជាផលលំបាកដល់ស្ថាប័នជាតិ និងតុលាការក្នុងការដោះស្រាយ។ ក៏ប៉ុន្តែ មិនមែនគ្រប់វិវាទទាំងអស់សុទ្ធតែអាចដោះស្រាយពីសំណាក់អាជ្ញាធរសាធារណៈ ឬចរចារដោយភាគីផ្ទាល់បាននោះទេ ។ ហេតុដូច្នេះហើយ ទើបត្រូវការស្ថាប័នតុលាការដើម្បីសម្រួលដល់ភាពលំបាករបស់ប្រជាពលរដ្ឋនៅពេលមានវិវាទ ឬបញ្ហាទំនាស់។

[៣៨២] សូមមើលផងដែររបាយការណ៍របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីឆ្នាំ២០០៩។

[៣៨៣] សមាគមអាដហុក: *ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៩*- ដ.ឯ.ម- ទំព័រ៣០។

រាជរដ្ឋាភិបាលនៅតែប្រឈមនឹងបញ្ហាជាច្រើនដែលទាក់ទងនឹងដីធ្លី ជាពិសេស វិវាទដីធ្លីចេះតែកើនឡើងនៅកម្ពុជា។ ឆ្លើយតបបញ្ហានេះ រាជរដ្ឋាភិបាលខិតខំដោះស្រាយ ទោះបីជាតាមផ្លូវរដ្ឋបាល ឬ តុលាការក្តីដោយទទួលបានជោគជ័យច្រើន តែនៅមានកម្រិត។ ច្បាប់ និងក្របខ័ណ្ឌគតិយុត្តនានាមិនទាន់ច្បាស់លាស់ និង មានភាពស៊ីចង្វាក់គ្នាតាមឋានានុក្រម ក្នុងការគ្រប់គ្រង និង ដោះស្រាយទំនាស់ដីធ្លី។ បញ្ហានេះធ្វើឱ្យមន្ត្រីអនុវត្តច្បាប់ភាន់ច្រឡំ ដោយមិនដឹងត្រូវដើរតាមផ្លូវណាដែលកត្តានេះងាយធ្វើឱ្យពួកគេត្រូវរើសយកវិធីដែលមិនស្របច្បាប់មកប្រើ ជាវិបាក តុលាការត្រូវបានចោទប្រកាន់ថា មិនឯករាជ្យ។ ម្យ៉ាងអវត្តមានច្បាប់ និងបទដ្ឋានច្បាប់ចាំបាច់មួយចំនួនបានធ្វើឱ្យសមត្ថកិច្ចមានភាពស្រពិចស្រពិលលើការដោះស្រាយទាំងបែបរដ្ឋបាល និងតុលាការ។ ម្យ៉ាងទៀត ទន្ទឹមនឹងការជួបប្រទះនូវភាពមិនច្បាស់លាស់ទាំងនេះ រាជរដ្ឋាភិបាលប្រឈមនឹងបញ្ហាជាច្រើនដូចជាកត្តាមធ្យោបាយ ធ្វើដំណើរ កត្តាសមត្ថភាព ធនធានមនុស្ស និងកត្តាថវិកាមិនគ្រប់គ្រាន់ជាដើម។

# ជំពូកទី៤
# ការវាយតម្លៃ

# ជំពូកទី៤
# ការវាយតម្លៃ

ជំពូកនេះនៃនិក្ខេបបទនឹងធ្វើការវិភាគទៅលើការដោះស្រាយវិវាទដីធ្លី តាមរយៈករណីសិក្សានៃវិវាទដីធ្លីនៅតំបន់ដីក្រហមរាជធានីភ្នំពេញ។ ភាពស្មុគស្មាញនៃករណីវិវាទត្រូវបានពិពណ៌នា និង តាមរយៈសាច់រឿងនេះ វាអាចឆ្លុះបញ្ចាំងឱ្យឃើញកាន់តែច្បាស់អំពីភាពខុសគ្នារវាងទិដ្ឋភាពនៃវិវាទអំពីអត្ថបទច្បាប់នៅជាធរមាន និង ការអនុវត្តច្បាប់។ ផ្នែកនេះក៏បានលើកឡើងផងដែរចំពោះអាជ្ញាធរមានសមត្ថកិច្ចក្នុងការអនុវត្តច្បាប់។ ការវិភាគផ្នែកនេះភាគច្រើន ផ្អែកទៅលើឯកសារបច្ចេកទេសផ្លូវការ ដូចជាច្បាប់ លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ លិខិតរដ្ឋបាល លិខិតកិច្ចសន្យា ពាក្យបណ្តឹង របាយការណ៍របស់អាជ្ញាធរដែនដីជាដើម។

## ៤.១ ករណីវិវាទដីក្រហម

### ៤.១.១ ប្រវត្តិរឿង

ករណីវិវាទកើតឡើងរវាងប្រជាពលរដ្ឋ និងក្រុមហ៊ុនឯកជននៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ លើដីមួយកន្លែងមានទំហំ៣,៦ ហិកតា មានទីតាំងនៅខាងត្បូងសាលមហោស្រពទន្លេបាសាក់ជាអតីតសួនសាធារណៈ។ តំបន់នេះជាកន្លែងមួយដែលដីមានតម្លៃខ្ពស់។ អគាររដ្ឋាភិបាល និង អគាររដ្ឋជាច្រើនរាប់បញ្ចូលទាំងអគារ រដ្ឋសភាជាតិ ដែលទើបត្រូវបានសាងសង់។ ក្រុមហ៊ុនឯកជនជាច្រើនតែងចង់បានដីនៅទីនោះ ដើម្បីអភិវឌ្ឍន៍ពាណិជ្ជកម្មដែលគេអាចរកផលចំណេញបានងាយស្រួល។ ប្រជាពលរដ្ឋនៅដីក្រហមត្រូវបានទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋានសាមី និងទីនោះត្រូវបានបែងចែកតាមរដ្ឋបាលជា២ភូមិគឺ ភូមិ២ និង ភូមិ១៥។ អ្នកភូមិភាគច្រើនបានរស់នៅសហគមន៍ដីក្រហមតាំងពីដើមឆ្នាំ១៩៨០។ តំបន់នោះជាដីលិចទឹកដែលសំបូរទៅដោយដើមឈើនៅពេលដែលពួកគេមកដល់ពីដំបូង។ អ្នកភូមិមករស់នៅមុនគេ បានកាប់ឆ្ការដើមឈើទាំងនោះ ហើយបានយកដីក្រហមមកចាក់នៅតំបន់នោះ ដែលដីក្រហមបានក្លាយជាឈ្មោះសហគមន៍គឺ "សហគមន៍ដីក្រហម"។ ច្រើនឆ្នាំក្រោយមក ប្រជាពលរដ្ឋនៅតំបន់ដីក្រហមបានកើនឡើង ដែលភាគច្រើននៅទីនោះគឺជាគ្រួសារក្រីក្រ។ មួយរយៈចុងក្រោយ ប្រជាពលរដ្ឋនៅសហគមន៍ដីក្រហមបានរស់នៅមានការភ័យខ្លាចពីការរើតាំងលំនៅថ្មីដោយសារដីនោះមានតម្លៃខ្ពស់ជាង៤៤ លានដុល្លារអាមេរិក ហើយអាចនឹងត្រូវរឹបអូសយកដោយក្រុមហ៊ុនឯកជន។

**ទិដ្ឋភាពនៃទំនាស់**

រាជរដ្ឋាភិបាលបានផ្តល់ ដីសម្បទានសង្គមកិច្ច តាមរយៈលិខិតលេខ៧៨៥ សជណ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៣ ឱ្យដល់អ្នកភូមិនេះ មានន័យថា ដីរបស់ពួកគេកំពុងរស់នៅគឺមានសុវត្ថិភាព។ ប្រជាពលរដ្ឋនឹងត្រូវធ្វើការអភិវឌ្ឍនៅនឹងកន្លែង ដីមួយភាគចែកគ្នាជាមួយក្រុមហ៊ុនដែលជាថ្នូរនឹងទទួលមកវិញនូវផ្ទះល្វែងថ្មីល្អប្រសើរជាងមុននៅលើផ្ទៃដីដែលនៅសល់។ ដំណោះស្រាយ

នោះគឺថា ក្រុមហ៊ុនឯកជននឹងទទួលបានដីមួយផ្នែកដើម្បីអភិវឌ្ឍពាណិជ្ជកម្ម ប៉ុន្តែក្រុមហ៊ុនត្រូវសាងសង់ផ្ទះល្វែងថ្មីជូនអ្នកភូមិនៅលើផ្ទៃដីដែលនៅសល់។ ការដោះស្រាយបែបនេះ ត្រូវចំណេញទាំងសងខាង។ ផ្ទុយទៅវិញ ការដោះស្រាយត្រូវបានផ្លាស់ប្តូរ អ្នកភូមិត្រូវបានប្រាប់ឱ្យប្រគល់ដីទាំងអស់នៃសហគមន៍ដីក្រហមឱ្យទៅក្រុមហ៊ុនឯកជនមួយ ហើយឱ្យទទួលយកផ្ទះល្វែងថ្មី ដែលស្ថិតនៅចម្ងាយ ២០គីឡូម៉ែត្រនៅជាយរាជធានីភ្នំពេញទៅវិញ។ អ្នកភូមិអះអាងថា ពួកគេមិនដែលត្រូវបានស្នើសុំឱ្យយល់ព្រមទទួលយកផ្ទះផ្សេងនៅខាងក្រៅតំបន់ដីក្រហមឡើយ។ អ្នកភូមិនិយាយថា នៅពេលនោះអ្នកតំណាងសហគមន៍របស់ពួកគាត់ បានចុះកិច្ចសន្យាយល់ព្រមទទួលយកផ្ទះល្វែងនោះដោយមិនបានឱ្យពួកគាត់ដឹងឡើយ។

កិច្ចសន្យាដែលត្រូវបានចុះហត្ថលេខា ក្នុងនាមប្រជាពលរដ្ឋសហគមន៍ដោយមិនមានការយល់ព្រម។ អ្នកភូមិទាំងនោះមិនត្រូវបានសាកសួរយោបល់ និងយល់ព្រមទាំងស្រុងជាមុន។ ចំពោះការប្រឈមមុខនឹងស្ថានភាពបែបនេះ ពួកគេត្រូវបានបង្ខំឱ្យបោះបង់លំនៅឋានរបស់ពួកគាត់នៅសហគមន៍ដីក្រហមដោយស្ម័គ្រចិត្ត។ សហគមន៍ដីក្រហមត្រូវរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចផ្តល់ជាដីសម្បទានសង្គមកិច្ចជូនដល់សហគមន៍ដើម្បីរស់នៅតំបន់នោះ តាមរយៈការអភិវឌ្ឍនៅនឹងកន្លែង។ ទីតាំងដែលគេរស់នៅលើផ្ទៃដីទំហំ៣.៧ ហិកតា ក្នុងទំហំផ្ទៃដីសរុបទាំងអស់ចំនួន៤.៧ ហិកតា។ ដីដែលនៅសល់ ទំហំ១ ហិកតា ត្រូវបានផ្តល់ឱ្យក្រុមហ៊ុនឯកជនសម្រាប់ធ្វើការអភិវឌ្ឍវិស័យពាណិជ្ជកម្មរបស់ខ្លួន។ តាមផែនការអភិវឌ្ឍរបស់ទីស្តីការគណៈរដ្ឋមន្ត្រី តាមរយៈ សជណ លេខ ៧៨៥ បានបញ្ជាក់ច្បាស់ពីចំនួនគ្រួសាររស់នៅសហគមន៍ដីក្រហម ដែលនឹងត្រូវចូលទៅរស់នៅក្នុងទីតាំងនោះចំនួន១.៤៦៥គ្រួសារ ដែលក្នុងនោះមានមនុស្សសរុប ចំនួន ៥.៨៥៤ នាក់។ មានបញ្ហាពីរពាក់ព័ន្ធនឹងផែនការអភិវឌ្ឍ។ បញ្ហាទី១ តាមការវាស់វែងជាបន្តបន្ទាប់ដោយការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌ ឃើញថា សហគមន៍ដីក្រហមមិនមានទំហំរហូតដល់៤.៧ ហិកតានោះទេ គឺមានទំហំតែ៣.៦ ហិកតាប៉ុណ្ណោះ។ បញ្ហាទី២ តំណាងសហគមន៍បានតវ៉ាច្រើនលើកអំពីស្ថិតិចំនួនអ្នកភូមិ មិនមែន ១.៤៦៥គ្រួសារទេ ប៉ុន្តែចំនួនគ្រួសារពិតប្រាកដមានមិនលើសពី ៨០៤ គ្រួសារឡើយដែលបានរស់នៅសហគមន៍ដីក្រហម។

ការផ្ទៀងផ្ទាត់ដោយឯករាជ្យនូវចំនួនគ្រួសារពិតប្រាកដ ដែលរស់នៅតំបន់នេះនៅពេលនោះមិនអាចធ្វើបានឡើយ។ អាជ្ញាធររាជធានីអះអាងថា តួលេខគ្រួសារត្រឹមត្រូវ ហើយផ្អែកតាមការស្រង់ស្ថិតិនោះគឺ១.៤៦៥គ្រួសារ។ អ្នកតំណាងសហគមន៍បានផ្តល់បញ្ជីចំនួនគ្រួសារមួយច្បាប់ឱ្យអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើឡើងក្រោយពីការស្រង់ស្ថិតិរបស់សាលារាជធានី ហើយបានបញ្ជាក់ថាចំនួនគ្រួសារជាច្រើននៅក្នុងបញ្ជីនោះ មិនដែលបានរស់នៅក្នុងសហគមន៍ដីក្រហមនេះទេ។ តំណាងសហគមន៍តវ៉ាថា ចំនួនគ្រួសារត្រូវបានបំប៉ោងដោយចេតនា ដើម្បីធ្វើឱ្យអំណាចនៃការតវ៉ារបស់អ្នកភូមិសហគមន៍ដីក្រហមត្រូវចុះខ្សោយ។ សហគមន៍ និងមេធាវីរបស់ពួកគេនិយាយថា ពិតជាមានអំពើពុករលួយដែលស្ថិតិត្រូវបានបំប៉ោងតាមរយៈការសូកប៉ាន់ ដើម្បីអនុញ្ញាតឱ្យអ្នកក្រៅដែលមិនមានសិទ្ធិមានឈ្មោះនៅក្នុងបញ្ជីទទួលផ្ទះល្វែងថ្មីដែរ។ ហេតុផលដែលនាំឱ្យមានការគណនាទំហំដីសហគមន៍

ដីក្រហមមិនត្រឹមត្រូវ និងអ្នកទទួលខុសត្រូវចំពោះការគណនានោះមិនច្បាស់លាស់ទេ។ ប៉ុន្តែកំហុសឆ្គងរួមផ្សំជាមួយស្ថិតិអ្នកភូមិដែលត្រូវបានបំប៉ោងនោះបានបង្កើតឱ្យមានបញ្ហាជាក់ស្តែងមួយ។

តាមរបាយការណ៍ដែលរៀបចំឡើងដោយលោកអភិបាលខណ្ឌបានឱ្យដឹងថាអតីតអ្នកតំណាងសហគមន៍បានទំនាក់ទំនងជាមួយក្រុមហ៊ុនឯកជនជាច្រើនដើម្បីអភិវឌ្ឍន៍ ដោយសហគមន៏ព្រមចែកដីពាក់កណ្តាល។ ក្រុមហ៊ុននោះអាចត្រូវបានផ្តល់ដីទំហំ១.៨ ហិកតា នៃផ្ទៃដីសរុបទាំងអស់ទំហំ៣.៦ ហិកតា ដើម្បីធ្វើការអភិវឌ្ឍពាណិជ្ជកម្ម ប្រសិនបើក្រុមហ៊ុននោះសាងសង់ផ្ទះល្វែងលើផ្ទៃដីដែលនៅសល់ទំហំ១.៨ហិកតា ឱ្យអ្នកភូមិនោះ។ ប៉ុន្តែការចរចាបានទទួលបរាជ័យ ក្រោយមកអ្នកតំណាងបានចាប់ផ្តើមពិភាក្សាជាមួយក្រុមហ៊ុនឯកជនមួយអំពីការដោះដូរដីទាំងមូល។ ក្រុមហ៊ុនអាចយកផ្ទៃដីសរុបទាំងអស់ទំហំ៣.៦ហិកតា នៅសហគមន៍ដីក្រហមជាថ្នូរនឹងការសាងសង់ផ្ទះល្វែងឱ្យអ្នកភូមិនៅកន្លែងផ្សេងនៃទីក្រុងភ្នំពេញ។

**កិច្ចសន្យាជាមួយក្រុមហ៊ុន**

នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៥ ក្រុមហ៊ុនបានចុះកិច្ចសន្យាមួយជាមួយតំណាងសហគមន៍ចំនួន៣៦នាក់ ដោយធ្វើការដោះដូរដីសហគមន៍ដីក្រហមទាំងអស់ជាថ្នូរនឹងផ្ទះល្វែងថ្មីសម្រាប់អ្នកភូមិនៅទីតាំងលំនៅឋានថ្មី ដែលមានចម្ងាយ២០គីឡូម៉ែត្រ។ កិច្ចសន្យានោះចែងថា ក្រុមហ៊ុននឹងត្រូវបានដីទំហំ៣.៦ ហិកតា ដែលជាដីសម្បទានសង្គមកិច្ចផ្តល់ឱ្យដោយរាជរដ្ឋាភិបាលកម្ពុជាទៅឱ្យសហគមន៍ដីក្រហមជាថ្នូរនឹងការសាងសង់អគារផ្ទះល្វែងចំនួន១.៤៧២ល្វែងនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ។ មន្ត្រីមួយចំនួនរួមមានទាំងអតីតមេភូមិ២ និងមេភូមិ១៥ ជាសាក្សីក្នុងការចុះកិច្ចសន្យានោះដែរ។ អ្នកភូមិសហគមន៍ដីក្រហមនិយាយថា អ្នកតំណាងរបស់ពួកគាត់មិនបានស្នើឱ្យមានការឯកភាពមុនការចុះកិច្ចសន្យានេះទេ ហើយពួកគាត់ក៏មិនដែលធ្លាប់យល់ព្រមផ្លាស់ទីតាំងចេញពីដីនេះឡើយ។ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០០៥ ទើបអ្នកភូមិបានដឹងអំពីការចុះកិច្ចសន្យា នៅពេលពួកគាត់ចូលរួមការប្រជុំមួយនៅសាលមហោស្រពទន្លេបាសាក់ ដែលនៅទីនោះអាជ្ញាធរមូលដ្ឋាន និងអ្នកតំណាងសហគមន៍បានជម្រាបឱ្យពួកគាត់ដឹង។

ក្រោយដឹងរឿងនេះអ្នកភូមិប្រតិកម្ម និងដើម្បីឱ្យសភាពការស្ងប់ស្ងាត់ទៅវិញ មន្ត្រីដែលមានវត្តមាននៅកិច្ចប្រជុំនោះ បានធានាអះអាងសារជាថ្មីចំពោះអ្នកភូមិពេលប្រជុំថា "គ្មានអ្នកណាម្នាក់នឹងត្រូវបានបង្ខំឱ្យទទួលយកកិច្ចសន្យានោះទេ" ។ អ្នកភូមិត្រូវគេប្រាប់ថា ប្រសិនបើពួកគាត់ចង់ទទួលយកសំណើរបស់ក្រុមហ៊ុនតាមកិច្ចសន្យា ពួកគាត់គួរចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន។ ប៉ុន្តែប្រសិនបើពួកគាត់មិនចង់ទទួលយកសំណើនោះទេ នឹងពុំមានបញ្ហាអ្វីកើតឡើងចំពោះពួកគាត់ឡើយ។ ក្រោយពីបានចុះកិច្ចសន្យា មានការធានាអះអាងសារថ្មីជាច្រើនថា កិច្ចសន្យាត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្តទាំងស្រុងដោយសហគមន៍ដីក្រហម ដែលភ្លាមនោះអ្នកភូមិបានបង្ហាញភស្តុតាង និងបញ្ជាក់ថា ការអះអាងនេះមិនត្រឹមត្រូវទេ។ ក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋានបានចាប់ផ្តើមយុទ្ធនាការដោយប្រើល្បិច ប៉ុន្តែក្រោយមកប្រើសំដីអសុរោះខ្លាំងៗដោយផ្ទាល់ដើម្បីបង្ខំអ្នកភូមិឱ្យទទួលយកកិច្ចសន្យានោះ ហើយចាកចេញពីសហគមន៍ដីក្រហម។

ឧបាយកលបង្ខិតបង្ខំកាន់តែមានខ្លាំងឡើងៗ ហើយអ្នកភូមិជាច្រើនមានការស្រងាកចិត្តព្រោះគ្មានការពិគ្រោះយោបល់អំពីកិច្ចសន្យា និង មានការភ័យខ្លាចក្រែងបញ្ហាកាន់តែរីកធំទៅៗ ដូច្នេះក៏បានចាប់ផ្តើមរៀបចំខ្លួនដើម្បីការពារសិទ្ធិលើទ្រព្យសម្បត្តិរបស់ពួកខ្លួន។ សហគមន៍ បានធ្វើការតវ៉ាជំទាស់អំពីនីត្យានុកូលភាពនៃកិច្ចសន្យា និង ភាពស្របច្បាប់នៃអ្នកតំណាងរបស់ពួកគាត់ដែលបានចុះហត្ថលេខាលើកិច្ចសន្យាដោយមិនបានឱ្យពួកគាត់ដឹង និងយល់ព្រមជាមុន។ អ្នកភូមិបានជ្រើសតាំងអ្នកតំណាងសហគមន៍ថ្មីចំនួន២៣រូបដោយនិយាយថា ពួកគេឈប់ទទួលស្គាល់អ្នកតំណាងចាស់ដែលអាជ្ញាធរបានចាត់តាំងដោយមិនជ្រើសរើសតាមការបោះឆ្នោត ដែលបានចុះកិច្ចសន្យាដោយមិនមានការឯកភាពពីសមាជិក។

## ពាក្យបណ្តឹង

នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០៥ អ្នកតំណាងថ្មីបានបញ្ជូនញត្តិមួយច្បាប់ ដែលផ្តិតមេដៃដោយអ្នកភូមិចំនួន៨០៤ គ្រួសារ នៅសហគមន៍ដីក្រហមទៅសាលារាជធានីភ្នំពេញ ដើម្បីស្នើសុំឱ្យមោឃភាពកិច្ចសន្យាជាមួយក្រុមហ៊ុន ពីព្រោះកិច្ចសន្យានោះធ្វើឡើងដោយមិនបានឱ្យអ្នកភូមិដឹង[៣៨៤]។ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៥ អ្នកតំណាងបានធ្វើការតាមដានដោយផ្ញើលិខិតមួយច្បាប់ទៅតំណាងរាស្ត្រដើម្បីស្នើសុំកិច្ចអន្តរាគមន៍ដើម្បីឱ្យជួយមោឃភាពកិច្ចសន្យានោះ[៣៨៥]។ នៅឆ្នាំ២០០៦ អ្នកតំណាងបានប្រមូលស្នាមមេដៃអ្នកភូមិចំនួន៣៧០ គ្រួសារ ដើម្បីបញ្ជាក់អំពីការទទួលស្គាល់ភាពជាតំណាងស្របច្បាប់របស់ពួកគេ ដោយសង្ឃឹមថានឹងទទួលបានភាពស្របច្បាប់នៅចំពោះមុខតុលាការ។ ចាប់តាំងពីពេលនោះអ្នកតំណាងសហគមន៍ដីក្រហមបាន ចំណាយពេលជិតបីឆ្នាំក្នុងការស្វែងរកដំណោះស្រាយដោយធ្វើការអំពាវនាវ និង ដាក់ពាក្យបណ្តឹងដ៏ច្រើនសន្ធឹកសន្ធាប់ទៅអាជ្ញាធរ ទោះជាតាមផ្លូវរដ្ឋបាល ឬតាមផ្លូវតុលាការដែលស្ថាប័នទាំងនោះមានដូចជា៖ គណៈកម្មការសុរិយោដីសាលារាជធានីភ្នំពេញ ក្រសួងនានា លោកនាយករដ្ឋមន្ត្រី និង ទៅកាន់តុលាការរាជធានីភ្នំពេញ ដើម្បីមោឃភាពកិច្ចសន្យានោះ។ ទោះបីជាបណ្តឹងអំពីនីត្យានុកូលភាពនៃកិច្ចសន្យារបស់ខ្លួននៅមានសុពលភាពក៏ដោយ ក៏ការអំពាវនាវរបស់អ្នកភូមិមិនត្រូវបានគេយកចិត្តទុកដាក់ឡើយ។ អាជ្ញាធរមិនត្រឹមតែមិនបានការពារ ប៉ុន្តែថែមទាំងបានរំលោភបំពានទៅលើសិទ្ធិលើទ្រព្យសម្បត្តិរបស់អ្នកភូមិទៀតផង។

## ការបង្ខិតបង្ខំ

អ្នកភូមិស៊ូទ្រាំនឹងយុទ្ធនាការបំភិតបំភ័យជាបន្តបន្ទាប់ដែលធ្វើឡើង ជាពិសេស ទៅលើអ្នកតំណាងថ្មីរបស់ពួកគាត់ដើម្បីបង្ខំឱ្យបោះបង់ចោលដីរបស់ខ្លួន។ យុទ្ធនាការនេះរួមមាន៖ ការគំរាមកំហែង ការប្រើអំពើហិង្សាលើរាងកាយ សកម្មភាពបង្ករឿង និងការប្តឹងរឿងព្រហ្មទណ្ឌដោយមិនសម

[៣៨៤] លិខិតរបស់មេធាវីតំណាងប្រជាពលរដ្ឋ ផ្ញើជូនលោកអភិបាលរាជធានីភ្នំពេញ ស្តីពី សំណើសុំជួយអន្តរាគមន៍ដល់ប្រជាពលរដ្ឋដែលកំពុងរស់នៅភូមិ២ និងភូមិ១៥ សង្កាត់ទន្លេបាសាក់ ដែលត្រូវបានប្រធានសហគមន៍ចាស់ ទាំង៣៦រូបមានឧបាយកលដេញប្រជាពលរដ្ឋ ឱ្យទៅនៅភូមិតំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥។

[៣៨៥] លិខិតតំណាងប្រជាពលរដ្ឋ ស្នើសុំឱ្យតំណាងរាស្ត្រមណ្ឌលភ្នំពេញជួយអន្តរាគមន៍ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៥។

ហេតុផលចំពោះពួកតំណាងទាំងនោះ។ មួយរយៈក្រោយមកអ្នកភូមិមួយចំនួននៅសហគមន៍ដីក្រហម បានទទួលយកលក្ខខណ្ឌរបស់ក្រុមហ៊ុន ហើយបានព្រមចាកចេញពីដី។ ពួកគេមួយចំនួនអាចពេញចិត្តនឹងការដោះស្រាយដែលក្រុមហ៊ុនបានផ្តល់ឱ្យ ប៉ុន្តែមួយចំនួនទៀត យុទ្ធនាការនៃការបំភិតបំភ័យអាចជាកត្តាមួយធ្ងន់ធ្ងរក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដើម្បីចាកចេញពីព្រោះមិនអាចស៊ូទ្រាំនឹងការយាយី ការបំភិតបំភ័យ អំពើហិង្សាការគំរាមបណ្តេញចេញ និង ភាពមិនច្បាស់យ៉ាងខ្លាំងអំពីអនាគតរបស់ពួកគេ។ ការពិតគឺថា ប្រសិនបើក្រុមហ៊ុនបានផ្តល់ដំណោះស្រាយត្រឹមត្រូវពិតប្រាកដដល់អ្នកភូមិ ហើយពួកគេមានឆន្ទៈបោះបង់សិទ្ធិរស់នៅលើសហគមន៍ដីក្រហម ដោយស្ម័គ្រចិត្តទាំងស្រុងនោះ យុទ្ធនាការនៃការបំភិតបំភ័យនឹងមិនចាំបាច់ប្រើប្រាស់ឡើយ។ ការផ្លាស់ទៅទីតាំងថ្មីនៅភូមិដំណាក់ត្រយឹង អាចជាការសមរម្យ និង អាចទទួលយកបានសម្រាប់អ្នកភូមិមួយចំនួននៅសហគមន៍ដីក្រហម ប៉ុន្តែសម្រាប់អ្នកផ្សេងទៀត តំបន់នោះនៅជាយរាជធានីភ្នំពេញ ដែលមានចម្ងាយ ២០ គីឡូម៉ែត្រពីលំនៅឋាន និងឆ្ងាយពីទីកន្លែងធ្វើការបច្ចុប្បន្នរបស់ពួកគេ ជាមូលហេតុដែលមិនអាចទទួលយកបានឡើយ។

ក្រោយទទួលស្គាល់បញ្ហានេះ ក្រុមហ៊ុនបានផ្តល់ជម្រើសមួយដល់អ្នកភូមិ ជម្រើសនោះគឺក្រុមហ៊ុននឹងទិញដីពួកគាត់ដោយផ្ទាល់ជំនួសឱ្យការផ្តល់ផ្ទះល្វែង នៅភូមិដំណាក់ត្រយឹង។ ប៉ុន្តែ តម្លៃដែលក្រុមហ៊ុនផ្តល់ឱ្យវាទាបជាងតម្លៃទីផ្សារឆ្ងាយពេកចំពោះដីតំបន់ទន្លេបាសាក់ ហើយដោយតម្លៃដីចេះតែកើនឡើងនៅប្រទេសកម្ពុជា តម្លៃនេះមិនអាចគ្រប់គ្រាន់ដើម្បីទិញដីផ្នែកណាមួយដែលប្រហាក់ប្រហែលគ្នានៅក្នុងរាជធានីភ្នំពេញបានឡើយ។ តម្លៃដែលក្រុមហ៊ុនហានទិញខុសៗគ្នា ប៉ុន្តែតម្លៃខ្ពស់បំផុតដែលក្រុមហ៊ុនហានទិញឱ្យអ្នកភូមិប្រហែល៧.៥០០ ដុល្លារអាមេរិក សម្រាប់ផ្ទះទំហំ៣២ម៉ែត្រការ៉េ (ឬស្មើនឹង ២៣៤ ដុល្លារអាមេរិក ក្នុង១ ម៉ែត្រការ៉េ) ដែលតម្លៃនេះទាបជាងតម្លៃទីផ្សារពាក់កណ្តាល។ នៅពេលនោះអ្នកតំណាងសហគមន៍បានឱ្យដឹងថា មានអ្នកភូមិចំនួន២៨០គ្រួសារដែលបដិសេធដំណោះស្រាយរបស់ក្រុមហ៊ុន។ ពួកគេបន្តស្វែងរកដំណោះស្រាយមួយប្រកបដោយយុត្តិធម៌ និងត្រឹមត្រូវអាចទទួលយកបានសម្រាប់ខ្លួនលើបញ្ហាទំនាស់ដីធ្លីនេះ។ ពួកគាត់ចង់បានដំណោះស្រាយមួយដែលអនុញ្ញាតឱ្យពួកគេនៅនឹងកន្លែង ប៉ុន្តែប្រសិនបើដំណោះស្រាយនេះមិនអាចធ្វើទៅបានទេ នោះយ៉ាងហោចណាស់ក៏បានទទួលសំណងជាប្រាក់ដោយត្រឹមត្រូវ និងសមរម្យសម្រាប់ទ្រព្យសម្បត្តិរបស់ពួកគេ។ ក្រោយការចរចារវាងប្រជាពលរដ្ឋសហគមន៍ដីក្រហម ក្រុមហ៊ុន និងសាលារាជធានី រហូតដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ ក្រុមហ៊ុនបើកឱ្យមួយថ្ងៃ ដើម្បីទិញដីពីសហគមន៍តម្លៃពីរម៉ឺនដុល្លាសហរដ្ឋអាមេរិក បើសហគមន៍យល់ព្រមចេញ។ មានគ្រួសារចំនួន៨បានមកក្រុមហ៊ុនដើម្បីទទួលបានការទូទាត់សងជាទឹកប្រាក់ ចំណែកគ្រួសារខ្លះទៀតក៏បានមកដែរ តែក្រោយថ្ងៃកំណត់ដែលធ្វើឱ្យក្រុមហ៊ុនបដិសេធមិនធ្វើការទូទាត់សង។

ចុងបញ្ចប់អ្នកភូមិដីក្រហមត្រូវបានបណ្តេញចេញពីលំនៅឋានដោយបង្ខំ ពីសំណាក់សាលារាជធានីភ្នំពេញ និងក្រុមហ៊ុន នៅថ្ងៃសៅរ៍ទី២៤ ខែមករា ឆ្នាំ២០០៩។ ការបណ្តេញចេញចាប់ផ្តើមធ្វើពីម៉ោង២ព្រឹកព្រលឹម ដោយបិតផ្លូវមិនឱ្យចេញចូលទីនោះ។ ក្រុមកម្មករចំនួនប្រហែល ៥០០ (ប្រាំរយ)នាក់ត្រូវបានជួលដោយក្រុមហ៊ុនឯកជនបំពាក់ទៅដោយអាវយឺតដៃខ្លីពណ៌ចំរុះ និងការពារ

ដោយនគរបាល និង កងរាជអាវុធហត្ថចំនួនជាង៣០០ (បីរយ) នាក់ប្រកបដោយអាវុធជាតិផ្ទុះ ខែល ការពារ ដំបង និងតំណាងអាជ្ញាធរដែលបានត្រៀមទុកជាស្រេច[៣៨៦]។ នៅម៉ោង៦ព្រឹកចាប់ផ្តើមរុះរើ កំទេចចោល ហើយកិច្ចប្រតិបត្តិការចប់នៅម៉ោង១២ថ្ងៃត្រង់ថ្ងៃអាទិត្យ ទី០១ ខែកុម្ភៈ ឆ្នាំ២០០៩។ គ្រួសារចំនួន៣៣៥ ត្រូវបង្ខំឱ្យចាកចេញទៅរស់នៅភូមិតំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ជាលទ្ធផលមានមនុស្សរងរបួសចំនួន១៧នាក់ ក្នុងនោះមានរបួសធ្ងន់ចំនួន៥នាក់។ ទ្រព្យសម្បត្តិជាច្រើនត្រូវបំផ្លាញ និងកំទេចចោល។ សកម្មភាពទាំងនេះតាមទស្សនៈរបស់លោក ម៉ាន់ ឈឿន អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញបានលើកឡើងថា៖

> "សកម្មភាពរុះរើផ្ទះ....គឺមិនមែនជាការបណ្តេញចេញនោះទេ ប៉ុន្តែវាគឺជាកិច្ចខិតខំប្រឹងប្រែងមួយដើម្បីសំអាតទីកន្លែងសម្រាប់អភិវឌ្ឍន៍"[៣៨៧]។

## ៤.១.២ ការវិភាគផ្លូវច្បាប់

នៅតំបន់សហគមន៍ដីក្រហម ជាបញ្ហាចោទមានការលំបាកយ៉ាងខ្លាំងនោះ វាជាកម្មសិទ្ធិដីធ្លីដែលអ្នកភូមិបានកាន់កាប់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ តែមិនត្រូវបានគេកំណត់ឱ្យបានច្បាស់លាស់នៅឡើយទេ។ ការវិភាគផ្លូវច្បាប់ចំពោះករណីនេះមានការយល់ឃើញផ្សេងៗគ្នានៅតំបន់ដីក្រហមនេះ។ ជាការគួរឱ្យចាប់អារម្មណ៍ដោយកត់សម្គាល់ថា ពីជ្រុងណាមួយក៏បានដែលយើងជ្រើសរើសយកមកវិភាគលើករណីនេះវាហាក់បីដូចជាថា ការដោះដូរដីធ្លីដែលបានកើតឡើងតាមទស្សនៈនីមួយៗវាផ្ទុយនឹងបទប្បញ្ញត្តិច្បាប់នានា។

### សម្បទានដីសង្គមកិច្ច

ផ្អែកតាមលិខិតលេខ ៨៧៥ សជណ របស់ទីស្តីការគណៈរដ្ឋមន្ត្រីចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៣ រដ្ឋាភិបាលបានប្រគល់ជូនសហគមន៍ដីក្រហមលើដីដែលពួកគេកំពុងរស់នៅ ជាដីសម្បទានសង្គមកិច្ច។ ទោះបីជាឯកសារនេះពុំបានចងកាតព្វកិច្ចខាងផ្លូវច្បាប់ ឬពុំមានប្រសិទ្ធភាពខាងផ្លូវច្បាប់ភ្លាមក៏ដោយក៏ឯកសារនេះ ត្រូវបានផ្តល់នូវអំណាចនយោបាយដ៏ខ្ពស់មួយរួចទៅហើយ។ ហេតុដូច្នេះផែនការអភិវឌ្ឍនេះ បង្ហាញឱ្យឃើញនូវចេតនារបស់រាជរដ្ឋាភិបាលចំពោះសហគមន៍ដីក្រហម ក្នុងការផ្តល់ដីសម្បទានសង្គមកិច្ចជូនដល់សហគមន៍នេះ។ តាមច្បាប់ភូមិបាលឆ្នាំ២០០១(មាត្រា៥១) បានបើកសិទ្ធិឱ្យមានដីសម្បទានដែលឆ្លើយតបទៅនឹងផលប្រយោជន៍សង្គម ហើយដែលសម្បទានដីនេះជាសិទ្ធិស្របច្បាប់ដែលមានចែងក្នុងឯកសារគតិយុត្តចេញដោយអាជ្ញាធរមានសមត្ថកិច្ច តាមអំណាចឆន្ទានុសិទ្ធិទៅឱ្យរូបវន្ត ឬនីតិបុគ្គល ឬក្រុមមនុស្សដើម្បីកាន់កាប់ដី និងប្រើប្រាស់សិទ្ធិលើដីនោះតាមការកំណត់នៃច្បាប់។ ឯកសារគតិយុត្តនេះមិនទាន់បានចេញនៅឡើយទេ។ ទោះបីជាយ៉ាងណាក៏គេអាចចាត់ទុកផែនការអភិវឌ្ឍ ជាសក្ខីកម្មដ៏រឹងមាំមួយនៃគោលនយោបាយរបស់រដ្ឋាភិបាលចំពោះសហគមន៍នេះ។ ម៉្យាងវិញទៀត សេចក្តីសម្រេចផ្តល់សម្បទានដីសង្គមកិច្ចធ្វើឡើងដោយមន្ត្រីដែល

---

[៣៨៦] Ryan Schlief: ***Without Worning, Bulldozers enter Deykraham***, joint press release; Civil Society Groups Strongly Condemn Illegal Eviction of Dey Kraham, Phnom Penh, Cambodia. <http://hub.witness.org/en/node/11909>; accessed on July26, 2010

[៣៨៧] Cambodian League for the Promotion and Defense of Human Rights, (LICADHO): ***Land Grabbing & Poverty in Cambodia: the Myth of Development***, Phnom Penh, 2009, page on cover.

មានឋានានុក្រមថ្នាក់កំពូល ។ ជានិច្ចជាកាល តំណាងសហគមន៍ និង អ្នកភូមិទាំងឡាយបានអំពាវនាវម្តងហើយម្តងទៀតដល់សម្តេចនាយករដ្ឋមន្ត្រី ឱ្យដោះស្រាយករណីនេះដោយផ្ទាល់ និងសុំអនុញ្ញាតឱ្យពួកគាត់បន្តរស់នៅលើដីរបស់ខ្លួន និងបែងចែកជាមួយក្រុមហ៊ុន។

ឯកសារជាច្រើនបង្ហាញថា សាលារាជធានីភ្នំពេញបានចាត់ទុកឯកសារនេះថា មានអំណាចផ្តាច់មុខ ពីព្រោះកាលពីខែកញ្ញា ឆ្នាំ ២០០៤ ខ្លួនបានចេញរបាយការណ៍មួយ មានចំណងជើងថា របាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំការអភិវឌ្ឍនៅនឹងកន្លែងនៅតំបន់សហគមន៍ដីក្រហម។ នៅក្នុងរបាយការណ៍នោះសាលារាជធានី បានទទួលស្គាល់សហគមន៍ដីក្រហមថា បានទទួលគោលនយោបាយពីសម្តេច ហ៊ុន សែន ព្រមទាំងត្រូវបានលោកអនុញ្ញាតឱ្យធ្វើការអភិវឌ្ឍនៅនឹងកន្លែង ហើយនៅពេលជាមួយគ្នានេះដែរ ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញលិខិតអនុញ្ញាត ជាគោលការណ៍ឱ្យសាលារាជធានីភ្នំពេញចាត់ចែងដីសម្បទានសង្គមកិច្ចនេះ។ លើសពីនេះទៅទៀតសាលារាជធានីបានប្រកាសបន្តដោយចេញលិខិតលេខ២៥៤ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ដើម្បីជំរុញឱ្យមានការអនុវត្តគោលនយោបាយខាងលើប្រកបដោយប្រសិទ្ធភាព។ ចុងក្រោយបានកំណត់ឯកសារពីការគណនាឡើងវិញទៅលើទំហំផ្ទៃដីសរុបទាំងមូលនៅតំបន់ដីក្រហមតាមការវាស់វែងសាជាថ្មី។ នៅពេលបានជ្រាបពីទំហំដីដែលបានវាស់មានទំហំតូចជាងការគិតពីដំបូង អភិបាលរាជធានីបានមានប្រសាសន៍ថា ទំហំដីដែលមានពិតប្រាកដនឹងត្រូវផ្តល់ជូនសហគមន៍ ដោយគ្មានការរឹបអូសយកផ្នែកណាមួយទុកជាសម្បត្តិរដ្ឋឡើយ។

វិធានការដែលសាលារាជធានីបានចាត់ឡើង ក៏ដូចជាសេចក្តីថ្លែងការណ៍របស់ខ្លួនទំនងជាបញ្ជាក់ថា ដីសហគមន៍ដីក្រហមត្រូវបានចាត់ទុកដោយភាគីពាក់ព័ន្ធទាំងអស់ជាដីសម្បទានសង្គមកិច្ច និងបញ្ជាក់អំពីគោលនយោបាយនានា ដែលបានដាក់ចេញនៅក្នុងផែនការអភិវឌ្ឍដែលរៀបចំឡើងកាលពីខែកក្កដា ឆ្នាំ២០០៣ ត្រូវបានអនុវត្ត ហើយអំណាចនយោបាយជាន់ខ្ពស់ត្រូវបានផ្តល់ជូនផងដែរ។ ប៉ុន្តែចាប់ពីពេលនោះមក សាលារាជធានីពុំបានអនុវត្តផែនការនោះឡើយ។ ផ្ទុយទៅវិញដីនោះមិនបានដល់ដៃសហគមន៍ បែរជាប្រែក្លាយដីនោះទៅជាកម្មសិទ្ធិរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ឯកជនដោយមានការគាំទ្រយ៉ាងសកម្មពីមន្ត្រីមួយចំនួន។ នេះជាកង្វះខាតយ៉ាងជាក់ស្តែងមួយរបស់អាជ្ញាធរក្នុងការអនុវត្តការអភិវឌ្ឍនៅនឹងកន្លែងឱ្យបានសម្រេច ចំពោះសហគមន៍ដីក្រហមនេះតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ច។

**ទ្រព្យឯកជនរបស់រដ្ឋ**

តំបន់សហគមន៍ដីក្រហមជាទ្រព្យឯកជនរបស់រដ្ឋ នៅពេលជាមួយគ្នានេះដោយយល់ឃើញថា ឯកសារគតិយុត្ត ដូចបានលើកឡើងខាងលើដែលបញ្ជាក់អំពីតំបន់ដីក្រហមជាដីសម្បទានសង្គមកិច្ច មិនទាន់ត្រូវបានចេញនៅពេលចុះហត្ថលេខាលើកិច្ចសន្យារវាងអតីតអ្នកតំណាងសហគមន៍ និងក្រុមហ៊ុន គេអាចសន្និដ្ឋានបានថា សហគមន៍ដីក្រហមមិនដែលត្រូវបានគេប្តូរឱ្យទៅជាដីសម្បទានសង្គមកិច្ចត្រឹមត្រូវនោះទេ។ ផ្ទុយទៅវិញ គឺជាដីឯកជនរបស់រដ្ឋ ហើយការពិតវានៅតែជាដីឯកជនរបស់រដ្ឋ។ ពិតណាស់ ច្បាប់ភូមិបាលគាំទ្រជំហរនេះ ដោយចែងថា សម្បទានដីអាចធ្វើឡើងបានតែនៅលើដីជាចំណែកនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ(មាត្រា៥៨ច្បាប់ភូមិបាល)។ ម៉្យាងទៀតប្រសិនបើ សហគមន៍

ដីក្រហមមិនមែនជាដីឯកជនរបស់រដ្ឋទេនោះ គេក៏មិនអាចចាត់ទុកវាជាដីសម្បទានសង្គមកិច្ចបានដែរ ទោះបីជាឋានៈដីនោះ ត្រូវបានកំណត់យ៉ាងច្បាស់ដោយច្បាប់ថាជាដីសម្បទានសង្គមកិច្ចក៏ដោយ។ មុនពេលតំបន់សហគមន៍ដីក្រហមត្រូវបានប្រើប្រាស់ក៏បញ្ជាក់ផងដែរ អំពីឋានៈដីនេះ ពីព្រោះគ្មានកំណត់ហេតុដីធ្លី ឬក៏បានចុះបញ្ជីកំណត់ថា ជាដីសាធារណៈរបស់រដ្ឋតាមច្បាប់ភូមិបាលឡើយ។ (មាត្រា១៥ និងមាត្រា២៣៨ ច្បាប់ភូមិបាល)។

## សិទ្ធិភោគលើៈដីធ្លី

ច្បាប់ភូមិបាលអនុញ្ញាតឱ្យប្រជាពលរដ្ឋរស់នៅលើអចលនទ្រព្យឯកជនរបស់រដ្ឋដើម្បីអាស្រ័យផលតាមបែបភោគៈនៅលើអចលទ្រព្យរបស់ខ្លួន ដែលក្រោយមកអាចក្លាយជាកម្មសិទ្ធិពេញលេញ[៣៩៨]។ ដើម្បីទទួលបានជាកម្មសិទ្ធិ ភោគីត្រូវតែរស់នៅលើអចលនទ្រព្យរបស់ខ្លួនរយៈពេលយ៉ាងតិច៥ឆ្នាំ ក្រោយច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវបានប្រកាសឱ្យប្រើជាធរមាន។ លើសពីនេះទៅទៀត ភោគៈនោះត្រូវតែរស់នៅដោយ ពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន និងដោយសុចរិត។ ប្រជាពលរដ្ឋនៅតំបន់ដីក្រហមបានបំពេញតាមលក្ខខណ្ឌទាំងអស់នេះរួចហើយ។ សៀវភៅគ្រួសារនៅតំបន់សហគមន៍ដីក្រហមផ្តល់ភស្តុតាងគ្រប់គ្រាន់ ចំពោះការរស់នៅរបស់ពួកគាត់នៅតំបន់ដីក្រហម ហើយបញ្ជាក់ច្បាស់អំពីសិទ្ធិភោគៈរបស់ខ្លួននៅលើដីនោះ។

ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៥ ចែងថា គ្មានបុគ្គលណាម្នាក់ត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះ មិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ជា បន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។ តាមអ្នកភូមិបានឱ្យដឹងថា លក្ខខណ្ឌផ្តល់សំណងដោយសមរម្យ និងយុត្តិធម៌មិនទំនងជាត្រូវបានបំពេញនោះឡើយ។ តាមការប្រៀបធៀបមួយដោយក្រុមហ៊ុនអចលនទ្រព្យ ប៊ុណ្ណា រៀលធីគ្រុប បានវាយតម្លៃដីកាលពីនាពេលនោះថា ដីនោះមានតម្លៃលើសពី ១.០០០ដុល្លាសហរដ្ឋអាមេរិកក្នុងមួយម៉ែត្រការ៉េ។ អ្នកភូមិសហគមន៍ដីក្រហមកាលនោះ ត្រូវបានផ្តល់តម្លៃប្រហែលជា ២៣៤ ដុល្លាអាមេរិក ក្នុងមួយម៉ែត្រការ៉េតែប៉ុណ្ណោះ។ ជាក់ស្តែងការដកហូតដីធ្លីនេះ មិនមែនដើម្បីផលប្រយោជន៍សាធារណៈនោះទេគឺដើម្បីផលប្រយោជន៍បុគ្គលឯកជនសុទ្ធសាធ។ ការណ៍នេះជាកំហុសផ្នែកច្បាប់ដ៏ធ្ងន់ធ្ងរមួយ ដែលរំលោភទៅលើមិនត្រឹមតែច្បាប់ភូមិបាលប៉ុណ្ណោះទេ ថែមទាំងទៅលើរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ អំពីការធានាការពារកម្មសិទ្ធិពីការដកហូតមិនស្របច្បាប់ណាមួយ(មាត្រា៤៤នៃរដ្ឋធម្មនុញ្ញ)។

## អសុពលភាពនៃកិច្ចសន្យា

ជាគោលការណ៍កិច្ចសន្យា ត្រូវធ្វើឡើងដោយបុគ្គលដែលមានសមត្ថភាព ទើបស្របច្បាប់។ ផ្ទុយទៅវិញ បើធ្វើឡើងដោយបុគ្គលគ្មានសមត្ថភាព វានាំឱ្យកិច្ចសន្យានោះត្រូវមោឃភាព។ ករណីសហគមន៍ដីក្រហម កិច្ចសន្យាត្រូវបានចុះហត្ថលេខាដោយបុគ្គលគ្មានសមត្ថភាព ពីព្រោះករណីសហគមន៍ដីក្រហមនេះ សមាជិក និងតំណាងសហគមន៍ទាំងអស់មិនបានយល់ព្រមជាលាយលក្ខណ៍

---

[៣៩៨] ព្រះរាជក្រមលេខ នស រកម ០៨០១ ១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ***ច្បាប់ភូមិបាល***៖មាត្រា ៣៨ និងមាត្រា៦២ ក្រឹត្យច្បាប់លេខ១០០ក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ ស្តីពី ច្បាប់ភូមិបាល ។

អក្សរជាមុន។ កត្តាជាច្រើននៃច្បាប់កិច្ចសន្យាគាំទ្រដំហរនេះ ហេតុដូច្នេះហើយ ក៏ជំទាស់នឹងនីត្យានុកូលភាពនៃកិច្ចសន្យា ដែលអតីតអ្នកតំណាងចាស់សហគមន៍ និង ក្រុមហ៊ុនបានចុះហត្ថលេខា។ ក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យាមានត្រា១ចែងថា កិច្ចសន្យាគឺជាឆន្ទៈព្រមព្រៀងរវាងបុគ្គល២នាក់ ឬច្រើននាក់ ដើម្បីបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចមួយ ឬច្រើនដែលទាក់ទិននឹងខ្លួន។ តាមនិយមន័យនេះ បុគ្គលអាចជារូបវន្តបុគ្គល ឬ ជានីតិបុគ្គលអាចធ្វើកិច្ចសន្យាតាមរយៈបុគ្គលដែលជាតំណាងរបស់ខ្លួនបាន។ បន្ថែមលើនេះទៀត កិច្ចសន្យាមួយអាចយកជាការបានលុះត្រាតែ ធ្វើឡើងដោយបុគ្គល ទាំងឡាយដែលមានសមត្ថភាពចុះកិច្ចសន្យា(មាត្រា៣)។ បញ្ហាចំពោះសហគមន៍ដីក្រហម គឺត្រូវរកឱ្យឃើញថា តើអតីតអ្នកតំណាងសហគមន៍ ដែលបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៥ ក្នុងនាមសហគមន៍នោះ បានទទួលការអនុញ្ញាតត្រឹមត្រូវឱ្យមានសិទ្ធិធ្វើដូច្នេះដែរឬទេ?។

តាមអ្នកតំណាងសហគមន៍ក្រោយពេលបានចុះកិច្ចសន្យាថា សហគមន៍មិនដែលត្រូវបានសាកសួរយោបល់អំពីកិច្ចសន្យា ឬ អំពីឆន្ទៈក្នុងការដោះដូរដីធ្លី ដើម្បីជាថ្នូរចាកចេញទៅរស់នៅកន្លែងមួយនៅក្រៅរាជធានីភ្នំពេញឡើយ។ ដូច្នេះអ្នកតំណាងមិនមានលិខិតអនុញ្ញាតដោយមានហត្ថលេខាយល់ព្រមពីប្រជាពលរដ្ឋនោះឡើយ។ ពួកគាត់ក៏មិនបានយល់ព្រមចាកចេញពីកន្លែងបច្ចុប្បន្នផងដែរ។ ជាភស្តុតាងសហគមន៍មិនដែលយល់ព្រមលើការដោះដូរដីធ្លីនេះ មានឯកសារមួយចេញនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៥ ក្នុងឯកសារនោះ តំណាងសហគមន៍ដែលត្រូវបានតែងតាំងថ្មី បានជម្រាបលោកតំណាងរាស្ត្រ ហូរ វ៉ាន់ អំពីលិខិតតវ៉ា ដែលពួកគាត់បានដាក់ជូននៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥។ លិខិតតវ៉ានោះធ្វើឡើងដោយប្រជាពលរដ្ឋចំនួន៨០៤ គ្រួសារ ភ្ជាប់ជាមួយស្នាមមេដៃប្រជាពលរដ្ឋទាំងនោះនឹងលិខិតតវ៉ាដែលបានដាក់ជូនសាលារាជធានីភ្នំពេញ និងលិខិតដែលបានផ្ញើជូនតំណាងរាស្ត្រ ហូរ វ៉ាន់។ ហេតុការណ៍នោះ សហគមន៍ធ្វើការតវ៉ាភ្លាមៗ បន្ទាប់ពីពួកគាត់បានទទួលដំណឹងអំពីកិច្ចសន្យាដោះដូរដីធ្លីដែលនេះជាការបង្ហាញឱ្យឃើញថា ពួកគាត់មិនមានឆន្ទៈក្នុងការធ្វើជាភាគីមួយនៃកិច្ចសន្យាបែបនោះឡើយ។

ប្រសិនបើ កិច្ចសន្យាពិតជាត្រូវបានចុះហត្ថលេខាដោយអតីតអ្នកតំណាង ដែលអ្នកភូមិមិនបានអនុញ្ញាតឱ្យធ្វើដូច្នេះមែន កិច្ចសន្យានោះត្រូវទុកជាមោឃយោងតាមលក្ខខណ្ឌទាំងឡាយនៃច្បាប់កិច្ចសន្យាដែលថា "កិច្ចសន្យាទាំងឡាយណា ដែលមិនបានធ្វើតាមទម្រង់ដែលច្បាប់បានកំណត់ត្រូវទុកជាមោឃ"(មាត្រា៤)។ ចំណែកមាត្រា ៦ ចែងអំពីកិច្ចសន្យាដូចតទៅត្រូវចាត់ទុកជាមោឃនៅពេលដែល៖ (១) កិច្ចសន្យានោះមិនកើតចេញពីការព្រមព្រៀងដោយពិតប្រាកដ ឬសេរី (២) កិច្ចសន្យានោះកើតចេញពីបុគ្គលគ្មានសមត្ថភាពចុះកិច្ចសន្យា។ លើសពីនេះទៀត មិនអាចចាត់ទុកថាមានការព្រមព្រៀងត្រឹមត្រូវទេ កាលណាការព្រមព្រៀងនោះធ្វើឡើងដោយការភាន់ច្រឡំ ដោយមានហិង្សា ឬ ដោយការបន្លំបោកប្រាស់(មាត្រា៧)។ ដោយសារតែមានការគាបសង្កត់លើអ្នកភូមិនៅតំបន់ដីក្រហមឱ្យទទួលយកកិច្ចសន្យា និងប្រគល់ដីពួកគាត់ទៅឱ្យក្រុមហ៊ុន គឺផ្ទុយនឹងច្បាប់កិច្ចសន្យាដែលចែងថា ហិង្សា និង ទៅជាមូលហេតុមោឃភាពនៃកិច្ចសន្យាបាន កាលណាហិង្សានោះជាការ

គំរាមកំហែង បង្ខិតបង្ខំតាមផ្លូវកាយ ឬ ផ្លូវចិត្ត ប្រព្រឹត្តទៅលើភាគីណាមួយប្តី ប្រពន្ធ បុព្វញាតិ ឬ បច្ឆាញាតិណាមួយរបស់ភាគីនោះ(មាត្រា៧)។

**សិទ្ធិរបស់គ្រួសារទទួលសម្បទានដីសង្គមកិច្ច**

ការវិភាគផ្លូវច្បាប់មួយទៀត បើសិនជាសហគមន៍ដីក្រហមមិនអាចត្រូវបានចាត់ទុកជាដីសម្បទានសង្គមកិច្ចដោយត្រឹមត្រូវតាមច្បាប់ទេនោះ មុខសញ្ញាអ្នកទទួលដី ក៏គ្មានសិទ្ធិអាចលក់ដូរ ជួល ឬ ធ្វើអំណោយ ដីសម្បទានសង្គមកិច្ចក្នុងរយៈពេល៥ឆ្នាំ ដំបូងនៃការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនេះទេ[៣៨៩]។ ប្រសិនបើមុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ចណាខកខានមិនបានបំពេញតាមលក្ខខណ្ឌនៃការកាន់កាប់ និងប្រើប្រាស់ដីសម្បទាននោះ ដីនេះនឹងត្រូវវិលមកជាដីរបស់រដ្ឋវិញដើម្បីធ្វើការបែងចែកសាជាថ្មី។ ហេតុដូច្នេះ អតីតអ្នកតំណាងសហគមន៍មិនមានសិទ្ធិក្នុងការផ្ទេរដីតាមកិច្ចសន្យាជាមួយក្រុមហ៊ុនឡើយ។ ចំពោះហេតុផលទាំងអស់នេះ វាកាន់តែច្បាស់ណាស់ថា តាមច្បាប់កិច្ចសន្យារវាងក្រុមហ៊ុន និងអតីតអ្នកតំណាងសហគមន៍មិនមានសុពលភាពឡើយ។ ផ្អែកតាមស្មារតីនៃច្បាប់ករណីសហគមន៍ដីក្រហម ក្រុមហ៊ុនមិនអាចប៉ះពាល់ដីនេះបានឡើយ លុះត្រាតែមុខសញ្ញាទទួលដីរស់នៅតាមច្បាប់រយៈពេល៥ឆ្នាំ ជាមុនសិន ហើយក្រោយពួកគេទទួលបានកម្មសិទ្ធិ ទើបក្រុមហ៊ុនអាចទិញ ឬដូរ ដីនោះដោយស្របច្បាប់ទៅបាន។ ខាងក្រោមនេះជាឯកសារគំរូសម្រាប់បញ្ជាក់ចំពោះគោលការណ៍នៃសម្បទានដីសង្គមកិច្ចមានលក្ខខណ្ឌច្បាស់លាស់ និងបានអនុវត្តដោយសាលារាជធានីភ្នំពេញនាពេលកន្លងមក៖

[៣៨៩] អនុក្រឹត្យ លេខ ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៣ ស្តីពី ***សម្បទានដីសង្គមកិច្ច*** ៖ មាត្រា១៨។

រូបភាពទី១៤ បណ្ណទទួលដីសម្បទានសង្គមកិច្ច



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាក្រុងភ្នំពេញ

សាលាខណ្ឌដង្កោ

សង្កាត់ត្រពាំងក្រសាំង

លេខ [redacted]

បណ្ណទទួលស្គាល់ម្ចាស់ដីឡូតិ៍

ឈ្មោះ [redacted] ភេទ [redacted] អាយុ [redacted] ឆ្នាំ សញ្ជាតិ [redacted] និងនាង [redacted] អាយុ [redacted] សញ្ជាតិ [redacted]

កន្លងមកស្នាក់នៅភូមិ... សង្កាត់... ខណ្ឌ... រាជធានីភ្នំពេញ [redacted] ។

បច្ចុប្បន្នបានទទួលដីឡូតិ៍លេខ [redacted] នៅភូមិត្រពាំងអញ្ចាញ ៤ សង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

កំណត់សំគាល់ :

១- យោងអនុក្រឹត្យលេខ ១៩ អ.ន.ក្រ.បក ចុះថ្ងៃទី១៩ ខែ មិនា ឆ្នាំ ២០០៣ ស្តីពីដីសម្បទានសង្គមកិច្ច បណ្ណនេះហាមលក់ដូរ ដាក់បញ្ចាំ ផ្ទេរសិទ្ធិ ឬធ្វើអំណោយឱ្យអ្នកដទៃក្នុងរយៈពេល ០៥ឆ្នាំ គិតចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...

២- ក្នុងករណីល្មើសនឹងចំណុចទី១ ខាងលើ សាលាក្រុងភ្នំពេញនឹងដកហូតយកដីនោះវិញ ដោយគ្មានសំណង ។

៣- ផុតរយៈពេល ០៥ឆ្នាំ រដ្ឋនឹងចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ជូនម្ចាស់កាន់កាប់ដើម្បីប្រើប្រាស់តទៅ ។

៤- ជនណាដែលប្រើប្រាស់បណ្ណនេះខុសគោលដៅ និងត្រូវទទួលទោសតាមច្បាប់កំណត់ ។

ភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០០...

បានឃើញ ចៅសង្កាត់ | បានឃើញ ប្រធានភូមិ | ស្នាមមេដៃអ្នកទទួលដីឡូតិ៍

ការវិភាគមួយផ្លូវទៀតតាមច្បាប់ភូមិបាលមាត្រា៦៦ "អំពីបុគ្គលដែលមានសមត្ថភាពក្នុងការលក់ ឬទិញទ្រព្យ អចលនវត្ថុបាន លុះត្រាតែបុគ្គលនោះពិតជាកម្មសិទ្ធិករនៃទ្រព្យដែលលក់នោះ"។ តែផ្ទុយទៅវិញ ករណីសហគមន៍ដីក្រហម អតីតតំណាងសហគមន៍មិនមែនជាកម្មសិទ្ធិករនៃដីទាំងនោះទេ។ ម៉្យាងវិញទៀត ច្បាប់បានកំណត់ថា ករណីមានការដេកហូតអចលនវត្ថុដោយហិង្សា ឬការប្រើអំណាចដោយរំលោភរបស់អាជ្ញាធរ អចលនវត្ថុនោះត្រូវបង្វិលមករដ្ឋវិញ ហើយមិនអាចជាកម្មវត្ថុនៃការកាន់កាប់ថ្មីបានឡើយ(មាត្រា៣៣)។ ដូចយើងបានវិភាគករណីសហគមន៍ដីក្រហមនេះប្រជាពលរដ្ឋជាភាគីស្របច្បាប់ ដូច្នេះពួកគេមានសិទ្ធិទាមទារដីនោះយកមកវិញ។ ចំណែកក្រុមហ៊ុនគ្មានករណីណាតាមផ្លូវច្បាប់ដែលអាចទាមទារដីនោះយកធ្វើជាកម្មសិទ្ធិបានទេ។

## និទណ្ឌភាព

ករណីបណ្ដេញចេញនៅសហគមន៍ដីក្រហមជាប់ពាក់ព័ន្ធជាមួយនគរបាល កងរាជអាវុធហត្ថ តំណាងក្រុមហ៊ុន និងតំណាងអាជ្ញាធររាជធានីភ្នំពេញ។ ការបណ្ដេញចេញធ្វើឡើងដោយប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ទោះបីជាមិនទាន់មានប័ណ្ណ ឬកំពុងមានទំនាស់ក៏ដោយគឺមិនស្របនឹងច្បាប់ឡើយ ផ្អែកតាមមាត្រា២៥៣នៃច្បាប់ភូមិបាល។ ទង្វើនេះជាអំពើខុសច្បាប់ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ ចំណែកអ្នកប្រព្រឹត្តដោយផ្ទាល់ត្រូវទទួលខុសត្រូវចំពោះសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះទៀតផង។ អ្នកបញ្ជាលើបញ្ហានេះ ក៏ត្រូវទទួលការផ្តន្ទាទោស ដូចអ្នកប្រព្រឹត្តអំពើហិង្សាដោយផ្ទាល់ដែរ។ ទាក់ទងការប្រើកម្លាំងឯកជនគឺផ្ទុយនឹងច្បាប់ភូមិបាលមាត្រា២៥៤ ដែលថា "គ្មានករណីណាមួយ ដែលអនុញ្ញាតឱ្យប្រើប្រាស់កម្លាំងឯកជនដើម្បីធានាចំពោះការគោរពប័ណ្ណកម្មសិទ្ធិក្នុងការបណ្ដេញចេញបានឡើយ"។ ទង្វើនេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធជានាគារថែមទៀតផង។

ចំណែកមន្ត្រីសុរិយោដីចេញប័ណ្ណកម្មសិទ្ធិឱ្យក្រុមហ៊ុនលើដីកំពុងមានទំនាស់ វាផ្ទុយទៅនឹងច្បាប់។ ប័ណ្ណកម្មសិទ្ធិអាចចេញបានតែទៅលើដីណាដែលគ្មានទំនាស់។ ករណីដីមានទំនាស់ត្រូវដោះស្រាយឱ្យចប់នីតិវិធី ក្រោយដឹងច្បាស់ថា អ្នកណាជាម្ចាស់ពិតប្រាកដ ទើបអាចចេញប័ណ្ណកម្មសិទ្ធិបាន។ ការចេញប័ណ្ណកម្មសិទ្ធិ ករណីតំបន់ដីក្រហមមិនស្របតាមច្បាប់ភូមិបាលឡើយ តាមមាត្រា ២៤៨ ទង្វើបែបនេះខុសច្បាប់ ហើយជាកម្មវត្ថុនៃបទល្មើសព្រហ្មទណ្ឌ អំពីការបំប្លែងពីសម្បទានមកកម្មសិទ្ធិ។ ម្យ៉ាងទៀតផ្អែកមាត្រា២៦១ ចែងពីការកសាងប័ណ្ណដោយបំពានដើម្បីបណ្ដេញចេញធ្វើឡើងចំពោះអ្នកកាន់កាប់អចលនវត្ថុ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារថែមទៀត។ ទោះបីជាយ៉ាងណា មិនមានបុគ្គលរំលោភសិទ្ធិណាម្នាក់ត្រូវបានទទួលទោសតាមច្បាប់ទោះផ្អែកតូចណាមួយក៏មិនមាន។

តាមផ្លូវច្បាប់ក្រុមហ៊ុនមានសិទ្ធិពេញលេញដើម្បីទិញដីប្រជាពលរដ្ឋ ចំណែកពលរដ្ឋវិញក៏មានសិទ្ធិក្នុងការលក់ ឬ មិនព្រមលក់ដីជាកម្មសិទ្ធិរបស់គេដែរ។ ករណីការអភិវឌ្ឍតំបន់ដីក្រហមត្រូវបានកំណត់ដកហូតដើម្បីជាផលប្រយោជន៍សាធារណៈនោះ ទាំងក្រុមហ៊ុន និងអាជ្ញាធរក្រុងមានសិទ្ធិក្នុងការធ្វើកិច្ចការនេះ។ សិទ្ធិកម្មសិទ្ធិត្រូវការពារដោយរដ្ឋធម្មនុញ្ញមាត្រា៤៤ និងមាត្រា៥ នៃច្បាប់ភូមិបាលពីសំណាក់ការបណ្ដេញចេញដោយមិនបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។ បើសិនជាគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុនដើម្បីផលប្រយោជន៍សាធារណៈ ក្រុមហ៊ុនអាចស្នើទិញដីនោះដោយសេរីមិនចាំបាច់បង្ខិតបង្ខំ និងបន្លំ ហើយសហគមន៍ពិតជាលក់ឱ្យយ៉ាងងាយ។ ទំនាស់ដីធ្លីនៅដីក្រហមបានបង្ហាញយ៉ាងច្បាស់ថា ដើម្បីអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវគឺពិតជាត្រូវការពារសុវត្ថិភាពនៃការកាន់កាប់ដីធ្លីដល់ប្រជាពលរដ្ឋ ជាពិសេសជនដែលងាយរងគ្រោះ។ រឿងនៅដីក្រហមមិនត្រូវបានគេទទួលស្គាល់សិទ្ធិភោគៈស្របតាមច្បាប់ភូមិបាលទេ។ សហគមន៍ត្រូវបណ្ដេញចេញទាំងបង្ខំដោយខុសច្បាប់ និង មិនទទួលស្គាល់សិទ្ធិស្របច្បាប់របស់ពួកគេ។ ការណ៍នេះ ធ្វើឱ្យអន្តរាយដល់សិទ្ធិស្របផ្លូវច្បាប់របស់ប្រជាពលរដ្ឋ។

## សរុបរឿង

ទំនាស់ដីធ្លីភាគច្រើនបណ្តាលមកពីប្រព័ន្ធនៃការគ្រប់គ្រងដីធ្លីនៅខ្សោយ។ ដីធ្លីដែលមិនច្បាស់ថាជាទ្រព្យសម្បត្តិសាធារណៈ ឬឯកជនរបស់រដ្ឋ ភាគច្រើនអាជ្ញាធរមានឋានៈខ្ពស់ និងអ្នកមានប្រាក់មួយចំនួនតូចកេងយកផលប្រយោជន៍ពីស្ថានភាពនោះ។ ភាគីទំនាស់ទាំងអស់មិនធ្វើទៅតាមច្បាប់ទេ គេតែងតែអនុវត្តទៅតាមទម្លាប់ជាជាងច្បាប់លើករណីមួយចំនួន ដូចជាការចាប់យកដីធ្លី និងដោះស្រាយទំនាស់។ ជាទូទៅក្នុងទំនាស់ដីធ្លីអ្នកក្រីក្រគ្មានអំណាច តែងតែចាញ់ភាគីដែលមានប្រាក់មានអំណាចជានិច្ច[៣៩០]។ កម្រឃើញអ្នកមានចាញ់ក្តី និងជួនកាលអ្នកមានឈ្នះក្តីលើវិវាទជាមួយរដ្ឋាភិបាលថែមទៀតផង។ ការណ៍នេះធ្វើឱ្យលោកនាយករដ្ឋមន្ត្រីបានលើកយកមកនិយាយជារឿយៗ។ មន្ត្រីដែលខិលខូចមួយចំនួនតែងនៅពីក្រោយខ្នងអ្នកមាន។ ករណីសហគមន៍ដីក្រហមការបណ្តេញចេញឬផ្លាស់ប្តូរលំនៅឋានការសងសំណងមានកម្រិតទាបពេក ភាគីមិនអាចទទួលយកបាន។ ក្រុមហ៊ុនខ្ចីដៃអាជ្ញាធរដើម្បីយកដី ដោយពួកគេផ្តល់ផលប្រយោជន៍ឱ្យអាជ្ញាធរ ជាជាងសងពេញថ្លៃទៅដល់សហគមន៍។

មន្ត្រីខិលខូចមួយចំនួន បានប្រើវិធីសាស្ត្របំបែកក្រុមភាគីម្ខាងដែលមានសំលេងភាគច្រើនក្នុងសហគមន៍ប្រកបដោយជោគជ័យ និងប្រើអ្នកកណ្តាលឱ្យធ្វើការជំនួសខ្លួនក្នុងការធ្វើលទ្ធកម្ម និងការចរចារ។ ការប្រើវិធីបែបនេះ ដើម្បីឱ្យកម្លាំងសហគមន៍ម្ខាងចុះខ្សោយតាមការបំបែករវាងអ្នកមាន និងអ្នកក្រ និងអ្នកមានអំណាច និងអ្នកគ្មានអំណាច។ ការណ៍នេះគឺបែបនៃទំនាក់ទំនងនាយចៅហ្វាយដែលធ្វើឱ្យក្រុមម្ខាងមានការពិបាកក្នុងការបន្តនូវភាពស្អិតរមួតដើម្បីតវ៉ា។ លទ្ធផលចុងក្រោយអ្នកដែលទទួលផលពីការអភិវឌ្ឍមានលក្ខណៈខុសៗគ្នា ដូចជាអ្នកខ្លះទទួលផលច្រើនកប់ក្តោង តែផ្ទុយទៅវិញមានអ្នកខ្លះទៀត រងគ្រោះរហូតដល់ជាប់ពន្ធនាគារ និងច្រើននាក់ទៀត ធ្លាក់ចូលទៅក្នុងអន្ទាក់នៃភាពក្រីក្រកាន់តែជ្រៅថែមទៀត។ ទង្វើទាំងនេះ វាផ្ទុយទៅនឹងគោលនយោបាយឈ្នះឈ្នះរបស់រាជរដ្ឋាភិបាល។ សូមមើលរូបភាពសង្ខេបលទ្ធផលនៃករណីសិក្សាខាងក្រោមជាភស្តុតាងបញ្ជាក់អំពីហេតុការណ៍ទាំងអស់នេះ។

[៣៩០] ការឆ្លើយសំណួរពីសំណាក់អ្នកយកព័ត៌មានទូរទស្សន៍ BBC របស់ជនរងគ្រោះពីការបណ្តេញចេញគឺ លោក ចាន់ វិចិត្រ អំឡុង ៣ ម៉ោង មុនលំនៅឋានរបស់គាត់ត្រូវបានរុះរើ និងកំទេចចោល។

រូបភាពទី១៥៖ អ្នកទទួលផលពីការអភិវឌ្ឍតំបន់សហគមន៍ដីក្រហម

| សមាជិកសហគមន៍ | តំណាងសហគមន៍ |
|---|---|
|  |  |
| ទីតាំងថ្មីខ្វះហេដ្ឋារចនាសម្ព័ន្ធ ទឹកស្អាត បង្គន់ សាលារៀន និងមន្ទីរពេទ្យ។ | ត្រូវចោទប្រកាន់បទឧក្រិដ្ឋ ផាកពិន័យ និងពីរករណីបានជាប់ពន្ធនាគាររយៈពេលយូរ។ |
| **សង្គមស៊ីវិញ** | **ក្រុមហ៊ុនអភិវឌ្ឍន៍** |
|  |  |
| សង្គមស៊ីវិលចំណាយថវិកាសរុបលើស ២៥,០០០ ដុល្លាអាមេរិកទៅលើការផ្តល់ស្បៀង និងជំនួយមនុស្សធម៌ដល់អ្នកត្រូវបណ្តេញចេញ។ | ដីដែលមានតម្លៃខ្ពស់នៅកណ្តាលរាជធានីភ្នំពេញ មានតម្លៃរវាង ៤៤-១៨០ លានដុល្លាអាមេរិក។ |

តាមរយៈករណីសិក្សានៃវិវាទដីធ្លីនៅតំបន់ដីក្រហមនេះមានភាពស្មុគស្មាញ ហើយវាក៏បានឆ្លុះបញ្ចាំងអំពីករណីវិវាទផ្សេងៗទៀតនៅកម្ពុជា។ ការវិភាគផ្លូវច្បាប់លើករណីនេះ នូវជ្រុងណាមួយក៏បាន ករណីវិវាទនេះជាការដោះដូរដីធ្លី ដែលបានកើតឡើងក្រោមរូបភាពផ្សេងៗគឺផ្ទុយនឹងច្បាប់។ ការអង្កេតស៊ីជម្រៅនៃករណីនេះ អាជ្ញាធរ និងអ្នកពាក់ព័ន្ធមួយចំនួន មានភាពលំអៀង។ ពេលខ្លះអាជ្ញាធរដើរតួជាភាគីទំនាស់ជំនួសក្រុមហ៊ុនឯកជន។ ការណ៍នេះ វាស្តែងឱ្យឃើញថា អាជ្ញាធរនៅមានភាពកម្សោយក្នុងការអនុវត្តច្បាប់ និង បទបញ្ជា។ ទោះបីជាបានប្រព្រឹត្តទង្វើខុសឆ្គងយ៉ាងណាក៏ដោយ មិនមានអ្នកណាម្នាក់ទទួលទោសកំហុសឡើយ ៕

# សន្និដ្ឋាន និងអនុសាសន៍

# សន្និដ្ឋាន និងអនុសាសន៍

និក្ខេបបទនេះ បានសិក្សាទៅលើស្ថានភាពដែលកើតឡើងជាក់ស្តែងទាក់ទងវិវាទដីធ្លី គោលនយោបាយ និង ក្របខ័ណ្ឌគតិយុត្ត ការអនុវត្តច្បាប់ និងការវិភាគលើការដោះស្រាយតាមរយៈករណីសិក្សាមួយ ដែលអាចធ្វើការឆ្លុះបញ្ចាំងទៅលើចំណុចទាំងអស់នេះ។ ដីមានសារសំខាន់សម្រាប់ប្រជាពលរដ្ឋដែលភាគច្រើនពឹងអាស្រ័យលើ ដោយតម្រូវការដីកើនឡើងជានិច្ច តែដីធ្លីនៅតែដដែល ដូច្នេះ វិវាទដីធ្លីនៅតែជាបញ្ហាក្តៅ និង រសើបសម្រាប់កម្ពុជាដែលមិនអាចជៀសវាងបាន។ ជាការពិតហេតុបណ្តាលឱ្យមានវិវាទដីធ្លី ដោយសារកត្តានយោបាយ កត្តាសេដ្ឋកិច្ច កត្តាប្រវត្តិសាស្ត្រ កត្តាសង្គម និងកង្វះចំណេះដឹងច្បាប់ដីធ្លីជាដើម។ វិវាទដីធ្លីបន្តកើនឡើង និង ក្លាយជាបញ្ហាស្មុគស្មាញឡើងៗ។ ទោះបីរាជរដ្ឋាភិបាលបានអះអាងថា វិវាទថយចុះនៅឆ្នាំ២០០៩ តែតួលេខនៃករណីវិវាទតាមឆ្នាំរបស់គណៈកម្មការសុរិយោដីកើនឡើង វាស្របជាមួយការសិក្សារបស់ដៃគូអភិវឌ្ឍន៍ផងដែរ។ វិវាទដីធ្លីមិនបានដោះស្រាយឱ្យទាន់ពេលវេលា ភាគីតវ៉ាខ្លាំងឡើងនឹងបង្កឱ្យកើតឡើងនូវអំពើហិង្សា បង្ករបួសស្នាម និងការស្លាប់មនុស្សដែលភាគច្រើនប្រព្រឹត្តឡើងដោយកងកម្លាំងប្រដាប់អាវុធ។

បញ្ហាដីធ្លីនៃប្រទេសមួយចំនួន ដូចជាប្រទេសថៃ នេប៉ាល់ និងប្រទេសទុយនីស៊ី វិវាទដីធ្លីមានលក្ខណៈស្រដៀងគ្នានឹងប្រទេសខ្មែរដែរ។ វិវាទនៅតែបន្តកើតឡើង និង ដោះស្រាយមិនចេះចប់ នេះដោយសារដីធ្លីជាប្រភពចម្បងនៃអ្វីៗទាំងអស់រួមទាំងអំណាច និងទ្រព្យសម្បត្តិ។ ការអនុវត្តច្បាប់នៅមានកម្រិត អ្នកមានប្រាក់ឬ ឈ្មួញឆក់ឱកាសកេងចំណេញពីស្ថានការណ៍ដោយបន្លំយកដីរដ្ឋធ្វើការកម្មសិទ្ធិផ្ទាល់ខ្លួន។ ចំណុចសំខាន់គឺពាក់ព័ន្ធនឹងឆន្ទៈនយោបាយរបស់ប្រទេសនីមួយៗក្នុងការដោះស្រាយបញ្ចប់វិវាទ។

វឌ្ឍនភាពនៃការកសាងឯកសារដីធ្លី និងក្របខ័ណ្ឌគតិយុត្តសម្រាប់អនុវត្តច្បាប់ភូមិបាលឆ្នាំ២០០១ មានការរីកចម្រើនគួរឱ្យកត់សំគាល់។ កង្វះខាតលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួនទាមទារឱ្យបំពេញ។ អវត្តមានច្បាប់ចាំបាច់មួយចំនួនធ្វើឱ្យស្ថានភាពច្របូកច្របល់មិនអាចដោះស្រាយបាន។ ដោយសារបញ្ហានេះទើបមានការចោទប្រកាន់មន្ត្រីអនុវត្តច្បាប់ថា រំលោភច្បាប់ និង សិទ្ធិមនុស្សដែលមហាជនបានដឹង ឮរាល់ថ្ងៃតាមរយៈសាព័ត៌មាន។ ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់មួយចំនួនស្ថិតក្នុងចំណុចអាទិភាពមាន៖ ច្បាប់ស្តីពី ការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងអភិបាលកិច្ចល្អ គោលនយោបាយស្តីពីការតាំងទីលំនៅថ្មី ច្បាប់ស្តីពីពន្ធលើដីធ្លី ច្បាប់ស្តីពីសិទ្ធិបុព្វក្រេ លិខិតបទដ្ឋានពាក់ព័ន្ធច្បាប់ស្តីពីអស្សាមិករណ៍ ច្បាប់ស្តីពីអនុបយោគ ច្បាប់ស្តីពីដីកសិកម្ម។ល។ ទន្ទឹមនឹងកង្វះខាតលិខិតបទដ្ឋានគតិយុត្ត ចំណែកលិខិតគតិយុត្តមួយចំនួនដែលនៅជាធរមានមិនមានភាពច្បាស់លាស់ និង ស៊ីចង្វាក់គ្នានៅឡើយ។ ដូច្នេះតម្រូវឱ្យមានការធ្វើវិសោធនកម្មលើច្បាប់ភូមិបាល និងកែប្រែឬលុបចោលនូវលិខិតបទដ្ឋានក្រោមច្បាប់មួយចំនួនដើម្បីបន្ស៊ីលិខិតបទដ្ឋានគតិយុត្តទាំងអស់នេះ ឱ្យស្របគ្នាទៅតាមឋានានុក្រមនៃច្បាប់។

ករណីសិក្សានៃវិវាទដីធ្លីនៅតំបន់ដីក្រហម បានឆ្លុះបញ្ចាំងអំពីករណីវិវាទផ្សេងៗទៀតនៅកម្ពុជា។ ការវិភាគផ្លូវច្បាប់នៃវិវាទដែលសិក្សានៅក្នុងនិក្ខេបបទនេះ ជ្រុងណាមួយក៏បានករណីវិវាទក្រោមរូបភាពនៃការដោះដូរដីធ្លីធ្វើឡើងដោយខុសច្បាប់។ តួអង្គដែលជាប់ពាក់ព័ន្ធក្នុងរឿងនេះ ចូលរួមចំណែកក្នុងទង្វើខុសច្បាប់ទៅតាមតួនាទី និងជំនាញរៀងៗខ្លួន។ តួអង្គដែលមានកំហុសធ្ងន់ជាងគេគឺអាជ្ញាធររាជធានី ធ្វើខុសពីតួនាទីរបស់ខ្លួនដែលជាអ្នកអនុវត្តច្បាប់ ដើម្បីធ្វើឱ្យកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាលសម្រេចបានជោគជ័យជូនដល់ប្រជាពលរដ្ឋ តែបែរទៅជាសម្របសម្រួលរវាងភាគីទំនាស់ប្រែក្លាយដីនោះ ឱ្យក្លាយទៅជាកម្មសិទ្ធិរបស់ក្រុមហ៊ុនទៅវិញ។ សារនេះបានបង្ហាញយ៉ាងច្បាស់ថាអាជ្ញាធររាជធានី និងអ្នកពាក់ព័ន្ធខិលខូចមួយចំនួនស្ថិតក្រោមឥទ្ធិពលរបស់ឈ្មួញតាមរយៈការដើរតួជាភាគីទំនាស់ជំនួសឈ្មួញ និងធ្វើជាអ្នកដោះស្រាយទំនាស់ផងដែរ។ ការណ៍នេះវាស្តែងឱ្យឃើញថា អាជ្ញាធរមានភាពលំអៀងទៅខាងអ្នកមានប្រាក់( ឈ្មួញ )។ ទោះបីជាមានទង្វើខុសច្បាប់ធ្ងន់ធ្ងរក៏ដោយក៏មិនមានអ្នកប្រព្រឹត្តខុសណាម្នាក់ទទួលទោសឡើយ វាថែមទាំងលើកស្ទួយវប្បធម៌នៃការរំលោភច្បាប់ និងនិទណ្ឌភាពបន្តទៅទៀត។ ទំនោរនៃការគោរពបទបញ្ជាធំជាងច្បាប់នៅតែបន្តតាមទស្សនៈ "ខ្លាចមនុស្សជាងខ្លាចច្បាប់" ។ ចំណែកឯ ស.ជ.ណ. ដែលគ្រាន់តែជាសេចក្តីជូនដំណឹងតែវាមានឥទ្ធិពលខ្លាំងជាជាងច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ដទៃផ្សេងៗទៀត។ វាបង្ហាញឱ្យកាន់តែច្បាស់ថា ការអនុវត្តច្បាប់ខ្សោយនៅកម្ពុជា។ តែបើត្រូវបានអនុវត្តវិញ ច្រើនមានការលំអៀងទៅភាគីម្ខាងដែលមានឥទ្ធិពលច្រើនជាងទៅលើអ្នកខ្សោយ។ ការណ៍នេះ វាផ្ទុយទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដែលលំអៀងទៅអ្នកក្រក្នុងន័យការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស។

អាជ្ញាធរមានសមត្ថកិច្ចបានខិតខំប្រឹងប្រែងដោះស្រាយវិវាទដីធ្លី ទោះបីជាជួបប្រទះការលំបាកខ្វះខាតយ៉ាងណាក៏ដោយ ក៏បញ្ហាប្រឈមចំពោះមុខនៅតែមានជាអាទិ៍បញ្ហាកង្វះខាតនូវធនធានមនុស្ស មធ្យោបាយ និង ថវិកា ក្នុងការបំពេញកិច្ចការរបស់សមត្ថកិច្ច។ បញ្ហានេះជួបប្រទះដូចគ្នាមិនចំពោះគណៈកម្មការសុរិយោដី និងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីតែប៉ុណ្ណោះទេ ថែមទាំងផ្នែកតុលាការទៀតផង។ ដោយសារបញ្ហាទាំងនេះហើយ ទើបធ្វើឱ្យការអនុវត្តច្បាប់នៅខ្សោយ នាំដល់កើតមានអំពើពុករលួយក្នុងស្ថាប័នអនុវត្ត រួមទាំងភាពទន់ខ្សោយនៃប្រព័ន្ធផ្សព្វផ្សាយ និងចំណេះដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋភាគច្រើននៅទន់ខ្សោយ។ បើក្រលេខមើលប្រភព និងមូលហេតុនៃវិវាទដីធ្លីនៅកម្ពុជា ដំណោះស្រាយនឹងមិនអាចធ្វើទៅបានភ្លាមៗនោះទេ។ ដូច្នេះវិធានការបង្ការ និងទប់ស្កាត់ត្រូវតែរៀបចំឡើង និងត្រូវតែធ្វើយ៉ាងណាឱ្យមានប្រសិទ្ធភាពខ្ពស់។ ការណ៍នេះវាអាចជៀសវាងបាននូវវិវាទដីធ្លី និងអាចរក្សាបាននូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លីតាមរយៈការចុះបញ្ជីដី។ ការចុះបញ្ជីអាចឱ្យកម្មសិទ្ធិករមានសំអាងដ៏រឹងមាំ ពោលគឺវិញ្ញាប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ទោះបីជាវិធីនេះមិនអាចកាត់បន្ថយវិវាទដីធ្លីបានទាំងស្រុងក៏ដោយ ក៏អាចជាវិធានការបន្ថែមមួយដែលឈានទៅដល់ការលុបបំបាត់វិវាទដីធ្លីទាំងស្រុងដោយរួមបញ្ចូលទាំងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ការបំពេញបន្ថែមនូវចន្លោះប្រហោងទាំងឡាយនៃច្បាប់ ការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅ

ទូទាំងប្រទេស។ ម្យ៉ាងរដ្ឋត្រូវបង្កើនល្បឿនការផ្ដល់ដីធ្លី ឱ្យប្រជាពលរដ្ឋក្រីក្រ និង ការកំណត់អត្តសញ្ញាណដីរដ្ឋ ធ្វើផែនទីដីរដ្ឋឱ្យច្បាស់លាស់។ ម្យ៉ាងវិញទៀត ពន្ធលើដីមិនប្រើប្រាស់ត្រូវអនុវត្តឱ្យបានតឹងរឹងជាទីបំផុត ដើម្បីបញ្ចៀសជនខិលខូចបង្កកដីទុកលក់យកចំណេញ។ យ៉ាងណាមិញលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមានត្រូវអនុវត្តឱ្យបានម៉ត់ចត់ ទាំងស្ថាប័នរដ្ឋាភិបាល និងស្ថាប័នយុត្តិធម៌ ដើម្បីឱ្យកម្ពុជាឈានទៅរកនីតិរដ្ឋពេញលេញ។

សរុបសេចក្ដីមកយើងអាចធ្វើការសន្និដ្ឋានបានថា រាជរដ្ឋាភិបាលបានខិតខំកសាងគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនដើម្បីដោះស្រាយបញ្ហាដីធ្លី។ តែនៅកង្វះខាតការអនុវត្តច្បាប់ទាំងផ្នែករដ្ឋបាល និង តុលាការ ដែលការណ៍នេះ វាមិនបាននាំឱ្យគោលនយោបាយរបស់រដ្ឋាភិបាលសម្រេចបានជោគជ័យទាំងស្រុងនោះទេ។ ទោះបីជា មានចំណុចខ្វះចន្លោះ និងនៅសេសសល់មួយចំនួនលើការអនុវត្តជាក់ស្ដែងនោះ វាទាមទារឱ្យមានការពង្រឹង និង បំពេញបន្ថែមលើចំណុចខ្វះខាតទាំងនោះ។ ទន្ទឹមនេះរាជរដ្ឋាភិបាលក៏កំពុងតែបានគិតគូដើម្បីដោះស្រាយបញ្ហាទាំងនេះ។

**អនុសាសន៍៖**

ស្ថិតក្នុងខ្លឹមសារជាសារវន្ត ដើម្បីធ្វើឱ្យយន្តការដោះស្រាយវិវាទដីធ្លីនៅប្រទេសកម្ពុជាកាន់តែមានលក្ខណៈសុក្រឹត្យថែមទៀត អនុសាសន៍មួយចំនួនដែលត្រូវបំពេញបន្ថែមទាំងនោះរួមជាអាទិ៍មាន៖

- កំណត់តំបន់ប្រើប្រាស់ដីធ្លីសម្រាប់ទីប្រជុំជនឱ្យបានច្បាស់លាស់ ចំពោះដីប្រភេទណាដែលអាចសាងសង់បាន និងដីប្រភេទណាមិនត្រូវសាងសង់។ ត្រូវគ្រប់គ្រងឱ្យបានតឹងរឹង ករណីមានការសាងសង់ខុសច្បាប់ ត្រូវចាត់វិធានការភ្លាមៗដើម្បីជៀសវាងកុំឱ្យរឿងកាន់តែធំ។
- បង្កើតនាយកដ្ឋាន ឬមណ្ឌលទិន្នន័យដីធ្លីដើម្បីរក្សាឯកសារបញ្ជីដីកម្មសិទ្ធិរបស់រដ្ឋ និងឯកជន ក្នុងគោលដៅជូនព័ត៌មានដល់សាធារណៈជន។
- ត្រូវបង្កើតឱ្យមានសម្បទានដីសង្គមកិច្ចនៅក្នុងសម្បទានសេដ្ឋកិច្ចដើម្បីកាត់បន្ថយទំនាស់ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋដែលងាយរងគ្រោះ។
- ពន្លឿនការកំណត់តំបន់ និងការផ្ដល់សម្បទានដីសង្គមកិច្ចជូនដល់ប្រជាពលរដ្ឋក្រីក្រគ្មានដី និងខ្វះដីធ្លី។
- បង្កើតយន្តការសមធម៌ និងប្រព័ន្ធដែលមានប្រសិទ្ធភាពសម្រាប់ធានានូវសុវត្ថិភាពដីធ្លីសម្រាប់ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។
- លើកទឹកចិត្តដើម្បីឱ្យគណៈកម្មការសុរិយោដីដោះស្រាយរឿងវិវាទដីធ្លីធំៗ។
- ពន្លឿនការចុះបញ្ជីដីធ្លីជាប្រព័ន្ធ ដោយរួមទាំងដីរបស់សហគមន៍ជនជាតិដើមភាគតិច។
- អត្រាពន្ធលើការចុះបញ្ជីដីធ្លីបច្ចុប្បន្ន ៤ភាគរយ នៃតម្លៃលក់ គួរបន្ថយឱ្យបានសមស្របជៀសវាងការគេចពន្ធខាតបង់ដល់រដ្ឋ។
- ពន្លឿនការប្រមូលពន្ធលើដីមិនប្រើប្រាស់ ដើម្បីកាត់បន្ថយការបង្កកដីទុកលក់ពេលឡើងថ្លៃដែលនាំឱ្យវិបាកដល់ការវិនិយោគពិតប្រាកដ និងកំណើនប្រជាពលរដ្ឋគ្មានដីនិង ខ្វះដីធ្លី។

- ពន្លឿនការចុះបញ្ជីដីសាធារណៈ និងដីឯកជនរបស់រដ្ឋឱ្យបានអស់ត្រឹមឆ្នាំ២០១៥ ដើម្បីទប់ការទន្ទ្រានចូលកាន់កាប់ខុសច្បាប់លើដីរដ្ឋ។
- ពង្រឹងបន្ថែមការផ្ទេរដីក្រៅប្រព័ន្ធសុរិយោដី ដូចជាតាមរយៈមេភូមិ មេឃុំ អភិបាលស្រុក ដែលជាហេតុធ្វើឱ្យជួបការលំបាកលើប្រព័ន្ធចុះបញ្ជីដីធ្លី និងកើតមានទំនាស់នាពេលអនាគត។
- គប្បីត្រូវមានការសិក្សាវាយតម្លៃអំពីផលប៉ះពាល់ និង ការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និង គប្បីមានការទូទាត់សំណងសមរម្យជាមុន មុននឹងការរើតាំងលំនៅឋានថ្មីណាមួយ។
- ពង្រឹងបន្ថែមការចាត់វិធានការលើក្រុមហ៊ុនទាំងឡាយណាដែលអនុវត្តល្មើសនឹងច្បាប់ និងមិនបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌនៃកិច្ចសន្យាសម្បទានរបស់ខ្លួន និងបន្តលុបចោលកិច្ចសន្យាអំពីសម្បទានតទៅទៀត។
- តំបន់តាំងទីលំនៅថ្មី ត្រូវតែធានាឱ្យមានលក្ខណៈសមស្រប ដូចជាៈ មានឱកាសរកប្រាក់ចំណូលបានស្មើ ឬល្អប្រសើរជាងមុន។
- អំពាវនាវឱ្យមានការដោះលែងប្រជាពលរដ្ឋដែលជាប់ឃុំឃាំងដោយការចោទពីបទព្រហ្មទណ្ឌដោយមិនត្រឹមត្រូវ និងបញ្ឈប់ការបន្តចាប់ខ្លួនពាក់ព័ន្ធរឿងវិវាទដីធ្លី។
- ពង្រឹងការអនុវត្តច្បាប់ភូមិបាល ជាពិសេស អនុវត្តទោសឱ្យបានត្រឹមត្រូវទៅលើជនល្មើសដោយមិនមានការរើសអើង។
- ផ្តល់អាទិភាពដល់ស្ថាប័នដោះស្រាយវិវាទដីធ្លី ដោយបន្ថែមថវិកាជាតិទៅក្នុងខ្ទង់ចំណាយចំពោះការដោះស្រាយបញ្ហាដីធ្លី។
- ជំរុញការផ្សព្វផ្សាយច្បាប់ភូមិបាល និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់នានា ដល់ប្រជាពលរដ្ឋឱ្យបានច្រើនថែមទៀត។
- ពង្រឹងបន្ថែមសមត្ថភាពបច្ចេកទេសដល់ស្ថាប័នដោះស្រាយវិវាទដីធ្លីទាំងគណៈកម្មការសុរិយោដី អាជ្ញាធរជាតិ និងតុលាការ។
- ពិនិត្យឡើងវិញទាក់ទងនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ដើម្បីឱ្យបានស្របគ្នាទៅតាមឋានានុក្រមនៃច្បាប់។
- គួរតាត់បន្ថយការចេញ ស.ជ.ណ ដើម្បីធានាការអនុវត្តច្បាប់ឱ្យបានច្បាស់លាស់។
- ពិនិត្យលើសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងប្រព័ន្ធទាំងបីនេះនាពេលបច្ចុប្បន្ន វាជាការគួរឱ្យត្រូវមានការយកចិត្តទុកដាក់ខ្ពស់និង តម្រូវឱ្យធ្វើការដោះស្រាយជាបន្ទាន់ដែរ៕

# គន្ថនិទ្ទេស

( References/Bibliographies )

# គន្ថនិទ្ទេស

( References/Bibliographies )

## ១.ឯកសារភាសាខ្មែរ

## ក.ឯកសារច្បាប់

.« *រដ្ឋធម្មនុញ្ញ សាធារណរដ្ឋខ្មែរ* » ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧២។

.« *រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ* » ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦។

.« *រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា* » លេខ២៩ក្រ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩។

.« *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា* » ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។

.« *រដ្ឋធម្មនុញ្ញ វិសោធនកម្មនៃព្រះរាជាណាចក្រកម្ពុជា* » ចុះថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩៩។

.ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ស្តីពី « *ក្រមរដ្ឋប្បវេណី* » (មកដល់ខែកក្កដា២០១០ ហើយ នៅមិនទាន់ប្រកាសឱ្យប្រើជាផ្លូវការនៅឡើយ មូលហេតុក្រមនេះនឹងប្រកាសឱ្យប្រើដោយច្បាប់ផ្សេង)។

.ព្រះរាជក្រម លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ស្តីពី « *ក្រមនីតិវិធីរដ្ឋប្បវេណី* »។

.« *ក្រមរដ្ឋប្បវេណី* » ឆ្នាំ១៩៦៧។

.ក្រឹត្យច្បាប់ លេខ ៥៦ក្រ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៩ ច្បាប់ស្តីពី « *អាពាហ៍ពិពាហ៍ និងគ្រួសារ* »

.ក្រឹត្យច្បាប់លេខ១០០/ក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ ស្តីពីច្បាប់ « *ភូមិបាល* »។

.ក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ស្តីពី « *កិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា* »។

.ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ច្បាប់ « *ភូមិបាល* »។

.ព្រះរាជក្រម លេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ខែសីហាឆ្នាំ២០០២ ច្បាប់ស្តីពី « *ព្រៃឈើ* »

.ព្រះរាជក្រម លេខ នស /រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ច្បាប់ស្តីពី « *ជលផល* »។

.ព្រះរាជក្រម លេខ នស/រកម/០២៩៧.០៣/ ចុះថ្ងៃទី២៤ ខែកម្ភៈ ឆ្នាំ១៩៩៧ ស្តីពី « *សារពើពន្ធ* »។

.ព្រះរាជក្រម លេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ច្បាប់ស្តីពី « *ការងារ* »។

.ព្រះរាជក្រម លេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ច្បាប់ស្តីពី « *ការរៀបចំនិងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ* »។

.ព្រះរាជក្រម លេខ នស /រកម/០៥០៦/០១០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ច្បាប់ស្តីពី « *មជ្ឈត្តការ ផ្នែកពាណិជ្ជកម្ម* »។

## ខ.ឯកសាររាជរដ្ឋាភិបាល

.ព្រះរាជក្រឹត្យលេខ ០៨/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើច្បាប់ស្តីពី «*ការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*»។

.ព្រះរាជក្រឹត្យ លេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពី «*ការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*»។

.ព្រះរាជក្រឹត្យ លេខ នស.រកត ១០០៨/១១០៦ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ ស្តីពី វិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/ ០២០៦/ ០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពី «*ការបង្កើតអាជ្ញាធរ ជាតិដោះស្រាយទំនាស់ដីធ្លី*»។

.អនុក្រឹត្យ លេខ ២៥ អនក្រ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩ ស្តីពី «*ការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា*»។

.អនុក្រឹត្យ លេខ ៦២ អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩, ស្តីពី «*ការរៀបចំ និងតួនាទីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*»។

.អនុក្រឹត្យ លេខ ១១៨ អនក្រ/បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពី «*ការគ្រប់គ្រងដីរដ្ឋ*»។

.អនុក្រឹត្យ លេខ៤៧ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០១ស្តីពី «*ការរៀបចំ និងប្រព្រឹត្តទៅនៃគណកម្មការសុរិយោដី*»។

.អនុក្រឹត្យ លេខ ៣៤ អនក្រ/បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ ស្តីពី ការកែប្រែមាត្រា៥ និងមាត្រា២៨ នៃអនុក្រឹត្យលេខ៤៧ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី «*ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*»។

.អនុក្រឹត្យ លេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី «*នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី*»។

.អនុក្រឹត្យ លេខ ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៣ ស្តីពី «*សម្បទានដីសង្គមកិច្ច*»។

.អនុក្រឹត្យ លេខ ១៣១ អនក្រ/បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី «*ការកែប្រួលនៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច*»។

.អនុក្រឹត្យ លេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ស្តីពី «*នីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់*»។

.អនុក្រឹត្យ លេខ៦៥ អនក្រ/បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦ ស្តីពី «*ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*»។

.អនុក្រឹត្យ លេខ ១១៤៦ អនក្រ.តត ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ ស្តីពី «*ការតែងតាំងសមាសភាព អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*»។

.អនុក្រឹត្យលេខ២៥ អនក្រ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩ ស្តីពី «*ការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា*»។

.ប្រកាស លេខ ១១២ ជនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី «*គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី* »។

.ប្រកាសអន្តរក្រសួង លេខ ០២ ប្រក/០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ស្តីពី «*ការកំណត់ការកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី* »។

.ប្រកាស លេខ ០៣២ ប្រក/គសដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ ស្តីពី «*ការធ្វើប្រតិភូកម្មមុខងារជូន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និង ជាប្រធានគណៈកម្មការសុរិយោដី រាជធានី ខេត្ត ដើម្បីធ្វើសេចក្តីសម្រេចលើសំណុំរឿងវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី* »។

.ប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពី «*ក្រុមប្រឹក្សាអាជ្ញាកណ្តាល*»

.ប្រកាស លេខ៣១៧/សកបយ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី «*នីតិវិធីនៃការដោះស្រាយវិវាទការងាររួម*»។

.សេចក្តីសំរេច លេខ ៩៦ សសរ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៧ ស្តីពី «*ការបង្កើតក្រុមការងារដោះស្រាយវិវាទចល័ត ក្នុងខេត្តកំពង់ចាម បាត់ដំបង និងខេត្តបន្ទាយមានជ័យ* »។

.សារាចរ លេខ ០៥.ស.រ.ច ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៨៩ ស្តីពី «*ការអនុវត្តអនុក្រឹត្យ ស្តីពីផ្តល់កម្មសិទ្ធិលើផ្ទះជូនប្រជាពលរដ្ឋនៅរដ្ឋធានីភ្នំពេញ* »។

.សេចក្តីណែនាំអនុវត្ត លេខ០៣ សណន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ ស្តីពី «*គោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី* »។

.សារាចរ លេខ ០១ សយ សរនន/០៧ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពី «*ចំណាត់ការ និងនីតិវិធីនៃការដោះស្រាយរឿងក្តីដែលមានពាក់ព័ន្ធនឹងដីរដ្ឋ* »។

.លិខិត លេខ ១២៦២ សជណ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ ស្តីពី «*ការជូនដំណឹងកិច្ចបញ្ចប់ករណីទំនាស់ដីធ្លីនៅភូមិដើមស្រល់ ឃុំមនោរម្យ ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគីរី* » ពីទីស្តីការគណៈរដ្ឋមន្ត្រីទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលខេត្តមណ្ឌលគីរី។

.«*ដីកាសម្រេច* » លេខ ៤៤៩ រប.២០០២ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០២ តុលាការខេត្តបាត់ដំបង។

.ហ៊ុន សែន៖ «*សុន្ទរកថាថ្លែងនៅក្នុងវេទិកាដីធ្លីថ្នាក់ជាតិនៅវិមានរដ្ឋាភិបាល* » ភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤។

.ហ៊ុន សែន៖ «*សុន្ទរកថាស្តីពីការរីកចម្រើនរបស់ប្រជាពលរដ្ឋ តាមរយៈសមិទ្ធិផលនានានៃការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល* » ឆ្នាំ២០០៤-២០០៧ ថ្លែងក្នុងពិធីបិទសន្និសីទជាតិនៅសាលសន្និសីទចតុមុខ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៨។

.ហ៊ុន សែន៖ «*សុន្ទរកថាវេទិកាដីធ្លីថ្នាក់ជាតិ នៅវិមានរាជរដ្ឋាភិបាល* » ភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤។

.ហ៊ុន សែន៖ «*សុន្ទរកថាស្តីពីយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី២ ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ សំរាប់អាណត្តិទី៤ នៃរដ្ឋសភា* » នៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨។

.ហ៊ុន សែន៖ «*សុន្ទរកថាក្នុងពិធីបើកសន្និសីទជាតិស្តីពីមីក្រូហិរញ្ញវត្ថុកម្ពុជា* » ភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦។

.រាជរដ្ឋាភិបាល៖ «*កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនៃនីតិកាលទី៤ នៃរដ្ឋសភា* » ភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨។

.រាជរដ្ឋាភិបាល៖ «*ផែនការសកម្មភាពអភិបាលកិច្ចទី២ ២០០៥ - ២០០៨* » អនុម័តដោយគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ភ្នំពេញ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៦។

.រាជរដ្ឋាភិបាលកម្ពុជា៖ «*របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ ២០០៨* » ស្តីពី ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ ភ្នំពេញ ឆ្នាំ២០០៨។

.ទីស្តីការគណៈរដ្ឋមន្ត្រី៖ លិខិតលេខ ៧៨៥ សជណ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៣ ស្តីពី «*ការសម្រេចលើករណីសំណើសុំគោលការណ៍រៀបចំសម្បទានដីសង្គមកិច្ច* » ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន ជូនសហគមន៍ក្រីក្រក្នុងរាជធានី ភ្នំពេញ។

.រាជរដ្ឋាភិបាលកម្ពុជា៖ «*ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី*» ឯកសារបឋម បានអនុម័តពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០២។

.រាជរដ្ឋាភិបាល៖ «*ឯកសារបឋម ស្តីពី ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី អនុម័តពីគណៈរដ្ឋមន្ត្រី* » នាសម័យប្រជុំពេញអង្គ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០២ រៀបចំដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

.រាជរដ្ឋាភិបាល៖ «*សេចក្តីប្រកាស ស្តីពី គោលនយោបាយដីធ្លី ដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី* » ខែឧសភា ឆ្នាំ២០០១។

.រាជរដ្ឋាភិបាល៖ «*សេចក្តីថ្លែងការស្តីពីគោលនយោបាយដីធ្លី* » ភ្នំពេញ ចុះថ្ងៃ ទី ០១ ខែកក្កដា ឆ្នាំ ២០០៩។

.រាជរដ្ឋាភិបាល៖ «*សេចក្តីថ្លែងការរបស់រាជរដ្ឋាភិបាល ស្តីពី គោលនយោបាយដីធ្លី* » ភ្នំពេញ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩។

.រាជរដ្ឋាភិបាល៖ សេចក្តីជូនដំណឹង លេខ៤៣ សជណ.កបច. ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០១ ស្តីពី «*ការបញ្ចប់ការចូល កាន់កាប់កោតៈលើអចលនៈវត្ថុ* »។

.អ៊ឹម ឈុនលឹម៖ «*សុន្ទរកថាស្វាគមន៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* » ក្នុងឱកាសមិទ្ទិញរំលឹកខួបទិវានារីអន្តរជាតិ៨ មិនា និងពិធីប្រកាសទទួលស្គាល់សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ភ្នំពេញ ថ្ងៃទី ០១ ខែមិនា ឆ្នាំ២០១០។

.អ៊ឹម ឈុនលឹម៖ «*សុន្ទរកថាក្នុងឱកាសបិទសន្និបាតបូកសរុបការងារឆ្នាំ២០០៩ និងលើកទិសដៅឆ្នាំ ២០១០* » របស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ២០១០។
.ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់៖ «*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្ន ២០០៩-២០១៣* » (ភយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣) របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លេខ: ជនស/អរប ឆ្នាំ២០០៩។
.លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ៖ «*របាយការណ៍ ស្តីពី សកម្មភាពការងាររបស់គណៈកម្មការសុរិយោដីប្រចាំឆ្នាំ២០០៩* »។
.អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី៖ «*កម្រងសំណួរ - ចំម្លើយ ពាក់ព័ន្ធនឹងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មការសុរិយោដី* » ភ្នំពេញ ខែមិនា ឆ្នាំ២០០៧។
.អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី៖«*ស្វែងយល់អំពីទោសបញ្ញត្តិស្តីពី បទល្មើស ពាក់ព័ន្ធនឹងច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ* » ភ្នំពេញ ឆ្នាំ២០០៧។
.សាលាខណ្ឌចំការមន៖ លិខិត ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៤ របាយការណ៍ស្តីពី «*លទ្ធផលនៃការរៀបចំអភិវឌ្ឍន៍ នៅនឹងកន្លែងរបស់សហគមន៍ដីក្រហម* »។
.ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច៖ «*ខ្លឹមសារសង្ខេប យុទ្ធសាស្ត្រជាតិ កាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥* » ភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០២។

## គ.ឯកសារស្នាដៃ

.Daniel Adler et all: «*ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងដំណើរការដោះស្រាយវិវាទការងារនៅកម្ពុជា ច្បាប់ និងសេចក្តីអត្ថាធិប្បាយ* » បោះពុម្ពផ្សាយលើកទី២ លេខ ISNB: ៩៧៨-៩៩៩៥០-៧៤-០៥-០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ឆ្នាំ២០០៧។
.Lacerda, K. Schmitt, P.Cutter and S. Meas: «*ការវាយតម្លៃប្រសិទ្ធភាពគ្រប់គ្រងនៃប្រព័ន្ធតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា* » ដោយប្រើប្រាស់វិធីសាស្ត្រ ស្តីពីការវាយតម្លៃបន្ទាន់ និងការកំណត់អាទិភាពនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ របស់អង្គការមូលនិធិពិភពលោកសំរាប់អភិរក្សធម្មជាតិ ក្រសួងបរិស្ថាន ភ្នំពេញ ឆ្នាំ២០០៤។
.កុយ នាម៖ «*ដំណើរការក្តីនៅក្នុងតុលាការកម្ពុជា* » Introduction Cambodian Judicial Process អង្គការមូលនិធិអាស៊ី ភ្នំពេញ ឆ្នាំ១៩៨៩។
.ប៉ែន សុផល៖ «*ការគ្រប់គ្រងដីធ្លីប្រកបដោយចីរភាព និងសមធម៌នៅព្រះរាជាណាចក្រកម្ពុជា* » និក្ខេបបទបណ្ឌិតនីតិសាស្ត្រ សកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ភ្នំពេញ ឆ្នាំ២០០៧។
.ច័ន្ទ សុផល និង សាទី អាចាយា៖ «*ការលក់ដូរដីធ្លីនៅកម្ពុជា* » ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី ឯកសារពិភាក្សាលេខ ២២ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ភ្នំពេញ ឆ្នាំ២០០២ ។

.ច័ន្ទ សុផល ទេព សារី និងសាទី អាធាយា៖ «*ការកាន់កាប់ដីនៅកម្ពុជា* » ការវិភាគលើទិន្នន័យចុងក្រោយ ឯកសារ ពិភាក្សាលេខ១៩ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ភ្នំពេញ ឆ្នាំ២០០១។
.ច័ន្ទ សុផល និងសាទី អាធាយា៖ «*បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទ: ករណីសិក្សាលើភូមិចំនួន៩ នៅកម្ពុជា* » ឯកសារពិភាក្សា លេខ ២៥ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ ភ្នំពេញ ឆ្នាំ២០០៣។
.ព្រហ្ម វិចិត្រអក្ខរា៖ «*ឯកសារជំនួយស្មារតីសម្រាប់កិច្ចពិភាក្សារបស់និស្សិតក្នុងវេទិកានិស្សិតប្រកួតពិភាក្សាស្តីពីបញ្ហាដីធ្លី នាយកដ្ឋានទប់ស្កាត់ បង្ការ និង អប់រំរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី* » ភ្នំពេញ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៨។
.ស្បន វីលៀម៖ «*ជម្លោះកម្មសិទ្ធិដីធ្លីនៅកម្ពុជា* » ការសិក្សាស្តីអំពី សមត្ថភាពដោះស្រាយទំនាស់ដីធ្លីនៅ ៥ ខេត្ត គំរោងសិក្សាដីធ្លីនៅកម្ពុជា អុកស្វាម ភ្នំពេញ ឆ្នាំ២០០០។
.ស៊្មីរិន អ៊ែម អូស្មើរមីឡឺរ៖ «*ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា* » សៀវភៅសិក្សាស្តីអំពីទស្សនាទានសំខាន់ៗ USAID Cambodia, EWMI ឆ្នាំ២០០៩។
.ស៊ិក បូរ៉ក្សៃ និងសុខ ហាច៖ «*ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០ ការផ្តោតលើបញ្ហាដីធ្លី កម្លាំងពលកម្ម និង ការចិញ្ចឹមជីវិតនៅជនបទ* » វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា ភ្នំពេញ ឆ្នាំ ២០០២ ។
.រ៉ូបឺន បីដុល៖ «*តើដីធ្លីត្រូវបាត់ទៅណា?* » ការបង្ហាញឱ្យកាន់តែឃើញពីភាពក្រីក្រ របាយការណ៍ស្តីពីការស្រាវជ្រាវនូវភាពគ្មានដីធ្លី និងការអភិវឌ្ឍន៍ អុកស្វាមអង់គ្លេស គម្រោងសិក្សាដីធ្លីនៅកម្ពុជា លេខ៤ ភ្នំពេញ ឆ្នាំ ២០០០។
.រ៉ូបឺន បីដុល៖ «*ការបង្ហាញឱ្យកាន់តែឃើញពីភាពក្រីក្រ* » របាយការណ៍បឋម អុកស្វាម ភ្នំពេញ ឆ្នាំ ២០០០។
.Ros Chantrabot: «*La Republique Khmer* », L' Harmattan ឆ្នាំ ? ប្រែសម្រួលដោយៈ ទីយាយុ។
.សាយ បូរី៖ «*នីតិវិធីរដ្ឋបាល*» បោះពុម្ពលើកទី១ ភ្នំពេញ ឆ្នាំ២០០៥។
.ហ្វ្រង់ស្វ័រ ប៉ុងសូដ៍៖ «*ប្រវត្តិសង្ខេបនៃប្រទេសកម្ពុជា*» ភ្នំពេញ ២០០៧។
.អ៊ូ វ៉ឌី៖ «*សុន្ទរកថាស្តីពីយុទ្ធសាស្ត្របែងចែក និងការគ្រប់គ្រងដីរដ្ឋ* » វេទិកាថ្នាក់ជាតិនៅសណ្ឋាគារសាន់វេ ភ្នំពេញ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩។
.អ៊ូ វ៉ឌី៖ «*ទស្សនវិជ្ជាភូមិវិជ្ជា*» ឯកសារថ្នាក់បណ្ឌិត ទីស្តីការគណៈរដ្ឋមន្ត្រី - រាជបណ្ឌិត្យសភា ភ្នំពេញ ឆ្នាំ ២០០៨។
.អេលីហ្សាបែត កាតូ៖ «*មានការពិបាកក្នុងការចាប់ផ្តើមសារជាថ្មី ករណីសិក្សាទី៤* » ស្តីពីបញ្ហាសិទ្ធិកាន់កាប់ដីធ្លី ភ្នំពេញ អង្គការអុកស្វាម ឆ្នាំ១៩៩៩។

# ឃ.ឯកសារស្ថាប័ន


.កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ៖ «*ដីធ្លី និង ការអភិវឌ្ឍមនុស្សនៅកម្ពុជា* » UNDP, Phnom Penh ២០០៧។

.កិច្ចព្រមព្រៀង៖ «*ស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជំលោះកម្ពុជា* » ថ្ងៃ២៣ ខែតុលា ឆ្នាំ ១៩៩១ បោះពុម្ភដោយអ៊ិនតាក់។

.គណៈកម្មាធិការប្រព្រឹត្តកម្ម៖ «*តម្លៃដី ដែលកាត់ថ្លៃមិនបាន មរណៈភាព នៃការបណ្តេញចេញនៅភូមិក្បាលស្ពាន* » ដោយគណៈកម្មាធិការប្រព្រឹត្តកម្មដែលរួមមានអង្គការចំនួន១៨ ជាសមាជិក ភ្នំពេញ ខែសីហា ឆ្នាំ២០០៥។

.គណៈកម្មាធិការប្រព្រឹត្តកម្ម នៃអង្គការ - សមាគមការពាសិទ្ធិមនុស្សកម្ពុជា៖ «*កំពុងបាត់បង់ដី ការបណ្តេញចេញដោយបង្ខំ និងការគំរាមគំហែងនៅកម្ពុជា* » ភ្នំពេញ ឆ្នាំ២០០៩។

.ធនាគារពិភពលោក អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច៖ «*កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេនាឆ្នាំ២០១៥?* » ឯកសារវាយតម្លៃភាពក្រីក្រឆ្នាំ២០០៦ ភ្នំពេញ ឆ្នាំ ២០០៦។

.មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់៖ «*កសាងស្ថាប័នយុត្តិធម៌?* » ការពិនិត្យមើលទៅលើការងាររបស់គណៈកម្មការសុរិយោដីនៅកម្ពុជាទាក់ទងនឹងការដោះស្រាយវិវាទដីធ្លី សហការជាមួយ ក្រសួងរៀបចំដែន ដីនគរូបនីយកម្ម និងសំណង់ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ភ្នំពេញ ឆ្នាំ២០០៦។

.មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម៖ «*កម្មវិធីវេទិកាអ្នកតំណាងរាស្ត្រ ខែកក្កដា ឆ្នាំ ២០០៤ - ខែកក្កដា ឆ្នាំ ២០០៥* » របាយការណ៍វេទិការអ្នកតំណាងរាស្ត្រ ក្នុងមណ្ឌលខេត្ត បន្ទាយមានជ័យ សៀមរាប ព្រៃវែង និងស្វាយរៀង ភ្នំពេញ ខែសីហា ឆ្នាំ២០០៥។

.មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម៖ «*ព្រឹត្តិបត្រស្រាវជ្រាវមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម* » ឆ្នាំទី១៣ លេខ ១៣២ ខែកក្កដា-សីហា ឆ្នាំ២០០៦។

.លេខាធិការដ្ឋានទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិមនុស្សប្រចាំកម្ពុជា៖ «*សម្បទានដីគោលដៅសេដ្ឋកិច្ច នៅក្នុងប្រទេសកម្ពុជា* » ទស្សនវិស័យខាងសិទ្ធិមនុស្សៈ ភ្នំពេញ ឆ្នាំ២០០៤។

.វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា៖ «*ដី និង ជីវិត* » ព្រឹត្តិបត្រប្រចាំត្រីមាស បណ្តាញសកម្មភាពដីធ្លីដើម្បីអភិវឌ្ឍន៍ ឆ្នាំទី១ លេខ ១០ ខែតុលា-ធ្នូ ឆ្នាំ២០០៨។

EWMI៖ «*ច្បាប់ភូមិបាលកម្ពុជា* » គោលការណ៍ណែនាំផ្នែកច្បាប់ជាមូលដ្ឋានសម្រាប់សិស្ស និងអ្នកអនុវត្ត ច្បាប់ រៀបចំគាំទ្រដោយគម្រោងអនុវត្តច្បាប់ភូមិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB TA 3577-CAM ភ្នំពេញ ឆ្នាំ២០០៣។

LICADHO៖ «*ការវាយប្រហារ និងការគំរាមគំហែង អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា* » របាយការណ៍សង្ខេប ភ្នំពេញ ឆ្នាំ២០០៦។

NGO Forum and CCC៖ «***ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងការកាត់បន្ថយភាពក្រីក្រ***» ការស្រាវជ្រាវនៅក្នុងសង្កាត់ទីពីរនៃខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ក្រុមគំពោងវិភាគបញ្ហាអភិវឌ្ឍន៍ និងសិក្ខាកាមស្រាវជ្រាវសហការជាមួយមជ្ឈមណ្ឌលព័ត៌មានដីធ្លី ភ្នំពេញ ឆ្នាំ២០០៧។

.សមាគមអាដហុក៖ «***របាយការណ៍សិក្ខាសាលា ស្តីពី នីតិវិធីដោះស្រាយទំនាស់ និងលើកស្ទួយសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋ***» ដោយគណៈកម្មការសុរិយោដីខេត្ត បាត់ដំបង ឆ្នាំ២០០៤។

.សមាគមអាដហុក៖ «***ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៥***» សមាគមអាដហុក ការពាសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា លេខ៥ ឆ្នាំទី៥ ខែកុម្ភៈ ឆ្នាំ២០០៥។

.សមាគមអាដហុក៖ «***ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៨***» របាយការណ៍ប្រចាំឆ្នាំ លេខ ៨ ឆ្នាំទី៨ ផ្សាយខែមករា ឆ្នាំ២០០៩ ភ្នំពេញ។

.សមាគមអាដហុក៖ «***ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៩***» របាយការណ៍លេខ៩ ឆ្នាំទី៩ ភ្នំពេញ ខែមករា ឆ្នាំ២០១០។

.សេចក្តីថ្លែងការណ៍ជាសកល៖ «***ស្តីអំពីសិទ្ធិមនុស្ស***» ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

.អុកស្វាមអង់គ្លេស៖ «***វិវាទដីធ្លីនៅឆ្នាំ ១៩៩១ - ២០០៤***» ភ្នំពេញ ឆ្នាំ២០០៤។

.អង្គការសហប្រជាជាតិ លេខ E/C.12/KHM/CO/1 ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច «***ការពិនិត្យពិចារណាលើរបាយការណ៍ដែលបានស្នើដោយរដ្ឋភាគី ក្រោមមាត្រា ១៦ និងមាត្រា១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌***»។

.លិខិតកិច្ចសន្យា៖ «***កិច្ចសិន្យាសាងសង់អគារផ្ទះល្វែងលើទីតាំងថ្មី រវាងតំណាងសហគមន៍ និងក្រុមហ៊ុនឯកជន***» ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៥។

## ២. ឯកសារជាភាសាបរទេស

### ក. ឯកសារស្នាដៃ

Ahmed, Mahfuzuddin et all: ***Socio-Economic Assessment of Freshwater Capture Fisheries of Cambodia-Report on Household Survey***, Mekong River Commission, Phnom Penh, 1998.

Anneli Nordling: ***Environment and Human Rights in Thailand***, Interim Report for Forum Syd's Environment and Human Rights Study in the Mekong Region, Forum Syd, January 2005.

Bebette Wehrmann: ***Land Conflicts: A practical guide to dealing with land disputes***, GTZ, Eschborn 2008.

Bib Hughes: ***Land Ownership Disputes in Cambodia: A Study of the Capacity of FourProvinces to Resolve Conflicts over Land***." Oxfam GB and GTZ, Phnom Penh 2001.

Bishnu Raj Upreti: ***Understanding Land Conflicts: Some basic issues in Nepal***, Unpublished paper, Nepal, 2001.

Brett Ballard and So Sovannarith: ***Cambodia Land Titling Program: Baseline Survey Project***, Final Report Phase I, Cambodia Development Resource Institute in collaboration with the Ministry of Land Management, Urban Planning, and Construction (MLMUPC), Phnom Penh, Cambodia, 2004: In Sophal Chan, Kim Seadara, and Sarthi Acharya. CDRI, 2003.

Elizabeth Kato: ***Where Has All the Land Gone?, Land Rights and Access in Cambodia***, Case Studies, Volume 2, Oxfam Great Britain, Cambodia Land Study Project, Phnom Penh, 1999.

Franklin E. Huffman and In Proum: ***English-Khmer Dictionary***, New Haven and London, Yale University Press, ISBN0- 300-02261-1, 1978.

Hanne Sophie Greve: ***Land Tenure and Property Rights in Cambodia***, Phnom Penh, 1993.

Jeffrey s. Brand: ***Cambodia Property law***, Khmer Version 4 k, Faculty of Public Management in Cooperation with The University of San Francisco Project to Strengthen the Faculty of Business, Phnom Penh, (1998).

Jouni ANTTONEN: ***Systematic registration of one million parcels in five years***, developing a successful Modern Cadastral the Cambodian Way, FIG Working Week 2008 Stockholm, Sweden, 14-19 June 2008.

Kate Dalrymple**:** ***Expending Rural Land Tenures to Alleviate Poverty***, PhD thesis, University of Melbourne, 2005, page 45: in (World Bank page 87, 1989).

Kathleen o's Keefe: ***Land is Life, Land Conflict interventions in Cambodia, a review of case studies & NGO perceptions***, NGO Forum on Cambodia, Phnom Penh, 2009.

Khorn Dinravy and Adreas Groetschel: "Potential ***Poverty and Social Impacts of Cambodia's Proposed Social Land Concession Program***." LMAP, WB, Oxfam GB, GTZ. Phnom Penh, 2004.

Lim Voan: ***Land Issues and Village Administration Law***, Central Land Department, Phnom Penh, 1998.

Maneth Hun: ***Is Market-Assist Land Reform an Appropriate Choice for Cambodia at the Present Time*** New York University, New York City, 2001, New York.

Paul Munro-Faure: ***Land Reform: Land Settlement and Cooperatives***, FAO, where?, 2002/2, page9: In Barringer 1972.

Pel Sokha, Pierre-Yeves Le Meur, Sam Vitou, and all: ***Land Transactions in Rural Cambodia: A Synthesis of Findings from Research on Appropriation and Derived Rights to Land***. Centre d'Etude et de Development Agricole Cambodgien (CEDAC) & Group de Researche et d'Echanges Technologiques (GRET), Phnom Penh, 2007..

Robert B. Oberndorf: ***Lagal Analysis of Forest and Land Laws in Cambodia, Community Forestry International*** (CFI), Phnom Penh, 2006.

Biddulph, R : "P***overty and Social Impact Assessment of Social Land Concessions in Cambodia: Landlessness Assessment***." 2000, Oxfam GB and GTZ, Phnom Penh.

Serge Thoin: ***Watching Cambodia: Ten Paths to Enter the Cambodia Tangle*** White Lotus, Bangkok, Thailand, (1993).

Shaun Williams: ***Where Has All the Land Gone?, Land Rights and Access in Cambodia***: Review of Land issues Literature and Property Law, Volume 1, Cambodia Land Study Project, Oxfam GB, Phnom Penh, 1999.

Shaun Williams: "***Where Has All the Land Gone? : Land Rights and Access in Cambodia***." Volume 2, Oxfam GB, Phnom Penh, 1999.

Shaun Williams: ***Participation in Land Reform in Cambodia: Problems and Possibilities***, Oxfam, Phnom Penh, 1999.

Shaun Williams: "***Land Ownership Disputes in Cambodia: A Study of the Capacity of Five Provinces to Resolve Conflicts Over Land***." Oxfam GB, Phnom Penh, 2000.

Williams, S: "***Urban Land Policy for Poverty Reduction in Cambodia***." Oxfam GB, Phnom Penh, 2000.

Solieng Mak: ***Rain-fed Lowland Rice Farming in Cambodia: A Study of Agriculture Change***, PhD Thesis, University of Western Sydney-Hawkesbury, 1997.

Sar Sovan: ***Experiences of Land Management in Cambodia:*** International Conference: Policy meets land management: Contributions to the Achievement of the MDGs, where?, 17-18 April 2008.

So Socheat and Terje Smedsud: " ***A Study of Land Titling in Prachea Thom Village***." NPA, 2000, Phnom Penh.

So Sovannarith and All: ***Social Assessment of Land In Cambodia: A Field Study***, Working Paper No 20, Cambodia Development Resource Institute, Phnom Penh, 2001.

Swift Peter: ***Developing a Research Framework for the Fishing Lot System in Cambodia***, MRC, DANIDA, Department of Fishery, Phnom Penh, 1997.

Virey An: ***The Orkida of English Cambodian Language***, software dictionary, 1998.

## ខ. ឯកសារស្ថាប័ន

CMAC: ***Registered Mine Location***, Database, Phnom Penh, 1998.

CHRAC: ***Losing Ground***, Forced Evictions and Intimidation in Cambodia, Phnom Penh, 2009.

Center for Advance Studies: ***Land, Development and Conflict: Urban & Peru-Urban Phnom Penh***, Justice for the Poor, Phase II, Draft, 20 February 2008.

Foods and Agriculture Organizations of United Nations: ***Gender and Participation in Agricultural Development Planning***, Lessons from Nepal, Kathmandu and Rome, 1997.
Land Watch Asia and Community Self Reliance Center: ***Land Tenure Security in Nepal***, Kathmandu, Nepal, January 2008.
Ministry of Environment: ***Cambodia National Environmental Action Plan***, Phnom Penh, 1998.
NGO Forum on Cambodia: ***Statistical Analysis on Land Dispute Occurring in Cambodia 2008***, Land Information Center, Phnom Penh, 2008.
NGO Forum on Cambodia: ***Statistical Analysis on Land Dispute Occuring in Cambodia 2009***, Land Information Centre, 2010, Phnom Penh.
NGO Forum on Cambodia: ***NGO Position Papers on Cambodia's Development in 2009-2010 to the 3rd Cambodia Development Cooperation Forum***, Phnom Penh, May2010.
Oxfam Great Britain: ***Workshop Reports Revised Land Law: Approaches to Reducing Landlessness, Institutional Cooperation about Resolving Land Disputes in Cambodia***, Phnom Penh, 1999.
Oxfam GB: ***Re-analysis of Survey Data from the Oxfam Land Holding Survey 2006***, Assessment, Selective Analysis and Interpretation of Survey data, Phnom Penh, 2008.
Oxfam GB: "***National Conference Papers on Landlessness and Development.***" Phnom Penh, 2000.
Oxfam GB: "***Learning lesions from settlement programs in Cambodia: a contribution to the development of appropriate social concessions legislation***. 2002, Phnom Penh.
Save Cambodia's Wildlife: ***The Atlas of Cambodia, National Poverty and Environment Maps***, Phnom Penh, 2006.
Women Agenda for Change-WAC: ***I come to back in the city because...***Phnom Penh, 2002.
World Bank: ***World Bank helps Government with Roads and Land for the Poor***, Newsletter, Volume6, Number 6 and 7.
World Bank: ***The Inspection Panel Report and Recommendation on Request for Inspection***, Re: Request for Inspection Cambodia: Land Management and Management Project (Credit No.3650-kh), WB, 2010.
World Bank, East Asia: ***Country Analysis Paper***, Thailand National Change Strategy Workshop, Boeng Kok , 17-18 June 2008.
World Bank: ***Project Appraisal Document on a Proposed Credit to the Kingdom of Cambodia for a Land Management and Administration Project***, Report No: 22869-KH: In Cambodia Development Resource Institute (CDRI) report on Land Tenure in Cambodia, Phnom Penh, 2002.
World Bank: ***Land Management and Administration Project***, Project Appraisal Document on a propose credit in the amount of SDR 19.3 million (US$24.3 million equivalent) to the Kingdom of Cambodia, Document of The World Bank, Report No: 22869-kh, 2002.

**៣. Internet:**

លី ម៉េងហួរ: ***វិបត្តិអចលនៈវត្ថុនៅកម្ពុជាអូសបន្លាយពេលទៅមុខទៀត*** វិទ្យុបារាំង RFI accessed dated 07 Mar 2009. <http://www.rfi.fr/actukm/articles /114/article_2041.asp>.
លី ម៉េងហួរ: ***ការធ្លាក់ចុះនៃតម្លៃអចលនទ្រព្យ*** វិទ្យុបារាំង RFI accessed dated 07 Mar 2009. <http://www.rfi.fr/actukm/articles/107/article_45.asp>.
អ៊ុក សារបូរី: ***បុរស៤នាក់ត្រូវតុលាការក្រុងព្រះសីហនុចាប់ខ្លួនក្នុងជំលោះដីធ្លី*** សូមមើល <http://www.rfa.org/khmer/indepth/four-arrested-in-landdispute-05202009064332.html> accessed dated 07 Feb 2009-AM.
រាជរដ្ឋាភិបាល: ***អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*** របាយការណ៍ ឆមាសទី១ ឆ្នាំ២០០៧ តាម <http://www.pressocm.gov.kh/authority/NALDR/6month_periad.php>; accessed on 07 July 2009-PM
DAP: ***ការរំលោភយកដីចំណីផ្លូវ សូមមើល*** <http://www.dap-news.com/index.php?option=com_content&view=article&id=2227%3Aefvipthrme_lapykdicmnipouvsafarns-rbcablrdaenam_knabtwggacja_frxnecatkargtecj&catid=1%3Adap-news&Ite mid=75&lang=en>. accessed dated 2 August 2009-AM.
DAP: ***រដ្ឋបាលព្រៃឈើរំលោភយកដីប្រជាពលរដ្ឋ សូមមើល*** <http://www.dapnews.com/index.php?option= com_content&view=article&id=2296%3Arb cacnrbmancag-330rkysar-enaxmutylkkir-smusemtcnaykrdaemrnti-hun-esn-cyygntrakmn&ca_tid=1%3Adap_news&Itemid =75&lang=en.> . accessed dated 12 August 2009, AM.

DAP: ***សកម្មភាពឈូសឆាយដីប្រជាពលរដ្ឋយ៉ាងអាណាធិបតេយ្យ សូមមើល*** <http://www.dap-news.com/index. php?option=com content&view=article&id=2477%3Agnkpumiekvpusmance moahdicamyyecomepn-sumgacjafr catiedahrsayvivatdifoiptlyuttifm&catid=1%3Adap-news& Itemid=75&lang=en>. Accessed on 20 August 2009-pm.

DAP: ***ក្រុមហ៊ុនប្រើគ្រឿងចក្រឈូសកំទេចផ្ទះអ្នកស្រុក សូមមើល*** <http://www.dap-news.com/index .php?option=com content&view=article&id=2186%3Arbfanrkumh unpangiumiucbbacakmmkr-ykerkogcrkquspthrbcablrdae&catid=1&Itemid=75&lang=en> ; Accessed on 04 Aug 09 Am.

DAP: see also <http:www.dap-news.com/typography/the-news/10647-vivatdifoienaqnam-2010-mankarekinelig-etahcatemodififoi-anfoakcuhyagkmhukkfeday.html>; accessed on 01 June 2010-pm.

DAP: see also <http://www.dap-news.com/typography/the-news/10647-vivatdifoienaqnam-2010-mankarekinelig-etahcatemodifoi-anfoakcuhyagkmhukkfeday.html>; Accessed on 01 June 2010-PM.

Hun Sen: ***speech of Address at the 30th Anniversary of the partnership Between The Royal Government, Non-Governmental Organizations and the People of Cambodia 1979-2009 at National Institute of Education, November24,2009***. Page 5. < http://www.cnv.gov.kh/> ; accessed dated on 5 January 2010-AM

RFA see also : <http://www.rfa.org/khmer/batyokka/2007/12/10/Land Conflicts More Brutal>; Accessed on 06 March 2008.

RFA: < http://www.rfa.org/khmer/program/economic/feature-KH0816-ECO07-0819200>, accessed dated 21 Aug 2009.

Regional Outlook: ***Southeast Asia 2009-2010***, Institute of Southeast Asian Study, Singapore, page 21, accessed dated 8 September 2009 <http://www.csua.berkeley.edu/-sophal/ro0909.pdf>.

RFA: ***មន្ត្រីសង្គមកិច្ចរំលោភយកដីប្រជាពលរដ្ឋ*** សូមមើល <http://www.rfa.org/khmer/indepth/villagers-protest-land-grabbing-in-kgcham-0311200904> Accessed dated 23 Mar 2009-PM.

RFA: ***មេភូមិបង្ខំឱ្យប្រជាពលរដ្ឋផ្តិតមេដៃប្រគល់ដីស្រែ*** សូមមើល <http://www.rfa.org/khmer/indepth/bbang-villagers-accused-village-chief-03062009230011>. Accessed dated 23 Mar 2009-PM.

RFA: ***នគរបាលបង្ខំឱ្យប្រជាពលរដ្ឋប្រគល់ដី*** សូមមើល <http://www/rfa.org/khmer/indepth/land-dispute-in-preyveng-03102009230305.html> ; Accessed dated 23 March 2009-AM.

RFI: see also <http://www.rfi.fr/actukm/articles/112/article 4595.asp>; accessed date 18 Mar 2010-AM.

Ryan Schlief: ***Without Warning, Bulldozers enter Deykraham***, joint press release; Civil Society Groups Strongly Condemn Illegal Eviction of Dey Kraham, Phnom Penh, Cambodia. <http://hub.witness.org/en/node/11909>; accessed on 26 July 2010.

Sothakhmer: <http://sothakhmer.blogspot.com/2009/04/blogpost-post 04.html> ; accessed on 26 December 2009-PM

Sovann Sar: ***Land Reform in Cambodia*** <http://webcache.googleusercontent.com/search?q=cache:7G3CF5z9laMJ:www.fig.net/pub/fig2010/ paper/ts07j%255Cts07j sovann 4633.pdf+land+legislative+dispute+in+cambodia&cd=11&hl=eg&ct=clnk> accessed on 10 May 2010.

Transparency International: Corruption Perceptions Index 2009 <http://transparency.org/policy research/surveys indices/cpi/2009/cpi 2009 table> , accessed dated 12December 2009-PM

WB: see also <http://web.worldbank.org/WBSITE/EXTERNAL/COUNTR IES/EASTASIAPACIFIC 12/28/2009>., Accessed on 18 Mar 2010-AM.

Xinhua News Agency: see also < http:/ki-media.blogspot.com/2009/09/cambodia-terminates-land-titling-html> ; Assessed on 5 February 2010-AM.

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១៖ ព្រះរាជក្រឹត្យតែងតាំងឯកឧត្តម ជីវ កេង

ឆ្នាំ ទី ៩ លេខ ៤២ សប្តាហ៍ទី ១ ថ្ងៃ ទី ០៨ ខែ មិថុនា ឆ្នាំ ២០០៩ រាជកិច្ច ទំព័រ ៣៨០០

ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៥៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតែងតាំងឯកឧត្តម **ជីវ កេង** ជាទីប្រឹក្សាប្រធានក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៥០៥.៥៧៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៩*

លេខ : ៥១៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

ឧបសម្ព័ន្ធ២៖ ឯកឧត្តម ជីវ កេង ជាប្រធានតុលាការរាជធានីភ្នំពេញ



92

# The Phnom Penh Court

President
Mr. Chiv Keng
011 956 665

Vice President
Mr. Ke Sakhan
011 617 878

Phnom Penh Municipal Court is composed of judges and prosecutors. It has general jurisdiction over the application of these rules, as well as laws and other norms in force in their respective jurisdictions. Alternate judges may be appointed in the same way to replace judges who disqualify themselves due to a conflict of interest or incapacity. Typically, there are three judges and two prosecutors on the average in each court of first instance. They are all appointed by Royal Decrees at the request of the Supreme Council of Magistracy.

Chief of Prosecutor
Mr. Ouk Savouth
012 771 771

## ចៅក្រម Judges

Mr. Chhay Kong
012 736 216

Mr. Suon Samnang
012 913 515

Mrs. Chan Madina
012 312 722

Mr. Chey Sovann
012 888 795

Mr. Kim Ravy
012 963 990

Mr. Nhean Sovann
011 888 822

Mr. Sau Mech
012 927 268

Mrs. Chang Cinat
016 716 016

Mr. Phu Pousun
016 838 782

## Prosecutors

Mr. Sok Roeun
016 825 176

Mr. Kry Sok Y
012 997 433

Mr. Hing Bun Chea
012 996 445

Mr. Sok Kalyan
012 887 970

Mr. Plang Sophal
012 932 525

MBN INTERNATIONAL

ឧបសម្ព័ន្ធ៣៖ ឯកឧត្តម ឌិត មន្នី ជាប្រធានតុលាការកំពូល



ឧបសម្ព័ន្ធ៤៖ ឯកឧត្តម ឱត មន្នី ជាសមាជិកគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈបក្ស



## ឧបសម្ព័ន្ធ៥៖ សារាចរណែនាំ ស្ដីពីចំណាត់ការ និងនីតិវិធីពាក់ព័ន្ធដីរដ្ឋ

ឆ្នាំ ទី ៧ លេខ ៥៦ សប្តាហ៍ទី ៤ ថ្ងៃ ទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ រាជកិច្ច ទំព័រ ៥៧៥៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការក្រសួងយុត្តិធម៌**

**លេខ:** ០១.សយ.សរណន/០៧

ចុះបញ្ជី
ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ០៧

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៧

**សារាចរណែនាំ**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**សូមជម្រាបមក**

- **លោក លោកស្រី ប្រធាន អនុប្រធាន និងចៅក្រមគ្រប់តុលាការខេត្ត-ក្រុង**
- **លោក លោកស្រី ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង អមតុលាការខេត្ត-ក្រុង**

**<u>កម្មវត្ថុ</u>:** សារាចរណែនាំស្ដីពីចំណាត់ការ និងនីតិវិធីនៃការដោះស្រាយរឿងក្ដីដែលមានពាក់ព័ន្ធនឹងដីរដ្ឋ ។

**<u>យោង</u>** : - អនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ

- អនុសាសន៍របស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានលើកឡើងក្នុងឱកាសប្រារព្ធពិធី "ទិវាមច្ឆជាតិ" នៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៧

កន្លងមកក្រសួងយុត្តិធម៌បានពិនិត្យឃើញថា តុលាការ និងអយ្យការអមតុលាការខេត្ត-ក្រុង មិនទាន់យកចិត្តទុកដាក់ខ្ពស់ ក្នុងការអនុវត្តភារកិច្ចលើចំណាត់ការ និងដោះស្រាយរឿងក្ដីដែលមានកម្មវត្ថុពាក់ព័ន្ធនឹងភោគៈ ឬកម្មសិទ្ធិលើដី ដែលចាត់ថាជាដីរដ្ឋ ឱ្យបានត្រឹមត្រូវតាមស្មារតីនៃរដ្ឋធម្មនុញ្ញ និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជានៅឡើយ ។ ការសម្រេចដល់អង្គសេចក្ដីលើវិវាទដីធ្លី ឬសំណុំរឿងដែលពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិលើដីធ្លី ដោយមិនបានពិនិត្យ និងពិចារណាលើនីត្យានុកូលភាពនៃលិខិតបញ្ជាក់សិទ្ធិ កិច្ចសន្យា ឬឯកសារគតិយុត្ត ពាក់ព័ន្ធនឹងសិទ្ធិលើដីវិវាទ បានបង្កឱ្យមានភាពអវិជ្ជមានកើតឡើង ហើយធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ការគ្រប់គ្រង និងសុវត្ថិភាពគតិយុត្តនៃដីធ្លី ជាពិសេសដីរដ្ឋ ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ភូមិបាលឆ្នាំ ២០០១ និង អនុក្រឹត្យ លេខ ១១៨ អនក្រ.បក ។

ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ ។ ទង្វើនេះ ក៏បានធ្វើឱ្យប៉ះពាល់ដល់កិត្យានុភាពរបស់ប្រព័ន្ធតុលាការ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា លើវិស័យគ្រប់គ្រងដីធ្លី ផងដែរ ។

ដើម្បីធានាសុវត្ថិភាពគតិយុត្តនៃដីរដ្ឋ និងបង្កើនការជឿទុកចិត្តសាធារណៈ ក៏ដូចជាការលើកកំពស់កិត្យានុភាពរបស់ប្រព័ន្ធតុលាការ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងយុត្តិធម៌ សូមធ្វើការណែនាំដល់តុលាការ និងអយ្យការអមតុលាការខេត្ត-ក្រុង ដូចខាងក្រោម :

## ១- វិវាទនៃសិទ្ធិលើដីធ្លី

នៅពេលទទួលបានបណ្តឹងពាក់ព័ន្ធនឹងវិវាទនៃសិទ្ធិលើដី តុលាការត្រូវពិនិត្យជាបឋមអំពីឯកសារគតិយុត្តដែលបញ្ជាក់សិទ្ធិលើដីវិវាទនោះ ជាអាទិ៍ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ដែលត្រូវបានផ្តល់ឱ្យតាមមាត្រា ២៤២ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ហើយត្រូវចាត់ការដូចតទៅ :

**ក**-ក្នុងករណីដីវិវាទនេះ មានឯកសារគតិយុត្តដូចបានកំណត់ខាងលើនេះ តុលាការអាចបន្តនីតិវិធីនៃបណ្តឹង រហូតដល់ចេញសេចក្តីសម្រេចដល់អង្គសេចក្តី បាន ។

**ខ**-ក្នុងករណីដីវិវាទនេះ គ្មានឯកសារគតិយុត្តដូចបានកំណត់ក្នុងមាត្រា ២៤២ នៃច្បាប់ភូមិបាលទេ តុលាការត្រូវពិនិត្យជាបឋមអំពីនីត្យានុកូលភាពនៃភោគៈលើដីវិវាទ ដែលតម្រូវឱ្យអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធធ្វើការបញ្ជាក់អំពីស្ថានភាពគតិយុត្តនៃដីដែលជាកម្មវត្ថុនៃវិវាទ ដើម្បីផ្ទៀងផ្ទាត់ថាតើជាដីរដ្ឋតាមស្មារតី នៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ ដែរឬទេ។ ក្នុងករណីចាំបាច់ ដើម្បីធានាប្រសិទ្ធិភាព និងសម្រួលដល់ការទទួលព័ត៌មានពាក់ព័ន្ធនឹងដីវិវាទពីអាជ្ញាធរមានសមត្ថកិច្ចថ្នាក់ជាតិពាក់ព័ន្ធ តុលាការត្រូវស្នើសុំមកក្រសួងយុត្តិធម៌ ដើម្បីឱ្យក្រសួងធ្វើការសម្របសម្រួល និង ចាត់វិធានការតាមផ្លូវច្បាប់ ។

កាលបើអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ បានធ្វើការបញ្ជាក់ជាផ្លូវការថា ដីវិវាទជាដីដែលត្រូវចាត់ជាដីរដ្ឋ តុលាការត្រូវបដិសេធពាក្យបណ្តឹងនោះចោល ។

## ២- រឿងក្តីដែលមានកម្មវត្ថុពាក់ព័ន្ធនឹងការផ្ទេរ-ប្រគល់សិទ្ធិលើដី

នៅពេលទទួលពាក្យបណ្តឹងទាមទារឱ្យអនុវត្តកាតព្វកិច្ច តាមអានុភាពនៃលិខិតលក់ ឱ្យ ដូរ ឬជំរះមរតក ដូចមានចែងក្នុងមាត្រា ២៤៤ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ឬលិខិតគតិយុត្តផ្សេងៗទៀតនោះ មុននឹងសម្រេចដល់អង្គសេចក្តី តុលាការត្រូវពិនិត្យជាបឋមអំពីសុពលភាព ឬនីត្យានុកូលភាពនៃលិខិតទាំងនេះ ដោយផ្អែកតាមស្មារតីនៃច្បាប់ភូមិបាល (ជាអាទិ៍ ជំពូកទី ៦ និងជំពូកទី ១៨) និងក្រឹត្យ-ច្បាប់លេខ

៣៨ ក្រ.ច ស្ដីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ជាអាទិ៍ ជំពូកទី ១ និងជំពូកទី ២ ។ តាមផ្លូវច្បាប់ កាលបើលិខិតដែលបញ្ជាក់អំពីទំនាក់ទំនងសិទ្ធិ ឬបង្កើតសិទ្ធិមិនស្របច្បាប់ ការសម្រេចដល់អង្គសេចក្ដីអំពីសិទ្ធិ ឬទំនាក់ទំនងសិទ្ធិដែលមានមូលដ្ឋានលើលិខិតទាំងនោះ មិនអាចមានភាពកពិយុត្តបានឡើយ ។

**៣-ភារកិច្ចរបស់ព្រះរាជអាជ្ញា**

ក្នុងគ្រប់រឿងក្ដីទាំងអស់ ដែលមានកម្មវត្ថុពាក់ព័ន្ធនឹងដី ដែលអាចចាត់ថាជាដីរដ្ឋ តាមស្មារតីនៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ ព្រះរាជអាជ្ញាត្រូវតាំងខ្លួនជាភាគីក្នុងរឿងក្ដី ដើម្បីការពារដីរដ្ឋ ដែលជាប្រយោជន៍សាធារណៈ និងសង្គម ។

ក្រសួងយុត្តិធម៌ នឹងចាត់វិធានការយ៉ាងតឹងរ៉ឹងតាមផ្លូវច្បាប់ ចំពោះការមិនអនុវត្តឱ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ និងសារាចរណែនាំនេះ ។

ទទួលបានសារាចរណែនាំនេះ តុលាការ និងអយ្យការគ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តឱ្យមានប្រសិទ្ធិភាព ។

អង្គ វង្សវឌ្ឍានៈ

**ចម្លងជូន :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ក្រសួងនរៀបចំដែនដី នគររូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម
- ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម
- តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ៦៖ សេចក្តីប្រកាស ស្តីពីការមោឃៈភាពលិខិតបញ្ជាក់កាន់កាប់ដី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

លេខ : ០៥...សជក.អធិ

ភ្នំពេញ ,ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០០៩

**សេចក្តីប្រកាស**

**ស្តីពី**

**ការមោឃភាពលិខិតបញ្ជាក់ការកាន់កាប់ដីស្ថិតក្នុងតំបន់បុស្សតាផង់ និង អន្លង់ភ្លៀង**

**ឃុំស្រែចែង ស្រុកជុំគីរី ខេត្តកំពត**

- យោងលិខិតលេខ ៦២១ ដនស/សជ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការបញ្ឈប់ចេញបង្កាន់ដៃទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី
- យោងលិខិតលេខ ៦២៣ ដនស/សជ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការណែនាំអនុវត្តបទបញ្ជាស្តីពីការទប់ស្កាត់ បង្ក្រាប និង លុបបំបាត់ការកាប់រាន ដុត ឈូសឆាយ និងហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ ។
- យោងលិខិតលេខ ៥៥៨ ដនសស/រប ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត
- យោងរបាយការណ៍ លេខ ២៣ ដនស/អធិ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ របស់អធិការដ្ឋានក្រសួងដនស.។

ដោយពិនិត្យឃើញថា ទោះបីជាមានច្បាប់ភូមិបាល បទបញ្ជា និងលិខិតបទដ្ឋានជាច្រើនទៀត ដែលរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ បានដាក់ចេញជាបន្តបន្ទាប់ សំដៅទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ដុត ឈូសឆាយ និងហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ ព្រមទាំងបញ្ឈប់ការចេញបង្កាន់ដៃទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី និងបញ្ឈប់នូវរាល់ការចេញលិខិតកាន់កាប់ដីធ្លី ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីធ្លី ដែលមានប្រភពពីការកាប់រានដីព្រៃឈើរបស់រដ្ឋ ក៏នៅតែមានមន្ត្រីខិលខូចមួយចំនួនបាន និងកំពុងឆ្លៀតឱកាសចេញលិខិតបញ្ជាក់ការកាប់ដីទាំងនោះខុសនឹងនីតិវិធីច្បាប់ ដើម្បីបំរើឱ្យប្រយោជន៍ផ្ទាល់ខ្លួន។ ជាក់ស្តែងករណីលោក អ៊ឹង សែម ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកជុំគីរី បានចេញលិខិតបញ្ជាក់ការកាន់កាប់ដីក្នុងតំបន់បុស្សតាផង់ និងអន្លង់ភ្លៀវ ឃុំស្រែចែង ស្រុកជុំគីរី ខេត្តកំពត ប្រមាណជាងមួយរយហិកតា ដែលជាដីព្រៃរបស់រដ្ឋ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកកាន់កាប់ដីទាំងនោះ ប្រើប្រាស់ជាសំអាងក្នុងការលក់ឱ្យទៅតតិយជន ដែលទង្វើនេះផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ជាធរមាន ។

ចំពោះករណីនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សំរេចចាត់ជាមោឃៈ នូវរាល់លិខិតបញ្ជាក់ការ

**អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ**
Tel : (855) 023 215 659-215 660 , Fax : (855) 023 215 277 , e-mail : im. c . lim. @ Camnet. Com. Kh

កាន់កាប់ដីធ្លីទាំងឡាយដែលលោក អ៊ឹង សែម បានចេញខុសនឹងបទប្បញ្ញត្តិច្បាប់ជាធរមាន ហើយរាល់ទង្វើទាំងអស់នេះ ជាការទទួលខុសត្រូវដោយផ្ទាល់របស់លោក អ៊ឹង សែម ចំពោះមុខច្បាប់ជាធរមាន ។

អាស្រ័យហេតុនេះ សូមសាធារណៈជនដែលមានដីស្ថិតក្នុងតំបន់ខាងលើជ្រាបជាព័ត៌មាន ។ ៚

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់** ✓

<u>ចម្លងជូន</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
- សាលាខេត្តកំពត
- គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ៧៖ ប្រកាសអន្តរក្រសួង ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ៦៤ ប្រក. ០៣ រាជធានីភ្នំពេញ ថ្ងៃទី២ ខែ [illegible] ឆ្នាំ២០០៣

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដី ពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី

### រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
### រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធមិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ/បក. ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

-តាមការចាំបាច់របស់ក្រសួងយុត្តិធមិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

### ស ំ រេ ច

**ប្រការ១** : វិវាទដីធ្លីទាំងឡាយត្រូវបានបែងចែកទៅតាមសមត្ថកិច្ចនីមួយៗដូចតទៅ ÷

-វិវាទដីធ្លីដែលបានចុះបញ្ជីសុរិយោដីរួចហើយ គឺដីធ្លីដែលមានប័ណ្ណសំគាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដី ត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការ

-វិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជីសុរិយោដី គឺដីធ្លីដែលពុំទាន់មានប័ណ្ណសំគាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដីត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ។

**ប្រការ២** : តុលាការគ្រប់ខេត្ត ក្រុង ត្រូវបញ្ឈប់ការទទួលបណ្តឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដែលជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ៣** : បណ្តឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដែលជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ហើយត្រូវបានតុលាការគ្រប់ថ្នាក់ទទួល និងកំពុងចាត់ការមុនថ្ងៃចេញប្រកាសនេះ តុលាការត្រូវចាត់ការបន្តរហូតចប់សព្វគ្រប់ជាស្ថាពរ ។

**ប្រការ៤** : វិវាទអំពីកិច្ចសន្យាពាក់ព័ន្ធនឹងដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដូចជា វិវាទអំពីការបែងចែកមរតក និងវិវាទអំពីកិច្ចសន្យាទិញ លក់ ជួល បញ្ចាំ ជាដើម ជាសមត្ថកិច្ចរបស់តុលាការ ។

**ប្រការ៥** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៦** : តុលាការគ្រប់ថ្នាក់ អគ្គាធិការដ្ឋាន នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងយុត្តិធម៌ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មការសុរិយោដីគ្រប់ថ្នាក់មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងយុត្តិធម៌**

នាវ.ស៊ីថុង

**រដ្ឋមន្ត្រី**
**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

អ៊ឹម ឈុនលឹម

**__កន្លែងទទួល__**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលាខេត្ត ក្រុង
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៦ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ៨៖ ដីកាសំរេចរបស់តុលាការខេត្តបាត់តំបង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

—៚*៛—

តុលាការខេត្តបាត់ដំបង

លេខ: ៤៤៨ រប.២០០២

បាត់ដំបង. ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០០២

### ដីកាសំរេច

**យើង និល ណុន ប្រធានតុលាការខេត្តបាត់ដំបង**

- បានឃើញបទបញ្ញត្តិមាត្រា ៤៧ ច្បាប់ភូមិបាលថ្មី ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស.រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ។
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ០១ ខែឧសភា ឆ្នាំ ២០០២ ។
- បានឃើញអនុក្រឹត្យលេខ ៣៤៧ អនក្រ.តត ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០២ ។
- បានឃើញប្រកាសអន្តរក្រសួងមហាផ្ទៃ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លេខ ០៧៦ ប្រក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០០២ ។
- បានឃើញលិខិតលេខ ១៦៣៥ ខបប ចុះថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០០២ របស់លោក អភិបាលរងទី ២ និងជាប្រធានគណៈកម្មការសុរិយោដីខេត្តបាត់ដំបង ។

### សំរេច

ប្រការ ១ : ឈប់ទទួលចាត់ការដោះស្រាយវិវាទដីធ្លី ដែលជាប្រភេទដីភោគៈ ដីមិនទាន់មានប័ណ្ណសំគាល់សិទ្ធិគ្រប់គ្រងកាន់កាប់អចលនៈវត្ថុ ឬប្លង់សុរិយោដី ។

ប្រការ ២ : ដីកាសំរេចនេះ មានអានុភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

និល ណុន

ចម្លងជូន :
- លោក អនុប្រធាន តុលាការខេត្តបាត់ដំបង
- លោក នាយកក្រឡាបញ្ជី
  "ដើម្បីអនុវត្ត"
- បិទផ្សាយជាសាធារណៈនៅទីតុលាការ ដើម្បីអោយប្រជាពលរដ្ឋបានជ្រាប ។

ឧបសម្ព័ន្ធ៩៖ សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលផ្តល់សម្បទានដីសង្គមកិច្ច

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ: ៧០៧៥ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៣

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ជំរាបជូន

ឯកឧត្តម អភិបាលរាជធានីភ្នំពេញ

កម្មវត្ថុ ៈករណីសំណើសុំគោលការណ៍រៀបចំសម្បទានដីសង្គមកិច្ច ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន ជូនសហគមន៍ក្រីក្រ ក្នុងរាជធានីភ្នំពេញ ។

យោង ៈ- លិខិតលេខ ១៥០០ របក ចុះថ្ងៃទី ២៧-៦-២០០៣ របស់សាលាក្រុងភ្នំពេញ

- ចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៤-៧-២០០៣ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជំរាបឯកឧត្តមជ្រាបថា : ចំពោះ បញ្ហានេះ រាជរដ្ឋាភិបាលបានសំរេច :

១- យល់ព្រមអនុញ្ញាតជាគោលការណ៍អោយសាលាក្រុងភ្នំពេញបានរៀបចំសម្បទានដីសង្គមកិច្ច ជូនសហគមន៍ក្រីក្រ តាមសំណើដូចតទៅ :

១.១-សហគមន៍បូរីកីឡា ស្ថិតនៅសង្កាត់វាលវង់ ខណ្ឌ៧មករា មានផ្ទៃដី ១៤.១២ ហិកតា មានប្រជាពលរដ្ឋរស់នៅបណ្តោះអាសន្នចំនួន ១.៧៧៦ គ្រួសារ មាន ១.៣៧៦ ផ្ទះ មនុស្ស ៩.៥៧៥ នាក់ ផ្តល់នូវសម្បទានដីសង្គមកិច្ច ៣០% លើផ្ទៃដីសរុប ១៤.១២ ហិកតា ស្មើនឹង ៤.៦០ ហិកតា ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន ។

១.២-សហគមន៍ដីក្រហម ស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន មានទីតាំងនៅខាងត្បូងសាលមហោស្រពទន្លេបាសាក់ ជាអតីតសួនសាធារណៈ មានផ្ទៃដីទំហំ ៤.៧០ ហិកតា ផ្ទះ ១.២២០ខ្នង មានប្រជាពលរដ្ឋ ១.៤៦៥ គ្រួសារ មនុស្ស ៥.៨៥៤ នាក់ ផ្តល់នូវសម្បទានដីសង្គមកិច្ចទំហំ ៣.៧០ ហិកតា លើផ្ទៃដីសរុប ៤.៧០ ហិកតា ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន ។

១.៣-សហគមន៍សន្តិភាព (ទេះភ្លើង អា) ស្ថិតនៅក្នុងសង្កាត់ស្រះចក ខណ្ឌដូនពេញ មានផ្ទៃដីទំហំ១០.៣២០ម² មានប្រជាជន ៧០គ្រួសារ មានផ្ទះ ៦០ខ្នង មនុស្សសរុប ៣៥០នាក់ ផ្តល់នូវសម្បទានដីសង្គមកិច្ច ២៥% លើទំហំ១០.៣២០ម² ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន។

១.៤-សហគមន៍ទេះភ្លើង បេ ស្ថិតនៅក្នុងសង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក មានផ្ទៃដីទំហំ ១០ ហិកតា មានផ្ទះ ២៣៣ ខ្នង ប្រជាជន ២៥៥គ្រួសារ មនុស្ស ១.១២៤ នាក់ ផ្តល់នូវសម្បទានដីសង្គមកិច្ចទំហំ ២.៥០ ហិកតា លើផ្ទៃដីសរុប ១០ហិកតា . ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន។

២- សុំប្រកាសជូនសហគមន៍បានជ្រាប ដើម្បីរក្សាហ្មត់ចត់ និងជួយការពារកុំឱ្យមានការចាប់ដីបន្ថែម ។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាប និង ចាត់ចែងអនុវត្តតាមការគួរ ។

សូមឯកឧត្តមមេត្តាទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

ជ.ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ស៊ុំ មានិត

ចម្លងជូន:
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- [illegible]
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ១០៖ លិខិតរបស់មេធាវី

# ជំនួយ ផ្នែកច្បាប់ នៃកម្ពុជា
# Legal Aid of Cambodia


N°. 43, ST.306, P.O.Box: 1197, Sangkat Boeung Kengkang I, Cham Karmorn, Phnom Penh, Cambodia
Tel: (855-23) 215-274 / 360-708 / 214 824, Fax: (855-23) 212-206, Email: lac@bigpond.com.kh



LAC Offices in CAMBODIA:

Phnom Penh: N°. 43, St. 306, P.O.Box: 1197, Sangkat Boeung Kengkang I, Khan Cham Karmorn, Phnom Penh. Tel: 023 215 274, 023 360 708

Battambang: N°. 48, Group 1, ...mchek 4 Village, ...ratanak Commune, Battambang District, Battambang. Tel: 053 370 027

Kampong Cham: N°. 404, Group 3, Village 15, Kg.Cham District. Tel: 042 941 371

Kandal: N°. 23, St.108, Khum Takmao, Srok Takmao, Kandal. Tel: 023 360 752

Koh Kong: Group 1, Phum 2, Smach Mean-chey District, Koh Kong. Tel: 035 936 053

Kratie: N°. 588, St. Samdack Sihanouk, Vatt Village, Kratie Commune, Kratie District. Tel: 072 971 471

Siem Reap: N°. 0316, Vatt Bo, Siem Reap Dist. Siem Reap. Tel: 063 380 026

Sihanouk Ville: N°. 94, Group 1, Center 1, Sangkat II, Khan Mittapheap, Kampong Som. Tel: 034 380 142

Svay Rieng: Mephleung Village, Svay Rieng Commune, Svay Rieng District. Tel: 044 945 716


I

ខ្ញុំបាទឈ្មោះ ជីន ម៉ុនថន មេធាវីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា អាសយដ្ឋានផ្ទះលេខ ៤៣ ផ្លូវ ៣០៦ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

សូមគោរពជូនមក
ឯកឧត្តម អភិបាលរាជធានីភ្នំពេញ

*សូមមេត្តាជ្រាប ។*

**កម្មវត្ថុ ៖** សំណើសុំជួយធ្វើអន្តរាគមន៍ដល់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងភូមិ ២ និងភូមិ ១៥ សង្កាត់ទន្លេបាសាក់ ដែលត្រូវបានប្រធានសហគមន៍ចាស់ទាំង ៣៦រូប មានឧបាយកល ដេញប្រជាពលរដ្ឋឱ្យទៅរស់នៅភូមិថ្មីដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ ។

**យោង ៖**
- លិខិតលេខ ៨៧៥ ស.ជ.ណ.ចុះថ្ងៃទី ៤ កក្កដា ២០០៣ ត្រង់ចំណុច ១.២
- របាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំអភិវឌ្ឍន៍នៅនឹងកន្លែងរបស់សហគមន៍ដីក្រហម លេខ ៣៧០/០៤ រ.ម.ក.ចុះថ្ងៃទី ៣./០៩/០៤
- កិច្ចសន្យា[illegible]ផ្ទះល្វែងលើទីតាំង[illegible]/០១/០៥

តបតាមកម្មវត្ថុ និង យោង ខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបឯកឧត្តមថា ៖ ប្រជាពលរដ្ឋដែលកំពុងរស់នៅភូមិ ២ និង ភូមិ ១៥ ដែលជាសហគមន៍ដីក្រហម មានការព្រួយបារម្ភយ៉ាងខ្លាំង ដោយសារតែលោកប្រធាន និង សមាជិកសហគមន៍ចាស់ ៣៦ រូប បានឃុបឃិតលួចចុះកិច្ចសន្យាសាងសង់ផ្ទះថ្មីនៅតំបន់ឆ្ងាយ សំរាប់ផ្តល់ឱ្យប្រជាពលរដ្ឋនៅសហគមន៍ដីក្រហមរស់នៅ ។ ប្រជាពលរដ្ឋទាំងនោះបានដឹងច្បាស់ថា ៖ សម្តេចនាយករដ្ឋមន្ត្រី បានសំរេចឱ្យពួកគាត់ធ្វើការអភិវឌ្ឍន៍នៅនឹងកន្លែង ជាមួយនោះ សាលាក្រុងភ្នំពេញ ក៏បានចេញលិខិតលេខ ២៥៤ ដ.ត.ស ចុះថ្ងៃទី ២៧/១១/០៣ ស្តីពីការបង្កើតគណៈកម្មការកណ្តាលអនុវត្តគំរោងសាកល្បង, បង្កើតគណៈកម្មការស្រង់ស្ថិតិ និង មានការចុះវាស់វែងជាក់ស្តែងនូវផ្ទៃដីដែលនឹងត្រូវអភិវឌ្ឍន៍ទៀតផង ។

ឯកឧត្តមជាទីគោរព នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៥ ប្រធានសហគមន៍ដីក្រហមទាំង ៧ បានលួចចុះកិច្ចសន្យាជាមួយនឹងក្រុមហ៊ុនសេវែនអ៊ុនជី (7NG Construction) ដោយពុំបាន

មេធាវី បំរើជនក្រីក្រកម្ពុជា ដោយឥតគិតថ្លៃ
LAWYERS SERVING CAMBODIA'S POOR

ឱ្យបំណាំងដល់ប្រជាពលរដ្ឋឡើយ ជាហេតុធ្វើឱ្យប្រជាពលរដ្ឋមានការខកចិត្តទៅនឹងទង្វើរបស់ប្រធានសហគមន៍ទាំង ៧ នឹងបានធ្វើការបដិសេធមិនទទួលស្គាល់ចាប់ពីថ្ងៃបានឃើញកិច្ចសន្យានេះមក ពីព្រោះអ្នកទាំង ៣៦ រូបនេះពុំមានការស្មោះត្រង់ចំពោះសមាជិករបស់ខ្លួនឡើយ ។

ផ្អែកតាមចំណុច ១.២ នៃលិខិតលេខ ៨៧៥ សជណ.របស់ទីស្ដីការគណៈរដ្ឋមន្ត្រី បានចែងយ៉ាងច្បាស់ថា : "ផ្ដល់នូវសម្បទានដីសង្គមកិច្ចទំហំ ៣.៧០ ហិកតា លើផ្ទៃដីសរុប ៤.៧០ ហិកតា ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន ។" ចុះហេតុដូចម្ដេច បានជាប្រធានសហគមន៍ដីក្រហមទាំង ៧ មិនព្រមគោរពតាមខ្លឹមសារលិខិតនេះសោះ មិនតែប៉ុណ្ណោះ បែរជានាំគ្នាឃុបឃិតចុះកិច្ចសន្យាផ្ទុយពីនេះទៅវិញ ហើយដែលធ្វើឱ្យប្រជាពលរដ្ឋទាំង ២ ភូមិមានការភ្ញាក់ផ្អើល និងធ្វើការប្រឆាំងតវ៉ាជាមួយប្រធានសហគមន៍ទាំង៧ នេះជាបន្តបន្ទាប់ និងប្ដេជ្ញាមិនព្រមទៅរស់នៅទីកន្លែងថ្មីដែលឆ្ងាយពីទីប្រជុំជន ដែលធ្វើឱ្យពួកគាត់ជួបការលំបាកក្នុងការប្រកបមុខរបរប្រចាំជីវិត ។

ជាមួយគ្នានេះដែរ រាល់សំណើសុំរបស់ប្រជាពលរដ្ឋកន្លងមកដែលដាក់ជូនទៅសាលាក្រុងដើម្បីជួយដោះស្រាយនោះ ពុំដែលបានឃើញចំលើយតបអ្វីសូម្បីបន្តិចឡើយ ហើយរឹងរឹតតែបានដៃមកលើប្រធានសហគមន៍ ដើរបំបិតបំភ័យប្រជាពលរដ្ឋឱ្យបាក់បបខួបខ្វាចថែមទៀត។ នៅពេលថ្មីៗនេះ ក្រោយពីសាលាក្រុងភ្នំពេញបានអញ្ជើញប្រធានសហគមន៍ទៅប្រជុំកាលពីថ្ងៃទី ០៩ ឧសភា ប្រធានសហគមន៍ បានមកបំភ័យប្រជាពលរដ្ឋជាថ្មីមកទៀត ដោយនិយាយថា "សាលាក្រុងបានយល់ព្រមហើយ ចំពោះអ្នកដែលប្រឆាំងចាំមើលសាលាក្រុងនឹងមានវិធានការយ៉ាងណានោះចាំតែមើលទៅ" ។

អាស្រ័យដូចបានជំរាបជូនខាងលើ ឯកឧត្តមមេត្តាពិនិត្យ និង ជួយធ្វើអន្តរាគមន៍ដល់ប្រជាពលរដ្ឋទាំងនោះ តាមសំណើសុំដោយអនុគ្រោះ និង សូមឯកឧត្តមមេត្តាជួយបង្កើតឱ្យមានវេទិកាសាធារណៈសំរាប់ប្រជាពលរដ្ឋ ដើម្បីបានសម្ដែងមតិផ្ទាល់ខ្លួន ជៀសវាងស្ដាប់តែមតិម្ខាងៗ ។

សូមឯកឧត្តមមេត្តាទទួលការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ ។

ភ្នំពេញ ថ្ងៃទី 17 ខែ ឧសភា ឆ្នាំ ២០០៥

ហត្ថលេខា

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

17.5.2005

មេធាវី.ជិន.ប៊ុនថន

## ឧបសម្ព័ន្ធ១១៖ របាយការណ៍ ស្តីពីការអភិវឌ្ឍនៅនឹងកន្លែង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*******

សាលាក្រុងភ្នំពេញ

សាលាខណ្ឌចំការមន

លេខ [illegible] /ខចម.

ភ្នំពេញ,ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ ២០០៤

### របាយការណ៍

ស្តីពីលទ្ធផលនៃការរៀបចំអភិវឌ្ឍន៍ នៅនឹងកន្លែង

របស់ សហគមន៍ ដីក្រហម

សហគមន៍ដីក្រហម ស្ថិតនៅក្នុងភូមិ ២ និង ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន បែងចែកជា ៧ សហគមន៍ ។ ក្នុងឱកាសខួប ៥ ឆ្នាំ របស់អង្គការមូលនិធិកាត់បន្ថយភាពក្រីក្រក្នុងទីក្រុង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា សហគមន៍ដីក្រហមត្រូវទទួលបាននូវគោលការណ៍ពីសម្តេចនាយករដ្ឋមន្ត្រី អនុញ្ញាតិអោយធ្វើការអភិវឌ្ឍន៍នៅនឹងកន្លែង ជាមួយគ្នានេះ ទីស្តីការគណៈរដ្ឋមន្ត្រីក៏ចេញលិខិតលេខ ៨៧៥ ស.ជ.ណ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៣ ស្តីពីការយល់ព្រមអនុញ្ញាតិជាគោលការណ៍អោយសាលាក្រុងភ្នំពេញ រៀបចំសម្បទានដីសង្គមកិច្ច ជូនសហគមន៍ក្រីក្រ ពាបសំណើរបស់សហគមន៍ចំនួន ៤ តំបន់ ក្នុង ៤ ខណ្ឌ ក្នុងនោះរួមទាំងសហគមន៍ដីក្រហមផងដែរ ។

ដើម្បីជម្រុញនៃការ អនុវត្តន៍ នូវគោលការណ៍ខាងលើ អោយមានប្រសិទ្ធិភាព សាលាក្រុងភ្នំពេញបានចេញលិខិតលេខ ២៥៤ ជ.គ.ស ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មការកណ្តាល អនុវត្តគំរោងសាកល្បង នៅនឹងកន្លែង ដោយមានឯកឧត្តម ចេង គីមសេង អភិបាលរងរាជធានីភ្នំពេញជាប្រធាន ។

ខាងក្រោមនេះគឺជាលទ្ធផលនៃការអនុវត្តរៀបចំអភិវឌ្ឍន៍ នៅ នឹងកន្លែងរបស់សហគមន៍ដីក្រហម ចាប់ពីបានទទួលគោលការណ៍របស់រាជរដ្ឋាភិបាល ។

I. អំពីការស្រង់ស្ថិតិប្រជាពលរដ្ឋ

-សាលាក្រុងភ្នំពេញបានចេញដីកាលេខ ១៨៨ ជ.គ.ស ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មការចុះស្រង់ស្ថិតិប្រជាពលរដ្ឋ នៅក្នុងសហគមន៍ដីក្រហមដែលរួមមាន លោក អភិបាលខណ្ឌចំការមន ជាប្រធាន លោក អធិការនគរបាលខណ្ឌជាអនុប្រធាន. លោក ប្រធានការិយាល័យរៀបចំដែនដីនគរូបនីយកម្មខណ្ឌជាសមាជិកអចិន្ត្រៃយ៍.មន្ត្រីខុទ្ទកាល័យសាលាក្រុងភ្នំពេញ.សង្កាត់ទន្លេបាសាក់ .តំណាងសហគមន៍ដីក្រហមនិង តំណាងគំរោងកាត់បន្ថយភាពក្រីក្រក្រុងភ្នំពេញ ជាសមាជិក គណៈកម្មការនេះបានដំណើរការចុះស្រង់ស្ថិតិចាប់ពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៣ រហូតដល់ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ បានចប់ជាស្ថាពរដូចមានតារាងស្ថិតិខាងក្រោម÷

| ល.រ | ឈ្មោះសហគមន៍ | ចំនួនគ្រួសារសរុប | ចំនួនមនុស្ស | | សរុប | ចំនួនគ្រួសារវៀតណាម | គ្រួសារសុំបំបែក | គ្រួសារជួល.និងសន្សំ | ខ្ទងផ្ទះសរុប |
|---|---|---|---|---|---|---|---|---|---|
| | | | ប្រុស | ស្រី | | | | | |
| ១ | បុរី ឧិញ្ញតិរី | ៣០៩ | ៥២៦ | ៧១០ | ១២៣៦ | ២១ | ២៨ | ១៨ | ២៩១ |
| ២ | ព្រះ គិរុណា | ៣៥៥ | ៦១២ | ៧៣០ | ១៣៤២ | ៣ | ៥០ | ៥៩ | ២៣៦ |
| ៣ | ភូមិ ២ | ២៧០ | ៤៧៨ | ៤៨៣ | ៩៦១ | ០ | ២៩ | ១២ | ២៣០ |
| ៤ | ដីក្រហមA | ២៨៩ | ៥៤៧ | ៦២៤ | ១១៧១ | ១២ | ២៤ | ៤៥ | ២០៩ |
| ៥ | ដីក្រហម ១ | ១១១ | ២១៧ | ២៤២ | ៤៥៩ | ៨ | ០ | ០ | ១១១ |
| ៦ | ដីក្រហម ៤ | ៣៣ | ៦៦ | ៦៧ | ១៣៣ | ០ | ០ | ០ | ៣៣ |
| ៧ | ដីក្រហម ៥ | ៩៨ | ២១៥ | ២៣៣ | ៤៤៨ | ៥ | ៩ | ១៩ | ៧០ |
| | ៧ សហគមន៍ | ១៤៦៥ | ២៦៦១ | ៣០៨៩ | ៥៧៥០ | ៤៩ | ១៤០ | ១៥៣ | ១១៧២ |

សមាជិកសន្សំប្រាក់: ១៣៦៥ គ្រួសារ សរុបទឹកប្រាក់ = ២៩៣.០០០.០០៛០០ ( ម្ភៃប្រាំបួនលានបីសែនរៀលគត់ )

II.**<u>អំពីលទ្ធផលនៃការអនុវត្ត</u>**

ក.<u>ការចោះប្រជុំផ្សព្វផ្សាយ</u>

-ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៣ ឯកឧត្តម កែប ជុំតិមា អភិបាលរាជធានីភ្នំពេញ បានអញ្ជើញមកប្រជុំផ្សព្វផ្សាយ ពីគោលនយោបាយសម្បទានដីសង្គមកិច្ច ជូនដល់សហគមន៍ដីក្រហមទាំង ០៧ សហគមន៍ នៅបរិវេណមហោស្រព ទន្លេបាសាក់ ដោយមានប្រជាពលរដ្ឋចូលរួមស្តាប់ចំនួន ១៣០០ គ្រួសារ ក្នុងនោះការប្រជុំផ្សព្វផ្សាយ ឯកឧត្តម អភិបាល បានជំរាបជូនប្រជាពលរដ្ឋអោយជ្រាបពីគោលការណ៍ដែលបានសំរេចអនុញ្ញាត អោយសាលាក្រុងធ្វើការអភិវឌ្ឍន៍ នៅនឹងកន្លែង សំរាប់ជាប្រយោជន៍របស់ប្រជាពលរដ្ឋទាំង ១៤៦៥ គ្រួសារ លើផ្ទៃដី ០៤ ហិកតា ៧០អា ដែលក្នុងនោះដីនេះត្រូវទុកជូនរដ្ឋវិញចំនួន ០១ ហិកតា ។

-ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៣ តំណាងសហគមន៍ បានចូលរួមសិក្ខាសាលា ស្តីពីយុទ្ធសាស្ត្រឆ្ពោះទៅរកការអភិវឌ្ឍន៍ផែនការចែករំលែកដីថ្មីទៅសាលាក្រុងភ្នំពេញតាមរយៈពេល ០១ថ្ងៃ ។

-ថ្ងៃទី ២៨-២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ប្រជាពលរដ្ឋចំនួន ១៤៦៥ គ្រួសារ បានទៅប្រជុំនៅសាលាក្រុងភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម កែប ជុំតិមា អភិបាលរាជធានីភ្នំពេញ ក្នុងការប្រជុំផ្សព្វផ្សាយនេះ ឯកឧត្តម អភិបាល បានសំរេចអោយបង្កើតគណៈកម្មការដេញថ្លៃ វាយតម្លៃ និង ប្រគល់ ទទួលសំណង់អភិវឌ្ឍន៍លំនៅដ្ឋានលើដីក្រហម ដោយមាន ឯកឧត្តម ចេច គីមសេង អភិបាលរងរាជធានីភ្នំពេញជាប្រធាន ហើយក៏បានសំរេចអនុញ្ញាតិអោយចេញសេចក្តីជូនដំណឹង ស្តីពីការដាក់អោយដេញថ្លៃ ការងារអភិវឌ្ឍន៍លំនៅដ្ឋាន នៅលើដីក្រហមផងដែរ ។

-តំណាងសហគមន៍ចំនួន ១៤ នាក់ បានចូលរួមសិក្ខាសាលា ២វគ្គ នៅសាលាបឋមសិក្សាវត្តភ្នំ ស្តីពីផែនការសកម្មភាព អភិវឌ្ឍន៍សហគមន៍ដីក្រហម ។

-ក្រោយពីការប្រជុំផ្សព្វផ្សាយខាងលើ សហគមន៍ទាំង ០៧ ក៏បាន ប្រជុំដល់ប្រជាពលរដ្ឋគ្រប់គ្រួសារទាំងអស់ ដើម្បីសុំយោបល់ថា តើ ការសាងសង់លំនៅដ្ឋានធ្វើតាមរូបភាព សង់ប្រវាស់ ឬ ស្វែងរកផលកទានសាងសង់ ក្នុងនោះ ប្រជាពលរដ្ឋបានឯកភាពគ្នា លើរូបភាពសាងសង់ប្រវាស ដោយស្វែងរកក្រុមហ៊ុនសំរាប់សាងសង់ ។

ខ. <u>អំពីការខារសិក្សា ប្លង់និង ការខាស់វែងដី</u>

-សហគមន៍ បានសំណូមពរសុំអោយ អង្គការ URC និង អង្គការ ACHR ជួយសិក្សា និង គូប្លង់ ក៏ប៉ុន្តែ មានការលំបាកលើផ្ទៃដីជាក់ស្តែង ហើយក៏បានទំនាក់ទំនង និងសំណូមពរការិយាល័យរៀបចំដែនដីនគរូបនីយកម្មខណ្ឌ ធ្វើការវាស់វែងជាក់ស្តែង ពេលការិយាល័យរៀបចំដែនដីនគរូបនីយកម្មចុះវាស់ ជាក់ស្តែង ដីនេះមានទំហំតែ ០៣ ហិកតា ៦០ អា ទេ គឺខុសពីរបាយការណ៍មុន ០១ ហិកតា ១០ អា ។ ករណីបាត់ដីនេះ សហគមន៍បានរាយការណ៍ ជូនឯកឧត្តមអភិបាលរាជធានីភ្នំពេញ ឯកឧត្តម បានមានប្រសាសន៍ថា: នឹងប្រគល់ដីដែលមានជាក់ស្តែងនេះនៅ សហគមន៍ទាំងអស់ ដោយពុំមានដកទុកជូនរដ្ឋវិញទេ ។

គ. <u>អំពីការស្វែងរកក្រុមហ៊ុនដើម្បីសាងសង់លំនៅដ្ឋាន</u>

-ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៣ សហគមន៍បានធ្វើការចរចារ ជាមួយក្រុមហ៊ុន ផាន អ៊ីម៉ិច ដោយមាន លោក ស្រី ស៊ុយ សុផាន ជាប្រធានក្រុមហ៊ុន រហូតដល់ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤ ការចរចារនេះពុំបាន ឯកភាពគ្នាទេ ដោយក្រុមហ៊ុនទាមទារយកដី ០២ ហិកតា ទុក ០១ ហិកតា ៦០ អា សំរាប់សាងសង់លំនៅដ្ឋាន ឯ សហគមន៍ទាមទារដីស្មើគ្នា គឺក្រុមហ៊ុន ០១ ហិកតា ៨០ អា និង សហគមន៍ ០១ ហិកតា ៨០ អា ។

-ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៤ រហូតដល់ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ សហគមន៍បានចរចារជាមួយ ក្រុមហ៊ុន ម៉ុង រិទ្ធី គ្រុប ដើម្បីធ្វើការសង់ប្រវាស់ពាក់កណ្តាលម្នាក់ ប៉ុន្តែមិនបានឯកភាពគ្នាទេ ។

-ចាប់ពីថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០០៤ មកសហគមន៍បានចរចារដោយផ្ទាល់ជាមួយក្រុមហ៊ុន ចិញ្ញ.ឃ្មីរ ក្នុង នោះក្រុមហ៊ុនបានយល់ព្រមធ្វើការសាងសង់លំនៅដ្ឋាន នៅសង្កាត់ចោមចៅ ខណ្ឌដង្កោ ជាផ្ទះនិង ដីចំនួន ០៣ ហិកតា ៦០ អា នៅដីក្រហម ការចរចារនេះសំរេចបាន ៩០ ភាគរយហើយ ។ ចំពោះមុខនេះសាលាខណ្ឌ និង រៀបចំការ ប្រជុំរវាងក្រុមហ៊ុន និង សហគមន៍ ដើម្បីធ្វើការចរចារដល់ទីបញ្ចប់ និង សុំគោលការណ៍ដឹកនាំពីសាលាក្រុង ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមឯកឧត្តមអភិបាលមេត្តាជ្រាបជារបាយការណ៍ និង សុំមតិដឹកនាំបន្ត ដោយអនុគ្រោះ ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

<u>ចំលងជូន:</u>

-សាលាសង្កាត់ទន្លេបាសាក់
-អង្គការ UN HABITAT
-សហគមន៍ដីក្រហម
-ឯកសារ.កាលប្បវត្តិ

អ្នកតំណាងសហគមន៍ដីក្រហម

ញ៉ូ - ស៊ុយ

## ឧបសម្ព័ន្ធ១២៖ ពាក្យបណ្តឹងទៅក្រសួងមហាផ្ទៃ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

18.7.08

### ពាក្យបណ្តឹង

យើងខ្ញុំជាតំណាងប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ដីក្រហម ស្ថិតនៅភូមិ ២ និង ភូមិ ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កម្មវត្ថុ : សុំប្តឹងបដិសេធ**

១. កិច្ចសន្យាសាងសង់អាគារផ្ទះល្វែងលើទីតាំងថ្មីរបស់គណៈកម្មការសហគមន៍ដីក្រហម និង ក្រុមហ៊ុនសេវ៉ែនអ៊ិនជី (7 NG Construction) ចុះថ្ងៃទី ១៣ មករា ២០០៥ ។

២. សេចក្តីជូនដំណឹងលេខ ០៥៨ សជណ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ ចេញដោយអភិបាលខណ្ឌចំការមន ។

៣. មិនទទួលស្គាល់តួលេខប្រជាពលរដ្ឋចំនួន ១៤៦៥ គ្រួសារ ។

៤. មិនទទួលស្គាល់ប្រធាន និង គណៈកម្មការសហគមន៍ទាំង ៧ តទៅទៀត ។

**យោង :** លិខិតលេខ ៨៧៥ សជណ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៣ ចេញដោយទីស្តីការគណៈរដ្ឋមន្ត្រី ។

ឯកឧត្តមជាទីគោរព! យើងខ្ញុំទាំងអស់គ្នាជាតំណាង និងជាប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ដីក្រហមភូមិ ២ និង ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន មានកិត្តិយសសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា :

កាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៣ រាជរដ្ឋាភិបាលដែលមានសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាប្រមុខ លោកបានសម្បទានដីសង្គមកិច្ចទំហំ ៣.៧០ ហិកតា ដែលមានទីតាំងខាងត្បូងសាលមហោស្រពទន្លេបាសាក់ ក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលមានឈ្មោះថាសហគមន៍ដីក្រហម ដើម្បីឱ្យប្រជាពលរដ្ឋអភិវឌ្ឍន៍លំនៅដ្ឋាននៅនឹងកន្លែង ។

ប៉ុន្តែនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៥ តំណាងសហគមន៍ទាំង ៧ ដែលមានសមាជិកទាំងអស់ចំនួន ៣៦ រូប បានឃុបឃិតគ្នាលួចចុះកិច្ចសន្យាមួយដើម្បីធ្វើការដោះដូរលំនៅដ្ឋានជាមួយនឹងក្រុមហ៊ុនសេវ៉ែនអ៊ិនជី (7 NG Construction) លើទីតាំងថ្មីដែលស្ថិតនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ ដោយពុំបានពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ឡើយ ។ ក្រោយមក

ប្រជាពលរដ្ឋមានការភ្ញាក់ផ្អើល ហើយបានធ្វើពាក្យបណ្តឹងទៅសាលាក្រុងភ្នំពេញដើម្បីសុំការជួយដោះអំពីបញ្ហានេះ ។ ប៉ុន្តែសាលាក្រុងពុំបានដោះស្រាយជូនប្រជាពលរដ្ឋយើងខ្ញុំឡើយ រហូតដល់ពេលនេះមេសហគមន៍ និង អាជ្ញាធរមូលដ្ឋានបំភិតបំភ័យគំរាមកំហែងប្រជាពលរដ្ឋឱ្យផ្តិតមេដៃចាកចេញ ។

ហេតុដូច្នេះហើយ ចំពោះកិច្ចសន្យាដែលមេសហគមន៍ និង ក្រុមហ៊ុន សេវ៉ែនអ៊ិនជី (7 NG Construction) យើងខ្ញុំពុំទទួលស្គាល់ឡើយ ។

ចំពោះតួលេខដែលមានចំនួន១៤៦៥ គ្រួសារនោះពុំពិតប្រាកដឡើយ ព្រោះតួលេខនេះ គឺជាតួលេខបំប៉ោង តាមការពិតប្រជាពលរដ្ឋមានមិនដល់ចំនួនខាងលើឡើយ ។

ដោយសារតែអំពើពុករលួយ និង ការប្រើអំណាចរបស់ពួកគេមកគាបសង្កត់ គំរាមកំហែងជេរប្រមាថមកលើប្រជាពលរដ្ឋយ៉ាងឃោរឃៅដូចនេះ ទើបពួកយើងខ្ញុំឈប់ទទួលស្គាល់ និង ឈប់ទទួលស្គាល់តទៅទៀត ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើនេះ សូមឯកឧត្តមមេត្តាជួយដោះស្រាយដល់យើងខ្ញុំទាំងអស់ឱ្យបានរស់នៅនឹងកន្លែងតទៅទៀត សមតាមបំណងរបស់សម្តេច ហ៊ុន សែន និងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលដឹកនាំដោយសម្តេចដ៏ខ្ពង់ខ្ពស់ ។ ជាមួយគ្នានេះដែរ សូមឯកឧត្តមមេត្តាបញ្ឈប់ជាបន្ទាន់នូវសកម្មភាពរបស់មេភូមិ និង មេសហគមន៍ដែលធ្វើការរុះរើផ្ទះដែលដើរទិញបានផ្ទះពីប្រជាពលរដ្ឋ ដើម្បីបញ្ចៀសនូវការរុះផ្ទះមួយខ្នង បំបោងផ្ទះពីបីខ្នង ទៅប្រាំពីរខ្នង ។ សូមឱ្យឯកឧត្តម មេត្តាធ្វើការរឹបអូសយកផ្ទះដែលមេភូមិ មេសហគមន៍បានទិញពីប្រជាពលរដ្ឋ មកទុកជាសម្បត្តិរួម ព្រោះអំពើនេះវាផ្ទុយទៅនឹងលក្ខន្តិកៈសហគមន៍ដែលត្រូវអនុវត្តលំនៅដ្ឋានដល់ជនក្រីក្រ ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំទាំងអស់គ្នា ។

ភ្នំពេញ,ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦

តំណាងប្រជាពលរដ្ឋ



ឡោ សីហា

ជូនភ្ជាប់មកជាមួយ

| | |
|---|---|
| -ស្នាមមេដៃផ្តិតចំលងប្រជាពលរដ្ឋចំនួន ៨០៤ គ្រួសារ | ០១ ច្បាប់ |
| -ស្នាមមេដៃផ្តិតចំលងផ្តល់សិទ្ធប្រជាពលរដ្ឋចំនួន | ០១ ច្បាប់ |
| -ស្នាមមេដៃតំណាងប្រជាពលរដ្ឋចំនួន | ០១ ច្បាប់ |
| -កិច្ចសន្យាសាងសង់ផ្ទះល្វែង | ០១ ច្បាប់ |
| -លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី | ០១ ច្បាប់ |
| -របាយការរបស់សាលាខណ្ឌចំការមន | ០១ ច្បាប់ |
| -សេចក្តីជូនដំណឹងរបស់សាលាខណ្ឌចំការមន | ០១ ច្បាប់ |
| -ឯកសារកាសែត | ០៣ ច្បាប់ |
| -របាយការណ៍ | ០១ ច្បាប់ |
| -ពាក្យបណ្តឹងមេធាវីទៅសាលាក្រុង | ០២ ច្បាប់ |

ឧបសម្ព័ន្ធ១៣៖ ពាក្យបណ្ដឹងទៅជំទាវ ម៉ែន សំអន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

57/06
14 07 06

# ពាក្យបណ្ដឹង

យើងខ្ញុំជាតំណាងប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ដីក្រហម ស្ថិតនៅភូមិ ២ និង ភូមិ ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

## សូមគោរពជូនចំពោះ

## លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួង

## ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច

**កម្មវត្ថុ** : **សុំប្ដឹងបដិសេធ**

៥. កិច្ចសន្យាសាងសង់អាគារផ្ទះល្វែងលើទីតាំងថ្មីរបស់គណៈកម្មការសហគមន៍ដីក្រហម និង ក្រុមហ៊ុនសេវ៉ែនអ៊ិនជី (7 NG Construction) ចុះថ្ងៃទី ១៣ មករា ២០០៥ ។

៦. សេចក្ដីជូនដំណឹងលេខ ០៥៨ សជណ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ ចេញដោយអភិបាលខណ្ឌចំការមន ។

៧. មិនទទួលស្គាល់តួលេខប្រជាពលរដ្ឋចំនួន ១៨៦៥ គ្រួសារ ។

៨. មិនទទួលស្គាល់ប្រធាន និង គណៈកម្មការសហគមន៍ទាំង ៧ តទៅទៀត ។

**យោង** : លិខិតលេខ ៨៧៥ សជណ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៣ ចេញដោយទីស្ដីការគណៈរដ្ឋមន្ត្រី ។

លោកជំទាវជាទីគោរព! យើងខ្ញុំទាំងអស់គ្នាជាតំណាង និងជាប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ដីក្រហមភូមិ ២ និង ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន មានកិត្តិយសសូមជំរាបជូនលោកជំទាវមេត្តាជ្រាបថា :

កាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៣ រាជរដ្ឋាភិបាលដែលមានសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាប្រមុខ លោកបានសម្បទានដីសង្គមកិច្ចទំហំ ៣,៧០ ហិកតា ដែលមានទីតាំងខាងត្បូងសាលមហោស្រពទន្លេបាសាក់ ក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលមានឈ្មោះថាសហគមន៍ដីក្រហម ដើម្បីឱ្យប្រជាពលរដ្ឋអភិវឌ្ឍន៍លំនៅដ្ឋាននៅនឹងកន្លែង ។



ប៉ុន្តែនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៥ តំណាងសហគមន៍ទាំង ៧ ដែលមានសមាជិកទាំងអស់ចំនួន ៣៦ រូប បានឃុបឃិតគ្នាលួចចុះកិច្ចសន្យាមួយដើម្បីធ្វើការដោះដូរលំនៅដ្ឋានជាមួយនឹងក្រុមហ៊ុនសេវ៉ែនអ៊ិនជី (7 NG Construction) លើទីតាំងថ្មីដែលស្ថិតនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ ដោយពុំបានពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ឡើយ ។ ក្រោយមក

ប្រជាពលរដ្ឋមានការភ្ញាក់ផ្អើល ហើយបានធ្វើពាក្យបណ្តឹងទៅសាលាក្រុងភ្នំពេញដើម្បីសុំការជួយដោះអំពីបញ្ហានេះ ។ ប៉ុន្តែសាលាក្រុងពុំបានដោះស្រាយជូនប្រជាពលរដ្ឋយើងខ្ញុំឡើយ រហូតដល់ពេលនេះ មេសហគមន៍ និង អាជ្ញាធរមូលដ្ឋានបំភិតបំភ័យគំរាមកំហែងប្រជាពលរដ្ឋឱ្យផ្តិតមេដៃចាកចេញ ។

ហេតុដូច្នេះហើយ ចំពោះកិច្ចសន្យាដែលមេសហគមន៍ និង ក្រុមហ៊ុន សេវ៉ែនអ៊ិនជី (7 NG Construction) យើងខ្ញុំពុំទទួលស្គាល់ឡើយ ។

ចំពោះតួលេខដែលមានចំនួន១៤៦៥ គ្រួសារនោះពុំពិតប្រាកដឡើយ ព្រោះតួលេខនេះ គឺជាតួលេខបំប៉ោង តាមការពិតប្រជាពលរដ្ឋមានមិនដល់ចំនួនខាងលើឡើយ ។

ដោយសារតែអំពើពុករលួយ និង ការប្រើអំណាចរបស់ពួកគេមកគាបសង្កត់ គំរាមកំហែង ជេរប្រមាថមកលើប្រជាពលរដ្ឋយ៉ាងឃោរឃៅដូចនេះ ទើបពួកយើងខ្ញុំឈប់ទទួលស្គាល់ និង ឈប់ទទួលស្គាល់តទៅទៀត ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើនេះ សូមលោកជំទាវមេត្តាជួយដោះស្រាយដល់យើងខ្ញុំទាំងអស់ឱ្យបានរស់នៅនឹងកន្លែងតទៅទៀត សមតាមបំណងរបស់សម្តេច ហ៊ុន សែន និងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលដឹកនាំដោយសម្តេចដ៏ខ្ពង់ខ្ពស់ ។ជាមួយគ្នានេះដែរ សូមលោកជំទាវមេត្តាបញ្ឈប់ជាបន្ទាន់នូវសកម្មភាពរបស់មេភូមិ និង មេសហគមន៍ដែលធ្វើការរុះរើផ្ទះដែលដើរទិញបានផ្ទះពីប្រជាពលរដ្ឋ ដើម្បីបញ្ឿសនូវការរុះផ្ទះមួយខ្នងបំប៉ោងផ្ទះពីបីខ្នងទៅប្រាំពីរខ្នង ។ សូមឱ្យលោកជំទាវ មេត្តាធ្វើការរឹបអូសយកផ្ទះដែលមេភូមិ មេសហគមន៍បានទិញពីប្រជាពលរដ្ឋ មកទុកជាសម្បត្តិរួម ព្រោះអំពើនេះវាផ្ទុយទៅនឹងលក្ខន្តិកៈសហគមន៍ដែលត្រូវអនុវត្តលំនៅដ្ឋានដល់ជនក្រីក្រ ។

សូមលោកជំទាវ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំទាំងអស់គ្នា ។

ភ្នំពេញ,ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦

ជូនភ្ជាប់មកជាមួយ

-ស្នាមមេដៃផ្តិតចំលងប្រជាពលរដ្ឋចំនួន ៨០៤ គ្រួសារ ០១ ច្បាប់

-កិច្ចសន្យាសាងសង់ផ្ទះល្វែង ០១ ច្បាប់

-លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ០១ ច្បាប់

-របាយការរបស់សាលាខណ្ឌចំការមន ០១ ច្បាប់

-សេចក្តីជូនដំណឹងរបស់សាលាខណ្ឌចំការមន ០១ ច្បាប់

-ឯកសារកាសែត ០៣ ច្បាប់

-របាយការណ៏ ០១ ច្បាប់

ឧបសម្ព័ន្ធ១៤៖ ពាក្យបណ្តឹងទៅអយ្យការរាជធានី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

[illegible] ...174

# ពាក្យបណ្តឹង

ខ្ញុំបាទ/នាងខ្ញុំ ដូចមានឈ្មោះខាងក្រោម :

១.ឈ្មោះ **ហៃម វុធី** ភេទ ប្រុស អាយុ ៤៥ ឆ្នាំ  ២.ឈ្មោះ **ឆន ស្រី** ភេទ ស្រី អាយុ ៤០ ឆ្នាំ

៣.ឈ្មោះ **ឡុង ស្រីលក្ខ័** ភេទ ស្រី អាយុ ៣១ ឆ្នាំ  ៤.ឈ្មោះ **អ៊ុង ស៊ីខួន** ភេទ ប្រុស អាយុ ៣៦ ឆ្នាំ

៥.ឈ្មោះ **អ៊ុន សំអាត** ភេទ ស្រី អាយុ ៥៣ ឆ្នាំ និងប្រជាពលរដ្ឋចំនួន ៥៦ គ្រួសារ បច្ចុប្បន្នស្នាក់នៅក្នុងសហគមន៍ដីក្រហមភូមិ ២ និងភូមិ ១៥ សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**សូមគោរពជូន**

**លោកព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ**

**កម្មវត្ថុ:** **សុំប្តឹង**

-លោក **ម៉ា សុភាព** អភិបាលរងខណ្ឌចំការមន រាជធានីភ្នំពេញ

-អ្នកស្រី **ប៉ែន សុធី** ប្រធានសហគមន៍ចាស់ សព្វថ្ងៃស្នាក់នៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ

-លោក ង៉ែត សំអាត ជាប៉ូលិសខណ្ឌដង្កោ និងជាអង្គរក្សនាយកក្រុមហ៊ុន 7NG

-**ក្រុមហ៊ុន 7NG** និងបក្សពួកមានទីស្នាក់ការនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ

**ពីបទ : ១.**បំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់អ្នកដទៃដោយចេតនា

**២.**ប្រើអំពើហិង្សាមកលើប្រជាពលរដ្ឋ និងបង្ករបួសស្នាមដោយចេតនា **៣.**បង្កភាពចលាចលនៅក្នុងភូមិ ។

តបតាមកម្មវត្ថុ ខាងលើយើងខ្ញុំទាំងអស់គ្នាមានកិត្តិយសសូមជំរាបលោកព្រះរាជអាជ្ញាមេត្តាជ្រាបៈ កាលពីថ្ងៃ ទី ២៥ ខែ សីហា ឆ្នាំ ២០០៧ ក្រុមហ៊ុន 7NG បាននាំកំលាំងកម្មករ និងសមត្ថកិច្ចចំរុះដែលរួមមានប៉ូលីស ប៉េអឹម ដឹកនាំដោយលោក **ម៉ា សុភាព** អភិបាលរងខណ្ឌចំការមន និងអ្នកស្រី **ប៉ែន សុធី** ប្រធានសហគមន៍ចាស់ បានចុះមកធ្វើការរុះរើ បំផ្លិចបំផ្លាញរឹបអូសយកទ្រព្យសម្បត្តិរបស់យើងខ្ញុំដែលរួមមាន តង់ ក្រែ ចាន ឆ្នាំង ចង្ក្រានហ្គាស ធុងអង្ករ មុង កន្ទេល ភួយ ខោអាវ សញ្ញាប័ត្រ អត្តសញ្ញាណប័ណ្ណ.... ខ្ទេចខ្ទីអស់គ្មានសល់អ្វីឡើយ ។ មិនតែប៉ុណ្ណោះ ពួកគេបានវាយធ្វើបាបលើពួកយើងខ្ញុំដែលជាប្រជាពលរដ្ឋដោយគ្មានត្រាប្រណីមិនថា ក្មេង ឬ ចាស់ ស្រី ឬ ប្រុសនោះឡើយ លើសពីនេះទៅទៀតឈ្មោះ **ង៉ែត សំអាត** បានយកខ្នោះមកដាក់ពួកយើងខ្ញុំ វាយតប់ធាក់ និងគំរាមបាញ់សម្លាប់ ចាប់ដាក់គុកថែមទៀត ។ ទង្វើរបស់ពួកគេដែលបានប្រព្រឹត្តមកលើពួកយើងខ្ញុំ គឺជាទង្វើមួយដែលផ្ទុយទៅនឹងច្បាប់ និងលិខិតរដ្ឋបាលទាំងស្រុង ព្រោះនៅក្នុងសេចក្តីជូនដំណឹងរបស់សាលាក្រុងភ្នំពេញលេខ ២៧៦ ឥត.ខ ចេញថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៧ គឺឱ្យធ្វើការរុះរើតែ តង់ រោង និងក្រែ សង់លើដីដែលប្រជាពលរដ្ឋបានរុះរើផ្ទះចេញទៅរស់នៅទីតាំងថ្មីរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ហើយដីរបស់ក្រុមហ៊ុនដែលយកពីអ្នកដែលព្រមធ្វើការដោះដូរហើយនោះ សុទ្ធតែស្រះរបងបន្ទាល្អូលទាំងអស់

គ្មានអ្នកណាទៅសង់នៅពីលើឡើយ ។ ផ្ទុយទៅវិញពួកក្រុមហ៊ុន និងអាជ្ញាធរដែនដីបែរជាមកធ្វើការរុះរើ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ តង់ រោង និងគ្រែ របស់យើងខ្ញុំដែលស្ថិតនៅលើដីកម្មសិទ្ធិប្រជាពលរដ្ឋ និងនៅលើផ្លូវទៅវិញ។

មូលហេតុដូចបានជំរាបជូនខាងលើ សូមលោកព្រះរាជអាជ្ញា មេត្តាចោទប្រកាន់ និងធ្វើការផ្តន្ទាទោសលើឈ្មោះ **ម៉ា សុភាព ប៉ែន សុធី ង៉ែត សំអាត** និងក្រុមហ៊ុន7NG ទៅតាមផ្លូវច្បាប់ជាធរមាន និងទាមទារជំងឺចិត្ត និងសងថ្លៃខូចខាតចំនួន **$50,000** (ប្រាំម៉ឺនដុល្លារអាមេរិក) ។

អាស្រ័យដូចនេះ សូមលោកព្រះរាជអាជ្ញាមេត្តារកយុត្តិធម៌ឱ្យយើងខ្ញុំជាជនរងគ្រោះដោយក្តីអនុគ្រោះ ។

សូមលោកព្រះរាជអាជ្ញា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា ។

សូមជូនភ្ជាប់មកជាមួយនូវ

-ស្នាមមេដៃប្រជាពលរដ្ឋ

-ភស្តុតាងផ្សេងៗ និងលិខិតរបស់សាលាក្រុងភ្នំពេញ

ធ្វើនៅភ្នំពេញ,ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៧

**ស្នាមមេដៃតំណាងប្រជាពលរដ្ឋ**



ឧបសម្ព័ន្ធ១៥៖ លិខិតពីតំណាងរាស្ត្រជូនអភិបាលរាជធានី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

**ជម្រាបជូន**

**ឯកឧត្តមអភិបាលរាជធានីភ្នំពេញ**

**តាមរយៈ** : ប្រធានរដ្ឋសភា

**កម្មវត្ថុ** : សំណើសុំរក្សាតូបលក់ដូរ និងរកកន្លែងលក់ដូរជូនអាជីវករ នៅក្នុងសហគមន៍ដីក្រហម ស្ថិតនៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ។

**យោង** : -លិខិតរបស់តំណាងអាជីវករ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា : បងប្អូនអាជីវកររស់នៅភូមិ១៥ ខ្លះទិញតូបពីគេបន្ត ខ្លះទៀតជួលកន្លែងមុខផ្ទះគេលក់ និងអ្នកខ្លះទៀតមានការយល់ព្រមពីអាជ្ញាធរមូលដ្ឋានក្នុងការតាំងទីលក់ដូរនៅក្នុងភូមិ១៥នេះ ។

ស្រាប់តែមកដល់ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៦ នេះ មានលិខិតរបស់អាជ្ញាធរសង្កាត់បានបង្ខំអោយពួកគាត់រុះរើក្នុងរយៈពេលពាថ្ងៃ ហើយពេលនោះពួកគាត់ក៏បានធ្វើការតវ៉ាសុំលក់ដូរនៅកន្លែងនោះដដែលចាំប្រជាពលរដ្ឋនៅភូមិដីក្រហមរុះរើលំនៅដ្ឋានរួចរាល់ ឬមួយបើចង់រុះរើបន្ទាន់ សូមអោយអាជ្ញាធរសង្កាត់រកកន្លែងសមរម្យមួយជិតកន្លែងចាស់ ដើម្បីអោយពួកគាត់បានគ្រាន់នឹងចិញ្ចឹមឆ្អាំងផង ព្រោះអាជីវករទាំងនោះមានជីវភាពក្រីក្រលំបាកណាស់ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាពិនិត្យ និងសំរេចដោះស្រាយការពារអាជីវករទាំងនោះអោយបានលក់ដូរជាធម្មតាដោយក្តីអនុគ្រោះ ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅ អំពីខ្ញុំ ។

លេខ:...............

ភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦

**បានឃើញ និងបញ្ជូនមក**

ឯកឧត្តម អភិបាលរាជធានីភ្នំពេញ

ដើម្បីពិនិត្យ និងសំរេច តាមការគួរ ។

.............ខែ សីហា ឆ្នាំ ២០០៦

ប្រធានរដ្ឋសភា

**ហេង សំរិន**

**ហូរ ចារិន**

**តំណាងរាស្ត្រមណ្ឌល ភ្នំពេញ**

**ចំលងជូន និង ជូន :**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អង្គការសិទ្ធិមនុស្សនានា

-សារព័ត៌មានជាតិ និងអន្តរជាតិ

"ដើម្បីជូនជ្រាប"

-ឯកសារ-កាលប្បវត្តិ

វិថីសម្តេចសុធារស សង្កាត់ចតុមុខ ភ្នំពេញ ទូរស័ព្ទលេខ : (៨៥៥-២៣) ២១២ ៥៣៧, ២១ ៤៥ ២៥, ទូរសារលេខ : (៨៥៥-២៣) ២១៧ ៧៦៩

ឧបសម្ព័ន្ធ១៦៖ សេចក្តីសុំប្តឹងតវ៉ារបស់អយ្យការរាជធានី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការ អមតុលាការ

ក្រុងភ្នំពេញ

******

លេខ ៥៦

ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៦

សំណុំរឿង [illegible]

លេខ 1857

ចុះថ្ងៃទី01 ខែ9 ឆ្នាំ2006

**សេចក្តីសុំប្តឹងតវ៉ា**

ឆ្នាំពីរពាន់ ប្រាំមួយ ខែ តុលា ថ្ងៃទី ដប់ពីរ វេលាម៉ោង [illegible]

យើង ហ៊ុន ប៊ុនហួរ ក្រឡាបញ្ជីអយ្យការអមតុលាការក្រុងភ្នំពេញ

បានឃើញឈ្មោះ [illegible]

[illegible] 305 [illegible] 2006 [illegible]

ឈ្មោះនេះទទួលថានឹងធ្វើពាក្យប្តឹងបន្ថែមអោយទាន់ពេលវេលា ក្រែងពុំប្រាកដ យើងសូត្រសេចក្តីនេះអោយឈ្មោះ [illegible] ស្តាប់ ហើយអោយចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង ។

អ្នកប្តឹង

ស្នាមមេដៃ ឬហត្ថលេខា

[illegible]

ក្រឡាបញ្ជី

ហត្ថលេខា

ហ៊ុន ប៊ុនហួរ

បានឃើញ

ភ្នំពេញថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៦

ព្រះរាជអាជ្ញា

អ៊ុក សាវុធ

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញថ្ងៃទី [illegible] ខែ តុលា ឆ្នាំ២០០៦

ក្រឡាបញ្ជី

ហ៊ុន ប៊ុនហួរ

## ឧបសម្ព័ន្ធ១៧៖ លិខិតជូនដំណឹងរបស់អយ្យការរាជធានី

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមតុលាការ
ក្រុងភ្នំពេញ

### លិខិតជូនដំណឹង

លេខ : 247/06

យើង [illegible] ព្រះរាជអាជ្ញា អយ្យការអមតុលាការក្រុងភ្នំពេញ

ជំរាបមក

លោក-លោកស្រី [illegible]
ទីលំនៅបច្ចុប្បន្ន [illegible]
ស្តីពីពាក្យបណ្តឹងរបស់លោក-លោកស្រី ប្តឹងពីឈ្មោះ [illegible]
ទីលំនៅបច្ចុប្បន្ន [illegible]
ពីបទល្មើស [illegible]
នោះយើងបានសំរេច [illegible]
តាមដីកាសំរេចលេខ 305 [illegible] ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ 2006 រួចហើយ ។

"១" លោក-លោកស្រី មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៦
ព្រះរាជអាជ្ញា

[illegible]

[illegible]
[illegible]
[illegible] ២០០៦

---

កំណត់សំគាល់ : "១" មានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល២ខែ គិតពីថ្ងៃបានទទួលលិខិតជូនដំណឹងនេះ ។

ឧបសម្ព័ន្ធ១៨៖ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុចេញដោយប្រធានមន្ទីររៀបចំដែនដីរាជធានី



ព្រំប្រទល់ :

ខាងជើង : ..........

ខាងត្បូង : ..........

ខាងកើត : ..........

ខាងលិច : .......... 124

ថ្ងៃទី 14 ខែ ..... ឆ្នាំ 2006

ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល.

ព្រះរាជាណាចក្រកម្ពុជា

ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ

លេខ : គត .....

សង្កាត់ : ..........ទន្លេបាសាក់

ខណ្ឌ : ..........ចំការមន

ក្រុង : ..........ភ្នំពេញ

ភ្នំពេញ ថ្ងៃទី 14 ខែ ..... ឆ្នាំ 2006

ត.ប រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី

រាជធានីភ្នំពេញ

លេខ : 255 II 0116

សន្លឹកលេខ S 17

| [illegible] | | | | អត្តសញ្ញាណក្រុមហ៊ុន | | | | ការផ្លាស់ប្ដូរ | | |
|---|---|---|---|---|---|---|---|---|---|---|
| ប្រភេទ | ចុះថ្ងៃ | | | ឈ្មោះត្រកូល និងឈ្មោះខ្លួន ទាំងប្ដី ប្រពន្ធ | ថ្ងៃ ខែ ឆ្នាំ និងស្រុកកំណើត | សញ្ជាតិ | ទីលំនៅ | សេចក្ដីសង្ខេបដោយសម្ដេចដែលកើត សញ្ញា និងសាលាក្រមតុលាការ | [illegible] | សេចក្ដីផ្សេងៗ |
| | ថ | ខ | ឆ | | | | | | | |
| សង្គមស្ត | 02 | 03 | 95 | ក្រុមហ៊ុន 7 មិនឌីខន - ក្រុមហ៊ុនអ៊ីសិន ខូអិលធីឌី | | | | ប្ដូរ ពីក្រុមហ៊ុន 7 មិនឌីខន ក្រុមហ៊ុន - សិន ខូអិលធីឌី តាមសាលក្រម... ចុះថ្ងៃ 13.12.2006 លេខ 5 Am 013/06 | | លិខិតលេខ 559 ពាណិជ្ជ ចុះថ្ងៃ 06-4-2006 ... 130/05 ... ចុះថ្ងៃ 19-01-2005 |